
មហាស្ត្រី ហ្សៃណាប់
زينب كبرى
បាដ់រ៍ ស្ហាហ៊ីន (Badr Shahin)

# សេចក្តីឧទ្ទិស

ខ្ញុំសូមបួងសួងអល់ឡោះហ៍عزوجل ព្រះសាស្ដាﷺព្រះអង្គعزوجلនិងព្រះរាជកុលដ្ឋានបរិសុទ្ធឥតខ្ចោះរបស់ព្រះសាស្ដាﷺអល់ឡោះហ៍عزوجل សូមព្រះអង្គعزوجلទទួលស្នាដៃដ៏ស្តួចស្តើងនេះ ។ ការពិតខ្ញុំខិតខំបង្ហាញជូននូវព្រឹត្តិការណ៍ស្តីអំពីវីរនារីមួយរូប ដែលដឹកនាំបដិវត្តន៍ប្រឆាំងរបបសង្កត់សង្កិននិងមុសាវាទដោយមានឯកសារសំអាង ។
ខ្ញុំសូមឧទ្ទិសនិពន្ធល្បងដ៏តូចតាចនេះដល់ អ៊ីម៉ាំ អាល់-ហ៊្វូសៃន៍صلوات الله عليه والسلام បុគ្គលជាទីស្រឡាញ់បំផុតរបស់ម្ចាស់ស្ត្រីស្រៃណាប់سلام الله عليها ពីព្រោះព្រះអង្គصلوات الله عليه والسلامបានបង្វឹកអប់រំព្រះនាងسلام الله عليهاឲ្យទៅជាបុគ្គលប្លែកពីធម្មតា - បុគ្គលឯកដាច់អស់បុគ្គលទាំងឡាយ ។ ដូច្នេះ ព្រះនាងسلام الله عليهاបានឆ្លងកាត់ព្រះពិសោធន៍បានយ៉ាងប្រសើរ ហើយបានធ្វើឲ្យគោលដៅទាំងអស់របស់ព្រះរៀមព្រះនាងسلام الله عليهاបានសម្រេច ។
ចំពោះព្រះអង្គصلوات الله عليه والسلام អ៊ីម៉ាំ អាល់-ហ៊្វូសៃន៍صلوات الله عليه والسلام ទូលបង្គំសូមឧទ្ទិសស្នាដៃនេះ ដោយសង្ឃឹមថានឹងត្រូវបានទទួល ពីព្រោះព្រះអង្គជាព្រះមគ្គទេសក៍ និងជាអ្នកញ៉ាំងចិត្តបណ្តាអ្នកស្វែងរកគុណធម៌ យុត្តិធម៌និងមនុស្សធម៌ពិតប្រាកដ ។

# យោបល់អ្នកបោះពុម្ព

សូមថ្វាយសេចក្តីគោរពសក្ការៈចំពោះអល់ឡោះហ៍عزوجل ដែលនឹងតបស្នងបណ្តាអ្នកដែលបូជាជីវិតដើម្បីព្រះអង្គعزوجل ដែលប្រកាសទាមទារសិទ្ធិឥតខ្លាច ដើម្បីសាបព្រោះយុត្តិធម៌និងសេចក្តីស្មោះត្រង់នៅលើផែនដីនិងចូលរួមក្នុងការសម្រេចគោលដៅ គឺគោលដៅដែលព្រះអង្គعزوجلបានបង្កើតសត្វលោកមកឲ្យបំពេញនោះ ។
សូមអល់ឡោះហ៍عزوجلប្រទានពរជ័យសិរីសួស្តីដល់មូហាំម៉ាដ់ﷺ និងព្រះ

រាជកុលដ្ឋានបរិសុទ្ធរបស់ព្រះអង្គ صلى الله عليه وآله وسلم ដែលបានរងទុក្ខវេទនាដ៏ឈឺចាប់ ។ ព្រះអង្គទាំងអស់ عليهم السلام បានធ្វើដូច្នេះ

ដើម្បីដឹកនាំមនុស្សជាតិទៅកាន់សុភមង្គលឥតអវសាន និងទៅរកការបម្រើអល់ឡោះហ៍ عز وجل ដោយវិធីល្អប្រសើរបំផុត ។

នៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ គេឃើញមានឈ្មោះបុគ្គលដែលមានគោលសីលធម៌កម្លាចិត្តឲ្យប្រកាសទាមទារសិទ្ធិនិងយុត្តិធម៌ ដោយចេញមុខនៅចំពោះមុខទុរជននិងជនអយុត្តិធម៌ ។ សៀវភៅនេះស្តីអំពីនារីប្រភេទនេះ ដែលបានឈានចូលទៅក្នុងលានប្រយុទ្ធប្រឆាំងអំពើអាក្រក់ដោយមានកម្លាំងអស្ចារ្យ ហើយបានថ្លែងអ្វីដែលត្រឹមត្រូវនិងការពិតដាក់មុខទុរជននិងជនកាន់អំណាចសង្កត់សង្កិន ។

សម្តីទាំងឡាយរបស់ស្ត្រីរូបនេះនៅតែឮខ្ទរកងរំពង ធ្វើឲ្យបុគ្គលកំណាចរំខានចិត្ត ។ ពាក្យសម្តីទាំងនេះនៅតែរំលឹកដល់ប្រវត្តិទុក្ខវេទនារបស់នាងពាក្យសម្តីដែលរួមជាមួយបដិវត្តន៍របស់បងប្រុសនាងនោះ បានធ្វើឲ្យសាសនាអ៊ីស្លាមរស់ឡើងវិញបន្ទាប់ពីត្រូវបង្ខូច ត្រូវបរាជ័យក្នុងដៃអ្នកកាន់ក្តាប់មិនស្របច្បាប់ ដែលបានឆក់យកអំណាចដឹកនាំសហាគមន៍អ៊ីស្លាមក្រោយពីព្រះសាស្តា صلى الله عليه وآله وسلم បានសោយទិវង្គត ។ វីរៈស្ត្រីរូបនេះគឺព្រះនាងស្សៃណាប់ سلام الله عليها ព្រះរាជធីតារបស់អ៊ីម៉ាំអ៊្លលី صلوات الله عليه والسلام ។

យើងត្រូវតែលាតត្រដាងដៃរនូវមូលហេតុដែលព្រះអនុជារបស់ អ៊ីម៉ាំអាល់-ហ៊្សៃន៍ صلوات الله عليه والسلام សៃយីដាស្ញ៉ ស្សៃណាប់ سلام الله عليها បានតាមព្រះអង្គ صلوات الله عليه والسلام ក្នុងការធ្វើដំណើរទៅកាន់ការបាឡាអ៍ បន្ទាប់ពីព្រះអង្គ صلوات الله عليه والسلام បានឃើញថាព្រះនាង سلام الله عليها សក្តិសមបំផុត ជាអ្នកធ្វើឲ្យមហាបដិវត្តន៍របស់ព្រះអង្គ صلوات الله عليه والسلام បានសម្រេច ។ ព្រះនាង سلام الله عليها បានធ្វើឲ្យបដិវត្តន៍បានសម្រេចបន្ទាប់ពីព្រះអង្គបានធ្វើទុក្ករកម្មដោយបូជាព្រះជន្ម ។

សៃយីដាស្ញ៉ស្សៃណាប់ سلام الله عليها ជាបុគ្គលដែលបានទៅដល់សុក្រឹតភាព ។ ព្រះនាង سلام الله عليها យល់ច្បាស់ នូវប៉ែកមួយដែលព្រះនាង سلام الله عليها ត្រូវចូលរួមក្នុងបដិវត្តន៍

ដែលដឹកនាំដោយព្រះរៀមព្រះនាងسلام الله عليها ទោះបីច្បាប់អ៊ីស្លាមសារីអុាស់[1] ដាក់បញ្ញាឲ្យបណ្ដាស្ត្រីនៅក្នុងផ្ទះ ដោយមិនមានកាតព្វកិច្ចចូលរួមក្នុងយីហាដ់[2]ទេក៏ដោយ ។ ទោះជាដូច្នេះក្ដី សៃយីដាស់សៃណាប់سلام الله عليها ព្រះរាជបុត្រីរបស់ព្រះរាជកុលដ្ឋានបរិសុទ្ធរបស់ព្រះសាស្ដាصلى الله عليه وآله وسلم ព្រះរាជកុលដ្ឋានដែលគេបានបើកឲ្យដឹងច្បាប់អ៊ីស្លាមសារីអុាស់ ដែលបានយល់ច្បាស់ជាងមនុស្សឯទៀតថា បេសកកម្មទាំងពីរដែលព្រះនាងسلام الله عليهاត្រូវបំពេញនោះជាបេសកកម្មដែលគាំទ្រសិទ្ធិអាស់-លុលបៃត៍عليهم السلام និងពង្រឹងគ្រឹះសាសនា ។ ដូច្នេះហើយបានជាព្រះនាងسلام الله عليهاបំពេញកាតព្វកិច្ចសាសនារបស់ព្រះនាងسلام الله عليهاឲ្យបានល្អប្រសើរតាមដែលអាចធ្វើទៅបាន ។ ព្រះនាងسلام الله عليهاជាពេជ្រមានតម្លៃនៅក្នុងក្រចាប់ចិញ្ចៀន ដែលនៅក្នុងចំណោមគ្រាប់ពេជ្រដែលជាកម្មសិទ្ធិរបស់អ៊ីស្លាម ។

អាស្រ័យរឿងនេះយើងអាចយល់បានថា បដិវត្តន៍របស់សៃយីដាស់សៃណាប់سلام الله عليها ព្រះរាជនត្តារបស់ព្រះសាស្ដាصلى الله عليه وآله وسلمនៃសាសនាអ៊ីស្លាម ព្រះរាជបុត្រីរបស់ព្រះអនុរក្សសាសនាអ៊ីស្លាម អ៊ីមុាំអុាលីصلوات الله عليه والسلامនោះ មកពីព្រះរាជបញ្ជារបស់អល់ឡោះហ៍عز وجل ។ គេដឹងច្បាស់ស្រាប់ហើយថាអ៊ីស្លាមមានពន្លឺត្រចះត្រចង់ឡើងដោយសារតែទ្រព្យសម្បត្តិរបស់ខ៉ូឌីយ៉ាស់رضي الله عنها (ព្រះរាជមហេសីរបស់ព្រះសាស្ដាមូហាំម៉ាដ់صلى الله عليه وآله وسلم) និងអាស្រ័យតែដាវរបស់អុាលី អ៊ីបនូ អាប៊ូ តុ៏លិបصلوات الله عليه والسلامទេ ។ ដូចនេះដែរ អ៊ីស្លាមបានគង់នៅក្រោយព្រះសាស្ដាصلى الله عليه وآله وسلم ដោយសារទុក្ករកម្មបូជាជីវិតរបស់អ៊ីមុាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلامនិងដោយសារបដិវត្តន៍ ដឹកនាំដោយម្ចាស់ស្ត្រីសៃណាប់سلام الله عليها ។ សាធារណៈជនបានស្គាល់កំហុសរបស់មូអុាវីយ៉ាស់ និងយ៉ាស៊ីដហើយបានដឹងថាបុគ្គលទាំងពីររូបនេះជាសត្រូវរបស់អ៊ីស្លាម តាមរយៈវាចា

[1] សារីអុាស់ជាច្បាប់ក្នុងសាសនាអ៊ីស្លាម ស្ថិតនៅលើការសិក្សាគួរអាននិងព្រះវចនៈរបស់ព្រះសាស្ដាមូហាំម៉ាដ់صلى الله عليه وآله وسلم ។

[2] យីហាដ់គឺសង្គ្រាមសាសនា ឬសង្គ្រាមដើម្បីផ្សាយឬដើម្បីការពារសាសនាអ៊ីស្លាម ។

បដិវត្តរបស់ម្ចាស់ស្ត្រីស្វៃណាប់ ។

សោកនាដកម្មរបស់ម្ចាស់ស្ត្រីស្វៃណាប់سلام الله عليها ជាមួយចំហៀងទីពីរនៃបដិវត្តន៍របស់អ៊ីម៉ាំអាល់-ហ៊្វសៃន៍صلوات الله عليه والسلام ។ ព្រះនាងسلام الله عليهاតស៊ូយ៉ាងមុតមាំទល់នឹងគ្រោះកាចដែលមិនអាចស៊ូទ្រាំបាន ។ ព្រះនាងسلام الله عليهاមើលថែរក្សាបណ្ដាអ្នកដែលត្រូវគេឃុំឃាំង បណ្ដាកូនកំព្រានិងអ៊ីម៉ាំ អ៊ុាលី អ៊ីបនូហ៊្វសៃន៍صلوات الله عليه والسلامដែលកំពុងព្រះប្រឈួន ។ ព្រះនាងسلام الله عليهاបានប្រឈមមុខតវ៉ាទល់នឹងពួកទុច្ចរិតដោយសម្ដី ហើយបានប្រកាសថ្កោលទោសការគាបសង្កត់ដ៏អាក្រក់ និងការរំលោភសិទ្ធិមនុស្សនិងសេចក្ដីថ្លៃថ្នូរ ។ ក្រោយមកព្រះនាងបានប្រជុំមហាជន ប្រឆាំងបនគាបសង្កត់ត្រកូលអ៊្វម៉ៃយ៉ាស់ដែលជាអ្នកត្រួតត្រា និងបណ្ដាអ្នកតាមពួកនេះ ទាល់តែបនទាំងនេះសុខចិត្តឲ្យព្រះនាងត្រឡប់ទៅកាន់ម៉ាឌីណាស្ហ៊ុវិញ ដើម្បីសង្គ្រោះរដ្ឋរបស់ខ្លួន ។ ទោះជាដូច្នេះក្ដី គ្រឹះនៃរដ្ឋាភិបាលរបស់ពួកគេត្រូវបែកបាក់ដោយសារការព្យាយាមរបស់ម្ចាស់ស្ត្រីស្វៃណាប់سلام الله عليها ។

រឿងរ៉ាវក្នុងសៀវភៅនេះត្រូវបានចងក្រងឡើង ដោយប្រើសៀវភៅប្រវត្តិសាស្ត្រនិងសៀវភៅជីវប្រវត្តិយោងដែលទុកចិត្តបាន ។ ក៏ប៉ុន្តែសៀវភៅដែលជាអំណះអំណាងក្នុងការរៀបចំរឿងរ៉ាវក្នុងសៀវភៅនេះនោះ គឺសៀវភៅដែលមានចំណងជើងថា *អាល់-សៃយីដាស្ហ៊ុ ស្វៃណាប់* និពន្ធដោយស្ហៃខ៍ យ៉ាក្ហ៊ុហ្វារ អាល់-ណាក្វ៉ឌី និងសៀវភៅ *អាល់-សៃយីដាស្ហ៊ុ ស្វៃណាប់* និពន្ធដោយស្ហៃខ៍ បាក្វៀរ ស្ហារិហ្វ អាល់-ក្វ៉រ៉ស្ហ៊ី ។

ពេងពុម្ពអាន់-ស្ហ៊ីរីយ៉ាន់មានសេចក្ដីសោមនស្ស ណែនាំអស់លោកអ្នកអានឲ្យស្គាល់នូវវណ្ណៈកម្មនេះ ដែលឆ្លុះបញ្ចាំងទៅលើសេចក្ដីរាយការណ៍អំពីជីវិត អំពីលក្ខណៈបុគ្គលនិងអំពីការតស៊ូរបស់ម្ចាស់ស្ត្រីស្វៃណាប់سلام الله عليها យ៉ាងខ្លីតែដោយមានឯកសារសំអាង សង្ឃឹមថាអស់លោកអ្នកអាននឹងបានទទួលផលប្រយោជន៍ ពីការយល់ដឹងហេតុការណ៍នៃជីវិតរបស់មហានារីរូបនេះ ហើយនឹងដកស្រង់បាននូវផលប្រយោជន៍ដើម្បីនឹងអាចឈានដល់ភាពជាមនុស្សសុក្រឹតបាន ។

នៅទីបញ្ចប់ យើងខ្ញុំសូមបួងសួងអល់ឡោះហ្វ៍عز وجل សូមឲ្យយើងខ្ញុំ បាននៅ

លើមាគ៌ាជោគជ័យ សូមឲ្យគោលបំណងរបស់យើងខ្ញុំជាគោលបំណងបរិសុទ្ធចំពោះព្រះអង្គ﷿ ។ ពិតណាស់ព្រះអង្គ﷿ជាប្រភពនៃជោគជ័យ និងគ្រោះល្អ ។

រោងពុម្ព អាន់ស្វ៍រីយ៉ាន់, ២០០២

# អាស់លុល-បៃត៍ﷺនៅក្នុងគួរអាននិងស៊ូណាស់

## ការណែនាំឲ្យស្គាល់អាស់លុល-បៃត៍

ចៅអធិការ ស្ទេក៏ មូសា មូហ៊ាំម៉ាដ៏ អ៊ុលី ថ្លែងនៅក្នុងសៀវភៅលោក *អាល់-សៃយីដាស៍ ស្ទៃណាប៍* ថា៖ សេចក្តីគោរពសរសើរទាំងអស់ជាកម្មសិទ្ធិរបស់អល់ឡោះហ្វ៍ ។ សូមពរជ័យសិរីសួស្តីកើតមានដល់ មូហ៊ាំម៉ាដ៏ព្រះបរមគ្រូយើង ព្រះសាស្តាដ៏ថ្លៃថ្លាដាច់អស់ព្រះសាស្តា ព្រះរាជអគ្គប្រមុខរបស់ព្រះសាសនៈទូតទាំងឡាយរបស់អល់ឡោះហ្វ៍ និងកើតមានដល់ព្រះរាជកុលដ្ឋានរបស់ព្រះអង្គﷺ ដល់បណ្តាសាវកនិងកូនចៅ ។ អល់ឡោះហ្វ៍មានព្រះបន្ទូលថា៖

رَحْمَتُ اللَّهِ وَبَرَكَاتُهُ عَلَيْكُمْ أَهْلَ الْبَيْتِ ۚ إِنَّهُ حَمِيدٌ مَجِيدٌ.

*សូមឲ្យព្រះមេត្តាធម៌អល់ឡោះហ្វ៍និងសិរីសួស្តីនៃព្រះអង្គ កើតមានដល់អស់លោក ឱរាជកុលដ្ឋានអើយ ។ ព្រះអង្គជាទីកោតសរសើរ ជាព្រះដ៏មហារុងរឿង (១១:៧៣) ។"*

إِنَّمَا يُرِيدُ اللَّهُ لِيُذْهِبَ عَنْكُمُ الرِّجْسَ أَهْلَ الْبَيْتِ وَيُطَهِّرَكُمْ تَطْهِيرًا

*អល់ឡោះហ្វ៍គ្រាន់តែប្រាថ្នាឲ្យពួកអ្នកចាកផុតពីមន្ទិល ហើយព្រះអង្គប្រាថ្នាសំអាតពួកអ្នកឲ្យបរិសុទ្ធជ្រះស្អាតតែប៉ុណ្ណោះទេ (៣៣:៣៣) ។*

قُلْ لَا أَسْأَلُكُمْ عَلَيْهِ أَجْرًا إِلَّا الْمَوَدَّةَ فِي الْقُرْبَىٰ ۗ

*ចូរអ្នកថា៖ "ខ្ញុំមិនសូមឈ្នួលពីអស់លោកសម្រាប់អ្វីទាំងនេះទេ សូមឲ្យតែអាណិតស្រឡាញ់បណ្តាសាច់សាលោហិតជំនិតរបស់ខ្ញុំ (៤២:២៣) ។"*

---

[3] ត្រង់នេះ កថាមុខនេះត្រូវបានជ្រើសយកដើម្បីបញ្ជាក់ថាសេចក្តីស្រឡាញ់អាស់លុល-បៃត៍មិនមែនជាការជំទាស់ ឬរឿងព្រេងបុរាណរបស់ពួកស្ទីអ៊ុស់ទេ ។ លោកអ្នកនិពន្ធកថាមុខនេះជាអ្នកនិយមនិកាយហ្វាណាហ្វី ។

នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា *អាល់-ស្វ៏ហ្ហិះហ្ហ៍* លោកមុស្លីមបានសរសេរថា៖ ស៊្រៃដ៍ អ៊ីបនូ អារក៏ុបានតំណាលថា៖ "នៅឯកន្លែងមួយដែលនៅចន្លោះម៉ាក់កាស់និងម៉ាឌីណាស់ ដែលគេហៅ "ឃុំម" ព្រះសាសនៈទូតﷺរបស់អល់ឡោះហ៎ﷻ បន្ទាប់ពីបានថ្លែងសុន្ទរកថាប្រាប់យើង បន្ទាប់ពីបានអរព្រះគុណអល់ឡោះហ៎ﷻ និងបន្ទាប់ពីបានថ្លែងរំលឹកអំពីព្រះអង្គﷻ ព្រះសាស្តាﷺមានព្រះវចនៈថា៖

أَلاَ أَيُّهَا النَّاسُ، فَإِنَّمَا أَنَا بَشَرٌ يُوشِكُ أَنْ يَأْتِيَنِي رَسُولُ رَبِّي فَأُجِيبُ، وَأَنَا تَارِكٌ فِيكُم ثَقَلَيْنِ: أَوَّلُهُمَا كِتَابُ اللهِ فِيهِ الهُدىٰ وَالنُّورُ؛ فَخُذُوا بِكِتَابِ اللهِ وَاسْتَمْسِكوا بِهِ... وَأَهْلُ بَيْتِي؛ أُذَكِّرُكُمُ اللهَ فِي أَهْلِ بَيْتِي، أُذَكِّرُكُمُ اللهَ فِي أَهْلِ بَيْتِي، أُذَكِّرُكُمُ اللهَ فِي أَهْلِ بَيْتِي.

*"ប្រជានិករអើយ ខ្ញុំﷺមិនមែនអ្វីក្រៅពីមនុស្សធម្មតាទេ ។ បន្តិចទៀតអ្នកនាំសាររបស់អល់ឡោះហ៎ﷻ (ពោលគឺ ទេវតាយកជីវិត) នឹងមកជួបខ្ញុំﷺ ហើយខ្ញុំﷺនឹងឆ្លើយតប ។ ខ្ញុំﷺនឹងទុកឲ្យអស់លោកនូវវត្ថុសំខាន់ពីរគឺ៖ មួយគឺព្រះគម្ពីររបស់អល់ឡោះហ៎ﷻដែលមាននូវការដឹកនាំល្អ និងពន្លឺត្រចះត្រចង់ ។ ចូរអស់ការពារខ្លួនដោយព្រះគម្ពីរអល់ឡោះហ៎ﷻ និងចូរអស់លោកតោងព្រះគម្ពីរនេះឲ្យជាប់ ។ ពីរគឺគ្រួសារខ្ញុំﷺ ។ ចូរអស់លោកនឹកដល់អល់ឡោះហ៎ﷻពាក់ព័ន្ធនឹងអ្នកផ្ទះខ្ញុំﷺ ចូរអស់លោកនឹកដល់អល់ឡោះហ៎ﷻពាក់ព័ន្ធនឹងអ្នកផ្ទះខ្ញុំﷺ ចូរអស់លោកនឹកដល់អល់ឡោះហ៎ﷻពាក់ព័ន្ធនឹងអ្នកផ្ទះខ្ញុំﷺ ។"*

ប្រការចម្បង ដែលគេអាចសិក្សាបានពីព្រះបណ្តាំរបស់ព្រះសាស្តាអវិរុទ្ធﷺគឺ អ្នកណាស្រឡាញ់អ្វីមួយ អ្នកនោះត្រូវស្រឡាញ់វាលើសខ្លួនឯង ពុំនោះទេសេចក្តីស្រឡាញ់នោះនឹងខុស មិនពិត ។ បាននូវអ្វីមួយក្រោយពីខិតខំព្យាយាមខ្លាំងធ្វើឲ្យមានសេចក្តីសោមនស្ស និងសេចក្តីស្រឡាញ់ជាងបានវាមកដោយពុំបានបង្ហូរញើសទៅទៀត ។

សេចក្តីស្រឡាញ់ពិតចំពោះព្រះសាសនៈទូតﷺអល់ឡោះហ៎ﷻ គឺប្រតិបត្តិតាមព្រះវចនៈនិងទង្វើព្រះអង្គﷺ គោរពបង្គាប់ព្រះអង្គﷺ

ចៀសវាងអំពើដែលព្រះអង្គﷺហាម ប្រតិបត្តិសីលធម៌ព្រះអង្គﷺ តាមព្រះអង្គﷺដូចព្រះអង្គﷺស្រឡាញ់ព្រះរាជកុលដ្ឋានព្រះអង្គﷺ (គឺអាស្ហ៍លុល-បៃត៍) ដោយស្រឡាញ់ព្រះរាជកុលដ្ឋានព្រះអង្គﷺដែរ ។

ព្រះរាជកុលដ្ឋានរបស់ព្រះសាស្តាﷺ នៅក្នុងចំណោមបុគ្គលបរិសុទ្ធឥតខ្ចោះ ។ បុគ្គលទាំងនេះឯងដែលអល់ឡោះហ្ទ៍عزوجلទ្រង់សព្វព្រះហឫទ័យដែលព្រះអង្គعزوجلប្រទានឲ្យនូវអព្ភូតហេតុអស្ចារ្យនានា ដែលព្រះអង្គعزوجلបានជម្រះបន្សុទ្ធសារធាតុវិញ្ញាណ ដែលព្រះអង្គعزوجلការពារមិនឲ្យធ្វើតាមក្បាលចិត្តឯង ។ ដូច្នេះ ចិត្តថ្លើមរបស់បុគ្គលទាំងនេះទៅជាប្រទាក់ជាប់នឹងអល់ឡោះហ្ទ៍عزوجلទាំងស្រុង ។

ដូច្នេះ សេចក្តីស្រឡាញ់ព្រះរាជកុលដ្ឋានរបស់ព្រះសាស្តាﷺជាដើមកំណើតនិងជាជំហានដំបូងបង្អស់ឈានទៅរកអល់ឡោះហ្ទ៍عزوجل ។ សុជីវធម៌និងឋានៈគ្រាន់តែជាលំដាប់ថ្នាក់នៃសេចក្តីស្រឡាញ់ទេ ។

ក្រៅពីព្រះអង្គعزوجلលើកតម្កើងបុគ្គលបរិសុទ្ធទាំងនេះ អល់ឡោះហ្ទ៍عزوجلអប់រំបុគ្គលអវិជ្ជាតាមរយៈគ្រួសារព្រះសាស្តាﷺ ព្រះអង្គعزوجلដឹកនាំមនុស្សវង្វេង ព្រះអង្គعزوجلពង្រឹងកម្លាំងមនុស្សទន់ខ្សោយ ។ អាស្រ័យហេតុនេះ ដាក់ខ្លួនចំពោះព្រះរាជកុលដ្ឋានបរិសុទ្ធនេះជាកាតព្វកិច្ច ថ្កោលទោសបណ្តាអ្នកប្រព្រឹត្តអាក្រក់ទៅលើបុគ្គលបរិសុទ្ធទាំងនេះជាការចាំបាច់ បម្រើបុគ្គលបរិសុទ្ធទាំងនេះតាមដែលអាចធ្វើបាន ទុកជាវិធីមួយក្នុងការស្វែងរកនូវភាពជិតស្និទ្ធនឹងបុគ្គលបរិសុទ្ធទាំងនេះ ។

នេះគឺអល់ឡោះហ្ទ៍عزوجل ព្រះអ្នកបង្កើត ព្រះដែលត្រាប្រណី ដែលឲ្យរង្វាន់ ដែលជម្រះបន្សុទ្ធ ដែលផ្តន្ទាទោស ដែលលើកតម្កើងព្រះរាជកុលដ្ឋានរបស់ព្រះសាស្តាﷺ ។ រឿងនេះលេចឡើងច្បាស់នៅក្នុងព្រះបន្ទូលព្រះអង្គعزوجلគឺ៖

إِنَّمَا يُرِيدُ اللَّهُ لِيُذْهِبَ عَنْكُمُ الرِّجْسَ أَهْلَ الْبَيْتِ وَيُطَهِّرَكُمْ تَطْهِيرًا

*អល់ឡោះហ្ទ៍គ្រាន់តែប្រាថ្នាឲ្យពួកអ្នកចាកផុតពីមន្ទិល ហើយព្រះអង្គប្រាថ្នាសំអាតពួកអ្នកឲ្យបរិសុទ្ធជ្រះស្អាតតែប៉ុណ្ណោះទេ (៣៣:៣៣) ។*

ដូច្នេះទាំងអស់គ្នា ប្រុសឬស្រី ត្រូវរក្សាទុកនៅក្នុងចិត្តថ្លើមថាព្រះមេត្តា

ប្រណីបែបនេះជាចម្លើយឆ្លើយតបព្រះរាជបង្គាប់របស់ព្រះអ្នកបង្កើត និងជាការអនុវត្តិតាមការប្រកាសរបស់ព្រះសាស្តាﷺ ។

ការស្រឡាញ់ព្រះរាជកុលដ្ឋានរបស់ព្រះសាស្តាﷺ នឹងបានសម្រេចអាស្រ័យតែលើការគោរពព្រះអង្គﷺ ពេលព្រះអង្គﷻមានវត្តមានឬអវត្តមាន ដូច្នេះមិនត្រូវនិយាយបង្ខូចឬប្រមាថព្រះអង្គﷺទេ ។ ដូច្នេះ ត្រូវហាមនិយាយបង្កាច់ ជាពិសេសអំពីព្រះរាជកុលដ្ឋានរបស់ព្រះសាស្តាﷺ និងបណ្តាសន្តបុគ្គលស្មោះត្រង់របស់អល់ឡោះហ្ទ៍ﷻ ។ អាស្រ័យហេតុនេះ មុស្លីមទាំងឡាយគប្បីប្រយ័តអំពីលក្ខណៈកំណាចបែបនេះ ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលណាប្រព្រឹត្តអំពើនេះ បុគ្គលនោះមិនបានជោគជ័យឡើយ ពីព្រោះគោរពបណ្តាសន្តបុគ្គលដូចគោរពព្រះសាស្តាﷺ ទាំងឡាយដែរ រើសអើងសន្តបុគ្គលទាំងនេះ គឺបំបាត់គុណសម្បត្តិពីខ្លួនសន្តបុគ្គលទាំងនេះ ព្រមទាំងអកតញ្ញូចំពោះធម៌មេត្តារបស់សន្តបុគ្គលទាំងនេះ[4] ។

អកុសល បុគ្គលគ្មានស្មារតីនិងបុគ្គលដែលត្រូវឆបោកមើលទៅមនុស្សត្រង់និងភ័ក្តីដោយស្អប់ខ្ពើម ។ ពួកគេស្មានខុសអំពីមនុស្សទាំងនោះ ចោទពួកគេថាវិមគ្គនិយម (គឺវៀចវេរចេញពីមាគ៌ាល្អ) ហើយចាត់ទុកពួកគេជាជនអវិជ្ជា ។

រីឯមនុស្សឈ្មេងយល់វិញនោះស្ងប់ចិត្តជានិច្ច ។ ពួកគេឃើញអ្វីដែលមើល

---

[4] នេះគឺការណែនាំឲ្យស្គាល់ព្រះបន្ទូលអល់ឡោះហ្ទ៍ﷻ គឺ៖

يَا أَيُّهَا الَّذِينَ آمَنُوا اجْتَنِبُوا كَثِيرًا مِنَ الظَّنِّ إِنَّ بَعْضَ الظَّنِّ إِثْمٌ ۖ وَلَا تَجَسَّسُوا وَلَا يَغْتَبْ بَعْضُكُمْ بَعْضًا ۚ أَيُحِبُّ أَحَدُكُمْ أَنْ يَأْكُلَ لَحْمَ أَخِيهِ مَيْتًا فَكَرِهْتُمُوهُ ۚ وَاتَّقُوا اللَّهَ ۚ إِنَّ اللَّهَ تَوَّابٌ رَحِيمٌ.

*អ្នកមានសទ្ធាទាំងឡាយអើយ ចូរចៀសវាងប៉ាន់ស្មាន ព្រោះការពិត ក្នុងករណីខ្លះប៉ាន់ស្មានជាបាប ។ ចូរពួកអ្នកកុំលបយកការណ៍ ។ ចូរពួកអ្នកកុំនិយាយបង្កាច់អ្នកឯទៀត ។ តើមានអ្នកណាក្នុងចំណោមពួកអ្នកចូលចិត្តស៊ីសាច់បងប្អូនឯងដែលស្លាប់នោះទេ ? ពួកអ្នកពិតជាស្អប់ខ្ពើមអំពើនេះខ្លាំងណាស់ ។ ចូរពួកអ្នកខ្លាចអល់ឡោះហ៍ ។ ពិតមែន អល់ឡោះហ៍ទ្រង់រមែងបែរត្រឡប់ (គឺព្រោសប្រណីគឺ ទទួលការសូមខមាទោស) ព្រះអង្គមានព្រះមេត្តាធម៌ (៤៩:១២) ។*

មិនឃើញដោយខ្សែភ្នែកចក្ខុពិចារណាឯនាយកញ្ចក់ទន់ ។
ដោយហេតុនេះ គ្រោះអាក្រក់មិនអាចរំលំពួកគេបានទេ ការវាយប្រហារនៃពេលវេលាមិនអាចធ្វើឲ្យពួកគេទោមនស្សបានទេ ។
មួយរំពេចទង់នៃសេចក្តីងាយស្រួល នឹងភ្លឺឡើងសម្រាប់ពួកគេ ពពកងងឹតនឹងរសាត់បាត់អស់ អល់ឡោះហ៍ﷻនិងកម្ចាត់ការចាប់អារម្មណ៍របស់ពួកធ្វើឧបាយកល ។
អាស្រ័យហេតុនេះ មនុស្សដែលមានវិចារណញ្ញាណ មានសេចក្តីវាងវៃ មានសុភាវធម៌និងនិងចេះពិនិត្យពិច័យ ជឿព្រះរាជកុលដ្ឋានរបស់ព្រះសាស្តាﷺដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ យ៉ាងម៉ឺងម៉ាត់ឥតល្អៀង យ៉ាងស្មោះអស់ពីចិត្តនិងដោយវាយតម្លៃខ្ពស់ ព្រោះអបុគ្គលទាំងនេះអនុវត្តិតាមព្រះបញ្ជារបស់ព្រះអ្នកបង្កើត គាវរភ័ក្តិចំពោះព្រះសាស្តាﷺនិងព្រមតាមបញ្ជាព្រះអង្គﷺនៅក្នុងហាឌីស្ហខាងក្រោមនេះ ។ អាល់-ត៏ាបារ៉នី (الطبراني) នៅក្នុងសៀវភៅរបស់លោក *អាល់-មុអ៏ុយ៉ាំ អាល់-កាបៀរ* (المعجم الكبير), អាប៊ូ អាល់-ស្ហៃខ៏, អ៊ីបនូ ហ្ពាប់បាន់ នៅក្នុង *ស្ហ័ហ៊ីះហ៍* របស់លោក និងអាល់-បៃហ្វាគ៊ី បានកត់ត្រាព្រះវចនៈ របស់ព្រះសាស្តាﷺដូចតទៅ គឺៈ

لاَ يُؤْمِنُ عَبْدٌ حَتَّى أَكُونَ أَحَبَّ إِلَيْهِ مِنْ نَفْسِهِ، وَتَكُونَ عِتْرَتِي أَحَبَّ إِلَيْهِ مِنْ عِتْرَتِهِ، وَأَهْلِي أَحَبَّ إِلَيْهِ مِنْ أَهْلِهِ، وَذَاتِي أَحَبَّ إِلَيْهِ مِنْ ذَاتِهِ.

*បាវអល់ឡោះហ៍ﷻមិនមានសទ្ធាទេ លើកលែងតែបាវនោះស្រឡាញ់ខ្ញុំជាងស្រឡាញ់ខ្លួនឯង ស្រឡាញ់អ្នកផ្ទះខ្ញុំជាងស្រឡាញ់អ្នកផ្ទះខ្លួនឯង ស្រឡាញ់គ្រួសារខ្ញុំជាងស្រឡាញ់គ្រួសារខ្លួនឯង ស្រឡាញ់ខ្លួនខ្ញុំជាងស្រឡាញ់ខ្លួនឯង*[5] ។

អាល់-បៃហ្វាគ៊ី, អាប៊ូ អាល់-ស្ហៃខ៏ និង អ៊ីបនូ ហ្ពាប់បាន់ នៅក្នុង *ស្ហ័ហ៊ីះហ៍* របស់លោក អស់លោកទាំងនេះបានកត់ត្រាហាឌីស្ហខាងក្រោមនេះក្រោម

[5] អាល់-ហ្ពាហ្វ៊ីស្ហ អាល់-ស្ហាហ្វាប៊ីបានសម្រេចថាហាឌីស្ហនេះជាហាឌីស្ហពិត ។

អាជ្ញាធរនៃអ៊ីម៉ាំអាលីصلوات الله عليه والسلام គឺ៖

ព្រះសាសនៈទូតﷺអល់ឡោះហ្ទ៏ﷻក្រោធ កាលព្រះអង្គចេញទៅក្រៅ ព្រះអង្គﷺអង្គុយលើវេទិកា អរព្រះគុណអល់ឡោះហ្ទ៏ﷻ ហើយមានព្រះវចនៈថា៖ "

مَا بَالُ رِجَالٍ يُؤْذُونَنِي فِي أَهْلِ بَيْتِي؟ وَالَّذِي نَفْسِي بِيَدِهِ لاَ يُؤْمِنُ عَبْدٌ حَتَّى يُحِبَّنِي، وَلاَ يُحِبَّنِي حَتَّى يُحِبَّ ذُرِّيَّتِي.

តើពួកគេកើតអ្វី ពួកដែលធ្វើឲ្យខ្ញុំﷺឈឺចាប់រឿងអ្នកផ្ទះខ្ញុំﷺនោះ ? ខ្ញុំﷺសូមស្បថចំពោះព្រះដែលក្ដាប់ជីវិតខ្ញុំﷺក្នុងព្រះហត្ថព្រះអង្គﷻ ថា បាវ[អល់ឡោះហ្ទ៏ﷻ]នឹងមិនមានសទ្ធាទេ លើកលែងតែបាវនោះស្រឡាញ់ខ្ញុំﷺ ហើយបាវនោះមិនស្រឡាញ់ខ្ញុំﷺពិតទេ លើកលែងតែបាវនោះស្រឡាញ់បណ្ដាកូនចៅខ្ញុំﷺ ។

ហេតុនេះឯងបានជា អាប៊ូ បាការ បានថា៖ "ខ្ញុំចូលចិត្តគោរពសាច់ញាតិរបស់ព្រះសាស្ដាជាងគោរពសាច់ញាតិរបស់ខ្ញុំ ។"

ព្រោះតែព្រះអង្គﷺទ្រង់ទៀងត្រង់ ទ្រង់មានព្រះញាណប្រាជ្ញា ព្រះអគ្គមហាប្រមុខរបស់សត្វលោក (ពោលគឺ ព្រះសាស្ដាមូហាំម៉ាដ្ឋﷺ) ដែលនិយាយតែការពិតនោះ មានព្រះវចនៈដូច អាល់-តៀរមីស៊ី (الترمذي) បានធ្វើសេចក្ដីរាយការណ៍នៅក្នុង *អាល់-ស៊ូណាន់* របស់លោក និង អាល់-ហ្កាគីម បានថ្លែងនៅក្នុង *អាល់-មុសតាដ់រ៉ាក់* តមកពី [អាប់ឌុលឡោះហ្ទ៏] អ៊ីបនូ អាប់បាស់ ថា៖

أَحِبُّوا اللهَ لِمَا يَغْذُوكُمْ بِهِ مِنْ نِعَمِهِ، وَأَحِبُّونِي لِحُبِّ اللهِ، وَأَحِبُّوا أَهْلَ بَيْتِي لِحُبِّي.

*"អស់លោកត្រូវស្រឡាញ់អល់ឡោះហ្ទ៏ﷻ ដោយសារព្រះអង្គﷻមានព្រះមេត្តាចំពោះអស់លោកឥតដាច់ ។ អស់លោកត្រូវស្រឡាញ់ខ្ញុំﷺព្រោះតែអស់លោកស្រឡាញ់អល់ឡោះហ្ទ៏ﷻ ។ អស់លោកត្រូវស្រឡាញ់កុលដ្ឋានខ្ញុំﷻ (គឺអ្នកផ្ទះខ្ញុំﷻ) ព្រោះតែអស់លោកស្រឡាញ់ខ្ញុំﷺ[6] ។"*

ពាក់ព័ន្ធនឹងការបកស្រាយព្រះវចនៈរបស់ព្រះសាស្ដាﷺ *"អស់លោកត្រូវ*

[6] អាល់-ហ្កាហ្វីស្ហ អាល់-ស្ហាហ្កាបីបានសម្រេចថាហ្កាឌីស្ហនេះជាហ្កាឌីស្ហពិត ។

*ស្រឡាញ់អល់ឡោះហ្វ៍﷿ ដោយសារព្រះអង្គ﷿មានព្រះមេត្តាចំពោះអស់លោកឥតដាច់"* លោកអ្នកនិពន្ធសៀវភៅ *ហ្វៃជ៍ អាល់-ក៏ដៀវ* បានថ្លែងថា៖ "មានន័យថាអស់លោកត្រូវស្រឡាញ់អល់ឡោះហ្វ៍﷿ ព្រោះព្រះអង្គ﷿ប្រទានឲ្យអស់នូវវត្ថុផ្សេងៗនិងព្រះគុណូបការជាក់ស្តែង ដូចជាជួយសម្រួលស្បៀងនិងគ្រឿងផឹកជាដើម ជាព្រះគុណផ្នែកវត្ថុ ឯការនាំឲ្យបានជោគជ័យនិងនៅលើមាគ៌ាត្រូវ ការតែងតាំងជាអ្នកមានចំណេះវិជ្ជា ការបង្កើតនូវសតិស្មារតី ការប្រទានឲ្យនូវពន្លឺនៃការជឿជាក់ក្នុងចិត្តនោះវិញ ជាព្រះគុណជាក់ស្តែងបន្ថែម ។"

អុីបនូ អ្ញុត់ត្ញុអ្ញុ-អល់ឡោះហ្វ៍ អាល់-អុីសកាន់ដួរី (ابن عطاء الله الاسكندري) បានថ្លែងថា៖ "គ្រប់ពេលវេលា អល់ឡោះហ្វ៍﷿មានព្រះ ឧបការគុណចំពោះអស់លោក អស់លោកត្រូវស្រឡាញ់ព្រះអង្គ﷿ព្រោះតែគុណប្រយោជន៍ទាំងនេះ ហើយត្រូវអរព្រះគុណព្រះអង្គ﷿គ្រប់ពេលវេលា ។"

ដោយហេតុនេះ មិនអាចធ្វើឲ្យបានស្រេចបាច់រឿងអរគុណបានឡើយ កាលណាពេលវេលារបស់វាបានកន្លងផុតហើយ ពីព្រោះការអរគុណត្រូវតែធ្វើសាឡើងវិញគ្រប់ចំរៀកវិនាទី ។ ដូចគ្នាដែរ ការសូមខមាទោសនិងការជម្រុះបាបត្រូវតែធ្វើសាឡើងវិញគ្រប់ពេលវេលា ។

អល់ឡោះហ្វ៍﷿មានព្រះបន្ទូលថា៖

وَإِنْ تَعُدُّوا نِعْمَةَ اللَّهِ لَا تُحْصُوهَا ۗ إِنَّ اللَّهَ لَغَفُورٌ رَحِيمٌ

*បើពួកអ្នកចង់រាប់ឲ្យដឹងចំនួនព្រះឧបការគុណរបស់អល់ឡោះហ្វ៍ ពួកអ្នកមិនអាចរាយរាប់បានទេ ។ អល់ឡោះហ្វ៍ទ្រង់មានព្រះខន្តីអភ័យទោស ព្រះអង្គមានព្រះមេត្តាករុណាប្រណី (១៦:១៨) ។*

ដូច្នេះព្រះសាស្តាﷺចង់មានព្រះវចនៈថា គេត្រូវស្រឡាញ់អល់ឡោះហ្វ៍﷿ពីព្រោះព្រះអង្គ﷿ព្រះរាជទានឲ្យយើងនូវព្រះឧបការគុណឥតដាច់ ។ អាល់-ស្សាម៉ាក់ស្សារី (الزمخشري) ស្តីអំពីរឿងនេះថា៖ "ឧបការគុណជាសញ្ញានៃអត្ថប្រយោជន៍ដែលត្រូវឧទ្ទិសជាទាន ។ ចំពោះរឿងនេះ អល់ឡោះហ្វ៍﷿បានបង្កើតលោកទាំងមូលឡើងជា ឧបការគុណ ។ ការពិត លោកជាជីវចលឬអជីវចល ។ អ្វីដែលអជីវចល ជាឧបការគុណសម្រាប់អ្វីដែល

ជីវចល (អជីវចលជាអត្ថប្រយោជន៍សម្រាប់ជីវចល) អ្វីដែលជីវចលជាឧបការគុណសម្រាប់អ្វីដែលរស់រវើក អ្វីដែលរស់រវើកជាឧបការសម្រាប់អ្វីដែលមានព្រលឹង ពីព្រោះបើពុំមានការរស់រវើកទេ អ្វីដែលមានព្រលឹងនឹងបាត់បង់សមត្ថភាព ទទួលផលប្រយោជន៍ពីឧបការគុណឯទៀត ។ ដូច្នេះ អ្វីៗដែលអាចមាន អត្ថប្រយោជន៍សុទ្ធតែជាឧបការគុណ ។"
អាល់-ហ្វាក្ខ័រ អាល់-រ៉ស៊ុី (الفخر الرازي) បានអធិប្បាយអំពីមតិខាងលើនេះថា៖ "ព្រះឧបការគុណរបស់អល់ឡោះហ្ម៍ﷻមិនអាចរាប់អស់ទេ ព្រោះអ្វីៗដែលព្រះអង្គﷻប្រទានឲ្យយើង ដូចជាផលប្រយោជន៍ សេចក្តីសោមនស្ស អវយវៈ សរីរៈដែលយើងប្រើសម្រាប់រកផលប្រយោជន៍និងសម្រាប់ចៀសវាងផលអាក្រក់ វត្ថុដែលព្រះអង្គﷻបានបង្កើតឡើងនៅក្នុងភពផែនដែនចក្រវាលនេះដើម្បីនឹងឲ្យដឹងថា មានព្រះអង្គﷻជាព្រះអ្នកបង្កើតតែមួយ និងវត្ថុដែលព្រះអង្គﷻធ្វើឲ្យមានឡើងដើម្បីទប់ស្កាត់អំពើល្មើស អ្វីៗទាំងអស់នេះជាព្រះឧបការគុណ ។ ម្យ៉ាងទៀត អ្វីៗដែលនាំមកនូវសេចក្តីសោមនស្សជាឧបការគុណ អ្វីៗដែលមិននាំមកនូវសេចក្តីសោមនស្សទេ តែប្រើសម្រាប់ចៀសវាងផលអាក្រក់ក៏ជាឧបការគុណដែរ ចំណែកឯអ្វីៗដែលមិននាំមកនូវសេចក្តីសោមនស្សទេ មិនប្រើសម្រាប់ចៀសវាងផលអាក្រក់ទេនោះក៏ជាឧបការគុណដែរ ព្រោះអាចប្រើវាជាភស្តុតាងថាមានព្រះអ្នកបង្កើត ដូច្នេះវាជាមធ្យោបាយដើម្បីនឹងស្គាល់និងគោរពសក្ការៈព្រះអង្គﷻ ។ សរុបគឺសត្វលោកទាំងអស់ជាព្រះឧបការគុណរបស់ព្រះអង្គﷻ ។"

ពេលនេះគេដឹងច្បាស់ហើយថា ដែលបាវស្រឡាញ់អល់ឡោះហ្ម៍ﷻនោះមិនបាច់បកស្រាយទេ តែដែលអល់ឡោះហ្ម៍ﷻស្រឡាញ់បាវនោះទាមទារការបកស្រាយ ។
ចំពោះរឿងនេះ អ៊ីម៉ាំ អាល់-ក៏ស្សាលី (الغزالي) បានថា៖ "សេចក្តីស្រឡាញ់អល់ឡោះហ្ម៍ﷻប្រកបទៅតាមការពិត មិនមែនជានិមិត្តរូបទេ ។ វាដូច្នេះពីព្រោះ ដូចពួកអ្នកប្រាជ្ញខាងភាសាថា វាចង្អុលបង្ហាញថាវិញ្ញាណទេរទៅ

រកអ្វីដែលមានប្រយោជន៍និងជាទីពេញចិត្ត ចំណែកឯទំនោរ (គឺការទេរទៅរក) ហួសប្រមាននោះវិញជាសេចក្ដីស្រឡាញ់ខ្លាំង។ ព្រោះតែអល់ឡោះហ៍មានចិត្តបុណ្យ មានមេត្តា ហើយទំនោរទៅរកចិត្ត បុណ្យ និងមេត្តាធម៌ធ្វើឲ្យសប្បាយចិត្ត សេចក្ដីស្រឡាញ់ព្រះអង្គទៅជាពិត។ ម្យ៉ាងទៀត សេចក្ដីស្រឡាញ់របស់អល់ឡោះហ៍ចំពោះបាវជានិមិត្ត ដែលកើតមកពីការបើកព្រះរបាំងរបស់ព្រះម្ចាស់ រវាងបាវនិងព្រះអង្គ ដើម្បីនឹងឲ្យបាវមើលឃើញព្រះម្ចាស់ដោយចិត្ត។ វាកើតមកពីព្រះម្ចាស់បើកសិទ្ធិឲ្យបាវចូលជិតព្រះអង្គនោះដែរ។"

សេចក្ដីខាងក្រោមនេះដកស្រង់មកពី *ស្ហារហ៍ អាល់-ម៉ាវាគហ្វ* (شرح المواقف)[7] គឺ៖

"សេចក្ដីស្រឡាញ់របស់យើងចំពោះអល់ឡោះហ៍ជារឿងចិត្ត ដែលផ្អែកទៅលើការយល់ឃើញអំពីនិរន្តរភាពរបស់ព្រះអង្គ សុក្រឹតភាពឥតដាច់ ហើយវាទាមទារឲ្យមានការយកចិត្តទុកដាក់ឥតខ្ចោះ អំពីព្រះសន្តវត្តមានរបស់ព្រះអង្គដែលគ្មានភាពស្រយុតស្រយង់ឬទីកន្លែង។ រីឯសេចក្ដីស្រឡាញ់របស់យើងចំពោះវត្ថុផ្សេងពីព្រះអង្គនោះវិញ វាជាបែបបទដែលផ្អែកទៅលើការសន្និដ្ឋានអំពីសុក្រឹតភាពនៃសេចក្ដីពេញចិត្ត ដែលពាក់ព័ន្ធតែនឹងមនុស្សលោក ឬវត្ថុប្រៀបធៀប ដូចជាសេចក្ដីស្រឡាញ់ចំពោះបុគ្គលជាទីស្រឡាញ់ ឬសេចក្ដីស្រឡាញ់របស់ឪពុកចំពោះកូនជាដើម។ ម្យ៉ាងទៀត សេចក្ដីស្រឡាញ់គឺការសុខចិត្ត ជាការសម្តែងឲ្យឃើញនូវសេចក្ដីប្រាថ្នា និងជាការបោះបង់ការតវ៉ា។

ក្នុងន័យអរូបិយ សេចក្ដីស្រឡាញ់របស់អល់ឡោះហ៍ចំពោះអ្នកដទៃមិនជាក់ស្ដែងទេ ពីព្រោះការជាក់ស្ដែងនៃសេចក្ដីស្រឡាញ់ចង្អុលបង្ហាញនូវសេចក្ដីប្រាថ្នា សេចក្ដីប្រាថ្នាសមតែនឹងវត្ថុដែលមានព្រំដែន (គឺមានកំណត់) ទេ រីឯអល់ឡោះហ៍វិញពុំមានព្រំដែនទេ (គឺពុំអាចកំណត់

---

[7] *ស្ហារហ៍ អាល់-ម៉ាវាគ្វិហ្វ* (شرح المواقف) និពន្ធដោយ អាល់-ស្ហារិហ្វ អាល់-យ៉ូរយ៉ានី។

បាន)។ និយាយម្យ៉ាងទៀត ការប៉ងប្រាថ្នាធ្វើអ្វីមួយ បានសេចក្ដីថាមិនទាន់បានធ្វើអ្វីមួយហ្នឹងនៅឡើយទេ រីឯការប៉ងប្រាថ្នាបោះបង់អ្វីមួយនោះវិញ បានសេចក្ដីថាអាចបោះបង់អ្វីមួយហ្នឹងបាន។ ចំពោះរឿងនេះ អល់ឡោះហ្ទ៍عزوجلទ្រង់មហាវិវេសវិសាលខ្ពង់ខ្ពស់ក្រៃពេក លើសពីការប៉ងប្រាថ្នាធ្វើឬបោះបង់អ្វីមួយ ពីព្រោះព្រះអង្គعزوجلទ្រង់គង់នៅជានិច្ច ព្រះដែលសព្វសារពើចង់បានឥតដាច់ជាអនន្ត។"

ព្រះវចនៈរបស់ព្រះសាស្ដាﷺ "អស់លោកត្រូវស្រឡាញ់ខ្ញុំﷺព្រោះតែអស់លោកស្រឡាញ់អល់ឡោះហ្ទ៍عزوجل" មានន័យថាព្រោះតែអល់ឡោះហ្ទ៍عزوجلទ្រង់សព្វព្រះហឫទ័យខ្ញុំﷺ បានជាព្រះអង្គعزوجلកំណត់ឲ្យសេចក្ដីស្រឡាញ់របស់អស់លោកចំពោះរូបខ្ញុំﷺនោះ ជាបញ្ញត្តិដែលអស់លោកត្រូវតែគោរព។ អត្ថន័យ នេះត្រូវបានថែងនៅក្នុងសេចក្ដីរាយការណ៍ខាងក្រោមនេះ ស្រង់មកពីប្រភពព័ត៌មានពិតគឺ៖ "ពេលអល់ឡោះហ្ទ៍عزوجلសព្វព្រះហឫទ័យបាវណាមួយ អគ្គទេវតាយ៉ីបរ៉អ៊ីល (جبرائيل) ប្រកាសថា៖ "អល់ឡោះហ្ទ៍عزوجلសព្វព្រះហឫទ័យអ្នកនេះមួយ ដូច្នេះ អស់លោកត្រូវតែស្រឡាញ់អ្នកនោះ។"

ព្រះវចនៈរបស់ព្រះសាស្ដា "អស់លោកត្រូវស្រឡាញ់អ្នកផ្ទះខ្ញុំﷺព្រោះតែអស់លោកស្រឡាញ់ខ្ញុំﷺ" មានន័យថា ព្រោះតែខ្ញុំﷺស្រឡាញ់បណ្ដាអ្នកផ្ទះខ្ញុំﷺ ព្រោះតែអល់ឡោះហ្ទ៍عزوجلសព្វព្រះហឫទ័យពួកគេនោះ អស់លោកក៏ត្រូវតែស្រឡាញ់ពួកគេដែរ។"

ព្រះវចនៈរបស់ព្រះសាស្ដាអាចមានសេចក្ដីថាបទបញ្ញត្តិផងដែរ ដែលត្រូវតែអនុវត្តិតាម ពីព្រោះស្រឡាញ់ព្រះរាជកុលដ្ឋាន (គឺបណ្ដាអ្នកផ្ទះ) របស់ព្រះសាស្ដាﷺជាការចាំបាច់ ព្រោះតែគេស្រឡាញ់ព្រះសាស្ដាﷺ។ អល់ឡោះហ្ទ៍عزوجلមានព្រះបន្ទូលថា៖

قُلْ لَا أَسْأَلُكُمْ عَلَيْهِ أَجْرًا إِلَّا الْمَوَدَّةَ فِي الْقُرْبَىٰ ۗ وَمَنْ يَقْتَرِفْ حَسَنَةً نَزِدْ لَهُ فِيهَا حُسْنًا ۚ إِنَّ اللَّهَ غَفُورٌ شَكُورٌ

*ចូរអ្នកថា៖ "ខ្ញុំមិនសូមឈ្នួលពីអស់លោកសម្រាប់អ្វីទាំងនេះទេ សូមឲ្យតែអាណិតស្រឡាញ់បណ្ដាសាច់សាលោហិតជំនិតរបស់ខ្ញុំ (៤២:២៣)។"*

អាល់-ហ្វាក់រ៍ អាល់-រ៉ស៊ី (الفخر الرازي) បានធ្វើសេចក្តីរាយការណ៍ថាព្រះសាស្តាﷺនិងព្រះរាជកុលដ្ឋានព្រះអង្គﷺស្មើគ្នាក្នុងប្រាំប្រការគឺ៖
នៅក្នុងតាស្ហ៊ហ្វ៊ុដពេលស្វ៊ឡាត់[8] ពរជ័យត្រូវឧទ្ទិសឲ្យទៅព្រះសាស្តាﷺនិងព្រះរាជកុលដ្ឋានព្រះអង្គﷺ ។
ពេលតាស់លិម[9]ក្នុងស្វ៊ឡាត់ ពរជ័យត្រូវឧទ្ទិសឲ្យទៅព្រះសាស្តាﷺនិងព្រះរាជកុលដ្ឋានព្រះអង្គﷺ ។ នៅក្នុងព្រះគម្ពីរគួរអាន អល់ឡោះហ្ទ៍ﷻ មានព្រះបន្ទូលថា៖

سَلَامٌ عَلَىٰ إِلْ يَاسِينَ .

*ចូរសិរីសួស្តីកើតមានដល់ក្រុមគ្រួសាររបស់យ៉ាស៊ីន (៣៧:១៣០) ។*
នៅក្នុងអត្ថន័យជម្រះបន្សុទ្ធ អល់ឡោះហ្ទ៍ﷻមានព្រះបន្ទូលទៅកាន់ព្រះសាស្តាមូហ៊ាំម៉ាដ្ឋﷺថា "طه" មានន័យថា "បរិសុទ្ធ" ។
អល់ឡោះហ្ទ៍ﷻមានព្រះបន្ទូលថា៖

قُلْ إِنْ كُنْتُمْ تُحِبُّونَ اللَّهَ فَاتَّبِعُونِي يُحْبِبْكُمُ اللهُ

*[សាស្តាអើយ] ចូរអ្នកថ្លែង[ប្រាប់បណ្តាមនុស្ស]ថា៖ "បើអស់លោកស្រឡាញ់អល់ឡោះហ្ទ៍ចូរតាមខ្ញុំ ។ អល់ឡោះហ្ទ៍នឹងសព្វព្រះហឫទ័យអស់លោក (៣:៣១) ។*
អល់ឡោះហ្ទ៍ﷻមានព្រះបន្ទូលថា៖

قُلْ لَا أَسْأَلُكُمْ عَلَيْهِ أَجْرًا إِلَّا الْمَوَدَّةَ فِي الْقُرْبَىٰ ۗ

*ចូរអ្នកថា៖ "ខ្ញុំមិនសូមឈ្នួលពីអស់លោកសម្រាប់អ្វីទាំងនេះទេ សូមឲ្យតែអាណិតស្រឡាញ់បណ្តាសាច់សាលោហិតជំនិតរបស់ខ្ញុំ (៤២:២៣) ។"*

---

[8] តាស្ហ៊ហ្វ៊ុដជាប៉ែកចាំបាច់ចុងក្រោយនៃស្វ៊ឡាត់ នៅក្នុងប៉ែកនេះអ្នកស្វ៊ឡាត់ជូនពរជ័យដល់ព្រះសាស្តាមូហ៊ាំម៉ាដ្ឋﷺនិងព្រះរាជកុលដ្ឋានព្រះអង្គﷺដោយថា៖

اَللَّهُمَّ صَلِّ عَلَىٰ مُحَمَّدٍ وَآلِ مُحَمَّدٍ.

[9] តាស់លិមជាគោលកាតព្វកិច្ចចុងក្រោយនៃស្វ៊ឡាត់ ក្នុងការគំនាប់ គឺឲ្យសាឡាម ។

ព្រះគម្ពីរគួរអាន ហាឌីស្សពិត ការស្របមតិគ្នារបស់លោកអ្នកប្រាជ្ញមុស្លីម ក្នុងជំនាន់នានាទាំងអស់ស្តីអំពីព្រះកាតព្វកិច្ចឲ្យស្រឡាញ់ ឲ្យប្រតិព័ទ្ធ ឲ្យលើកតម្លៃ ឲ្យគោរពនិងឲ្យលើកតម្កើងព្រះរាជកុលដ្ឋានរបស់ព្រះសាសនៈទូតﷺរបស់អល់ឡោះហ្ﷻ។ ក្រៅពីនេះ វិចារណញ្ញាណក៏ចង្អុលទៅរកការពិតនេះដែរដោយផ្អែកលើភ័ស្តុតាងខាងលើ រឿងកាតព្វកិច្ចនេះដែលត្រូវតែធ្វើ ព្រោះយើងជំពាក់គុណដែលបានទទួលឧបការគុណទាំងអស់ មកពីព្រះម្ចាស់ដ៏មានព្រះហឫទ័យទូលំទូលាយ ។ ត្រូវតែអរព្រះគុណ ត្រូវតែស្រឡាញ់ ត្រូវតែគោរពនិងលើកតម្កើងព្រះសាស្តាﷺយើងដែលជាព្រះសាស្តាﷺប្រកបដោយព្រហ្មវិហារធម៌ ដែលជាព្រះមគ្គទេសក៍របស់អ៊ុមម៉ាត់ ដែលជាអ្នកស្រោចស្រង់មនុស្សជាតិ ។ លើកតម្កើងនិងស្រឡាញ់ព្រះរាជកុលដ្ឋានរបស់ព្រះសាស្តាﷺ ជាប៉ែកមួយនៃការលើកតម្កើងនិងជាការស្រឡាញ់ព្រះសាស្តាﷺ ។

អាស្រ័យលើមូលដ្ឋាននេះ គោលការណ៍ណែនាំធំៗនៃច្បាប់អ៊ីស្លាមស្ហារីអ៊ាស់បួនប្រការ ពោលគឺ ព្រះគម្ពីរគួរអាន ព្រះស៊ូណាស់ ការស្របមតិគ្នារបស់អស់លោកអ្នកប្រាជ្ញមុស្លីមជំនាន់ផ្សេងៗ និងការពិចារណាដោយប្រៀបធៀប ជាករណីយកិច្ចលើមុស្លីមទាំងឡាយឲ្យស្រឡាញ់ព្រះរាជកុលដ្ឋានរបស់ព្រះសាស្តាﷺ ។ មិនអាចលើកយកភ័ស្តុតាងទាំងអស់នេះមកអធិប្បាយនៅក្នុងបទនិពន្ធខ្លីនេះបានទេ ព្រោះវាទាមទារនូវអត្ថបទចងក្រងច្រើនក្បាល ។ ទោះជាយ៉ាងណាក៏ដោយ ព្រមទទួលការពិតនេះជារឿងដែលមិនអាចជជែកបានសម្រាប់មនុស្សទាំងពីរប្រភេទ គឺមនុស្សសាមញ្ញនិងអ្នកប្រាជ្ញ ។ យើងគ្រាន់តែលើកឡើងនូវចំណុចមួយចំនួននៃប្រធានបទនេះទេ ដើម្បីបំភ្លឺបណ្តាអ្នកស្រឡាញ់ព្រះរាជកុលដ្ឋានរបស់ព្រះសាស្តាﷺ ព្រោះអល់ឡោះហ្ﷻមានព្រះបន្ទូលថា៖

إِنَّ اللَّهَ اصْطَفَىٰ آدَمَ وَنُوحًا وَآلَ إِبْرَاهِيمَ وَآلَ عِمْرَانَ عَلَى الْعَالَمِينَ .

*ពិតណាស់អល់ឡោះហ្បានជ្រើសរើសអាដាំ នុះហ្ បណ្តាកូនចៅរបស់អ៊ិបរ៉ហ៊ីមនិងបណ្តាកូនចៅរបស់អ៊ីមរ៉ននៃលើប្រជានិករទាំងឡាយ ។ (៣:៣៣)*

ពិតណាស់ ព្រះសាស្ដាﷺមូហាំម៉ាដ់ﷺនៅក្នុងចំណោមព្រះរាជបុត្ររាជនត្តារបស់អ៊ីបរ៉ហ៊ីម(عليه السلام) ដោយហេតុនេះ ព្រះរាជកុលដ្ឋានរបស់ព្រះអង្គﷺ ក៏នៅក្នុងចំណោមព្រះរាជបុត្ររាជនត្តារបស់អ៊ីបរ៉ហ៊ីម(عليه السلام)ដែរ ។ សរុបសេចក្ដី ព្រះរាជកុលដ្ឋានរបស់ព្រះសាស្ដាﷺត្រូវអល់ឡោះហ្ (عز وجل) ជ្រើសរើស ។

ពាក់ព័ន្ធនឹងព្រះបន្ទូលរបស់អល់ឡោះហ្(عز وجل)៖

إِنَّمَا يُرِيدُ اللَّهُ لِيُذْهِبَ عَنْكُمُ الرِّجْسَ أَهْلَ الْبَيْتِ وَيُطَهِّرَكُمْ تَطْهِيرًا

*អល់ឡោះហ្គ្រាន់តែប្រាថ្នាឲ្យពួកអ្នកចាកផុតពីមន្ទិល ហើយព្រះអង្គប្រាថ្នាសំអាតពួកអ្នកឲ្យបរិសុទ្ធជ្រះស្អាតតែប៉ុណ្ណោះទេ (៣៣:៣៣) ។*

នេះគឺភ័ស្តុតាងច្បាស់ទែង បញ្ជាក់អំពីឋានៈពិសេសរបស់ព្រះរាជកុលដ្ឋាន(عليهم السلام)របស់ព្រះសាស្ដាﷺ ។ មានអាយ៉ាត់គួរអាននិងហាឌីស្សច្រើនទៀតដែលអះអាងបញ្ជាក់គាំទ្រគ្នារឿងនេះ ។ ឧទាហរណ៍សំខាន់បំផុតគឺព្រះបន្ទូលអល់ឡោះហ្(عز وجل)៖

قُلْ لَا أَسْأَلُكُمْ عَلَيْهِ أَجْرًا إِلَّا الْمَوَدَّةَ فِي الْقُرْبَىٰ ۗ

*ចូរអ្នកថា៖ "ខ្ញុំមិនសូមឈ្នួលពីអស់លោកសម្រាប់អ្វីទាំងនេះទេ សូមឲ្យតែអាណិតស្រឡាញ់បណ្ដាសាច់សាលោហិតជំនិតរបស់ខ្ញុំ (៤២:២៣) ។"*

ហាឌីស្សប្រាកដដែលត្រូវគេបញ្ជាក់ថាជាហាឌីស្សពិត ដែលស្ដីអំពីព្រះរាជកុលដ្ឋាន(عليهم السلام)របស់ព្រះសាសាﷺនោះមានច្រើនរាប់មិនអស់ ។ យើងសូមលើកយកហាឌីស្ស នោះខ្លះមកអធិប្បាយជូន គឺ៖

អាល់-តៀរមីស៊ី (الترمذي) នៅក្នុង *អាល់-ស៊ូណាន់* របស់លោក និង អាប៊ូ-ហាតាំ បានធ្វើសេចក្ដីរាយការណ៍ហាឌីស្សខាងក្រោមនេះ ក្រោមអាជ្ញាធររបស់ស្សៃដ៍ អ៊ីបនូ អារក្ខំ គឺ៖

أَنَا حَرْبٌ لِمَنْ حَارَبَهُمْ وَسِلْمٌ لِمَنْ سَالَمَهُمْ.

*"ខ្ញុំﷺនឹងប្រយុទ្ធទល់នឹងបុគ្គលណាដែលប្រយុទ្ធទល់នឹងពួកគេ(عليهم السلام) (គឺព្រះរាជកុលដ្ឋាន(عليهم السلام)របស់ព្រះសាស្ដាﷺ) ។ ខ្ញុំﷺនឹងស្រុះស្រួលជាមួយបុគ្គលណាដែលស្រុះស្រួលជាមួយពួកគេ(عليهم السلام) ។"*

អាល់-តៀរមីស៊ី (الترمذي) និង អ៊ីម៉ាំអាស់ម៉ាដ្ញបានកត់ត្រាទុកនូវហាឌីស្ហ នេះ គឺ៖

مَنْ آذَىٰ قَرَابَتِي فَقَدْ آذَانِي، وَمَنْ آذَانِي فَقَدْ آذَىٰ اللهَ.

*"អ្នកណាធ្វើឲ្យសាច់ញាតិខ្ញុំﷺឈឺចាប់ អ្នកនោះធ្វើឲ្យខ្ញុំﷺឈឺចាប់ ។ អ្នកណាធ្វើឲ្យខ្ញុំﷺឈឺចាប់ អ្នកនោះធ្វើឲ្យអល់ឡោះហ្ម៍ﷻឈឺចាប់ ។"*

អ៊ីម៉ាំ អាល់-ប៊ូខ៊ំរី នៅក្នុង *អាល់-ស្ហ៏ហ៊ិះហ្ម៍* របស់លោក បានកត់ត្រាទុកនូវសេចក្តីរាយការណ៍តមកពី អាប់ឌុល់-រ៉ោះហ្មាន អ៊ីបនូ អាប៊ូ ឡៃឡា (عبد الرحمن بن أبي ليلى) ថា៖ "កាអាប់ អ៊ីបនូ អាល់-យ៉ាររ៉ោះហ្មបានជួបខ្ញុំ បាន ថា៖ "តើខ្ញុំអាចបង្ហាញលោកនូវអំណោយមួយដែលខ្ញុំបានឮមកពីព្រះសាសនៈទូតﷺរបស់អល់ឡោះហ្ម៍ﷻបានទេ ?" ខ្ញុំបានឆ្លើយថា៖ "បាន សូមប្រាប់ខ្ញុំមក ។" លោកបាននិយាយថា៖ "យើងបានសួរព្រះសាស្តាﷺថា តើជូនពរដល់អាស្ហ៍លុល-បៃត៍(عليهم السلام)ដូចម្តេចទៅ ? ព្រះអង្គﷺមានព្រះវចនៈថា៖ "អស់លោកគប្បីថា៖

قُولُوا: اللَّهُمَّ صَلِّ عَلَىٰ مُحَمَّدٍ وَعَلَىٰ آلِ مُحَمَّدٍ كَمَا صَلَّيْتَ عَلَىٰ إِبْرَاهِيمَ وَعَلَىٰ آلِ إِبْرَاهِيمَ، إِنَّكَ حَمِيدٌ مَجِيدٌ. اللَّهُمَّ بَارِكْ عَلَىٰ مُحَمَّدٍ وَعَلَىٰ آلِ مُحَمَّدٍ كَمَا بَارَكْتَ عَلَىٰ إِبْرَاهِيمَ وَعَلَىٰ آلِ إِبْرَاهِيمَ، إِنَّكَ حَمِيدٌ مَجِيدٌ.

*"ចូរថា៖ "អល់ឡោះហ្ម៍ﷻអើយ សូមព្រះអង្គﷻអាណិតមេត្តាមូហាំម៉ាដ្ញﷺ និងគ្រួសាររបស់មូហាំម៉ាដ្ញﷺ ដូចព្រះអង្គﷻអាណិតមេត្តាអ៊ីបរ៉ហ៊ីម(عليه السلام) និងគ្រួសាររបស់អ៊ីបរ៉ហ៊ីម(عليه السلام)ដែរ ។ ពិតណាស់ ព្រះអង្គﷻជាទីគោរពសក្ការៈ ព្រះអង្គﷻទ្រង់មហារុងរឿង ។ អល់ឡោះហ្ម៍ﷻអើយ សូមព្រះអង្គﷻប្រទានពរជ័យដល់មូហាំម៉ាដ្ញ និងគ្រួសាររបស់មូហាំម៉ាដ្ញ ដូចព្រះអង្គﷻប្រទានពរជ័យដល់អ៊ីបរ៉ហ៊ីម(عليه السلام) និងគ្រួសាររបស់អ៊ីបរ៉ហ៊ីម(عليه السلام)ដែរ ។ ពិតណាស់ ព្រះអង្គﷻជាទីគោរពសក្ការៈ ព្រះអង្គﷻទ្រង់មហារុងរឿង ។"*

យ៉ាបៀរ លោកព្រឹទ្ធាចារ្យយើង អធិប្បាយហាឌីស្ហនេះថា៖ "ខ្ញុំមិនជឿជាក់

ទេថាស្ទ៏ឡាត់ខ្ញុំ   បើខ្ញុំមិនជូនពរជ័យដល់មូហាំម៉ាដ់និងគ្រួសារ(عليهم السلام)របស់មូហាំម៉ាដ់ទេនោះ ថាគេនឹងព្រមទទួលយកស្វ៏ឡាត់បែបនេះ ។"

អាល់-តៀរមីស៊ី (الترمذي) នៅក្នុង *អាល់-ស៊ូណាន់* របស់លោក បានថ្លែងតមកពី អ៊ូម៉ារ អ៊ីបនូ អាប៊ូ សាឡាម៉ាស់ កូនធម៌របស់ព្រះសាស្តា(صلى الله عليه وآله وسلم)ថា៖ "ពាក់ព័ន្ធនឹងអាយ៉ាស់នេះ គឺ៖

إِنَّمَا يُرِيدُ اللَّهُ لِيُذْهِبَ عَنْكُمُ الرِّجْسَ أَهْلَ الْبَيْتِ وَيُطَهِّرَكُمْ تَطْهِيرًا.

*អល់ឡោះហ៏គ្រាន់តែប្រាថ្នាឲ្យពួកអ្នកចាកផុតពីមន្ទិល  ហើយព្រះអង្គប្រាថ្នាសំអាតពួកអ្នកឲ្យបរិសុទ្ធជ្រះស្អាតតែប៉ុណ្ណោះទេ (៣៣:៣៣) ។*

កាលអាយ៉ាស់នេះត្រូវបើកឲ្យដឹងឡើង ព្រះសាស្តា(صلى الله عليه وآله وسلم)នៅឯផ្ទះរបស់ អ៊ូម សាឡាម៉ាស់ - ព្រះមហេសីត្រឹមត្រូវរបស់ព្រះសាស្តា(صلى الله عليه وآله وسلم) ។ ព្រះអង្គ(صلى الله عليه وآله وسلم)បានកោះហៅ អាលី ហ្វាទីម៉ាស់ អាល់-ហាសាន់ និង អាល់-ហ៊ូសែន៍(عليهم السلام)បានគ្របផួយលើអ្នកទាំងអស់គ្នា(عليهم السلام)  ផួយនោះគ្របខ្នងព្រះអង្គ(صلى الله عليه وآله وسلم)ដែរ ហើយព្រះអង្គ(صلى الله عليه وآله وسلم)មានព្រះវចនៈថា៖

اللَّهُمَّ هٰؤُلاَءِ أَهْلُ بَيْتِي فَأَذْهِبْ عَنْهُمُ الرِّجْسَ وَطَهِّرْهُمْ تَطْهِيراً.

*អល់ឡោះហ៏(عزّ وجلّ)អើយ នេះគឺអ្នកផ្ទះរបស់ទូលព្រះបង្គំជាខ្ញុំ(صلى الله عليه وآله وسلم) ដូច្នេះ [សូមព្រះអង្គ(عزّ وجلّ)] កុំឲ្យមន្ទិលប៉ះពាល់ពួកគេ(عليهم السلام) សូមព្រះអង្គ(عزّ وجلّ)ជម្រះបន្សុទ្ធពួកគេដោយការជម្រះបន្សុទ្ធហ្មត់ចត់ ។*

ឃើញដូច្នេះ អ៊ូម សាឡាម៉ាស់ បានសួរថា៖ "ព្រះសាសនៈទូត(صلى الله عليه وآله وسلم)អល់ឡោះហ៏(عزّ وجلّ)អើយ  តើខ្ញុំម្ចាស់នៅក្នុងចំណោមពួកគេ(عليهم السلام)ទេ ?"  ព្រះសាស្តា(صلى الله عليه وآله وسلم)បានឆ្លើយថា៖  "អ្នកនៅក្នុងឋានៈរបស់អ្នក  ហើយអ្នកនៅលើមាគ៌ាល្អ[10] ។"

នេះគឺអ្នកអាស្ល់លុល-បៃត៏(عليهم السلام)  ដែលអល់ឡោះហ៏(عزّ وجلّ)បានធ្វើឲ្យចាកផុតពីមន្ទិល ដែលព្រះអង្គ(عزّ وجلّ)បានជម្រះបន្សុទ្ធិយ៉ាងហ្មត់ចត់ ។ នៅក្នុងហាឌីស្ស

[10] បន្ទាប់ពីបានកត់ត្រាហាឌីស្សនេះ អាល់-បៃហាគីបានអធិប្បាយថា៖ យោលតាម អាប៊ូ អាប់ឌុលឡោះហ៏ អាល់-តៀរមីស៊ី (الترمذي) ហាឌីស្សនេះជាហាឌីស្សពិតបណ្តាអ្នកតំណាលហាឌីស្សនេះជាអ្នកត្រឹមត្រូវ ។

ខាងលើ ព្រះសាសនៈទូត ﷺ របស់អល់ឡោះហ្ម៍ عز وجل បានបង្ហាញឲ្យឃើញថាកិត្តិយសនេះ (គឺការជម្រះបន្សុទ្ធ) បានទៅលើព្រះអង្គទាំងនេះដាច់មុខ មិនបានទៅលើអ្នកណាផ្សេងទេ ។

យោលតាមការតំណាល ឋានៈដាច់មុខនេះបញ្ជាក់ថា អ៊ុម សាឡាម៉ាស្ហ៍ បានឮនិងបានឃើញព្រឹត្តិការណ៍ទាំងអស់ ហើយបានសូមព្រះសាស្ដា ﷺ ឲ្យរាប់បញ្ចូលព្រះនាងទៅក្នុងចំណោមវរបុគ្គលទាំងនេះដែរ ។ ពេលព្រះនាងបើកជាយផ្ទួយចូលទៅក្នុងផ្ទួយនោះដែរ ព្រះសាស្ដា ﷺ បានយកជាយផ្ទួយពីដៃព្រះនាង ហើយមានព្រះវចនៈថា៖ "អ្នកនៅក្នុងឋានៈរបស់អ្នក ហើយអ្នកនៅលើមាគ៌ាល្អ ។"

ព្រោះឋានៈដាច់មុខនេះឧទ្ទិសចំពោះតែអាស្ហ៍លុល-បៃត៍ عليهم السلام ទេ មិនរាប់បញ្ចូលអ្នកណាផ្សេងទេ ទោះជាព្រះនាង អ៊ុម សាឡាម៉ាស្ហ៍ក៏ដោយ ដែលជាព្រះអគ្គមហេសីប្រកបដោយគុណធម៌របស់ព្រះសាស្ដា ﷺ និងជាមាតារបស់បណ្ដាអ្នកមានសទ្ធា (សូមអល់ឡោះហ្ម៍ عز وجل ទ្រង់សព្វព្រះហឫទ័យអស់ព្រះមាតារបស់បណ្ដាអ្នកមានសទ្ធា)[11] ។

បើគេអនុញ្ញាត ឬយល់ព្រមឲ្យអ្នកណាមួយមានសិទ្ធិចូលរួមចំណែកឋានៈដាច់មុខរបស់ព្រះរាជកុលដ្ឋានរបស់ព្រះសាស្ដាដែរនោះ គេប្រាកដជាអនុញ្ញាតឲ្យព្រះនាង អ៊ុម សាឡាម៉ាស្ហ៍ ចូលទៅក្នុងផ្ទួយនោះដែរ យ៉ាងហោចដើម្បីបំពេញបំណងព្រះនាង ដើម្បីលោមចិត្តព្រះនាង ឬដើម្បីលើកតម្លៃព្រះនាងដែលព្រះនាងជាបុគ្គលប្រកបដោយគុណធម៌ និងស្មោះត្រង់ ឬបំពេញបំណងព្រះនាងដោយឲ្យព្រះនាងនៅក្នុងចំណោមអ្នក "ជិតស្និទ្ធនឹងណ្ដាអ្នកមានសទ្ធាជាងខ្លួនពួកគេផ្ទាល់ទៅទៀត" និង

---

[11] នៅក្នុងព្រះគម្ពីរគួរអាន ស៊.៣៣, អា.៦ អល់ឡោះហ្ម៍ عز وجل មានព្រះបន្ទូលថា៖

النَّبِيُّ أَوْلَىٰ بِالْمُؤْمِنِينَ مِنْ أَنْفُسِهِمْ ۖ وَأَزْوَاجُهُ أُمَّهَاتُهُمْ

*ព្រះសាស្ដាជិតស្និទ្ធនឹងណ្ដាអ្នកមានសទ្ធាជាងខ្លួនពួកគេផ្ទាល់ទៅទៀត ភរិយាទាំងឡាយរបស់គេ (គឺព្រះសាស្ដា ﷺ) ជាម្ដាយរបស់ពួកគេ ។*

អាស្រ័យហេតុនេះ ព្រះមហេសីទាំងឡាយរបស់ព្រះសាស្ដា ﷺ ត្រូវហៅថា "មាតារបស់បណ្ដាអ្នកមានសទ្ធា" ។

ដែល "មានខន្តី មានធម៌មេត្តា[ពិសេស]ចំពោះបណ្តាអ្នកមានសទ្ធា[12]" គេហៅបុគ្គលទាំងនោះថាជាអ្នកចិត្តល្អ ជាបុគ្គលបាសាទិក (ប៉ាសាទិកៈ គឺមានសេចក្តីជ្រះថ្លា) បុគ្គលថ្លៃថ្នូរ បុគ្គលចិត្តទូលាយនិងត្រង់ ។ ដូច្នេះ គេបានឃើញច្បាស់ថា អាយ៉ាស់នេះសំដៅទៅលើតែបុគ្គលដែលនៅក្នុងផ្ទះទេ មិនសំដៅទៅលើអ្នកផ្សេងទេ ។ សេចក្តីរាយការណ៍ពិតក៏បានអះអាងបញ្ជាក់ដែរថារឿងនេះជាព្រឹត្តិការណ៍ពិត ។

ដូច្នេះគេបានអះអាងបញ្ជាក់ថាពិតហើយថា អាយ៉ាស់នេះសំដៅទៅលើព្រះរាជកុលដ្ឋានعليهم السلامរបស់ព្រះសាស្តាصلى الله عليه وآله وسلمដែលញែកដាច់ពីគេ អាស្រ័យលើគុណសម្បត្តិខ្ពង់ខ្ពស់នេះ ។ សេចក្តីបន្ថែម ព្រះស៊ូណាស់មានពាសពេញពិភពអ៊ីស្លាម សម្បូរដោយសេចក្តីរាយការណ៍អំពីគុណសម្បត្តិរបស់ព្រះរាជកុលដ្ឋានعليهم السلامរបស់ព្រះសាស្តាصلى الله عليه وآله وسلم គឺ៖

នៅក្នុងសៀវភៅលោកដែលមានចំណងជើងថា *អាល់-ស្ហ៍ហ៊ិះហ៍* លោកមុស្លីមបានថ្លែងតមកពីយ៉ាស៊ីដ្ន អ៊ីបនូ ហៃយ៉ាន់ អាល់-តៃមី ថា៖ ហ៊្វសៃន៍ អ៊ីបនូ សាបារ៉ោះត៍, មុស្លីម អ៊ីបនូ ស៊ៃដ៍និងខ្ញុំបានទៅជួបស៊ៃដ៍ អ៊ីបនូ អាុរកុំ ។ បន្ទាប់ពីបានអង្គុយពីមុខលោក ហ៊្វសៃន៍បានសួរលោក ថា៖ "ស៊ៃដ៍អឺយ លោកបានទទួលផលប្រយោជន៍ធំមែនព្រោះលោកបានឃើញព្រះសាស្តាصلى الله عليه وآله وسلم បានស្តាប់សម្តីព្រះអង្គصلى الله عليه وآله وسلم បានចូលរួមក្នុងសមរភូមិជាមួយព្រះអង្គصلى الله عليه وآله وسلم បានស្ហ៍ឡាត់តាមក្រោយព្រះអង្គصلى الله عليه وآله وسلم ។ ស៊ៃដ៍អឺយ សូមលោកតំណាលប្រាប់យើងផង តើលោកបានឮអ្វីខ្លះពីព្រះសាសនៈទូតصلى الله عليه وآله وسلم របស់អល់ឡោះហ៍عز وجل ។" ស៊ៃដ៍បានថា៖ "កូនរបស់បងប្អូនខ្ញុំអឺយ សូមស្បថចំពោះអល់ឡោះហ៍عز وجل ខ្ញុំចាស់ជរាហើយ ខ្ញុំបានភ្លេចរឿងនេះខ្លះ

---

[12] ផ្តោតទៅលើព្រះបន្ទូលអល់ឡោះហ៍តាអាុឡានៅក្នុងគម្ពីរគួរអាន ស.៩ អា.១២៨ គឺ៖

لَقَدْ جَاءَكُمْ رَسُولٌ مِنْ أَنْفُسِكُمْ عَزِيزٌ عَلَيْهِ مَا عَنِتُّمْ حَرِيصٌ عَلَيْكُمْ بِالْمُؤْمِنِينَ رَءُوفٌ رَحِيم.

*ពិតណាស់ មានសាស្តាមួយរូប[ដែលត្រូវជ្រើសរើស]ក្នុងចំណោមពួកអ្នក បានមកដល់ពួកអ្នក ។ គេកើតទុក្ខព្រោះតែឃើញពួកអ្នករងទុក្ខ គេបារម្ភអំពីពួកអ្នកណាស់ ។ គេមានខន្តី មានធម៌មេត្តា[ពិសេស]ចំពោះបណ្តាអ្នកមានសទ្ធា ។*

ហើយ ដែលខ្ញុំតែងតែទន្ទេញចងចាំទុកពីព្រះសាសនៈទូតصلى الله عليه وآله وسلمរបស់អល់ឡោះហ្វ៍عز وجلផ្ទាល់តែម្តង ។ ដូច្នេះ ចូរលោកទទួលយកអ្វីដែលខ្ញុំប្រាប់លោក កុំសួរខ្ញុំលើសពីនេះនិងលើសពីសមត្ថភាពខ្ញុំ ។" លោកបាននិយាយបន្តថា៖ "ថ្ងៃមួយ នៅរវាងម៉ាក់កាស់និងម៉ាឌីណាស់ ដែលគេហៅថា "ឃុម" ព្រះសាសនៈទូតصلى الله عليه وآله وسلمរបស់អល់ឡោះហ្វ៍عز وجلបានថ្លែង ប្រាប់យើង ។ បន្ទាប់ពីបានថ្លែងគារវកិច្ចនិងអំណរព្រះគុណអល់ឡោះហ្វ៍عز وجل បន្ទាប់ពីបានថ្លែងដាស់តឿនប្រដៅ និងរំលឹកអំពីអល់ឡោះហ្វ៍عز وجلហើយព្រះសាស្តាصلى الله عليه وآله وسلمមានព្រះវចនៈថា៖

أَلاَ أَيُّهَا النَّاسُ، فَإِنَّمَا أَنَا بَشَرٌ يُوشِكُ أَنْ يَأْتِيَنِي رَسُولُ رَبِّي فَأُجِيبُ، وَأَنَا تَارِكٌ فِيكُم ثَقَلَيْنِ: أَوَّلُهُمَا كِتَابُ اللهِ فِيهِ الهُدىٰ وَالنُّورُ؛ فَخُذُوا بِكِتَابِ اللهِ وَاسْتَمْسِكوا بِهِ... وَأَهْلُ بَيْتِي؛ أُذَكِّرُكُمُ اللهَ فِي أَهْلِ بَيْتِي، أُذَكِّرُكُمُ اللهَ فِي أَهْلِ بَيْتِي، أُذَكِّرُكُمُ اللهَ فِي أَهْلِ بَيْتِي.

ប្រជានិករអើយ ខ្ញុំصلى الله عليه وآله وسلمមិនមែនអ្វីក្រៅពីមនុស្សធម្មតាទេ ។ អ្នកនាំសាររបស់ព្រះម្ចាស់ខ្ញុំصلى الله عليه وآله وسلم - បន្តិចទៀតទេវតាយកព្រលឹងនឹងមកជួបខ្ញុំصلى الله عليه وآله وسلم ដូច្នេះខ្ញុំصلى الله عليه وآله وسلمត្រូវតែឆ្លើយតប ។ ខ្ញុំصلى الله عليه وآله وسلمទុកឲ្យអស់លោកនូវវត្ថុសំខាន់បំផុតពីរ ។ មួយគឺព្រះគម្ពីររបស់ អល់ឡោះហ្វ៍عز وجلដែលមាននូវការដឹកនាំត្រឹមត្រូវ និងរស្មីត្រចះត្រចង់ ចូរអស់លោកព្យាយាមតាមព្រះគម្ពីររបស់អល់ឡោះហ្វ៍عز وجل ចូរតោងព្រះគម្ពីរនេះឲ្យជាប់ ។ ពីរគឺបណ្តាអ្នកផ្ទះعليهم السلام របស់ខ្ញុំصلى الله عليه وآله وسلم ចូរនឹករលឹកដល់អល់ឡោះហ្វ៍عز وجلពាក់ព័ន្ធនឹងបណ្តាអ្នកផ្ទះعليهم السلام របស់ខ្ញុំصلى الله عليه وآله وسلم ចូរនឹករលឹកដល់អល់ឡោះហ្វ៍عز وجلពាក់ព័ន្ធនឹងបណ្តាអ្នកផ្ទះعليهم السلام របស់ខ្ញុំصلى الله عليه وآله وسلم ចូរនឹករលឹកដល់អល់ឡោះហ្វ៍عز وجلពាក់ព័ន្ធនឹងបណ្តាអ្នកផ្ទះعليهم السلام របស់ខ្ញុំصلى الله عليه وآله وسلم ។" ហ្ស៊ូសែន៍បានសួរទៀតថា៖ "ស្សៃដ៍អើយ អ្នកណាទៅអ្នកផ្ទះعليهم السلامរបស់ព្រះសាស្តាصلى الله عليه وآله وسلمនោះ ? តើរាប់បញ្ចូលព្រះមហេសីទាំងឡាយរបស់ព្រះអង្គصلى الله عليه وآله وسلمក្នុងចំណោមអ្នកផ្ទះعليهم السلامព្រះអង្គصلى الله عليه وآله وسلمផងទេ ?" ស្សៃដ៍បានឆ្លើយថា៖ "រាប់បញ្ចូលព្រះមហេសីទាំងឡាយរបស់ព្រះអង្គصلى الله عليه وآله وسلمក្នុងចំណោមអ្នកផ្ទះរបស់ព្រះអង្គصلى الله عليه وآله وسلم តែអ្នកផ្ទះعليهم السلامរបស់ព្រះអង្គصلى الله عليه وآله وسلمត្រូវហាមទទួលយកអំណោយទានអត់ពីព្រះអង្គصلى الله عليه وآله وسلمទៅ ។" ហ្ស៊ូសែន៍បានសួរថា៖

"តើពួកគេعليهم السلامជាអ្នកណា ?" ស្រ៊ែដ៏បានឆ្លើយថា៖ "ពួកគេعليهم السلامគឺគ្រួសារ របស់អាលីصلوات الله عليه والسلام គ្រួសាររបស់អាគ៊ីល គ្រួសាររបស់យ៉ាក់ហ្វារ៍ និងគ្រួសាររបស់អាប់បាស់ ។"

[អាប់ឌុលឡោះហ៍] អ៊ីបនូ អាប់បាស់ បានតំណាលថាព្រះសាសនៈទូតصلى الله عليه وآله وسلمរបស់អល់ឡោះហ៍عز وجلមានព្រះវចនៈថា៖

يَا بَنِي عَبْدِ ٱلمطَّلِبِ؛ إِنِّي قَدْ سَأَلْتُ اللهَ أَنْ يُثَبِّتَ قَائِمَكُمْ وَأَنْ يَهْدِيَ ضَالَّكُمْ وَأَنْ يُعَلِّمَ جَاهِلَكُمْ وَأَنْ يَجْعَلَكُمْ جُوَدَاءَ نُجَدَاءَ رُحَمَاءَ. فَلَوْ أَنَّ رَجُلاً صَفَنَ بَيْنَ ٱلرُّكْنِ وَالمقَامِ فَصَلَّىٰ وَصَامَ، ثُمَّ لَقِيَ اللهَ مُبْغِضاً لأَهْلِ بَيْتِ مُحَمَّدٍ دَخَلَ النَّارَ.

*"បណ្ដាកូនៗរបស់ អាប់ឌុល-មុត្តត៍លិបអើយ ខ្ញុំصلى الله عليه وآله وسلمបានអង្វរសូមអល់ឡោះហ៍عز وجل ឲ្យព្រះអង្គعز وجلតែងតាំងអ្នកដឹកនាំម្នាក់ក្នុងចំណោមអស់លោកដែលនឹងធឹង (គឺមានគោលជំហរត្រឹមត្រូវ) ដែលដឹកនាំបណ្ដាអ្នកវង្វេងក្នុងចំណោមអស់លោក ដែលអប់រំអ្នកមិនចេះដឹងក្នុងចំណោមអស់លោក ដែលធ្វើឲ្យអស់លោកមានចិត្តទូលាយ ថ្លៃថ្នូរនិងមានធម៌មេត្តា ។ អ្នកដែលតម្រៀបជួរនៅចន្លោះ រុកន៍ និង ម៉ាកូម[13] ដើម្បីស៊ូឡាត់និងកាន់សីលត្រណមអាហារ ប្រាកដជានឹងត្រូវចូលភ្លើងនរកពេលអ្នកនោះជួបអល់ឡោះហ៍عز وجل (ក្នុងថ្ងៃរស់ពីស្លាប់) បើអ្នកនោះព្យាបាទបណ្ដាអ្នកផ្ទះعليهم السلامរបស់មូហាំម៉ាដ៍صلى الله عليه وآله وسلم ។"*

ហាឌីស្សនេះត្រូវកត់ត្រាដោយអាល់-ហាគីម (នៅក្នុងសៀវភៅលោកដែលមានចំណងជើងថា *អាល់-មុសតាដ់រ៉ក់)* ដោយប្រើលក្ខណៈវិនិច្ឆ័យរបស់លោកមុស្លីម[14] ។

---

[13] រុកន៍ (ركن) គឺជ្រុងកាក់ប៉ាស់ ។ ម៉ាកូម (مقام) គឺកន្លែងដែលណាប៊ីអ៊ីបរ៉ហ៊ីមعليه السلامឈរនៅក្បែរកាក់បាស់ ។

[14] សៀវភៅយោងរបស់បងប្អូនស៊ុន្នីយើងដែលគួរទុកចិត្តបំផុតនោះ មានប្រាំមួយនីមួយៗមានលក្ខណៈវិនិច្ឆ័យមិនពាក់ព័ន្ធគ្នាទេ ក្នុងការសម្រេចថាហាឌីស្សនីមួយមានសភាវៈពិតត្រឹមប៉ុណ្ណោះ ។ លោក មុស្លីម ជាអ្នកចងក្រងម្នាក់របស់សៀវភៅមួយក្នុងចំណោមសៀវភៅទាំងប្រាំមួយនេះ ។ ដូច្នេះហើយបានជាលោកមានលក្ខណៈវិនិច្ឆ័យផ្ទាល់ខ្លួនលោកដើម្បីសម្រេចថា ហាឌីស្សមានសភាវៈ

ព្រះរាជកុលដ្ឋានﷺរបស់ព្រះសាស្តាﷺ សក្តិសមនឹងការយកចិត្តទុកដាក់របស់អល់ឡោះហ៍ﷻលើសគេ ហើយសក្តិសមនឹងការស្រឡាញ់របស់ព្រះសាសនៈទូតﷺរបស់អល់ឡោះហ៍ﷻលើសគេ ពីព្រោះវរបុគ្គលទាំងនេះត្រូវចាត់ទុកជាសន្តិសុខសម្រាប់ប្រជានិករនៅលើផែនដីនេះ ។ អ៊ីម៉ាំ អាស្ម៉ាដ្ម អ៊ីបនូ ហាន់បាល់ នៅក្នុង *អាល់-មុសណាដ់* របស់លោក និងលោក អាប៊ូ អាំរូ អាល់-គ៊ីហ្សារី បានធ្វើសេចក្តីរាយការណ៍តមកពីអ៊ាលី ថាព្រះសាសនៈទូតﷺរបស់អល់ឡោះហ៍ﷻមានព្រះវចនៈថា៖

النُّجُومُ أَمَانٌ لأَهْلِ السَّمَاءِ، فَإِذَا ذَهَبَتِ النُّجُومُ ذَهَبَ أَهْلُ السَّمَاءِ. وَأَهْلُ بَيْتِي أَمَانٌ لأَهْلِ الأَرْضِ، فَإِذَا ذَهَبَ أَهْلُ بَيْتِي ذَهَبَ أَمَانُ أَهْلِ الأَرْضِ.

*"ផ្កាយជាស្តិសុខសម្រាប់ប្រជានិករមេឃ ។ បើផ្កាយរលាយបាត់អស់ប្រជានិករមេឃក៏រលាយបាត់អស់ដែរ ។ ដូចគ្នាដែរ ព្រះរាជកុលដ្ឋានﷺខ្ញុំﷺក៏ជាសន្តិសុខសម្រាប់ប្រជានិករផែនដីដែរ ។ បើពួកគេបាត់ខ្លួនអស់ប្រជានិករផែនដីក៏នឹងអន្តរធានដែរ ។"*

លោក ណាស្វារ (ឬណាស្វ៊ូរ៍) អ៊ីបនូ អ៊ាលី អាល់-យ៉ាស់ឌូមីបានលើកយកមកអធិប្បាយនូវសេចក្តីរាយការណ៍នេះដែលស្តីអំពី អ៊ាលី អ៊ីបនូ អាប៊ូ តុ៏លិប ថា៖ "ព្រះសាស្តាﷺបានកាន់ដៃអាល់-ហាសាន់និងអាល់-ហ៊ូសៃន៍ﷺ ហើយបានប្រកាសថា៖

مَنْ أَحَبَّنِي وَأَحَبَّ هٰذَيْنِ وَأَبَاهُمَا وَأُمَّهُمَا كَانَ مَعِي فِي دَرَجَتِي يَوْمَ الْقِيَامَةِ

*"អ្នកណាស្រឡាញ់អ្នកទាំងពីរនាក់នេះ ឪពុករបស់ពួកគេនិងម្តាយរបស់ពួកគេ ពិតណាស់អ្នកនោះនឹងបាននៅជាមួយខ្ញុំﷺនៅក្នុងឋានៈដូចគ្នាក្នុងថ្ងៃរស់ពីស្លាប់វិញ ។"*

ស៊ីហ្វយ៉ាន អ៊ីបនូ វ៉ាគី និង អ៊ាប់ឌូ អ៊ីបនូ ហាមីដ្ឋបានធ្វើសេចក្តីរាយការណ៍ថាខ៉ុលិដ្ឋ អ៊ីបនូ មូខ៉ុឡាដ្ឋ៉បានតំណាលប្រាប់អស់លោកតមកពីអ៊ូសាម៉ាស៊ុ អ៊ីបនូ ស្ស៊ៃដ្ឋថា៖ "យប់មួយខ្ញុំបានទៅជួបព្រះសាស្តាﷺដែលបានចេញពីផ្ទះដោយឱបរបស់ពីរនៅក្នុងផ្ទួយដែលខ្ញុំមើលមិនឃើញ ។ បន្ទាប់ពីខ្ញុំ

---

ពិត មិនភ្លេងក្លាយនោះ ប៉ុណ្ណាខ្លះ ។

បានសួរព្រះអង្គﷺរឿងដែលខ្ញុំមកជួបព្រះអង្គﷺនោះ ខ្ញុំបានសួរអំពីរបស់ដែលព្រះអង្គﷺឱប ។ ព្រះអង្គﷺក៏បានបើកជួយ ឯរបស់ទាំងពីរនោះគឺ អាល់-ហាសាន់និងអាល់-ហ៊ូសែន៍عليهم السلامនៅលើចង្កេះព្រះអង្គﷺ ។ ហើយព្រះអង្គﷺមានព្រះវចនៈថា៖

هٰذَانِ ابْنَايَ وَابْنَا ابْنَتِي. اللَّهُمَّ إِنِّي أُحِبُّهُمَا فَأَحِبَّهُمَا وَأَحِبَّ مَنْ يُحِبُّهُمَا.

*"ទាំងពីរនេះគឺកូនប្រុសខ្ញុំﷺ និងកូនប្រុសរបស់កូនស្រីខ្ញុំﷺ ។ អល់ឡោះហ៍عز وجلអើយ ទូលព្រះបង្គំជាខ្ញុំﷺស្រឡាញ់គេទាំងពីរ ទូលព្រះបង្គំﷺជាខ្ញុំអង្វរសូមឲ្យព្រះអង្គعز وجلទ្រង់សព្វព្រះហឫទ័យពួកគេ និងទ្រង់សព្វព្រះហឫទ័យបណ្ដាដែលស្រឡាញ់ពួកគេដែរ ។"*

អាល់-ហាសាន់ អ៊ីបនូ ហ៊្វារ៉យ់ស្វ៍បានថ្លែងថា អាប៊ូ ប៊ូរ៉យ់ដ្ហាស់បានថា៖ "ខណៈដែលព្រះសាស្តាﷺថ្លែងសុន្ទរកថា (យុត្ថបាស់) នៅលើវេទិកាឲ្យយើងស្តាប់ អាល់-ហាសាន់និងអាល់-ហ៊ូសែន៍عليهم السلامដែលបានពាក់អាវក្រហម បានដើរចូលមករកព្រះអង្គﷺចំពប់ជើង ។ ព្រះសាសនៈទូតﷺរបស់អល់ឡោះហ៍ﷺចុះពីលើវេទិកាភ្លាម ពរអ្នកទាំងពីរعليهم السلامទៅដាក់ពីមុខព្រះអង្គﷺ ។ ហើយព្រះអង្គﷺបានអធិប្បាយថា៖

صَدَقَ اللهُ: "انَّمَا أَمْوَالُكُمْ وَأَوْلَادُكُمْ فِتْنَةٌ" نَظَرْتُ إِلَىٰ هٰذَيْنِ الصَّبِيَّيْنِ يَمْشِيَانِ وَيَعْثُرَانِ فَلَمْ أَصْبِرْ حَتَّىٰ قَطَعْتُ حَدِيثِي وَرَفَعْتُهُمَا.

*"ព្រះបន្ទូលសច្ចៈរបស់អល់ឡោះហ៍عز وجل៖ "ទ្រព្យសម្បត្តិនិងកូនៗរបស់ពួកអ្នកជាការល្បងពិសោធន៍ (៦៤:១៥)" ។ ពេលខ្ញុំﷺឃើញ អ្នកទាំងពីរعليهم السلامដើរចំពប់ជើង ខ្ញុំﷺមិនអាចចៀសវាងឈប់ថ្លែងសុន្ទរកថាបានទេដើម្បីលើកអ្នកទាំងពីរعليهم السلامពីដី ។"*

អល់ឡោះហ៍عز وجل ក៏បានដាក់កំហិតឲ្យគោរពព្រះរាជកុលដ្ឋានعليهم السلامរបស់ព្រះសាស្តាﷺដែរ ។ ចំពោះរឿងនេះ អាល់-ប៊ូខ៉ូរី នៅក្នុង *ស្វ៉ហ៊ិះហ៍* របស់លោក បានកត់ត្រាថា អាប៊ូ បាការ បានតំណាលព្រះវចនៈរបស់ព្រះសាស្តាﷺថា៖

يَا أَيُّهَا النَّاسُ، أُرْقُبُوا مُحَمَّداً فِي أَهْلِ بَيْتِهِ.

*"ប្រជានិករអើយ ចូរគោរពមូហាំម៉ាដ់ صلى الله عليه وآله وسلمតាមរយៈការលើកតម្កើងព្រះរាជកុលដ្ឋាន عليهم السلامរបស់មូហាំម៉ាដ់ ។"*

អ៊ីម៉ាំ អាស៊ម៉ាដ់ អ៊ីបនូ ហាន់បាល់ បានកត់ត្រានៅក្នុង *ស៊្ហីហ៊ុះហ្ហ៍* លោកតមកពីអ៊ាលី صلوات الله عليه والسلامថាព្រះសាស្តា صلى الله عليه وآله وسلمមានព្រះវចនៈថា៖

إِنِّيْ وَإِيَّاكِ وَهٰذَيْنِ (يعني حسناً وحسيناً) وَهٰذَا الرَّاقِدَ (يعني علياً) فِي مَكَانٍ وَاحِدٍ يَوْمَ القِيَامَةِ.

*"អស់ទាំងអ្នក عليهم السلام គឺអ្នកទាំងពីរនេះ عليهم السلام (ពោលគឺ អាល់-ហាសាន់និងអាល់-ហ៊ូសែន៍ عليهم السلام) អ្នកដេកម្នាក់នេះ (ពោលគឺ អ៊ាលី صلوات الله عليه والسلام) និងខ្ញុំ صلى الله عليه وآله وسلمនឹងមានឋានៈស្មើគ្នាយ៉ាងពិតប្រាកដថ្ងៃរស់ពីស្លាប់វិញ ។"*

អាល់-ត្ព័បារ៉នី (الطبراني) បានកត់ត្រាតមកពីអ៊ាលី صلوات الله عليه والسلامថាព្រះសាសនៈទូត صلى الله عليه وآله وسلمរបស់អល់ឡោះហ្ម៍ عز وجلមានព្រះវចនៈថា៖

أَوَّلُ مَنْ يَرِدُ عَلَيَّ الحَوْضِ أَهْلُ بَيْتِي وَمَنْ أَحَبَّنِي مِنْ أُمَّتِي.

*"ព្រះរាជកុលដ្ឋាន عليهم السلامខ្ញុំ صلى الله عليه وآله وسلمនិងបណ្តាអ្នកដែលស្រឡាញ់ខ្ញុំ صلى الله عليه وآله وسلم ក្នុងចំណោមបណ្តាអ្នកនៅក្នុងអ៊ុមម៉ាត់ខ្ញុំ صلى الله عليه وآله وسلمនឹងបានមកជួបខ្ញុំ صلى الله عليه وآله وسلمមុនគេនៅឯព្រះរាជស្រះទឹក ។"*

អាល់-ត្ព័បារ៉នី (الطبراني) បានកត់ត្រានៅក្នុងសៀវភៅរបស់លោក *អាល់-មុអ៊ុយហ្ហាំ អាល់-ស្ហ៊ក្ហៀរ* (المعجم الصغير) តមកពីអ៊ាប់ឌុលឡោះហ្ម៍ អ៊ីបនូយ៉ាក្ហ៊ុហ្វារថាព្រះសាសនៈទូត صلى الله عليه وآله وسلمរបស់អល់ឡោះហ្ម៍ عز وجلមានព្រះវចនៈថា៖

يَا بَنِي هَاشِمَ، إِنِّيْ قَدْ سَأَلْتُ اللهَ عَزَّ وَجَلَّ أَنْ يَجْعَلَكُمْ جُوَدَاءَ نُجَدَاءَ رُحَمَاءَ. وَسَأَلْتُهُ أَنْ يَهْدِيَ ضَالَّكُمْ وَيُؤْمِنَ خَائِفَكُمْ وَيُشْبِعَ جَائِعَكُمْ.

*"កូនៗរបស់ហាស៊ីមអើយ ខ្ញុំ صلى الله عليه وآله وسلمបានអង្វរអល់ឡោះហ្ម៍ عز وجلសូមព្រះអង្គធ្វើឲ្យអស់លោកមានចិត្តទូលាយ ថ្លៃថ្នូរនិងមានធម៌មេត្តា ។ ខ្ញុំ صلى الله عليه وآله وسلمបានសូមព្រះអង្គ عز وجلដែរ សូមឲ្យព្រះអង្គ عز وجلដឹកនាំបណ្តាអ្នកវង្វេងក្នុងចំណោមអស់លោក*

*សូមឲ្យព្រះអង្គﷻ ធ្វើឲ្យបណ្ដាអ្នកខ្លាចក្នុងចំណោមអស់លោកផុតភ័យ និងសូមឲ្យព្រះអង្គﷻផ្គត់ផ្គង់បណ្ដាអ្នកឃ្លានក្នុងចំណោមអស់លោក ។"*

នៅក្នុងសៀវភៅ *អាល់-មុសតាដ្រ៉ក់* របស់លោក អាល់-ហ្វាគីមដែលបាន កត់ត្រាហាឌីស្ហនេះតមកពី អាណាស់ អ៊ីបនូ ម៉ាលិក (أنس بن مالك) ហើយ បានសម្រេចថាជាហាឌីស្ហពិត មិនក្លែងក្លាយនោះ បានធ្វើសេចក្ដីរាយ ការណ៍ថាព្រះសាសនៈទូតﷺរបស់អល់ឡោះហ្ម៉ាﷻមានព្រះវចនៈថា៖

رشدني ربي في أهل بيتي من أقر منهم بالتوحيد ولي بالبلاغ ألا يعذبهم.

*"ពាក់ព័ន្ធនឹងអ្នកផ្ទះខ្ញុំﷺ ព្រះម្ចាស់ﷻខ្ញុំﷺបានសន្យាខ្ញុំﷺថាព្រះអង្គﷻ នឹងមិនដាក់ទោសអ្នកម្នាក់ក្នុងចំណោមពួកគេទេ ដែលជឿថា អល់ឡោះហ្ម៉ាﷻជាព្រះតែមួយគត់ (គឺជឿតៅហ៊ីដអល់ឡោះហ្ម៉ាﷻ) និងជឿ ព្រះរាជសាររបស់ខ្ញុំﷺ[ដែលអល់ឡោះហ្ម៉ាﷻដាក់មក] ។"*

អាល់-ត៏្ហបារ៉នី (الطبراني) បានកត់ត្រានៅក្នុងសៀវភៅរបស់លោក *អាល់-មុអ្ហ៍យ៉ាំ អាល់-កាបៀរ* (المعجم الكبير) ក្រោមអាជ្ញាធរ [អ៊ាប់ឌុលឡោះហ្ម៉ា] អ៊ីបនូ អ៊ាប់បាស់ (ពោលគឺ តមកពី[អ៊ាប់ឌុលឡោះហ្ម៉ា] អ៊ីបនូ អ៊ាប់បាស់) នូវហាឌីស្ហមួយ ដែលអស់លោកអ្នករាយការណ៍បានសម្រេចថាជា ហាឌីស្ហពិតមិនក្លែងក្លាយ ថាព្រះសាសនៈទូតﷺរបស់អល់ឡោះហ្ម៉ាﷻ មានព្រះវចនៈប្រាប់ហ្វាទិ៍ម៉ាស្ហ់سلام الله عليهاថា៖

إِنَّ اللهَ غَيْرُ مُعَذِّبِكِ وَلاَ وُلْدِكِ.

*"ពិតណាស់ អល់ឡោះហ្ម៉ាﷻមិនធ្វើទោសកូនៗរបស់កូននិងកូនទេ ។"*

អាស្ហ៊ម៉ាដ្ហ, អាល់-ហ្វាគីម និង អាល់-បៃហ្ម៉ាគ្អី បានកត់ត្រាតមកពីអាប៊ូ សាអ៊ីដ្ហ (អាល់-ឃ៊ុដ្ហរី) ថាព្រះសាសនៈទូតﷺរបស់អល់ឡោះហ្ម៉ាﷻមាន ព្រះវចនៈនៅលើវេទិកាថា៖

مَا بَالُ رِجَالٍ يَقُولُونَ أَنَّ رَحِمَ رَسُولِ اللهِ لاَ تَنْفَعُ قَوْمَهُ يَوْمَ القِيَامَةِ؟ بَلَىٰ وَاللهِ، إِنَّ رَحِمِي مُوصِلَةٌ فِي الدُّنْيَا وَالآخِرَةِ، وَإِنِّي، أَيُّهَا النَّاسُ، فَرْطٌ لَكُمْ عَلَىٰ الحَوْضِ.

*"តើបុគ្គលមួយចំនួននោះកើតអ្វី បានជាថាសាច់ញាតិរបស់ព្រះសាសនៈទូត*صلى الله عليه وآله وسلم*របស់អល់ឡោះហ្ទ៍*عز وجل*នឹងមិនអាចជួយអ្វីបានទេ ក្នុងថ្ងៃរស់ពីស្លាប់នោះ ? ច្បាស់ណាស់ រឿងនេះមិនត្រឹមត្រូវទេ ។ សូមស្បថចំពោះអល់ឡោះហ្ទ៍*عز وجل *ខ្ញុំ*صلى الله عليه وآله وسلم*សូមស្បថថាសាច់ញាតិរបស់ខ្ញុំ*صلى الله عليه وآله وسلم*ផ្ដល់នូវជំនួយទាំងក្នុងលោកនេះនិងក្នុងលោកមុខ ។ ប្រជានិករអើយ ខ្ញុំ*صلى الله عليه وآله وسلم*នឹងទៅឯព្រះរាជស្រះទឹកមុនអស់លោក ។"*

អាល់-ប៊ូខ៉រី បានកត់ត្រានៅក្នុង *ស្វ៉ហ៊ិះហ្ទ៍* របស់លោកនូវហាឌីស្ហ៍នេះតមកពីអាប៊ូ បាការថាខណៈដែលព្រះសាស្ដាصلى الله عليه وآله وسلمកំពុងតែសម្ដែងធម៌ អាល់-ហាសាន់صلوات الله عليه والسلامបានមកដល់ ដូច្នេះព្រះសាស្ដាصلى الله عليه وآله وسلمមានព្រះវចនៈថា៖

إِبْنِي هٰذَا سَيِّدٌ، وَلَعَلَّ اللهَ يُصْلِحُ بِهِ فِئَتَيْنِ مِنَ الـمُسْلِمِينَ.

*"នេះគឺកូនប្រុសខ្ញុំ*صلى الله عليه وآله وسلم *។ គេជាចៅហ្វាយ ។ ប្រហែលជាអល់ឡោះហ្ទ៍*عز وجل*នឹងសម្រុះសម្រួលមុស្លីមពីរប៉ែកតាមរយៈរូបគេនេះ ។"*

អ៊ីបនូ ហាយ៉ារបានកត់ នៅក្នុងសៀវភៅលោក *ហ្វាទិះហ្ទ៍ អាល់-បារី* (فتح الباري) (គឺសេចក្ដីអធិប្បាយនិងសេចក្ដីបំភ្លឺអាល់-ប៊ូខ៉រី) នូវសម្ដីរបស់អាល់-មូហាល់ឡាប់ថានៅក្នុងហាឌីស្ហ៍ខាងលើនេះ ព្រះសាស្ដាصلى الله عليه وآله وسلمថ្លែងអំពីអ្នកដឹកនាំទៅរកការស្រុះស្រួលគ្នា ។ ដូច្នេះរឿងនេះបញ្ជាក់ឲ្យឃើញថាមានតែបណ្ដាអ្នកដែលផ្ដល់ផលប្រយោជន៍ដល់មនុស្សទេ ដែលសក្តិសមជាអ្នកដឹកនាំគេ ។

អ៊ីម៉ាំអាស្ហ៍ម៉ាដ្ហ៍ និង អាល់-ត៉្ហបារ៉នី (الطبراني) បានកត់ត្រានៅក្នុងសៀវភៅរបស់លោក *អាល់-មុអ្ញ៉ាំ អាល់-កាបៀរ* (المعجم الكبير) ថាអ៊ាលីصلوات الله عليه والسلامបានរាយការណ៍ថា ព្រះសាសនៈទូតصلى الله عليه وآله وسلمរបស់អល់ឡោះហ្ទ៍عز وجلបានចាត់តាំងខ្ញុំصلوات الله عليه والسلامអ្នកកាត់ក្ដីនៃប្រទេសយេមេន ខ្ញុំصلوات الله عليه والسلامបានទូលព្រះអង្គصلى الله عليه وآله وسلمថា៖ "រ៉ស៊ូលុលឡោះហ្ទ៍صلى الله عليه وآله وسلمអើយ ព្រះអង្គصلى الله عليه وآله وسلمជ្រើសរើសទូលបង្គំصلوات الله عليه والسلامដែលនៅក្មេងថ្មីបើមានមនុស្សចាស់ទុំច្រើននាក់ ។ ម្យ៉ាងទៀតទូលបង្គំصلوات الله عليه والسلامមិន

ទាន់ចេះដឹងការវិនិច្ឆ័យបរិបូរនៅឡើយទេ ។" ព្រះសាស្ដា(صلى الله عليه وآله وسلم)បានឆ្លើយថា៖

إِنْطَلِقْ فَإِنَّ اللهَ سَيَهْدِي قَلْبَكَ وَيُثَبِّتُ لِسَانَكَ.

"ចូរអ្នក(صلوات الله عليه والسلام)ទៅចុះ ព្រោះអល់ឡោះហ្ទា(عز وجل)ជាអ្នកដឹកនាំចិត្តអ្នក(صلوات الله عليه والسلام)និងពង្រឹងអណ្ដាតអ្នក ។ អាលី(صلوات الله عليه والسلام)មានវចនៈថា៖ "បន្ទាប់ពីព្រះវចនៈនេះ ខ្ញុំ(صلوات الله عليه والسلام)មិនដែលបរាជ័យឡើយ ។"

ការពិត ហាឌីស្ហពិតមិនក្លែងក្លាយទាក់ទងនឹងរឿងនេះមានច្រើនរាប់មិនអស់ ពីព្រោះសៀវភៅហាឌីស្ហយោងទាំងប្រាំមួយដែលទុកចិត្តបាន ព្រមទាំងសៀវភៅច្រើនទៀត ពោរពេញដោយសេចក្ដីរាយការណ៍បែបនេះ ដែលស្ដីអំពីការលើកតម្កើង និងការឲ្យតម្លៃដល់ឋានៈវិសេសវិសាលនិងគោលជំហរខ្ពង់ខ្ពស់ដែលគេទទួលស្គាល់ទូទៅ របស់ព្រះរាជកុលដ្ឋាន(عليهم السلام)របស់ព្រះសាស្ដា(صلى الله عليه وآله وسلم) ។ ម្យ៉ាងទៀត ទាំងអស់គ្នាដឹងរឿងនេះ មិនអាចឃើញថា អ្នកមានសទ្ធាណាម្នាក់មិនស្គាល់សេចក្ដីគោរពរាប់អានព្រះរាជកុលដ្ឋាន(عليهم السلام)របស់ព្រះសាសនៈទូត(صلى الله عليه وآله وسلم)របស់អល់ឡោះហ្ទា(عز وجل)នោះឡើយ ។

លោកអ្នកប្រាជ្ញដ៏ល្បី អាប៊ូ បាការ អាល់-បៃហាគ្គី បានថ្លែងថា៖ "សេចក្ដីរាយការណ៍ទាំងនេះ ដែលទាក់ទងនឹងគុណសម្បត្តិរបស់ព្រះរាជកុលដ្ឋាន(عليهم السلام)របស់ព្រះសាស្ដា(صلى الله عليه وآله وسلم) មានចែងនៅក្នុងសៀវភៅហាឌីស្ហទាំងឡាយដែលនៅក្នុងចំណោមសេចក្ដីរាយការណ៍ពិតមិនក្លែងក្លាយ ។ សូមមើលសៀវភៅទាំងនេះបើចាប់អារម្មណ៍រឿងនេះ ។"

ព្រះរាជកុលដ្ឋាន(عليهم السلام)របស់ព្រះសាស្ដា(صلى الله عليه وآله وسلم)គឺអាលី(صلوات الله عليه والسلام) ហ្វាទីម៉ាស្ហ(سلام الله عليها) អាល់-ហាសាន់និងអាល់-ហ៊ូសៃន៍(عليهم السلام) ។ បណ្ដាកូនចៅជំនាន់ក្រោយនិងកូនៗរបស់ព្រះអង្គទាំងនេះ(عليهم السلام) ត្រូវរាប់បញ្ចូលជាមួយព្រះអង្គទាំងនេះ(عليهم السلام)ដែរ ។ ហាឌីស្ហមូបាហាឡាស្ហ (المباهلة) - ការបួងសួងសូមឲ្យអល់ឡោះហ្ទា(عز وجل)ដាក់បណ្ដាសា - ជាភស្ដុតាងបញ្ជាក់ថា មានតែបុគ្គលទាំង

ប្រាំរូបខាងលើនេះទេ ដែលមានសិទ្ធិបាននូវឋានៈពិសេសដែលគេឲ្យទៅព្រះរាជកុលដ្ឋានعليهم السلامរបស់ព្រះសាស្ដាصلى الله عليه وآله وسلمនោះ ។
សម្រាយព្រះគម្ពីរគួរអានមួយនេះបានអះអាងបញ្ជាក់ថា ព្រឹត្តិការណ៍នេះជាព្រឹត្តិការណ៍ពិត គឺព្រះបន្ទូលអល់ឡោះហ្ញ៍عز وجل៖

فَمَنْ حَاجَّكَ فِيهِ مِنْ بَعْدِ مَا جَاءَكَ مِنَ الْعِلْمِ فَقُلْ تَعَالَوْا نَدْعُ أَبْنَاءَنَا وَأَبْنَاءَكُمْ وَنِسَاءَنَا وَنِسَاءَكُمْ وَأَنْفُسَنَا وَأَنْفُسَكُمْ نَبْتَهِلْ فَنَجْعَلْ لَعْنَتَ اللَّهِ عَلَى الْكَاذِبِين. ثُمَّ

*ដូច្នេះអ្នកណាមួយឈ្លោះប្រកែកជាមួយអ្នកអំពីរឿងនេះ ក្រោយពីព្រះអភិញ្ញាបានមកដល់អ្នកហើយនោះ ចូរអ្នកថា៖ "អស់លោកចូរមកចុះ យើងនឹងហៅកូនប្រុសៗរបស់យើង និងកូនប្រុសៗរបស់អស់លោក បណ្ដាស្ត្រីរបស់យើងនិងបណ្ដាស្ត្រីរបស់អស់លោក ខ្លួនយើងផ្ទាល់និងខ្លួនអស់លោកផ្ទាល់ រួចហើយយើងបួងសួងយ៉ាងស្មោះអស់ពីចិត្ត សូមឲ្យព្រះបណ្ដាសារបស់ អល់ឡោះហ្ញ៍ពើបពះលើមុសាវាទី (គឺអ្នកនិយាយកុហក) (៣:៦១) ។"*

កាលអាយ៉ាស់នេះត្រូវបានបើកឲ្យដឹង ព្រះសាសនៈទូតصلى الله عليه وآله وسلمរបស់អល់ឡោះហ្ញ៍عز وجلបានឱបអាល់-ហាសាន់និងអាល់-ហ៊ូសៃន៍عليهم السلام ហ្វាទីម៉ាស់سلام الله عليهاដើរពីក្រោយព្រះអង្គទាំងបីعليهم السلام អាលីصلوات الله عليه والسلامដើរពីក្រោយព្រះអង្គទាំងបួនعليهم السلام ។ បន្ទាប់មកព្រះសាស្ដាصلى الله عليه وآله وسلمបានប្រាប់ព្រះអង្គទាំងបួនعليهم السلامឲ្យថា "អាមីន" ពេលព្រះអង្គصلى الله عليه وآله وسلمបួងសួងអល់ឡោះហ្ញ៍... ។ល ។[15]

អំពីព្រឹត្តិការណ៍នេះ យ៉ាហ្ររ៉ល់ឡោះហ្ញ៍ បានអធិប្បាយថា៖ "អាយ៉ាស់នេះជាភ័ស្តុតាងសំខាន់បំផុតបញ្ជាក់អំពីគុណសម្បត្តិរបស់ អាស្ហាប់ អាល់-គីសាអ៊ុ (اصحاب الكِساء) គឺបណ្ដាអ្នកក្នុងផួយ គឺព្រះរាជកុលដ្ឋានعليهم السلامរបស់

---

[15] ព្រឹត្តិការណ៍មូបាហាឡាស់ (المباهلة) - ការបួងសួងសូមឲ្យអល់ឡោះហ្ញ៍عز وجلដាក់បណ្ដាសា - នេះគេស្គាល់ច្បាស់ព្រោះគេនិយាយអំពីរឿងនេះនៅក្នុងសៀវភៅស្ទើរទាំងអស់ដែលស្ដីអំពីប្រវត្តិសាស្ត្រអ៊ីស្លាម ។

ព្រះសាស្តាﷺ)[16] ។

អាយ៉ាស់ខាងក្រោមនេះជាភ័ស្តុតាងបញ្ជាក់ថា ព្រះរាជបុត្ររាជនត្តារបស់វរបុគ្គលទាំងនេះមានគុណសមស្បត្តិតជាប់មកពីវរបុគ្គលទាំងនេះដែរ គឺះ

وَالَّذِينَ آمَنُوا وَاتَّبَعَتْهُمْ ذُرِّيَّتُهُمْ بِإِيمَانٍ أَلْحَقْنَا بِهِمْ ذُرِّيَّتَهُمْ.

*បណ្តាអ្នកមានសទ្ធា ដែលបណ្តាកូនចៅរបស់ខ្លួនបានអនុចរតាមគន្លងសទ្ធាពួកគេដែរនោះ យើងនឹងឲ្យបណ្តាកូនចៅពួកគេជួបជុំពួកគេ (៥២:២១) ។*

អស់លោកអ្នកប្រាជ្ញបានអះអាងបញ្ជាក់ថាពិត ថា "បណ្តាកូនចៅ" រាប់បញ្ចូលបច្ឆាជន (គឺកូនចៅ) ដើមរបស់ព្រះរាជកុលដ្ឋានعليهم السلامរហូតទៅដល់ថ្ងៃគ្ចីយ៉ាម៉ាត្ត់ ។ អំពីរឿងនេះ រាប់បញ្ចូលព្រះរាជបុត្ររាជនត្តារបស់ព្រះរាជកុលដ្ឋានعليهم السلامរបស់ព្រះសាស្តាﷺ ក្នុងព្រះរាជកុលដ្ឋានរបស់ព្រះសាស្តាﷺដែររហូតដល់ថ្ងៃគ្ចីយ៉ាម៉ាត្ត់ ។ ចំពោះចំណុចនេះ អស់លោកអ្នកប្រាជ្ញខាងច្បាប់អ៊ីស្លាមបានចេញច្រើនច្បាប់រឿងវ៉ាក្វហ្វ[17] និងរឿងស្រដៀងនេះ ។ ពាក់ព័ន្ធនឹងរឿងនេះដែរ បញ្ហាទ្រព្យរបស់បច្ឆានារីរបស់ព្រះរាជបុត្រីរបស់ព្រះសាស្តាﷺ និងកូនចៅតៗមកនោះជាបញ្ហាល្បីខ្លាំងមួយ អ៊ីមុាំ អាប៊ូ ហ្វានីហ្វាស់ អាល់-នុអ៍ម៉ាន អ៊ីបនូ ស្ហាប៊ីតបានសម្តែងយោបល់

[16] អាស្ហ្វាប់ អាល់-គីសាអ៍ (اصحاب الكِساء) ជាឈ្មោះ ដែលគេហៅព្រះសាស្តាﷺ អ៊ីមុាំអាលីصلوات الله عليه والسلام ហ្វាទីម៉ាស់سلام الله عليها អ៊ីមុាំអាល់-ហ្វាសាន់صلوات الله عليه والسلامនិងអ៊ីមុាំអាល់-ហ៊ូសែន៍صلوات الله عليه والسلام ព្រោះព្រះសាស្តាﷺបានដណ្តប់ព្រះអង្គទាំងបួននេះក្នុងជួយ ហើយបានបួងសួងអល់ឡោះហ្វ៍ﷻ សូមព្រះអង្គﷻធ្វើឲ្យវរបុគ្គលទាំងនេះជ្រះអស់ពីមន្ទិល សូមឲ្យជម្រះបន្សុទ្ធវរបុគ្គលទាំងនេះយ៉ាងជ្រះបរិសុទ្ធ ។ នៅក្នុងព្រឹត្តិការណ៍នេះព្រះសាស្តាﷺហៅវរបុគ្គលទាំងនេះថា "ព្រះរាជកុលដ្ឋានរបស់ខ្ញុំ" (ពោលគឺ អាស្ហ្វលុល-បៃត៍عليهم السلام គឺអ្នកផ្ទះខ្ញុំﷺ) ។

[17] វ៉ាក្វហ្វគឺការប្រគល់ទ្រព្យជាទាន ឬការដាក់ទ្រព្យឲ្យនៅក្រោមការបម្រើសាសនាឬក្នុងគោលដៅសប្បុរសធម៌ ។

យ៉ាងច្បាស់អំពីបញ្ហានេះ ។

លោកអ្នកចងក្រងសៀវភៅ *ម៉ាហ្វាស៊ីន អាល់-តាក់វីល* (محاسن التأويل) បានធ្វើសេចក្តីអធិប្បាយអាយ៉ាស់ខាងលើនេះថា៖ "អាយ៉ាស់នេះសំដៅទៅលើបណ្តាអ្នកយកតម្រាប់តាមបណ្តាដូនតារបស់ខ្លួន ក្នុងជំនឿនិងការធ្វើល្អ ។ អាយ៉ាស់បំភ្លឺដែរថាបណ្តាបច្ឆាជនទាំងនោះនឹងតាមជាប់ដូនតារបស់ខ្លួននៅក្នុងឋានសួគ៌បរមសុខ ។ ព្រោះបណ្តាអ្នកដែលគេនិយាយដល់នៅក្នុងអាយ៉ាស់នេះនោះគឺបណ្តាសាវករបស់ព្រះសាស្តា ﷺ ដែលអល់ឡោះហ៍ ﷻ បានសន្យា ពួកគេនឹងបានទទួលដំណឹងល្អថាបណ្តាកូនចៅរបស់ពួកគេដែលយកតម្រាប់តាមពួកគេយ៉ាងត្រឹមត្រូវនោះ នឹងត្រូវរាប់បញ្ចូលជាមួយពួកគេដែរ ។"

ពួកហ្វាស្ហីមឯទៀតដែលត្រូវហាមទទួលអំណោយទាននោះ មានបុណ្យស័ក្តិខ្ពង់ខ្ពស់ជាងពួកហ្វាស្ហីមឯទៀត តែមិនអាចលក្ខណៈជា "អាស្ហាប់អាល់-គីសាអ៊ុ (اصحاب الكساء)" និងមិនអាចមានលក្ខណៈជាព្រះរាជបុត្រាជនត្តារបស់ព្រះសាស្តា ﷺ ដែលច្បាប់តម្រូវឲ្យស្រឡាញ់ ឲ្យគោរព ឲ្យគំនាប់លំឱនលំទោននិងលើកតម្កើងនោះទេ ។

លោកអ្នកប្រាជ្ញមានយោបល់ផ្សេងៗ អំពីព្រះបន្ទូលអល់ឡោះហ៍ ﷻ

إِنَّمَا يُرِيدُ اللَّهُ لِيُذْهِبَ عَنْكُمُ الرِّجْسَ أَهْلَ الْبَيْتِ وَيُطَهِّرَكُمْ تَطْهِيرًا.

*អល់ឡោះហ៍គ្រាន់តែប្រាថ្នាឲ្យពួកអ្នកចាកផុតពីមន្ទិល ហើយព្រះអង្គប្រាថ្នាសំអាតពួកអ្នកឲ្យបរិសុទ្ធជ្រះស្អាតតែប៉ុណ្ណោះទេ (៣៣:៣៣) ។*

លោកអ្នកប្រាជ្ញខ្លះបានសម្រេចថា អាយ៉ាស់នេះផ្តោតទៅលើតែបច្ឆាជន (គឺបណ្តាកូនចៅ) របស់អាលី صلوات الله عليه والسلام និងហ្វាទីម៉ាស់ سلام الله عليها ទេ ចំណែកឯលោកអ្នកប្រាជ្ញឯទៀតរាប់បញ្ចូលគ្រួសាររបស់អាល់-អាប់បាស់ គ្រួសាររបស់យ៉ាក់ហ្វារ៍និងគ្រួសាររបស់អាគីលជាមួយបច្ឆាជនខាងលើនេះដែរ ។

នៅក្នុងសៀវភៅ *អាល់-រីសាឡាស្ស៊ អាល់-ស្រៃណាប់ប៊ីយ៉ាស្ស៊* លោកយ៉ាឡាល់លូឌីន អាល់-ស៊ូយូទី បានកត់ត្រានូវពាក្យពេជន៍ថ្លៃថ្លាអំពីអត្តសញ្ញាណកម្មរបស់ "ស្ហារីហ្វ" (شريف គឺព្រះអង្គម្ចាស់) ។ លោកបានថ្លែងថា៖ "នាសម័យដំបូងនៃសាសនាអ៊ីស្លាម វិសេសសព្ទ "ស្ហារីហ្វ" ត្រូវប្រើសម្រាប់ហៅបុគ្គល ដែលជាព្រះរាជកុលដ្ឋានعليهم السلامរបស់ព្រះសាស្តាﷺ ទោះជាជាប់ខាងអាល់-ហ្ហាសាន់ ឬ អាល់-ហ្ហ៊ូសៃន៍صلوات الله عليه والسلامក្តី ដែលជាប់ឈាមជ័រនឹងអាលីصلوات الله عليه والسلام ទោះជាជាប់ខាងមូហ្ហាំម៉ាដ្ឋ អ៊ីបនូ អាល់-ហ្ហាណាហ្វីយ៉ាស្ស៊ ឬជាប់ខាងកូនៗឯទៀតក៏ដោយ ឬដែលជាប់ឈាមជ័រនឹងយ៉ាក់ហ្វារ៍, អាគីល ឬ អាប់បាស់ក្តី ។"

ដូច្នេះ នៅក្នុងជីវប្រវត្តិចែងនៅក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់លោកអាល់-ស្ហាហ្ហាប៊ី (الذهبي) អស់លោកអាចឃើញមាននូវព្រះនាមច្រើន ដូចជា "ស្ហារីហ្វ អាល់-អាប់បាស់", "ស្ហារីហ្វ អាគីល", "ស្ហារីហ្វ យ៉ាក់ហ្វារ៍" ឬ "ស្ហារីហ្វ ស្រៃណាប់" ជាដើម ។

តែ ពេលសន្តតិវង្សហ្វាត៏មីយ៉ាស្ស៊ (الفاطمية)កាន់ក្តាប់ប្រទេសអេស៊ីបត៍ ពួកគេឧទ្ទិសវិសេសសព្ទនេះឲ្យទៅបច្ឆាជនរបស់ព្រះបរមគ្រូយើង អាល់-ហ្ហាសាន់និងអាល់ហ្ហ៊ូសៃន៍عليهم السلام ។ រឿងនេះនៅតែមានដូច្នេះនៅក្នុងប្រទេសអេស៊ីបត៍តរៀងមកដល់សព្វថ្ងៃ ។

ព្រះនាងស្រៃណាប់سلام الله عليها បានអភិសេកជាមួយព្រះអង្គម្ចាស់របស់ខ្ញុំ អាប់ឌុលឡោះហ្ហ៍ អ៊ីបនូ យ៉ាក់ហ្វារ៍ បងប្អូនជីដូនមួយរបស់ព្រះនាងسلام الله عليها ។ ព្រះរាជបុត្របរិសុទ្ធរបស់ព្រះនាងគឺ សៃយីដ្ឋ អាលី - យកតាមព្រះនាមរបស់ព្រះអយ្យកោព្រះអង្គ - សៃយីដ អោន៍ អាល់-អាក់បារ៍ (عَوْن الاكبر) សៃយីដ អាប់បាស់ សៃយីដ មូហ្ហាំម៉ាដ់ និង ព្រះនាង អ៊ូម គុលស៊្ហូម រាប់តាមលេខរៀង ។ បណ្តាកូនចៅរបស់ព្រះនាងស្រៃណាប់سلام الله عليها សព្វថ្ងៃនេះមានច្រើន ។ យោលតាមលោកអ្នកប្រាជ្ញ អាល់-ស្ហូប់បាន់ វរបុគ្គលទាំងនេះត្រូវបូកបញ្ចូលក្នុងគ្រួសារនិងព្រះរាជកុលដ្ឋានរបស់ព្រះសាស្តាﷺ ។ គេបានវិនិច្ឆ័យរឿងនេះជាឯកច្ឆន្ទ ព្រោះគ្រួសារព្រះសាស្តាﷺជាបណ្តា

អ្នកមានសទ្ធាសិប់ចិត្តក្នុងត្រកូលហាស្ហ៊ីម ជាកូនប្រុសរបស់អាប់ឌុល-មុត្តត៌លិប ជាកូនចៅនិងជាបច្ឆាជនរបស់អាប់ឌុល-មុត្តត៌លិប ។ កូនៗ (និងបច្ឆាជន) របស់កូនស្រីរបស់បុគ្គលនីមួយត្រូវចាត់ទុកជាបណ្ដាកូនចៅនិងជាបច្ឆាជនរបស់បុគ្គលនោះ ។ ពេលបុគ្គលនោះធ្វើមរតកសាស្ត្រទុកឲ្យបច្ឆាជនក្រោយៗរបស់ខ្លួន បច្ឆាជនរបស់កូនស្រីបុគ្គលនោះត្រូវបានមរតកមួយចំណែក ។ ក៏ប៉ុន្តែវាមានន័យចំៗជាងខាងលើនេះ ។ ដូច្នេះព្រោះតែគេមូលមតិគ្នាជាឯកច្ឆ័ន្ទ បណ្ដាបច្ឆាជនរបស់យ៉ាក់កុំហ្វារ៍ត្រូវហាមទទួលយកអំណោយទាន ព្រោះរបុគ្គលទាំងនេះជាព្រះរាជកុលដ្ឋានعليهم السلام របស់ព្រះសាស្ដាﷺ ។

ទោះបីសព្វថ្ងៃនេះគេឧទ្ទិសឲ្យទៅបណ្ដាបច្ឆាជនរបស់ អាល់-ហាសាន់និងអាល់-ហ៊ូសែន៍عليهم السلامក៏ដោយ វិសេសសព្ទ "ស្ហារីហ្វ" ត្រូវតែប្រើសម្រាប់ហៅបុគ្គលគ្រប់រូប ដែលនៅក្នុងព្រះរាជកុលដ្ឋានعليهم السلامរបស់ព្រះសាស្ដាﷺ យោលតាមទស្សនៈចាស់របស់វិសេសសព្ទនេះ ។

លោកអ្នកចងក្រងសៀវភៅ *អាល់-ម៉ាក់ហ៊ីប* បានថ្លែងថាព្រះសាសនៈទូតﷺរបស់អល់ឡោះហ៍عز وجلមិនមានបច្ឆាជនទេ ក្រៅពីបច្ឆាជនខាងព្រះនាងហ្វាទីម៉ាស់سلام الله عليها អាស់-ស្ហាស់រ៉អ៍ ព្រះរាជបុត្រីព្រះអង្គﷺនោះ ។ ដូច្នេះព្រះរាជបុត្ររាជនត្តាបរិសុទ្ធរបស់ព្រះសាស្ដាﷺ កើតមកពីព្រះនត្តាពីរអង្គរបស់ព្រះអង្គﷺ អ៊ីម៉ាំអាល់-ហាសាន់និងអ៊ីម៉ាំអាល់-ហ៊ូសែន៍عليهم السلام ។ គេហៅបណ្ដាអ្នកដែលនៅក្នុងចំណោមបណ្ដាបច្ឆាជន (គឺកូនចៅតៗរៀងមក) របស់អ៊ីម៉ាំទាំងពីរអង្គនេះថា "ហាសានី" និង "ហ៊ូសែនី" ។ ដាច់ឡែកឈ្មោះ "អ៊ីសហាគ៉ី" ត្រូវបូកបញ្ចូលក្នុងចំណោមបណ្ដាអ្នកដែលជាសមាជិកគ្រួសាររបស់អ៊ីសហាក់ ព្រះរាជបុត្ររបស់យ៉ាក់កុំហ្វារ៍ អាល់-ស្ហ៊ឌិក្វដែលជាព្រះរាជបុត្ររបស់មូហាំម៉ាដ្ឋ អាល់-បាគៀរ៍ដែលជាព្រះរាជបុត្ររបស់អ៊ីម៉ាំ ស៊ែន៍ អាល់-អាប៊ីឌីនصلوات الله عليه والسلام ដែលជាព្រះរាជបុត្ររបស់អ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلام ។ ព្រះអង្គ គឺអ៊ីសហាក់ ជាព្រះស្វាមីរបស់ព្រះនាងណាហ្វីសាស់ (نفيسة) ព្រះរាជបុត្រីរបស់ អាល់-ហាសាន់ អ៊ីបនូ ស៊ែដ្ឋ អ៊ីបនូ

អាល់-ហាសាន់ អ៊ីបនូ អាល់-ហាសាន់ អ៊ីបនូ អាលី صلوات الله عليه والسلام ។

អាល់-ស្វប់បានបានថា "កិត្តិសព្ទស្វារីហ្វ" មានថ្នាក់ផ្សេងៗ។ គឺបុគ្គលទូទៅរាប់បញ្ចូលក្នុងព្រះរាជកុលដ្ឋានទាំងអស់របស់ព្រះសាស្តា صلى الله عليه وآله ឯបុគ្គលពិសេសគឺព្រះរាជបុត្ររាជនត្តារបស់ព្រះសាស្តា صلى الله عليه وآله ហេតុដូច្នេះ រាប់បញ្ចូលបច្ឆាជនរបស់ព្រះនាងស្វៃណាប់ سلام الله عليها និងបច្ឆាជនទាំងអស់របស់ព្រះរាជបុត្រីរបស់ព្រះសាស្តា صلى الله عليه وآله ដែរ ឯថ្នាក់ទីបីគឺសម្រាប់តែអាល់-ហាសាន់និងអាល់-ហ៊ូសៃន៍ទេ ហើយត្រូវហៅថា "ស្វារីហ្វញាតិវង្ស"

ភ័ស្តុតាងសម្រាប់បណ្តាអ្នកដែលអះអាងថាព្រះនាម អាស្វ៉ុលុល-តៃប៍បានត្រឹមតែលើបុគ្គលច្បាស់លាស់ទេនោះគឺអាយ៉ាស្វ៍ខាងក្រោមនេះ ដែលនាំមកថ្លែងតាមរយៈសេចក្តីរាយការណ៍ពិតមិនក្លែងក្លាយផ្សេងៗជាច្រើន គឺៈ ព្រះសាស្តា صلى الله عليه وآله ដឹកដៃអាល់-ហាសាន់និងអាល់-ហ៊ូសៃន៍ عليهم السلام ដោយមានអាលី صلوات الله عليه والسلام និងហ្វាទីម៉ាស្វ៍ سلام الله عليها តាមក្រោយ បានដើរចូលមក។ ព្រះអង្គ صلى الله عليه وآله បានហៅអាលី صلوات الله عليه والسلام និង ហ្វាទីម៉ាស្វ៍ سلام الله عليها ឲ្យចូលមកជិត អង្គុយពីមុខព្រះអង្គ صلى الله عليه وآله ។ ព្រះអង្គ صلى الله عليه وآله ដាក់អាល់-ហាសាន់និងអាល់-ហ៊ូសៃន៍ عليهم السلام ឲ្យអង្គុយលើភ្លៅព្រះអង្គ صلى الله عليه وآله ព្រះអង្គ صلى الله عليه وآله បានដណ្តប់អ្នកទាំងអស់គ្នានឹងជួយ ហើយសូត្រថាៈ

إِنَّمَا يُرِيدُ اللَّهُ لِيُذْهِبَ عَنْكُمُ الرِّجْسَ أَهْلَ الْبَيْتِ وَيُطَهِّرَكُمْ تَطْهِيرًا

*"អល់ឡោះហ្ទ៍គ្រាន់តែប្រាថ្នាឲ្យពួកអ្នកចាកផុតពីមន្ទិល ហើយព្រះអង្គប្រាថ្នាសំអាតពួកអ្នកឲ្យបរិសុទ្ធជ្រះស្អាតតែប៉ុណ្ណោះទេ (៣៣:៣៣) ។*

យោលតាមសេចក្តីរាយការណ៍មួយទៀត ព្រះសាស្តា صلى الله عليه وآله មានព្រះវចនៈថាៈ

اللَّهُمَّ هٰؤُلاءِ أَهْلُ بَيْتِي فَأَذْهِبْ عَنْهُمُ الرِّجْسَ وَطَهِّرْهُمْ تَطْهِيراً.

*"អល់ឡោះហ្ទ៍ عز وجل អឺយ នេះគឺព្រះរាជកុលដ្ឋានរបស់ទូលព្រះបង្គំជាខ្ញុំ صلى الله عليه وآله [ដូច្នេះ ទូលព្រះបង្គំជាខ្ញុំ صلى الله عليه وآله អង្វរព្រះអង្គ عز وجل] សូមព្រះអង្គ عز وجل ធ្វើឲ្យពួកគេឃ្លាតឆ្ងាយពីមន្ទិល សូមព្រះអង្គ عز وجل ជម្រះបន្សុទ្ធពួកគេឲ្យជ្រះស្អាត ។"*

យោលតាមសេចក្តីរាយការណ៍ទីបី ព្រះសាស្តាﷺមានព្រះវចនៈថាៈ *"អល់ឡោះហ្វ៏﷿អើយ នេះគឺគ្រួសាររបស់មូហាំម៉ាដ្ឋ៏ﷺ [ដូច្នេះទូលព្រះបង្គំជាខ្ញុំﷺអង្វរព្រះអង្គ﷿] សូមព្រះអង្គ﷿អាណិតមេត្តាពួកគេ សូមព្រះអង្គ﷿ប្រទានពរជ័យដល់គ្រួសាររបស់មូហាំម៉ាដ្ឋ៏ﷺ ដូចព្រះអង្គ﷿បានប្រទានពរជ័យដល់គ្រួសាររបស់អ៊ីបរ៉ហ៊ីមﷺដែរ ។ ព្រះអង្គ﷿ទ្រង់ជាទីគោរពសក្ការៈ ព្រះអង្គ﷿ទ្រង់មហារុងរឿង ។"*

យល់ស្របនឹងបណ្តាអ្នកគាំទ្រភាពទូទៅ នៃអត្តសញ្ញាណអាស្ហ់លុល-បៃត៍លោកអាល់-បៃដាវីថ្លែងថា ដៅអត្តសញ្ញាណអាស្ហ់លុល-បៃត៍លើរបុគ្គលតែប្រាំអង្គនោះមិនត្រូវនឹងអាយ៉ាស្ហ់មុន និងអាយ៉ាស្ហ់ក្រោយអាយ៉ាស្ហ់ដែលគេនិយាយដល់នេះទេ (ពោលគឺ អាយ៉ាស្ហ់ជម្រះបន្សុទ្ធ) ។ ថែមពីលើនេះ ហ្ញាឌីស្ហ៍បានស្តីអំពីបុគ្គលទាំងនោះជាពិសេសដើម្បីចង្អុលទៅលើព្រះរាជកុលដ្ឋានរបស់ព្រះសាស្តាﷺ មិនមែនអ្នកណាក្រៅពីបុគ្គលទាំងនោះទេ ។

ម្យ៉ាងទៀត និយាយអំពីការដៅនោះគឺដើម្បីបូកព្រះរាជបុត្ររាជនត្តាដោយចំពោះបញ្ចូលជាមួយរបុគ្គលទាំងនោះ ព្រោះព្រះរាជបុត្ររាជនត្តាទាំងនេះមានឋានៈពិសេស ។ ដូច្នេះវាមិនជំទាស់លក្ខណៈទូទៅនៃអត្តសញ្ញាណអាស្ហ់លុល-បៃត៍عليهم السلامទេ ។

គួរជឿដែរថាការដៅបុគ្គលទាំងបួនជាពិសេសនោះជាព្រះបញ្ញា ។ សំអាងរបស់រឿងនេះគឺហ្ញាឌីស្ហ៍ដែល អ៊ុម សាឡាម៉ាស្ហ់បានថ្លែង គឺៈ ដោយឃើញដូច្នេះ អ៊ុម សាឡាម៉ាស្ហ់បានបើកជាយជួយប្រុងចូលទៅក្នុងជួយនោះជាមួយព្រះអង្គទាំងអស់ដែរ ។ តែព្រះសាស្តាﷺបានយកជាយជួយពីដៃព្រះនាង ។ ព្រះនាងក៏បានសួរថាៈ "ព្រះសាសនៈទូតﷺ អល់ឡោះហ្វ៏﷿អើយ តើខ្ញុំម្ចាស់នៅក្នុងចំណោមព្រះអង្គعليهم السلامដែរទេ ?" ព្រះសាស្តាﷺបានតបថាៈ "អ្នកនៅក្នុងឋានៈរបស់អ្នក ហើយអ្នកនៅលើមាគ៌ាល្អ ។"

នៅក្នុងសៀវភៅ *អាល់-មុសណាដ* លោកអាស្ម៉ាដ្ [អ៊ីបនូ ហាន់បាល់] និង លោកអាល់-ត៉ាបារ៉នី បានថ្លែងហាឌីស្សមួយនេះតមកពីអាប៊ូ សាអ៊ីដ្ អាល់-ឃុីដ្ររីថាព្រះសាសនៈទូតﷺរបស់អល់ឡោះហ្ទ៌ﷻមានព្រះវចនៈ ថា៖

نَزَلَتْ هٰذِهِ الآيَةُ فِي خَمْسَةٍ: فِيَّ، وَفِي عَلِيٍّ، وَحَسَنٍ، وَحُسَيْنٍ، وَفَاطِمَةَ.

*"អាយ៉ាស្ម់នេះ (គឺអាយ៉ាស្ម់ជម្រះបន្ទុទ្ធ) សំដៅទៅលើបុគ្គលទាំងប្រាំរូប គឺ អ៊ាលីﷺ អាល់-ហាសាន់ﷺ អាល់-ហ៊ូសៃន៍ﷺ ហ្វាទីម៉ាស្ម់ﷺ និងរូបខ្ញុំﷺ ។"*

អ៊ីបនូ អាប៊ូ ស្ហៃបាស្ម់, អាស្ម៉ាដ្ម, អាល់-តៀរមីស៊ី, អាល់-ត៉ាបារ៉នី និង អាល់-ហាគីម (ដែលសម្រេចថាហាឌីស្សនេះជាហាឌីស្សពិតមិនក្លែង) បាន ថ្លែងតមកពីអាណាស់ថា៖ "កាលព្រះអង្គﷺចេញទៅស្វ៊ឡាត្ម់អាល់-ហ្វាច់រ៍ - មុនថ្ងៃរះ (នៅឯម៉ាស់យ៉ិដ) ព្រះសាស្តាﷺតែងតែដើរកាត់តាម ផ្ទះរបស់ហ្វាទីម៉ាស្ម់ﷺ ហើយមានព្រះវចនៈថា៖

الصَّلاَةَ أَهْلَ البَيْتِ. إِنَّمَا يُرِيدُ اللَّهُ لِيُذْهِبَ عَنْكُمُ الرِّجْسَ أَهْلَ الْبَيْتِ وَيُطَهِّرَكُمْ تَطْهِيرًا

"ចូរប្រញាប់ស្វ៊ឡាត្ម់ ឱព្រះរាជកុលដ្ឋានﷺអើយ (ពោលគឺ អាស្ម់លុល-បៃត៍) ។ *អល់ឡោះហ្ទ៌គ្រាន់តែប្រាថ្នាឲ្យពួកអ្នកចាកផុតពីមន្ទិល ហើយព្រះអង្គប្រាថ្នាសំអាតពួកអ្នក ឲ្យបរិសុទ្ធជ្រះស្អាតតែប៉ុណ្ណោះទេ (៣៣:៣៣) ។"*

ទោះជាយ៉ាងណាក៏ដោយ សេក្តីចរាយការណ៍មួយចំនួនពោលអះអាងថា វាជាការនិយាយទូទៅ ។ លោកមុស្លីមនិងលោកអាល់-ណាសាអ៊ីបានថ្លែង តមកពីស្ស៊ៃដ្ អ៊ីបនូ អារក្វំថាព្រះសាសនៈទូតﷺរបស់អល់ឡោះហ្ទ៌ﷻ ថ្លែងប្រាប់យើងថា៖

أُذَكِّرُكُمُ اللهَ فِي أَهْلِ بَيْتِي، أُذَكِّرُكُمُ اللهَ فِي أَهْلِ بَيْتِي، أُذَكِّرُكُمُ اللهَ فِي أَهْلِ بَيْتِي.

*"ចូរអស់លោកនឹកដល់អល់ឡោះហ្ទ៌ﷻពាក់ព័ន្ធនឹងអ្នកផ្ទះខ្ញុំﷺ ។ ចូរអស់លោកនឹកដល់អល់ឡោះហ្ទ៌ﷻពាក់ព័ន្ធនឹងអ្នកផ្ទះខ្ញុំﷺ ។ ចូរអស់លោក*

*នឹកដល់អល់ឡោះហ៍ عز وجل ពាក់ព័ន្ធនឹងអ្នកផ្ទះខ្ញុំ صلى الله عليه وآله وسلم ។"* គេបានសួរលោកថា៖ "អ្នកណាទៅអ្នកផ្ទះរបស់ព្រះសាស្តា صلى الله عليه وآله وسلم នោះ ?" ស៊ែដ្ឋ៍បានឆ្លើយថា៖ "ព្រះរាជកុលដ្ឋាន عليهم السلام របស់ព្រះអង្គ صلى الله عليه وآله وسلم គឺបណ្តាអ្នកដែលគេហាមទទួលយកអំណោយទានអត់ពីព្រះអង្គ صلى الله عليه وآله وسلم ទៅ ។" គេបានសួរលោកថា៖ "តើពួកគេជាអ្នកណា ?" ស៊ែដ្ឋ៍បានឆ្លើយថា៖ "ពួកគេគឺគ្រួសាររបស់អ៊ុលី صلوات الله عليه والسلام គ្រួសាររបស់អ៊ុគ៊ីល គ្រួសាររបស់យ៉ាក់ហ្វារ៍ និងគ្រួសាររបស់អ៊ុាប់បាស់ ។"

និយាយសង្ខេប គឺបុគ្គលដែលជាព្រះរាជបុត្ររាជនត្តាបរិសុទ្ធរបស់ព្រះសាស្តា صلى الله عليه وآله وسلم ធានាបាននូវកិត្តិយសលំដាប់ថ្នាក់ខ្ពស់ដាច់គេ ព្រោះតែបានទទួលនូវគុណសម្បត្តិខ្ពង់ខ្ពស់ តាមរយៈព្រះនាងហ្វាទ៏ម៉ាស់ سلام الله عليها ។ ព្រះអង្គទាំងនេះ عليهم السلام ទ្រង់ព្រះពស្រ្តកិត្តិយសនិងគារវៈ ព្រមទាំងទទួលបាននូវសេចក្តីគោរពសក្ការៈលើសគេ ។

# អារម្ភកថា

ព្រះនាងស្ហ៊ែណាប់سلام الله عليها ព្រះរាជបុត្រីរបស់អ៊ីម៉ាំអាលីصلوات الله عليه والسلام ព្រះរាជនត្តារបស់ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلم ជានារីដំបូងបង្អស់ក្នុងលោកអ៊ីស្លាមដែលបង្កើតប្រវត្តិសាស្ត្រ ដែលនាំប្រព្រឹត្តិដើម្បីសិទ្ធិនិងយុត្តិធម៌ ដែលកម្ទេចមហាគ្រោះវិរុទ្ធខ្មៅងងឹតនិងការគាបសង្កត់ ដែលបានចារគំរូថ្មីនៃកិត្តិយសនិងសេចក្ដីថ្លៃថ្នូរសម្រាប់អ៊ីស្លាមនិងមុស្លីម តាមរយៈព្រឹត្តិការណ៍ថ្លៃថ្នូររបស់ព្រះនាងពេញមួយប្រវត្តិសាស្ត្រ ។ ដូច្នេះ ព្រះនាងسلام الله عليهاជាមេដឹកនាំមួយរូបដែលប្រព្រឹត្តិតាមស្ទូឧត្ដមគតិ និងសេចក្ដីរុងរឿងនៃមនុស្សលោកដែលព្រះបិតាصلوات الله عليه والسلامព្រះនាងسلام الله عليها ព្រះរៀមصلوات الله عليه والسلامព្រះនាងسلام الله عليها ព្រះបច្ឆាជនរបស់ព្រះរៀមصلوات الله عليه والسلامព្រះនាងسلام الله عليهاនិងបណ្ដា អ្នកគាំទ្រព្រះអង្គទាំងពីរعليهم السلام នោះបាននាំមកឲ្យមនុស្សជាតិ ។

ព្រះនាងسلام الله عليهاបានចូលរួមយ៉ាងសកម្ម ក្នុងការកសាងដើម្បីធ្វើឲ្យឧត្ដមគតិមុស្លីមរស់ឡើងវិញជាថ្មី និងដើម្បីផ្សព្វផ្សាយសាសនានិងការយល់ដឹងនយោបាយ ។ ព្រះនាងسلام الله عليهاអនុវត្តិបានសម្រេចគោលដៅទាំងនេះក្នុងសម័យដែលអាជ្ញាធរកាន់ក្ដាប់ និងបណ្ដាអ្នកតាមពួកគេដែលពូកែបញ្ឆោរនោះប្រើមធ្យោបាយឃោសនា ដើម្បីក្រសោបមនោគតិបរិសុទ្ធរបស់ប្រជារាស្ត្រ ព្រមទាំងបានកាឡៃហេតុការណ៍ផ្ទៃក្នុងរបស់អ៊ីស្លាម ។

យ៉ាងជាក់ច្បាស់ ព្រះនាងស្ហ៊ែណាប់سلام الله عليهاបានធ្វើឲ្យការក្លែងបន្លំទាំងនេះបរាជ័យ ហើយបានធ្វើឲ្យការពិតរបស់ពួកដឹកនាំត្រកូលអ៊ូម៉ៃយ៉ាស្ហ៊ លេចច្បាស់ក្រឡែតឡើង គឺពួកសត្រូវពិតរបស់អ៊ីស្លាម ។ ព្រះនាងسلام الله عليهاបានបង្ហាញប្រាប់មហាជនផងដែរថា ពួកដឹកនាំត្រកូលអ៊ូម៉ៃយ៉ាស្ហ៊ប្រទ្បាក់ដោយអំពើឧក្រិដ្ឋនិងបទរំលោភសិទ្ធិមនុស្ស ហើយអាជ្ញាធររបស់ពួកគេមិនស្របច្បាប់ទេព្រោះពួកគេបានប្លន់យកសិទ្ធិអ្នកដទៃ បានលើកខ្លួនឯងជាអ្នកកាន់ក្ដាប់ពួកមុស្លីមដាច់មុខ ដោយមិនបានទទួលការយល់ស្របពី

ពួកគេទេ ឬដោយមិនបានពិភាក្សាជាមួយពួកគេទេ ។

តាមរយៈពាក្យពេជន៍និងស្ថានការណ៍អស្ចារ្យរបស់ព្រះនាងﷺ ព្រះនាងស្ហៃណាប់ﷺបានធ្វើឲ្យការពិត ដែលត្រូវលាក់បាំងពីភ្នែកមហាជននោះមានលក្ខណៈច្បាស់ឡើងយ៉ាងល្អិតល្អន់ ហើយបានបើកឲ្យឃើញទោសកម្ម និងអំពើក្បត់ផ្ទៃកនយោបាយរបស់ពួកអ្នកកាន់ក្ដាប់ត្រកូលអ៊ូម៉ៃយ៉ាស្ហ ។

ព្រះនាងស្ហៃណាប់ﷺ ព្រះរាជនត្តារបស់ព្រះសាស្ដាﷺ ប្រកបដោយលក្ខណៈបុគ្គលដែលប្រជុំគោលសីលធម៌ខ្ពង់ខ្ពស់ទាំងអស់ និងការស្រឡាញ់សេចក្ដីថ្លៃថ្នូរ ។ អាស្រ័យហេតុនេះ ព្រះនាងﷺជាគំរូកិត្តិយសប្រសើរបំផុត ប្រកបដោយព្រហ្មចរិភាព ប្រកបដោយសេចក្ដីថ្លៃថ្នូរ ព្រមទាំងប្រកបដោយគុណសម្បត្តិសុក្រឹតឥតខ្ចោះទាំងអស់នៃមនុស្ស ។ ព្រះនាងﷺបានទទួលកេរដំណែលចិត្តសប្បុរសខ្ពង់ខ្ពស់បំផុត ព្រមទាំងមានជំនឿជឿជាក់រឹងមាំចំពោះអល់ឡោះហ្ទ៍ﷻក្នុងបែបបទប្រសើរឥតខ្ចោះ តមកពីព្រះមាតាបិតានិងព្រះអយ្យកោﷺព្រះនាងﷺ ។

អ្នកប្រវត្តិសាស្ត្របានកត់ត្រាទុកនូវស្ថានការណ៍អស្ចារ្យ ដែលបង្ហាញឲ្យឃើញថាព្រះនាងﷺមានជំនឿឥតប្រៀបផ្ទឹមបាន ហើយតស៊ូនៅលើគោលសីលធម៌ ។ តួនាទីនាំមុខគេនៃស្ថានការណ៍ទាំងនេះត្រូវបានទៅលើព្រះនាងស្ហៃណាប់ﷺជាមោទនភាព ។ យប់បន្ទាប់ថ្ងៃអាស៊ួរ៉អ៍[18]ខ្លោចផ្សារនៅឯការបាឡាអ៍ ព្រះនាងស្ហៃណាប់ﷺបានស៊ូឡាតុំអរព្រះគុណអល់ឡោះហ្ទ៍ﷻ សម្រាប់សោកនាដកម្មដែលមិនត្រឹមតែបានធ្វើឲ្យអាស្ហលុល-បៃត៍ﷺតែមួយឈឺចាប់នោះទេ តែមនុស្សជាតិទូទៅទាំងអស់ផងដែរ ជាពិសេសបណ្ដាមុស្លីម ។

---

[18] ថ្ងៃអាស៊ួរ៉អ៍ គឺថ្ងៃទី ១០ ខែ មូហារ៉ម ជាថ្ងៃកាន់ទុក្ខ (ថ្ងៃរំលឹកវិញ្ញាណក្ខន្ធអ៊ីមុាំអាល់-ហ៊្សៃន៍ﷺដែលបានបូជាព្រះជន្ម) ។

ព្រឹត្តិការណ៍មួយទៀតនៃជំនឿអស្ចារ្យរបស់ព្រះនាងស្ទៃណាប់ﷺគឺ ថ្ងៃអាស៊ូរ៉អ៊ុ ព្រះនាងﷺទៅឈប់ក្បែរព្រះរាជសព្វរបស់ព្រះរៀមﷺព្រះនាងﷺ អ៊ីម៉ាំអាល់-ហ៊្សូសែន៍ﷺដែលបានធ្វើទុក្ករកម្ម (គឺបូជាជីវិតដើម្បីជំនឿ) ព្រះសិរ (គឺក្បាល) ព្រះអង្គﷺត្រូវកាត់ផ្ដាច់ពីព្រះកាយយ៉ាងឃោរឃៅបំផុត ដោយដាវរបស់បនយោធាឧក្រិដ្ឋរបស់ត្រកូលអ៊ូម៉ៃយ៉ាស់ ។ ព្រះនាងﷺបានថ្លែងពាក្យពេជន៍អមតៈថាៈ

اَللّٰهُمَّ تَقَبَّلْ هٰذَا الْقُرْبَانَ، وَأَثِبْهُ عَلَى عَمَلِهِ.

*"អល់ឡោះហ្ទ៍ﷻអើយ សូមព្រះអង្គﷻទទួលយកព្រះតង្វាយនេះ សូមព្រះអង្គﷻតបស្នងទង្វើរបស់ព្រះអង្គﷺនេះផង ។"*

តើមនុស្សដែលឃើញនូវការសម្ដែងឲ្យឃើញជំនឿដូចនេះទេ ?

សត្រូវអន្តរាយបំផុតរបស់អ៊ីស្លាម ក្នុងសម័យនោះបានទាត់អាស្ល់លុល-បៃត៍ﷺចេញពីឆាកនយោបាយអ៊ីស្លាម ចំណែកឯទាំងអស់គ្នា ជាពិសេសបណ្ដាអ្នកដែលបានចូលរួមដោយផ្ទាល់ក្នុងការរារាំង មិនឲ្យអាស្ល់លុល-បៃត៍ﷺទទួលបាននូវបុណ្យស័ក្តិពេញច្បាប់ ដែលពួកគេﷺត្រូវបានទេនោះ ដឹងច្បាស់ថាអល់ឡោះហ្ទ៍ﷻបានសម្រេចឲ្យជ្រើសយកវរបុគ្គលទាំងនេះ (គឺអាស្ល់លុល-បៃត៍ﷺ) ជាអ្នកដឹកនាំសហគមន៍អ៊ីស្លាម ។ អ្នកប្រវត្តិសាស្ត្របានកត់ត្រាជាឯកច្ឆន្ទថា បន្ទាប់ពីព្រះសាស្ដាﷺបានចូលទិវង្គត បុគ្គលមួយចំនួនបាននាំគ្នាបះបោរប្រឆាំងការសម្រេចរបស់ព្រះអង្គﷺរឿងស្នងតំណែងដឹកនាំសហគមន៍អ៊ីស្លាម ដោយតវ៉ាថាមិនអាចទទួលយកបានទេដែលពួក បានី ហ្ញាស៊ីម[19] បានទាំងសាស្ដាភាពទាំងការស្នងតំណែងដឹកនាំនោះ[20] ។

---

[19] បានី ហ្ញាស៊ីមគឺកូនៗនិងបច្ឆាជនកូនចៅរបស់ហ្ញាស៊ីម ព្រះអយ្យកោរបស់ព្រះសាស្ដាមូហ៊ាំម៉ាដ្ឋﷺ ។

[20] សូមមើលសៀវភៅរបស់លោក អាស្ស៊ុម៉ាដ្ឋ ហ៊្សូសែន៍ យ៉ាកុំគូប The Conception of the Sahaba's Ultimate Decency and the Political Leadership in Islam

ការប្រទូសរ៉ាយនេះបណ្ដាលឲ្យប្រគល់ការដឹកនាំ និងជោគវាសនាសហគមន៍អ៊ីស្លាមឲ្យទៅបុគ្គលមិនសក្តិសម ដែលជាដើមហេតុធំលើសពីធ្វើឲ្យមុស្លីមដុនដាបទៅទៀត ។

ដូច្នេះសហគមន៍អ៊ីស្លាម ជាទូទៅ បានបាត់បង់ប្រភពបរិសុទ្ធនៃចំណេះរបស់អាស្ហ៍លុល-បៃត៍عليهم السلام ដែលជាផ្នែកបន្ថែមនៃព្រះអភិញ្ញារបស់ព្រះសាស្ដាصلى الله عليه وآله وسلم ។ អ៊ីម៉ាំអ៊ាលីصلوات الله عليه والسلام ដោយហេតុនេះ បានរស់នៅក្នុងការបង្ខាំងឆ្ងាយពីជីវិតនយោបាយនិងជីវិតប្រតិបត្តិការនៃសហគមន៍អ៊ីស្លាម ក្នុងរបបកាន់កាប់របស់ស្ដេចខ៊ិលិហ្វទាំងបី ។ ពេលគេបានជ្រើសរើសព្រះអង្គصلوات الله عليه والسلامដោយសេរីជាលើកទីមួយជាមេដឹកនាំសហគមន៍អ៊ីស្លាម ពួកមូលធននិយម ពួកលោភលន់ ពួកវៀចវេរ ពួកអវិជ្ជាបានបះបោរប្រឆាំងរដ្ឋបាលត្រឹមត្រូវរបស់ព្រះអង្គصلوات الله عليه والسلام បណ្ដាលឲ្យព្រះអង្គصلوات الله عليه والسلامជាប់រវល់ក្នុងការប្រឆាំងច្រើនរឿង ។

ដោយសារការជាប់រវល់នេះ ពិភពអ៊ីស្លាមបានទទួលរងនូវការខាតបង់ធំពេលអ៊ីម៉ាំអ៊ាលីصلوات الله عليه والسلامមិនមានពេលច្រើនដើម្បីវាតយុត្តិធម៌ និងសមធម៌ប្រសើរបំផុតទៅលើរដ្ឋអ៊ីស្លាមទាំងមូល ។ ការពិត អ៊ីម៉ាំអាស្ហ៍លុល-បៃត៍عليهم السلامបរិសុទ្ធឥតខ្ចោះរងជោគវាសនាដូចអ៊ីម៉ាំអ៊ាលីصلوات الله عليه والسلام ព្រះអយ្យកោរបស់ព្រះអង្គដែរ ពេលអ្នកកាន់ក្ដាប់ត្រកូលអ៊ូម៉ៃយ៉ាស្ហ៍និងអ៊ាបាស៊ីយ៉ាស្ហ៍បានរាំងព្រះអង្គعليهم السلام មិនឲ្យវាតការផ្សព្វផ្សាយឧត្ដមគតិនិងចំណេះរបស់ព្រះអង្គعليهم السلامទៅលើប្រជារាស្ដ្រ បណ្ដាលឲ្យមនុស្សជាតិបាត់ផលប្រយោជន៍ដែលបានមកពីប្រភពប្រាជ្ញាញាណដ៏សម្បើមនេះ ។

ដោយសារនយោបាយរបស់ពួកស្ដេចខ៊ិលិហ្វគ៊ូរ៉យស្ហ៍[21] បានជាពួកសត្រូវអន្តរាយរបស់អ៊ីស្លាមអាចក្ដាប់អំណាចបាន ត្រួតត្រាលើពួកមុស្លីម ហើយ

---

បកប្រែដោយលោក Badr Shahin បោះពុម្ពដោយរោង ពុម្ព Ansariyan Publications – Qum, 1998

[21] គ៊ូរ៉យ៉ស្ហ៍គឺកុលសម្ព័ន្ធរបស់ព្រះសាស្ដាមូហាំម៉ាដ្ហ៍صلى الله عليه وآله وسلم ។

ផ្លាស់ប្តូររដ្ឋអ៊ីស្លាមទៅជាអាណាចក្រ ដែលកាន់កាប់ដោយប្រយោជន៍ផ្ទាល់ខ្លួននិងដោយសន្តវង្សសូពូជ ។

ដូច្នេះ ធ្វើអាក្រក់និងសង្កត់សង្កិនក្លាយទៅជាសញ្ញាសំគាល់លក្ខណៈពិសេសរបស់អាជ្ញាធរកាន់ក្តាប់ក្នុងសម័យនោះ ។ អ្នកណាមានសេរីភាពក្នុងការគិត អ្នកនោះត្រូវសម្លាប់ មនុស្សត្រូវបាត់បង់សិទ្ធិផ្ទាល់ខ្លួន សិទ្ធិនោះក្លាយទៅជាកម្មសិទ្ធិ ដែលនៅក្នុងកណ្តាប់ដៃបនចោរមួយចំនួនដែលស្មោះត្រង់ចំពោះអាជ្ញាធរកាន់ក្តាប់ អំពើពុករលួយរាលដាលនៅតាមបណ្តាខេត្តអ៊ីស្លាម ។

អំពើអាក្រក់ ការសង្កត់សង្កិននិងអំពើពុករលួយបានឈានដល់កម្រិតកំពូលសម័យយ៉ាស៊ីដ្ធ បុគ្គលកំណាច សោយរាជ្យ ។ អ្នកប្រវត្តិសាស្ត្រទាំងឡាយបានស្របមតិគ្នាជាឯកច្ឆន្ទថា៖ "យ៉ាស៊ីដជាបុគ្គលមិនត្រឹមត្រូវជាបុគ្គលអសីលធម៌ ជាបុគ្គលសាងបាបកម្ម មិនជឿអល់ឡោះហ៍ﷻនិងព្រះសាស្តាﷺរបស់អល់ឡោះហ៍ﷻទេ សូម្បីតែមួយភ្លែតក៏ដោយ ។" និយាយឲ្យខ្លី នយោបាយរបស់យ៉ាស៊ីដលោតផ្លោះក្នុងគ្រប់រឿងដែលល្មើសច្បាប់អ៊ីស្លាម ។

នៅក្នុងកាលៈទេសៈទាំងនេះ ពុំមានអ្នកណាអាចហើបមាត់និយាយការត្រឹមត្រូវបានឡើយក្រៅពីអ៊ីម៉ាំអាល់-ហ៊្វូសៃន៍ صلوات الله عليه والسلام ដែលបានដឹកនាំមហាបដិវត្តន៍ ដើម្បីបើកផ្លូវទៅរកការប្រឆាំងតទល់គ្រប់បុគ្គលអយុត្តិធម៌និងដើម្បីប្រកាសពាក្យពិតដោយចេញមុខនិងដោយសេចក្តីក្លាហាន ។

ដោយសារព្រឹត្តិការណ៍គួរឲ្យរន្ធត់របស់បដិវត្តន៍នេះ បដិវត្តន៍របស់អ៊ីម៉ាំអាល់-ហ៊្វូសៃន៍ صلوات الله عليه والسلام បានអង្រួនសតិសម្បជញ្ញៈពិភពលោក ហើយបាននាំមកនូវអំណោយប្រាជ្ញានិងមេរៀនគ្រចះគ្រចង់ ជូនដល់មនុស្សទាំងអស់ដែលរងគ្រោះដោយសារអាណានិគមនិយមនិងទាសៈភាព ។

ព្រះនាងស្ញៃណាប់سلام الله عليهاបានចូលរួមយ៉ាងសកម្មនិងដោយវិជ្ជមាន នៅក្នុងគ្រប់វគ្គ និងក្នុងគ្រប់អំពើអង់អាចរួមជាមួយបដិវត្តន៍របស់អ៊ីម៉ាំអាល់-ហ៊្វូសែន៍صلوات الله عليه والسلام ។ ក្នុងដំណាក់កាលដំបូងនៃបដិវត្តន៍ ព្រះនាងស្ញៃណាប់سلام الله عليها ឈរនៅជាមួយព្រះរៀមصلوات الله عليه والسلامព្រះនាងسلام الله عليهاយ៉ាងអង់អាចក្លាហាន ទោះបីព្រះនាងسلام الله عليهاដឹងច្បាស់ អំពីជោគវាសនាដែលព្រះរៀមصلوات الله عليه والسلامព្រះនាងسلام الله عليها ប្រឈមនោះក៏ដោយ ។ ឆន្ទះអំណត់ធ្មត់ និងការប្ដេជ្ញាចិត្តរបស់ព្រះនាងسلام الله عليهاក្នុងការគាំទ្រព្រះរៀមصلوات الله عليه والسلامព្រះនាងسلام الله عليها នៅក្នុងបដិវត្តន៍របស់ព្រះអង្គصلوات الله عليه والسلامជាសញ្ញាសំគាល់លក្ខណៈពិសេសរបស់បដិវត្តន៍នេះ ដែលបានផ្លាស់ប្ដូរដំណើរប្រវត្តិសាស្ត្រ ហើយបានផ្ដល់ឲ្យបណ្ដាអ្នកស្វែងរកសេរីភាពនូវកត្តារស់រានឡើងវិញនិងអភិវឌ្ឍន៍ ។

ព្រះនាងស្ញៃណាប់سلام الله عليها ទុកចិត្តលើបដិវត្តន៍ព្រះរៀមصلوات الله عليه والسلامព្រះនាងسلام الله عليها ។ ព្រះនាងسلام الله عليهاបានចូលរួមក្នុងការតស៊ូរបស់ព្រះអង្គصلوات الله عليه والسلامប្រឆាំងអំពើអាក្រក់និងអំពើសង្កត់សង្កិនយ៉ាងខ្លាំងក្លា ហើយបានសម្រេចគោលដៅមហាបដិវត្តន៍នេះ ។ អាស្រ័យពាក្យពេជន៍ព្រះនាងسلام الله عليهاប្រកបដោយរបៀបថ្មីនៅឯខ្លោងទ្វារនៃរាជធានីរបស់ពួកកាន់កាប់អំណាច ត្រកូលអ៊ូម៉ៃយ៉ាស្ញុំ ព្រះនាងسلام الله عليهاបានគាំទ្រគោលការណ៍ពិតប្រាកដ នៃដបិវត្តន៍របស់អ៊ីម៉ាំអាល់-ហ៊្វូសែន៍صلوات الله عليه والسلام ។ ព្រះនាងسلام الله عليهاអាចធ្វើឲ្យមតិមហាជនប្រាកដឡើងឲ្យភ្ញាក់ស្មារតីអំពីរឿងនេះ ហើយក្រោយមកបណ្ដាលឲ្យប្រជារាស្ត្រងើបឡើងបះបោរប្រឆាំងរបបអ៊ូម៉ៃយ៉ាស្ញុំជាបន្តបន្ទាប់ ។

ព្រះនាងបានបង្ហាញគំរូនៃអំណាចចិត្តឥតប្រៀបបាន គំរូនៃជំនឿចាក់ឫសស៊ប់ចិត្តនិងគំរូនៃភាពរឹងមាំមិនតក់ស្លុត តាមរយៈការប្រព្រឹត្តរបស់ព្រះនាងក្នុងកាលៈទេសៈរន្ធត់ដែលព្រះនាងបានជួបប្រទះ ។ ការពិត គំរូព្រះនាងស្ញៃណាប់عليهم السلام មិនអាចឃើញមាននៅក្នុងប្រវត្តិសាស្ត្រអ៊ីស្លាមទេ ហើយក៏មិនអាចឃើញមាននៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិទេដែរ ។

មហានារីរូបនេះ បានឃើញសមាជិកគ្រួសារព្រះនាងរងទុក្ខវេទនាដ៏សាហាវយង់ឃ្នង អាចទទួលស្ថានភាពទាំងនេះបានដោយការស៊ូទ្រាំ មិនតក់ស្លុត ព្រោះព្រះនាងចុះចូលខ្លួនទាំងស្រុងចំពោះអល់ឡោះហ្៍عز وجل ។

ព្រះនាងបានឃើញយុវបុរសក្នុងចំណោមព្រះរាជបុត្រព្រះនាង ព្រះភាតុបុត្តព្រះនាង (គឺក្មួយៗប្រុស) បងប្អូនជីដូនមួយព្រះនាងដែលប្រកបដោយបុគ្គលលក្ខណៈត្រចះត្រចង់ គួរឲ្យស្រឡាញ់ដូចដួងខែ ត្រូវកាប់សម្លាប់ សរីរៈត្រូវកាត់ផ្តាច់ពីខ្លួន ត្រូវគេជាន់ឈ្លីយ៉ាងសាហាវព្រៃផ្សៃនៅលើផ្ទៃដីការបាឡាអ៍ ។ ព្រះនាងបានឃើញកូនខ្ចីទើបនឹងបានឃើញពន្លឺថ្ងៃនិងទារកព្រះរាជកុលដ្ឋានព្រះនាងត្រូវសម្លាប់យ៉ាងសាហាវ ដោយដៃបនឧក្រិដ្ឋសាហាវយង់ឃ្នងអន្យតិរ្ថិយអមនុស្សធម៌ ។

ព្រះនាងបានឃើញព្រះរាជធីតា ព្រះរាជកុលដ្ឋានព្រះសាស្តាﷺហោរហាត់ខ្លាំងដោយសារស្រេកទឹក ខណៈដែលទ្រហោយំសោកស្តាយកូនៗនិងបងប្អូន តែព្រះនាងព្យាយាមជួយរំលែកទុក្ខនិងជួយណែនាំឲ្យស៊ូទ្រាំអត់ធ្មត់ ។

ព្រះនាងបានឃើញព្រះរៀមصلوات الله عليه والسلامព្រះនាង ព្រះអគ្គមហាប្រមុខនៃទុក្ករបុគ្គលត្រូវបនទុជិនចោមវាយប្រហារដោយដាវនិងលំពែង លុះត្រាតែកាត់ព្រះសិរព្រះអង្គصلوات الله عليه والسلامយ៉ាងអាក្រក់បំផុត ។

ព្រះនាងបានឃើញបនឈ្លានពានក្បត់សាសនាវាយប្រហារជំរំនារី ហើយបានដុតជំរំនោះ ព្រះរាជហារីម (គឺបណ្តាស្ត្រីដែលជាព្រះរាជវង្ស) ព្រះសាស្តាﷺរត់គេចខ្លួនទៅឯវាលរហោឋានព្រោះតែខ្លាច ។

ព្រះនាងស្រៃណាប់سلام الله عليهاបានជួបប្រទះគ្រោះអាក្រក់ទាំងនេះ ហើយបានតស៊ូទល់នឹងគ្រោះអាក្រក់ទាំងនេះដោយជំនឿ ដោយអំណត់និងដោយ

ការទុកកាយថ្វាយចិត្តលើអល់ឡោះហ៍ عزّ وجلّ ។

សោកនាដកម្មការបាឡាអ៍ ជាមួយព្រឹត្តិការណ៍រន្ធត់និងអប្រិយដែលបានកើតឡើងបន្ទាប់ពីនោះ ព្រមទាំងការចាប់ជាឈ្លើយ ការបំបាក់មុខ និងការធ្វើទណ្ឌកម្មបុរសនិងនារីអាស្ល់លុល-បៃត៍ عليهم السلام ជាគំរូនោះ ញ៉ាំងយើងឲ្យពិនិត្យយ៉ាងខ្លីៗនូវឯកសារនយោបាយ និងព្រឹត្តិការណ៍ដែលបានកើតឡើងពេលបន្ទាប់ពីព្រះសាស្តា صلى الله عليه وآله وسلم ចូលទិវង្គតភ្លាម ពីព្រោះវាជាប្រភពព័ត៌មានអត្តខាត់ (គឺមិនសូវសម្បូរ) ដែលប្រាប់យើងអំពីហេតុការណ៍អកុសលរបស់អាស្ល់លុល-បៃត៍ عليهم السلام ជាពិសេសនិងរបស់មុស្លីមជាទូទៅ ។

ពិតប្រាកដណាស់ កត្តាសំខាន់បំផុតដែលបណ្តាលឲ្យសន្តតិវង្សអ៊ូម៉ៃយ៉ាស្ល់កាន់ក្តាប់រដ្ឋអ៊ីស្លាមនោះគឺកូដោបាយសាគីហ្វាស្ល់[22] (السقيفة) និងការកែបំភ្លៃស៊ូរ៉ោះត៍[23] ។ ដោយសារតែប្រព័ន្ធគ្មានមូលដ្ឋានទាំងពីរនេះ

---

[22] សាគីហ្វាស្ល់ - រោងរបស់ បានូ សាអ៊ីដាស្ល់ - គឺទីកន្លែងមួយដែល អាប៊ូ បាការ, អ៊ុម៉ារ អ៊ីបនូ អាល់-ខុត្តត្តប់ និង អាប៊ូ អ៊ុបៃដាស្ល់ អ៊ីបនូ អាល់-យ៉ារ៉ោះត៍ បានជួបគ្នាស្ងាត់ៗ ដោយមានពួកអាន់ស្វារចូលរួមផង - ពួកអ្នកស្រុកយ៉ាស្រ៉ីបដែលបានទទួលនិងបានគាំទ្រព្រះសាស្តា صلى الله عليه وآله وسلم និងជនភៀសខ្លួនមកពីម៉ាក់កាស្ល់ ។ ជំនួបនេះបានប្រព្រឹត្តឡើងភ្លាមៗបន្ទាប់ពីព្រះសាស្តាមូហាំម៉ាដ្ល់ صلى الله عليه وآله وسلم បានចូលទិវង្គត ដើម្បីជ្រើសរើសអ្នកទទួលតំណែងដឹកនាំសហគមន៍អ៊ីស្លាម ទោះបីអ្នកចូលរួមទាំងអស់ដឹងច្បាស់ថាព្រះសាស្តា صلى الله عليه وآله وسلم ជាច្រើនលើកច្រើនគ្រា បានតែងតាំងអាលី អ៊ីបនូ អាប៊ី តាលិប صلوات الله عليه والسلام ជាអ្នកស្នងព្រះអង្គ صلى الله عليه وآله وسلم ហើយបានប្រកាសប្រាប់ថានេះជាការសម្រេចរបស់អល់ឡោះហ៍ عزّ وجلّ ក៏ដោយ ។

[23] ទោះបីលោកបានប្រកាសចំពោះមុខទាំងអស់គ្នាថា ព្រះសាស្តា صلى الله عليه وآله وسلم ពុំបានតែងតាំងអ្នកណាមួយជាអ្នកដឹកនាំសហគមន៍អ៊ីស្លាម ស្នងព្រះអង្គ صلى الله عليه وآله وسلم ទេនោះក៏ដោយក៏ អាប៊ូ បាការ ពេលលោកជិតស្លាប់ បានតែងតាំង អ៊ុម៉ារ អ៊ីបនូ អាល់-ខុត្តត្តប់ ជាអ្នកដឹកនាំស្នងលោកដែរ ។ បុគ្គលរូបនេះក៏បានបង្កើតក្រុមប្រឹក្សាក្លែងក្លាយដែរដើម្បីតែងតាំងអ្នកដឹកនាំស្នងខ្លួន ។ គេហៅប្រព័ន្ធនេះថា "ស៊ូរ៉ (شورَى)" ។ សូមមើលសៀវភៅប្រវត្តិសាស្ត្រអ៊ីស្លាមជាព័ត៌មានលំអិត ។

ដែលត្រូវនាំចូលមកជាការកែប្រែថ្មីនោះឯង បានជាពួកក្បត់សាសនា ត្រកូលអ៊ូម៉ៃយ៉ាស់នោះ ដែលធ្លាប់អាម៉ាស់មុខដោយសារអ៊ីស្លាមហើយ ត្រូវគេទុកជាទាសៈនោះ អាចវាយប្រហារអ៊ីស្លាមបានដោយអាវុធគ្រប់ធុន ដែលខ្លួនមានពេលមានសេរីភាពវិញ ។ ដូចនេះឯងបានពួកគេអាចឡើង កាន់អំណាចបាន អាចមានប្រៀបលើពួកមុស្លីមនិងលើជោគវាសនាពួក មុស្លីមបាន ។

អាជ្ញាធរកាន់អំណាចដែលបានប្លន់យកសិទ្ធិរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام នោះ ឲ្យ ប្រយោជន៍ពួកមេដឹកនាំត្រកូលអ៊ូម៉ៃយ៉ាស់ ។ អំពើនេះបានបើករបាំងមុខ នៃភាពរាបសា និងសេចក្ដីឱនលំទោនដែលអ៊ីស្លាមដាក់លើមុខពួកគេ ។ ពួកគេបានប្រគល់ឲ្យពួកត្រកូលអ៊ូម៉ៃយ៉ាស់នូវទ្រព្យសម្បត្តិហូរហៀរ បាន ធ្វើវិនិយោគទៅលើពួកគេ ដោយប្រគល់តំណែងដឹកនាំនៅក្នុងរដ្ឋអ៊ីស្លាម ឲ្យទៅពួកគេ ។ មូអាវីយ៉ាស់ អ៊ីបនូ អាប៊ូ ស៊ុហ្វយ៉ាន ជាអ្នកទទួលផល ប្រយោជន៍ធំជាងគេពីទម្រង់ការនេះ ។ គេបានតែងតាំងគាត់ជាអភិបាល ប្រទេសស៊ីរី គាត់បានទទួលការគាំទ្រនិងការជួយធ្វើអន្តរាគមន៍ពិសេស ។ អ៊ូម៉ារ អ៊ីបនូ អាល់-ខុត្តុត្តុប់ បានដំណឹងថាអភិបាលស្រុកស៊ីរី ពោលគឺ មូអាវីយ៉ាស់ បានប្រព្រឹត្តល្មើសព្រំដែនដោយរំលោភលើហិរញ្ញវត្ថុមុស្លីម ក្នុងការសាងវិមានផ្ទាល់ខ្លួន បានប្រព្រឹត្តអំពើបាបគ្រប់ប្រការដែលអ៊ីស្លាម ហាម ស្លៀកពាក់សូត្រ បានបរិភោគក្នុងចានមាសចានប្រាក់ អ៊ូម៉ារអត់ ឱនទោសឲ្យគាត់ដោយថា៖ "នេះគឺឃុសរ៉ូ (خسرو) - ស្ដេចរបស់ពួក អារ៉ាប់" ។

ទាំងអស់គ្នាដឹងស្រាប់ហើយថាអ៊ីស្លាមពុំមានរាជាធិបតេយ្យ ឬ អភិជនាធិបតេយ្យទេ ។ សម្រាប់អ៊ីស្លាម មនុស្សទាំងអស់គ្នាមានវណ្ណៈ ស្មើគ្នា ។ ក្រៅពីសទ្ធាជ្រះថ្លានិងសប្បុរសធម៌ ពុំមានអ្វីប្លែកគ្នាទេ ។ ជាការ ប្រមាថមើលងាយដែលបុគ្គលដូចមូអាវីយ៉ាស់ ដែលបានប្រឆាំងអ៊ីស្លាម ដោយចេញមុខ ហើយបានបង្ខំចិត្តព្រមទទួលសាសនាអ៊ីស្លាមដើម្បីរួច

ជីវិតពីការសម្លាប់នោះត្រូវគេចាត់ទុកជាស្តេចរបស់ពួកអារ៉ាប់ ។

ព្រះគម្ពីរគួរអានហៅ មូអុាវីយ៉ាស់និងគ្រួសារគាត់ថាដើមឈើត្រូវបណ្តាសា[24] ។ នៅក្នុងច្រើនអត្ថបទទាក់ទងនឹងព្រះសាស្តាﷺដែលគេបានចាត់ទុកជាអត្ថបទពិតមិនក្លែងក្លាយនោះ ត្រកូលអុមៃយ៉ាស់ត្រូវបណ្តាសា ។ យ៉ាងណាមិញ ពួកគេគ្រាន់តែជាទាសៈរបស់មុស្លីមទេ ទាល់តែព្រះសាស្តាﷺបានដោះលែងពួកគេ ហើយពួកគេត្រូវហៅថា "បុគ្គលដោះលែង" ។

និយាយសង្ខេប សោកនាដកម្មការបាឡាអ៊ុំនិងទុក្ខវេទនាដែលអាស់លុលបៃត៏ﷺបានទទួលរងនោះត្រូវបានពិនិត្យហើយ ។ ត្រូវបានបញ្ជាក់ឲ្យឃើញហើយថាព្រឹត្តិការណ៍ទាំងនេះ ជាពិសេសបណ្តាលមកពីកូដោបាយសាគីហ្វាស់និងការកែបំភ្លៃស៊ូរ៉ា ។ លើសពីនេះ ប្រព័ន្ធឥតមូលដ្ឋានទាំងពីរនេះជាមូលហេតុនៅពីក្រោយទុក្ខវេទនា ដែលមុស្លីមទាំងឡាយជួបប្រទះពេញមួយប្រវត្តិសាស្រ្ត ។

ការពិត អត្ថប្រយោជន៍សំខាន់បំផុតនិងដែលមានអំណោយផលធំបំផុតដែលគេអាចធ្វើជូនសហគមន៍អុីស្លាមបាននោះ គឺណែនាំ ផ្សព្វផ្សាយនិង

---

[24] សូមមើលសម្រាយគួរអានរបស់អាយ៉ាស់៖

وَإِذْ قُلْنَا لَكَ إِنَّ رَبَّكَ أَحَاطَ بِالنَّاسِ ۚ وَمَا جَعَلْنَا الرُّؤْيَا الَّتِي أَرَيْنَاكَ إِلَّا فِتْنَةً لِلنَّاسِ وَالشَّجَرَةَ الْمَلْعُونَةَ فِي الْقُرْآنِ ۚ وَنُخَوِّفُهُمْ فَمَا يَزِيدُهُمْ إِلَّا طُغْيَانًا كَبِيرًا

*កាលយើងមានតម្រាស់ចំពោះអ្នកថា៖ "ព្រះម្ចាស់អ្នកហ៊ុមព័ទ្ធ (គ្រប់គ្រង) មនុស្សទាំងពួង ។" ការមើលឃើញដែលយើងបានឲ្យអ្នកឃើញនោះគ្រាន់តែជាការល្បួងពិសោធមនុស្សទាំងឡាយប៉ុណ្ណោះ និង[ដូចគ្នានឹង]ដើមឈើត្រូវបណ្តាសា[នោះដែរដែលមានចែង]នៅក្នុងគួរអាន ។ យើងបានគំរាមពួកគេ (មនុស្សមិនទៀងត្រង់) តែការគំរាមនេះបានត្រឹមតែកាន់តែធ្វើឲ្យពួកគេប្រព្រឹត្តល្មើសបញ្ជាខ្លាំងឡើង (១៧:៦០) ។*

ចង្អុលទៅរកគុណសម្បត្តិពិតប្រាកដ និងឧត្តមគតិខ្ពង់ខ្ពស់រាប់មិនអស់របស់អាស្ហ៊លុល-បៃត៍ﷺ។ ពីព្រោះរឿងទាំងនេះជះឥទ្ធិពលទៅលើការខ្វះខ្វាយគំរូគុណសម្បត្តិនិងសីលធម៌ និងការរីកចម្រើនឧត្តមភាពផ្នែកចរិយា។ អាស្ហ៊លុល-បៃត៍ﷺអនុវត្តិដោយសម្តី ដោយទង្វើ ដោយចរិយា ដើម្បីពួកគេ (គឺអាស្ហ៊លុល-បៃត៍) ដូចកាំរស្មីដែលចែងចាំងចេញមកពីព្រះរស្មីរបស់អល់ឡោះហ្ទ៍ ពីព្រោះ ដូចសេចក្តីរាយការណ៍ពិតមិនក្លែងក្លាយដែលព្រះសាស្តាﷺបានអះអាងបញ្ជាក់ហើយនោះ ពួកគេﷺ (គឺអាស្ហ៊លុល-បៃត៍ﷺ) ជា "ពួកដែលមិននិយាយដោយចំណង់ឥតខ្លឹមសារនោះទេ"។ ពួកគេﷺជានាវាសង្គ្រោះសហគមន៍អ៊ីស្លាមនិងជាទំនាក់ទំនងទៅរកព្រះគម្ពីរអល់ឡោះហ្ទ៍។

ប្រវត្តិជីវិតអាស្ហ៊លុល-បៃត៍ﷺជាមេរៀនល្អ ជាជំនឿសុទ្ធ និងជាការតស៊ូប្រឆាំងអំពើអាក្រក់។ ព្រះអង្គ (គឺអាស្ហ៊លុល-បៃត៍ﷺ) បានឧទ្ទិសជីវិតឆ្ពោះទៅអល់ឡោះហ្ទ៍ បានប្រព្រឹត្តយ៉ាងសុក្រឹត យ៉ាងស្មោះអស់ពីចិត្ត ដើម្បី អល់ឡោះហ្ទ៍។ ដូច្នេះជីវប្រវត្តិរបស់ព្រះអង្គគ្រប់រូបﷺមិនមែនអ្វីក្រៅពីគំរូនៃការខ្លាចក្រែងអល់ឡោះហ្ទ៍ និងជាគំរូនៃការគោរពតាមព្រះម្ចាស់ហ្ទ៍នោះទេ។ ព្រះអង្គﷺបានចំណាយ ពេលថ្ងៃដើម្បីកាន់សីលត្រណម បានចំណាយពេលយប់ដើម្បីស្វ័រឡាត់និងសូត្រព្រះគម្ពីរអល់ឡោះហ្ទ៍។

បុរសនិងស្ត្រីអាស្ហ៊លុល-បៃត៍ﷺប្រព្រឹត្តដោយស្មោះអស់ពីចិត្ត ដើម្បីផ្សព្វផ្សាយអភិញ្ញា ប្រាជ្ញាញាណ និងគំរូសីលធម៌ខ្ពង់ខ្ពស់ ឲ្យទៅមនុស្សទាំងឡាយ។ ព្រះអង្គﷺប្រើប្រាស់ជីវិតដោយដាក់ទានឲ្យជនទាល់ក្រ ធ្វើល្អចំពោះជនគោកយ៉ាកលំបាកក្រៃក្រាស់ ប្រយុទ្ធយ៉ាងសកម្មទល់នឹងអំពើអាក្រក់ ព្យាយាមអស់ពីសមត្ថភាពដើម្បីប្រឆាំងអំពើអយុត្តិធម៌ និងបុគ្គលទុច្ចរិត ទោះបីបុគ្គលទាំងនោះមានឥទ្ធិពលខ្លាំង និងមានបុណ្យសក្តិធំប៉ុណ្ណាក៏ដោយ។

ព្រះអង្គعليهم السلامដោះស្រាយបញ្ហាសហាគមន៍អ៊ីស្លាម យ៉ាងអង់អាចក្លាហាន ដោយហេតុនេះ ព្រះអង្គعليهم السلامអាចនឹងត្រូវសម្លាប់ដោយដៃពួកកាន់ក្ដាប់ទុច្ចរិតដែលកាន់ខ្សែបង្ហៀរសហាគមន៍អ៊ីស្លាមមិនត្រឹមត្រូវ ។

ព្រះនាងសៃណាប់سلام الله عليها ព្រះរាជធីតារបស់អ៊ីម៉ាំអាលីصلوات الله عليه والسلام ជាវរបុគ្គលអាស់លុល-បៃត៍عليهم السلامមួយអង្គ ដែលបានធ្វើសកម្មភាពទាំងអស់ខាងលើរីឯគុណសម្បត្តិពិព័ណ៌នាខាងលើនេះក៏សមនឹងព្រះនាងដែរ ។ ព្រះនាងជាបុគ្គលមួយរូបដែលបានផ្សព្វផ្សាយព្រះបន្ទូលអល់ឡោះហ្ទ៍عز وجل នៅលើផែនដី បានតស៊ូដោយចេតនាប្រឆាំងជនសង្កត់សង្កិន ។ ព្រះនាងបានរងការឈឺចាប់និងទុក្ខវេទនាធ្ងន់បំផុតក្នុងរឿងនេះ ។ បន្ទាប់ពីព្រះរៀមព្រះនាង អ៊ីម៉ាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلام ត្រូវសម្លាប់ ព្រះនាងសៃណាប់سلام الله عليها ព្រមទាំងសមាជិកព្រះរាជកុលដ្ឋានឯទៀតរបស់ព្រះសាស្ដាصلى الله عليه وآله وسلم ត្រូវចាប់ជាឈ្លើយ ត្រូវនាំខ្លួនទៅបង្ហាញបុគ្គលអន្សតិរ្ថិយ អ៊ូបៃឌុលឡោះហ្ទ៍عز وجل អ៊ីបនូស៊ីយ៉ាដ្ទ ដែលកាន់តំណែងអភិបាលអាណាខេត្តអ៊ីស្លាមពីរ ។ ព្រះនាងសៃណាប់سلام الله عليهاបានសម្ដែងនូវសេចក្ដីក្លាហានអស្ចារ្យ ពេលប្រឈមមុខនឹងអ៊ូបៃឌុលឡោះហ្ទ៍عز وجل ធ្វើឲ្យបុគ្គលរូបនេះអត់ទ្រាំពុំបានក៏ស្ទុះទៅវាយព្រះនាង ។

គេបាននាំព្រះរាជកុលដ្ឋានព្រះសាស្ដាصلى الله عليه وآله وسلمទៅកាន់ប្រទេសស៊ីរី ទៅបង្ហាញយ៉ាស៊ីដ្ទ អ៊ីបនូ មូអាវីយ៉ាស្ទ ។ ដាក់មុខបុគ្គលឧក្រិដ្ឋរូបនេះឯង ដែលជាកូនចៅរបស់សត្រូវរបស់អ៊ីស្លាមប្រកបដោយវិនាសនោះ ដែលព្រះនាងសៃណាប់سلام الله عليهاបានថ្លែងពាក្យពេជន៍ល្បីរន្ទឺប្រវត្តិសាស្ត្រ ពាក្យពេជន៍ដែលត្រូវចាត់ទុកជាស្នាដៃសំខាន់បំផុតដែលកាត់ទោស និងប្រកាសអនីត្យានុកូល (គឺប្រកាសថាខុសច្បាប់) រដ្ឋរបស់ត្រកូលអ៊ូម៉ៃយ៉ាស្ទព្រមទាំងបណ្ដាអ្នកគាំទ្ររដ្ឋនេះដែរ ។

ដើម្បីអ៊ីស្លាម ព្រះរាជនត្ថាស្ត្រីរបស់ព្រះសាស្តាﷺអង្គនេះបានរងការឈឺចាប់និងទុក្ខវេទនាធ្ងន់បំផុត។ ស្ត្រីក្នុងលោកនេះត្រូវយកព្រះនាងជាគំរូ អាស្រ័យការតស៊ូដ៏ក្លាហាន ដ៏ថ្លៃថ្លារបស់ព្រះនាងប្រឆាំងអំពើអាក្រក់និងការគាបសង្កត់។ អាស្រ័យលើការយល់ដឹងយ៉ាងជ្រៅជ្រះអំពីព្រះនាងដែលជាអ្នកត្រួសត្រាយក្នុងការប្រយុទ្ធនឹងអំពើអាក្រក់នោះ ស្ត្រីទាំងអស់គប្បីស្គាល់មុខនាទីរបស់ខ្លួន ក្នុងការទទួលយកបញ្ហាយុត្តិធម៌ក្នុងលោកនេះ។

# ជីវិតព្រះនាងស្មៃណាប់سلام الله عليها

ឆ្លុះបញ្ចាំងទៅលើអនុស្សាវរីយល្អ និងការព្យាយាមស្វែងរកព័ត៌មានលំអិតបញ្ជាក់អំពីរឿងប្រភេទនេះជាកត្តាពីរដែលជះចរិយាល្អប្រពៃ ជះគុណធម៌ជះការដឹងសុជីវធម៌របស់បុគ្គលទាំងឡាយ ដែលប្រកបដោយគុណសម្បត្តិខ្ពង់ខ្ពស់ ជះសទ្ធាជ្រះថ្លា ជះចរិយាល្អប្រពៃនិងភាពសមរម្យមកលើវិញ្ញាណ ។ ដូច្នេះ មិនត្រូវកន្លងចោលសេចក្តីថ្លៃថ្នូរដែលជាលក្ខណៈសម្បត្តិកាន់ជាប់នៅក្នុងខ្លួនព្រះនាងស្មៃណាប់سلام الله عليهاនោះទេ ។ ព្រះនាងមាននូវគុណសម្បត្តិទាំងអស់ ដែលឆ្លុះបញ្ចាំងទៅរកព្រះរាជវង្សអរិរុទ្ធរបស់ព្រះនាងដែលត្រចះត្រចង់ថ្លៃថ្នូរនិងខ្ពង់ខ្ពស់ ។ ព្រះនាងប្រកបដោយគុណសម្បត្តិល្បីៗច្រើន ដូចជាការតស៊ូនៅលើគោលការណ៍ សេចក្តីក្លាហានវោហារកោសល្យ សេចក្តីប្តេជ្ញាចិត្តមិនស្ទាក់ស្ទើរ ក្រៅពីការកាន់វត្តប្រតិបត្តិតឹងរ៉ឹង សេចក្តីបរិសុទ្ធ សទ្ធាស៊ប់ចិត្ត សន្តភាព និងចិត្តសប្បុរសដ៏មហាខ្ពង់ខ្ពស់ ។ ចំពោះរឿងនេះ ជាការចាំបាច់សម្រាប់អ្នកស្វែងរកគុណសម្បត្តិនិងអ្នកស្វែងរកការពិត ដើម្បីស្រង់យកពីហេតុការណ៍នៃជីវិតដ៏មានតម្លៃរបស់ព្រះនាង និងផ្តាប់ត្រចៀកដោយស្តាប់កំណត់ប្រវត្តិគួរឲ្យស្ញើច ដើម្បីទទួលបាននូវគន្ធពិដោរនៃលក្ខណៈសម្បត្តិរបស់ព្រះនាងដែលជាគំរូក្នុងការហាត់ពត់ខ្លួនឯង នៃចំណេះចេះដឹងនិងសន្ទុះចិត្តទៅរកឧត្តមគតិ ។ យើងសូមណែនាំឲ្យស្គាល់ជីវប្រវត្តិសង្ខេបរបស់ព្រះនាងស្មៃណាប់سلام الله عليها ។

## ព្រះរាជវង្សព្រះនាងស្មៃណាប់سلام الله عليها

ព្រះនាងស្មៃណាប់سلام الله عليهاមានព្រះរាជវង្សរុងរឿងខ្ពង់ខ្ពស់បំផុត ព្រោះព្រះនាងជាព្រះរាជចៅនៃព្រះសាស្តានិងអ៊ីម៉ាំ ព្រមទាំងប្រកបដោយព្រះកិត្តិយសនិងបុណ្យសក្តិ ។ ព្រះរាជកុលដ្ឋានរបស់អ៊ីម៉ាំអាលីصلوات الله عليه والسلامខ្ពង់ខ្ពស់បំផុតក្នុងប្រវត្តិសាស្ត្រ ក្នុងវិស័យប្រយុទ្ធប្រឆាំងអំពើអាក្រក់និងក្នុងការ

សម្រួបសម្រួលបញ្ហាសិទ្ធិមនុស្សនានា ។ ព្រះរាជបុត្រនិងព្រះបច្ឆាជនរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام បានបូជារាប់រយទុក្ករបុគ្គលដើម្បីបញ្ហាទាំងនេះ ។

ព្រះអយ្យកោព្រះនាងស្រៃណាប់ ជូរខាងព្រះមាតាព្រះនាង គឺព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم បានធ្វើឲ្យប្រភពនៃការចេះដឹងនិងញាណប្រាជ្ញាផុសឡើងនៅលើផែនដី ព្រះអង្គ صلى الله عليه وآله وسلم បានចាក់គ្រឹះនៃលក្ខណៈអរិយធម៌និងអភិវឌ្ឍន៍ បានសាងសង្គមថ្លៃថ្នូរគ្រប់គ្រងដោយយុត្តិធម៌និងច្បាប់ បានរំលំទំនៀមទម្លាប់និងជំនឿឆ្វេងរបស់ពាហិរជន (គឺអ្នកមិនជឿសាសនា) និងសង្គមកុលសម្ព័ន្ធអរញ្ញវាសី (គឺសង្គមអ្នកព្រៃ) ដែលគ្របលើឧបទ្វីបអារ៉ាប់ ។ ព្រះអង្គ صلى الله عليه وآله وسلم បានប្រកាសឲ្យគោរពសក្ការៈព្រះអ្នកបង្កើតតែមួយ ហើយបាននាំមកឲ្យសហគមន៍ព្រះអង្គ صلى الله عليه وآله وسلم នូវសេចក្តីល្អដ៏ច្រើនលើសលុប ។ មែនអល់ឡោះហ្ទ៍ عز وجل បានចាត់បញ្ជូនព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم មកជាព្រះមេត្តាធម៌សម្រាប់មនុស្សជាតិ ។ ព្រះនាងស្រៃណាប់ سلام الله عليها បានទទួលជាមរតកមកពីព្រះឥស្សរបុគ្គលដ៏មហាឧត្តុង្គឧត្តមនេះ នូវន័យនៃការការពារសិទ្ធិនិងការតស៊ូដើម្បីលើកតម្កើងព្រះបន្ទូលអល់ឡោះហ្ទ៍ عز وجل ។

ព្រះអយ្យិកាព្រះនាង ជូរខាងព្រះមាតាព្រះនាង គឺខ៍ឌីយ៉ាស់ដែលបានគាំទ្រអ៊ីស្លាមក្នុងសម័យលំបាកបំផុត ។ ព្រះនាងបានតស៊ូដើម្បីអល់ឡោះហ្ទ៍ عز وجل ដោយវិធីប្រសើរបំផុត ហើយបានចំណាយទ្រព្យសម្បត្តិព្រះនាងទាំងស្រុងដើម្បីសាសនាព្រះនាង ។ ដូច្នេះព្រះនាងជាពំនាក់មួយក្នុងចំណោមពំនាក់ទាំងពីរដែលអ៊ីស្លាមពឹងផ្អែកដើម្បីឋិតនៅ ។ ព្រះសាស្តា صلى الله عليه وآله وسلم តែងតែឲ្យតម្លៃព្រះរាជមហេសីដ៏ស្មោះស្ម័គ្ររបស់ព្រះអង្គ صلى الله عليه وآله وسلم និងឲ្យតម្លៃទៅលើសភាពការណ៍ព្រះនាងក្នុងជីវិតព្រះនាង និងក្រោយពីព្រះនាងបានចូលទិវង្គត ។

ព្រះនាងស្រៃណាប់ سلام الله عليها បានទទួលជាមរតកមកពីព្រះអយ្យិកាអង្គនេះ នូវគំរូសីលធម៌ខ្ពង់ខ្ពស់បំផុតនិងការព្យាយាមនៅលើគោលកាណ៍ ។ យក

គំរូមតាមព្រះអយ្យិកាព្រះនាង ព្រះនាងគាំទ្រព្រះរៀមព្រះនាង អ៊ីម៉ាំអាល់-ហ៊្សៃន៍ صلوات الله عليه والسلام ក្នុងបដិវត្តន៍ព្រះអង្គ صلوات الله عليه والسلام ហើយបានជាជំនួយធ្វើឲ្យការងើបឡើងបះបោររបស់ព្រះអង្គ صلوات الله عليه والسلام នេះមានអមតៈភាព ។

ព្រះបិតាព្រះនាងហ្វាតិម៉ៈ (ស្រែណាប់)គឺអ៊ីម៉ាំ អាលី អាមីរុល-មុមីនីន صلوات الله عليه والسلام (ព្រះអគ្គមហាប្រមុខរបស់បណ្ដាអ្នកមានសទ្ធាជ្រះថ្លា) ព្រះរាជប្រមុខរបស់អស់ព្រះរាជឧត្តរាធិការី (គឺអ្នកស្នង) របស់ព្រះសាស្ដាទាំងឡាយ ព្រះមគ្គុទេសក៍របស់បណ្ដាអ្នកមានសទ្ធាស៊ប់ចិត្ត អ្នកនាំមុខបណ្ដាអ្នកគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ ។ អាលី صلوات الله عليه والسلام ជាតំណាង ជាអ្នកស្នង ជាព្រះទាយាទរបស់ព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم ។ ព្រះគុណសម្បត្តិព្រះអង្គរាប់មិនអស់ទេ ការតស៊ូរបស់ព្រះអង្គ ដើម្បីអល់ឡោះហ៍ عزوجل នោះគ្មានអ្វីប្រៀបបានទេ ។ ព្រះអង្គជាបុគ្គលចេះដឹងបំផុត ព្រះអង្គមានស្មារតីរឹងបំផុត (មិនតក់ស្លុត) ព្រះអង្គមានព្រះព្រហ្មវិហារធម៌បំផុត ព្រះអង្គមានព្រះហឫទ័យទូលំទូលាយបំផុត ព្រះអង្គមានវត្តប្រតិបត្តិតឹងរឹងបំផុត ព្រះអង្គក្លាហានបំផុត ព្រះអង្គមានព្រះកិត្តិនាមបំផុត ព្រះអង្គជាអ្នកធ្វើសក្ការៈបូជាប្រសើរបំផុត ព្រះអង្គស្មោះត្រង់បំផុត ព្រះអង្គសច្ចៈបំផុត ព្រះអង្គមានសទ្ធាស៊ប់ចិត្តបំផុតក្នុងចំណោមមុស្លីមទាំងអស់ ។

អ្នកប្រវត្តិសាស្ត្របានកត់ត្រាជាឯកច្ឆន្ទថា ព្រះនាងហ្វាតិម៉ៈ (ស្រែណាប់) سلام الله عليها អនុចរតាមព្រះគន្លងព្រះបិតាព្រះនាងក្នុងវិស័យចរិយា ក្នុងវិស័យចំណេះចេះដឹង និងក្នុងវិស័យគំនិតមារយាទ ។ ព្រះនាងក៏បានទទួលយកដោយរីករាយដៃរនូវគោលដៅនិងការខិតខំព្យាយាមដើម្បីជួយទ្រទ្រង់អ៊ីស្លាម ។ ដូច្នេះហើយបានជាព្រះនាង ទន្ទឹមនឹងព្រះរៀមព្រះនាង អ៊ីម៉ាំអាល់-ហ៊្សៃន៍ صلوات الله عليه والسلام បានធ្វើឲ្យឧបាយកលក្បត់សាសនារបស់ពួកត្រកូលអ៊ូម៉ៃយ៉ាស់ខកខាន គឺឧបាយកលដែលប៉ងលុបបំបាត់អ៊ីស្លាម ហើយយកទំនៀមទម្លាប់បុរាណមុនអ៊ីស្លាមមកប្ដូរផ្លាស់វិញ ។

ព្រះមាតាព្រះនាងស្មេរណាប់سلام الله عليهاគឺព្រះនាង ហ្វាទិម៉ាស្ហ់ អាស្ស់-ស្សាស្ហ៍រ៉អ៊ុ (فاطمة الزهراء)سلام الله عليها សច្ចការិនីដែលដូចព្រះបិតាព្រះនាងបេះបិទក្នុងការគោរពសក្ការៈអល់ឡោះហ្វ៍عز وجل ក្នុងការមានសទ្ធាស៊ប់ចិត្ត ក្នុងការទប់ខ្លួន ក្នុងការចេះដឹង ក្នុងការស៊ប់នៅក្នុងគុណធម៌ ក្នុងការស៊ប់នៅក្នុងសេចក្ដីប្រោសប្រណី ក្នុងការស៊ប់នៅក្នុងសេចក្ដីគោរពយ៉ាងជ្រាលជ្រៅ និងប្រកបដោយលក្ខណៈសម្បត្តិសុក្រឹតច្រើនទៀត ។ ព្រះបិតាصلى الله عليه وآله وسلمព្រះនាងបានដាក់ព្រះនាមឲ្យព្រះនាងថា ព្រះនាយិកានៃបណ្ដាស្ត្រីក្នុងលោក ។ អាស្រ័យហេតុនេះ ព្រះបិតាصلى الله عليه وآله وسلمព្រះនាងសម្ដែងថោមនាការនិងគារវតាដល់ព្រះរាជបុត្រីព្រះអង្គصلى الله عليه وآله وسلمដែលជាឧត្ដមស្ត្រីក្នុងលោកនេះ[25] ។ នេះគឺ

---

[25] ហ្វាទិម៉ាស្ហ់ អាស្ស់-ស្សាស្ហ៍រ៉អ៊ុ (فاطمة الزهراء) سلام الله عليها សច្ចការិនីដែលត្រូវកោតសរសើរមិនត្រឹមតែដោយព្រះសាស្ដាមូហាំម៉ាដ្ហ៍صلى الله عليه وآله وسلمទេ តែត្រូវបណ្ដាអ្នករស់នៅទាំងអស់គ្នាក្នុងសម័យព្រះនាងកោតសរសើរដែរ ។ លោក អ៊ីបនូ ហាយ៉ាុរ អាល់-អ៊ាស់ក្ហ៊ុឡានី (بن حجر العسقلاني) បានកត់ត្រានៅក្នុងសៀវភៅលោក *អាល់-អ៊ីស្វ៉ាបាស្ហ់ (الإصابة)* ថាអ៊ុស្ហាស្ហ់ ព្រះមហេសីរបស់ព្រះសាស្ដាصلى الله عليه وآله وسلمបានថា៖ "ពុំមានបុគ្គលជាទីស្រឡាញ់ជាងហ្វាទិម៉ាស្ហ់سلام الله عليهاទេ ក្រៅពីព្រះសាស្ដាصلى الله عليه وآله وسلم ។" នៅក្នុងសៀវភៅយោងខាងលើនេះ លោក អ៊ុប់ឌុលឡោះហ្វ៍ អ៊ីបនូ អ៊ុប់បាស់ មានប្រសាសន៍ថា៖ "ស្ត្រីឋានសួគ៌ប្រសើរបំផុតមានបួនគឺ៖ ខ៊ុឌីយ៉ាុស្ហ់, ហ្វាទិម៉ាស្ហ់, ម៉ារីយ៉ាំ និង អាស៊ីយ៉ាស្ហ់ ព្រះមហេសីរបស់ហ្វៀរអ៊ោន៍ ។" លោក អាល់-ប៊ូខ៊ុរី មានប្រសាសន៍នៅក្នុងអាល់-ស្វ៉ហ៊ិះហ្វ៍របស់លោកថាលោក អាល់-មូសៅវៀរ អ៊ីបនូ ម៉ាខ៊ុរ៉ម៉ាស្ហ់ បានស្រង់ឡើងនូវព្រះវចនៈព្រះសាស្ដាصلى الله عليه وآله وسلمថា៖ "ហ្វាទិម៉ាស្ហ់عليهم السلامជាប៉ែកមួយនៃខ្លួនខ្ញុំصلى الله عليه وآله وسلم ។ អ្វីក៏ដោយដែលធ្វើឲ្យព្រះនាងឈឺចាប់ វាធ្វើឲ្យខ្ញុំصلى الله عليه وآله وسلمឈឺចាប់ដែរ ។ អ្វីក៏ដោយដែលឲ្យព្រះនាងរីករាយ វាធ្វើឲ្យខ្ញុំصلى الله عليه وآله وسلمរីករាយដែរ ។" អ៊ុលី صلوات الله عليه والسلامមានវចនៈថាព្រះសាស្ដាصلى الله عليه وآله وسلمបានប្រាប់ហ្វាទិម៉ាស្ហ់سلام الله عليهاថា៖ "ហ្វាទិម៉ាស្ហ់سلام الله عليها អើយ អល់ឡោះហ្វ៍عز وجلមាន សេចក្ដីសោមនស្សពេលបុត្រីមានសេចក្ដីសោមនស្ស ។ អល់ឡោះហ្វ៍عز وجلទ្រង់ព្រះពិរោធពេលបុត្រីក្រោធ ។" ទីបញ្ចប់សៀវភៅប្រវត្តិសាស្ត្រអ៊ីស្លាមយោងទាំងឡាយនិងសេចក្ដីថ្លែងការណ៍ ពោរពេញដោយសេក្ដីរាយការណ៍ស្ដីអំពីកេរ្ដិ៍ឈ្មោះខ្ពង់ខ្ពស់របស់សច្ចៈការិនី ព្រះនាងហ្វាទិម៉ាស្ហ់ អាស្ស់-ស្សាស្ហ៍រ៉អ៊ុسلام الله عليها ។

ព្រះរាជមាតា ព្រះរាជគ្រូ ព្រះសិក្ខាបនធារី (គឺអ្នកអប់រំ) របស់ព្រះនាង ស៊ែណាប់سلام الله عليهاដែលត្រូវបំប៉នដោយលក្ខណៈសុក្រឹតទាំងអស់នៃមនុស្ស ។

យើងសូមបំបែរអារម្មណ៍ទៅរកព្រះអយ្យកោ និងព្រះអយ្យិការបស់ព្រះនាងស៊ែណាប់سلام الله عليهاជួរខាងព្រះបិតា ។

អាប៊ូ ត៉ូលិប ព្រះបិតារបស់អ៊ីមុាំអាលីصلوات الله عليه والسلام ជាអ្នកការពារអ៊ីស្លាមព្រោះលោកបានការពារព្រះសាស្ដាមូហាំម៉ាដ់ﷺយ៉ាងក្លាហាន បានរងទុក្ខវេទនាដែលពិបាកស៊ូទ្រាំបានក្នុងចលនានេះ ។ នៅក្នុងអាណាព្យាបាលភាពរបស់ អាប៊ូ ត៉ូលិបប៉ុណ្ណោះដែលព្រះសាស្ដាមូហាំម៉ាដ់ﷺអាចផ្សព្វផ្សាយព្រះបេសកកម្មព្រះអង្គﷺបាន អាចវាតគោលការណ៍បេសសកម្មនេះឲ្យដាលពាសពេញបានដោយឥតខ្លាច ។ ពេលអាណាព្យាបាលរបស់ព្រះអង្គﷺបានសោយទិវង្គត ព្រះសាស្ដាﷺបានថ្លែងការបាត់បង់និងការសោកសៅដ៏ធំ ។ ដូច្នេះព្រះអង្គﷺបានហៅឆ្នាំនោះថា "ឆ្នាំសោកសៅ" ។ បន្ទាប់ពីអាប៊ូ ត៉ូលិបចូលទិវង្គត សត្រូវរបស់ព្រះសាស្ដាﷺបានមូលគំនិតគ្នាធ្វើគុតព្រះអង្គﷺ តែអល់ឡោះហ្ទ៍عز وجلបានសង្គ្រោះព្រះអង្គﷺ បានដាក់បញ្ជាឲ្យព្រះអង្គﷺគេចខ្លួនទៅឯស្រុកយ៉ាស្រ៊ីប ឲ្យអាលីصلوات الله عليه والسلام ប្អូនជីដូនមួយព្រះអង្គﷺផ្ទំក្នុងគ្រែព្រះអង្គﷺ ដើម្បីនឹងធ្វើឲ្យបនក្បត់គិតថាព្រះអង្គﷺនៅទីនោះដដែល ។

ព្រះនាងស៊ែណាប់سلام الله عليهاបានស្រង់យក នូវមេរៀនល្អប្រសើរបំផុតពីឧត្ដមបុគ្គលរូបនេះដើម្បីធ្វើការការពារគោលការណ៍ ។

ព្រះអយ្យិការបស់ព្រះនាងស៊ែណាប់سلام الله عليها ហ្វាទ៉ីម៉ាស់ ប៊ិនទី អាសាដ់ ជាគំរូនៃជំនឿជ្រះថ្លានិងសេចក្ដីបរិសុទ្ធ ។ ព្រះនាងបានចិញ្ចឹមព្រះសាស្ដាﷺ បានបីបាច់រក្សាព្រះអង្គﷺ បានថ្នាក់ថ្នមព្រះអង្គﷺជាងកូនបង្កើតទៅទៀត ព្រះនាងបានអាណិតមេត្តា បានផ្ដល់សេចក្ដីស្រឡាញ់ដល់ព្រះអង្គ

ﷺ ។ ដូច្នេះ ព្រះអង្គﷺគោរពព្រះនាងជាទីបំផុត ។ ពេលព្រះនាងចាកលោកនេះ ព្រះអង្គﷺបានពាក់អាវព្រះអង្គﷺឲ្យព្រះនាង បានដាក់ព្រះនាងទៅក្នុងផ្នូរដោយដៃព្រះអង្គﷺផ្ទាល់ ជាការសម្តែងនូវសេចក្តីស្រឡាញ់ដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គﷺចំពោះព្រះនាង ។ ព្រះនាងស្សៃណាប់سلام الله عليهاទទួលបានមេរៀននៃសេចក្តីស្រឡាញ់ដ៏ល្អ និងការជ្រោមជ្រែងសាសនានិងបណ្តាអ្នកដឹកនាំស្របច្បាប់របស់សាសនានេះ ពីព្រះអយ្យិកាអង្គនេះ ។

យើងមិនអាចចោលហេតុការណ៍ដែលមានអ៊ីម៉ាំអាល់-ហ៊ាសាន់صلوات الله عليه والسلام និងអ៊ីម៉ាំអាល់-ហ៊្វូសែន៍បានចូលរួម ក្នុងការបណ្តុះបណ្តាលលក្ខណៈបុគ្គលរបស់ព្រះនាងស្សៃណាប់سلام الله عليها ព្រះអនុជារបស់ព្រះអង្គទាំងពីរនោះបានទេ ព្រោះព្រះនាងបានរស់នៅ ក្រោមអាណាព្យាបាលភាពរបស់ព្រះអង្គទាំងពីរមួយប៉ែកធំនៃជីវិតព្រះនាង ។ បុណ្យបារមីនិងគុណសម្បត្តិរបស់អ៊ីម៉ាំទាំងពីរច្រើនលើសលុបមិនអាចរៀបរាប់អស់ត្រង់នេះបានទេ ។ ដូច្នេះ ព្រះសាស្តាﷺបានហៅព្រះអង្គទាំងពីរថា "ព្រះអគ្គប្រមុខរបស់យុវជនឋានសួគ៌"[26] ។

ព្រះនាងស្សៃណាប់سلام الله عليهاអនុចរតាមគន្លងសីលធម៌ និងចរិយាមារយាទរបស់អ៊ីម៉ាំអាល់-ហ៊ាសាន់صلوات الله عليه والسلام ដែលល្បីល្បាញព្រោះព្រះអង្គصلوات الله عليه والسلامជាបុគ្គលស្ងប់ ព្រោះព្រះអង្គصلوات الله عليه والسلامដោះស្រាយបញ្ហាដោយវិធីពិនិត្យពិច័យមើលឃើញវែងឆ្ងាយ ថែមទាំងមានគំរូសីលធម៌ខ្ពស់ទៀតផង ។ ព្រោះតែព្រះអង្គបានឃើញព្រះអយ្យកោ និងព្រះមាតាបិតាព្រះអង្គបានថែរក្សាព្រះនាងស្សៃណាប់سلام الله عليهاយ៉ាងហ្មត់ចត់ បានជាអ៊ីម៉ាំអាល់-ហ៊ាសាន់صلوات الله عليه والسلامអាណិតស្រឡាញ់ព្រះនាង មានសន្តោសប្រណីដល់ព្រះនាង ជាងព្រះហ៊ារីម (គឺសមាជិកស្ត្រីនៃព្រះរាជកុលដ្ឋានព្រះសាស្តាﷺ) ឯទៀត ។

---

[26] សូមមើលសៀវភៅ *យ៉ាណាប៊ីអ៊ុ អាល់-មូវ៉ាដ់ដាស្ញ* ទំព័រ ១៩៦ ។

ទំនាក់ទំនងរវាងអ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلامនិងព្រះអនុជាព្រះអង្គ ជាទំនង ភ្លេងដ៏ពីរោះសម្រាប់បណ្តាអ្នកស្វែងរកសុក្រឹតភាពនៃមនុស្ស ។ ព្រះនាង អាចគ្រប់គ្រងអារម្មណ៍ព្រះអង្គបាន (គឺអាចកាន់ចិត្តគំនិតដូចព្រះរៀមព្រះ នាងបាន) អាចធ្វើឲ្យរំភើបចិត្តបានមកពីសេចក្តីស្មោះត្រង់នៃសេចក្តី គោរពរបស់ព្រះនាង មកពីការលើកតម្កើងនៃចរិយាមារយាទរបស់ព្រះ នាងនិងគំរូសីលធម៌ខ្ពង់ខ្ពស់ ។ ព្រះនាងជាបុគ្គលដែលទុកចិត្តបានបំផុត សម្រាប់អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلامដែលតែងតែសូមយោបល់ពីព្រះនាង ក្នុង គ្រប់កិច្ចការរបស់ព្រះអង្គ ។ ព្រះនាងបានអមតាមព្រះអង្គនៅក្នុងគ្រប់ តំណាក់កាលបដិវត្តន៍របស់ព្រះអង្គ ។

បើមិនមានការតស៊ូ ការព្យាយាមនិងស្ថានការណ៍ថ្លៃថ្នូររបស់ព្រះនាង ស៊្រែណាប់سلام الله عليهاទេ បដិវត្តន៍របស់អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلامអាចបរាជ័យ បាន ។ ឧទាហរណ៍កេរ្តិ៍ឈ្មោះខ្ពង់ខ្ពស់របស់ព្រះនាងស៊្រែណាប់سلام الله عليها សម្រាប់អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلامគឺ ពេលព្រះអង្គបានសូមលាព្រះនាងក្នុង ថ្ងៃអាស៊្ហ៊ូរ៉អ៍ ព្រះអង្គសូមឲ្យព្រះនាងថ្លែងអំពីព្រះអង្គ (គឺសូមឲ្យបួងសួង អល់ឡោះហ៍عز وجلឲ្យព្រះអង្គផង) ក្នុងស៊្វឡាត់ពេលយប់របស់ព្រះនាង ។

នៅក្នុងជំពូកទីពីរនៃសៀវភៅនេះ យើងនឹងផ្តោតទៅលើប៉ែកនៃទំនាក់ ទំនងមិនអាចប្រៀបផ្ទឹមបានរវាងអ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلام និងព្រះអនុជា របស់ព្រះអង្គ ព្រះនាងស៊្រែណាប់سلام الله عليها ។

## ព្រះទារកប្រកបដោយសិរីសួស្តី

ជីវិតរបស់ព្រះរាជកុលដ្ឋានរបស់ព្រះសាស្តាصلى الله عليه وآله وسلم រីកចម្រើនដោយព្រះ អត្ថិភាពនៃអ៊ីម៉ាំទាំងពីរអង្គ គឺអ៊ីម៉ាំអាល់-ហ្ាសាន់صلوات الله عليه والسلامនិងអ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلام ដែលជិតជាប់ពេញក្នុងបេះដូងព្រះអយ្យកោរបស់ព្រះអង្គ ទាំងពីរ ។ ព្រះមាតាបិតារបស់ព្រះអង្គទាំងពីរក៏សព្វព្រះហឫទ័យជាទី បំផុតដែរពេលបានឃើញបុត្រទាំងពីរ និងពេលបានឃើញសាស្តាصلى الله عليه وآله وسلم

ទ្រង់សព្វព្រះហឫទ័យព្រះអង្គទាំងពីរ ។ គ្រាមួយព្រះអង្គﷺបានថ្លែងសេចក្ដីស្រឡាញ់ចំពោះព្រះរាជបុត្រទាំងពីរថា៖

هَذانِ رَيْحَانَتَايَ مِنَ الدُّنْيَا.

*"អ្នកទាំងពីររូបនេះជាជីរ (រុក្ខជាតិ) តែមួយមុខដែលខ្ញុំទទួលទាននៅក្នុងលោកនេះ[27] ។"*

នៅក្នុងបរិយាកាសដ៏សែនមនោរមនេះព្រះនាងហ្វាទីម៉ាស្ហ៎អាស្ស-ស្ហាស្ហ៎រ៉អ៊ ﷺ ទ្រង់ព្រះគភ៌ជាគ្រាទីបី ។ ទាំងអស់គ្នា ព្រមទាំងព្រះសាសនៈទូតﷺ របស់អល់ឡោះហ្ហ៍ﷻដែរ រង់ចាំព្រះរាជទារក[28] ។

ដោយសេចក្ដីមនោរមនិងនិងសេចក្ដីសោមនស្ស ព្រះនាងហ្វាទីម៉ាស្ហ៎ سلام الله عليها បានប្រសូតព្រះរាជបុត្រីដែលប្រសើរដាច់អស់នារី ក្នុងវិស័យជំនឿ កិត្តិយស ព្រហ្មចារីភាព និងក្នុងវិស័យរក្សាគោលការណ៍ ។ អាស្ហ៍លុល-

---

[27] សូមមើលសៀវភៅ *កាន់ស៊្ហ អាល់-អ៊ុម៉ាល់* (كنز العمال), 7/110; *ស្វ៊ហ្ហិះហ្ហ៍* របស់លោក អាល់-ប៊ូខ៊ុរី ជំពូក *គីតាប់ អាល់-អាដាប់; ម៉ាជ់ម៉ាក់ អាល់-ស្ហាវ៉ាអ៊ីដ្ហ (مجمع الزوائد),* 9/181; និងសៀវភៅ *អាត់-តារិក្ហ* របស់លោក អ៊ីបនូ អាស្ហាកៀរ,13/30 ។

[28] អ្នកប្រវត្តិសាស្ត្រខ្លះបានថាព្រះរាជបុត្រីទីមួយរបស់ព្រះនាងហ្វាទីម៉ាស្ហ៎ អាស្ស-ស្ហាស្ហ៎រ៉អ៊ سلام الله عليها គឺរុក្កយ៉យ៉ាស្ហ៎ មានព្រះនាមក្រៅថា អ៊ូម គុលស៊្ហុម តែអ្នកប្រវត្តិសាស្ត្រភាគច្រើនបានបញ្ជាក់ដោយមានភ័ត្តុតាងថា ព្រះនាងស្ហៃណាប់ سلام الله عليها ជាព្រះរាជទារកស្ត្រីទីមួយរបស់ព្រះនាងហ្វាទីម៉ាស្ហ៎ سلام الله عليها ។ ភ័ស្តុតាងគឺ គេបានតំណាលថានៅក្នុងរជ្ជកាលរបស់បុគ្គលត្រកូលអ៊ូម៉ៃយ៉ាស្ហ៎ កាលអាស្ហ៍លុល-បៃត៍ عليهم السلام និងបណ្ដាអ្នកគាំទ្រត្រូវសង្កត់សង្កិន អ្នកណាមួយដែលចង់និយាយរឿងអ្វីមួយពីអ៊ីម៉ាំអ្ហលី صلوات الله عليه والسلام អ្នកនោះថា៖ "បិតារបស់ស្ហៃណាប់ سلام الله عليها បានថាដូច្នេះមួយ ដូច្នេះពីរ..." ។ គេនិយាយដូច្នេះពីព្រោះព្រះនាងស្ហៃណាប់ سلام الله عليها ជាព្រះរាជបុត្រីបងគេ ហើយពួកសត្រូវមិនស្គាល់ព្រះនាមក្រៅមួយនេះទេ ។ សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ូ អាល់-ហ្ហាឌីដ្ហ (ابن أبي الحديد) និងសៀវភៅ *ស្ហារណាស្ហ៍យ៉ាល់-បាឡាក្ហោះត៍ (شرح نهج البلاغة)* ។

បៃត៍عليهم السلام និងបណ្តាសាវករបស់ព្រះសាស្តាﷺបានទទួលដំណឹងប្រសូតព្រះនាងស្មៃណាប់سلام الله عليهាដោយសេចក្តីរីករាយ ។

អ៊ីម៉ាំអាលីصلوات الله عليه والسلامប្រញាប់ទៅលើកព្រះរាជទារកព្រះអង្គ មកថើបច្រើនលើក ហើយធ្វើពិធីបុណ្យទារកទើបនឹងកើតថ្មីៗតាមច្បាប់ស្ហារីអាស់ ។ អ៊ីម៉ាំصلوات الله عليه والسلامបានសូត្រ អាស្ទាន (أَذَان)[29] ដាក់ត្រចៀកស្តាំព្រះរាជទារក សូត្រ អ៊ីក៏ម៉ាស់ (إقامة)[30] ដាក់ត្រចៀកឆ្វេងព្រះរាជទារក ។ ដូច្នេះ សម្លេងដំបូងបង្អស់ដែលបានចូលត្រសេចៀកព្រះរាជទារក គឺសម្លេងព្រះបិតារបស់ព្រះនាង ថា៖

អល់ឡ៏ហ៊្វ អាក់បារ (اللّٰهُ أَكْبَر) - អល់ឡោះហ៊្វ៏عز وجلទ្រង់មហាធំថ្កើង ។ ឡាអ៊ីឡាហ្វា អ៊ីលឡុលឡោះហ៊្វ៏ (لَا إِلٰهَ إِلَّا ٱللّٰه) - មិនមានព្រះទេ ក្រៅពីអល់ឡោះហ៊្វ៏عز وجل ។

ពាក្យពេជន៍អស្ចារ្យនេះជាមហាគ្រឹះនៅក្នុងខ្លួនព្រះនាង ។ ក្រោយមក ពាក្យពេជន៍ទាំងនេះក្លាយទៅជាលក្ខណៈបុគ្គលរបស់ព្រះនាង ដែលមានសារៈសំខាន់បំផុត ។ នៅក្នុងអនាគតកាល ព្រះនាងនឹងប្រកាសឲ្យអនុវត្តិតាមពាក្យពេជន៍ទាំងនេះដែលបណ្តាលឲ្យព្រះនាងរងទុក្ខវេទនាធ្ងន់ ។

លុះបានទទួលដំណឹងប្រសូតព្រះរាជទារកភ្លាម ព្រះសាស្តាﷺរួសរាន់មកឯព្រះរាជដំណាក់ព្រះរាជបុត្រីព្រះអង្គ ឱបព្រះរាជទារកផ្ទាប់នឹងទ្រូងព្រះអង្គដ៏កក់ក្តៅហើយបានស្រក់ព្រះអស្សុ (គឺទឹកភ្នែក) ។ ព្រះនាងហ្វាទីម៉ាស់ អាស់-ស្ហាស់រ៉អ៍سلام الله عليها ព្រះរាជមាតា ឆ្ងល់ណាស់ដែលបានឃើញព្រះបិតាព្រះនាងហូរព្រះអស្សុ ។ ព្រះនាងបានសួរថា៖ "ហេតុព្រះបិតាទ្រង់ព្រះកន្សែង ?"

---

[29] អាស្ទាន គឺការប្រកាសហៅស្ហ៏ឡាត់ ។

[30] អ៊ីក៏ម៉ាស់ គឺការថ្លែងដំបូងក្នុងពិធីស្ហ៏ឡាត់ ។

ព្រះរាជបិតាﷺមានព្រះវចនៈថា៖ "ហ្វាទីម៉ាស្ហ់سلام الله عليهاអឺយ បុត្រីគប្បីដឹងថា បុត្រីរូបនេះនឹងរងការឈឺចាប់ដោយសារទុក្ខវេទនាធ្ងន់ និងសោកនាដកម្ម ក្រោយពីបុត្រីនិងបិតាសោយទិវង្គត[31] ។"

សម័យនោះព្រះសាស្តាﷺបានដឹងដោយវិញ្ញាណ នូវការឈឺចាប់គួរឲ្យតក់ស្លុតដែលនឹងពើបពះលើព្រះនត្តាស្ត្រីអង្គនេះ ។ អញ្ចឹងហើយបានជាព្រះនាង ហ្វាទីម៉ាស្ហ់ អាស្ហ់-ស្ហាស្ហ់រ៉អ៊្ហ៏سلام الله عليها បានសោកសៅជាមួយព្រះបិតាព្រះនាងកាលនោះ ។ បន្ទាប់មក ពេលមិត្តជំនិតរបស់អាស្ហ់-លុលបៃត៍عليهم السلام ដូចជាវីរៈបុរស សាល់ម៉ាន ជាដើម បានមកសម្តែងសេចក្តីអបអរសាទរក្នុងឱកាសនេះ លោកបានឃើញព្រះរាជកុលដ្ឋាននៅក្នុងអាការក្រៀមក្រំមិនសប្បាយរីករាយទេ ។ ដូច្នេះ លោកក៏បានចូលរួមក្នុងពិធីលួងលោមចិត្ត រំលែកទុក្ខ[32] ។

## ការជ្រើសរើសព្រះនាម

ព្រះសន្តមាតាបានបីព្រះរាជទារករបស់ព្រះនាងឲ្យទៅឲ្យព្រះបិតា សូមឲ្យព្រះអង្គជ្រើសរើសព្រះនាមឲ្យព្រះរាជទារក ។ ព្រះបិតាបានឆ្លើយតបដោយដាក់ព្រះកាយថា៖ "ខ្ញុំصلوات الله عليه والسلامនឹងមិនកាត់មុខព្រះសាសនៈទូតﷺរបស់អល់ឡោះហ្ទ៍عز وجلក្នុងរឿងសំខាន់បែបនេះទេ ។" ព្រះអង្គصلوات الله عليه والسلامក៏បាននាំទារកទៅជួបព្រះសាស្តាﷺ សូមឲ្យព្រះអង្គដាក់ព្រះនាមឲ្យព្រះរាជទារក ។ ព្រះសាសនៈទូតﷺរបស់អល់ឡោះហ្ទ៍عز وجل បានឆ្លើយដោយដាក់ព្រះកាយថា៖ "ខ្ញុំនឹងមិនកាត់ព្រះភ័ក្ត្រព្រះម្ចាស់عز وجلខ្ញុំក្នុងរឿងសំខាន់បែបនេះទេ ។" ព្រះអគ្គទេវតាយ៉ីបរ៉អ៊ីលعليه السلامបានចុះពីលើមេឃ មកប្រាប់ព្រះសាស្តាﷺថា៖ "ព្រះនាមរបស់ព្រះរាជទារកអង្គនេះគឺ "ស្ហៃណាប់"[33] ។

[31] សូមមើលសៀវភៅ *អាត្ហ់-ត្ហីរ៉ាស្ហ់ អាល់-មូស្ហាស្ហ់ហ្ទាប់ (الطراز المذهب)*, ៣៨ ។

[32] សូមមើលសៀវភៅ *បាតាឡាត់ ការបាឡាអ៊្ហ៍* ទំព័រ ២១ ។

[33] ក្នុងភាសាអារ៉ាប់ ពាក្យថា "ស្ហៃណាប់" ជាឈ្មោះរបស់បុគ្គលដែលស្អាត ។

អល់ឡោះហ្ទ៍تعالىបានជ្រើសរើសព្រះនាមនេះឲ្យព្រះនាង ។" គេបានដាក់ឈ្មោះក្រៅឲ្យព្រះនាងដែរថា "អ៊ុម គុលស៊្ហុម" ឬ "អ៊ុម អាល់-ហ៊្ាសាន់" ។

## វិសេសសព្ទ

វិសេសសព្ទជាពាក្យសម្តី ឬជាឃ្លាដែលចង្អុលបង្ហាញគុណសម្បត្តិ ឬនិមិត្តដែលជាបុគ្គលិកលក្ខណៈរបស់បុគ្គល ឬរបស់វត្ថុដែលគេនិយាយដល់ ។ ដូច្នេះ វិសេសសព្ទពណ៌នាអំពីឥរិយាបថផ្នែកអារម្មណ៍និងលក្ខណៈដោយមិននិយាយអំពីអាក្រក់ឬល្អរបស់បុគ្គលទេ ។ ដូច្នេះ ព្រះនាងស៊្សៃណាប់سلام الله عليهاមានច្រើនវិសេសសព្ទ ដែលចង្អុលបង្ហាញនូវចំណុចលក្ខណៈបុគ្គលរបស់ព្រះនាង ។

### ១) អាល់-អ៊្ាគីឡាស់ (العقيلة)

ភាសាអារ៉ាប់ អ៊្ាគីឡាស់ មានន័យថាស្ត្រីថ្លៃថ្នូរ ដែលគេលើកកិត្តិយសនៅក្នុងចំណោមប្រជានិកររបស់ស្ត្រីនោះ ហើយដែលគេគោរពដ៏ខ្ពង់ខ្ពស់នៅក្នុងផ្ទះស្ត្រីនោះ ព្រោះតែស្ត្រីនោះមានប្រាជ្ញាញាណ (គឺមានគតិបណ្ឌិតខ្ពង់ខ្ពស់) ។ ព្រះនាងស៊្សៃណាប់سلام الله عليهاជាស្ត្រីថ្លៃថ្នូរនិងប្រកបដោយគុណសម្បត្តិបែបនេះ ហើយគេហៅព្រះបច្ឆាជនរបស់ព្រះនាងតរៀងមកថាបានូ អាល់-អ៊្ាគីឡាស់ មានន័យថា បណ្តាកូនចៅរបស់ស្ត្រីថ្លៃថ្នូរនិងប្រកបដោយប្រាជ្ញាញាណ (គឺប្រកបដោយគតិបណ្ឌិតខ្ពង់ខ្ពស់) ។ ក្នុងពេលអ៊ីម៉ាំអាល់-ហ៊្ុសែន៍صلوات الله عليه والسلامធ្វើដំណើរពីម៉ាឌីណាស់ ទៅកាន់ការបាឡាអ៍ ព្រះនាងស៊្សៃណាប់سلام الله عليهاជាព្រះនាយិកាដឹកនាំព្រះហ៊្ារីមទាំងអស់ ហើយទាំងអស់គ្នាស្តាប់បង្គាប់និងគោរពព្រះនាង ។ សូមបន្ថែមទៀតថា គេហៅព្រះនាងដែរថា "អ៊្ាគីឡាទូ បានី ហ្ាស៊ីម មានន័យថា ស្ត្រីប្រកបដោយប្រាជ្ញាញាណរបស់ត្រកូលហ្ាស៊ីម" និង "អ៊្ាគីឡាត់ អ៊ុត្ត៍លីប៊ីយីន" មានន័យថាស្តីប្រកបដោយប្រាជ្ញាញាណរបស់បណ្តាកូនចៅរបស់ អាប៊ូ ត៍្លិបرضي الله عنه ។"

## ២) អាល់-អាលីម៉ាស់ (العالمة)

ព្រោះតែព្រះនាងចេះដឹងកំពូល ទើបគេហៅព្រះនាងថាអាល់-អាលីម៉ាស់ មានន័យថា "ស្ត្រីចេះដឹង"។ អ្នកប្រវត្តិសាស្ត្របានអះអាងបញ្ជាក់ថាព្រះនាងជាអាជ្ញាធរសម្រាប់បណ្ដាស្ត្រីមុស្លីម ដែលតែងតែសូមយោបល់ព្រះនាងរឿងសាសនា។ ពិតមែន ព្រះនាងទទួលបាននូវចំណេះចេះដឹងកម្រិតនេះពីព្រះអយ្យកោ ពីព្រះបិតាមាតានិងពីព្រះរៀមទាំងពីររបស់ព្រះនាងដែលជាប្រភពអភិញ្ញាសម្រាប់សហគមន៍អ៊ីស្លាម។ ម្យ៉ាងទៀត ព្រះនាងស្ងែណាប់ﷺមានព្រះវិសេសសព្វស្រដៀងនេះដែរ ដូចជា "អាល់-អារីហ្វាស់" មានន័យថា អ្នកដឹងការពិត និង "អាល់-មូវ៉ាស្សាកោះត៍" មានន័យថា អ្នកដែលទុកចិត្តបាន។"

## ៣) អាប៊ីដាទូ អាលី អាលី

គេទទួលស្គាល់ព្រះនាងស្ងែណាប់ﷺដែរថា ជាអ្នកធ្វើគោរពសក្ការៈដ៏ប្រសើរក្នុងចំណោមបណ្ដាស្ត្រីមុស្លីម។ ព្រះនាងប្រតិបត្តិពិធីទាំងអស់ក្នុងសាសនាអ៊ីស្លាមដែលមិនមែនជាកាតព្វកិច្ចទេនោះ (គឺមិនមែនវ៉ាយ៊ីប) ដល់ថ្នាក់ ទោះជានៅក្នុងយប់អាក្រក់ក្ដី ក៏ព្រះនាងនៅតែប្រតិបត្តិពិធីក្នុងសាសនាទាំងនេះដែរ - ពោលគឺ នៅក្នុងយប់ទី ១០ ខែ មូហារ៉មេ ឆ្នាំ ៦១ ហ៊ីច្រ៉េះត៍សករាជ - ព្រះនាងបានស្វ៊ឡាត់ស៊ូណាត់។ ដូច្នេះឯងបានជាគេហៅព្រះនាងថា អាប៊ីដាទូ អាលី អាលី មានន័យថា ស្ត្រីដែលធ្វើគោរពសក្ការៈបំផុតក្នុងព្រះរាជកុលដ្ឋានរបស់អាលី។

## ៤) អាល់-កាមីឡាស់ (الكاملة)

ក្នុងគ្រប់វិស័យសុក្រឹតភាពនៃមនុស្ស ព្រះនាងស្ងែណាប់ﷺនាំមុខគេបង្អស់ ហើយព្រះនាងជាប់ក្នុងលំដាប់ថ្នាក់ជាអ្នកនាំមុខគេ។ ដូច្នេះហើយបានជាគេហៅព្រះនាងថា "អាល់-កាមីឡាស់ មានន័យថា ស្ត្រីសុក្រឹតឥតខ្ចោះ"។

## ៥) អាល់-ហ្វាឌីឡាស្ហ៍ (الفضيلة)

ព្រោះតែព្រះនាងធ្វើឃ្ញីហ្វាដ្ហ៍សែនធំ (គឺតស៊ូ អត់ធ្មត់ ពុះពារឧបសគ្គគ្រប់សព្វ) បម្រើអ៊ីស្លាម ខ្ជាប់ខ្ជួនដើម្បីអល់ឡោះហ៍ عز وجل ព្រហ្មធម៌របស់ព្រះនាងស្ហៃណាប់ سلام الله عليها ហួសព្រំដែនទាំងអស់ ។ ដូច្នេះហើយបានជាគេដាក់វិសេសសព្ទឲ្យព្រះនាងដោយមោទនភាពថា "អាល់-ហ្វាឌីឡាស្ហ៍" មាន ន័យថាស្ត្រីប្រកបដោយព្រហ្មធម៌ (គឺប្រកបដោយធម៌ខ្ពង់ខ្ពស់) ។

## ៦) អាល់-ស្វាដ្ហ៍ឌីកោះត៍ អាល់-ស៊ុក្ររ៉ (الصادقة الصغرى)

ដូចព្រះមាតាព្រះនាងដែរដែលគេស្គាល់ថាជាព្រឹទ្ធាសច្ចៈការិនី ព្រះនាងស្ហៃណាប់ سلام الله عليها មានសច្ចៈ មានសេចក្ដីទៀងត្រង់ក្រៃលែងដល់ថ្នាក់បានទទួលនូវវិសេសសព្ទដោយសក្ដិសមថា "អាល់-ស្វាដ្ហ៍ឌីកោះត៍ អាល់-ស៊ុក្ររ៉ មានន័យថា យុវសច្ចការិនី (គឺយុវតីសច្ចៈ)" ។

## ៧) អ៊ុម្ម អាល់-ម៉ាស្វ៊ែអ៊ីប (أم المصائب)

ព្រោះតែព្រះនាងរងទុក្ខសែនច្រើន រាប់មិនអស់ពេញមួយជីវិតព្រះនាងបានជាគេហៅព្រះនាងស្ហៃណាប់ سلام الله عليها ថា "អ៊ុម្ម អាល់-ម៉ាស្វ៊ែអ៊ីប" មានន័យថា "មាតាទុក្ខ" ។ យើងសូមលើកមកអធិប្បាយជូននូវទុក្ខវេទនាទាំងនេះដែលព្រះនាងបានពើបពះក្នុងរយៈពេលមួយខែ គឺ៖

-ព្រះនាងបានឃើញ អាល់-ហ៊្វរ អ៊ីបនូ យ៉ាស៊ីដ្ហ (الحر بن يزيد) ឃាត់ដំណើរអ៊ីម៉ាំអាល់-ហ៊្វសែន៍ صلوات الله عليه والسلام បង្ខំព្រះអង្គ صلوات الله عليه والسلام ឲ្យបោះជំរំនៅឯកន្លែងលំបាក ។

-ព្រះនាងឃើញកនអ៊ីម៉ាំសែនតិច ប្រៀបនឹងទ័ពមហាធំរបស់ពួកសត្រូវ ។

-ព្រះនាងឃើញកនអ៊ីម៉ាំរត់ចោលព្រះអង្គ صلوات الله عليه والسلام ទៅចូលដៃជាមួយសត្រូវព្រះអង្គ صلوات الله عليه والسلام ។

-ព្រះនាងឃើញបណ្ដាស្ត្រីព្រះរាជកុលដ្ឋានភ័យខ្លាច ពេលដែលត្រូវបោះជំរំនៅឯការបាឡាអ៍ ។

-ព្រះនាងឃើញឃើញពួកសត្រូវបង្អត់ទឹកព្រះនាង និងគ្រួសារព្រះនាង ។

-ព្រះនាងបានទទួលបន្ទុកមើលថែទាំកូនក្មេងនិងបណ្តាស្ត្រី ពេលពួកគេយំនិងស្រេកទឹក ។

-ព្រះនាងយល់ចិត្តព្រះរៀមصلوات الله عليه والسلامព្រះនាងដែលខកចិត្ត និងតែលតោលម្នាក់ឯង ។

-ព្រះនាងបានឃើញផ្ទាល់ភ្នែក បុត្រពីរអង្គរបស់ព្រះនាងធ្វើទុក្ករកម្មបូជាជីវិត ព្រមទាំងសាច់ញាតិនិងបណ្តាសាវកព្រះនាងឯទៀតដែរដែលបានធ្វើទុក្ករកម្មបូជាជីវិតម្តងម្នាក់ៗ ។ តែទុក្ករកម្មរបស់អាល់-អ៊ុប់បាស់នោះ អាណោចអាធ័មបំផុតសម្រាប់ព្រះនាង ។

-ព្រះនាងបានឃើញអ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلامពុំមានអ្នកគាំទ្រ ឬអ្នកជួយទេ ខណៈដែលព្រះអង្គصلوات الله عليه والسلامស្វែងរកជំនួយ ។

-ព្រះនាងបានឃើញព្រះសិរអ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلامត្រូវផ្តាច់ពីខ្លួនហើយត្រូវគេដោតនៅលើផ្លែលំពែង ។

-ព្រះនាងបានឃើញពួកសត្រូវវាយលុក ទៅលើក្រុមព្រះរៀមصلوات الله عليه والسلامព្រះនាង និងវាយលុកទៅលើបណ្តាស្ត្រី ចង់ដុតបំផ្លាញជំរំ ។

-ព្រះនាងខិតខំប្រមូលក្មេងៗដែលរត់គេចខ្លួន រប៉ាត់រប៉ាយពាសពេញនៅក្នុងវាលខ្សាច់នោះ ។

-ក្នុងពេលដើរប្រមូលបណ្តាស្ត្រី និងក្មេងៗព្រះរាជកុលដ្ឋានព្រះនាង ព្រះនាងបានប្រទះលើព្រះរាជសព្វព្រះរៀមصلوات الله عليه والسلامព្រះនាងដែលដាច់ព្រះសិរ ។

-ព្រះនាងបានជិះអូដ្ឋស្គម គ្មានកែប ហើយជួយក្មេងៗនិងបណ្តាស្ត្រីឡើងជិះជំនិះបែបនេះ ។

-ព្រះនាងប្រឹងប្រែងព្យាបាលជម្ងឺនិងលួងចិត្តព្រះភាតុបុត្ត (ក្មួយប្រុស) ព្រះនាង ។

-ព្រះនាងត្រូវគេដណ្តើរអាក្រោសជាឈ្លើយសឹក ពីស្រុកមួយទៅ

> ស្រុកខណៈដែលប្រជារាស្ត្រមើលនិងចាត់ទុកព្រះនាង និងក្រុមព្រះនាងជាជនបះបោរ ។

សព្វមួយដង ព្រះសាស្តាصلى الله عليه وآله وسلمមានព្រះវចនៈថា៖ "យំសោកអាណិតស្រណោះស្ទៃណាប់سلام الله عليها ដូចយំសោកអាណិតស្រណោះអាល់-ហាសាន់صلوات الله عليه والسلامនិងអាល់-ហ៊្វសែន៍صلوات الله عليه والسلام បងៗរបស់នាងដែរ[34] ។"

## ឆ្នាំប្រសូត

បណ្តាអ្នកប្រវត្តិសាស្ត្រនិងបណ្តាអ្នកតំណាលមិនស្របមតិគ្នាទេ អំពីឆ្នាំកំណើតរបស់ព្រះនាងស្ទៃណាប់سلام الله عليها ។ អ្នកខ្លះថាព្រះនាងបានប្រសូតក្នុងឆ្នាំទីប្រាំសករាជហ៊្វីច្រ៉េះត៍្[35] អ្នកខ្លះថាក្នុងឆ្នាំទីប្រាំមួយ អ្នកខ្លះទៀតថាក្នុងឆ្នាំទីប្រាំបួន ។ មតិចុងក្រោយនេះមិនត្រឹមត្រូវទេ[36] ចំណែកឯមតិដំបូងគួរទទួលយកបានជាង ។

[34] សូមមើលសៀវភៅរបស់លោក យ៉ាកុំហ្វារ អាល់-ណាក្វឌី *ស្ទៃណាប់ អាល់-គុបរ៍*, ៣២ ។

[35] ហ៊្វីច្រ៉េះត៍្គឺការភៀសខ្លួនរបស់ព្រះសាស្តាមូហាំម៉ាដ្ឋ៍صلى الله عليه وآله وسلم និងព្រះរាជកុលដ្ឋានព្រះអង្គនិងបណ្តាសាវកព្រះអង្គពីម៉ាក់កាស្ទ៍ទៅកាន់ម៉ាឌីណាស្ទ៍ក្នុងឆ្នាំ ៦២២ គ្រិស្តសករាជ ។ សម័យកាលរបស់មុស្លីមត្រូវចាប់រាប់ពីប្រវត្តិនេះ ។

[36] ស្ហៃខ៍ យ៉ាក់ហ្វារ អាល់-ណាដៀរ នៅក្នុងសៀវភៅលោក *ស្ទៃណាប់ អាល់-គុបរ៍* ទំព័រ ១២ បដិសេធសម្តីដែលថាព្រះនាងស្ទៃណាប់ប្រសូតក្នុងឆ្នាំទី ៩ សករាជហ៊្វីច្រ៉េះត៍ ថា៖ "ទោះជាមានការតំណាលផ្សេងក៏ដោយ ព្រះនាងស្ទៃណាប់سلام الله عليها សច្ចការិនី បានសោយទិវង្គតក្នុងឆ្នាំទី១០ ឬក្នុងឆ្នាំទី១១ ហ៊្វីច្រ៉េះត៍្សករាជ ពេលអ៊ុម គុលស៊្ហូម ព្រះអនុជារបស់ព្រះនាងប្រសូត ហើយពេល អាល់-មុះហ៊ាស៊ិនព្រះរាជបុត្រទីបីរបស់អ៊ីម៉ាំអាលីصلوات الله عليه والسلامប្រសូត" ដូច្នេះទើបគេអាចយល់បានថា ព្រះនាងស្ទៃណាប់បានប្រសូតក្នុងឆ្នាំទី៥ហ៊្វីច្រ៉េះត៍្សករាជ ។" ម្យ៉ាងទៀត ស្ហៃខ៍ អាល់-ណាក្វឌីផ្អែកលើព្រឹត្តិការណ៍ផ្សេងៗទៀតដើម្បីអះអាងបញ្ជាក់មតិ នេះ ។

## បឋមវ័យ

ព្រះនាងស្សៃណាប់سلام الله عليهاត្រូវចិញ្ចឹម បីបាច់ថែរក្សាដោយព្រះសាស្ដាមូហ្ហាំម៉ាដ្ឋصلى الله عليه وآله وسلم អ៊ីមុាំអាុលីصلوات الله عليه والسلام និងព្រះនាងហ្វាទ្ទីម៉ាស់سلام الله عليها សច្ចការិនី ។ អាចនិយាយបានថាព្រះនាងត្រូវចិញ្ចឹម បីបាច់ថែរក្សាក្នុងរង្វង់សាស្ដាភាព ព្រះនាងបានធាត់ធំក្នុងបឋមវ័យ នៅក្នុងព្រះរាជដំណាក់នៃព្រះបេសកកម្ម ព្រះនាងបានបៅទឹកក្សីរ (ទឹកដោះ) របស់ស្ត្រីសុក្រឹតគ្រប់យុគសម័យ ព្រះនាងត្រូវបំប៉នអាហារដោយព្រះហត្ថព្រះរាជអគ្គមហាប្រមុខរបស់បណ្ដាអ្នកមានសទ្ធាជ្រះថ្លា ។ ដូច្នេះព្រះនាងបានទទួលនូវការបីបាច់ថែរក្សានិងការអប់រំផ្នែកសាសនាដែលមកពីព្រះ ។ ព្រះនាងត្រូវបំពាក់ដោយសំលៀកបំពាក់នៃសេចក្ដីថ្កុំថ្កើង នៃសេចក្ដីខ្ពង់ខ្ពស់ នៃសេចក្ដីបរិសុទ្ធនិងនៃសុភាវធម៌ ។ ក្រោយពីព្រះសាស្ដាមូហ្ហាំម៉ាដ្ឋصلى الله عليه وآله وسلمនិងព្រះរាជបុត្រីព្រះអង្គصلى الله عليه وآله وسلم ព្រះនាងហ្វាទ្ទីម៉ាស់سلام الله عليها សោយព្រះទិវង្គត អាុលីصلوات الله عليه والسلام បានអភិសេកព្រះនាងអ៊ូម៉ាម៉ាស់ (أمامة)[37] ដែលបានបីបាច់ថែរក្សាព្រះនាងស្សៃណាប់سلام الله عليهاយ៉ាងល្អឥតខ្ចោះ ព្រោះព្រះនាងអូម៉ាម៉ាស់ជាស្ត្រីមួយរូបដែលគេឯងស្គាល់ថាជាស្ត្រីមានសទ្ធាស៊ប់ចិត្ត និងទុកកាយថ្វាយចិត្តលើព្រះជាម្ចាស់ទាំងស្រុង ។

ព្រះនាងស្សៃណាប់سلام الله عليهاបានទទួលការបីបាច់ថែរក្សា ក្រោមការអប់រំបំពាក់បំប៉នដ៏ត្រចះត្រចង់ ក្រោមកិត្តិយស ក្រោមសេចក្ដីថ្លៃថ្នូរ ក្រោមសេចក្ដីប្រោសប្រណីនិងមេត្តាធម៌ ។ ព្រះនាងបានសិក្សាសីលច្រើនមុខដែលធ្វើឲ្យលក្ខណៈបុគ្គលព្រះនាងសុក្រឹតឥតខ្ចោះ មកពីអាចារៈព្រះមាតាបិតានិងព្រះរៀមទាំងពីររបស់ព្រះនាង ។

---

[37] អ៊ូម៉ាម៉ាស់ជាព្រះរាជបុត្រីរបស់ព្រះនាងស្សៃណាប់ (ស្សៃណាប់ជាព្រះរាជបុត្រីរបស់ព្រះសាស្ដាមូហ្ហាំម៉ាដ្ឋصلى الله عليه وآله وسلم) ។ ដោយធ្វើតាមបណ្ដាំរបស់ព្រះនាងហ្វាទ្ទីម៉ាស់អាស្សុ-ស្សាស្សុរ៉អ៊ុسلام الله عليها អ៊ីមុាំអាុលីصلوات الله عليه والسلامបានរៀបអភិសេកព្រះនាងអ៊ូម៉ាម៉ាស់ក្រោយពីព្រះនាងហ្វាទ្ទីម៉ាស់سلام الله عليهاសោយទិវង្គត ។ ត្រូវដឹងដែរថាព្រះសាស្ដាមូហ្ហាំម៉ាដ្ឋصلى الله عليه وآله وسلمគោរពព្រះនាងអ៊ូម៉ាម៉ាស់ណាស់ ។

ឧទាហរណ៍ ពេលព្រះនាងទៅលេងព្រះរៀមព្រះនាង អ៊ីម៉ាំអាល់-ហ៊្វសែន៍ صلوات الله عليه والسلام ព្រះអង្គងើបឈរជាសញ្ញានៃសេចក្តីគោរពនិងសេចក្តីគួរសមចំពោះព្រះនាង ។ ពេលព្រះនាងទៅស៊ីរ៉ាស់ផ្ទះព្រះអយ្យកោព្រះនាង ព្រះបិតានិងព្រះរៀមទាំងពីរបស់ព្រះនាងបានជូនព្រះនាងទៅ ។ ព្រះអង្គតែងតែពន្លត់ភ្លើងនៅទីនោះដើម្បីកុំឲ្យគេមើលឃើញព្រះនាង[38] ។

ព្រះនាងជាអ្នកស្នងគុណសម្បត្តិ សីលធម៌និងអភិសមាចាររបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام ។ សម្រាប់អស់លោកអ្នកប្រាជ្ញនិងអស់លោកអ្នកថ្លែងហាឌីស្ស[39] ព្រះនាងស៊ែណាប់ سلام الله عليها ប្រកបដោយបុណ្យសក្តិខ្ពស់ ។ ហេតុដូច្នេះ អស់លោកទាំងនេះតែងតែនិយាយយោងដល់អ៊ីម៉ាំអាលី صلوات الله عليه والسلام ថា "បិតារបស់ស៊ែណាប់បានថ្លែងថា..." នៅក្នុងរបបអ៊ូម៉ៃយ៉ាស់ដែលបានហាមឃាត់ហៅឈ្មោះអ៊ីម៉ាំ صلوات الله عليه والسلام ។

## កម្រិតប្រាជ្ញា

ចាប់តាំងពីកុមារភាពមកម្ល៉េះ ព្រះនាងស៊ែណាប់ سلام الله عليها មានប្រាជ្ញានិងគតិបណ្ឌិតអស្ចារ្យ ។ ព្រះនាងសិក្សាព្រះគម្ពីរគួរអាននិងព្រះវចនៈព្រះសាស្តា صلى الله عليه وآله وسلم ដែលចែងអំពីច្បាប់អ៊ីស្លាម អំពីច្បាប់អប់រំនិងអំពីគោលការណ៍នៃអភិសមាចារ ដោយចិត្ត ដោយអារម្មណ៍ ។ ព្រះនាងបានចង់ចាំព្រះវចនៈរបស់ព្រះមាតាព្រះនាង - ព្រះនាង ហ្វាទិ៍ម៉ាស់ អាស់-ស៊ាស់រ៉អ៊ី سلام الله عليها - ដែលបានថ្លែងនៅក្នុងម៉ាស់ឃ្ជិដព្រះសាស្តា صلى الله عليه وآله وسلم ជំទាស់ អាប៊ូ បាការ ដែលបានប្លន់យកតំណែងដឹកនាំអ៊ុមម៉ាត់អ៊ីស្លាម ដែលត្រូវបានមកអ៊ីម៉ាំអាលី صلوات الله عليه والسلام តាមព្រះរាជបន្ទូលអល់ឡោះហ៍ تعالى និងបណ្តាំព្រះសាស្តាមូហាំម៉ាដ់

[38] មើលសៀវភៅរបស់លោក អាត់-ត៍បារ៉នី (الطبراني) *អាល់-មុអ៍ឃ្ជាំ អាល់-កាបៀរ* (المعجم الكبير) ដែលគេបានថ្លែងប្រាប់លោក យ៉ាស់យ៉ា អាល់-ម៉ាស៊ីនី ។

[39] ហាឌីស្សគឺទំនៀមទម្លាប់ពាក់ព័ន្ធនឹងព្រះវចនៈ និងទង្វើរបស់ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم ។

صلى الله عليه وآله وسلم ។ ព្រះនាងسلام الله عليهاបានតវ៉ារឿងគេរឹបយកចម្ការហ្វាដាក់ដែរព្រោះព្រះសាស្ដាصلى الله عليه وآله وسلمបានប្រទានចម្ការនេះឲ្យមកព្រះនាងسلام الله عليها ដោយមានមុស្លីមទាំងអស់បានដឹងឮផ្ទាល់ ។ ព្រះនាងស្ដៃណាប់سلام الله عليهاបានថ្លែងពាក្យពេជន៍របស់ព្រះមាតាព្រះនាងថែមពីលើសេចក្ដីតាយការណ៍ច្រើនទៀត ពេលស្ត្រីមុស្លីមមកស៊ីវ៉ាស់ព្រះនាងជាលើកចុងក្រោយ កាលព្រះនាងទ្រង់ប្រឈួន ។

ព្រះបិតាព្រះនាង ក៏កោតសរសើរប្រាជ្ញាឈ្លាសវៃរបស់ព្រះនាងណាស់ដែរ ។ ថ្ងៃមួយព្រះនាងបានសួរព្រះអង្គថា៖ "ព្រះបិតាអឺយ តើព្រះបិតាសព្វហឫទ័យអស់ទូលបង្គំទេ ?" ព្រះអង្គបានតបថា៖ "បុត្រីអឺយ បិតាស្រឡាញ់ ។ បិតាស្រឡាញ់បុត្រទាំងអស់គ្នាព្រោះបុត្រទាំងអស់ជាសម្បត្តិបេះដូងបិតា ។" ព្រះនាងបានឆ្លើយយ៉ាងសុភាពថា៖ "ព្រះបិតាអឺយ សេចក្ដីស្រឡាញ់បានតែលើអល់ឡោះហ្ ៍عز وجلទេ ចំណែកឯយើងវិញបាននូវសេចក្ដីមេត្តា ។"

កាលព្រះអង្គបង្គាប់ព្រះនាងឲ្យចេះរាប់ ព្រះអង្គមានវចនៈថា៖ "ថាមួយ ។" ព្រះនាងបានថា៖ "មួយ ។" ព្រះអង្គមានវចនៈថា៖ "ពីរ ។" ព្រះនាងស្ងាត់មាត់ ។ ព្រះបិតាព្រះនាងបានសួរថា៖ "ម្ដេចមិនថាពីរ ?" ព្រះនាងបានឆ្លើយថា៖ "អណ្ដាតដែលបានថា "មួយ" មិនអាចថា "ពីរ"[40] បានទេ ។" ពេលព្រះអង្គបានឮចម្លើយធំនេះ ព្រះអង្គថើបហើយឱបព្រះនាង[41] ។

---

[40] នេះមានន័យថាអ្នកណាជឿយ៉ាងស្មោះថាមានតែអល់ឡោះហ្ ៍عز وجلមួយគត់ អ្នកនោះមិនត្រូវយកអ្នកផ្សេងជាព្រះទេ ។

[41] សូមមើលសៀវភៅ *រ៉យ៉ាហ្ហ៊ីន អាល់-ស្ហារីអ៊ាស្ហ់ (رياحين الشريعة)* ក្បាលទី ៣ ទំព័រ ៥៤, សៀវភៅ *យ៉ាណាប៊ី អាល់-ម៉ោះហ្ហ៍ម៉ាស្ហ់* របស់ ហាច្ហ៍យ្ហ៍ អ៊ុប់ឌុល-ហ្ហ៊ាឌី អាល់-ស្ហាស្ហ៍រីសតានី ទំព័រ ៨ ។ លោក អ៊ីបនូ អ៊ុសាកៀរ, លោក អ៊ីបនូ ម៉ាន់ដ្ហាស្ហ់, លោក អ៊ុលី មុលឡាស្ហ់ អាល់-ក្ហូដ្ហ៍រី បានសរសេរដូចនេះដែរ ។

ព្រះនាងតែងតែមានវចនៈថាដែរថា៖ "

مَنْ أَرَادَ أَنْ لا يَكونَ الخَلْقُ شُفَعَاءَهُ إلى اللهِ فَلْيَحْمِدْهُ. أَلَمْ تَسْمَعْ إلى قَولِهِ:

سَمِعَ اللهُ لِمَنْ حَمِدَهُ. فَخَفِ اللهَ لِقُدْرَتِهِ عَلَيْكَ، وَاسْتَحِ مِنْهُ لِقُرْبِهِ مِنْكَ.

*"អ្នកណាក៏ដោយ ដែលមិនចង់បានសត្វលោកជាអ្នកជួយធ្វើអន្តរាគមន៍ឲ្យខ្លួនចំពោះអល់ឡោះហ្ទ៍عزوجلទេ អ្នកនោះគប្បីក្រាបអភិវន្ទសក្ការព្រះអង្គعزوجل ។ ចូរស្តាប់ព្រះបន្ទូលព្រះអង្គعزوجل៖ "អល់ឡោះហ្ទ៍ទ្រង់សវនាការគ្រប់បុគ្គលដែលក្រាបអភិវន្ទសក្ការព្រះអង្គ ។" ដូច្នេះ បុគ្គលត្រូវខ្លាចក្រែងអល់ឡោះហ្ទ៍عزوجل ព្រោះព្រះអង្គعزوجلមានអំណាចលើបុគ្គលទាំងអស់ ហើយបុគ្គលត្រូវក្រែងរអែងព្រះអង្គعزوجلព្រោះព្រះអង្គعزوجلនៅជិតបុគ្គលណាស់ ។"*[42]

ការពិតពាក្យពេជន៍នេះសឲ្យឃើញថាព្រះនាងបរិសុទ្ធណាស់ ហើយវ័ណ្ណជាប់នឹងអល់ឡោះហ្ទ៍عزوجلមិនដាច់ ។

ម្យ៉ាងទៀតព្រះនាងតាង (គឺជាជំនួស) អ៊ីម៉ាំអាល់-ហ៊្វូសៃន៍صلوات الله عليه والسلام ព្រះរៀមព្រះនាង ពេលព្រះអង្គអវត្តមាន ។ ដូច្នេះហើយបានជាមុស្លីមទាំងឡាយតែងតែសូមយោបល់ពីព្រះនាង ពាក់ព័ន្ធនឹងបញ្ហាច្បាប់អ៊ីស្លាម ។ ដោយសារតែការចេះដឹងដ៏ទូលំទូលាយនោះឯងបានជា អ៊ីម៉ាំ ស៊ែ្សន៍ អាល់-អ៊ុាប៊ីឌីនصلوات الله عليه والسلام (زين العابدين), អ៊ុាប់ឌុលឡោះហ្ទ៍ អ៊ីបនូ យ៉ាក់ហ្វារ៍, ព្រះនាងហ្វាទីម៉ាស្ទ់ បុត្រីរបស់អ៊ីម៉ាំអាល់-ហ៊្វូសៃន៍صلوات الله عليه والسلام, មូហាំម៉ាដ្ទ់ អ៊ីបនូ អ៊ុាំរូ និង អាត៍្ត អ៊ីបនូ អាល់-សាអ៊ីប តែងតែលើកយកនូវវចនៈរបស់ព្រះនាងមកថ្លែង ។[43]

---

[42] សូមមើលសៀវភៅរបស់ សៃយីដ្ទ មុះហ៊្ម៍ស៊ីន អាល់-អាមីន អាល់-អាមីលី *អាយ៉ាន់ អាល់-ស៊្ទីអ៊ុាស្ទ់* ក្បាលទី ៧ ទំព័រ ១៤០ ។

[43] សូមមើលសៀវភៅរបស់លោក បាគ្ញៀរ ស្ទារីហ្វ អាល់-ក្វ៍រ៉ស្ទី *អាល់-សៃយីដ្ទាស្ទ់ ស៊ែ្សណាប់ ។*

នៅគូហ្វាស្ហ៍ សម័យព្រះបិតាព្រះនាងដឹកនាំអ៊ុមម៉ាត់ ព្រះនាងស្ហៃណាប់ سلام الله عليها មានអង្គប្រជុំពិសេសមួយសម្រាប់ស្ត្រីមុស្លីមមកសិក្សាអ៊ីស្លាម និងសិក្សាសម្រាយព្រះគម្ពីរគួរអាន ។ ដូច្នេះព្រះនាងជាទីសំអាងជាទីទុកចិត្តបំផុត ដែលស្ត្រីមុស្លីមសូមយោបល់ពាក់ព័ន្ធនឹងរឿងអ៊ីស្លាម រឿងសីលធម៌ និងរឿងអភិសមាចារទូទៅ ។

ដោយសារគុណសម្បត្តិដ៏ខ្ពង់ខ្ពស់របស់ព្រះនាងដែរ បានជាលោក អាប់ឌុលឡោះហ្ហ៍ អ៊ីបនូ អាប់បាស់[44]សួរព្រះនាងយ៉ាងញឹកញយអំពីរឿងនានាដែលលោកមិនដឹង ។ លោកបានធ្វើសេចក្តីរាយការណ៍ដោយមោទនភាពច្រើនដែរតមកពីព្រះនាង ។ លោកបានថ្លែងថា៖

حَدَّثَتْنَا عَقِيلَتُنَا زَيْنَبُ بِنْتُ عَلِيٍّ...

*"អាគីឡាស្ហ៍ [45] (ពោលគឺ ម្ចាស់ស្ត្រីដ៏ថ្លៃថ្នូរ) របស់យើង ព្រះនាងស្ហៃណាប់ سلام الله عليها ព្រះរាជបុត្រីរបស់អាលី صلوات الله عليه والسلام មានវចនៈប្រាប់យើងថា..."*

សេចក្តីរាយការណ៍មួយ ដែលលោកបានថ្លែងតមកពីព្រះនាងស្ហៃណាប់ عليهم السلام គឺព្រះវចនៈដ៏ល្បីរបស់ព្រះនាង ហ្វាទីម៉ាស្ហ៍ អាស្ហ-ស្ហារ៉អ៊ី سلام الله عليها នៅក្នុងម៉ាស់ឃ្ញិដូរស៊ូលុលឡោះហ្ហ៍ صلى الله عليه وآله وسلم ។

ព្រះនាងស្ហៃណាប់ سلام الله عليها ជាតំណាងរបស់អ៊ីម៉ាំ ស្ហៃន៍ អាល់-អាប៊ីឌីន صلوات الله عليه والسلام ដែរកាលព្រះអង្គទ្រង់ព្រះប្រឈួន ។ ព្រះអង្គមានវចនៈអំពីព្រះនាងថា៖

إِنَّهَا عَالِمَةٌ غَيْرُ مُعَلَّمَةٍ.

*"ព្រះនាងចេះដឹងក្រៃលែង ព្រះនាងមិនត្រូវការអ្នកផ្សេងបង្ហាត់បង្រៀន*

---

[44] អាប់ឌុលឡោះហ្ហ៍ អ៊ីបនូ អាប់បាស់ត្រូវគេចាត់ទុកជាអាជ្ញាធរមួយរូបរបស់អ៊ុមម៉ាត់អ៊ីស្លាមព្រោះលោកចេះដឹងហ្វាឌីស្ហ៍និងច្បាប់អ៊ីស្លាម ។

[45] អាប់ឌុលឡោះហ្ហ៍ អ៊ីបនូ អាប់បាស់តែងតែនិយាយថា "អាគីឡាស្ហ៍របស់យើង" ព្រោះលោកជាសាច់ញាតិមួយរូបរបស់ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم ។

*ព្រះនាងទេ ។"*[46]

ទីបញ្ចប់ ព្រះនាងមានវោហារកោសល្យបំផុតអំពីអ៊ីស្លាម ។ ព្រះនាងអាចធ្វើឲ្យពួកសត្រូវរំភើបចិត្តបាន អាចបែងចែកមតិមហាជនបាន អាចធ្វើឲ្យមហាជនប្រឆាំងរបបអ៊ូម៉ៃយ៉ាស់កាន់អំណាចបាន កាលព្រះនាងថ្លែងសុន្ទរកថាដ៏ល្បីនៅឯគូហ្វាស់និងដាម៉ាស់ ។ ការពិត សុន្ទរកថាទាំងនេះចង្អុលបង្ហាញទៅរកវប្បធម៌ដ៏មានតម្លៃ និងសម្បត្តិអក្សរសិល្បរបស់ព្រះនាង ។

សេចក្តីបន្ថែម អាចលើកមកអធិប្បាយបាននូវចំណុចខាងក្រោមនេះដើម្បីបំភ្លឺមូលហេតុដែលព្រះនាងមានកម្រិតចេះដឹងដាច់គេ គឺ៖

១-ព្រះនាងមានសទ្ធាស៊ប់ចិត្តជានិច្ច អនុវត្តិតាមព្រះបញ្ញានិងព្រះសិក្ខាបទរបស់អល់ឡោះហ្ទ៍ﷻ ។ ដោយខ្លាចក្រែងអល់ឡោះហ្ទ៍ﷻនិងមានសទ្ធាស៊ប់ចិត្ត បុគ្គលបានជោគជ័យក្នុងការចេះដឹងនិងក្នុងសិក្សាដ៏សម្បើម ។ ចំណុចនេះលេចឡើងច្បាស់ទែងនៅក្នុងព្រះបន្ទូលអល់ឡោះហ្ទ៍ﷻ គឺ៖

وَٱتَّقُواْ ٱللَّهَۖ وَيُعَلِّمُكُمُ ٱللَّهُۗ وَٱللَّهُ بِكُلِّ شَيۡءٍ عَلِيمٌ

*ចូរពួកអ្នកក្រែងខ្លាចអល់ឡោះហ្ទ៍ អល់ឡោះហ្ទ៍បង្ហាត់បង្រៀនពួកអ្នក អល់ឡោះហ្ទ៍ទ្រង់ញាណសព្វសារពើ (២:២៨២) ។*

ព្រះនាងស៊ៃណាប់عليها السلامក្រែងខ្លាចអល់ឡោះហ្ទ៍ﷻ មានសទ្ធាស៊ប់ចិត្តក្រៃលែង ដល់ថ្នាក់ព្រះនាងធ្វើការប្រចាំថ្ងៃមួយពេលធំដើម្បីព្រះម្ចាស់ﷻព្រះនាង ព្រះនាងស្មាធិ ចុះចិត្តស៊ប់ក្នុងការអភិវន្ទលើកតម្កើងព្រះម្ចាស់ﷻព្រះនាងក្នុងរយៈពេលដ៏ធំនេះ ។ ពេលយប់ ពេលស្ងាត់ ពេលគេដេកលក់ស្កប់ស្កល់អស់ ព្រះនាងបំបែរមុខនិងចិត្តទៅរកព្រះម្ចាស់ﷻព្រះនាងដោយ

[46] សូមមើលសៀវភៅរបស់លោក អាល់-ត៍្របៀរស៊ី (الطبرسي) *អាល់-អ៊ិះហ្ទ៍ទីយ៉ាជ្* ទំព័រ ១៦៦ ។

ហូរទឹកភ្នែក ដោយចិត្តក្រែងខ្លាច ដោយអារម្មណ៍សង្ឃឹម ទូលព្រះអង្គ﷿ ថា៖

يَا مَنْ لَبِسَ العِزَّ وَتَرَدَّى بهِ وَتَعَطَّفَ بالمجَدِ وَتحَلَّى بهِ، أسْأَلُكَ بمِعَاقِدِ العِزِّ مِن عَرشِكَ وَمُنتَهى الرَّحمْةِ مِن كِتابِكَ وَباِسمْكَ الأعْظَم وَجَدَّكَ الأعْلى وَكَلِماتِكَ التَّامَّاتِ الَّتي تمَّتْ صِدقاً وعَدلاً أنْ تُصَلّيَ عَلى محَمَّدٍ وَآلِ محُمَّدٍ الطَّيّبين الطَّاهِرينَ وَأنْ تجَمعَ لي خَيرَيِ الدُّنيا وَالآخِرَةِ.

*"ឱព្រះដែលស្អិតស្អាងនិងតាក់តែងព្រះអង្គ﷿ឯង ដោយសេចក្តីក្លាហាន ។ ឱព្រះដែលហ៊ានគ្របដណ្តប់ព្រះអង្គ﷿ឯងដោយភាពរុងរឿង ។ ខ្ញុំម្ចាស់សូមលន់តួអង្វរព្រះអង្គ﷿ ក្នុងព្រះនាមនៃព្រះរាជអាសនៈនៃរាជបល្ល័ង្កព្រះអង្គ﷿ ក្នុងព្រះនាមនៃព្រះមេត្តាធម៌ក្នុងព្រះគម្ពីរព្រះអង្គ﷿ ក្នុងព្រះនាមព្រះអង្គដ៏មហាថ្កុំថ្កើងបំផុត ក្នុងព្រះនាមនៃព្រះមហិទ្ធារាសីនៃព្រះអង្គ﷿ និងក្នុងព្រះនាមនៃព្រះបន្ទូលសុក្រឹតឥតខ្ចោះនៃព្រះអង្គ﷿ ដែលបានសម្រេចឡើងយ៉ាងពិតប្រាកដនិងយ៉ាងសុចរិត សូមព្រះអង្គ﷿ព្រះរាជទានព្រះពរជ័យដល់មូហាំម៉ាដ់ﷺ និងព្រះរាជកុលដ្ឋានរបស់មូហាំម៉ាដ់ﷺ សូមព្រះអង្គ﷿ជួយឲ្យខ្ញុំម្ចាស់បាននូវផលល្អក្នុងលោកនេះនិងលោកមុខ ។"*

២-ព្រះនាងស្សៃណាប់(سلام الله عليها)ល្បីល្បាញ ព្រោះព្រះនាងមានប្រាជ្ញាឥតប្រៀបបាន ព្រោះព្រះនាងមានយោបល់ជំទាស់និងមានគតិបណ្ឌិតខ្ពង់ខ្ពស់ ។ ពាក្យពេជន៍ព្រះនាងត្រូវជ្រើសរើសសម្រិតសម្រាំងដោយប្រយ័ត្ន ហើយត្រូវចងក្រងឡើងជាកម្រងត្បូងគជ់ ចំណែកឯយោបល់ព្រះនាងតម្រង់រកគោលដៅ ។ ព្រះនាងជាឧត្តមគតិនៃវោហារកោសល្យនិងមនោសញ្ចេតនា ។ អល់ឡោះហ៍﷿បានប្រទានអភិញ្ញាកំពូល សីលធម៌ ស្មារតីរឹង ការចុះចិត្តស៊ប់និងអភិសមាចារ ឲ្យព្រះនាង ។ នេះមិនអ្វីប្លែកទេ ពីព្រោះព្រះនាងជាព្រះនត្តាស្ត្រីរបស់ព្រះសាស្តាﷺ ជាព្រះរាជបុត្រីរបស់ព្រះមាតាបិតាគំរូនៃអ៊ីស្លាម ជាព្រះអនុជារបស់ព្រះអគ្គប្រមុខទាំងពីរអង្គ

របស់យុវជនឋានសួគ៌ ។ ព្រះនាងមានមោទនភាពចំពោះព្រះអយ្យកោព្រះនាងបំផុត ដោយមានវចនៈថា៖

وَمَن كَجَدِّي النَّبِيِّ العَرَبِيِّ الهاشِمِيِّ القُرَشِيِّ الَّذي اصطَفاهُ اللهُ تَعالى وَاختارَه لِيُبَيِّنَ للنّاسِ طَريقَ الحَياةِ مِن خَيرٍ وشَرٍّ في أسْلوبِه العَذِبِ الجَميلِ وعِبارَتِه الطَّلية المُمتِعَة الّتي تَفيضُ رِقَّةً وَحناناً وعَطفاً وإشْفاقاً.

*"ពុំមានអ្នកណាដូចព្រះអយ្យកោខ្ញុំទេ ព្រះសាស្តាﷺអារ៉ាប់ ព្រះសាស្តាﷺហាស្ហុីម ព្រះសាស្តាﷺគូរ៉យស្ហ៍ដែលត្រូវអល់ឡោះហ៊ូ تعالى ជ្រើសរើសដើម្បីដឹកនាំមនុស្សឲ្យដឹងផ្លូវល្អនិងផ្លូវអាក្រក់នៅលើមាគ៌ាជីវិត ។ ព្រះអង្គﷺបានអនុវត្តិទង្វើទាំងនេះដោយប្រើវិធីប្រសើរជាទីគាប់ចិត្ត ដោយប្រើពាក្យពេជន៍ពោរពេញដោយសេចក្តីទន់ភ្លន់ ដោយសេចក្តីផ្អែមល្ហែម ដោយសេចក្តីសមគួរនិងដោយធម៌សន្តោស ។"*[47]

៣-គូស្វាមីភរិយាដែលចេះដឹងអុីស្លាមបំផុត - ព្រះបិតានិងព្រះមាតាព្រះនាង - បានបង្ហាត់បង្រៀនព្រះនាង ។ ដូច្នេះ ជាធម្មតាទេដែលសិស្សប្រកបដោយលក្ខណៈបុគ្គលប្រភេទនេះនឹងឆ្លាតវាងវៃ និងមានប្រាជ្ញាដែរនោះ ។

អំពីប្រាជ្ញាមុតនិងសុខុមប្បញ្ញា (គឺប្រាជ្ញាល្អិត ឈ្លាសវៃ) របស់ព្រះនាងស៊ៃណាប់ سلام الله عليها យើងសូមលើកយកនូវសេចក្តីរាយការណ៍ខាងក្រោមនេះកត់ត្រាដោយលោក អុីបនូ ហ្ជូម៉ៃដ៍ នៅក្នុងសៀវភៅលោក *អាល់-មុសណាដ៍* និងដោយលោក *អាល់-យ៉ាហ្វុីអុី* (اليافعي) នៅក្នុងសៀវភៅរបស់លោក *មីរ៉ាត់ អាល់-ស្សាម៉ាន* (مرآة الزمان) គឺ៖ "ថ្ងៃមួយ អុីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام និងអុីម៉ាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام បានពិភាក្សាគ្នា អំពីព្រះវចនៈរបស់ព្រះអយ្យកោព្រះអង្គទាំងពីរថា៖ "ហាឡាល់ប្រចក្ស ឯហារ៉ាំក៏ប្រចក្សដែរ តែអ្វីដែលនៅរវាងទាំងពីរនេះ មានរឿងសង្ស័យច្រើនដែលមនុស្ស

---

[47] សូមមើលសៀវភៅរបស់លោក មូសា មូហ៊ាំម៉ាដ៍ អុាលី *អាល់-សៃយីដាស្ស៊ៃណាប់* ទំព័រ ៦៩ ។

ភាគច្រើនមិនដឹង ។ ដើម្បីចៀសវាងរឿងសង្ស័យទាំងនេះ គឺបំពេញករណីយកិច្ចខ្លួនដើម្បីសាសនានិងសេចក្តីថ្លៃថ្នូរ រីឯធ្លាក់ទៅក្នុងរឿងសង្ស័យបែបនេះគឺមុជក្បាលទៅរកហារ៉ាំ ។ គង្វាលចៀមដែលឲ្យចៀមស៊ីស្មៅនៅជុំវិញជម្រក វានឹងស៊ីស្មៅនៅក្នុងជម្រកនោះយ៉ាងម៉ឺងម៉ាត់ ។ អាណាចក្រនីមួយៗមានជម្រកមួយ ព្រះជម្រករបស់អល់ឡោះហ្ទ៍عزوجلគឺការចៀសវាងអ្វីដែលព្រះអង្គعزوجلចាត់ទុកថាមិនស្របច្បាប់ ។ នៅក្នុងខ្លួនមនុស្សនីមួយៗក៏មាននូវប៉ែកមួយដែរ ពេលប៉ែកនេះល្អខ្លួនទាំងមូលក៏នឹងល្អដែរ ពេលប៉ែកនេះអាក្រក់ ខ្លួនទាំងមូលក៏នឹងអាក្រក់ដែរ ។ ប៉ែកនោះគឺបេះដូង (ចិត្ត) ។" [48]

ព្រះនាងស៊ៃណាប់سلام الله عليهاបានអធិប្បាយបំភ្លឺហាឌីស្ទនេះថា៖ "ហាសាន់صلوات الله عليه والسلامហ៊ូសៃន៍صلوات الله عليه والسلامអឺយ សូមស្តាប់ខ្ញុំម្ចាស់! ព្រះអយ្យកោរបស់ព្រះរៀមទាំងពីរ ព្រះសាសនៈទូតﷺរបស់អល់ឡោះហ្ទ៍عزوجل ទទួលបាននូវអភិសមាចារមកពីព្រះម្ចាស់عزوجل ។ អល់ឡោះហ្ទ៍عزوجلជាអ្នកអប់រំព្រះអង្គយ៉ាងសុក្រឹតឥតខ្ចោះ ។ អំពីរឿងនេះ ព្រះសាស្តាﷺមានព្រះវចនៈថា៖ "ព្រះម្ចាស់عزوجلខ្ញុំﷺបានអប់រំខ្ញុំﷺ ព្រះអង្គعزوجلបានអប់រំបានសម្រេចយ៉ាងសុក្រឹតឥតខ្ចោះ ។" ពុំមានអ្នកណាដូចព្រះអយ្យកោខ្ញុំម្ចាស់ទេ ព្រះសាស្តាអារ៉ាប់ ព្រះសាស្តាហាស៊ីម ព្រះសាស្តាគូរ៉យស៍ដែលត្រូវអល់ឡោះហ្ទ៍عزوجلជ្រើសរើសដើម្បីដឹកនាំមនុស្សទៅរកមាគ៌ាជីវិតរបស់ខ្លួនដែលបែកជាសាខាល្អ និងសាខាអាក្រក់ ព្រះអង្គﷺបានអនុវត្តិទង្វើទាំងនេះដោយប្រើវិធីប្រសើរជាទីគាប់ចិត្ត ដោយប្រើពាក្យពេជន៍ពោរពេញដោយសេចក្តីទន់ភ្លន់ ដោយសេចក្តីផ្អែមល្ហែម ដោយសេចក្តីសមគួរនិងដោយធម៌សន្តោស ។ ហាឡាល់ប្រចក្ស ឯហារ៉ាំក៏ប្រចក្សដែរ តែអ្វីដែលនៅរវាងទាំងពីរនេះមានរឿងសង្ស័យច្រើន ។ ដោយហេតុនេះ សាសនាមានបីកម្រិតគឺ៖ ហាឡាល់ ហារ៉ាំ និងប្រការសង្ស័យ ។ ហាឡាល់គឺអ្វីដែលអល់ឡោះហ្ទ៍عزوجلចាត់ទុកថាស្របច្បាប់តាមរយៈលាយលក្ខណ៍អក្សរនៅក្នុងព្រះគម្ពីរគួរអាន ឬតាម

---

[48] ហាឌីស្ទនេះត្រូវបានកត់ត្រាទុកដោយលោក អាល់-ប៊ូខ៉ារី នៅក្នុង *អាល់-ស្ទ៍ហ៊ិះហ៍* របស់លោក ។

រយៈសេចក្ដីអធិប្បាយរបស់ព្រះសាស្ដាﷺ ដូចជាការជួញដូរត្រូវច្បាប់និងការប្រគល់របស់ឲ្យគេវិញជាដើម...។ ហ្វារ៉ាំគឺអ្វីដែលអល់ឡោះហ្ទ៍ﷻចាត់ទុកថាខុសច្បាប់នៅក្នុងព្រះគម្ពីរគួរអាន។ វាផ្ទុយពីហ្ទាឡាល់ដែរ។ ប្រការសង្ស័យគឺអ្វីៗដែលមិនដឹងថាជាហ្ទាឡាល់ ឬ ជាហ្ទារ៉ាំទេ។ អ្នកមានសទ្ធាជ្រះថ្លា ដែលប៉ងប្រាថ្នាប្រកបដោយសុភមង្គលនៅក្នុងលោកនោះនិងប្រកបដោយបរមសុខក្នុងលោកមុខ ត្រូវតែប្រតិបត្តិប្រការទាំងអស់ដែលអល់ឡោះហ្ទ៍ﷻដាក់មក ត្រូវតែអនុចរតាមមាគ៌ាដែលព្រះគម្ពីរគួរអានគួសឲ្យ ត្រូវយកព្រះអយ្យកោខ្ញុំម្ចាស់ ព្រះសាស្ដាﷺ ជាគំរូ ត្រូវចៀសឆ្ងាយពីប្រការសង្ស័យតាមដែលអាចធ្វើបាន។ ដើម្បីចៀសវាងប្រការសង្ស័យ ត្រូវបំពេញករណីយកិច្ចខ្លួនរឿងសាសនា និងសេចក្ដីថ្លៃថ្នូរ ហើយត្រូវបំពេញករណីកិច្ចខ្លួនឲ្យបរិសុទ្ធ សម្រាប់រឿងទាំងពីរនេះដែរ។ ករណីយកិច្ចខ្លួននេះ នាំឲ្យការគោរពបង្គាប់យ៉ាងស្មោះចំពោះព្រះម្ចាស់ﷻ បានសម្រេច។

أَلَا لِلَّهِ الدِّينُ الْخَالِصُ

*អល់ឡោះហ្ទ៍ជាម្ចាស់នៃជំនឿស្មោះអស់ពីចិត្ត (៣៩:៣)។*

រីឯបណ្ដាអ្នកដែលតាមគន្លងសង្ស័យ ពុំមានសន្តិសុខទេព្រោះពួកគេអាចរអិលជើងបាន ដូច្នេះ ពួកគេអាចប្រព្រឹត្តិអំពើខុសច្បាប់បាន។ មានជម្រកមួយនៅក្បែរអ្វីៗដែលគេមាន។ ក៏ប៉ុន្តែជម្រករបស់ព្រះមហារាជាﷻរបស់សព្វសារពើអាចរកបាន ដោយចៀសវាងធ្វើអ្វីដែលព្រះអង្គﷻចាត់ទុកថាខុសច្បាប់។ ព្រះសាស្ដាﷺមានព្រះវចនៈថា៖ "ចៀសវាងអំពើខុសច្បាប់អស់លោកនឹងទៅជាអ្នកមានសទ្ធាស៊ប់ចិត្តបំផុត។" អល់ឡោះហ្ទ៍ﷻបានដាក់នៅក្នុងខ្លួនមនុស្សគ្រប់រូបនូវត្បូងដ៏តូចមួយ ពេលវាល្អ អង្គប្រាណទាំងមូលល្អ បរិសុទ្ធ ជ្រះស្អាតពីភាពកខ្វក់ ជ្រះស្អាតពីការអន់ថយ ជ្រះស្អាតពីអំពើល្មើសព្រះបង្គាប់របស់ ព្រះម្ចាស់ﷻពិភពទាំងពួង។ នេះគឺបេះដូង (គឺចិត្ត)។ បើបេះដូង (គឺចិត្ត) របស់មនុស្សនោះល្អ មនុស្សនោះនឹងយកចិត្តទុកដាក់នឹងរឿងសាសនារបស់ខ្លួន និងគោលការណ៍នៃច្បាប់សាសនា ហើយមនុស្សនោះនឹងបានឃើញនូវសុភមង្គលពិត ដោយនៅ

យ៉ាងខ្ជាប់ខ្ជួនក្នុងពន្លឺមគ្គទេសក៍ នៃព្រះគម្ពីរគួរអាននិងព្រះស៊ូណាស់ ។ បណ្ដាអ្នកដែលអនុចរតាមមាគ៌ាត្រង់ត្រូវ និងតាមបង្គាប់របស់អល់ឡោះហ៍ﷻទាំងនេះ អ្នកទាំងនោះនឹងនៅក្នុងចំណោមអ្នកជោគជ័យថ្ងៃរស់ពីស្លាប់វិញ ។ ជីវិតគ្រាន់តែជាជំណាក់មួយ ក្នុងចំណោមដំណាក់ច្រើនទៀត ដែលនាំទៅកាន់ឋានសួគ៌ឬឋាននរក ។ ការស្លាប់ជាអវសានការស្ដីបន្ទោសពុំអាចធ្លាក់មកបានទេក្រោយពីនេះ ។ ពុំមានអ្វីឡើយក្រោយពីលោកនេះ លើកលែងតែឋានសួគ៌ឬឋាននរក ។" ព្រះនាងមានវចនៈចប់ អ៊ីម៉ាំអាល់-ហ៊្វសៃន៍صلوات الله عليه والسلامមានវចនៈប្រាប់ព្រះនាងថា៖ "ព្រះនាងអស្ចារ្យណាស់ ! ព្រះនាងប្រាកដជានៅក្នុងពង្សាវលីនៃព្រះសាស្ដានិងនៅក្នុងបណ្ដូលព្រះរាជសារមែន ។"

សព្វមួយដង ព្រះនាងមានវចនៈថា៖ "ព្រះអយ្យកោﷺខ្ញុំបានសម្រេចឲ្យយើង (ពោលគឺ ស្ត្រី) មានសិទ្ធិដែលជាភារកិច្ចរបស់ស្វាមីយើង ដូចព្រះអង្គﷺបានសម្រេចឲ្យស្វាមីយើងមានសិទ្ធិដែរ ដែលជាភារកិច្ចរបស់យើងដែរ ។ ព្រះគម្ពីរគួរអានចែងថា៖

وَلَهُنَّ مِثْلُ ٱلَّذِى عَلَيْهِنَّ بِٱلْمَعْرُوفِ ۚ وَلِلرِّجَالِ عَلَيْهِنَّ دَرَجَةٌ ۗ وَٱللَّهُ عَزِيزٌ حَكِيمٌ

*ឯបណ្ដាពួកនាងមានសិទ្ធិស្មើនឹង អ្វីដែលជាកាតព្វកិច្ចរបស់ពួកនាងដោយសមរម្យតាមរបៀប [ដោយគោរពច្បាប់អល់ឡោះហ៍] ។ បណ្ដាបុរស (ជាស្វាមី) នោះមានឯកសិទ្ធិលើសពួកនាង (មួយឋានៈទៀត នោះគឺឋានៈជាអ្នកត្រូវបីបាច់រក្សាមើលថែទាំ) (២:២២៨) ។*

ព្រះអយ្យកោﷺដ៏ថ្លៃថ្លារបស់ខ្ញុំមានព្រះវចនៈដែរថា៖ "ស្ត្រីណាដែលបំពេញស្វ៍ឡាត់ចាំបាច់ទាំងប្រាំ ដែលកាន់សីលត្រណមក្នុងខែកាន់សីលត្រណម ដែលរក្សាសេចក្ដីបរិសុទ្ធ ដែលគោរពស្វាមី ស្ត្រីនោះមានជម្រើសចូលទៅក្នុងឋានសួគ៌តាមទ្វារមួយណាក៏បាន ។"

លោកអ៊ីបនូ អាស្សាកៀរ បានកត់ត្រានៅក្នុងសៀវភៅលោក *អាល់-តារីក្ខ* ថា៖ "បន្ទាប់ពីបានទៅដល់ប្រទេសអេស៊ីបត៍ ព្រះនាងស្ងៀណាប់មិនស្រួលព្រះកាយ ។ អភិបាលប្រទេសអេស៊ីបត៍បាននាំគ្រូពេទ្យមកព្យាបាល

ព្រះនាង តែព្រះនាងបដិសេធដោយមានវចនៈថា៖ "យើងនៅក្នុងចំណោមបុគ្គលដែលមិនប្រាថ្នាលោកនេះ និងនិវន្តកម្មក្នុងលោកនេះទេ ។ យើងជាព្រះរាជកុលដ្ឋាន ﷺ របស់ព្រះសាស្តា ជំនួបជាស្រឡាញ់បំផុតរបស់យើងគឺជំនួបនឹងព្រះម្ចាស់ ﷻ យើង ។ គ្រូពេទ្យមិនអាចផ្លាស់ប្តូរកាលបរិច្ឆេទនៃការស្លាប់របស់បុគ្គលបានទេ ។"

លោក អ៊ីបនូ ហ្វ៊ម៉ៃដ៍ លោក អ៊ីបនូ អាប៊ូ អាស៊ីម (أبو عاصم) និងលោក អ៊ីបនូ អាប៊ី ស្ហៃបាស់ (ابن أبي شيبة) បានតំណាលថា ថ្ងៃមួយព្រះនាងស្ហៃណាប់ سلام الله عليها បានសូត្រព្រះបន្ទូលអល់ឡោះហ្ទ ﷻ ៖

يَـٰٓأَيُّهَا ٱلْمُزَّمِّلُ ... وَطَآئِفَةٌ مِّنَ ٱلَّذِينَ مَعَكَ

*អ្នកដណ្តប់សំលៀកបំពាក់អើយ ... និងជនមួយចំនួន[ដែរ]ដែលតាមអ្នក ។ (៧៣:១...២០)*

ព្រះនាងបានអធិប្បាយថា៖ "សូមអរព្រះគុណអល់ឡោះហ្ទ ﷻ យើងនៅក្នុងបក្សនេះ (គឺនៅក្នុងចំណោមអ្នកដែលនៅជាមួយព្រះសាស្តា ﷺ) ។"

ការសន្ទនាជាសាធារណៈរបស់ព្រះនាងស្ហៃណាប់ سلام الله عليها លើសពីមួយដងជាភ័ស្តុតាងបញ្ជាក់វោហារកោសល្យនិងការពូកែចរចា ។ ពាក្យពេជន៍ទាំងនេះបានធ្វើឲ្យមតិសាធារណៈជនផ្លាស់ប្តូរបែរប្រឆាំងយ៉ាស៊ីដ្ និងរដ្ឋអ៊ូម៉ៃយ៉ាស់ ហើយបង្ហាញឲ្យឃើញនូវគោលដៅពិតនៃបដិវត្តន៍របស់អ៊ីម៉ាំអាល់-ហ្វ៊ូសៃន៍ صلوات الله عليه والسلام ។ យើងថ្លែងលម្អិតអំពីពាក្យពេជន៍ទាំងនេះនៅខាងមុខ ។

ព្រះនាងស្ហៃណាប់ سلام الله عليها មានឋានន្តរបុណ្យស័ក្តិពិសេស ផ្នែកអធិធម្ម (គឺការកាន់សីលតឹងរ៉ឹង) ។ អាឡាម៉ាស់ អាល់-ប៊ូរក៉ានី បានថ្លែងអំពីរឿងនេះថា៖ "លំដាប់ថ្នាក់ផ្នែកសាសនារបស់ព្រះនាងស្ហៃណាប់ سلام الله عليها ស្ទើរតែស្មើនឹងលំដាប់ថ្នាក់ផ្នែកសាសនារបស់អ៊ីម៉ាំអវិរុទ្ធឥតខ្ចោះ..."

លោក អាល់-រ៉ាហ៊ន់ឌី បានថ្លែងនៅក្នុងសៀវភៅលោក *អាល់-ទីរ៉ស៍ អាល់-មុស្ហាប់ (الطراز المذهب)* ថា៖ "ថែមទាំងមានលំដាប់ថ្នាក់ធម៌ខ្ពស់ ព្រះនាងស្ហៃណាប់ سلام الله عليها មានព្រហ្មចរិយភាពបន្ទាប់ព្រះមាតាព្រះនាង មានគុណសម្បត្តិខ្ពស់ មានលក្ខណៈពិសេស មានភាពសម្បើមគួរឲ្យគោរព ប្រកប

ដោយអភិញ្ញា ប្រកបដោយអរិរុទ្ធភាព បរិសុទ្ធ ប្រកបដោយភាពត្រចះត្រចង់ ប្រកបដោយរស្មី ប្រកបដោយកិត្តិយស និងប្រកបដោយវិរោចនភាព ។"

លោក មូហ៊ាំម៉ាដ់ រីដ្ធ៏ អាល់-អ៊ីស្វហ្វាហ្វានីបានថ្លែងនៅក្នុងសៀវភៅលោក *យ៉ាន់ណាត់ អាល់-ឃូលុដ្ធ* ថា៖ "ព្រះនាងស្វៃណាប់سلام الله عليهاមានវោហារកោសល្យ មានការកាន់វត្តប្រតិបត្តិខ្ពស់ មានស្មារតីគ្រប់គ្រង និងមានសេចក្តីក្លាហានទៀបមាតាបិតារបស់ព្រះនាង ។ ក្រោយពីអ៊ីម៉ាំអាល់-ហ៊្វូសែន៍صلوات الله عليه والسلامបានទទួលទុក្ករកម្ម ព្រះនាងជាណាអាព្យាបាលរបស់សមាជិកព្រះរាជកុលដ្ឋាន ម្យ៉ាងទៀត ជាអាណាព្យាបាលរបស់ត្រកូលហ្វាស្ស៊ីម ។"

លោក អ៊ីបនូ អាន់សាប់ បានថ្លែងនៅក្នុងសៀវភៅលោក អាន់សាប់ អាល់-ត៏លីប៊ីយីន (أنساب الطالبيين) ថា៖ "ព្រះនាងស្វៃណាប់سلام الله عليهاលេចត្រដែតដាច់គេអាស្រ័យគុណសម្បត្តិច្រើនរាប់មិនអស់ ព្រះនាងមានគុណសម្បត្តិខ្ពង់ខ្ពស់ មានលក្ខណៈសម្បត្តិជាទីគោរព មានឫកពាគួរឲ្យកោតសរសើរ មានសម្មានភាពអស្ចារ្យ និងប្រកបដោយសេចក្តីបរិសុទ្ធប្រចក្សជាក់ស្តែង ។"

## ព្រះអាពាហ៍ពិពាហ៍

ពេលព្រះនាងស្វៃណាប់سلام الله عليهاគ្រប់វ័យ បណ្តាបុរសល្បីៗប្រជែងគ្នាសូមចងស្ពានមេត្រីព្រះនាង ។ ក៏ប៉ុន្តែព្រះបិតាព្រះនាងបដិសេធបុរសទាំងនោះ ។

អាប់ឌុលឡោះហ្វ៍ ប៊ិន យ៉ាក់ហ្វារ៍ ប៊ិន អាប៊ូ ត៏លិប ក៏បានសូមចងស្ពានមេត្រីព្រះនាងដែរ ។ ព្រះអង្គជាបុរសហ្វាស្ស៊ីមថ្លៃថ្នូរបំផុតមួយរូប ហើយជាអ្នកមានសប្បុរសធម៌អារ៉ាប់មួយរូប ។ម្យ៉ាងទៀត អ៊ីម៉ាំអាលីصلوات الله عليه والسلام ស្រឡាញ់ព្រះអង្គណាស់ ។ ដូច្នេះព្រះអង្គصلوات الله عليه والسلامព្រមទទួលការស្តីដណ្តឹងរបស់ព្រះអង្គ ព្រមអភិសេកព្រះនាងស្វៃណាប់سلام الله عليهاជាមួយព្រះអង្គ ។
បិតារបស់អាប់ឌុលឡោះហ្វ៍ គឺយ៉ាក់ហ្វារ៍ដែលគេបានរៀបរាប់ថាមាន

សីលធម៌និងចរិតមារយាទស្រដៀងព្រះសាស្តាﷺ[49] ។ ព្រះអង្គនៅក្នុងចំណោមបុគ្គលដំបូងបង្អស់ដែលចូលសាសនាអ៊ីស្លាម និងការពារសាសនាអ៊ីស្លាម ។ ព្រះអង្គបានភៀសខ្លួនពីរដង - ម្តងទៅកាន់ប្រទេសអេត្យូពី (الحبشة) បន្ទាប់ពីនោះទៅកាន់ម៉ាឌីណាស្ស៊ំ គេស្គាល់ព្រះអង្គច្បាស់ថាព្រះអង្គជាបុគ្គលចុះចូលស៊ប់ចិត្ត និងមានសេចក្តីអាណិតមេត្តាចំពោះជនក្រីក្រនិងតោកយ៉ាក ។ ដូចព្រះរៀមព្រះអង្គដែរ គឺអ៊ីម៉ាំមុាំអាលីصلوات الله عليه والسلام ព្រះសាស្តាﷺរបស់អល់ឡោះហ្ ់عز وجل គោរពរាប់អានយ៉ាក់ហ្វារ៍ណាស់ ព្រះអង្គﷺបានឲ្យព្រះអង្គតាំងទីលំនៅក្បែរម៉ាស់យិដព្រះអង្គﷺ ព្រោះព្រះអង្គﷺដឹងថាយ៉ាក់ហ្វារ៍ មានជំនឿមាំហើយតាំងចិត្តលះបង់ជីវិតដើម្បីអ៊ីស្លាម ។

ក្នុងឆ្នាំទី ៨ ហ៊ីជ្រ៉ោះគ័សករាជ ព្រះសាស្តាﷺបានតែងតាំងយ៉ាក់ហ្វារ៍ជាមេបញ្ជាការទ័ពមុស្លីមក្នុងសមរភូមិមុតាស្ស៊ំ (مؤتة) ។ យ៉ាក់ហ្វារ៍ទទួលទុក្ករកម្មនៅក្នុងសមរភូមិនេះ ដៃទាំងពីររបស់ព្រះអង្គត្រូវកាត់ដាច់ព្រោះព្រះអង្គបានកាន់ទង់យ៉ាងខ្ជាប់ខ្ជួន ។ ព្រះសាស្តាﷺបានថ្លែងអំពីព្រះអង្គថា៖ "អល់ឡោះហ្ ់تعالى នឹងឲ្យយ៉ាក់ហ្វារ៍នូវស្លាបពីរ លោកនឹងហោះនៅក្នុងឋានសួគ៌គ្រប់ទីកន្លែងតាមតែចិត្តលោក ជាជំនួសដៃទាំងពីររបស់លោកដែលត្រូវគេកាត់ ។"

ដូច្នេះហើយបានជាគេហៅយ៉ាក់ហ្វារ៍ថា "ស៊្ទុល យ៉ាណាហ៉ៃន៍" (ស្លាបពីរ) ។ ទុក្ករកម្មរបស់យ៉ាក់ហ្វារ៍ជាទុក្ខសោកដ៏ធ្ងន់មួយរបស់ព្រះសាស្តាﷺ ។ ដូច្នេះហើយបានជាព្រះអង្គﷺមានព្រះវចនៈថា៖ "ការយំសោកស្តាយយ៉ាក់ហ្វារ៍មិនត្រូវឈប់ឈរទេ ព្រមទាំងបុគ្គលដូចលោកដែរ[50] ។"

មាតារបស់អាប់ឌុលឡោះហ្ ់គឺ មហាស្ត្រី អាស់ម៉ាក់ ប៊ិនទី អ៊ុម៉ៃស៍

[49] សូមមើលសៀវភៅលោក អ៊ីបនូ ហាយ៉ារ អាល់-អាស់ក៏ឡានី (بن حجر العسقلاني) *អាល់-អ៊ីសទីអាប់ ហ្វី ម៉ាក់រីហ្វាស្ស៊ំ អាល់-អាស្ស៊ហាប់* ក្បាលទី ១ ទំព័រ ២៤២ ។

[50] សូមមើលសៀវភៅលោក អ៊ីបនូ ហាយ៉ារ អាល់-អាស់ក៏ឡានី (بن حجر العسقلاني) *អ៊ុសដ៏ អាល់-ក៏បាស្ស៊ំ ហ្វី ម៉ាក់រីហ្វាស្ស៊ំ អាល់-ស្ស៊ហាបាស្ស៊ំ (أُسْدُ الغَابَة فِي مَعْرِفَةِ الصَّحَابة)* ក្បាលទី ១ ទំព័រ ២៨៩ ។

(أَسْمَاء بِنْت عُمَيْس) ។ ព្រះនាងនៅក្នុងចំណោមបុគ្គលដែលបានចូលសាសនាអ៊ីស្លាមពីដំបូង ។ ព្រះនាងបានភៀសខ្លួនតាមស្វាមីព្រះនាងទៅឯប្រទេសអេត្យូពី ព្រះនាងបានប្រសូត អាប់ឌុលឡោះហ្វ៍, អោន៍ និង មូហាំម៉ាដ់ នៅឯប្រទេសនេះ ។ បន្ទាប់មកព្រះនាងបានភៀសខ្លួនទៅកាន់ម៉ាឌីណាស់ ។ ក្រោយពីយ៉ាក់ហ្វារ៍បានទទួលទុក្ករកម្ម ព្រះនាងបានរៀបអភិសេកជាមួយអាប៊ូ បាការ ហើយបានបុត្រមួយឈ្មោះមូហាំម៉ាដ់ដែលជាបុរសដ៏ល្បីមួយរូបរបស់អ៊ីស្លាម ។ ពេលអាប៊ូ បាការស្លាប់ អ៊ីម៉ាំអាលី អាមីរុល-មុមីនីនបានរៀបអភិសេកជាមួយព្រះនាង បានបុត្រមួយឈ្មោះយ៉ាស់យ៉ា[51] ។

ព្រះនាងអាស់ម៉ាក់គាំទ្រអាស្ហ់លុល-បៃត៍ﷺដោយស្មោះ ហើយមានទំនាក់ទំនងជិតដិតជាមួយព្រះនាងហ្វាទីម៉ាស់ អាស់-ស្សារ៉អ៍ﷺ ។ ព្រះនាងបានធ្វើសេចក្តីរាយការណ៍ហាឌីស្សប្រមាណហុកសិប តផ្ទាល់មកពីព្រះសាស្តាﷺ ។

ពេលព្រះនាងបានមករស់នៅរួមលំនៅជាមួយអ៊ីម៉ាំអាលីﷺ ក្នុងឋានៈជាព្រះមហេសីរបស់ព្រះអង្គﷺ ព្រះនាងថ្នាក់ថ្នមអ៊ីម៉ាំអាល់-ហាសាន់ អ៊ីម៉ាំអាល់-ហ៊ូសៃន៍និងព្រះនាងសៃណាប់ﷺដូចមាតាបង្កើត ។ ដូច្នេះហើយបានជា ព្រះអង្គទាំងបីចូលចិត្តការបីបាច់ថ្នាក់ថ្នមរបស់ព្រះនាង ។ ដូច្នេះព្រះនាងជាគំរូនៃព្រហ្មចរិយភាព ជាគំរូនៃសេចក្តីបរិសុទ្ធ និងជាគំរូនៃសេចក្តីស្មោះត្រង់ចំពោះអាស្ហ់លុល-បៃត៍ﷺ ។

អាប់ឌុលឡោះហ្វ៍ អ៊ីបនូ យ៉ាក់ហ្វារ៍ជាវរបុរសឆ្នើមបំផុត ដល់ថ្នាក់ទោះបីពួកសត្រូវរបស់ព្រះអង្គ ក៏មិនអាចអត់កោតសរសើរលក្ខណៈបុគ្គលឥតប្រៀបផ្ទឹមបានរបស់ព្រះអង្គបានឡើយដែរ ។ មូអាវីយ៉ាស់ អ៊ីបនូ អាប៊ូស៊ុហ្វយ៉ានបាននិយាយអំពីព្រះអង្គថា៖ "អាប់ឌុលឡោះហ្វ៍ អ៊ីបនូ យ៉ាក់ហ្វារ៍ជាបុគ្គលដែលសក្តិសមនឹងកិត្តិយសទាំងអស់ ។ លោកជា

[51] សូមមើលសៀវភៅលោក អ៊ីបនូ ហាយ៉ារ អាល់-អាស់ក៏ឡានី (بن حجر العسقلاني) *អ៊ុសដ៏ អាល់-ក៏បាស់ ហ្វី ម៉ាក់រីហ្វាស់ អាល់-ស្ហ៏ហាបាស់ (أُسْدُ الغَابَة فِي مَعْرِفَةِ الصَّحَابَة)* ក្បាលទី ៥ ទំព័រ ២៧១ ។

បុគ្គលមុខគេបង្អស់ក្នុងការធ្វើអំពើថ្លៃថ្នូរនិងប្រកបដោយគុណធម៌[52] ។"

ព្រះអង្គស្មោះត្រង់ចំពោះអាស់លុល-បៃត៍ عليهم السلام ជាទូទៅ និងចំពោះអ៊ីម៉ាំអាល់-ស៊្ហួសៃន៍ صلوات الله عليه والسلام ជាពិសេស ទោះបីព្រះអង្គមិនបានតាមអ៊ីម៉ាំ صلوات الله عليه والسلام ទៅការបាទ្បាអ៊្ក៏ដោយ ។ អ្នកប្រវត្តិសាស្ត្របានធ្វើសេចក្តីរាយការណ៍ថា អាុប់ឌុលឡោះហ្វ៍បានធ្វើពិធីបុណ្យព្រះរាជសពធំបំផុត ឲ្យអ៊ីម៉ាំអាល់-ហ៊្សួសៃន៍ صلوات الله عليه والسلام ដែលបានបូជាព្រះជន្ម ទោះបីបុត្រពីររូបរបស់ព្រះអង្គបានបូជាជីវិតដែរក្នុងពេលតែមួយនោះក៏ដោយ ។ ក្នុងពិធីបុណ្យនេះ ទាសៈម្នាក់បានប្រាប់ព្រះអង្គថា៖ "យើងទាំងអស់គ្នាឈឺចាប់ដ៏យូរដោយសារអាល់-សៃន៍ صلوات الله عليه والسلام !"

ពេលបានឮសម្តីនេះ អាុប់ឌុលឡោះហ្វ៍ចោលស្បែកជើងទៅលើទាសៈនោះដោយកំហឹងហើយថា៖ "កូនរបស់បុគ្គលមានទោសអើយ ហេតុអ្វីអ្នកឯងហ៊ាននិយាយបែបនេះអំពីអាល់-ហ៊្សួសៃន៍ صلوات الله عليه والسلام ។ សូមស្បថចំពោះអល់ឡោះហ្វ៍ عز وجل បើខ្ញុំបាននៅជាមួយព្រះអង្គ صلوات الله عليه والسلام ខ្ញុំនឹងមិនចោលព្រះអង្គ صلوات الله عليه والسلام ឡើយមុននឹងខ្ញុំស្លាប់នៅទីនោះ ។ សម្រាប់ខ្ញុំ មិនស្នាក់ស្ទើរទេ ព្រះអង្គ صلوات الله عليه والسلام ជាទីស្រឡាញ់លើសកូនពីរនាក់របស់ខ្ញុំទៅទៀត ។ អ្វីដែលអាចជួយសម្រាលទុក្ខខ្ញុំបាននោះ គឺកូនទាំងពីររបស់ខ្ញុំបានស្លាប់ជាមួយព្រះអង្គ صلوات الله عليه والسلام ដោយមិនត្អូញត្អែរ ឬមិនអន្ទះអន្ទែង ។ សូមអរព្រះគុណអល់ឡោះហ្វ៍ عز وجل ថ្វីបើខ្ញុំមិនបានជួយគាំទ្រអាល់-ហ៊្សួសៃន៍ صلوات الله عليه والسلام ក្នុងសមរភូមិនេះទេក៏ដោយ តែកូនទាំងពីររបស់ខ្ញុំបានជួយគាំទ្រព្រះអង្គ صلوات الله عليه والسلام ។"[53]

គេស្គាល់ច្បាស់អាុប់ឌុលឡោះហ្វ៍ អ៊ីបនូ យ៉ាក់ហ្វារ៍ដែរថាព្រះអង្គជាមនុស្សចិត្តទូលាយ ហើយគេបានតំណាលរឿងអស្ចារ្យច្រើនអំពីចិត្តទូលំ

---

[52] សូមមើលសៀវភៅលោក អ៊ីបនូ ហាយ៉ារ អាល់-អាុស់ក៏ឡានី (بن حجر العسقلاني) *អ៊ុសដ៍ អាល់-ក៏បាស់ ហ្វី ម៉ាក់រីហ្វាស់ អាល់-ស៊្ហាបាស់ (أُسْدُ الغَابَة فِي مَعْرِفَةِ الصَّحَابة)* ក្បាលទី ៥ ទំព័រ ១៧១ ។

[53] សូមមើលសៀវភៅរបស់លោក មូហ៊ាំម៉ាដ់ អ៊ីបនូ យ៉ារៀរ អាល់-ត៏បារី (محمد بن جرير طبري) *តារិក អាល់-អ៊ូម៉ាំ វ៉ា អាល់-មុលុក (تاريخ الأمم والملوك)*, ៩:៣៥៧ ។

ទូលាយនេះ ។ នេះពីព្រោះព្រះសាស្តាصلى الله عليه وآله وسلمបានបួងសួងអល់ឡោះហ៍عز وجلសូមឲ្យព្រះអង្គ ទៅជាអ្នកមានទ្រព្យសម្បត្តិជាងគេម្នាក់នៃស្រុកម៉ាឌីណាស្ញ់ ។ ម្យ៉ាងទៀតព្រះអង្គជាបុគ្គលដែលមានគុណសម្បត្តិប្រពៃ ។ ព្រះអង្គបានថ្លែងហាឌីស្សច្រើនតមកពីព្រះបិតុលាព្រះអង្គ (គឺឪពុកមា ឬ ឪពុកធំ) អ៊ីម៉ាំអ៊ាលី អាមីរុល-មុមីនីនصلوات الله عليه والسلام និងបងប្អូនជីតាមួយទាំងពីររបស់ព្រះអង្គ អ៊ីម៉ាំអាល់-ហាសាន់និងអ៊ីម៉ាំអាល់-ហ៊ូសែន៍عليهم السلام ។
ព្រះនាងស្រៃណាប់سلام الله عليهاមានបុត្របួនអង្គ មានបុត្រីមួយអង្គគឺ៖ អ៊ោន៍, អ៊ាលីអាល់-ស្រៃណាប់, មូហាំម៉ាដ្ញ់, អ៊ាប់បាស់ និងព្រះនាង អ៊ូម គុលស៊្សូម ។
អ៊ោន៍ប្រកបដោយគុណសម្បត្តិល្អប្រពៃ និងប្រកបដោយឥរិបថសម្បត្តិប្រពៃ ។ ព្រះអង្គបានតាមព្រះមាតុលា (ឪពុកធំ ឬ ឪពុកមាខាងមាតា) របស់ព្រះអង្គ អ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامទៅប្រទេសអ៊ីរ៉ាក់ ។ ក្នុងសមរភូមិការបាឡាអ៍ អ៊ោន៍បានប្រយុទ្ធយ៉ាងក្លាហានបំផុត ព្រះអង្គបាននាំមោទនភាពមកឲ្យបិតាព្រះអង្គ អ៊ាប់ឌុលឡោះហ៍និងយ៉ាក់ហ្វារ៍ ព្រះអយ្យកោព្រះអង្គ ។ បន្ទាប់ពីបានប្រយុទ្ធយ៉ាងក្លាហានក្នុងជុំទីមួយ អ៊ោន៍ត្រូវបុគ្គលកំណាច អ៊ាប់ឌុលឡោះហ៍ អាល់-ត៏អ៊ី (عبد الله الطائي) វាយប្រហារនិងត្រូវបុគ្គលនោះសម្លាប់ ។[54]
អ្នកអង្គម្ចាស់ អ៊ូម គុលស៊្សូម ព្រះធីតារបស់ព្រះនាងស្រៃណាប់سلام الله عليها ល្បីល្បាញព្រោះនាងមានឆោមសម្រស់ស្អាត មានព្រហ្មចរិយភាពនិងមានលក្ខណៈបុគ្គលប្រពៃ ។ មនុស្សជាទូទៅនិងពួកហាស្ស៊ីមជាពិសេសគោរពព្រះនាងណាស់ ។ ក្នុងបំណងគោលផ្គាប់ផ្គុនរកប្រយោជន៍ពីពួកហាស្ស៊ីមដើម្បីនឹងឲ្យមុស្លីមគោរពខ្លួន មូអ៊ាវីយ៉ាស្ញ់ អ៊ីបនូ អាប៊ូ ស៊ុហ្វយ៉ានបានផ្ញើសំបុត្រទៅ ម៉ារវ៉ាន អ៊ីបនូ អាល់-ហាកាំ អភិបាលស្រុកម៉ាឌីណាស្ញ់ដាក់បញ្ជាឲ្យទៅសូមស្ដីដណ្ដឹងអង្គម្ចាស់ អ៊ូម គុលស៊្សូម រាជព្រះធីតារបស់ព្រះនាងស្រៃណាប់سلام الله عليهاឲ្យយ៉ាស៊ីដ្ឋ កូនប្រុសរបស់ខ្លួន ។
ម៉ារវ៉ាន អ៊ីបនូ អាល់-ហាកាំដឹងថាអ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامច្បាស់នឹង

---

[54] សូមមើលសៀវភៅរបស់លោក អាល់-ស្វៃខ៍ អាល់-មូហ្វីដ្ឋ *អាល់-អៀរស្សាដ្ញ់* ទំព័រ ២៦៨ ។

បដិសេធនិងប្រឆាំងរឿងនេះ ។ ដូច្នេះគាត់បានពន្យារពេលដើម្បីស្វែងរកឱកាសល្អ ។ គាត់ឆ្លៀតយកឱកាសអ៊ីម៉ាំអាល់-ហ៊្វសៃន៍صلوات الله عليه والسلامធ្វើដំណើរប្រញាប់ប្រញាល់ទៅជួប អាុប់ឌុលឡោះហ្ន៍ អ៊ីបនូ យ៉ាក់ហ្វារ៍ ដែលយល់ដឹងរឿងទាំងអស់ ។ ព្រះអង្គបានប្រាប់ម៉ារវ៉ានថាឲ្យរង់ចាំអ៊ីម៉ាំអាល់-ហ៊្វសៃន៍صلوات الله عليه والسلامប្រឡប់មកវិញ ។

លុះអ៊ីម៉ាំصلوات الله عليه والسلامត្រឡប់មកវិញ អាុប់ឌុលឡោះហ្ន៍ប្រញាប់ប្រាប់ព្រះអង្គصلوات الله عليه والسلامឲ្យទ្រង់ជ្រាបរឿងរ៉ាវទាំងអស់ ។ អ៊ីម៉ាំصلوات الله عليه والسلامទ្រង់អភិក្រោធ ព្រះអង្គصلوات الله عليه والسلامបដិសេធដាច់អហង្ការ មិនព្រមឲ្យព្រះភាគិនេយ្យា (ក្មួយស្រី) ព្រះអង្គصلوات الله عليه والسلامក្លាយទៅជាភរិយារបស់មនុស្សអាក្រក់អន្យតិរ្ថិយ តណ្ហាក្រាស់ ចៅរបស់អាប៊ូ ស៊ុហ្វយ៉ាន ជាដាច់ខាត ។ ដូច្នេះព្រះអង្គصلوات الله عليه والسلامប្រញាប់ទៅជួបព្រះអនុជាព្រះអង្គصلوات الله عليه والسلام ព្រះនាងស្ហៃណាប់سلام الله عليها សូមឲ្យព្រះនាងហៅព្រះធីតាព្រះនាង អ៊ូម គុលស៊្ហូម មកជួបព្រះអង្គصلوات الله عليه والسلام ។ ពេលព្រះធីតាមកដល់អ៊ីម៉ាំصلوات الله عليه والسلامបានប្រាប់ថា អាល់-ក៏ស៊ីម បុត្ររបស់មូហាំម៉ាដ់ អ៊ីបនូ យ៉ាក់ហ្វារ៍ បងប្អូនជីដូនមួយ របស់ព្រះនាងសក្តិសមរៀបអភិសេកជាមួយព្រះនាងជាជាង ។ ព្រះមាតាសូមស្វាគមន៍ ព្រះធីតាយល់ព្រម ព្រះបិតាក៏មិនបដិសេធ អ៊ីម៉ាំصلوات الله عليه والسلامបានលើកព្រះនាងឲ្យទៅអាល់-ក៏ស៊ីមជាមួយអំណោយច្រើន ។

ទាំងអស់គ្នាបានរក្សារឿងនេះជាសម្ងាត់លុះដល់យប់រៀបអភិសេក ។ ក្នុងយប់នោះ អ៊ីម៉ាំصلوات الله عليه والسلامបានអញ្ជើញឥស្សរជនច្រើនរូបរួមទាំងម៉ារវ៉ាន អ៊ីបនូអាល់-ហ៊ាកាំដែរដែលគិតថា ការអញ្ជើញនេះជាការប្រកាសរបស់អ៊ីម៉ាំصلوات الله عليه والسلامថាព្រះអង្គصلوات الله عليه والسلامព្រមអភិសេកព្រះភាគិនេយ្យាព្រះអង្គصلوات الله عليه والسلام អ្នកអង្គម្ចាស់ អ៊ូម គុលស៊្ហូម ជាមួយយ៉ាស៊ីដ្ន ។ ដូច្នេះ គាត់បានខកចិត្តពេលអ៊ីម៉ាំصلوات الله عليه والسلامប្រកាសអភិសេក អាល់-ក៏ស៊ីម ជាមួយ អ៊ូម គុលស៊្ហូម ។ ម៉ារវ៉ានបានថ្លែងរឿងនេះប្រាប់មូអាុវីយ៉ាស្ទ៍ដែល ចងគំនុំព្យាបាទជាប់នៅក្នុងចិត្តមកលើអ៊ីម៉ាំصلوات الله عليه والسلام ។ [55]

[55] សូមមើលសៀវភៅ *ស្ហៃណាប់ អាុគ៊ីឡាទូ បានី ហ្វាស៊្ហីម* ទំព័រ ២៧ ។

# លក្ខណៈបុគ្គល

ព្រះនាងស៊ែណាប់سلام الله عليهاប្រកបដោយចំណុចសំខាន់ទាំងអស់ ដែលបញ្ជាក់នូវអភិជនភាពនិងគុណសម្បត្តិប្រសើរ ដែលអល់ឡោះហ្វ៍تعالىបានព្រះរាជប្រទានឲ្យព្រះអយ្យកោព្រះនាង ឲ្យព្រះបិតាព្រះនាង ឲ្យព្រះមាតាព្រះនាង និងឲ្យព្រះរៀមទាំងពីររបស់ព្រះនាង ។ ព្រះនាងទទួលដំណែលលក្ខណៈពិសេសរបស់ព្រះអង្គទាំងអស់عليهم السلام ហើយអនុចរដោយយកតាមគំរូសីលធម៌ខ្ពង់ខ្ពស់របស់ព្រះអង្គទាំងអស់عليهم السلام ។

អាស្រ័យកេរដំណែលអភិសមាចារ និងលក្ខណៈពិសេសឥតប្រៀបបាន ព្រះនាងស៊ែណាប់سلام الله عليهاជាមហាស្ត្រីក្នុងសាសនាអ៊ីស្លាម ព្រោះព្រះនាងជានិមិត្តរូបនៃតម្លៃនិងគោលការណ៍ពិត ។ ដូចព្រះមាតាព្រះនាងដែរ ព្រះនាងស៊ែណាប់سلام الله عليهاប្រយុទ្ធនៅលើមាគ៌ាប្រសើរបំផុត ហើយមានគោលជំហរនឹងមាំ តទល់នឹងក្រុមឃោសនាដែលព្យាយាមប្រើគ្រប់មធ្យោបាយ និងអំណាចដើម្បីបាំងមុខពិតរបស់ពួកប្រធាន និងពួកមគ្គុទេសក៍ដឹកនាំអ៊ុមម៉ាត់អ៊ីស្លាម ។

ដូចមធ្យោបាយរស់ព្រះនាងហ្វាទីម៉ាស់ អាស់-សាស់រ៉អ៍سلام الله عليهاដែរដែលបានបញ្ឈប់យ៉ាងខ្លាំងក្លា ជាមួយអ៊ីម៉ាំអាលីصلوات الله عليه والسلام និងបានប្រឆាំងរដ្ឋបាលមិនស្របច្បាប់របស់អាប៊ូ បាការ តាមរយៈសុន្ទរកថាអស្ចារ្យរបស់ព្រះនាងនិងឋានៈថ្លៃថ្នូររបស់ព្រះនាង ព្រះនាងស៊ែណាប់سلام الله عليهاបានបញ្ឈប់ លុះអវសានជីវិត ជាមួយព្រះរៀមព្រះនាង អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلام ហើយបានប្រឆាំងរដ្ឋបាលខ្មៅងងឹតរបស់ពួកកាន់អំណាចអ៊ូម៉ៃយ៉ាស់ ដែលបម្រុង ដោយចេតនា កម្ចាត់និងលុបបំបាត់សាសនាអ៊ីស្លាមឲ្យអស់ឫសកែវដោយទាត់អាស់លុល-បៃត៍عليهم السلامចេញពីជីវិតសង្គមនិងជីវិតនយោបាយរបស់មុស្លីម ។ យើងសូមលើកឡើងនូវលក្ខណៈពិសេស ដែលបញ្ជាក់ថាព្រះនាងស៊ែណាប់سلام الله عليهاជានារីឯកដាច់អស់នារីមុស្លីម គឺ៖

## ជំនឿ

នៅកណ្តាលមណ្ឌល ដែលព្រះប្រកាសិតឲ្យមករកអល់ឡោះហ្វ៍تعالىត្រូវ

លេចឡើង នៅកណ្តាលព្រះមហាគ្រឹះស្ថានដែលព្រះរាជសារត្រូវដាក់ចុះមក នៅចំបណ្តូលពាក្យពេជន៍តៅហ៊្រីដូជះរស្មីទៅលើប្រជានិករក្នុងលោកនេះ នៅក្នុងគ្រឹះស្ថាននេះឯង ដែលព្រះនាងស្វៃណាប់سلام الله عليها បានទទួលការអប់រំ ។ ព្រះនាងត្រូវបំប៉នដោយខ្លឹមជំនឿពិត និងដោយការពិតនៃសាសនាអ៊ីស្លាម ។ ដូច្នេះហើយបានជាសេចក្តីស្រឡាញ់អល់ឡោះហ៍عز وجل ជ្រួតជ្រាបខ្លួនព្រះនាងជាធម្មជាតិ ហើយក្រោយមកសេចក្តីស្រឡាញ់នេះទៅជាគ្រឿងសម្គាល់លក្ខណៈបុគ្គលរបស់ព្រះនាង ដែលបណ្តាលឲ្យព្រះនាងប្រឈមនឹងទុក្ខវេទនានិងឧបសគ្គនានាចាប់តាំងពីយុវវ័យម្ល៉េះ ។

ជំនឿមាំ និងការចុះចូលស៊ប់ចិត្តចំពោះអល់ឡោះហ៍تعالى ជាលក្ខណៈពិសេសដែលមាននៅក្នុងព្រះរាជវង្សរបស់ព្រះសាស្តាមូហាំម៉ាដ្ឋ์صلى الله عليه وآله وسلم ក្នុងលក្ខណៈពិសេស ។ ព្រះសមាជិកនីមួយៗនៃព្រះរាជវង្សថ្កើងថ្កាននេះសម្តែងនូវជំនឿមាំរបស់ខ្លួនដាច់គេ ។ ឧទាហរណ៍ ព្រះនាងស្វៃណាប់سلام الله عليها បានមកឈប់ត្រង់កន្លែងព្រះរាជសពព្រះរៀមព្រះនាង អ៊ីម៉ាំអាល់-ហ៊្វូសៃន៍صلوات الله عليه والسلام ដែលត្រូវពួកសត្រូវកាត់ព្រះសិរ ហើយបានសម្តែងជំនឿមាំរបស់ព្រះនាងថា៖

اَللّٰهُمَّ تَقَبَّلْ مِنَّا هَذا الْقُرْبَانَ.

*"អល់ឡោះហ៍عز وجل អឺយ សូមព្រះអង្គទទួលព្រះរាជតង្វាយនេះពីអស់ទូលព្រះបង្គំជាខ្ញុំ ។"*

ពាក្យពេជន៍ទាំងនេះជាឧទាហរណ៍ប្រសើរបំផុត នៃមហោឡារិកភាពនៃព្រះកេរដំណែលព្រះសាស្តា ។ ពាក្យពេជន៍ទាំងនេះបង្ហាញឲ្យឃើញដែរនូវអ៊ីស្លាមពិតតាមរយៈមេរៀនដែលបង្ហាត់ឲ្យចេះដឹងថា ពលីកម្មនីមួយៗត្រូវតែធ្វើឡើងដើម្បីអល់ឡោះហ៍عز وجل តែមួយគត់ ។

មនុស្សជាតិ គ្រប់យុគសម័យ ត្រូវលំឱនកាយចំពោះជំនឿឥតប្រៀបនេះ នេះជាអាថ៌កំបាំងហួសពីនិច្ចភាពរបស់ព្រះនាងស្វៃណាប់سلام الله عليها និងជាគោលការណ៍របស់ព្រះនាង ។

ក្នុងយប់ឃោរឃៅបំផុតក្នុងជីវិតព្រះនាងស្វៃណាប់سلام الله عليها និងអ៊ុមម៉ាត្ទ៍អ៊ីស្លាមផងដែរនេះ ព្រះនាងបានស្ញ៏ឡាត្ទ៍អរព្រះគុណអល់ឡោះហ៍عز وجل ក្នុងពេល

ដែលព្រះនាងរងសោកនាដកម្មដ៏តក់ស្លុតបំផុត ។ សាកសពរបស់ព្រះរាជវង្សព្រះសាស្តាﷺនិងបណ្តាសាវកបរិសុទ្ធ ត្រូវគេយកមកបោះពីមុខព្រះនាងឥតសំពត់បិទបាំង ។ អណ្តាតភ្លើងឆាបឆេះសន្ធោសន្ធៅពីមុខបណ្តាស្ត្រីត្រកូលអុលីដែលបានបាត់បង់ជម្រក បន្ទាប់ពីត្រូវពួកទាហានតិរច្ឆានឥតមេត្តាបានប្លន់យកគ្រឿងអលង្ការនិងទ្រព្យនានា ។ កុមារៗពុំអាចធ្វើអ្វីបានក្រៅស្រែកទ្រហោយំទេ ។ នៅក្នុងស្ថានភាពដ៏តក់ស្លុតនេះព្រះនាងស៊្សៃណាប់ سلام الله عليها បានបែរទៅរកព្រះម្ចាស់ عز وجل ព្រះនាង អរព្រះគុណព្រះអង្គ عز وجل ដែលប្រោសប្រទានព្រះធម៌មេត្តា ។
ការពិត ជំនឿប្រភេទនេះបិតថេរជាងអារ្យធម៌ ជាងទ្រព្យសម្បត្តិនិងជាងនិរន្តភាពទៅទៀត ។

## សេចក្តីរឹងមាំ

តាំងពីកុមារភាពមកម្ល៉េះ ព្រះនាងស៊្សៃណាប់ سلام الله عليها តែងតែប្រកាន់យកនូវសេចក្តីរឹងមាំដាក់ក្នុងខ្លួនតទល់នឹងទុក្ខវេទនានានា ។ ដំបូងព្រះនាងបានបាត់បង់ព្រះអយ្យកោ ព្រះសាស្តាមូហាំម៉ាដ់ﷺ ដែលអាណិតស្រឡាញ់ព្រះនាងណាស់ ។ បន្ទាប់មកព្រះនាងបានឃើញព្រឹត្តិការណ៍តក់ស្លុតមួយដែលបានពើបពះលើព្រះបិតាមាតាព្រះនាង ក្រោយពីព្រះសាស្តាﷺបានសោយទិវង្គតភ្លាម ។ គេបានប្លន់យកតំណែងរបស់ព្រះបិតាព្រះនាង តំណែងដែលអល់ឡោះហ៍ تعالى និងព្រះសាស្តាមូហាំម៉ាដ់ﷺបានជ្រើសរើសឲ្យព្រះអង្គ صلوات الله عليه والسلام ។ ព្រះមាតាព្រះនាងត្រូវមនុស្សធ្វើបាបទាល់តែបានចាកចោលលោកនេះខណៈដែលព្រះនាងនៅក្មេងខ្ចី ។ បន្ទាប់មកព្រះនាងបានឃើញប្រជារាស្ត្រស្រុកគូហ្វាស្ង់បោកប្រាស់ព្រះរៀមព្រះនាង អ៊ីម៉ាំអាល់-ហ្សាសាន់ صلوات الله عليه والسلام បោះបង់ចោលព្រះអង្គ صلوات الله عليه والسلام ដល់ថ្នាក់ព្រះអង្គ صلوات الله عليه والسلام ចាំបាច់ត្រូវធ្វើសន្ធិសញ្ញាសន្តិសុខជាមួយម៉ូអាវីយ៉ាស្ង់ មហាសត្រូវរបស់អ៊ីស្លាមនិងអាស្ង់លុល-បៃត៍ عليهم السلام ។ ពីរបីឆ្នាំក្រោយមក អ៊ីម៉ាំអង្គនេះ صلوات الله عليه والسلام ត្រូវគេលួចធ្វើគុតដោយដាក់ថ្នាំបំពុល ។ ព្រះនាងបានឃើញព្រះអង្គទ្រង់អាចៀន (គឺក្អួត) ឈាមលុះសោយទិវង្គត ។

ថ្ងៃទី ១០ ខែ មូហារ៉ម ហ៊ីជ្រោះគ័សករាជ ព្រះនាងបានឃើញអកុសលកម្មដូរចត់បំផុត ព្រះរៀមព្រះនាង អ៊ីមុាំអាល់-ហ៊្វូសៃន៍ﷺ ឈានទៅរកការស្លាប់ បន្ទាប់ពីបានបាត់បង់ការគាំទ្រនិងជំនួយទាំងអស់ ដាវពួកទាហានអ៊ូម៉ៃយ៉ាស្ទុំអន្សតិរ្លិយ កាប់សម្លាប់យុវជនដែលស្រឡាញ់អុាលីﷺ កាប់សម្លាប់កុមារនិងទារក ។ ព្រះនាងស៊ៃណាប់عليها السلام នៅក្នុងគោលជំហរប្រៀបបាននឹងភ្នំសែនមាំ ប្រឈមនឹងទុក្ខវេទនាពុំអាចទ្រាំបានទាំងនេះ ។ ព្រះនាងតស៊ូនឹងទុក្ខវេទនាទាំងអស់នេះដោយមានសេចក្ដីមោះមុតជាងអាវុធ ទប់ទល់នឹងព្រឹត្តិការណ៍ទាំងអស់ដោយការជឿជាក់ ។ ដូច្នេះហើយបានជាព្រះបន្ទូលអលឡោះហ្វ៍تعالى ចែងអំពីព្រះនាងថា៖

...وَبَشِّرِ الصَّابِرِينَ. الَّذِينَ إِذَا أَصَابَتْهُمْ مُصِيبَةٌ قَالُوا إِنَّا لِلَّهِ وَإِنَّا إِلَيْهِ رَاجِعُونَ. أُولَٰئِكَ عَلَيْهِمْ صَلَوَاتٌ مِنْ رَبِّهِمْ وَرَحْمَةٌ ...

*...ចូរអ្នកផ្សាយដំណឹងល្អដល់ បណ្ដាអ្នកអត់ធ្មត់ ។ គឺបណ្ដាអ្នកដែលពេលជួបប្រទះទុក្ខវេទនា ថ្លែងថា៖ "ពិតណាស់យើងជាកម្មសិទ្ធិរបស់អល់ឡោះហ្វ៍ យើងវិលត្រឡប់ទៅរកព្រះអង្គវិញ ។" ជនានុជនទាំងនោះគឺជនដែលបាននូវពរជ័យសិរីសួស្ដី និងព្រះមេត្តាធម៌ពីព្រះម្ចាស់ពួកគេ... (២:១៥៥-១៥៧) ។*

កវីជាច្រើន បានបរិយាយអំពីសេចក្ដីមោះមុតរបស់ព្រះនាងស៊ៃណាប់عليها السلام ដោយពាក្យពេជន៍ដ៏ពីរោះ ។ ព្រះនាងជាព្រះរាជនត្តាស្ត្រីរបស់ព្រះសាស្ដាﷺ ព្រះនាងបានសម្ដែងនូវសេចក្ដីរឹងមាំនិងការអត់ធ្មត់នៅចំពោះមុខខ្មាំងសត្រូវរបស់អល់ឡោះហ្វ៍عز وجل ។ ព្រះនាងស៊ៃណាប់عليها السلام អាចអត់ទ្រាំឧបសគ្គនិងទុក្ខវេទនាទាំងអស់បាន អាស្រ័យលើគុណសម្បត្តិ ការប្ដេជ្ញាចិត្តនិងការស៊ូទ្រាំ ។

## សេចក្ដីថ្លៃថ្នូរ

សេចក្ដីថ្លៃថ្នូរជាលក្ខណៈសម្បត្តិប្រចក្ស នៅក្នុងលក្ខណៈបុគ្គលរបស់ព្រះ

នាងស៊ែរណាប់ﷺ ។ បន្ទាប់ពីអ៊ីម៉ាំអាល់-ហ៊្វូសែបន៍ﷺត្រូវធ្វើគុត ព្រះនាង និងព្រះនត្តាស្រ្តីឯទៀតរបស់ព្រះសាស្តាﷺត្រូវគេចាប់ជាឈ្លើយសឹក នាំខ្លួនពីការបាឡាអ៊្ទៅគូហ្វាស្ ឯរបស់ផ្ទាល់ខ្លួនត្រូវគេប្លន់យកអស់ ។ ពេលក្មេងៗអត់បាយ អត់ទឹក ព្រះនាងមិនព្រមសូមបាយពីទាហានអ៊ូម៉ៃយ៉ាស់ទេ ។ ពេលក្រុមចំណាប់ឈ្លើយបានមកដល់គូហ្វាស់បណ្តាស្ត្រីស្រុកនេះបានដឹងថាចំណាប់ឈ្លើយ ក្រុមនេះជាព្រះរាជកុលដ្ឋានﷺរបស់ព្រះសាស្តាﷺ ពួកនាងប្រញាប់យកអាហារមកឲ្យក្មេងៗ ។ ព្រះនាងបានរាំងដោយប្រាប់បណ្តាស្ត្រីទាំង នោះថា៖

الصَدَقَةُ مُحَرَّمَةٌ عَلَيْنَا أَهْلَ الْبَيْتِ.

*"គេហាមយើង អាស់លុល-បៃត៍ﷺ មិនឲ្យទទួលយកអំណោយទានទេ ។"*

ពេលក្មេងៗបានឮសម្តីនេះពីមាត់ម្តាយមីង ពួកគេចោលពីដៃនិងពីមាត់អ្វីដែលខ្លួនបានទទួលពីបណ្តាស្ត្រីទាំងនោះ សុខចិត្តទ្រាំអត់ឃ្លានជាជាងទទួលអំណោយទានដែលគេហាមខ្លួនទទួល ។ នេះគឺលទ្ធផលនៃការអប់រំរបស់អស់បុគ្គលសម្រិតសម្រាំង ព្រះសាស្តាទាំងឡាយ បណ្តាសច្ចការីនិងបណ្តាអ្នកតាមបុគ្គលទាំងនេះ ។

តាមផ្លូវដែលនាំក្រុមចំណាប់ឈ្លើយពីគូហ្វាស់ទៅដ្ឋាម៉ាស់ ព្រះនាងស៊ែរណាប់ﷺមិនបានហាមាត់សូមជំនួយឲ្យក្មេងៗ និងបណ្តាស្ត្រីឡើយទោះបីស្ថិតនៅក្នុងសេចក្តីត្រូវការចាំបាច់ក៏ដោយ ព្រោះវាជាការរើសអើង(ប្រឆាំងសត្រូវ) និងជាស្មារតីរក្សាកិត្តិយសថ្លៃថ្នូរ ។

ដូច្នេះ ព្រះនាងស៊ែរណាប់ﷺមិនបានឱនក្បាលទៅរកអ្នកណាផ្សេងពីអល់ឡោះហ៊ូﷻឡើយ ។ ព្រះនាងបានបង្ហាញនូវសេចក្តីថ្លៃថ្នូរ កិត្តិយសនិងការរើសគ្តើស(ចំពោះសត្រូវ) ជាកេរដំណែលមកពីព្រះអយ្យកោនិងព្រះបិតាព្រះនាងទោះជាព្រះនាងឈឺចាប់ក្តី ។

## សេចក្តីក្លាហាន

ពុំមានអ្នកណាសង្ស័យ អំពីសេចក្តីក្លាហានរបស់ព្រះរាជវង្សព្រះសាស្តា

ﷺ ឡើយ ។ ព្រះសមាជិកនៃព្រះរាជវង្សនេះឲ្យគំរូនៃសេចក្តីអង់អាចនិងសេចក្តីក្លាហាន ។ ឧទាហរណ៍ អ៊ីម៉ាំអាលី صلوات الله عليه والسلام ព្រះអាណាព្យាបាលព្រះរាជវង្សរបស់ព្រះសាស្តា ﷺ មានវចនៈថា៖ "ទោះបីពួកអារ៉ាប់ប្រួតដៃគ្នាប្រយុទ្ធទល់នឹងខ្ញុំក៏ដោយ ក៏ខ្ញុំនឹងមិនរត់ឡើយ ។"

ព្រះអង្គ صلوات الله عليه والسلام បានសម្តែងឲ្យឃើញនូវសេចក្តីក្លាហានគ្រប់បែប នៅក្នុងសមរភូមិនិងការប្រយុទ្ធផ្សេងៗរបស់អ៊ីស្លាម ។ ព្រះរាជបុត្រព្រះអង្គ صلوات الله عليه والسلام ក៏ឲ្យគំរូឧត្តមនៃសេចក្តីអង់អាចនិងសេចក្តីក្លាហានច្រើនដែរ ។ ក្នុងថ្ងៃអាស៊ូរ៉អ៍ (عاشوراء) ព្រះអង្គ صلوات الله عليه والسلام បានធ្វើឲ្យពួកសត្រូវព្រះអង្គ صلوات الله عليه والسلام ស្រឡាំងកាំង ហើយបានប្រឈមមុខយ៉ាងក្លាហាននិងយ៉ាងមាំមួននឹងពួកសត្រូវទាំងនេះដែលមានវរេហ៍ពលច្រើនអនេក ។ ទោះជាព្រះអង្គ صلوات الله عليه والسلام បានពើបពះទុក្ខវេទនាគួរឲ្យតក់ស្លុតក្នុងថ្ងៃនោះក៏ដោយ ព្រះអង្គ صلوات الله عليه والسلام មិនសម្តែងឲ្យឃើញនូវការបោះបង់ ឬការទន់ខ្សោយឡើយ ។ ផ្ទុយទៅវិញសេចក្តីមោះមុតរបស់ព្រះអង្គ صلوات الله عليه والسلام កើនឡើង ជាមួយកំណើនទុក្ខវេទនា ។ ព្រះអង្គ صلوات الله عليه والسلام តែឯងបានវាយប្រហារទ័ព ៣០ ០០០ យុទ្ធជន ធ្វើឲ្យពួកវាបែរក្រោយដូចពពែរត់គេចពីសិង្ហ ។ ទោះបីព្រះអង្គ صلوات الله عليه والسلام រលំដោយត្រូវរបួសធ្ងន់ក៏ដោយ ពួកសត្រូវក៏នៅតែខ្លាចចូលទៅជិតព្រះអង្គ صلوات الله عليه والسلام ដែរ ។

យកគំរូតាមព្រះសមាជិកព្រះរាជវង្សរបស់ព្រះនាង ព្រះនាងស៊ៃណាប់ سلام الله عليها កាន់អាកប្បកិរិយាក្លាហានបំផុត នៅចំពោះមុខពួកសត្រូវដែលបានធ្វើគុតព្រះរៀមព្រះនាង ។ កាលព្រះនាងបានទៅប្រឈមមុខនឹងអ៊ូបៃឌុលឡោះហ៍ អ៊ីបនូ ស៊ីយ៉ាដ្ធ អភិបាលក្រុងគូហ្វាស្ហ ក្នុងឋានៈជាចំណាប់ឈ្លើយ ព្រះនាងបានសម្តែងការស្អប់ខ្ពើមនិងអគារវៈដាក់បុគ្គលរូបនេះ ។ បុគ្គលរូបនេះបានត្រេកអរលើគំនរទុក្ខព្រះនាងដោយថា៖ "សូមអរគុណអល់ឡោះហ៍ عز وجل ដែលបានបើកមុខ បានសម្លាប់និងបានបង្ហាញបដិវត្តន៍របស់ព្រះនាងឲ្យឃើញថាខុស ។" ព្រះនាងតបវិញយ៉ាងក្លាហានថា៖ "

اَلحَمْدُ للهِ ٱلَّذِي أَكْرَمَنَا بِنَبِيِّهِ، وَطَهَّرَنَا مِنَ ٱلرِّجْسِ تَطْهِيراً. إِنَّمَا يُفْتَضَحُ ٱلْفَاسِقُ وَيُكَذَّبُ ٱلْفَاجِرُ، وَهُوَ غَيْرُنَا، وَهُوَ غَيْرُنَا يَا بْنَ مَرْجَانَةَ...

*"សូមអរព្រះគុណអល់ឡោះហ្ ﷻ ដែលលើកតម្កើងយើងដោយព្រះសាស្តា ﷺ ព្រះអង្គ ﷻ ដែលបានជម្រះបន្សុទ្ធយើងពីអាការកខ្វក់ គគ្រិចយ៉ាងជ្រះស្អាត់ឥតខ្ចោះ ។ មានតែបុគ្គលអាក្រក់អន្សត្តិរ្កិយទេដែលត្រូវបើកមុខ មានតែបុគ្គលខុសគន្លងធមិទេដែលត្រូវបង្ហាញឲ្យឃើញថាខុសនោះ ។ យើងមិននៅក្នុងចំណោមបុគ្គលប្រភេទទាំងពីរនេះទេ ។ ការពិតយើងមិនមែនបុគ្គលប្រភេទនេះឡើយ ឱកូនរបស់ម៉ារយ៉ាណាស្ញុ[56] អឺយ ។"*[57]

ការពិត សម្តីនេះប្រកបដោយឥទ្ធិពលមរណៈខ្លាំងជាងអាវុធទៅទៀត ។ ព្រះនាងបាននិយាយពាក្យពេជន៍ទាំងនេះ ខណៈដែលព្រះនាងនិងបណ្តាស្ត្រីព្រះរាជវង្សព្រះសាស្តា ﷺ ឯទៀតនៅក្នុងឋានៈចំណាប់ឈ្លើយ ហើយព្រះសិរអាណាព្យាបាលរបស់ព្រះនាងទាំងអស់នៅលើចុងលំពែង ។

ពាក្យពេជន៍ទាំងនេះដែរដែលធ្វើឲ្យបុគ្គលកំណាចធ្លាក់ពីលើបល្ល័ង្កទៅក្នុងផ្នូរ ។ ឮពាក្យពេជន៍នេះពីមាត់ព្រះនាងនៅចំពោះមុខបម្រើនិងមន្ត្រីទាំងឡាយរបស់ខ្លួន ធ្វើឲ្យបុគ្គលកំណាចរូបនេះដឹងខ្លួនថាការពិតខ្លួនឯងទេដែលជាអ្នកចាញ់ពិតនិងជាអ្នកដែលត្រូវបើកមុខ ចំណែកឯងជ័យជនៈនោះវិញនៅលើអ៊ីម៉ាំអាល់-ហ៊្វសៃន៍ صلوات الله عليه والسلام បុគ្គលដែលត្រូវគេសម្លាប់ និងបណ្តាសាវករបស់ព្រះអង្គ صلوات الله عليه والسلام ។

ពេលបានឮសម្តីទ្រគោះខ្លាំងនេះ អ៊្លូបៃឌុលឡោះហ្វ៍ កូនរបស់ម៉ារយ៉ាណាស្ញុ មិនមានពាក្យអ្វីឆ្លើយតបទេ ។ ដោយហេតុនេះ បុគ្គលរូបនេះបានប្រាប់ឲ្យគេដាក់ទោស ក្នុងបំណងបិទបាំងបរាជ័យរបស់ខ្លួននិងការគ្មានសមត្ថភាពឆ្លើយតបវិញ ។ បុគ្គលរូបនេះបានសួរព្រះនាងថា៖ "តើព្រះនាងយល់ឃើញយ៉ាងណា ដែលអល់ឡោះហ្វ៍ ﷻ បានប្រព្រឹត្តចំពោះ

[56] ម៉ារយ៉ាណាស្ញុ - ម្តាយរបស់ អ៊្លូបៃឌុលឡោះហ្វ៍ អ៊ីបនូ ស្ញុីយ៉ាដ្ញុ ស្ត្រីពេស្យាល្បីដែលគេស្គាល់ឈ្មោះពេញរដ្ឋអ៊ីស្លាម ។

[57] សូមមើលសៀវភៅរបស់លោក មូហ្ញាំម៉ាដ្ញុ អ៊ីបនូ យ៉ាររៀរ អាល់-ត្ញ័បារី (محمد بن جرير طبري) *តារិក្ញ អាល់-អ៊ូមុាំ វ៉ា អាល់-មុលុក (تاريخ الأمم والملوك)*, ៦:២៦៣ ។

ព្រះរៀមព្រះនាងនោះ ?"

ព្រះនាងស៊ែណាប់ﷺបានតបវិញយ៉ាងក្លាហាននិងមោះមាំ ដោយសម្តីជោគជ័យថា៖

مَا رَأَيْتُ إِلاّ جَمِيلاً. هٰؤُلاَءِ قَوْمٌ كَتَبَ ٱللهُ عَلَيْهِمُ ٱلْقَتْلَ فَبَرَزُوا إِلىٰ مَضَاجِعِهِمْ، وَسَيَجْمَعُ ٱللهُ بَيْنَكَ وَبَيْنَهُمْ فَتُحَاجَّ وَتُخَاصَمَ. فَانْظُرْ لِمَنِ ٱلْفَلَجُ يَوْمَئِذٍ. ثَكَلَتْكَ أُمُّكَ يَا بْنَ مَرْجَانَةَ.

*"ខ្ញុំមិនឃើញអ្វីក្រៅពីព្រះគុណព្រះអង្គﷻទេ ។ បុគ្គលទាំងនេះជាបុគ្គលដែលរង់ចាំលះបង់ជីវិតដើម្បីធ្វើទុក្ករកម្ម ។ ដូច្នេះហើយបានជាពួកគេមកកាន់កន្លែងដែលត្រូវស្លាប់ ។ អល់ឡោះហ្ទ៍ﷻនឹងប្រជុំលោកនិងអស់បុគ្គលទាំងនេះដើម្បីជម្រះក្តីនិងកាត់ទោស ។ ដូច្នេះលោកនឹងបានឃើញថាអ្នកណាជាអ្នកឈ្នះក្នុងថ្ងៃនោះ ។ មហន្តរាយនឹងបានលើលោក ឱកូនរបស់ម៉ារយ៉ាណាស្ទុំអឺយ ។"*

ពាក្យពេជន៍ទាំងនេះជាប្រភពនៃឧបការគុណ មិនត្រឹមតែសម្រាប់ព្រះនាងស៊ែណាប់ﷺទេ តែសម្រាប់អ៊ីស្លាមនិងមុស្លីមដែរ ។ ពាក្យពេជន៍ទាំងនេះត្រូវចាត់ទុកជាការលើកតម្កើងព្រះរាជវង្សព្រះសាស្តាﷺជានិច្ចនិរន្តរ៍ ។ កាលៈទេសៈ ដែលបានធ្វើឲ្យព្រះនាងស៊ែណាប់ﷺប្រឈមមុខនឹងបុរសជាតិស៊ីរី នៅក្នុងរាជវាំងរបស់យ៉ាស៊ីដូនិងសម្តីបដិវត្តន៍អមតរបស់ព្រះនាងបានធ្វើឲ្យបល្ល័ង្កអុំម៉ៃយ៉ាស្ទុំកក្រើក ហើយបានបើកឲ្យឃើញនូវការពិតគ្មានមូលដ្ឋានរបស់យ៉ាស៊ីដូ និងរបស់បណ្តាអ្នកដែលបានបើកដៃឲ្យយ៉ាស៊ីដូឡើងកាន់អំណាច ។ យើងនឹងបរិយាយរឿងនេះនៅក្នុងចំពូកមុខ ។

## ចៀសវាងសេចក្តីត្រេកត្រអាលលោកិយ

ប្រព្រឹត្តតាមគន្លងព្រះបិតាព្រះនាង ដែលបានចៀសវាងសេចក្តីត្រេក

ត្រអាលលោកិយឥតបង្អង់[58] និងព្រះមាតាព្រះនាងដែលពុំមានអ្វីឡើយ លើកលែងតែកម្រាលមួយធ្វើអំពីស្លឹកត្នោតនិងស្បែកចៀម ព្រះនាងស្ស៊ែណាប់سلام الله عليهاលះបង់ចោល នូវសេចក្តីត្រេកត្រអាលលោកិយទាំងអស់ តោងអល់ឡោះហ្ទ៍تعالىជាប់និងទង្វើសប្បុរសធម៌ ។ ព្រះនាងមិនដែលទុក អ្វីសម្រាប់ថ្ងៃស្អែកឡើយ[59] ។

ព្រះនាងចាកចោលអ្វីៗទាំងអស់ កាលព្រះនាងទៅតាមព្រះរៀមព្រះនាង អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلام សូម្បីតែព្រះនាងជាមហេសីរបស់បុរសសម្បូរ ទ្រព្យសម្បត្តិជាងគេនៃនគរម៉ាឌីណាស្ទ៍ក៏ដោយ ដើម្បីគាំទ្រសាសនានិង ការពារគោលការណ៍និងតម្លៃសាសនា ។

## សេចក្តីម៉ឺងម៉ាត់

ព្រោះតែព្រះនាងស្ស៊ែណាប់سلام الله عليهاប្រឈមមុខនឹងជនកំណាច យ៉ាងម៉ឺងម៉ាត់ ក្រៃលែងបានជាព្រះនាងជាតំណាងកម្លាំងសិទ្ធិនិងយុត្តិធម៌បាន យ៉ាង សក្តិសមឥតខ្ចោះ ។ នៅក្នុងគ្រប់ស្ថានភាព ព្រះនាងឆ្លើយតបជនកំណាច យ៉ាងអង់អាចក្លាហាន ព្រះនាងតស៊ូទល់នឹងភាពមិនពិតរបស់ជនកំណាច

[58] នេះគឺការចង្អុលទៅរកព្រះវចនៈដ៏ល្បីរបស់អ៊ីម៉ាំអាុលីصلوات الله عليه والسلامគឺ៖ "លោកអឺយ លោកអឺយ ! ចូរចៀសឆ្ងាយពីខ្ញុំ ។ ហេតុអ្វីអ្នកបង្ហាញខ្លួនឲ្យខ្ញុំឃើញ ? ឬមួយអ្នក ចង់បានរូបខ្ញុំ ? អ្នកនឹងមិនមានឱកាសធ្វើឲ្យខ្ញុំស៊ើចទេ ។ ចូរអ្នកបញ្ឆោតអ្នកផ្សេង ទៅ ។ ខ្ញុំមិនទាក់ទងជាមួយអ្នកទេ ។ ខ្ញុំបានលះលែងអ្នកចោលបីដងហើយ ដូច្នេះខ្ញុំមិនបែរក្រោយវិញទេ ។ ជីវិតអ្នកខ្លី សេចក្តីសំខាន់របស់អ្នកស្តួចស្តើង ណាស់ ការចូលចិត្តអ្នកទាបណាស់ ។ ឱអនិច្ចំ ! មគ្គផលក៏តូច ផ្លូវក៏ឆ្ងាយ ដំណើរ ក៏យូរ ឯគោលដៅក៏ពិបាកនឹងទៅដល់ ។"

[59] អ៊ីម៉ាំស្ស៊ែន៍ អាល់-អាុប៊ីឌីនصلوات الله عليه والسلامថ្លែងលក្ខណៈសម្បត្តិនេះអំពីព្រះបិតុច្ឆា (ម្តាយ មីង) ព្រះនាងស្ស៊ែណាប់سلام الله عليها ។ សូមមើលសៀវភៅ *អាល់-មុសតាដ្រ៉ក់* របស់ លោក អាល់-ហ្កាគីម ក្បាលទី ៣ ទំព័រ ១៩៩, សៀវភៅ *អ៊ុសដ្ទ៍ អាល់-ក៏បាស្ទ៍* របស់លោក អ៊ីបនូ អាល់-អាស្ស៊ៀរ ក្បាលទី ៥ ទំព័រ ៥២៣, សៀវភៅ *អាល់-តារិក៏ អាល់-បាក់ដ្ឋាដ្ទ៍* ក្បាលទី ៧ ទំព័រ ៣៦៦ របស់លោក អាល់-ខ៏ទិប អាល់-បាក់ដ្ឋាឌី និងច្រើនទៀត ។

ទាំងនោះ ដោយពាក្យពេជន៍ត្រចះត្រចង់ប្រកបដោយរស្មីដែលឋិតថេរ និងជាគំរូសម្រាប់ទប់ស្កាត់ប្រឆាំងបុគ្គលកំណាចគ្រប់រូប ដើម្បីសិទ្ធិនិងយុត្តិធម៌ ។

ក្នុងពេលដែលពលទាហាននិងចៃរាំងដែលយ៉ាស៊ីដ្ធបានអញ្ជើញមកធ្វើជាសាក្សីជ័យជំនះមិនពិតរបស់ខ្លួនចោមរោមព្រះនាង ព្រះនាងស្រៃណាប់ سلام الله عليهاតបតរាល់ពាក្យរាល់សម្ដីរបស់យ៉ាស៊ីដ្ធ ទាល់តែព្រះនាងបានបើកមុខបុគ្គលរូបនេះឲ្យឃើញច្បាស់ទែង ហើយបានអះអាងបញ្ជាក់ថារឿងព្រះរៀមព្រះនាងនោះជាការពិត មិនក្លែងក្លាយទេ ។ម្យ៉ាងទៀត ព្រះនាងបានគំរាមកំហែង ស្ដីបន្ទោសស្រោចទៅលើបុគ្គលកំណាចរូបនេះហាក់ដូចជាព្រះនាងជាអភិបាលស្រុក រីឯយ៉ាស៊ីដ្ធជាឈ្លើយសឹកទៅវិញ ។ ព្រះនាងបានលើកយកអាយ៉ាស់គួរអាន និងចំណុចសមហេតុសមផលជាអំណះអំណាង មិនបណ្ដោយឲ្យបុគ្គលកំណាចតវ៉ាបានឡើយ ។ ពាក្យពេជន៍ព្រះនាងដូចផ្លែដាវកាប់យ៉ាស៊ីដ្ធ និងមនុស្សដូចយ៉ាស៊ីដ្ធទាល់តែស្លាប់ ។

ព្រះនាងបានប្រព្រឹត្តបែបនេះដែរ ចំពោះជនកំណាចមួយទៀតអ៊ូបៃឌុលឡោះហ្វ៍ អ៊ីបនូ ស៊ីយ៉ាដ្ធ ដែលបានរីករាយលើគំនរទុក្ខព្រះនាង តែការបៀតបៀនរបស់បុគ្គលនេះត្រូវបានវាយបកវិញ ដោយពាក្យពេជន៍មុតនិងដោយការប៉ិនប្រសប់ ដែលធ្វើឲ្យបុគ្គលនេះចុកមាត់និយាយមិនរួច ។ ព្រះនាងធ្វើសោះអង្គើយដាក់ដាក់បុគ្គលនេះ លែងយកចិត្តទុកដាក់សោះឡើយ អាកប្បកិរិយាបែបនេះធ្វើឲ្យបុគ្គលរូបនេះខ្មាស់គេជាក្រៃល ។ សេចក្ដីអង់អាចរបស់ព្រះនាងបានលេចប្រចក្សឡើង នៅក្នុងពេលធ្វើដំណើរជាមួយព្រះរៀមព្រះនាងនិងក្នុងពេលក្រោយពីនោះ កាលព្រះនាងកាន់មុខងារថ្មែថ្នូរផ្សេងៗក្នុងបដិវត្តន៍អមតៈរបស់ព្រះអង្គ ។ ព្រះនាងបានចាត់ចែងរឿងអ៊ីម៉ាំصلوات الله عليه والسلامដោយសកម្មភាពឥតប្រៀបបាន ទោះបីពួកសត្រូវកំពុងឡោមព័ទ្ធក៏ដោយ ។ ក្រឡេកមើលព្រះភក្ត្រត្រចះត្រចង់របស់ព្រះរៀមព្រះនាងធ្វើឲ្យព្រះនាងបាត់នឿយហត់ ។

ព្រះនាងបានថែរក្សាកុមារនិងព្រះរាជវង្សដែរ បន្ទាប់ពីអ៊ីម៉ាំصلوات الله عليه والسلامបានធ្វើ

ទុក្ករកម្មដោយលះបង់ព្រះជន្ម នេះជាបេសកកម្មពិបាកដែលស្ត្រីធម្មតាមិនអាចចាត់ចែងបាន ។ ប្រភពនៃកម្លាំងនិងសេចក្តីម៉ឺងម៉ាត់បែបនេះនោះគឺព្រះនាងយល់បដិវត្តន៍របស់អ៊ីម៉ាំអាល់-ហ៊្វូសៃន៍صلوات الله عليه والسلام ច្បាស់ឥតខ្ចោះ ហើយព្រះនាងប្រឹងប្រែងឥតសំចៃកម្លាំងឡើយ ដើម្បីបដិវត្តន៍នេះនឹងបានទទួលជោគជ័យ ។

នេះគឺលក្ខណៈពិសេសមួយចំនួន ដែលឆ្លុះបញ្ចាំងលក្ខណៈបុគ្គលឥតប្រៀបបានរបស់ព្រះនាងស៊្សៃណាប់سلام الله عليها ។ ការពិតលក្ខណៈបុគ្គលរបស់ព្រះនាងស៊្សៃណាប់سلام الله عليهاរួមមានលក្ខណៈសីលធម៌ខ្ពង់ខ្ពស់ និងលក្ខណៈសុក្រឹតភាពទាំងអស់ ។ ស្រង់យកនូវលក្ខណៈពិសេសទាំងអស់នេះត្រូវព្យាយាមខ្លាំងនិងប្រើពេលច្រើន ដ្បិតលក្ខណៈពិសេសរបស់ព្រះនាងស៊្សៃណាប់سلام الله عليهاមិនចេះចប់ទេ ។ ហេតុដូច្នេះហើយបានជាយើងលើកយកតែលក្ខណៈពិសេសមួយចំនួនតូចប៉ុណ្ណោះ ដែលឆ្លុះបញ្ចាំងលក្ខណៈបុគ្គលព្រះនាងស៊្សៃណាប់سلام الله عليهاត្រង់នេះ ។

## ព្រះនាងស៊្សៃណាប់នៅក្នុងហាឌីស្ស

ព្រោះតែព្រះនាងមានគោលជំហរខ្ពង់ខ្ពស បានជាហាឌីសច្រើនដែលជាហាឌីស្សរបស់ព្រះសាស្តាصلى الله عليه وآله وسلم និងអាស្ហ់លុល-បៃត៍عليهم السلامថ្លែងអំពីព្រះនាងស៊្សៃណាប់سلام الله عليها ។ យើងបានអធិប្បាយហើយថាយំសោកស្តាយព្រះនាងដូចយំសោកស្តាយព្រះរៀមទាំងពីររបស់ព្រះនាងដែរ ។

ស្ហៃខ៍ ស៊ូឡៃម៉ាន អាល់-ហាណាហ្វី បានធ្វើសេចក្តីរាយការណ៍នៅក្នុងសៀវភៅល្បីរបស់លោក *យ៉ាណាប៊ីអ៊ុ័ អាល់-ម៉ៅដ្ហាស្ហ៊ុ (ينابيع المودة)* វគ្គ ៥៨ - យើងសូមលើកយកតែចំណុចត្រូវការ ថា៖ "រ៉ប៊ីអ្ហាស្ហ៊ុ អាល់-សាឌីបានថ្លែងថា៖ "កាលខ្ញុំបានសួរហ៊្វូស្សៃហ្វាស្ហ៊ុច្រើនរឿង លោកបានថា៖ "សូមស្តាប់រឿងនេះនិងសូមយល់ ហើយសូមនិយាយប្រាប់គេផង ។ ខ្ញុំបានឃើញព្រះសាសនៈទូតصلى الله عليه وآله وسلمរបស់អល់ឡោះហ្វ៍عز وجل និងបានឮព្រះអង្គصلى الله عليه وآله وسلمមានព្រះវចនៈផ្ទាល់ត្រចៀកថាកាល អាល់-ហ៊្វូសៃន៍ អ៊ីបនូ អ្ហាលីصلوات الله عليه والسلامចូលមករកព្រះអង្គصلى الله عليه وآله وسلمនៅលើវេទិកា ព្រះអង្គصلى الله عليه وآله وسلمបានលើកព្រះអង្គصلوات الله عليه والسلامមក

ដាក់លើស្មាព្រះអង្គﷺ ហើយមានព្រះវចនៈថា៖ "ប្រជារាស្ត្រអើយ នេះគឺ អាល់-ហ៊្វូសៃន៍ؑ ព្រះអយ្យកោនិងព្រះអយ្យិការបស់គេؑជាមនុស្ស ប្រសើរដាច់គេ ។ ព្រះអយ្យកោរបស់គេؑជាព្រះសាសនៈទូតﷺរបស់ អល់ឡោះហ៍ﷻ និងជាព្រះអគ្គមហាប្រមុខរបស់កូនចៅអាដាំؑ... នេះគឺ អាល់-ហ៊្វូសៃន៍ؑ ព្រះបិតា ព្រះមាតា ព្រះរៀមនិងព្រះអនុជាؑរបស់ គេؑជាបុគ្គលប្រសើរដាច់គេ... ព្រះអនុជារបស់គេؑគឺស្ហៃណាប់ؑនិងរូគ៊ីយ៉ាស្ញ... ព្រះអនុជាទាំងពីររបស់គេؑនឹងបាននៅក្នុងឋាន សួគ៌ ។" [60]

ព្រះវចនៈព្រះសាស្តាមួយនេះជាភ័ស្តុតាងច្បាស់ទែង បញ្ជាក់អំពីឋានៈមិន ធម្មតារបស់ព្រះនាងស្ហៃណាប់ؑ ពីព្រោះព្រះនាងត្រូវរាប់បញ្ចូលថែម នៅក្នុងបញ្ជីព្រះសាស្តានិងអ៊ីម៉ាំទាំងឡាយ ហើយត្រូវចាត់ទុកជាបុគ្គល ប្រសើរបំផុត ។

ស្ហៃខ៍ អាល់-ស្វ៏ឌូក្វ (الشيخ الصدوق) បានធ្វើសេចក្ដីរាយការណ៍នៅក្នុង សៀវភៅលោក *អ៊ីកម៉ាល់ អាល់-ឌីន វ៉ា អ៊ីតម៉ាំ អាល់-ណាអ៊ីម៉ាស្ញ (إكمالُ الدّين و إتمامُ النِعمَة)* - យើងសូមលើកយកតែចំណុចត្រូវការ - ថា អាលី អ៊ីបនូ ម៉ាស្ញស៊ីយ៉ារ (علي بن مهزيار) បានថ្លែងថា អាប៊ូ អាល់-ហ៊្វូសៃន៍ មូហាំម៉ាដ្ញ អ៊ីបនូ យ៉ាក់ហ្វារ អាល់-អាសាឌីបានថ្លែងថា អាស្ញម៉ាដ្ញ អ៊ីបនូ អ៊ីបរ៉ហ៊ីមបានថ្លែងថា៖ "ក្នុងឆ្នាំ ២៦២ ខ្ញុំបានទៅស៊ីរ៉ាស្ញព្រះនាង ហាគីម៉ាស្ញ រាជបុត្រីរបស់ មូហាំម៉ាដ្ញ អ៊ីបនូ អាលី ដែលជាព្រះអនុជារបស់ អ៊ីម៉ាំអាល់-ហាសាន់ អាល់-អាស់ការីؑ ហើយបានសួរព្រះនាងរឿង សាសនា... ព្រះនាងមានវចនៈថា៖ "នេះគឺអ្វីដែលអាល់-ហ៊្វូសៃន៍ អ៊ីបនូ អាលីؑបានធ្វើ កាលព្រះអង្គؑបានតែងតាំងព្រះនាងស្ហៃណាប់ؑ ព្រះអនុជាព្រះអង្គؑជាតំណាងព្រះអង្គؑជាសាធារណៈ ។ៈ ហេតុ

[60] លោក អាប៊ូ អាល់-ស្ហៃខ៍ អ៊ីបនូ ហៃយ៉ាន់ បានធ្វើសេចក្ដីរាយការណ៍ហាឌីស្ហ នេះនៅក្នុងសៀវភៅ *អាល់-តាន់ប៊ីះហ៍ អាល់-ការបៀរ* ។ លោក យ៉ាម៉ាលុដ្ឌីន មូហាំម៉ាដ្ញ អ៊ីបនូ យូស៊ុហ្វ អាល់-ស្ហារ៉ាន់ឌី ក៏បានធ្វើសេចក្ដីរាយការណ៍ហាឌីស្ហ នេះដែរនៅក្នុងសៀវភៅលោក *ឌូរ៉ារ អាល់-ស៊ីមត្វយ៉ន៍* ។

ដូច្នេះ មុខតំណែងចំណោះចេះដឹងដែល អាលី អ៊ីបនូ អាល់-ហ៊ូសែន៍ صلوات الله عليه والسلام បានថានោះជាស្នាដៃរបស់ព្រះនាងស៊ែណាប់ سلام الله عليها ។"

នេះគឺភ័ស្តុតាងមួយទៀត ដែលបញ្ជាក់អំពីឋានៈខ្ពង់ខ្ពស់របស់ព្រះនាងស៊ែណាប់ سلام الله عليها សម្រាប់អ៊ីម៉ាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام ព្រោះព្រះអង្គ صلوات الله عليه والسلام បានជ្រើសរើសព្រះនាងដើម្បីទទួលកេរមរតកអ៊ីម៉ាម៉ាស៎ុដ៏ធ្ងន់ ។

ស្ញេខ៍ អាល់-មូហ្វីដូបានធ្វើសេចក្ដីរាយការណ៍ថា៖ ក្នុងសមរភូមិអាល់-យ៉ាមីល អ៊ែស្ហាស៎ុបានប្រមូលក្មេងៗនិងបម្រើស្រីៗ បានឲ្យពួកគេវាយស្គរ និងបញ្ជាឲ្យពួកគេថ្លែងពាក្យកំណាព្យប្រឆាំងអាលី صلوات الله عليه والسلام ។ ពេលព្រះនាងអ៊ូម សាឡាម៉ាស៎ុ ព្រះមហេសីរបស់ព្រះសាស្ដា صلى الله عليه وآله وسلم បានឮដំណឹងនេះ ព្រះនាងចង់ទៅកាន់កន្លែងនោះ ទៅស្ដីបន្ទោសអ៊ែស្ហាស៎ុនិងក្រុមនារីនោះ ។ ព្រះនាងស៊ែណាប់ سلام الله عليها បានសូមធ្វើការនេះជួសព្រះនាង អ៊ូម សាឡាម៉ាស៎ុ ព្រោះព្រះនាងស្គាល់បណ្ដាស្ត្រីទាំងនេះច្បាស់ ។ ដូច្នេះ ព្រះនាងនិងបម្រើស្រីៗរបស់ព្រះនាងបានក្លែងខ្លួន ហើយបានចាកចេញទៅរកក្មេងៗនិងបណ្ដាស្រីទាំងនោះ ។ ពេលព្រះនាងបានទៅដល់កន្លែងនោះ ក៏បានឃើញរឿងឥតខ្លឹមសារ ឥតប្រយោជន៍ ។ ដូច្នេះព្រះនាងក៏បានបង្ហាញមុខឲ្យអ៊ែស្ហាស៎ុស្គាល់ ហើយមានវចនៈថា៖ "នេះមិនមែនអ្វីប្លែកដែលចេញមកពីព្រះនាងនិងគូកនព្រះនាង (ពោលគឺ ហាហ្វ៉ស្សោះត៍) ទេ ដែលតែងតែចូលដៃគ្នាប្រឆាំងអាមីរុល-មុមីនីន صلوات الله عليه والسلام ព្រោះព្រះនាងទាំងពីរបានចូលដៃគ្នាប្រឆាំងព្រះរៀម صلى الله عليه وآله وسلم ព្រះអង្គ صلوات الله عليه والسلام ព្រះសាសនៈទូត صلى الله عليه وآله وسلم របស់អល់ឡោះហ្ម៍ عز وجل ដល់ថ្នាក់ព្រះគម្ពីរគួរអានស្ដីបន្ទោសព្រះនាងទាំងពីរ ។" [61]

អ៊ែស្ហាស៎ុអៀនខ្មាស់ ឆ្លើយដោះសារខ្លួនថាស្ត្រីទាំងនេះបានប្រព្រឹត្តបែបនេះដោយសេចក្ដីល្ងង់ខ្លៅ ។

ហាឌីស្ហនេះបានបំភ្លឺយ៉ាងច្បាស់អំពីសុខុមញាណ និងគតិបណ្ឌិតរបស់

[61] រឿងអ៊ែស្ហាស៎ុ និង ហាហ្វ៉ស្សោះត៍បានធ្វើផែនការណ៍ក្បត់ព្រះសាស្ដា صلى الله عليه وآله وسلم ជារឿងល្បីណាស់ ព្រោះព្រះគម្ពីរគួរអានចែងលំអិតអំពីរឿងនេះ ។ សូមមើលសៀវភៅតាហ្វសៀរទាំងអស់ដែលទាក់ទងនឹងស៊ូរ៉ោះត៍ អាត់-តាស៎ុរីម (ស៊ូរ៉ោះត៍ ៦៦) ។

ព្រះនាងស្សៃណាប់سلام الله عليها ដែលបានចូលរួមក្នុងការអភិរក្សសាសនាអ៊ីស្លាម ជាមួយព្រះបិតានិងព្រះរៀមព្រះនាង ។

ហាឌីស្សខាងក្រោមនេះមានចែងនៅក្នុងសៀវភៅ *អាល់-ទីរ៉ស្ស អាល់-មុស្ហាប់ (الطراز المذهب)* ដូចមានចែងនៅក្នុងសៀវភៅ *ណាស៊ីក្ហ អាល់-តាវ៉ារិក្ហ (ناسخ التواريخ)* ដែរគឺ៖ អព្ភូតហេតុអស្ចារ្យមួយរបស់ព្រះសាស្ដាصلى الله عليه وآله وسلمគឺ ព្រះអង្គصلى الله عليه وآله وسلمតែងតែដាក់អណ្ដាតព្រះអង្គصلى الله عليه وآله وسلم ក្នុងមាត់កូនៗរបស់ហ្វាទីម៉ាស្ហ سلام الله عليهاឲ្យបៅ កូនៗទាំងនោះឆ្អែត ។ ស្សៃណាប់سلام الله عليها និង អ៊ូម គុលស៊្ហូមក៏បាន ទទួលគុណបុណ្យនេះជាប់តមកដែរ រួមជាមួយអាល់-ហាសាន់និងអាល់-ហ៊ូសៃន៍عليهم السلام ។ ការពិត នេះជាកិត្តិយសគ្រប់គ្រាន់ណាស់សម្រាប់ព្រះនាង ស្សៃណាប់سلام الله عليها ។

សេចក្ដីរាយការណ៍តទៅនេះមានចែងនៅក្នុងសៀវភៅ *ប៊ីហារ អាល់-អាន់វ៉ារ (بحارالانوار)* ដូចមានចែងនៅក្នុងសៀវភៅ *ម៉ាអានី អាល់-អាក់ បារ (مَعانِي الأخبار)* ដែរ គឺ៖ មូហាំម៉ាដ់ អ៊ីបនូ អ៊ុំមរ៉ានបានសួរអ៊ីម៉ាំយ៉ាក់ហ្វារ អាល់-ស្ហ៊ឌិក្ហصلوات الله عليه والسلامថាតើពិតមែនទេ ដែលព្រះសាស្ដាصلى الله عليه وآله وسلمមានព្រះវចនៈថា ព្រោះតែហ្វាទីម៉ាស្ហعليهم السلامបានរក្សាព្រហ្មចារិយភាព បានជាអល់ឡោះហ្ទ៍عز وجل ហាមនរកយកព្រះរាជបុត្ររាជនត្តារបស់ព្រះនាងسلام الله عليها ។ អ៊ីម៉ាំអាល់-ស្ហ៊ឌិក្ហ صلوات الله عليه والسلامមានវចនៈថា៖ "ពិតមែន ។ ព្រះរាជបុត្ររាជនត្តារបស់ព្រះនាងسلام الله عليهاគឺ អាល់-ហាសាន់ អាល់-ហ៊ូសៃន៍ ស្សៃណាប់និងអ៊ូម គុលស៊្ហូមعليهم السلام ។"

ហាឌីស្សមុនៗគ្រាន់តែជាហាឌីស្សតូចៗ ដែលថ្លែងអំពីព្រះនាងស្សៃណាប់ سلام الله عليها ។ បានពិព័ណ៌នារួចហើយថាព្រះនាងផ្ទាល់ ជាអ្នកថ្លែងហាឌីស្សព្រះ សាស្ដាصلى الله عليه وآله وسلم និងព្រឹត្តិការណ៍ដែលព្រះនាងបានឆ្លងកាត់ដោយផ្ទាល់ ឬបាន ឮតមកពីព្រះមាតាព្រះនាង ដែលជាទីទុកចិត្ត ។

## ហាឌីស្សព្រះនាងស្សៃណាប់

សេចក្ដីរាយការណ៍ល្បីបង្អស់របស់ព្រះនាងស្សៃណាប់سلام الله عليها គឺពាក្យពេជន៍ របស់ព្រះមាតាព្រះនាងអំពីហ្វាដាក់ ។

នៅក្នុងសៀវភៅ *ស្ហារ ណាស់យ៉ាល់-បាឡាក៉ោះត៍* លោក អ៊ីបនូ អាប៊ូ

អាល់-ហ្វាឌីដ្ធ បានធ្វើសេចក្ដីរាយការណ៍ពាក្យពេជន៍នេះតមកពីលោកអ្នកតំណាលតៗគ្នាដែលបានថ្លែងតមកពីព្រះនាងស្វៃណាប់سلام الله عليها ច្រើនបែប ។ អ៊ុប់ឌុលឡោះហ្វ៍ អ៊ីបនូ អ៊ុប់បាស់ក៏បានថ្លែងពាក្យពេជន៍នេះតមកពីព្រះនាងស្វៃណាប់سلام الله عليهاដែរ[62] ។ ព្រះនាងបានធ្វើសេចក្ដីរាយការណ៍ព្រះវចនៈចុងក្រោយរបស់ព្រះបិតាព្រះនាងដែរ កាលព្រះអង្គបានប្រាប់ព្រះរៀមទាំងពីររបស់ព្រះនាង និងពាក្យផ្ដាំផ្ញើរបស់ព្រះអង្គឲ្យផ្ងូតព្រះរាជសពព្រះអង្គដូចម្ដេចខ្លះ ឲ្យបញ្ចុះព្រះរាជសពព្រះអង្គនៅកន្លែងណា ។ ព្រះនាងបានធ្វើសេចក្ដីរាយការណ៍អំពីកំណើតរបស់អ៊ីម៉ាំអាល់-ហ៊្វូសែន៍صلوات الله عليه والسلامដែរ តមកពីព្រះមាតាព្រះនាង ។ [63]

ព្រះនាងស្វៃណាប់سلام الله عليهاបានធ្វើសេចក្ដីរាយការណ៍ រឿងអាហារសួគ៌ដែរដែលព្រះនាងហ្វាទីម៉ាស្ទ៍ អាស្ស-ស្វាស្ទ់រ៉អ៊្វ៍سلام الله عليهاបានបួងសួងសូមព្រះម្ចាស់عز وجل ដើម្បីឲ្យព្រះបិតាព្រះនាងសោយ[64] ។ ព្រះនាងបានធ្វើសេចក្ដីរាយការណ៍ដែរ អំពីរឿងព្រះមាតាព្រះនាងបួងសួងឲ្យបណ្ដាអ្នកមានសទ្ធាថា៖ "អ្នកជិតខាងគប្បីមានសមាជិកគ្រួសារនាំមុខ[65] ។"

ព្រះនាងបានថ្លែងប្រាប់ព្រះភាតុបុត្តព្រះនាង អ៊ីម៉ាំ ស្វៃន៍ អាល់ អ៊ុប៊ីឌីនصلوات الله عليه والسلامនូវព្រះវចនៈព្រះសាស្ដាصلى الله عليه وآله وسلمអំពីព្រឹត្តិការណ៍ ដែលព្រះអង្គទាំងអស់នឹងពើបពះអត់ពីព្រះអង្គصلى الله عليه وآله وسلمទៅ [66] ។ ព្រះនាងបានថ្លែងព្រះវចនៈព្រះបិតាព្រះនាងដើម្បីបញ្ជាក់សម្ដីរបស់ អ៊្វូម អ៊ៃម៉ាន ដែលបានថ្លែងរឿងដូចនេះ ។

---

[62] សូមមើលសៀវភៅរបស់លោក អាប៊ូ អាល់-ហ្វារ៉ជ្ជ អាល់-អ៊ីស្វហ្វាហ្វានី (أبو الفرج الإصفهاني) និង សៀវភៅ អាល់-អាក៏្ញនី (الأغاني) ។

[63] សូមមើលសៀវភៅរបស់លោក អ៊ុលី អាល់-ខ្ស៊ស្វាស្ទ់ អាល់-គុម្មី (علي الخزاز القمي) *គីហ្វាយ៉ាស្ទ៍ អាល់-អាស្សារ (كفاية الاثر)* ។

[64] សូមមើលសៀវភៅរបស់លោក អ៊ីម៉ាដ្ធ៍ អាល់-ឌីន មូហ្វាំម៉ាដ្ធ៍ អ៊ីបនូ អ៊ុលី អាល់-ទូសី, *ស្វាគ៊ីប អាល់-ម៉ាណាគ៊ីប ។*

[65] សូមមើលសៀវភៅរបស់លោក ស្វៃខ៍ អាស្ស៊ម៉ាដ្ធ៍ ស្វៃនុដ្ធឌីន អាល់-អ៊ិះសាអ៊ី, *អាល់-ម៉ាយ៉្ជាមីអ៊៍ ។*

[66] សូមមើលសៀវភៅរបស់លោក អ៊ីបនូ កៅ្ញឡាឡាវៃហ្វ៍, *កាមីល អាល់-ស្វីយ៉ារ៉ត់ ។*

# ព្រឹត្តិការណ៍ខ្លោចផ្សា

ព្រះនាងស្វៃណាប់عليها السلام បានរស់នៅក្រោមអាណាព្យាបាលរបស់ព្រះអយ្យកោព្រះនាង ព្រះសាស្តាមូហាំម៉ាដ់ﷺ កាលព្រះនាងនៅក្នុងវ័យកុមារ ។ នៅក្នុងអំឡុងពេលនេះ ព្រះនាងនៅក្នុងសេចក្តីស្ងប់និងសេចក្តីស្រណុក ព្រោះព្រះអង្គﷺតែងតែទទួលព្រះនាងដោយសេចក្តីរាក់ទាក់និងកិត្តិយស ។ ព្រះមាតាបិតាព្រះនាងក៏អាណិតស្រឡាញ់ព្រះនាងដែរ ។ ព្រះនាងបានឃើញអ៊ីស្លាមទទួលជោគជ័យធំ ឃើញសត្រូវរបស់អ៊ីស្លាមទទួលបរាជ័យ ។

កាលនៅក្នុងវ័យកុមារ កត្តាសំខាន់បំផុតដែលព្រះនាងស្វៃណាប់عليها السلامបានកត់សម្គាល់គឺព្រះសាស្តាﷺបានយកចិត្តទុកដាក់ ជាពិសេសនឹងព្រះមាតាបិតានិងព្រះរៀមព្រះនាង[67] ។ ព្រះនាងយល់ថាការយកចិត្តទុកដាក់

---

[67] ព្រះសាស្តាមូហាំម៉ាដ់ﷺបានឲ្យទៅរកព្រះរាជកុលដ្ឋានព្រះអង្គﷺស្ទើរតែគ្រប់ឱកាសនិងកាលៈទេសៈ ។ ព្រះអង្គﷺបានផ្តាំផ្ញើឲ្យមុស្លីមតាមព្រះរាជកុលដ្ឋានព្រះអង្គﷺ ឲ្យយកព្រះរាជកុលដ្ឋានព្រះអង្គﷺតែមួយជាមេដឹកនាំ ពីព្រោះការលំអៀងចេញពីសាសនានឹងកើតមានឡើងយ៉ាងពិតប្រាកដ បើបោះបង់ចោលមាគ៌ារបស់ព្រះរាជកុលដ្ឋានព្រះអង្គﷺ ។ និយាយម្យ៉ាងទៀតថា ព្រះសាស្តាមូហាំម៉ាដ់ﷺបានបង្ហាញព្រះរាជកុលដ្ឋានព្រះអង្គﷺ ជាបុគ្គលនិងជាប្រភពតែមួយគត់ ដែលដឹកនាំឲ្យបានទៅដល់សេចក្តីស្រឡាញ់របស់អល់ឡោះហ៍تعالى ។ ឧទាហរណ៍ សេចក្តីរាយការណ៍មួយនេះនៅក្នុងសៀវភៅរបស់លោក អាល់-ត៏បារី *ស្សាខ៏អៀរ អាល់-អ៊ុក្ខបា* (ذخائر العقبى) ទំព័រ ២៤; *ម៉ាជ់ម៉ាក់ អាល់-ស្សាវ៉ាអ៊ិដ* (مجمع الزوائد), ក្បាលទី ៩ ទំព័រ ១៦៩; *អាន់សាប់ អាល់-អាស្សរ៉ហ្វ* (أنساب الأشراف), ក្បាលទី ១ ទំព័រ ១៥៧ និង សៀវភៅហាឌីស្សយោងច្រើនទៀត ដែលឲ្យដឹងថាព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "ព្រះរាជកុលដ្ឋានعليهم السلامរបស់ខ្ញុំﷺ ក្នុងចំណោមអស់លោក ប្រៀបបាននឹងសំពៅរបស់នុះហ៍عليه السلام អ្នកណាឡើងជិះសំពៅនេះ អ្នកនោះប្រាកដជារួចខ្លួន តែអ្នកណាចោលសំពៅនេះ អ្នកនោះនឹងលិចលង់ ។ ព្រះរាជកុលដ្ឋានعليهم السلامរបស់ខ្ញុំﷺ ក្នុងចំណោមអស់លោក ក៏ដូចទ្វារនៃខមាទោសសម្រាប់បណ្តាកូនចៅអ៊ីស្សរ៉អ៊ីលដែរ អ្នកណាចូលតាមទ្វារនេះ អ្នក

ជាពិសេសចំពោះព្រះមាតាបិតានិងព្រះរៀមព្រះនាងនេះ មិនមែនគ្រាន់តែជាចេតនារម្មណ៍ ឬជាគំនិតឯងទេ ។ តែវាមានដើមកំណើតមកពីព្រះបញ្ញាដើម្បីសម្តែង នូវសេចក្តីស្រឡាញ់ចំពោះលក្ខណៈសុក្រឹតឥតខ្ចោះរបស់បុគ្គលជាទីស្រឡាញ់ និងដើម្បីសម្តែងនូវសេចក្តីទុកចិត្តចំពោះពួកគេដែលជាអ្នកដឹកនាំអ៊ុមម៉ាត់អ៊ីស្លាម ។

នេះគឺសម័យសប្បាយរីករាយបំផុតក្នុងជីវិតព្រះនាងស្ហ្វៃណាប់سلام الله عليها ។

ប៉ុន្តែសេចក្តីសប្បាយរីករាយនេះមិនមានតទៅទៀតទេ ។ ព្រះសាស្តាមូហាំម៉ាដ្ឋ៍ﷺដឹងខ្លួនថាព្រះអង្គﷺជិតសោយទិវង្គត ក៏បានប្រាប់ព្រះរាជបុត្រីព្រះអង្គﷺឲ្យដឹង[68] ។ ដំណឹងនេះបានជះទុក្ខនិងសេចក្តីសោកសៅមកលើព្រះរាជវង្សព្រះសាស្តាﷺ ព្រមទាំងមុស្លីមទាំងឡាយដែរដែលគិតដល់ជីវិតថ្មីដោយគ្មានព្រះអគ្គមហាប្រមុខដឹកនាំ និងព្រះសាស្តារបស់ខ្លួន ។

## សុបិនរបស់ព្រះនាងស្ហ្វៃណាប់سلام الله عليها

ថ្ងៃមួយ ព្រះនាងស្ហ្វៃណាប់سلام الله عليهاបានសុបិនអាក្រក់ ។ ដូច្នេះ ព្រះនាងប្រញាប់ទៅរកព្រះអយ្យកោ ថ្លែងប្រាប់ព្រះអង្គនូវសុបិនព្រះនាង ។ ព្រះសាស្តាﷺបានលើកព្រះនាងមកអង្គុយលើភ្លៅ ថើបព្រះនាងថ្នមៗ ហើយបានឲ្យព្រះនាងថ្លែងសុបិនព្រះនាងប្រាប់ព្រះអង្គﷺ ។ ព្រះនាងបានទូលថា៖ "យប់មិញ ខ្ញុំម្ចាស់បានឃើញដូចជាខ្យល់ខ្លាំងធ្វើឲ្យមនុស្សទាំងអស់ទៅជាខ្មៅងងឹត ។ ដូច្នេះខ្ញុំម្ចាស់រត់ទៅជ្រកក្រោមដើមឈើធំមួយ តោងស្លឹកវាយ៉ាងជាប់ដើម្បីកុំឲ្យខ្យល់ផាត់ខ្ញុំម្ចាស់ឃ្លាតទៅឆ្ងាយ ។ អកុសលខ្យល់នោះបានធ្វើឲ្យដើមឈើនោះរលើងឫស រលំមកលើដី ។ ខ្ញុំម្ចាស់តោងមែកឈើមាំមួយ តែខ្យល់នោះធ្វើវាដាច់ពីដើមឈើនោះ ។ ខ្ញុំម្ចាស់ក៏ខំតោងមែកមួយទៀត តែខ្យល់ក៏បានធ្វើឲ្យមែកឈើនោះបាក់ដែរ ។ ខ្ញុំ

---

នោះនឹងបានទទួលការលើកលែងទោស ។"

[68] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ស្ហាស្ហ៍រ អាស្ហ៊ូប (ابن شهراشوب) *ម៉ាណាគ៊ីប អាលី អ៊ីបនូ អាប៊ី ត៉ូលិប (مَناقِبُ آلِ أبی طالب)* ក្បាលទី ១ ទំព័រ ១៦៧ ។

ម្ចាស់ក៏ព្យាយាមតោងស្លឹកឈើមួយ ក្នុងចំណោមស្លឹកឈើពីរ តែខ្យល់ព្យុះបានធ្វើឲ្យវាដាច់ ។ ខ្ញុំម្ចាស់ក៏បានភ្ញាក់ពីដំណេក ។"
បានស្តាប់សុបិនព្រះនាងហើយ ព្រះសាស្តាﷺទ្រង់ព្រះកន្សែង ហើយបកស្រាយសុបិនថា៖ "ដើមឈើគឺព្រះអយ្យកោរបស់ចៅ ។ មែកឈើទីមួយគឺមាតាចៅ មួយទៀតគឺព្រះបិតាចៅ ។ ឯស្លឹកពីរទៀតគឺព្រះរៀមចៅ អាល់-ហាសាន់និងអាល់-ហ៊ូសៃន៍عليهم السلام ។ ពិភពលោកនឹងងងឹត ពេលពួកគេعليهم السلام ចាកចោលលោកនេះ ចៅនឹងគ្រងសំលៀកបំពាក់កាន់ទុក្ខពួកគេعليهم السلام[69] ។"

## -ពិធីហាជ្ជលាគ្នា (ចុងក្រោយ)

ពេលព្រះសាស្តាﷺដឹងខ្លួនថាព្រះអង្គﷺជិតចាកចោលលោកនេះ ព្រះអង្គﷺបានបើកអង្គប្រជុំសាធារណៈជាមួយមុស្លីម ហើយបានជ្រើសរើសអាជ្ញាធរនិងអ្នកដឹកនាំដែលនឹងដឹកនាំពេលអត់ពីព្រះអង្គﷺ ។ ដើម្បីបំពេញគោលដៅនេះ ព្រះសាស្តាﷺបានបំពេញពិធីហាជ្ជចុងក្រោយដែលគេហៅថាពិធីហាជ្ជលាគ្នា ។ ព្រះអង្គﷺបានចាកចេញពីកន្លែងមួយទៅកាន់កន្លែងមួយទៀតក្នុងចំណោមពួកមុស្លីម ដើម្បីដឹកនាំពួកគេទៅកាន់មាគ៌ាផុតទុក្ខភ័យ និងដឹកនាំពួកគេទៅរកមេដឹកនាំដែលពួកគេត្រូវតាមពេលអត់ពីព្រះអង្គﷺ ។ ព្រះអង្គﷺមានព្រះវចនៈច្រើនដងថា៖

أَيُّهَا ٱلنَّاسُ، إِنِّي تَرَكْتُ فِيكُمُ ٱلثَّقَلَيْنِ: كِتَابَ اللهِ وَعِتْرَتِي أَهْلَ بَيْتِي.

*"ប្រជារាស្ត្រអើយ ខ្ញុំﷺទុកឲ្យអស់លោកវត្ថុមានតម្លៃពីរគឺ៖ ព្រះគម្ពីរអល់ឡោះហ៍عز وجل និងរាជបុត្រារាជនត្តាខ្ញុំﷺ - ព្រះរាជកុលដ្ឋានខ្ញុំﷺ ។"*[70]
ព្រះសាស្តាﷺបានឈប់ក្បែរអណ្តូងទឹកស៊ាំស៊ាំ បានថ្លែងសុន្ទរកថាឱឡារិក នៅក្នុងសុន្ទរកថានោះព្រះអង្គﷺស្តីអំពីរឿងទាំងអស់ដែល

---

[69] សូមមើលសៀវភៅ *អាល់-ស្ស៊ីហ្វារ៉ះហ៍* ក្បាលទី ២ ទំព័រ ៣០៨ របស់លោក អាល់-តៀរមីស៊ុី ។

[70] សូមមើលសៀវភៅរបស់លោក អាល់-យ៉ាក់គូប៊ី (اليعقوبي) *អាល់-តារិក្ហ (التاريخ),* ក្បាលទី ២ ទំព័រ ៩១-៩២ ។

មនុស្សត្រូវដឹងពេលអត់ពីព្រះអង្គﷺ ។ អំពីរឿងដឹកនាំអ៊ុមម៉ាត្ន់ ព្រះអង្គﷺបានប្រកាសយ៉ាងច្បាស់ថា៖

إِنِّي خَلَّفْتُ فِيكُمْ مَا إِنْ تَمَسَّكْتُمْ بِهِ لَنْ تَضِلُّوا بَعْدِي أَبَداً: كِتَابَ اللهِ وَعِتْرَتِي أَهْلَ بَيْتِي. أَلاَ هَلْ بَلَّغْتُ

*"ខ្ញុំﷺទុកឲ្យអស់លោក នូវអ្វីដែលការពារអស់លោកពីការឃ្លៀងឃ្លាតបើអស់លោកតោងឲ្យជាប់ព្រះគម្ពីរនិងបណ្តាកូនចៅខ្ញុំﷺ - ព្រះរាជកុលដ្ឋានខ្ញុំﷺ ។ តើខ្ញុំﷺបានប្រាប់អស់លោកឲ្យដឹង (រឿងនេះ) ហើយឬទេ ?" មនុស្សចំនួន ១០០ ០០០ នាក់នៅក្នុងអង្គប្រជុំនោះបានឆ្លើយតបដោយសម្លេងតែមួយថា៖ "ព្រះអង្គﷺបានប្រាប់ឲ្យដឹងហើយ ។"*[71]

ក្រោយពីបានបំពេញពិធីហាច្ចចុងក្រោយហើយ ព្រះសាស្តាﷺបានទទួលព្រះរាជសារ ដាក់បង្គាប់ឲ្យព្រះអង្គﷺតែងតាំងអ៊ីម៉ាំអាលីصلوات الله عليه والسلامជាអ្នកស្នងព្រះអង្គﷺនិងជាអាជ្ញាធរលើអ៊ុមម៉ាត្ន់ទាំងមូល ។ ព្រះរាជសារគឺព្រះបន្ទូលអល់ឡោះហ៍تعالى៖

يَـٰٓأَيُّهَا ٱلرَّسُولُ بَلِّغْ مَآ أُنزِلَ إِلَيْكَ مِن رَّبِّكَ ۖ وَإِن لَّمْ تَفْعَلْ فَمَا بَلَّغْتَ رِسَالَتَهُۥ ۚ وَٱللَّهُ يَعْصِمُكَ مِنَ ٱلنَّاسِ ۗ إِنَّ ٱللَّهَ لَا يَهْدِى ٱلْقَوْمَ ٱلْكَـٰفِرِينَ

*សាស្តាអើយ ចូរអ្នកផ្សព្វផ្សាយអ្វីដែលគេបានបើកឲ្យអ្នកដឹងមកពីព្រះម្ចាស់អ្នក ។ បើអ្នកមិនធ្វើ[ការផ្សព្វផ្សាយនោះ]ទេ [ព្រោះខ្លាចមនុស្សកំណាច វាដូចជា]អ្នកពុំបានផ្សព្វផ្សាយ[ប្រាប់មនុស្សជាតិ]នូវព្រះរាជសាររបស់ព្រះអង្គទេ ។ អល់ឡោះហ៍នឹងការពារអ្នកទល់បណ្តាមនុស្ស ។ ពិតណាស់អល់ឡោះហ៍មិនដឹកនាំ[ដោយបង្ខំ]ជនបដិសេធសទ្ធាទេ*
*(៥:៦៧) ។*[72]

ដូច្នេះព្រះអង្គﷺបានឲ្យក្រុមអ្នកធ្វើពិធីហាច្ចឈប់ ហើយប្រជុំគ្នានៅ

---

[71] សូមមើលសៀវភៅ *អាល់-កុំដៀរ* ក្បាលទី ២ ទំព័រ ៣៤ ។

[72] សូមមើលសៀវភៅរបស់លោក អាល់-វ៉ាហ៊ីឌី *អាស់បាប់-អាល់-នូស៊ុល (أسباب النزول)*, សៀវភៅ *អាល់-តាហ្វសៀរ* របស់លោក អាល់-រ៉ស៊ី, និងសៀវភៅតាហ្វសៀរច្រើនទៀត (គឺសៀវភៅសម្រាយគួរអាន) ។

កន្លែងមួយដែលគេហៅថា "ក៏ដៀរ ឃុម"។ ធាតុអាកាសក្តៅណាស់ មនុស្សម្នាឈរលើពំនូកអាវធំដើម្បីកុំឲ្យកម្តៅផ្ទៃដីក្តៅមកដល់បាតជើង ។ នៅក្នុងស្ថានភាពបែបនេះ ព្រះអង្គﷺបាននាំស្វ៏ឡាត់ជុំគ្នា ហើយបានឲ្យសាវកព្រះអង្គﷺលើកវេទិកាមួយ ។ ព្រះអង្គﷺបានឡើងលើវេទិកានេះ ហើយបានថ្លែងសុន្ទរកថាសំខាន់បំផុត ក្នុងជីវិតរបស់មុស្លីមទាំងអស់ ។ កត្តាសំខាន់បំផុតក្នុងសុន្ទរកថានេះ គឺព្រះអង្គﷺបានហៅអ៊ីម៉ាំអាលី صلوات الله عليه والسلام បានចាប់ដៃអ៊ីម៉ាំអាលី صلوات الله عليه والسلام បានលើកអ៊ីម៉ាំអាលី صلوات الله عليه والسلام ឡើងតាមដែលព្រះអង្គﷺអាចធ្វើបាន ហើយព្រះអង្គﷺបានប្រកាសជាឱឡារិកនិងយ៉ាងត្រង់ៗថា៖

مَنْ كُنْتُ مَوْلاَهُ فَهٰذَا عَلِيٌّ مَوْلاَهُ. اَللّٰهُمَّ وَالِ مَنْ وَالاَهُ، وَعَادِ مَنْ عَادَاهُ، وَأَحِبَّ مَنْ أَحَبَّهُ، وَابْغَضْ مَنْ أَبْغَضَهُ، وَانْصُرْ مَنْ نَصَرَهُ، وَاخْذُلْ مَنْ خَذَلَهُ، وَأَدِرِ ٱلحَقَّ مَعَهُ حَيْثُ دَارَ. أَلاَ فَلْيُبَلِّغِ ٱلشَّاهِدُ ٱلْغَائِبَ.

*"អ្នកណាក៏ដោយដែលមានខ្ញុំﷺជាអភិបាល (ឬ ម្ចាស់ អគ្គប្រមុខ...) អាលី صلوات الله عليه والسلام ជាអភិបាលរបស់អ្នកនោះ ។ អល់ឡោះហ៍ عز وجل អើយ សូមព្រះអង្គ عز وجل ទទួលបុគ្គលណាដែលទទួលគេ صلوات الله عليه والسلام សូមព្រះអង្គ عز وجل ជាសត្រូវរបស់អ្នកណាដែលជាសត្រូវរបស់គេ صلوات الله عليه والسلام សូមព្រះអង្គ عز وجل ទ្រង់សព្វព្រះហឫទ័យអ្នកណាដែលស្រឡាញ់គេ صلوات الله عليه والسلام សូមព្រះអង្គ عز وجل ស្អប់អ្នកណាដែលស្អប់គេ صلوات الله عليه والسلام សូមព្រះអង្គ عز وجل ព្រះរាជទានជោគជ័យឲ្យអ្នកណាដែលគាំទ្រគេ صلوات الله عليه والسلام សូមព្រះអង្គ عز وجل ធ្វើឲ្យខូចចិត្តអ្នកណាដែលធ្វើឲ្យគេ صلوات الله عليه والسلام ខូចចិត្ត សូមព្រះអង្គ عز وجل ដឹកនាំការពិតទៅកាន់ទិសដៅដែលគេ صلوات الله عليه والسلام យក ។ បណ្តាអ្នកមានវត្តមាននៅទីនេះ មានកាតព្វកិច្ចផ្សាយបណ្តាំនេះប្រាប់បណ្តាអ្នកដែលអវត្តមាន[73] ។"*

ព្រះសាស្តាﷺ បានផ្សាយព្រះរាជសារព្រះម្ចាស់ عز وجل ព្រះអង្គﷺស្រេចបាច់ហើយ ទើបព្រះម្ចាស عز وجل បានបើកឲ្យដឹងថា៖

[73] សូមមើលសៀវភៅរបស់លោក អាស្ម៉ាដ្ង់ អ៊ីបនូ ហ្ហាន់បាល់ *អាល់-មុសណាដ្ង់,* ក្បាលទី ៤ ទំព័រ ២៨១ ។

ٱلۡيَوۡمَ أَكۡمَلۡتُ لَكُمۡ دِينَكُمۡ وَأَتۡمَمۡتُ عَلَيۡكُمۡ نِعۡمَتِي وَرَضِيتُ لَكُمُ ٱلۡإِسۡلَٰمَ دِينٗاۚ

*ថ្ងៃនេះអញបានធ្វើឲ្យសាសនាពួកអ្នកសុក្រឹតឥតខ្ចោះ សម្រាប់ពួកអ្នក បានបង្គ្រប់ឧបការធម៌អញលើពួកអ្នក ហើយអញបានជ្រើសយកអ៊ីស្លាម ជាសាសនាសម្រាប់ពួកអ្នក (៥:៣) ។*[74]

ចាប់តាំងពីកុមារភាពមកម្ល៉េះ ព្រះនាងស្ទើរណាប់បានសម្រេចការអប់រំរបស់ព្រះសាស្តាﷺមួយនេះ ហើយបានគោរពដឹងគុណចំពោះព្រះបិតាព្រះនាង - អ៊ីម៉ាំអាលី صلوات الله عليه والسلام - បានសម្រេច គឺការគោរពដឹងគុណដែលអ៊ុមម៉ាត់ត្រូវតែធ្វើ ។ ម្យ៉ាងទៀត ព្រះនាងដឹងថាអភិបាលភាពរបស់ព្រះបិតាព្រះនាងជាព្រះបញ្ញត្តិ អាស្រ័យហេតុនេះ វាជាគ្រឹះមួយរបស់សាសនានេះ ។

## ជម្ងឺចុងក្រោយរបស់ព្រះសាស្តាﷺ

លុះព្រះសាស្តាﷺបានត្រឡប់មកពីបំពេញពិធីហាជ្ជលាគ្នាវិញ ព្រះអង្គﷺទ្រង់ប្រឈួន ។ ត្រូវរោគគ្រុនក្តៅបៀតបៀនជាដំណំ បង្ខំឲ្យព្រះអង្គﷺងើបពីដំណេកមិនបាន ។ ពេលពួកមុស្លីមបានទទួលដំណឹងអកុសលនេះ ក៏បានរួសរាន់មកសួរសុខទុក្ខព្រះអង្គﷺជាក្រុមៗ ។ ព្រះអង្គﷺបានផ្តាំឲ្យពួកគេកុំចោលអភិបាលភាពរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام ក្រោយពីព្រះអង្គﷺបានចាកលោកនេះ[75] ។

---

[74] សូមមើលសៀវភៅ *អាល់-តារិក អាល់-បាក់ដាដ់* ក្បាលទី ២ ទំព័រ ២៩ របស់លោក អាល់-ខ៉ិទិប អាល់-បាក់ដាឌី, សៀវភៅរបស់លោក អាល់-ស៊ូយូទី (السيوطي) *អាល់-ឌួរ អាល់-ម៉ាន់ស៊ួរ (الدر المنثور)* និងសៀវភៅប្រវត្តិសាស្ត្រនិងហាឌីស្ទយោងច្រើនទៀត ។

[75] សូមមើលសៀវភៅរបស់លោក អាស្ស៊ុម៉ាដ់ ហ៊្សៃសែន៍ យ៉ាក៉ុគូប The Conception of the Sahaba's Ultimate Decency and the Political Authority in Islam បកប្រែជាភាសាអង់គ្លេសដោយលោក Badr Shahin បោះ ពុម្ពដោយរោងពុម្ព Ansariyan Publications – Qum, 1998 ។

ព្រោះតែរឿងអ៊ីម៉ាំអាលី صلوات الله عليه والسلام អនាគតអ្នកដឹកនាំអ៊ុមម៉ាត់ នោះសំខាន់បំផុតបានជាព្រះសាស្ដា صلى الله عليه وآله وسلم ថ្លែងបំភ្លឺច្រើនលើកច្រើនគ្រា គ្រប់កាលៈទេសៈ ។ ព្រះអង្គ صلى الله عليه وآله وسلم តែងតែមានព្រះវចនៈថា៖

هٰذَا عَلِيٌّ مَعَ ٱلْقُرْآنِ، وَٱلْقُرْآنُ مَعَ عَلِيٍّ؛ لاَ يَفْتَرِقَانِ حَتَّىٰ يَرِدَا عَلَيَّ ٱلحَوْضَ.

*"ពិតណាស់ អាលី صلوات الله عليه والسلام នៅជាប់ជាមួយគួរអានជានិច្ច គួរអាននៅជាប់ជាមួយអាលី صلوات الله عليه والسلام ជានិច្ច ។ ទាំងពីរនេះមិនបែកគ្នាឡើយ លុះគ្រាបានមកជួបខ្ញុំ صلى الله عليه وآله وسلم នៅឯព្រះរាជស្រះ[76] ។"*

ព្រះអង្គ صلى الله عليه وآله وسلم បានធ្វើមុនការបំពានការសម្រេចរបស់ព្រះអង្គ صلى الله عليه وآله وسلم ក្រោយពីព្រះអង្គ صلى الله عليه وآله وسلم បានសោយទិវង្គត ដូច្នេះព្រះអង្គ صلى الله عليه وآله وسلم បានដាក់ព្រះបញ្ជាលើអស់បុគ្គលដែលជាប់សង្ស័យថានឹងប្រព្រឹត្តបែបនេះ[77] ឲ្យទៅចូលរួមក្នុងកងទ័ព ហើយទៅកាន់ប្រទេសស៊ីរីក្នុងសមរភូមិមួយដើម្បីចៀសវាងកុំឲ្យអស់បុគ្គលជាប់សង្ស័យទាំងនេះបះបោរ ក្រោយពីព្រះអង្គ صلى الله عليه وآله وسلم សោយទិវង្គត[78] ។ តែបុគ្គលទាំងនេះយល់គោលដៅបង្គាប់របស់ព្រះសាស្ដា صلى الله عليه وآله وسلم ។ ដូច្នេះពួកគេបានសម្រេចចិត្តបះបោរប្រឆាំងបង្គាប់ព្រះអង្គ صلى الله عليه وآله وسلم មិនព្រមទៅចូលរួមក្នុងសមរភូមិនោះទេ ។

ទោះបីព្រះសាស្ដា صلى الله عليه وآله وسلم ទ្រង់ព្រះប្រឈួនក៏ដោយ ព្រះអង្គ صلى الله عليه وآله وسلم ឡើងមិនបារ (គឺវេទិកាក្នុងម៉ាស់ឃិដ្ឋ) ដាក់បញ្ជាឲ្យបណ្ដាសាវកព្រះអង្គ صلى الله عليه وآله وسلم ទៅប្រយុទ្ធ

---

[76] សូមមើលសៀវភៅ *អាល់-ស្វ៏វ៉ាអ៊ីក្វ អាល់-មុះហ្ក៏រីក្វោះត៍ (الصواعق المحرقة)* ទំព័រ ១២៤ ។

[77] អាប៊ូ បាការ, អ៊ុម៉ារ អ៊ីបនូ អាល់-ខត្តត្ទប់, អាប៊ូ អ៊ុបៃដ្ធាស្ស៍ អ៊ីបនូ អាល់-យ៉ារ៉ោះត៍ ជាបុគ្គលចំបងដែលព្រះសាស្ដា صلى الله عليه وآله وسلم ប្រាប់ហើយប្រាប់ទៀត ឲ្យទៅចូលរួមប្រយុទ្ធក្នុងសមរភូមិ ។ តែក្រោយមក បុគ្គលជាប់សង្ស័យទាំងនេះបានក្លាយទៅជាមេដឹកនាំចលនាបះបោរ ។

[78] សូមមើលសៀវភៅរបស់លោក អាល់-មុតតាគ្គី អាល់-ហ៊ុនឌី (المتقي الهندي) *កាន់ស៍ អាល់-អ៊ុមម៉ាល់ (كنز العمال)* ក្បាលទី ៥ ទំពព័រ ៣១២; សៀវភៅរបស់លោក អ៊ីបនូ សាអាដ្ធ៍ *អាត់-តាបាក្វត់ (الطبقات)* ក្បាលទី ៤ ទំព័រ ៤៦ និងសៀវភៅ *តារិក្ខ អាល់-ខ៏មីស (تاريخ الخميس)* ក្បាលទី ២ ទំព័រ ៤៦ ។

ក្នុងសមរភូមិ ។ នៅទីបំផុត ព្រះអង្គﷺបានដាក់បណ្តាសាអ្នកណាដែលល្មើសព្រះបញ្ជានេះ[79] ។ ការគំរាមដ៏ធ្ងន់នេះបញ្ជាក់គោលបំណងព្រះអង្គﷺយ៉ាងច្បាស់ណាស់សម្រាប់បុគ្គលទាំងនោះ ដែលធ្វើអ្វីគ្រប់យ៉ាងដើម្បីគេច មិនចង់ចាកចេញពីម៉ាឌីណាស្ញកាលនោះ ។

## មហន្តរាយថ្ងៃព្រហស្បតិ៍

លើកទីពីរ ដើម្បីប៉ុនប៉ងទប់ស្កាត់ផែនការណ៍អាក្រក់របស់បនក្បត់ជាមុនក្នុងគ្រាអវសានព្រះជន្ម កាលព្រះអង្គﷺត្រូវចោមរោមដោយបណ្តាសាវកដែលមានបនក្បត់ចូលរួមនោះ ព្រះសាស្តាﷺបានឲ្យគេយកដបទឹកខ្មៅនិងប៉ាកកាមកឲ្យព្រះអង្គﷺ ដើម្បីសរសេរទុកឲ្យពួកគេនូវមរតកសាសន៍ចុងក្រោយរបស់ព្រះអង្គﷺដែលសំខាន់បំផុត ។ ព្រះអង្គﷺបានប្រាប់ឲ្យដឹងថាមរតកសាសន៍នោះនឹងជួយពួកគេឲ្យរួចផុតពីការវង្វេង ដើរខុសមាគ៌ា[80] ។

បនក្បត់យល់គំនិតព្រះសាស្តាﷺ ដូច្នេះពួកវាបានបង្កឲ្យកើតមានហេតុការណ៍ឡូឡាដោយនិយាយស្រែកខ្លាំងៗ - អ្នកខ្លះគាំទ្រការសុំរបស់ព្រះសាស្តាﷺ អ្នកខ្លះទៀតបដិសេធយ៉ាងព្រហើន ។ ប្លែកណាស់ដែលឃើញបុគ្គលបែបនេះបដិសេធបណ្តាំ មរតកសាសន៍ចុងក្រោយរបស់ព្រះសាស្តាﷺ ដែលស្គាល់ព្រះសាស្តាﷺច្បាស់ថាព្រះអង្គﷺមិនដែលនិយាយអ្វីតាមតែចិត្តឯងឡើយ[81] ។

---

[79] សូមមើលសៀវភៅ *អាល់-ស៊ីរ៉ោះត៍ អាល់-ហាឡាប៊ីយ៉ាស្ញ (السيرة الحلبية)*, ក្បាលទី ៣ ទំព័រ ៣៤ ។

[80] ព្រឹត្តិការណ៍ដ៏ល្បីនេះមានចែងនៅក្នុងសៀវភៅហាឌីស្ញ ដែលគួរឲ្យទុកចិត្តបំផុតរបស់មុស្លីមស៊ុននី ដូចជាសៀវភៅ *អាល់-ស្វ៉ហ៊ិះហ៍* របស់លោក អាល់-ប៊ូខ៊ំរី, សៀវភៅ *អាល់-ស្វ៉ហ៊ិះហ៍* របស់លោក មុស្លីម, សៀវភៅ *អាល់-មុអ៊្យ៉ាំ អាល់-អៅសាត្ញ (المعجم الاوسط)* របស់លោក អាល់-ត្ញបារ៉នី (الطبراني)

[81] សូមមើលព្រះបន្ទូលអល់ឡោះហ្ញ៍تعالى (ស៊ូរ៉ោះត៍ ៥៣ អាយ៉ាស្ញ ២-៥) គឺ៖

مَا ضَلَّ صَاحِبُكُمْ وَمَا غَوَىٰ وَمَا يَنْطِقُ عَنِ الْهَوَىٰ إِنْ هُوَ إِلَّا وَحْيٌ يُوحَىٰ عَلَّمَهُ شَدِيدُ الْقُوَىٰ

ស្ត្រីខ្លះបានដឹងរឿងនេះ ក៏បានរួសរាន់ទៅស្តីបន្ទោសបុគ្គលទាំងនេះដែលបានបង្ខូចកិត្តិយសដោយហ៊ានប្រឆាំងព្រះបញ្ជាព្រះសាស្តាﷺ ។ ក្រុមដែលគាំទ្រព្រះសាស្តាﷺហៀបនឹងឈ្នះ តែបុគ្គលមួយចំនួន (ពោលគឺ អ៊ុម៉ារ អ៊ិបនូ អាល់-ខុត្ត៉ុត្តប់) បានទន្ទ្រានប្រកាសពាក្យសម្តីអាក្រក់ថា៖ "ព្រះសាស្តាﷺឡប់ស្មារតីហើយ !" [82]

ព្រឹត្តិការណ៍នេះ ជាព្រឹត្តិការណ៍ប្រកបដោយមហន្តរាយធំបំផុតមួយនៅក្នុងប្រវត្តិសាស្ត្រអ៊ីស្លាម ។ អ៊ុប់ឌុលឡោះហ្វ៍ អ៊ិបនូ អ៊ុប់បាស់ អាជ្ញាធរកំពូលរបស់អ៊ុមម៉ាត់អ៊ីស្លាម តែងតែស្រក់ទឹកភ្នែកកាលណាលោករំលឹកព្រឹត្តិការណ៍នេះឡើង ។ លោកបានហៅព្រឹត្តិការណ៍នេះថា "មហន្តរាយថ្ងៃព្រហស្បតិ៍" ។ [83]

ដោយពិនិត្យមើលព្រឹត្តិការណ៍ទាំងនេះ ព្រះនាងស្ហ៊ែណាប់سلام الله علیهاស្គាល់គោលដៅរបស់បុគ្គល ដែលប៉ងទាត់ព្រះបិតាព្រះនាងចេញពីតំណែងដែលអល់ឡោះហ្វ៍تعالى និងព្រះសាស្តាមូហាំម៉ាដ់ﷺបានជ្រើសរើសឲ្យព្រះអង្គ ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍នេះបានបើកផ្លូវឲ្យឧបសគ្គច្រើនទៀតជ្រាបចូល ដូចជាសោកនាដកម្មការបាឡាអ៊ុំជាដើម ។

## ទុក្ខព្រួយរបស់ព្រះនាងហ្វាទីម៉ាស់ អាស់-ស្ហាស់រ៉អ៊ុំسلام الله علیها

ព្រះនាងហ្វាទីម៉ាស់ អាស់-ស្ហាស់រ៉អ៊ុំسلام الله علیهاព្រួបារម្ភបំផុតដោយសារជម្ងឺព្រះ

---

*មិត្តរបស់ពួកអ្នកមិនប្រព្រឹត្តខុសទេ ហើយមិនវង្វេងទេ ហើយគេមិននិយាតាមតែទំនើងចិត្តឯងទេ ។ នេះមិនមែនអ្វីផ្សេងពីការបើកឲ្យដឹង (វ៉ាហ៊ុី) ដែលត្រូវបានបើកឲ្យដឹង (វ៉ាហ៊ុី) នោះទេ ។ ព្រះដ៏មានព្រះមហិទ្ធឫទ្ធិឧត្តុងឧត្តម (អល់ឡោះហ្វ៍) បានបង្ហាត់បង្រៀនគេ (៥៣:២-៥) ។*

[82] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហ៊ាឌីដ្ស *ស្ហារហ៊្ណាស់យ៉ាល់-បាឡាកោះត៍* ក្បាលទី ៣ ទំព័រ ១១៩ ។

[83] ទោះបីសៀវភៅហ៊ាឌីស្ហយោងទាំងអស់ បានកត់ត្រាព្រឹត្តិការណ៍នេះក៏ដោយ តែភាគច្រើនមិនបើកឲ្យដឹងឈ្មោះរបស់បុគ្គល ដែលបាននិយាយជាសាធារណៈនូវសម្តីអាក្រក់អពមង្គលនេះទេ ។

បិតាﷺព្រះនាង ។ ព្រះនាងនៅក្បែរព្រះអង្គﷺ សង្រេងចិត្តហាក់ដូចជាព្រះនាងកំពុងតែរងការស្លាប់[84] ។ ព្រះសាស្តាﷺបានឃើញបុត្រីជាទីស្រឡាញ់នៅក្នុងសភាពនេះ ក៏បានលួងលោមនិងសម្រាលទុក្ខព្រួយព្រះនាង ។ ព្រះអង្គﷺបានប្រាប់ព្រះនាងនូវការណ៍សម្ងាត់មួយ ។ ព្រះនាងហូរទឹកភ្នែក ។ បន្ទាប់មកព្រះអង្គﷺបានប្រាប់ការណ៍មួយទៀត ជាការណ៍សម្ងាត់ដែរ តែលើកនេះព្រះនាងញញឹម ។

ពេលអ៊ែស្ហាស៊្វ មហេសីរបស់ព្រះសាស្តាﷺ សួរព្រះនាងហ្វាទីម៉ាស៊្វسلام الله عليها អំពីការសម្ងាត់ដែលធ្វើឲ្យព្រះនាងទ្រង់កន្សែងនិងទ្រង់សិតាការៈ (គឺញញឹម) ព្រះនាងسلام الله عليهاបានបែរមុខចេញពីអ៊ែស្ហាស៊្វ មិនប្រាប់ទេ ។ ប៉ុន្តែព្រះនាងسلام الله عليهاបានប្រាប់ស្ត្រីត្រឹមត្រូវមួយចំនួនអំពីរឿងនេះ ។ ព្រះនាងسلام الله عليهاមានវចនៈថា៖ "ដំបូងព្រះបិតាﷺខ្ញុំسلام الله عليهاបានប្រាប់ខ្ញុំسلام الله عليهاថា មិនយូរទេព្រះអង្គﷺនឹងចាកលោកនេះ ។ ដំណឹងនេះបានធ្វើឲ្យខ្ញុំسلام الله عليهاយំ ។ បន្ទាប់មកព្រះអង្គﷺបានប្រាប់ខ្ញុំسلام الله عليهاថា ខ្ញុំسلام الله عليهاនឹងបានទៅជួបព្រះអង្គﷺមុនគេនៅឋានសួគ៌ ។ ព្រះអង្គﷺបានប្រាប់ខ្ញុំعليهم السلامដែរថា ខ្ញុំسلام الله عليهاជាអគ្គនាយិការបស់បណ្តាស្ត្រីនៃសហគមន៍នេះ ។ ដំណឹងនេះធ្វើឲ្យខ្ញុំسلام الله عليهاសប្បាយចិត្ត ។" [85]

ព្រះនាងស៊ែណាប់سلام الله عليهاបានចូលរួមទុក្ខព្រួយព្រះមាតាព្រះនាង ។ ព្រះនាងអាណិតព្រះមាតានិងព្រះអយ្យកោព្រះនាង ។ ជិតចូលទិវង្គត ព្រះសាស្តាﷺបានបួងសួងអល់ឡោះហ៍عزّ وجلّ សូមឲ្យព្រះអង្គعزّ وجلّថែរក្សាព្រះរាជកុលដ្ឋានព្រះអង្គﷺ និងសូមឲ្យចិត្តអ្នកមានសទ្ធាប្រុសស្រីជួយឈឺឆ្អាលព្រះរាជកុលដ្ឋានទាំងអស់عليهم السلام ។

នៅគ្រាអវសានព្រះជន្ម ព្រះអង្គﷺបានសូមឲ្យបម្រើទាំងអស់មើលថែរក្សាព្រះរាជកុលដ្ឋាននិងព្រះរាជបុត្ររាជនត្តាព្រះអង្គﷺថា៖

قَدْ خَلَّفْتُ فِيكُمْ كِتَابَ اللهِ وَعِتْرَتِي أَهْلَ بَيْتِي. فَالمُضَيِّعُ لِكِتَابِ اللهِ كَالمُضَيِّعِ لِسُنَّتِي،

---

[84] សូមមើលសៀវភៅរបស់លោក អាស៊ុម៉ាដ្ឋ អ៊ីបនូ ហ៊ាន់បាល់ *អាល់-មុសណាដ្ឋ,* ក្បាលទី ១ ទំព័រ ៣៥៥ ។

[85] សូមមើលសៀវភៅរបស់លោក បាគ្វៀរ ស្ហារីហ្វ អាល់-ក៏រ៉ស្ហ៊ី (شريف القرشي) *ហ្វាយ៉ាស៊្វ អាល់-អ៊ីម៉ាំ អាល់-ហ្វាសាន់ (حياة الامام الحسن)* ក្បាលទី ១ ទំព័រ ១១៣ ។

وَٱلْمُضَيِّعُ لِسُنَّتِي كَالْمُضَيِّعِ لِعِتْرَتِي. إِنَّهُمَا لَنْ يَفْتَرِقَا حَتَّىٰ يَرِدَا عَلَيَّ ٱلْحَوْضَ.

*"ខ្ញុំﷺទុកឲ្យអស់លោកនូវព្រះគម្ពីរអល់ឡោះហ្ទ៍ﷻ និងរាជបុត្ររាជនត្តាខ្ញុំﷺ - រាជកុលដ្ឋានខ្ញុំﷺ ។ បោះបង់ព្រះគម្ពីរអល់ឡោះហ្ទ៍ﷻដូចបោះបង់ស៊ុណាត់ខ្ញុំﷺដែរ បោះបង់ស៊ុណាត់ខ្ញុំﷺដូចបោះបង់រាជបុត្ររាជនត្តាខ្ញុំﷺដែរ ។ ពួកគេ (គឺព្រះគម្ពីរអល់ឡោះហ្ទ៍ﷻនិងអាស្ល់លុល-បៃត៍) នឹងមិនបែកគ្នាឡើយ លុះពួកគេនឹងបានមកជួបខ្ញុំﷺនៅឯព្រះរាជស្រះ ។"*[86]

## ព្រះសាស្តាមូហាំម៉ាដ់ﷺចូលទិវង្គត

ព្រះសាស្តាﷺបានដកដង្ហើមចុងក្រោយក្នុងលោកនេះ ហើយបានចាកចោលព្រះជន្មាយុនៅលើភ្លៅអ៊ីម៉ាំអាលីصلوات الله عليه والسلام ។[87]

អ៊ីម៉ាំصلوات الله عليه والسلامក៏បានរៀបចំពិធីបុណ្យព្រះរាជសពក្នុងពេលរងទុក្ខធំ ។ ព្រះអង្គصلوات الله عليه والسلامបានផ្ងូតទឹកព្រះរាជសពព្រះសាស្តាﷺ ហោព្រះរាជសពក្នុងកាហ្វាន់ស្វ៍ឡាត់ឲ្យអ្នកស្លាប់ ហើយបានអនុញ្ញាតឲ្យមុស្លីមស្វ៍ឡាត់ឲ្យសពដោយមានវចនៈថា៖ "សូមសិរីសួស្តី ព្រះមេត្តាប្រណីរបស់អល់ឡោះហ្ទ៍ﷻ និងព្រះពរជ័យកើតមានដល់ព្រះអង្គﷺ ឱព្រះសាស្តាﷺនៃព្រះមេត្តាធម៌ ។ អល់ឡោះហ្ទ៍ﷻអើយ អស់ទូលព្រះបង្គំជាខ្ញុំសូមប្រកាសយ៉ាងស្មោះថាព្រះអង្គﷺបានប្រាប់អ្វីៗដែលគេបានបើកឲ្យព្រះអង្គﷺដឹងនោះ ឲ្យសហគមន៍ព្រះអង្គﷺដឹងសព្វគ្រប់ហើយ ថាព្រះអង្គﷺបានប្រយុទ្ធដើម្បីអល់ឡោះហ្ទ៍ﷻ លុះអល់ឡោះហ្ទ៍ﷻបានពង្រឹងព្រះសាសនាព្រះអង្គﷻ ហើយបានធ្វើព្រះបន្ទូលព្រះអង្គﷻទៅជាពិត ។ អល់ឡោះហ្ទ៍ﷻអើយ សូមព្រះអង្គﷻដឹកនាំអស់ទូលព្រះបង្គំជាខ្ញុំ ឲ្យអនុចរតាមអ្វីដែលគេបានបើក

---

[86] សូមមើលសៀវភៅរបស់លោក អាល់-ខ៉ូវ៉ារីស្មី (الخوارزمي) *អាល់-ម៉ាណាគ៊ីប,* ក្បាលទី ១ ទំព័រ ១១៤ ។

[87] សូមមើលសៀវភៅរបស់លោក អាល់-មុតតាគ៊ី អាល់-ហ្ទ៊ីនឌ្វី (المتقي الهندي) *កាន់ស៊្ហ៍ អាល់-អ៊ុមម៉ាល់ (كنز العمال)* ក្បាលទី ២ ទំព័រ ៥៥; សៀវភៅរបស់លោក អ៊ីបនូ សាអ៊ុដ្ទ៍ *អាត់-តាបាក្វត់ (الطبقات),* និងសៀវភៅប្រវត្តិសាស្ត្រយោងច្រើនទៀត ។

ឲ្យព្រះអង្គﷺដឹង សូមព្រះអង្គﷻធ្វើឲ្យអស់ទូលព្រះបង្គំជាខ្ញុំនៅលើមាគ៌ានេះតរៀងទៅ និងសូមព្រះអង្គﷻធ្វើឲ្យអស់ទូលព្រះបង្គំជាខ្ញុំនៅជាប់ជាមួយព្រះអង្គﷺ ។" [88]

បន្ទាប់មក អ៊ីម៉ាំអាលីصلوات الله عليه والسلامបានបញ្ចុះព្រះរាជសពព្រះសាស្ដាﷺក្នុងផ្នូរ បានឈរនៅឯក្បាលផ្នូរ ស្រក់ទឹកភ្នែកនិងថ្លែងទុក្ខសោក ។

ព្រះនាងហ្វាទីម៉ាស់ អាស់-ស្ហាស់រ៉អ៍سلام الله عليهاសោកសៅជាងគេបង្អស់ ហាក់ដូចជាស្ទើរបាត់បង់វិញ្ញាណដោយសារទុក្ខព្រួយនិងយំខ្លាំងពេក ។ នៅក្នុងកាលៈទេសៈបែបនេះ ព្រះនាងមានវចនៈថា៖ "ព្រះបិតាអឺយ ព្រះសាសនៈទូតﷺអល់ឡោះហ្ញ៉ាﷻអឺយ ព្រះសាស្ដាﷺនៃព្រះមេត្តាធម៌អឺយ ចាប់ពីពេលនោះតទៅការបើកឲ្យដឹងមកពីលើមេឃនឹងចប់ ។ ចាប់ពីពេលនេះតទៅយ៉ីប់រ៉អ៊ីលعليه السلامនឹងមិនមកលេងយើងទេ ។ អល់ឡោះហ្ញ៉ាﷻអឺយ [ខ្ញុំម្ចាស់ជាខ្ញុំបួងសួងព្រះអង្គﷻ] សូមព្រះអង្គﷻឲ្យខ្ញុំម្ចាស់ជាខ្ញុំបាននៅជាប់ជាមួយព្រះអង្គﷺ សូមព្រះអង្គﷻទ្រង់ព្រះអាណិតមេត្តាខ្ញុំម្ចាស់ជាខ្ញុំដោយឲ្យខ្ញុំម្ចាស់ជាខ្ញុំបានឃើញមុខព្រះអង្គﷺ ។ អល់ឡោះហ្ញ៉ាﷻអឺយ ខ្ញុំម្ចាស់ជាខ្ញុំអង្វរសូមព្រះអង្គﷻកុំផ្ដាច់រង្វាន់ព្រះអង្គﷺពីខ្ញុំម្ចាស់ជាខ្ញុំ និងកុំផ្ដាច់ការជួយធ្វើអន្តរាគមន៍របស់ព្រះអង្គﷺពីខ្ញុំម្ចាស់ជាខ្ញុំឡើយ ក្នុងថ្ងៃរស់ពីស្លាប់វិញ ។" [89]

ក្រោយពីព្រះសាស្ដាﷺបានសោយទិវង្គត ព្រះរាជកុលដ្ឋានព្រះអង្គﷺបានរងសេចក្ដីសោកសៅនិងទុក្ខព្រួយ ។ ម្យ៉ាងទៀត ព្រះរាជកុលដ្ឋានព្រះសាស្ដាﷺរងការតក់ស្លុតនិងការខ្លាចព្រោះតែបានដឹងជាមុន ថានឹងត្រូវពួកអារ៉ាប់បៀតបៀន ដើម្បីសងសឹកព្រះសាស្ដាﷺដែលពួកគេចាត់ទុកជាអ្នកបង្កឲ្យមានទុក្ខសោកនៅក្នុងគ្រប់ផ្ទះ ។ អ៊ីម៉ាំយ៉ាក់ហ្វារ អាល់-ស្វ៉ឌិក្វصلوات الله عليه والسلامមានវចនៈអំពីរឿងនេះថា៖ "កាលព្រះសាស្ដាﷺបានចាកចោលលោកនេះ ព្រះរាជកុលដ្ឋានព្រះអង្គﷺទទួលអារម្មណ៍ដូចជាគ្មាន

---

[88] សូមមើលសៀវភៅរបស់លោក អាល់-មុតតាគ្គី អាល់-ហ៊្វីនឌ្វី (المتقي الهندي) *កាន់ស៊្វ អាល់-អ៊ុមម៉ាល់ (كنز العمال)* ក្បាលទី ៤ ទំព័រ ៥៤ ។

[89] សូមមើលសៀវភៅ *តារិក្វ អាល់-ខ៊្វមីស (تاريخ الخميس)* ក្បាលទី ២ ទំព័រ ១៩២ ។

ជម្រក គ្មានសោះឡើយ សូម្បីតែមេឃក៏មិនអាចការពារព្រះរាជកុលដ្ឋានពីខាងលើបានឡើយ រីឯផែនដីក៏មិនអាចការពារព្រះរាជកុលដ្ឋានពីខាងក្រោមបានឡើយ ។"
ព្រះនាងស្រ៊ែណាប់ﷺ ទោះបីព្រះនាងនៅក្មេងវ័យក៏ដោយ ព្រះនាងរងការឈឺចាប់យ៉ាងខ្លាំងដោយសារទុក្ខវេទនាដ៏ធំនេះ ។ ព្រះនាងបានពើបពះផលវិបត្តិដែលកើតពីព្រឹត្តិការណ៍នេះ ។ ព្រះនាងមានព្រះជន្មត្រឹមតែប្រាំខួបពេលគ្រោះកាចទន្ទ្រានលើបេះដូងខ្ចីព្រះនាង ។ ព្រះនាងបានឃើញ ព្រះអយ្យកោជាទីស្រឡាញ់ចាកចោលដោយគ្មានថ្ងៃវិលត្រឡប់វិញ បានឃើញព្រះបិតាព្រះនាងលេបទុក្ខព្រួយព្រោះតែបាត់បង់បងជីតាមួយ បានឃើញព្រះមាតាព្រះនាងពាំទុក្ខ និងយំខ្លាំងសោកស្តាយព្រះបិតាដែលបានចែកស្ថាន ។ ការពិត ថ្ងៃនោះជាដើមទីនៃការសោយទុក្ខសោយគ្រោះរបស់ព្រះនាងស្រ៊ែណាប់ﷺ ។

## រជ្ជកាលខ៉ូលិហ្វ

ព្រះគម្ពីរគួរអានបានរៀបរាប់យ៉ាងស្ទាត់ជំនាញ ពុំមានអ្នកណាអាចរៀបរាប់ចក្ខុវិស័យនេះដូចឡើយ អំពីសោកនាដកម្មដែលអ៊ុមម៉ាត់អ៊ីស្លាមពើបពះដោយសារអត់ព្រះសាស្តាមូហាំម៉ាដ់ﷺ ។ ព្រះគម្ពីរគួរអានចែងថា៖

وَمَا مُحَمَّدٌ إِلَّا رَسُولٌ قَدْ خَلَتْ مِنْ قَبْلِهِ الرُّسُلُ ۚ أَفَإِنْ مَاتَ أَوْ قُتِلَ انْقَلَبْتُمْ عَلَىٰ أَعْقَابِكُمْ ۚ وَمَنْ يَنْقَلِبْ عَلَىٰ عَقِبَيْهِ فَلَنْ يَضُرَّ اللَّهَ شَيْئًا ۗ وَسَيَجْزِي اللَّهُ الشَّاكِرِينَ

*មូហាំម៉ាដ់គ្រាន់តែជាសាស្តាម្នាក់ (គឺសាស្តាក្រោយបង្អស់) ។ មុនគេ មានសាស្តាជាច្រើនបានចាកលោកនេះទៅហើយ ។ បើសិនជាគេស្លាប់ ឬត្រូវសម្លាប់ ពួកអ្នកនឹងត្រឡប់ក្រោយវិញមែនទេ ? អ្នកណាមួយត្រឡប់ក្រោយវិញ អ្នកនោះពុំអាចធ្វើឲ្យអល់ឡោះប៉ះខូចខាតអ្វីឡើយ ។ អល់ឡោះប្រទានតបស្នងបណ្តាអ្នកដឹងព្រះគុណ (៣:១៤៤) ។*

ការពិត សោកនាដកម្មអន្តរាយបំផុតដែលពើបពះលើអ៊ុមម៉ាត់អ៊ីស្លាម

ពេលអត់ពីព្រះសាស្តាصلى الله عليه وآله وسلمនោះ គឺការទាត់ព្រះរាជ កុលដ្ឋានعليهم السلامចេញពីវិស័យនយោបាយ និងការបើកដៃឲ្យបុគ្គលមិនសក្តិសមទៅជាអ្នកដឹកនាំ ។ ក្រៅពីឧបសគ្គច្រើនទៀតដែលអ៊ុមម៉ាត់អ៊ីស្លាមជួបប្រទះដោយសារព្រឹត្តិការណ៍ទាំងនេះ រឿងនេះបណ្តាលឲ្យបណ្តាអ្នកកាន់ក្តាប់ត្រកូលអ៊ូម៉ៃយ៉ាស់ឡើងកាន់អំណាច ។ បុគ្គលទាំងនេះប្រព្រឹត្តយ៉ាងសាហាវយង់ឃ្នងចំពោះមុស្លីមទូទៅ និងចំពោះព្រះរាជកុលដ្ឋានعليهم السلامព្រះសាស្តាصلى الله عليه وآله وسلمជាពិសេស ។

និយាយឲ្យខ្លី ផែនការទាត់អ៊ីម៉ាំអាលីصلوات الله عليه والسلامចេញពីតំណែងដឹកនាំអ៊ុមម៉ាត់អ៊ីស្លាម ជាឧបាយនៅពីក្រោយការកាប់សម្លាប់ព្រះរាជកុលដ្ឋានعليهم السلامព្រះសាស្តាصلى الله عليه وآله وسلم និងបណ្តាសាវកស្មោះត្រង់របស់អ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامនៅឯការបាឡាអ៊័ ដោយដៃកងទ័ពអ៊ូម៉ៃយ៉ាស់ ។

ដូច្នេះព្រឹត្តិការណ៍ដែលបានកើតឡើង នៅក្នុងរជ្ជកាលស្តេចខ៊ំលិហ្វទាំងបីមុនៗនោះ ជាស្នាមច្បាស់ក្រឡែតដែលជិតជាប់នៅក្នុងជីវិតព្រះនាងស្វែណាប់سلام الله عليها ។ យើងសូមលើកយកនូវព្រឹត្តិការណ៍ទាំងនេះខ្លះមកអធិប្បាយជូន ។

## ផែនការណ៍ក្បត់អាល់-សាគីហ្វាស់

ក្នុងពេលដែលគេមិនទាន់បានបញ្ចុះព្រះរាជសពព្រះសាស្តាصلى الله عليه وآله وسلم នៅឡើយ បុគ្គលអាន់ស្វារ (أنصار)[90] មួយចំនួនប្រញាប់ប្រជុំគ្នាដោយសម្ងាត់ក្នុងសាគីហ្វាស់ - គឺរោង - របស់ពួកបានូ សាអ៊ីដ្ឋាស់ដើម្បីស្នើសូមឲ្យពួកគេម្នាក់ដឹកនាំអ៊ុមម៉ាត់អ៊ីស្លាម ព្រោះពួកគេចុះដៃធ្វើមុនដូច្នេះដើម្បីកុំឲ្យពួកមូហ្វាយ៊ីរូន (مهاجرون)[91] ក្តាប់អំណាចទាន់ ។

---

[90] អាន់ស្វារ គឺអ្នកគាំទ្រ គឺពួកអ្នកស្រុកម៉ាឌីណាស់ (អតីតយ៉ាស្ស៊ីរីប) ដែលគាំទ្រព្រះសាស្តាصلى الله عليه وآله وسلمនិងជនភៀសខ្លួននៃស្រុកម៉ាក់កាស់ បន្ទាប់ពួកគេបានចាកចេញពីស្រុកកំណើត ។

[91] មូហ្វាយ៊ីរីន គឺជនភៀសខ្លួន គឺពួកអ្នកស្រុកម៉ាក់កាស់ដែលបានចាកចោលស្រុកកំណើត ព្រោះតែត្រូវជនរួមស្រុករបស់ខ្លួនធ្វើបាបព្រោះខ្លួនបានកាន់

សាអុដ្ធ អ៊ីបនូ អ៊ូបាដាស្ទុ (سعد بن عبادة) មេដឹកនាំកុលសម្ព័ន្ធអាល់-ខ្ហស់រ៉ច្ចុ បានប្រកាសថា លោកអបអរសាទរចំពោះការតស៊ូដើម្បីអ៊ីស្លាមរបស់ពួកអាន់ស្វារ ថាពួកអាន់ស្វារសក្តិសមជាងគេក្នុងការដឹកនាំអ៊ុមម៉ាត់អ៊ីស្លាមជាងកុលសម្ព័ន្ធគូរ៉យស្ហ៍ដែលប្រឆាំងព្រះសាស្តាﷺ ហើយបានប៉ងធ្វើគុតព្រះអង្គﷺ ។

មេដឹកនាំអាន់ស្វារម្នាក់ទៀត ពោលគឺ អាល់-ហ៊ាប់បាប់ អ៊ីបនូ អាល់-មុនស្ហៀរ (الحباب بن المنذر) បានប្រកាសព្រមានជនរួមកុលសម្ព័ន្ធគូរ៉យស្ហ៍របស់លោក ហើយបានផ្តល់យោបល់សូមឲ្យពួកគេយកពួកគូរ៉យស្ហ៍ចូលរួមក្នុងការកាន់អំណាចផង ព្រោះលោកគិតជាមុនថាបណ្តាកូនចៅរបស់បណ្តាអ្នកដែលបានស្លាប់ក្នុងការប្រយុទ្ធរបស់ព្រះសាស្តាﷺនោះ នឹងឡើងកាន់អំណាចហើយនឹងសងសឹកមកលើពួកអាន់ស្វារ ។

អកុសល ការគិតជាមុនរបស់លោកអាល់-ហ៊ាប់បាប់ អ៊ីបនូ មុនស្ហៀរនោះទៅជាពិតដូចស្មាន ។ ពេលមូអាវីយ៉ាស្ទុ អ៊ីបនូ ស៊ុហ្វយ៉ាន ដែលមានសាច់ញាតិស្លាប់ ដោយដៃបណ្តាអ្នកការពារអ៊ីស្លាមក្នុងសមរភូមិព្រះសាស្តាﷺ នោះ បានឡើងកាន់អំណាច ។ មូអាវីយ៉ាស្ទុ អ៊ីបនូ ស៊ុហ្វយ៉ានបំបាក់មុខពួកអាន់ស្វារដោយចេតនា ហើយបានធ្វើឲ្យពួកគេទៅជាជនក្រីក្រ ។ យ៉ាស៊ីដ្ធ កូនរបស់មូអាវីយ៉ាស្ទុ បានប្រព្រឹត្តអាក្រក់លើសនេះទៅទៀត ។ បុគ្គលនេះបានប្លន់យកទ្រព្យពួកគេ បានបង្ហូរឈាមពួកគេ បានរំលោភសិទ្ធិពួកគេ ។

## ពួកមូហាយីរូនលេចមុខច្រងោ

ក្នុងពេលដែលពួកអាន់ស្វារកំពុងតែពិភាក្សាគ្នារឿងដឹកនាំ ក្នុងអនាគតពួកគេភ្ញាក់ផ្អើលព្រោះអាប៊ូ បាការ, អ៊ូម៉ារ អីបនូ អាល់-ខ្ហត្តុប់, អាប៊ូ អ៊ូបៃដាស្ទុ អ៊ីបនូ អាល់-យ៉ារ៉ោះត៍, សាលីមនិងមូហាយីរូនច្រើននាក់ទៀតបានលេចមុខច្រងោ ។ ថ្វីបើការប្រជុំរបស់ពួកអាន់ស្វារជាការប្រជុំសម្ងាត់

---

សាសនាអ៊ីស្លាម ។

ក៏ដោយ ពួកអាន់ស្វារត្រូវបើកមុខ ផែនការសម្ងាត់ពួកគេក៏ត្រូវបរាជ័យ ។ ដោយឃើញឱកាសល្អ អាប៊ូ បាការបានប្រកាសដោយវោហារកោសល្យ ថាពួកមូហាជៀរីនជាអ្នកចូល និងជាអ្នកការពារសាសនាអ៊ីស្លាមមុនគេបង្អស់ ។ បន្ទាប់មកគាត់បានស្នើទុកតំណែងអគ្គប្រមុខរងឲ្យពួកអាន់ស្វារ ហើយទុកតំណែងមេដឹកនាំឲ្យប្រជាកុលសម្ព័ន្ធរបស់គាត់និងរូបគាត់

នៅក្នុងការប្រកាសនេះ អាប៊ូ បាការមិននិយាយដល់ព្រះសាស្តាមូហាំម៉ាដ់ صلى الله عليه وآله وسلم ដែលសោយទិវង្គត ឬនិយាយដល់អាស្ហ៍លុល-បៃត៍ عليهم السلام នោះទេ ។ យ៉ាងហោចណាស់ គាត់គួរតែដាក់កំហិតឲ្យលើកការប្រជុំនេះនៅពេលក្រោយវិញព្រោះមិនទាន់បានបញ្ចុះព្រះរាជសពព្រះសាស្តា صلى الله عليه وآله وسلم ទេ ។ គាត់គួរតែនឹកឃើញបណ្តាំព្រះសាស្តា صلى الله عليه وآله وسلم ដែលព្រះអង្គ صلى الله عليه وآله وسلم បានផ្តាំហើយផ្តាំទៀតថាឲ្យជ្រើសរើសយកអ៊ីម៉ាំអាលី صلوات الله عليه والسلام ជាអ្នកស្នងព្រះអង្គ صلى الله عليه وآله وسلم និងជាតំណាង ។

ទោះជាយ៉ាងណាក៏ដោយ បក្សគាត់ប្រញាប់ប្រញាល់គាំទ្រគាត់ និងអបអរសាទរព្រមគោរពគាត់ជាមេដឹកនាំបន្ទាប់ ។ អ៊ូម៉ារ អ៊ីបនូ អាល់-ខុត្តុប់ ដោយប្រើដំបងនិងវិធីកាចដ៏ល្បី បានដើរតួសំខាន់ក្នុងឆាកល្ខោននេះ ។ ការពិតពួកគេដើរតួបានដោយជោគជ័យ ពីព្រោះពួកគេបានស្គាល់ផែនការរបស់ខ្លួនហើយបានមូលមតិគ្នាជាស្រេចបាច់ហើយ ។ មិនចូលរួមក្នុងពិធីបុណ្យព្រះរាជសពព្រះសាស្តា صلى الله عليه وآله وسلم ទេ បក្សអាប៊ូ បាការ បានលីអាប៊ូ បាការ ទៅកាន់ម៉ាស់យ៊ិដូរ៉ស៊ូលុលឡោះហ៍ صلى الله عليه وآله وسلم ដូចគេហែអាពាហ៍ពិពាហ៍ ។

## អ៊ីម៉ាំអាលី صلوات الله عليه والسلام និងការគោរពបុគ្គលមិនស្របច្បាប់

ពេលអ៊ីម៉ាំអាលី អាមីរុល-មុមីនីន صلوات الله عليه والسلام បានដឹងផែនការពួកគេ ព្រះអង្គ صلوات الله عليه والسلام មិនព្រមគោរព មិនព្រមទទួលស្គាល់រដ្ឋបាលខុសច្បាប់របស់អាប៊ូ បាការទេ ព្រោះព្រះអង្គ صلوات الله عليه والسلام ចាត់ទុករឿងនេះជាបទរំលោភសិទ្ធិព្រះអង្គ صلوات الله عليه والسلام យ៉ាងជាក់ស្តែង ។ ស្ថានភាពរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام នៅក្នុងទំនាក់ទំនងជាមួយថ្នាក់ដឹកនាំអ៊ុមម៉ាត់អ៊ីស្លាមដូចស្នូលនិងត្បាល់កិន ។ ទឹកហូរចុះមក

ពីព្រះអង្គ صلوات الله عليه والسلام តែសត្វមិនអាចហើរទៅដល់ព្រះអង្គ صلوات الله عليه والسلام បានទេ[92] ។ ទោះជាយ៉ាងណាក៏ដោយ អាប៊ូ បាការនិងបក្សគាត់មូលមតិគ្នាបង្ខិតបង្ខំអ៊ីមុាំអាលី صلوات الله عليه والسلام ដោយគ្រប់មធ្យោបាយ ឲ្យព្រមទទួលស្គាល់គាត់ជាមេដឹកនាំអុមម៉ាត់អ៊ីស្លាម ។ ដូច្នេះពួកគេបានបញ្ជូនទ័ពទៅចាប់ខ្លួនព្រះអង្គ صلوات الله عليه والسلام នៅឯលំនៅដ្ឋាន បង្ខំព្រះអង្គ صلوات الله عليه والسلام ឲ្យចេញពីក្នុងផ្ទះ ។ ការប្រកែករបស់អ៊ីមុាំ صلوات الله عليه والسلام ប្រឆាំងពួកគេនោះប៉ិនប្រសប់និងមានប្រសិទ្ធិភាពណាស់ ទើបពួកគេមិនមានអ្វីសមហេតុ សមផលឆ្លើយតបព្រះអង្គ صلوات الله عليه والسلام វិញបាន[93] ។ ដូច្នេះព្រះអង្គ صلوات الله عليه والسلام ត្រឡប់មកលំនៅវិញ ដោយមិនបានទទួលស្គាល់អាប៊ូបាការជាមេដឹកនាំទេ ។

នៅឯលំនៅដ្ឋាន សេចក្តីព្រួយបារម្ភបៀតបៀនអ៊ីមុាំ صلوات الله عليه والسلام ដែលត្រូវគេប្លន់សិទ្ធិនៅចំពោះមុខតែម្តង ។ ចំណែកឯសមាជិកព្រះរាជវង្សព្រះអង្គ صلوات الله عليه والسلام ក៏ត្រូវរលកព្រួយបារម្ភបៀតបៀនដែរ ។ នៅក្នុងចំណោមសមាជិកព្រះរាជវង្សនេះមានព្រះនាងស្រៃណាប់ سلام الله عليها ព្រះរាជកុមារីតូចមួយអង្គដែលបានឃើញព្រះបិតាទប់ទុក្ខព្រួយនិងខំអត់ធ្មត់ ឃើញព្រះមាតាទ្រង់កន្សែងសោកស្តាយព្រះបិតា صلى الله عليه وآله وسلم ដែលបានសោយទិវង្គត និងអាណិតព្រះស្វាមីដែលកំពុងព្រួយបារម្ភ ។

## វិធានការតឹងរ៉ឹងប្រឆាំងអាស្ហ៍លុល-ស៊ៃបត៍ عليهم السلام

ទទួលបរាជ័យក្នុងការបង្ខិតបង្ខំអ៊ីមុាំអាលី صلوات الله عليه والسلام ឲ្យព្រមទទួលស្គាល់ខ្លួនជាមេដឹកនាំអុមម៉ាត់អ៊ីស្លាម អាប៊ូ បាការប្រើមធ្យោបាយមិនគម្បីច្រើនដើម្បីបង្ខំអ៊ីមុាំអាលី صلوات الله عليه والسلام ឲ្យលះបង់សិទ្ធិព្រះអង្គ صلوات الله عليه والسلام ។ ជាដំបូងពួកគេបានលុប

[92] នេះគឺពាក្យស្លោកដែលអ៊ីមុាំអាលី صلوات الله عليه والسلام ផ្ទាល់តែងតែប្រើ ពេលនិយាយអំពីការប្លន់យកតំណែងព្រះអង្គ صلوات الله عليه والسلام ដែលអល់ឡោះហ្ទ៍ تعالى និងព្រះសាស្តា صلى الله عليه وآله وسلم បានតែងតាំងឲ្យព្រះអង្គ صلوات الله عليه والسلام ។ សូមមើលសៀវភៅ *ណាស្ហ៍យ៉ាល់-បាឡាកោះត៍,* ឃុត្ថបាស្ហ៍ ស្ហាក់ស្ហាគីយ៉ាស្ហ៍ លេខ ៣ ។

[93] សូមមើលសៀវភៅរបស់លោក អ៊ីបនូ គូតៃបាស្ហ៍ (بن قتيبة) *អាល់-អ៊ីម៉ាម៉ាស្ហ៍ វ៉ា អាល់-ស៊ីយ៉ាសាស្ហ៍,* ក្បាលទី ១ ទំព័រ ១១-១២ ។

យុមស៍ (គឺមួយភាគប្រាំ) ចោល គឺពន្ធដែលអល់ឡោះហ្វ៍ﷻព្រះរាជទាន ឲ្យព្រះសាស្ដាមូហាំម៉ាដ្ឋ៍ﷺនិងព្រះរាជវង្សعليهم السلامព្រះអង្គﷺជាច់មុខ ។ អាប៊ូ បាការបានដាក់បញ្ញាឲ្យហ៊ុមព័ទ្ធសេដ្ឋកិច្ចព្រះរាជកុលដ្ឋានعليهم السلامព្រះសាស្ដាﷺដោយរឹបអូសយកទ្រព្យព្រះអង្គعليهم السلام បង្ខំឲ្យព្រះអង្គعليهم السلام អាស្រ័យលើទ្រព្យសាធារណៈ ដើម្បីកុំឲ្យព្រះអង្គعليهم السلامអាចរើបម្រះប្រឆាំងរដ្ឋបាលខុសច្បាប់របស់ខ្លួនបាន ។ គាត់បានរឹបអូសយកដីហ្វាដាក់ដែរ ដែលព្រះសាស្ដាﷺបានប្រទានឲ្យព្រះរាជបុត្រីព្រះអង្គﷺ ព្រះនាងហ្វាទីម៉ាស់ អាស់-សារ៉អ៊៍سلام الله عليها ជាពិសេសនៅចំពោះមុខមុស្លីមទាំងអស់ ព្រមទាំងអាប៊ូ បាការផងដែរ[94] ។

ព្រះនាងហ្វាទីម៉ាស់ អាស់-សាស់រ៉អ៊៍سلام الله عليهاក្រោធអាប៊ូ បាការណាស់ដែលបានរាំង បិទផ្លូវព្រះនាងគ្រប់វិស័យ ។ ព្រះនាងបានទៅជួបអាប៊ូ បាការ ជាមួយស្ត្រីជ្រះថ្លាមួយចំនួននៅឯម៉ាស់យ៉ិដ្ឋព្រះបិតាﷺព្រះនាង ដោយមានពួកមូហាយ៉ីរូននិងពួកអាន់ស្វារនៅទីនោះ ។ លុះគេបានដាក់វាំងននរវាងព្រះនាងនិងបណ្ដាអ្នកនៅទីនោះហើយ ព្រះនាងហ្វាទីម៉ាស់سلام الله عليها អាស់-សាស់រ៉អ៊៍سلام الله عليهاបានចាប់ផ្ដើមថ្លែងរៀបរាប់ ធ្វើឲ្យមនុស្សទាំងអស់ដែលនៅទីនោះខ្លោចចិត្ត ទប់យំមិនបាន ។ បន្ទាប់ពីនោះព្រះនាងបានថ្លែងពាក្យពេជន៍ដែលធ្វើឲ្យស្រឡាំងកាំង ។

ដំបូងព្រះនាងថ្លែងអំពីអភិញ្ញាអ៊ីស្លាម ទស្សនវិជ្ជានៃច្បាប់អ៊ីស្លាម បន្ទាប់ពីនោះបានលើកឡើងនូវរឿងសំខាន់ៗ ។ ព្រះនាងបានថ្លែងអំពីគុណបុណ្យព្រះបិតាﷺព្រះនាងលើបណ្ដាជនដែល កាលពីមុនព្រះអង្គﷺ បានរស់នៅក្នុងអន្ធការនៃភាពអវិជ្ជា នៅក្នុងភាពឥតការគួរសមនិងនៅក្នុងសេចក្ដីអាម៉ាស់ ។ ព្រះនាងបានថ្លែងអំពីគុណសម្បត្តិនិងអាទិភាព (គឺការនៅមុខគេ) របស់បងប្អូនជីដូនមួយ របស់ឪពុកធំឪពុកមានិងអ៊ីម៉ាំអាលីصلوات الله عليه والسلام ព្រះស្វាមីព្រះនាង អំពីការពុះពារតស៊ូរបស់ព្រះអង្គصلوات الله عليه والسلامដើម្បីអ៊ីស្លាមខណៈ

[94] សូមមើលរឿងហ្វាដាក់ក្នុងប្រវត្តិសាស្ត្រ (Fadak in History) ស្នាដៃរបស់ លោកមូហាំម៉ាដ្ឋ បាគៀរ អាល់-ស្វដ្ឋ័រ បកប្រែដោយលោក អ៊ុប់ឌុលឡោះហ្វ៍ អាល់-ស្វាហ៊ីន បោះពុម្ពដោយរោងពុម្ព Ansariyan Publications – Qum, 2002.

ដែលអ្នកឯទៀតរស់នៅក្នុងប្រណិតភាពហ៊ឺហា មិនអើពើរឿងសាសនាទេនោះ ។

មុននឹងចូលដល់រឿងធំ ព្រះនាងហ្វាទីម៉ាស់ អាស់-ស្ហាស់រ៉អ៊ុ سلام الله عليها បានថ្លែងសេចក្តីបារម្ភអំពីការលំអៀងចេញ និងអំពើកំណាចដែលអ៊ុមម៉ាត់អ៊ីស្លាមកំពុងពើបពះ ព្រះនាងបានទាយជាមុនថាអ៊ុមម៉ាត់នឹងវិនាស ឧបសគ្គនិងទុក្ខវេទនានឹងកើតមានឡើង ដោយសារតែទាត់អាស់លុល-បៃត៍ عليهم السلام ចេញពីកន្លែងដែលអល់ឡោះហ្ទ៍ تعالى និងព្រះសាសនៈទូត صلى الله عليه وآله وسلم ព្រះអង្គ عز وجل បានជ្រើសរើសឲ្យពួកគេ ។ បន្ទាប់មកព្រះនាងបានថ្លែងអំពីរឿងហាមព្រះនាងមិនឲ្យទទួលបាននូវមរតករបស់ព្រះបិតា صلى الله عليه وآله وسلم ព្រះនាង ដោយដកស្រង់អំណះអំណាងពីក្នុងព្រះគម្ពីរគួរអាន និងពីក្នុងច្បាប់អ៊ីស្លាមដែលស្តីអំពីរឿងនេះ ។

ការពិត ព្រះនាងហ្វាទីម៉ាស់ អាស់-ស្ហាស់រ៉អ៊ុ سلام الله عليها បានបង្ហាញឲ្យឃើញថាអាប៊ូ បាការខុសដោយមិនអាចប្រកែកបាន ទើបពុំមានអ្នកណាមួយអាចឆ្លើយតបព្រះនាងបានឡើយ ។ បន្ទាប់មកព្រះនាងបានលើកយកអនាគតជូរចត់មកដាក់ពីមុខគាត់ដែលគាត់ប្រាកដជានឹងជួបប្រទះ ពេលគាត់នឹងត្រូវជំនុំជម្រះដោយអល់ឡោះហ្ទ៍ تعالى និងព្រះសាស្តា صلى الله عليه وآله وسلم ព្រះអង្គ عز وجل ។ រួចហើយព្រះនាងបានថ្លែងប្រាប់អស់មុស្លីម ព្យាយាមដាស់សតិអារម្មណ៍ពួកគេអំពីរឿងសិទ្ធិព្រះនាង និងដើម្បីនឹងឲ្យពួកគេរើបម្រះប្រឆាំងរដ្ឋបាលខុសច្បាប់ ។[95]

ទោះជាយ៉ាងក៏ដោយ ព្រះនាងដឹងថាពួកគេទន់ខ្សោយណាស់ មិនអាចធ្វើឲ្យភ្ញាក់ស្មារតីដោយពាក្យសម្តីឬដោយស្ថានភាពណាមួយបានទេ ។ ទោះជាយ៉ាងណាក៏ដោយ ពាក្យពេជន៍នេះត្រូវចាត់ទុកជាពាក្យពេជន៍ដ៏ប៉ិនប្រសប់គួរឲ្យស្ញើចបំផុតនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ។

អាប៊ូ បាការមិនអាចគ្រប់គ្រងស្ថានការណ៍បានទេ ដែលរកកលផ្ទុះឆាប់ៗដូច្នេះ ព្រោះតែគាត់ជាមនុស្សសម្បូរកលល្បិចនិងប្រសប់ដោះសារ ក៏បាន

---

[95] សូមមើលសៀវភៅ *អាក់ឡាំ អាល់-នីសាអ៊ ( أعلام النساء)*, ក្បាលទី ៣ ទំព័រ ២០៨ និង *បាឡាកុត់ អាល់-នីសាអ៊ (بلاغات النساء)* ទំព័រ ១២-១៩ ។

ឆ្លើយតបព្រះនាងហ្វាទីម៉ាស្ញ អាស្ស-ស្សាស្សរ៉អ៊្សسلام الله عليهاដោយសម្ដីសូមស្វាគមន៍និងការលើកកិត្តិយស ។ គាត់បានបង្អោនខ្លួនចំពោះមុខព្រះនាង ហើយបានបញ្ជាក់ប្រាប់ថាវិធានការតឹងរ៉ឹងទាំងនោះ មិនមែនយោបល់របស់គាត់ទេ តែវិធានការតឹងរ៉ឹងទាំងនោះជាការសម្រេចចិត្តរបស់អស់មុស្លីម ។

និយាយសង្ខេប មនុស្សប្រកបដោយវិចារណញ្ញាណមិនអាចអត់ឱនឲ្យអាប៊ូបាការបានទេ ដែលក្រៅពីបានលើកខ្លួនឯងជាមេដឹកនាំអ៊ុមម៉ាត្ទ៍អ៊ីស្លាមថែមទាំងបានរឹបអូសយកមរតករបស់ព្រះសាស្ដាصلى الله عليه وآله وسلم ដកហូតយកដីហ្វាដាក់និងទ្រព្យផ្ទាល់ខ្លួនឯងទៀត បានដាក់បញ្ញាបិទសេដ្ឋកិច្ចលើព្រះរាជវង្សព្រះសាស្ដាصلى الله عليه وآله وسلم ។ គាត់បាននិយាយកុហកថាគាត់មិនបានប្រឌិតកាឡៃដើម្បីប្រឆាំងព្រះសាស្ដាصلى الله عليه وآله وسلمទេ កាលគាត់ថាមុស្លីមទាំងអស់គ្នាបានមូលមតិគ្នាបំបាត់សិទ្ធិអ៊ីម៉ាំអាលីصلوات الله عليه والسلامជាមេដឹកនាំនោះ ។[96]

ព្រះនាងស្ស៊ៃណាប់سلام الله عليها ដោយបានឃើញព្រឹត្តិការណ៍ទាំងអស់នេះ យល់ច្បាស់បុគ្គលទាំងនោះដែលបានបង្កបញ្ហា បង្កការឈឺចាប់និងទុក្ខព្រួយមកលើព្រះមាតាព្រះនាង ។

គួរកត់សម្គាល់ថាព្រះនាងស្ស៊ៃណាប់سلام الله عليها ដែលមានព្រះវន្នាយុត្រឹមតែប្រាំខួបសោះ បានចងចាំរត់មាត់នូវសុន្ទរកថាដ៏វែងនិងប្រកបដោយវោហារកោសល្យរបស់ព្រះមាតាព្រះនាង ។ ព្រះនាងជាអ្នកធ្វើសេចក្ដីរាយការណ៍ចម្បងនូវសុន្ទរកថានេះ ។ ការពិត នេះគឺទេពកោសល្យអស្ចារ្យជាក់ស្ដែងរបស់ព្រះនាង ។

## បដិសេធខមាទោស

[96] អាប៊ូ បាការបានអះអាងថាគាត់បានឮព្រះសាស្ដាមូហាំម៉ាដ្ទ៍صلى الله عليه وآله وسلمមានព្រះវចនៈថា៖ "យើង ព្រះសាស្ដាعليهم السلام មិនទុកមរកឲ្យទេ ។ អ្វីដែលយើងទុកឲ្យនោះត្រូវចាត់ទុកជាទាន ។" តែព្រះនាងហ្វាទីម៉ាស្ញ អាស្ស-ស្សាស្សរ៉អ៊្សسلام الله عليهاបានបង្ហាញភ័ស្ដុតាងឲ្យឃើញថាអំណះអំណាងនេះមិនត្រឹមត្រូវទេ ដោយផ្អែកលើអាយ៉ាស្ញគួរអានជាច្រើននិងភ័ស្ដុតាងសមហេតុផល ។ សូមមើលសៀវភៅ *ហ្វាដាក់ក្នុងប្រវត្តិសាស្ត្រ (Fadak in History)* ស្នាដៃរបស់ សៃយីដ្ទ មូហាំម៉ាដ្ទ៍ បាគៀរ អាល់-ស្សាដ្ទ៍រ ។

អាប៊ូ បាការ និង អ៊ូម៉ារ ព្យាយាមផ្គាប់ផ្គុនព្រះនាងហ្វាទីម៉ាស្ហ៍ អាស់-ស្ហាស្ហ៍រ៉អ៊្រ៍سلام الله عليهاគ្រប់បែបយ៉ាង តែព្រះនាងបដិសេធ មិនព្រមឲ្យពួកគេជួបព្រះនាងទេ ។ ពួកគេក៏បានបែរទៅរកអ៊ីម៉ាំអាលីصلوات الله عليه والسلام អង្វរព្រះអង្គصلوات الله عليه والسلام សុំឲ្យជួយសូមព្រះនាងឲ្យបើកឱកាសឲ្យពួកគេចូលជួបផង ។ អ៊ីម៉ាំصلوات الله عليه والسلام និងព្រះនាងហ្វាទីម៉ាស្ហ៍عليهم السلامក៏បានអនុញ្ញាតឲ្យពួកគេចូលជួប ។

ពេលបុគ្គលទាំងពីរនេះអង្គុយទល់មុខព្រះនាងៗបែរមុខចេញ ។ បុគ្គលទាំងពីរក៏បានសូមខមាទោសព្រះនាង តែព្រះនាងបានសួរបុគ្គលទាំងពីរនេះថា៖ "ពេលនេះបើខ្ញុំប្រាប់អស់លោកនូវអ្វីមួយដែលព្រះសាស្តាصلى الله عليه وآله وسلم របស់អល់ឡោះហ៊្វ៍عز وجلបានប្រាប់ តើអស់លោកព្រមទទួលនិងព្រមធ្វើតាមទេ ?" បុគ្គលទាំងពីររូបនេះបានទូលថា៖ "ព្រម ។" ព្រះនាងបានសួរថា៖ "ខ្ញុំسلام الله عليهاសួរអស់លោកក្នុងព្រះនាមអល់ឡោះហ៊្វ៍عز وجل តើអស់លោកបានឮព្រះសាស្តាصلى الله عليه وآله وسلمរបស់អល់ឡោះហ៊្វ៍عز وجلមានព្រះវចនៈទេ ថា៖ "ធ្វើឲ្យហ្វាទីម៉ាស្ហ៍សប្បាយចិត្ត គឺធ្វើឲ្យខ្ញុំصلى الله عليه وآله وسلمសប្បាយចិត្ត ។ ធ្វើឲ្យ ហ្វាទីម៉ាស្ហ៍ក្រោធ គឺធ្វើឲ្យខ្ញុំصلى الله عليه وآله وسلمក្រោធ ។ ដូច្នេះ អ្នកណាស្រឡាញ់ ហ្វាទីម៉ាស្ហ៍ បុត្រីខ្ញុំصلى الله عليه وآله وسلم អ្នកនោះស្រឡាញ់ខ្ញុំصلى الله عليه وآله وسلم ។ អ្នកណាធ្វើឲ្យ ហ្វាទីម៉ាស្ហ៍ បុត្រីខ្ញុំصلى الله عليه وآله وسلم សប្បាយចិត្ត អ្នកនោះធ្វើឲ្យខ្ញុំصلى الله عليه وآله وسلمសប្បាយចិត្ត ។ អ្នកណាធ្វើឲ្យហ្វាទីម៉ាស្ហ៍ បុត្រីខ្ញុំصلى الله عليه وآله وسلم ក្រោធ អ្នកនោះធ្វើឲ្យខ្ញុំصلى الله عليه وآله وسلمក្រោធ ។" អស់លោកបានឮឬទេ ?" បុគ្គលទាំងពីរបានឆ្លើយបញ្ជាក់ថាពិតថា៖ "អស់ ទូលបង្គំបានឮក្រាបទូល ។ អស់ទូលបង្គំបានឮព្រះសាស្តាصلى الله عليه وآله وسلمរបស់អល់ឡោះហ៊្វ៍عز وجلមានព្រះវចនៈដូចនេះ មែន ។" ព្រះនាងបានថ្លែងដាក់អាប៊ូ បាការនិងកនគាត់យ៉ាងក្រេវក្រោធ ថា៖ "ពេលនេះខ្ញុំسلام الله عليهاសូមយកអល់ឡោះហ៊្វ៍عز وجل និងអស់ទេវតាព្រះអង្គعز وجلជាសាក្សីថាលោកទាំងពីរបានធ្វើឲ្យខ្ញុំسلام الله عليهاក្រេវក្រោធ លោកទាំងពីរមិនដែលធ្វើឲ្យខ្ញុំسلام الله عليهاសប្បាយចិត្តឡើយ ។ ខ្ញុំسلام الله عليهاនឹងប្តឹងអំពីលោកទាំងពីរកាលណាខ្ញុំسلام الله عليهاនឹងបានជួបព្រះសាស្តាصلى الله عليه وآله وسلم ។" ព្រះនាងបានថ្លែងបន្ថែមដោយប្រើសម្តីធ្ងន់ៗថា៖ "សូមស្បថចំពោះអល់ឡោះហ៊្វ៍عز وجل ខ្ញុំسلام الله عليهاនឹងបួងសួងអល់ឡោះហ៊្វ៍عز وجلប្តឹងអំពីលោកទាំងពីរក្នុងគ្រប់ស្វ៊ឡាត្ហ៍របស់ខ្ញុំسلام الله عليها ។" ដូច្នេះ អាប៊ូ បាការនិងកន

គាត់បានត្រឡប់ទៅវិញដោយពុំបានធ្វើឲ្យព្រះនាងហ្វាទីម៉ាស់ អាស់-ស្ហាស្ហ់រ៉អ៊ុ عليها سلام الله គាប់ព្រះហឫទ័យទេ ។
ជាធម្មតាទេ ព្រះនាងស៊ៃណាប់ عليها سلام الله ដែលបានឃើញព្រឹត្តិការណ៍ទាំងនេះផ្ទាល់នោះមានឥរិយាបថតែមួយ ហើយបានជួយឈឺឆ្អាលព្រះមាតាព្រះនាងក្នុងអភិក្រោធចំពោះអាប៊ូ បាការ ។

## សេចក្តីសៅហ្មងរបស់ព្រះនាងហ្វាទីម៉ាស់ អាស់-ស្ហាស្ហ់រ៉អ៊ុ عليها سلام الله

តាំងពីព្រះបិតាព្រះនាងសោយទិវង្គតមក ព្រះនាងហ្វាទីម៉ាស់ អាស់-ស្ហាស្ហ់រ៉អ៊ុ عليها سلام الله មិនដែលសប្បាយឬមានអារម្មណ៍ធូរស្បើយទេ ។ ព្រះនាងទ្រង់កន្សែងទាំងយប់ទាំងថ្ងៃដល់ថ្នាក់ "ពួកអ្នកមានអំណាច" ក្នុងនគរម៉ាឌីណាស់សូមព្រះស្វាមីព្រះនាង អ៊ីម៉ាំអាលី صلوات الله عليه والسلام ឲ្យព្រះអង្គ صلوات الله عليه والسلام លួងព្រះនាងឲ្យយំពេលថ្ងៃឬពេលយប់ កុំយំទាំងយប់ទាំងថ្ងៃឡើយ ។ ដូច្នេះព្រះនាងនាំអាល់-ហ្ហាសាន់ អាល់-ហ៊ូសៃន៍និងព្រះនាងស៊ៃណាប់ عليها السلام ទៅកន្លែងមួយនៅក្រៅស្រុកម៉ាឌីណាស់ អង្គុយយំក្រោមដើមឈើមួយដោយសេរី ទាល់តែឆ្អែត ។ ការយំសោករបស់ព្រះនាងបានធ្វើឲ្យពួកអ្នកស្រុកម៉ាឌីណាស់ទាំងនោះនឹកឃើញឥរិយាបថមិនត្រឹមត្រូវរបស់ខ្លួន ហើយពួកគេបានលួកដៃអប្រិយទៅកាប់ដើមឈើនោះចោល ។
ព្រះនាងក៏អង្គុយហាលថ្ងៃកាន់ព្រះមរណៈទុក្ខព្រះបិតាព្រះនាង ។ តែអ៊ីម៉ាំអាលី صلوات الله عليه والسلام ពិបាកបណ្តោយឲ្យព្រះមហេសីព្រះអង្គ صلوات الله عليه والسلام បុគ្គលជាទីស្រឡាញ់ អង្គុយហាលកម្តៅថ្ងៃ ។ ព្រះអង្គ صلوات الله عليه والسلام ក៏បានសាងសង់អគារមួយដែលហៅថា "បៃត៍ អាល់-អាស់ស្ហាន់ (بيت الأحزان អាស្រមសំណោក)" សម្រាប់ឲ្យព្រះនាងជ្រកដើម្បីយំសោក កាន់ព្រះមរណៈទុក្ខព្រះបិតាព្រះនាង ។ ដូច្នេះ អបអមដោយព្រះរាជបុត្រនិងព្រះរាជបុត្រីព្រះនាង ព្រះនាងអង្គុយនៅក្នុងអាស្រមសំណោកនោះពេញមួយថ្ងៃ អ៊ីម៉ាំ صلوات الله عليه والسلام បាននាំព្រះអង្គ عليهم السلام ទាំងអស់មកផ្ទះវិញពេលយប់ ។ អ្វីដែលធ្វើឲ្យព្រះនាងរីករាយនោះគឺទៅមើលផ្នូរព្រះបិតាព្រះនាង ។ ព្រះនាងចង់ទៅទីនោះ បោកខ្លួនលើផ្នូរនោះ ត្អូញត្អែរអំពីរឿងដែលបានកើតឡើងពេលអត់

ពីព្រះបិតាព្រះនាង ។[97]

## ព្រះនាងហ្វាទីម៉ាស់ﷺសោយទិវង្គត

ព្រោះតែព្រះនាងសោកសង្រេងឥតស្រាកស្រាន្ត បានជាព្រះរាជបុត្រីព្រះសាស្តាﷺបាត់បង់កម្លាំងពីខ្លួន ។ ព្រះនាងដើបឡើងយ៉ាងលំបាកដើម្បីបំពេញកិច្ចការប្រចាំថ្ងៃ ។ ព្រះនាងស្រៃណាប់ﷺបានជួយមាតាតាមដែលអាចធ្វើបាន ។ ព្រះនាងអាចស្វាបស្ទង់ដឹងបានថាព្រះមាតាព្រះនាងមានទុក្ខក្នុងខ្លួន ព្រះនាងជួយធ្វើការនិងនៅក្បែរមាតាព្រះនាង ។ ដូច្នេះសុខភាពព្រះនាងកាន់តែដុនដាប បណ្តាលឲ្យជម្ងឺបៀតបៀន មិនអាចធ្វើឲ្យព្រះនាងដើបពីដំណេកបាន ។

ថ្ងៃមួយ ស្ត្រីខ្លះបានមកសួរសុខទុក្ខព្រះនាង ។ ខ្សោយខ្លាំង មានសម្លេងប្រកបដោយទុក្ខព្រួយ ព្រះនាងបានឆ្លើយតបថា៖ "ខ្ញុំស្អប់លោកនេះ ខ្ញុំនឹងសប្បាយបើខ្ញុំអាចចាកចោលអ្នកទាំងអស់គ្នា ។ ខ្ញុំនឹងបានជួបអល់ឡោះហ៍ﷻនិងព្រះសាស្តាﷺព្រះអង្គﷻ ជាមួយទុក្ខសោកច្រើន ។ គេបានរំលោភសិទ្ធិខ្ញុំ គេមិនគោរពញាតិវង្សរបស់ខ្ញុំជាមួយព្រះសាស្តាﷺទេ គេមិនអើពើមរតកព្រះសាស្តាﷺរឿងខ្ញុំទេ គេមិនជឿសន្តភាពរបស់ខ្ញុំទេ ។" [98]

ដូចផ្កាបាត់បង់សម្រស់ ព្រះរាជបុត្រីព្រះសាស្តាﷺក៏បានចាប់ផ្តើមស្រពោន ការស្លាប់បានឈានចូលមករកព្រះនាងយ៉ាងលឿនថ្វីបើព្រះនាងនៅក្នុងវ័យក្មេង ។

លុះអ៊ីម៉ាំអាលីﷺបានមកជួបព្រះនាងតាមសំណូមពរ ព្រះនាងបានប្រាប់ព្រះអង្គﷺអំពីបណ្តាំមរតកសាសន៍ព្រះនាង ដែលមានច្រើនខ ។ ខសំខាន់បំផុតគឺ៖ ឲ្យបញ្ចុះព្រះរាជសពព្រះនាងក្នុងពេលយប់ជ្រៅបំផុត

[97] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ស្ហាស្ហ៍រ៉ស្ហ៊ូប (ابن شهراشوب) *អាល់-ម៉ាគ៊ីប,* ក្បាលទី ២ ទំព័រ ១៣១ ។

[98] សូមមើលសៀវភៅរបស់លោក អាល់-យ៉ាក់គូប៊ី (اليعقوبي) *អាល់-តារិក (التاريخ),* ក្បាលទី ២ ទំព័រ ៩៥ ។

អស់បុគ្គលដែលធ្វើឲ្យព្រះនាងឈឺចាប់ ដែលធ្វើអាក្រក់ ដែលរំលោភសិទ្ធិព្រះនាង មិនត្រូវឲ្យចូលរួមក្នុងពិធីបុណ្យព្រះរាជសពព្រះនាងជាដាច់ខាត ព្រះរាជផ្នូរព្រះនាងមិនត្រូវឲ្យអ្នកណាមួយស្គាល់ជាដាច់ខាត ដើម្បីនឹងធ្វើឲ្យរឿងព្រះនាង និងអំពើអយុត្តិធម៌ដែលព្រះនាងបានរងនោះទៅជារឿងដែលគួរឲ្យចាប់អារម្មណ៍សម្រាប់មនុស្សជំនាន់ក្រោយៗ ។

អ៊ីម៉ាំ صلوات الله عليه والسلام បានទុកឲ្យព្រះនាងសម្រាកទាំងខ្លោចចិត្ត បន្ទាប់ពីបានសូមធានាធ្វើតាមសំណូមពរព្រះនាង ។

ព្រះនាងបានសូមឲ្យព្រះរាជបុត្រីព្រះនាង ព្រះនាងស៊ៃណាប់ سلام الله عليها ធ្វើការសាស្តាមួយនៅក្នុងអនាគតកាល ក្នុងកាលៈទេសៈមួយ ។ ព្រះរាជបុត្រីបានសន្យាព្រះមាតាថាព្រះនាងនឹងធ្វើការនោះ ។ បន្ទាប់មកព្រះនាងបានសូមឲ្យព្រះនាងអាស់ម៉ាក់ ប៊ិនទី អ៊ូម៉ៃស៍ (أَسْمَاء بِنْت عُمَيْس) ធ្វើក្តារមឈូសដែលគ្របព្រះរាជសពបរិសុទ្ធព្រះនាង ។[99]

ថ្ងៃអវសានព្រះជន្ម អាការជម្ងឺព្រះនាងហ្វាទ្តីម៉ាស្ហ៍ អាស្ស់-ស្សាស្ហ់រ៉អ៊ែ سلام الله عليها ហាក់ដូចជាប្រសើរឡើងវិញ ពីព្រោះព្រះនាងដឹងថាបន្តិចនឹងបានជួបព្រះបិតាព្រះនាង ព្រះនាងរីករាយ ។ ព្រះនាងបានងូតទឹកឲ្យព្រះរាជបុត្រទាំងពីររបស់ព្រះនាង បានធ្វើអាហារឲ្យព្រះអង្គទាំងពីរ ហើយបានឲ្យព្រះអង្គទាំងពីរទៅស៊ីរ៉ាស្ហ៍ផ្នូរព្រះអយ្យកោ ។ បន្ទាប់មកព្រះនាងបានសម្លឹងមើលព្រះអង្គទាំងពីរយ៉ាងមុត ហើយបានបែរទៅសម្លឹងមើលព្រះនាងស៊ៃណាប់ سلام الله عليها ដោយខ្សែភ្នែកដដែល ។

ព្រះនាងបានសូមឲ្យអាស់ម៉ាក់ទៅដងទឹកឲ្យព្រះនាង បន្ទាប់ពីនោះឲ្យស្លៀកសំលៀកបំពាក់កាន់មរណៈទុក្ខ ហើយឲ្យដាក់គ្រែព្រះនាងនៅកណ្តាលផ្ទះ ។ អាស់ម៉ាក់ដឹងថានេះជាពេលចុងក្រោយបង្អស់នៃព្រះជន្មព្រះនាងហ្វាទ្តីម៉ាស្ហ៍ អាស្ស់-ស្សាស្ហ់រ៉អ៊ែ سلام الله عليها ។ ហេតុដូច្នេះបានជាព្រះនាងស្រឡាំងកាំង ។

បន្ទាប់មក ព្រះនាងហ្វាទ្តីម៉ាស្ហ៍ អាស្ស់-ស្សាស្ហ់រ៉អ៊ែ سلام الله عليها បានចាប់ផ្តើមសូត្រ

---

[99] សូមមើលសៀវភៅរបស់លោក អាល់-ហ៊ាគីម *អាល់-មុសតាដ្ស៉រ៉ក (المستدرك)* ក្បាលទី ៣ ទំព័រ ១៦២ ។

គួរអានទាល់តែព្រះវិញ្ញាណព្រះនាងបានឡើងទៅកាន់ឋានសួគ៌ ដើម្បីជួបព្រះបិតាصلى الله عليه وآله وسلمព្រះនាងក្រោយពីបានសោយទិវង្គត ព្រះនាងស្អប់ជីវិតលោកិយ ។ លុះព្រះនាងស្រ៊ៃណាប់سلام الله عليهاបានឃើញព្រះកាយព្រះមាតាព្រះនាងនឹងថ្កល់ មិនកម្រើក ព្រះនាងចាប់ផ្តើមថ្ងូរ ហើយក៏បានទ្រហោរយំដោយស្តាយស្រណោះ ។

ពេលអាល់-ហាសាន់ និងអាល់-ហ៊ូសៃន៍عليهم السلامបានដឹងថាព្រះមាតាសោយទិវង្គត ក៏បានស្ទុះទៅឱបសពមាតា យំ ។ តែអាស់ម៉ាក៉ុំបានឲ្យព្រះអង្គទាំងពីរទៅប្រាប់ដំណឹងអាណោចអាធ័មដល់ព្រះបិតានៅឯម៉ាស់យ៉ិដ្ទ ។

ពេលព្រះបិតាព្រះអង្គទាំងពីរបានទទួលដំណឹង ព្រះអង្គទទួលអារម្មណ៍ដូចជាបេះដូងត្រូវហែក ហើយចង់ចាកចោលលោកនេះ ។ ព្រះអង្គប្រញាប់ទៅលំនៅដ្ឋានទាំងទឹកភ្នែក សម្លឹងមើលព្រះរាជសព ហើយសាទុក្ខពោរពេញដោយការឈឺចាប់ ។ ព្រះនាងស្រ៊ៃណាប់នៅក្បែរព្រះរាជសព ទ្រហោរយំដោយទុក្ខសោក បន្ទាប់ពីបានបាត់បង់ទីពឹង ។ សម្រាប់ក្មេង ពុំមានអ្វីលំបាកជាងការអត់ទ្រាំការចែកដ្ឋានរបស់ម្តាយគ្មានថ្ងៃវិលត្រឡប់វិញនោះទេ ។

អ៊ីម៉ាំصلوات الله عليه والسلامសូមឲ្យសាល់ម៉ាន (បុរសជាតិហ្វារីស៊ី Persian) ប្រាប់ប្រជារាស្ត្រដែលបានប្រជុំគ្នាយ៉ាងស្ងៀមស្ងាត់នៅមាត់ទ្វារ ថាពិធីបុណ្យសពនឹងប្រព្រឹត្តទៅក្នុងពេលយប់ ។ មិនអនុញ្ញាតឲ្យអ្នកណាម្នាក់ឃើញព្រះរាជសពព្រះនាងហ្វាទិម៉ាស់ អាស់-ស្សាស់រ៉អ៊ុسلام الله عليهاទេ សូម្បីតែអ៊ុំស្មាស់មហេសីមេម៉ាយរបស់ព្រះសាស្តាصلى الله عليه وآله وسلمក៏ត្រូវហាមដែរ ។ [100]

លុះយប់ជ្រៅណាស់ហើយ អ៊ីម៉ាំអាលីصلوات الله عليه والسلامបានងូតទឹកឲ្យព្រះរាជសពបរិសុទ្ធ រីឯបុត្រាទាំងពីរ បុត្រីនិងអាស់ម៉ាក៉ុំមើលទាំងទឹកភ្នែក ខ្លោចចិត្ត ។ រួចហើយព្រះអង្គصلوات الله عليه والسلامបានដាក់ព្រះរាជសពក្នុងមឈូស ហើយឲ្យបុត្រាបុត្រីមើលព្រះមាតាគ្រាចុងក្រោយបង្អស់ ។ អស់ទាំងបុត្របានឱបសពព្រះមាតា ។ លុះយប់នៅសល់តែពីរបីម៉ោង អ៊ីម៉ាំصلوات الله عليه والسلامបានស្ញ៉ឡាត់ឲ្យព្រះ

---

[100] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ស្មាស់រ៉ស៊ូប (ابن شهراشوب) *អាល់-ម៉ាគ្ញីប,* ក្បាលទី ៣ ទំព័រ ៣៦៥ ។

រាជសព បាននាំព្រះរាជសពទៅកាន់លំនៅចុងក្រោយដោយមានបុគ្គលជ្រើសរើសជាជំនួយ ដូចជាសាល់ម៉ាននិងបុរសហ្ស៊ាស្ទិមមួយចំនួនជាដើម បានបញ្ចុះព្រះរាជសពក្នុងផ្នូរ លុបផ្នូរ ហើយបានលុបបំបាត់សញ្ញាសម្គាល់ផ្នូរ ។ ទឹកភ្នែកអ៊ីមុាំصلوات الله عليه والسلامទទឹកជោកដីខណៈដែលព្រះអង្គصلوات الله عليه والسلام ថ្លែងអំពីព្រះនាងហ្វាទិ៍ម៉ាស្ហ៍ អាស្ស៊-ស្សាស្ស៊រ៉អ៊ំ ព្រះសច្ចការិនីسلام الله عليها ព្រះអគ្គមហេសីព្រះអង្គصلوات الله عليه والسلام ដោយពាក្យពេជន៍បង្កប់អត្ថន័យសោកសៅនិងទុក្ខធំមហាសាល ។[101]

ស្រេចហើយ អ៊ីមុាំصلوات الله عليه والسلامបានត្រឡប់ទៅលំនៅដ្ឋានវិញ ទៅរកបុត្រព្រះអង្គصلوات الله عليه والسلامដែលយំសោកស្តាយមាតា ។

ដូច្នេះ កុមារវ័យរបស់ព្រះនាងស្រ៊ៃណាប់ជិតដាមដោយសេចក្តីសោកសៅនិងការឈឺចាប់ ព្រះនាងបានបាត់បង់ព្រះអយ្យកោصلى الله عليه وآله وسلم ដែលប្រកបដោយមេត្តាធម៌ មិនច្រើនអាទិត្យក្រោយមក បានបាត់បង់ព្រះមាតាជាទីស្រឡាញ់ ។ ថ្វីបើព្រះនាងមានព្រះជន្មខ្ចី ព្រះនាងស្រ៊ៃណាប់ស្គាល់គោលបំណងធំដែលធ្វើឲ្យអស់បុគ្គលទាំងនោះសង្កត់សង្កិន និងរំលោភសិទ្ធិព្រះមាតាព្រះនាង ។ ហេតុដូច្នេះ ព្រះនាងបានសម្រេចចិត្តដើរតាមគន្លងព្រះមាតាព្រះនាង មិនចុះញមអស់បុគ្គលកំណាចអន្យតិរ្ថិយ កាន់ក្តាប់អ៊ុមម៉ាត្ហ៍អ៊ីស្លាមដោយខុសច្បាប់នោះជាដាច់ខាត ។

## រជ្ជកាលអ៊្ហ៊ម៉ារ

ក្រោយពីបានកាន់ក្តាប់ប្រមាណពីរឆ្នាំ អាប៊ូ បាការត្រូវជម្ងឺបៀតបៀន ក៏បានជ្រើសរើស អ៊្ហ៊ម៉ារ អ៊ីបនូ អាល់-ខ្ហ៊ត្ត៍ត្ហ៍ប់ ជាអ្នកកាន់ក្តាប់ជំនួសគាត់ ទោះបីឥសរជនល្បីៗច្រើនរូបនៃរដ្ឋអ៊ីស្លាមបានជំទាស់រឿងនេះ ព្រមទាំងបានត្អូញត្អែរថាអ៊្ហ៊ម៉ារជាមនុស្សកម្រោល ទ្រគោះ ក៏ដោយ ។ ទោះជាយ៉ាងណាក៏ដោយ អាប៊ូ បាការ មិនឆ្លើយតបការប្រកែកជំទាស់នេះទេ នៅតែធ្វើ

---

101 សូមមើលសៀវភៅ *ណាស្ហ៍យ៉ាល់-បាឡាក្ហ៊ះត្ហ៍* អធិប្បាយដោយលោកមូហ៊ាំម៉ាដ្ហ៍ អ៊្ហាប់ឌុះហ្វ៍ (محمد عبده) ក្បាលទី ២ ទំព័រ ២០៧ ។

តាមការសម្រេចចិត្តមិនត្រឹមត្រូវរបស់គាត់ ។ [102]

លក្ខណៈប្លែកនៃរបបគ្រប់គ្រងរបស់ អាប៊ូ បាការ គឺវិហិង្សា (គឺធ្វើការទុក្ខបុកម្នេញ) ទៅលើព្រះរាជវង្សព្រះសាស្តាعليهم السلام និងការកម្ចាត់សន្តភាពរបស់ព្រះរាជវង្សនេះعليهم السلام គឺសន្តភាពដែលព្រះសាស្តាصلى الله عليه وآله وسلمប្រោះមកលើព្រះអង្គទាំងនេះعليهم السلام ដោយគោរពតាមព្រះបញ្ជាអល់ឡោះហ្ទ៍عز وجل ។ រឿងនេះបើកចំហឲ្យបនកាន់ក្តាប់មិនស្របច្បាប់ ដែលបានសោយរាជ្យលើអ៊ុមម៉ាត់អ៊ីស្លាមជំនាន់ក្រោយៗ ធ្វើបាបនិងគាបសង្កត់ព្រះអង្គعليهم السلامឥតត្រាប្រណី ។ បានសេចក្តីថា អាប៊ូ បាការ បើកដៃឲ្យបនកាន់ក្តាប់ត្រកូលអ៊ូម៉ៃយ៉ាស់ប្រព្រឹត្តការកាប់សម្លាប់នៅការបាឡាអ៍ នៅក្នុងសោកនាដកម្មនេះអ៊ីម៉ាំអាល់-ហ៊្សៃសែន៍صلوات الله عليه والسلام ព្រមទាំងព្រះសច្ចរាជវង្សនិងបណ្តាសច្ចសាវកព្រះអង្គصلوات الله عليه والسلامត្រូវកាប់សម្លាប់ ព្រះរាជសពព្រះអង្គصلوات الله عليه والسلامត្រូវកាត់ផ្តាច់ព្រះសិរដោយប្រមាថ រីឯព្រះរាជវង្សព្រះអង្គصلوات الله عليه والسلام ដែលមានព្រះនាងស្ហៃណាប់ដឹកនាំនោះ ត្រូវចាប់ខ្លួនជាឈ្លើយ ដោយមូលហេតុតែព្រះអង្គទាំងនេះជាអាស្ហ៍លុល-បៃត៍عليهم السلام ។

បន្ទាប់ពី អាប៊ូ បាការ ស្លាប់ អ៊ុម៉ារបានដឹកនាំអ៊ុមម៉ាត់អ៊ីស្លាមដោយក្រញាំដៃដែក ។ ការកាន់ក្តាប់របស់អ៊ុម៉ារតឹងណាស់ដល់ថ្នាក់បណ្តាសាវកធំៗរបស់ព្រះសាស្តាصلى الله عليه وآله وسلم ដូចជាអ៊ាប់ឌុលឡោះហ្ទ៍ អ៊ីបនូ អ៊ាប់បាស់ ជាដើមបានដកខ្លួនចេញឆ្ងាយពីគាត់ ។ [103]

អ៊ីម៉ាំអ៊ាលីصلوات الله عليه والسلام អគ្គប្រមុខពិតរបស់អ៊ុមម៉ាត់អ៊ីស្លាម បានដកខ្លួនចេញពីសង្គមកិច្ច (តាមផ្លូវការ) និងការនយោបាយក្នុងរជ្ជកាលអ៊ុម៉ារ ដូចនៅក្នុងរជ្ជកាលអាប៊ូ បាការដែរ ។ ការពិតបុគ្គលដឹកនាំទាំងពីរនេះព្យាយាមធ្វើឲ្យព្រះអង្គصلوات الله عليه والسلامនៅឆ្ងាយពីគ្រប់កិច្ចការ ទាក់ទងនឹងរដ្ឋបាលរបស់ខ្លួន[104] ។

---

[102] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហាឌីដ្ *ស្ហារហ្ទ៍ ណាស្ហ៍យ៉ាល់-បាឡាកោះត្ទ៍* ក្បាលទី ៦ ទំព័រ ៣៤៣ ។

[103] សូមមើលសៀវភៅរបស់លោក អ៊ាប់ឌុល-ហ៊្សៃសែន៍ ស្ហារ៉ហ្វ៍ អាល់-ឌីន (عبد الحسين شرف الدين) *អាន់-ណាស្ហ៍ វ៉ា អាល់-អ៊ីជ្ទីហ្វាដ្ទ៍ (النَّص و الاِجتِهاد)* ។

[104] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហាឌីដ្ *ស្ហារហ្ទ៍*

ក៏ប៉ុន្តែ បុគ្គលទាំងពីរនេះចាំបាច់ត្រូវតែសូមជំនួយពីព្រះអង្គصلوات الله عليه والسلامពាក់ព័ន្ធនឹងគ្រប់បញ្ហាដែលខ្លួនជួបប្រទះ ។ [105]

អ៊ីម៉ាំصلوات الله عليه والسلامមិនចេញពីផ្ទះទេ មានតែសេចក្ដីសោកសៅ សេចក្ដីល្វីងជូរចត់ និងទុក្ខព្រួយជាមិត្ត ។ ដូចព្រះបិតាដែរ ព្រះរាជបុត្ររបស់អ៊ីម៉ាំអាុលីصلوات الله عليه والسلام ក៏រងទុក្ខដែលស្រោចមកលើគ្រួសារខ្លួនដែរ ហើយក្រោធអ៊ុម៉ារខ្លាំងណាស់ ។ ថ្ងៃមួយ អ៊ីម៉ាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلامបានស្រែកឲ្យអ៊ុម៉ារដែលបានឡើងវេទិកា (មីមបារ) ព្រះសាស្ដាصلى الله عليه وآله وسلم ស្ដីឲ្យគាត់ចុះមកវិញពីព្រោះគាត់មិនស័ក្ដិសមនឹងកន្លែងនេះទេ[106] ។

ព្រះនាងស្ហៃណាប់سلام الله عليهاក៏មានអារម្មណ៍ដូចនេះដែរចំពោះអ៊ុម៉ារ ព្រះនាងបាននិយាយដល់បុគ្គលរូបនេះ នៅក្នុងពាក្យពេជន៍ប្រវត្តិសាស្ត្ររបស់ព្រះនាង កាលព្រះនាងបានថ្លែងទៅកាន់យ៉ាស៊ីដ្ទនៅឯវាំង គឺ៖

"وَسَيَعْلَمُ مَنْ سَوَّلَ لَكَ وَمَكَّنَكَ مِنْ رِقَابِ ٱلمسْلِمِينَ..."

*"បុគ្គលដែលបានទាក់ទាញអារម្មណ៍របស់អ្នកឯង ដែលបានផ្ទេរអំណាចឲ្យអ្នកឯង ហើយអាស្រ័យអំណាចនេះអ្នកឯងគ្រប់គ្រងលើមុស្លីមនោះប្រាកដជានឹងដឹង..."*

ទោះជាយ៉ាងណាក៏ដោយ អ៊ុម៉ារបានប្រព្រឹត្តចំពោះអ៊ុមម៉ាត់អ៊ីស្លាមដោយ

---

*ណាស្ទ់យ៉ាល់-បាឡាក្មោះត៍* ក្បាលទី ៩ ទំព័រ ២៨ ។

[105] ព័ត៌មានលំអិត សូមមើលសៀវភៅ *ក៉ូដ៏អ៍ អាមីរុល-មុមីនីន អាុលី ប៊ិន អាប៊ីត៉ូលិប (قَضاءُ أميرالمؤمنين علي بن ابى طالب) ។* ការពិតសៀវភៅទាំងអស់ដែលស្ដីអំពីប្រវត្តិសាស្ត្រអ៊ីស្លាមលើកឡើងនូវសេចក្ដីរាយការណ៍ជាច្រើនរឿងដែល អ៊ុម៉ារ អ៊ីបនូ អាល់-ខុត្ត៉ប់ សូមជំនួយពីអ៊ីម៉ាំអាុលីصلوات الله عليه والسلامជាញឹកញយក្នុងបញ្ហាដែលគាត់បានជួបប្រទះ ។ ម្យ៉ាងទៀត គេបានលើកឡើងនូវសម្ដីរបស់អ៊ុម៉ារដែលបានថា៖ "បើគ្មានអាុលីទេ អ៊ុម៉ារច្បាស់ជាស្លាប់" និងសម្ដីស្រដៀងនេះច្រើនទៀតនៅក្នុងគ្រប់សៀវភៅដែលស្ដីអំពីរជ្ជកាលអ៊ុម៉ារ ។

[106] សូមមើលសៀវភៅរបស់លោក បាក្ទៀរ ស្ហារីហ្វ អាល់-ក៉ូរ៉ស្ហី *អាល់-សៃយីដ្ទាស្ទ់ ស្ហៃណាប់* ទំព័រ ១១៤; *អ៊ីសបាស្ទ់ ហ្វី ម៉ាក់រីហ្វាស្ទ់ អាល់-ស្ហ៍ហ្វាបាស្ទ់ (الإصابة في معرفة الصحابة)* ក្បាលទី ២ ទំព័រ ៤៦១ ។

ផ្អែកលើយោបល់ខ្លួនឯង ។ ឧទាហរណ៍ គាត់ស្អប់ជនជាតិពែរ្ស (Persian) ណាស់ ឯជនជាតិពែរ្សក៏ស្អប់គាត់វិញដែរ ។ គាត់បានហាមឃាត់ជនជាតិនេះចូលនគរម៉ាឌីណាស់ រាជធានីនៃរដ្ឋអ៊ីស្លាម លើកលែងតែជនជាតិនេះមិនទាន់គ្រប់អាយុនៅឡើយ ហើយគាត់បានសម្រេចថាជនជាតិនេះមិនមានសិទ្ធិទទួលកេរមរតកទេ លើកលែងតែបុគ្គលដែលបានកើតនៅលើទឹកដីអារ៉ាប់ ។[107]

លទ្ធផលចុងក្រោយ អ៊ុម៉ារត្រូវទាសៈជាតិពែរ្សម្នាក់សម្លាប់ គឺទាសៈដែលគាត់បានបង្អាប់បន្ថោក បំបាក់មុខ[108] ។

ពេលជិតស្លាប់ អ៊ុម៉ាររិះគិតអស់មួយរយៈពេលដើម្បីជ្រើសរើសអ្នកដឹកនាំអ៊ុមម៉ាត់អ៊ីស្លាម ។ ពេលគាត់បាននឹកដល់បណ្ដាគូកនគាត់ដែលបានចូលរួមយ៉ាងសកម្ម ក្នុងការរៀបចំផែនការកម្ចាត់ព្រះរាជវង្សព្រះសាស្ដាﷺពីតំណែងដឹកនាំ គាត់សោកស្ដាយបនទាំងនេះព្រោះពួកគេត្រូវយមបាលឆក់យកជីវិតបាត់អស់ហើយ ។

ចុងក្រោយ គាត់បានរៀបចំផែនការកំណាចមួយដើម្បីធ្វើឲ្យអ៊ីម៉ាំអាលីصلوات الله عليه والسلامមិនអាចទទួលបាននូវមុខតំណែងដឹកនាំបានជាដាច់ខាត ។ គាត់បានហៅឆាកល្ខោនឥតខ្លឹមសាររបស់គាត់ថាស្ហ៊ូរ៉ (شورَى) ។ គាត់បានសម្រេចចិត្តជ្រើសរើសបុគ្គលប្រាំមួយនាក់ ដែលត្រូវតែងតាំងមួយនាក់ក្នុងចំណោមគ្នាឯងទាំងប្រាំមួយនាក់នេះ ជាស្ដេចខ៍លិហ្វ ។ ក្រោយពីអ៊ុម៉ារបានស្លាប់ទៅ បុគ្គលទាំងប្រាំមួយនាក់នេះបានប្រជុំគ្នា ។ ក្រោយពីបានពិភាក្សា ជជែកដេញដោលគ្នា អ៊ុស្ម៉ាន អ៊ីបនូ អាហ្វហ្វាន (عثمان بن عفان) តំណាងត្រកូលអ៊ូម៉ៃយ៉ាស់ត្រូវជ្រើសរើសជាស្ដេចខ៍លិហ្វ

---

[107] សូមមើលសៀវភៅ ម៉ាលិក អ៊ីបនូ អាណាស់ *អាល់-មូវ៉ាត្តត្ត៍ (الموطأ)* ក្បាលទី ២ ទំព័រ ១២ ។

[108] សូមមើលសៀវភៅរបស់លោក អាល់-ម៉ាស់អ៊ូឌី (المسعودي) *មូរូជ អាល់-ស្ហាហ្ហាប់ (مروج الذهب)* ក្បាលទី ២ ទំព័រ ២១២; *អាល់-អ៊ីសទីអាប់* (ដើមទំព័រសៀវភៅ *អ៊ីសបាស់ ហ្វី ម៉ាក់រីហ្វាស់ អាល់-ស្ហ៍ហ្ហាបាស់ (الإصابة في معرفة الصحابة)* ក្បាលទី ២ ទំព័រ ៤៦១ ។

ថ្មី ។ ចាប់តាំងពីដើមអឺយមកម្ល៉េះ គោលបំណងតែមួយគត់ ក្រៅពីការប្រឌិតឆាកល្ខោនស៊្ហូរ៉សំគិស និងការព្រមព្រៀងចម្លែកដែលអ៊ូម៉ារបាន រៀបចំនោះ គឺតែងតាំងអ៊ុស្ម៉ានជាស្តេចខ៉ូលិហ្វ ហើយទាត់អ៊ីម៉ាំអាលី صلوات الله عليه والسلام ចេញពីមុខតំណែងនេះ ។

ការពិត ស៊្ហូរ៉ (គឺសភា) របស់អ៊ូម៉ារបានបណ្តាលឲ្យកើតមានការបះបោរចលាចលក្នុងអ៊ុមម៉ាត់អ៊ីស្លាម ។ នេះគឺដំណាក់ការសំខាន់ដំបូងក្នុងការបើកដៃឲ្យសត្រូវស្លាប់រស់របស់អ៊ីស្លាម គឺត្រកូលអ៊ូម៉ៃយ៉ាស់ ឡើងកាន់អំណាច និងសងសឹកឲ្យបណ្តាសាច់ញាតិរបស់ខ្លួនដែលបានស្លាប់នៅឯសមរភូមិបាដ្ររដោយដៃអ៊ីម៉ាំអាលី صلوات الله عليه والسلام ដែលជាយុវជនហាស៊្ហីម ជាមុស្លីមជ្រះថ្លា ។

## រជ្ជកាលអ៊ុស្ម៉ាន

លុះអ៊ុស្ម៉ានកាន់អំណាច ត្រកូលអ៊ូម៉ៃយ៉ាស់និងត្រកូល អាប៊ូ ម៉ាអ៊ីត្ (أبي معيط) បានចោមរោមគាត់ ហើយបានគ្រប់គ្រងជោគវាសនាអ៊ុមម៉ាត់ ។ អ៊ុស្ម៉ានស្រឡាញ់សាច់ញាតិគាត់ ត្រកូលអ៊ូម៉ៃយ៉ាស់ ហើយបានផុងខ្លួនក្នុងការស្មោះត្រង់ចំពោះអស់បុគ្គលត្រកូលនេះ[109] ។ ដោយហេតុនេះ មន្ទីរការិយាល័យរបស់រដ្ឋទាំងអស់នៅក្នុងកណ្តាប់បុគ្គលអស់ទាំងនេះ ឯទ្រព្យទាំងអស់របស់មុស្លីមក្លាយទៅជាកម្មសិទ្ធិដាច់មុខរបស់ពួកគេ ។ ដូច្នេះហើយបានជាចលាចល ការបះបោរនិងអនាធិបតេយ្យកើតមានឡើងពាសពេញតាមអាណាខេត្តនៃរដ្ឋ ។ ម្យ៉ាងទៀត អ៊ុស្ម៉ានបានសង្កត់សង្កិនបណ្តាមុស្លីមជំនាន់មុននិងអាជ្ញាធរអ៊ុមម៉ាត់ ដូចជាអាប៊ូ ស្ហារ៍ អាល់-គ៊ីហ្វារី, អាប់ឌុលឡោះហ្វ៉ អ៊ីបនូ ម៉ាស់អ៊ូដ្ និង អាំម៉ារ៍ អ៊ីបនូ យ៉ាសៀរ៍ ជាដើម ។ សូម្បីតែអ៊ៃស្ហាស់ មហេសីមេម៉ាយរបស់ព្រះសាស្តា صلى الله عليه وآله وسلم និងកូនស្រីរបស់អាប៊ូ បាការ ក៏ប្រឆាំងអ៊ុស្ម៉ានដែរ បានចោទគាត់ថាកាហ្វៀរហើយបានជំរុញប្រជារាស្ត្រឲ្យសម្លាប់គាត់ ។

---

109 សូមមើលសៀវភៅរបស់លោក អាស្ម៉ាដ្ អ៊ីបនូ ហ្ហាន់បាល់ *អាល់-មុសណាដ្* ក្បាលទី ១ ទំព័រ ៦២ ។

រឿងនេះបានឈានដល់កម្រិតកំពូលពេលអាណាខេត្តទាំងមូល ដូចជាអ៊ីរ៉ាក់និងអេស៊ីសបត៍ជាដើម បានបះបោរ ។ មនុស្សជាទ័ពៗបានឆ្ពោះទៅកាន់ម៉ាឌីណាស់ ទៅឡោមព័ទ្ធផ្ទះអ៊ុស្មម៉ាន សូមឲ្យដេញម៉ារវ៉ាន អ៊ីបនូ អាល់-ហ្កាកាំនិងបនអ៊ូម៉ៃយ៉ាស់ចេញពីមុខតំណែងរដ្ឋ ឬឲ្យលាចេញពីមុខតំណែងខ្លួន ។

ដំបូង អ៊ុស្មម៉ានបានសន្យាពួកបះបោរថានឹងឆ្លើយតបពួកគេ តែគាត់មិនបានឆ្លើយតបទេ ។ ដូច្នេះពួកបះបោរក៏បានសម្លាប់គាត់យ៉ាងសាហាវ ហើយបានចោលសពគាត់លើគំនរអាចម៍សត្វស្រុកម៉ាឌីណាស់ ដោយដាក់បម្រាមមិនឲ្យអ្នកណាយកសពទៅកប់ទេ ។ ក៏ប៉ុន្តែអ៊ីម៉ាំអាលី صلوات الله عليه والسلام បានសូមពួកបះបោរកប់សពគាត់ ពួកគេក៏បានយល់ព្រម ។

ប៉ែកចុងក្រោយនៃរជ្ជកាលអ៊ុស្មម៉ានបានចប់ ទំព័រថ្មីនៃប្រវត្តិសាស្ត្រអ៊ីស្លាមបានចាប់ផ្តើម ។ ប្រសិនបើគ្មានការប្រទូសបះបោរប្រឆាំងរដ្ឋបាលរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام ទេ គឺការប្រទូសបះបោរដែលអ៊ៃស្ហាស់ ម៉ារីយ៉ាស់ ត្ហល់ហ្ហាស់ និងអាល់-ហ្ស៊ូបៃរ៍បានបង្កនោះ ប្រាកដជារជ្ជកាលព្រះអង្គ صلوات الله عليه والسلام បានកែបញ្ហាដែលស្តេចខ័លិហ្វបីមុននោះបានបង្កទៅលើអ៊ុមម៉ាត់ ។

## រជ្ជកាលអ៊ីម៉ាំអាលី صلوات الله عليه والسلام

ក្រោយពីបានរំលំរដ្ឋបាលអ៊ុស្មម៉ាន ពួកបះបោរបានចោមរោមអ៊ីម៉ាំអាលី صلوات الله عليه والسلام ហើយបានប្រកាសថាពួកគេបានជ្រើសរើសព្រះអង្គ صلوات الله عليه والسلام ជាឯកច្ឆន្ទជាអ្នកដឹកនាំអ៊ុមម៉ាត់អ៊ីស្លាម ។ ព្រោះតែព្រះអង្គ صلوات الله عليه والسلام ដឹងវិបត្តិជាមុន បានជាអ៊ីម៉ាំអាលី صلوات الله عليه والسلام បដិសេធ តែមហាជនទទូចសូមហើយថាពួកគេមិនបានជ្រើសយកអ្នកណាផ្សេងពីព្រះអង្គ صلوات الله عليه والسلام ទេ ហើយអ៊ុមម៉ាត់អ៊ីស្លាមនឹងពុំមានអ្នកដឹកនាំទេបើព្រះអង្គ صلوات الله عليه والسلام បដិសេធ ។

ដូច្នេះ អ៊ីម៉ាំ صلوات الله عليه والسلام ចាំបាច់ត្រូវតែយល់ព្រម ប្រជារាស្ត្រក៏ប្រញាប់សូមស្វាគមន៍ សម្តែងនូវសេចក្តីគោរពព្រះអង្គ صلوات الله عليه والسلام ។ ត្ហល់ហ្ហាស់ អាល់-ហ្ស៊ូបៃរ៍ កងទ័ព អតីតយោធិននិងអាជ្ញាធរអ៊ីស្លាម ព្រមទាំងមហាជនទាំងអស់បានស្វាគមន៍ សូមគោរពដោយស្មោះស្ម័គ្រចំពោះអ៊ីម៉ាំអាលី

صلوات الله عليه والسلام[110] ។ ការពិត ស្តេចខ៍្លលិហ្វទាំងបីមុន ឬអ្នកកាន់ក្តាប់រដ្ឋអ៊ីស្លាមមិនដែលបានទទួលនូវការស្វាគមន៍ស្មោះ ដោយមិនបង្ខិតបង្ខំឡើយ លើកលែងតែអ៊ីម៉ាំអាលី صلوات الله عليه والسلام ។

បណ្តាកុលសម្ព័ន្ធគូរ៉យ៉ស្ទទួលអភិបាលភាពអ៊ីម៉ាំអាលី صلوات الله عليه والسلام ដូចពួកគេបានទទួលសាស្តាភាពរបស់ព្រះសាស្តា صلى الله عليه وآله وسلم មូហាំម៉ាដ់ صلى الله عليه وآله وسلم ដែរ ពោលគឺដោយមិនស្រួលចិត្តនិងបារម្ភ[111] ។ ពួកគេស្គាល់អ៊ីម៉ាំ صلوات الله عليه والسلام តាមទិដ្ឋភាពមួយផ្សេង សម្រាប់ពួកគេ ព្រះអង្គ صلوات الله عليه والسلام ជាអ្នកកាត់ក្បាលពួកគេ ជាអ្នកកម្ទេចមោទនភាពពួកគេក្រោមទង់អ៊ីស្លាម[112] ។ ពួកគេដឹងដែរថាអ៊ីម៉ាំ صلوات الله عليه والسلام ប្រាកដជាមិនភ្លេចរឿងពួកគេប្លន់ទ្រព្យសាធារណៈ ក្នុងរជ្ជកាលខ្មៅងងឹតរបស់អ៊ុស្មាននោះទេ ។

លុះព្រះអង្គ صلوات الله عليه والسلام បានឡើងកាន់មុខតំណែងដឹកនាំភ្លាម អ៊ីម៉ាំអាលី صلوات الله عليه والسلام មហាបុរសមួយគត់ដែលសក្តិសមនឹងវិសេសសព្ទ អាមីរុល-មុមីនីន ព្រះអគ្គមហាប្រមុខរបស់បណ្តាអ្នកមានសទ្ធាជ្រះថ្លា បានដកហូតយកទ្រព្យទាំងអស់ដែលអ៊ុស្មានបានលួចពីសម្បត្តិសាធារណៈ ទៅឲ្យបណ្តាសាច់អសទ្ធារបស់គាត់ដោយដាច់មុខ ។ បន្ទាប់ពីនោះព្រះអង្គ صلوات الله عليه والسلام បានទម្លាក់អស់មន្ត្រីរបស់អ៊ុស្មានដែលបានប្រព្រឹត្តអំពើអយុត្តិធម៌ និងការសង្កត់សង្កិនក្នុងអ៊ុមម៉ាត់អ៊ីស្លាម ។ ដំណាក់ការទីបីក្នុងកម្មវិធីសង្គមយុត្តិធម៌របស់ព្រះអង្គ صلوات الله عليه والسلام អ៊ីម៉ាំអាលី صلوات الله عليه والسلام បានប្រកាសនូវសមភាពរវាងមនុស្ស ហើយបានលុបបំបាត់ការរើសអើង ប្រកាន់វណ្ណៈនៅក្នុងសង្គម[113] ។

---

[110] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប់ដ៍ រ៉ប់ប៊ិះហ៍ (ابن عبد ربه) *អាល់-អាក់ដ៍ អាល់-ហ្វារីដ (العقد الفريد)* ក្បាលទី ២ ទំព័រ ៩៣ ។

[111] សូមមើលសៀវភៅរបស់លោក អាស្ស៊ម៉ាដ់ ហ៊្សែន៍ យ៉ាកុំគូប The Conception of the Sahaba's Ultimate Decency and the Political Authority in Islam បកប្រែជាភាសាអង់គ្លេសដោយលោក Badr Shahin បោះ ពុម្ពដោយរោងពុម្ព Ansariyan Publications, 1999 ។

[112] សូមមើលសៀវភៅរបស់លោក អាល់-យ៉ាកុំគូប៊ី (اليعقوبي) *អាល់-តារិក (التاريخ)* ក្បាលទី ២ ទំព័រ ១៥៥ ។

[113] សូមមើលសៀវភៅ *អាន់សាប់ អាល់-អាស្ស៊រ៉ហ្វ (أنساب الأشراف)* ក្បាលទី ១ ទំព័រ

អ៊ីម៉ាំអាលី صلوات الله عليه والسلام បានអប់រំព្រះរាជបុត្រទាំងពីររបស់ព្រះអង្គ صلوات الله عليه والسلام នៅលើផែនការប្រកបដោយគុណធម៌នេះឯង គឺព្រះរាជបុត្រដែលលើកតម្កើងពាក្យស្លោកយុត្តិធម៌របស់ព្រះអង្គ صلوات الله عليه والسلام ដែលបានប្រយុទ្ធដើម្បីពាក្យស្លោកនេះ ដែលបានប្រឆាំងអស់បុគ្គលសង្កត់សង្កិនគេនិងអស់បុគ្គលអន្យតិរ្ថិយ ។

## ការប្រទូសប្រឆាំងអ៊ីម៉ាំ صلوات الله عليه والسلام

អ៊ីម៉ាំអាលី صلوات الله عليه والسلام ព្យាយាមអនុវត្តិតាមព្រះបញ្ញាគួរអាន និងស៊ុណាស់យ៉ាងទៀងទាត់ ឥតលំអៀង ។ ក្រុមមានអំណាចវៀចវេរជាច្រើនបានប្រឆាំងព្រះអង្គ صلوات الله عليه والسلام ដើម្បីការពារផលប្រយោជន៍ផ្ទាល់ខ្លួន ដែលបានមកដោយមិនត្រឹមត្រូវ ។

បុគ្គលមុនគេបង្អស់ ដែលចេញមុខបះបោរប្រឆាំងរដ្ឋបាលអ៊ីម៉ាំអាលី صلوات الله عليه والسلام គឺតុល់ហាស់និងអាល់-ស៊ូបៃរ៍ ។ ព្រោះតែអ៊ីម៉ាំ صلوات الله عليه والسلام ចាត់ទុកពួកគេដូចមុស្លីមឯទៀត មិនព្រមឲ្យពួកគេមានឯកសិទ្ធិពិសេសលើសមុស្លីមឯទៀត បានជាពួកគេបះបោរប្រឆាំងព្រះអង្គ صلوات الله عليه والسلام បានផ្ដាច់ការគោរពស្មោះស្ម័គ្រចំពោះព្រះអង្គ صلوات الله عليه والسلام ដូចកាលពីដើម ។ ព្រះអង្គ صلوات الله عليه والسلام មិនព្រមឲ្យពួកគេកាន់មុខតំណែងណាមួយទេ ព្រោះព្រះអង្គ صلوات الله عليه والسلام ដឹងថាបុគ្គលទាំងនេះជាមនុស្សល្មោភ ។

ថ្ងៃមួយបុគ្គលទាំងពីរនេះបានសូមអនុញ្ញាតពីអ៊ីម៉ាំ صلوات الله عليه والسلام ទៅម៉ាក់កាស់ ធ្វើអ៊ុមរ៉ោះត៍ ។[114] អ៊ីម៉ាំ صلوات الله عليه والسلام បានសម្លឹងមើលបុគ្គលទាំងពីរ ហើយមានវចនៈថា៖ "សូមស្បថចំពោះអល់ឡោះហ្ទ៍ عز وجل លោកទាំងពីរមិនប៉ងទៅធ្វើអ៊ុមរ៉ោះត៍ទេ ។ តែលោកទាំងពីរប៉ងបះបោរនិងផ្ដាច់ការស្មោះស្ម័គ្រមកលើរូបខ្ញុំ ។"

ក៏ប៉ុន្តែអ៊ីម៉ាំ صلوات الله عليه والسلام បានអនុញ្ញាតឲ្យពួកគេទៅ បន្ទាប់ពីព្រះអង្គ صلوات الله عليه والسلام បានឲ្យ

---

១៥០ (ក្បាលទី ១) ។

[114] អ៊ុមរ៉ោះត៍ គឺពិធីហាច្ជមិនចាំបាច់នៅឯព្រះមហាគ្រិះរបស់អល់ឡោះហ្ទ៍ عز وجل នៅឯម៉ាក់កាស់ ។ គេហៅអ៊ុមរ៉ោះត៍ដែរថា ពិធីហាច្ជតូច ។

បុគ្គលទាំងពីរនេះប្ដេជ្ញាស្មោះស្ម័គ្រចំពោះព្រះអង្គ صلوات الله عليه والسلام ម្ដងទៀត ។ ឥតរួញរា បុគ្គលទាំងពីរក៏បានប្ដេជ្ញាស្មោះស្ម័គ្រ ហើយស្បថថានឹងមិនបះបោរជាដាច់ខាត ។

បានទៅដល់ម៉ាក់កាស្ហ្គ្លាម បុគ្គលទាំងពីរនេះទៅជួបអ៉ែស្ហាស្ហ៍ ។ ទោះបីអ៉ែស្ហាស្ហ៍បានដឹកនាំការបះបោរប្រឆាំង អ៊ុស្ហ្ម៉ាន អ៊ីបនូ អាហ្វ៊ហ្វាន ហើយបានអារកាត់ថាគាត់ជាកាហ្វៀរនោះក៏ដោយ ក៏អ៉ែស្ហាស្ហ៍មិនអាចអត់ទ្រាំ ដំណឹងអ៊ីម៉ាំអាលី صلوات الله عليه والسلام ទទួលមុខតំណែងដឹកនាំអ៊ុមម៉ាត្ហ៍អ៊ីស្លាមនោះបានដែរ ពីព្រោះអ៉ែស្ហាស្ហ៍មានចិត្តព្យាបាទដែលមិនអាចទប់បានចំពោះអ៊ីម៉ាំអាលី صلوات الله عليه والسلام ។ ដូច្នេះ អ៉ែស្ហាស្ហ៍បានផ្លាស់ប្ដូរស្ថានភាពជំហរទាំងស្រុងដោយបែរទៅរកអ៊ុស្ហ្ម៉ានវិញ ។ គាត់បានផ្ដើមកាន់ទុក្ខអ៊ុស្ហ្ម៉ាន បានយកការសម្លាប់អ៊ុស្ហ្ម៉ានជាលេស ដើម្បីរំលំរដ្ឋបាលអ៊ីម៉ាំអាលី صلوات الله عليه والسلام[115] ។ ត្ហល់ហ្ហាស្ហ៍និងអាល់-ស៊ូបៃរ៍ ព្រមទាំងពួកទាញយកផលប្រយោជន៍ពីរដ្ឋបាលអ៊ុស្ហ្ម៉ានបានរួមដៃជាមួយអ៉ែស្ហាស្ហ៍ បានសម្រេចចិត្តលើកទ័ពទៅកាន់ស្រុកបាស្ហ្រ៉ោះត្ហ៍ ដើម្បីតស៊ូទល់នឹងអាជ្ញាធរអ៊ីម៉ាំ صلوات الله عليه والسلام ។

អស់បុគ្គលបះបោរខុសគន្លងធម៌បានទាក់ទាញចិត្តអ៉ែស្ហាស្ហ៍ ដោយបន្ដុបគាត់លើខ្នងអូដ្ឋ[116]និងដោយហៅគាត់ថាព្រះមាតា ។ ពេលគាត់បានទៅដល់កន្លែងមួយ ឆ្កែបានទទួលបក្សពួកគាត់និងខ្លួនគាត់ដោយព្រុស ។ សម្លេងឆ្កែព្រុះ បានធ្វើឲ្យគាត់នឹកឃើញព្រះវចនៈរបស់ព្រះសាស្ដា صلى الله عليه وآله وسلم ហើយក៏បានសួរដោយសម្ដីភ័យរន្ធត់ថា៖ "តើគេហៅកន្លែងនេះថាកន្លែងអ្វី ?" គេបានឆ្លើយប្រាប់ថា៖ "គេហៅកន្លែងនេះថា អាល់-ហ្ហៅអ៊ាប់

---

[115] សូមមើលសៀវភៅរបស់លោក មូហ្ហាំម៉ាដ្ហ៍ អ៊ីបនូ យ៉ាហ្ជៀរ អាល់-ត្ហ៍បារី (محمد بن جرير طبري) *តារីក្ហ៍ អាល់-អ៊ូម៉ាំ វ៉ា អាល់-មុលុក (تاريخ الأمم والملوك)* ក្បាលទី ៣ ទំព័រ ៤៥៤ ។

[116] សូមមើលសៀវភៅរបស់លោក មូហ្ហាំម៉ាដ្ហ៍ អ៊ីបនូ យ៉ាហ្ជៀរ អាល់-ត្ហ៍បារី (محمد بن جرير طبري) *តារីក្ហ៍ អាល់-អ៊ូម៉ាំ វ៉ា អាល់-មុលុក (تاريخ الأمم والملوك)* ក្បាលទី ៣ ទំព័រ ៤៧៥ ។

(حَوْأَب) ។"

ពេលបានឮឈ្មោះនេះ អ៊ែស្ហាស់ភ័យតក្កមា ឲ្យពួកគេនាំគាត់ត្រឡប់ទៅផ្ទះវិញ ។ ពេលគេសួរគាត់រកមូលហេតុ គាត់បានតបថាថ្ងៃមួយគាត់ បានឮព្រះសាស្តាﷺ មានព្រះវចនៈប្រាប់ព្រះមហេសីទាំងឡាយរបស់ព្រះអង្គﷺថា៖ "ខ្ញុំបានឃើញព្រឹត្តការណ៍មួយនឹងកើតឡើងគឺ ឆ្កែស្រុកអាល់-ហៅអាប់នឹងព្រុសដាក់បុគ្គលម្នាក់ ក្នុងចំណោមពួកនាង ។ នារីតូចក្រហម[117] ចូរកុំទៅជាបុគ្គលរូបនោះឡើយ !"[118]

ពួកបះបោរទាំងអស់ខិតខំធ្វើឲ្យអ៊ែស្ហាស់ដូរចិត្ត តែឥតប្រយោជន៍ ។ ដូច្នេះ ពួកនេះ ដែលមានតួលហ្ហាស់និងអាល់-ស៊ូបៃរ៍ជាមេនាំអាទិ៍ បានសូកបុគ្គលមួយចំនួនឲ្យមកធ្វើសាក្សីថា កន្លែងនេះមិនមែនកន្លែងដែលគេហៅថាអាល់-ហៅអាប់ទេ ។ នោះគឺសម្បថបំពានដំបូងក្នុងអ៊ីស្លាម[119] ។ អកុសល អ៊ែស្ហាស់ត្រូវបោកប្រាស់ដោយសាសក្ខីភាពទុច្ចរិតនោះ ។

ពេលអស់បុគ្គលបះបោរខុសគន្លងធម៌ បានមកដល់ជាយស្រុកបាស្ស៉រ៉ោះត៍ អ៊ុស្មម៉ាន អ៊ីបនូ ហ៊ានិហ្វ អភិបាលស្រុកបាស្ស៉រ៉ោះត៍ បានចាត់បញ្ជូនអាប៊ូអាល់-អាស់វ៉ាដ៍ អាល់-ឌូអាលីទៅមើលខុសត្រូវរឿងនេះ ។ បុរសនេះបានជួបអ៊ែស្ហាស់និងអាល់-ស៊ូបៃរ៍ បានពិភាក្សារឿងនេះយ៉ាងសមគួរជាមួយ

[117] គេបានហៅអ៊ែស្ហាស់ថា "ហ៊ូម៉ៃរ៉អ៍ (حميراء ក្រហម) - គឺ នារីតូចក្រហម ។

[118] នៅក្នុងសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហ៊ាឌីដ៍ *ស្ហារហ៍ ណាស្ស៉ អាល់-បាឡាក៉ោះត៍* ក្បាលទី ២ ទំព័រ ៤៩៧ មានសរសេរថា អាប់ឌុលឡោះហ៍ អ៊ីបនូ អាប់បាស់បានតំណាលថា ថ្ងៃមួយព្រះសាស្តាមូហ៊ាំម៉ាដ៍ﷺបានថ្លែងប្រាប់មហេសីទាំងឡាយរបស់ព្រះអង្គﷺ ដែលមានវត្តមាននៅជុំជាមួយព្រះអង្គﷺថា៖ "តើអ្នកណាមួយ ក្នុងចំណោមពួកនាង ចង់ជិះអូដ្ឋយក្សហើយត្រូវឆ្កែស្រុកអាល់-ហាវ៉ាប់ព្រុស ? នៅខាងឆ្វេងនិងខាងស្តាំនាងនោះនឹងមានមនុស្សស្លាប់ច្រើន ។ ពួកទាំងអស់នោះនឹងនៅក្នុងនរក ។ នាងនោះនឹងពិបាកគេចរួចពីនរកនោះ ។"

[119] សូមមើលសៀវភៅរបស់លោក អាល់-ម៉ាស់អ៊ូឌី (المسعودي) *មូរូច អាល់-ស្ហាហ្អាប់ (مُروجُ الذَّهَب)* ក្បាលទី ២ ទំព័រ ៣៤២; សៀវភៅរបស់លោក អាល់-យ៉ាក់គូប៊ី (اليعقوبي) *អាល់-តារិក្ហ (التاريخ)* ក្បាលទី ១ ទំព័រ ១៨១ ។

ពួកគេ ។ តែពួកគេមិនព្រមស្តាប់លោកទេ ។

អាប៊ូ អាល់-អាស់វ៉ាដ៍បានប្រាប់អភិបាលស្រុកថាពួកគេសម្រេចចិត្តប្រយុទ្ធ ។ ដូច្នេះ ប៉ែកទាំងពីរក៏បានធ្វើកិច្ចសន្យាមិនច្បាំងគ្នាក្នុងចន្លោះពេលរង់ចាំយោបល់អ៊ីម៉ាំអ៊ាលី صلوات الله عليه والسلام ។

ទោះជាយ៉ាងណាក៏ដោយ បក្សអ៊ៃស្ហាស់បានផ្តាច់កិច្ចសន្យាសន្តិសុខបានវាយប្រហារ បានចាប់ខ្លួនអភិបាលស្រុកហើយបានធ្វើទារុណកម្មលោក បានប្លន់យកទ្រព្យសាធារណៈ ហើយបានបង្កចលាចលក្នុងស្រុកបាស្ហ៍រ៉ោះត៍ ។

អ៊ីម៉ាំ صلوات الله عليه والسلام ក៏បាននាំទ័ពទៅបាស្ហ៍រ៉ោះត៍ ប្រយុទ្ធទល់នឹងពួកបេះបោរ ។ លុះមកដល់ភ្លាម ព្រះអង្គ صلوات الله عليه والسلام បានចាត់បញ្ជូនអ៊ាប់ឌុលឡោះហ៍ អ៊ីបនូ អ៊ាប់បាស់និងស៊ៃដ៍ អ៊ីបនូ ស្ហៅហ្ហាន (زيد بن صوحان) ទៅចរចាសន្តិសុខជាមួយពួកនោះ ។ តែពួកនោះមិនស្តាប់ទេ ។ បន្ទាប់ពីនោះព្រះអង្គ صلوات الله عليه والسلام បានចាត់បញ្ជូនក្មេងត្រឹមត្រូវម្នាក់ ឲ្យនាំយកគួរអានទៅជាមួយផង ទៅចរចាហៅពួកនោះមករកសន្តិសុខនិងឲ្យអនុវត្តតាមព្រះបញ្ញាគួរអាន ។

ពួកបះបោរបានវាយប្រហារក្មេងនោះ បានកាត់ដៃទាំងពីររបស់ក្មេងនោះបានបាញ់ក្មេងនោះដោយគ្រាប់ព្រួញលុះក្ស័យជីវិត ។

ដូច្នេះ អ៊ីម៉ាំ صلوات الله عليه والسلام ចាំបាច់ត្រូវវាយប្រហារបក្សនោះ ដឹកនាំដោយអ៊ៃស្ហាស់ ។ ពួកបះបោរមិនអាចតទល់នឹងទ័ពរបស់អ៊ីម៉ាំ صلوات الله عليه والسلام បានទេ ។ ដូច្នេះ អ៊ៃស្ហាស់ខិតខំកម្លាចិត្តយោធារបស់ខ្លួនឲ្យមានសេចក្តីក្លាហានឡើង តែពួកទាំងនេះខ្សោយណាស់សម្រាប់ផ្លែដាវដ៏ល្បីរបស់ព្រះអង្គ صلوات الله عليه والسلام ។ ពួកគេបានឡោមព័ទ្ធអូដ្ឋរបស់ព្រះមាតាពួកនោះ អ៊ីម៉ាំ صلوات الله عليه والسلام បានបញ្ជាឲ្យអ៊ាំម៉ារ អ៊ីបនូ យ៉ាស់សៀរ៍និងម៉ាលិក អាល់-អាស្ហ៍តារ៍ កាត់ជើងអូដ្ឋពីព្រោះយោលតាមសម្តីរបស់អ៊ីម៉ាំ صلوات الله عليه والسلام ពួកយុទ្ធជនរបស់អ៊ៃស្ហាស់បានយកអូដ្ឋនេះចំណុចកណ្តាល ។ ពួកគេក៏បានធ្វើដូច្នេះ ចម្បាំងក៏បានចប់ បរាជ័យដ៏ជូរចត់បានទៅពួកបះបោរអន្សត្តិរ្លិយ ។ គេហៅសមរភូមិនេះថា "សមរភូមិអូដ្ឋ" ។

បន្ទាប់មកអ៊ីម៉ាំ صلوات الله عليه والسلام ក៏បានប្រកាសលើកលែងទោសឲ្យទាំងអស់គ្នា ហើយ

ដោះលែងអ៊ែស្ហាស់ឲ្យទៅកាន់ម៉ាឌីណាស់វិញ ។[120]
អាស្រ័យព្រឹត្តិការណ៍ទាំងនេះ ព្រះនាងស៊ែណាប់ عليها سلام الله យល់យ៉ាងជ្រៅជ្រះនូវអំពើហិង្សា ដែលពួកកុលសម្ព័ន្ធគូរ៉យ៉ស្ហ៍បានធ្វើមកលើព្រះអយ្យកោ និងព្រះបិតាព្រះនាង ។ ព្រះនាងយល់ផងដែរនូវការពិតនៃអ៊ុមម៉ាត់អ៊ីស្លាម និងកាតព្វកិច្ចដែលមុស្លីមទាំងអស់ត្រូវធ្វើចំពោះអ៊ុមម៉ាត់ ។

## មូអ៊ាវីយ៉ាស់បង្កចលាចល

ការពិត អ៊ែស្ហាស់បានត្រួសត្រាយផ្លូវបះបោរឲ្យមូអ៊ាវីយ៉ាស់ដែលបានលើកយករឿងឃាតកម្មអ៊ុស្ហ្ម៉ានមកធ្វើជាលេសដែរ ដើម្បីប្រឆាំងរដ្ឋបាលមិនលំអៀងរបស់អ៊ីម៉ាំ صلوات الله عليه والسلام ។
មូលហេតុមួយគត់ដែលបណ្ដាលឲ្យមូអ៊ាវីយ៉ាស់បះបោរនោះគឺ គាត់ដឹងច្បាស់ថាអ៊ីម៉ាំ صلوات الله عليه والسلام នឹងទម្លាក់គាត់ពីមុខតំណែង[121] នឹងដកហូតទ្រព្យសម្បត្តិដែលគាត់បានប្លន់យកពីសម្បត្តិសាធារណៈ នឹងសងសឹកគាត់ព្រោះគាត់បានប្រព្រឹត្តបំពារបំពានសាសនាអ៊ីស្លាម ដូចជាស្លៀកពាក់សូត្រ ប្រើប្រាស់ភាជនៈមាសនិងប្រាក់ សាងសង់ប្រាសាទដោយខ្ជះខ្ជាយទ្រព្យជាដើម ។ ម្យ៉ាងទៀត អ៊ីម៉ាំ صلوات الله عليه والسلام នឹងមិនអនុញ្ញាតឲ្យគោលបំណងរបស់អ៊ុម៉ារបានសម្រេចទេ ដោយលើកតម្កើងនិងគាំទ្រគាត់នោះ ។ ទោះជាយ៉ាងណាក៏ដោយ មូអ៊ាវីយ៉ាស់បានច្រានចោលសន្ធិសញ្ញាសន្តិសុខរបស់អ៊ីម៉ាំ صلوات الله عليه والسلام និងការព្រមចុះចូលក្រោមអាជ្ញាធរព្រះអង្គ صلوات الله عليه والسلام ។ គាត់បានប្រមូលទ័ពធំមួយ ហើយបានឆ្ពោះទៅកាន់កន្លែងមួយដែលហៅថា

[120] អ៊ីម៉ាំអ៊ាលី صلوات الله عليه والسلام ខមាទោសឲ្យសត្រូវទាំងអស់របស់ព្រះអង្គ صلوات الله عليه والسلام ដូចជាអ៊ាប់ឌុលឡោះហ្វ៍ អ៊ីបនូ អាល់-ស្ហ៊ូបៃរ៍និងម៉ារវ៉ាន អ៊ីបនូ អាល់ហ្ហាកាំ ជាដើម មិនធ្វើទោសបុគ្គលទាំងនេះទេ ។ ពត៌មានលំអិត សូមមើលសៀវភៅរបស់លោកអាល់-យ៉ាក៊ូគូប៊ី (اليعقوبي) *អាល់-តារិក្ហ (التاريخ)* ។

[121] ចាប់តាំងពីរជ្ជកាលអ៊ុម៉ារមក មូអ៊ាវីយ៉ាស់ អ៊ីបនូ អាប៊ូ ស៊ុហ្វយ៉ាន សត្រូវស្លាប់រស់របស់អ៊ីស្លាម កូនរបស់សត្រូវស្លាប់រស់របស់អ៊ីស្លាម បានកាន់មុខតំណែងអភិបាលប្រទេសស៊ីរី ។

ស្ស៊ីហ្វហ្វ៊ីន (صفين) នៅឯព្រំប្រទល់អ៊ីរ៉ាក់-ស៊ីរី ។ ដំបូងបង្អស់គាត់បានកាន់កាប់ត្រើយទាំងពីរនៃស្ទឹងអឺប្រ្ហាត់ (Euphrate) ដើម្បីបង្អត់ទឹកកងទ័ពរបស់អ៊ីម៉ាំ صلوات الله عليه والسلام ។

ម្ខាងឯណោះ អ៊ីម៉ាំ صلوات الله عليه والسلام ត្រៀមខ្លួនប្រឈមនឹងទ័ពបះបោរ ។ ទ័ពព្រះអង្គ صلوات الله عليه والسلام មិនអាចចូលទៅដល់ស្ទឹងអឺប្រ្ហាត់បានដើម្បីផ្តល់ទឹក ។ ហេតុដូច្នេះ ព្រះអង្គ صلوات الله عليه والسلام បានបញ្ជូនបណ្តាសាវកព្រះអង្គ صلوات الله عليه والسلام ទៅអន្វងមូអាវីយ៉ាស្ទ ឲ្យបើកឲ្យទ័ពព្រះអង្គ صلوات الله عليه والسلام ទៅយកទឹក ។ មូអាវីយ៉ាស្ទបដិសេធយ៉ាងកំណាច ។ អ៊ីម៉ាំ صلوات الله عليه والسلام ក៏បានបញ្ជាឲ្យទ័ពកាន់កាប់ស្ទឹងនិងផឹកទឹក ។ កងទ័ពក៏បានធ្វើដូច្នេះ ចំណែកឯពួកបះបោរក៏បានទទួលបរាជ័យ រត់គេចពីត្រើយស្ទឹង ។ បន្ទាប់ពីនោះ ពួកមេបញ្ជាការទ័ពអ៊ីម៉ាំ صلوات الله عليه والسلام ឆ្លៀតយកឱកាសនេះសងសឹកវិញ ដោយបង្អត់ទឹកកងទ័ពរបស់មូអាវីយ៉ាស្ទវិញដែរ មិនឲ្យពួកគេចូលមកក្នុងស្ទឹងទេ តែអ៊ីម៉ាំ صلوات الله عليه والسلام ព្រោះតែព្រះអង្គ صلوات الله عليه والسلام ប្រកបដោយមនុស្សធម៌ឥតប្រៀបបាននិងប្រកបដោយសីលធម៌ខ្ពង់ខ្ពស់ មិនយល់ព្រមឲ្យធ្វើបែបនេះទេ ។

ដើម្បីទប់ស្កាត់ការបង្ហូរឈាម អ៊ីម៉ាំ صلوات الله عليه والسلام បានចាត់បញ្ជូនអ្នកនាំសារចរចាសន្តិសុខទៅឯជំរុំមូអាវីយ៉ាស្ទ តែបុគ្គលរូបនេះបដិសេធហើយសម្រេចចិត្តធ្វើសង្គ្រាមតទល់អ៊ីម៉ាំ صلوات الله عليه والسلام ។ ដូច្នេះ អ៊ីម៉ាំ صلوات الله عليه والسلام ចាំបាច់ត្រូវតែប្រយុទ្ធទល់នឹងពួកគេ ។ ដំបូង មានការប្រយុទ្ធតតួរវាងក្រុមទាំងពីរ ព្រោះអ៊ីម៉ាំ صلوات الله عليه والسلام សង្ឃឹមថាមូអាវីយ៉ាស្ទនឹងព្រមធ្វើសន្ធិសញ្ញាសន្តិសុខ ។ លុះអ៊ីម៉ាំ صلوات الله عليه والسلام លែងសង្ឃឹម ហើយបានដឹងថាមីអាវីយ៉ាស្ទត្រៀមខ្លួនប្រយុទ្ធស្រុះគ្នា ព្រះអង្គ صلوات الله عليه والسلام ចាំបាច់ត្រូវកែនពល ។ ដូច្នេះ សង្គ្រាមដ៏សាហាវបានផ្ទុះឡើង នៅក្នុងសង្គ្រាមនេះបុគ្គលដ៏ល្បីៗក្នុងសាសនាអ៊ីស្លាម ដូចជា អាំម៉ារ៍ អ៊ីបន្ទយ៉ាសៀរ៍ជាដើមបានបូជាជីវិត ។[122]

ពួករួមគំនិតក្បត់នៅក្នុងក្រុមអ៊ីម៉ាំ صلوات الله عليه والسلام បានឆ្លៀតយកឱកាសនេះបញ្ចេះអ្នកឯទៀតឲ្យឆ្លើយតបការស្នើសូមរបស់ទ័ពស៊ីរី ។ ទោះបីព្រះអង្គ صلوات الله عليه والسلام ស្គាល់កលល្បិចនេះក៏ដោយ ក៏អ៊ីម៉ាំ صلوات الله عليه والسلام ពុំអាចធ្វើអ្វីបានក្រៅពីព្រមឲ្យ

---

[122] គេហៅសង្គ្រាមនេះថា "សមរភូមិស្ស៊ិហ្វហ្វ៊ីន" ។

កងទ័ពព្រះអង្គឆ្លើយតបការស្នើសុំធ្វើសន្ធិសញ្ញាសន្តិសុខ ។ តែពីមុននេះ ព្រះអង្គصلوات الله عليه والسلامបានបញ្ជាក់ ឲ្យដឹងអំពីកលល្បិចមិនត្រឹមត្រូវរបស់ មូអាវីយ៉ាស់ ហើយព្រះអង្គصلوات الله عليه والسلامបានប្រាប់ឲ្យដឹងថាមូអាវីយ៉ាស់និងបក្សពួកមិនដែលគោរពឬជឿគម្ពីរអានម្តងណាឡើយ

តែយោធិនមិនស្តាប់សម្តីអ៊ីម៉ាំصلوات الله عليه والسلامទេ ហើយព្រមចូលទៅក្នុងឧបាយកលរបស់មូអាវីយ៉ាស់ ថែមទាំងបានគំរាមសម្លាប់ព្រះអង្គصلوات الله عليه والسلامទៀតផង បើព្រះអង្គصلوات الله عليه والسلامមិនព្រមធ្វើសន្ធិសញ្ញាសន្តិសុខទេនោះ ។

មិនត្រឹមតែប៉ុណ្ណោះទេ យោធិនរបស់អ៊ីម៉ាំصلوات الله عليه والسلامបានជ្រើសរើស អាប៊ូ មូសា អាល់-អាស្ហ់អារីជាតំណាងពួកគេ ក្នុងអាជ្ញាកណ្តាលរវាងអ៊ីម៉ាំអាលីصلوات الله عليه والسلام និងមូអាវីយ៉ាស់ រីឯអ៊ីម៉ាំصلوات الله عليه والسلامបានជ្រើសរើស អាប់ឌុលឡោះហ្ប៍ អ៊ីបនូអាប់បាស់ អាជ្ញាធរអ៊ីស្លាមប្រសើរបំផុត ។ លើកនេះទៀត យោធិនរបស់អ៊ីម៉ាំصلوات الله عليه والسلامបានច្រានចោលអ្នកតំណាងរបស់ព្រះអង្គصلوات الله عليه والسلام ហើយបានទាមទារឲ្យយក អាប៊ូ មូសា បុគ្គលឥតប្រាជ្ញា ។ ចំណែកឯទ័ពស៊ីរីឯណោះវិញបានជ្រើសរើស អាំរ៉ូ អ៊ីបនូ អាល់-អាស្វ៊ - [ហៅ]កញ្ជ្រោង ។

លុះក្រុមទាំងពីរបានជួបគ្នាដើម្បីកំណត់ពេលវេលាវិនិច្ឆ័យ អាំរ៉ូ អ៊ីបនូអាល់-អាស្វ៊បានធ្វើឲ្យបុរសឥតប្រាជ្ញា តំណាងទ័ពរបស់អ៊ីម៉ាំصلوات الله عليه والسلام ដោយបំភាន់ ថាពួកគេទាំងពីរត្រូវតែទម្លាក់ក្រុមទាំងពីរ គឺមូអាវីយ៉ាស់និងអ៊ីម៉ាំអាលីصلوات الله عليه والسلامដើម្បីធ្វើឲ្យអ៊ុមម៉ាត់អ៊ីស្លាមចៀសផុតពីការប៉ះទង្គិចគ្នា ។ កលល្បិចរបស់បុរសលាក់ពុត តំណាងរបស់បក្សមូអាវីយ៉ាស់ មានប្រសិទ្ធភាពទៅលើបុគ្គលឥតប្រាជ្ញា តំណាងរបស់អ៊ីម៉ាំصلوات الله عليه والسلام ។ មុននឹងប្រតិភូនៃបក្សទាំងពីរបានជួបគ្នា អាំរ៉ូបានបញ្ឆោត អាប៊ូ មូសា ឲ្យឡើងលើវេទិកាមិមបារប្រកាសការសម្រេចទម្លាក់អ៊ីម៉ាំصلوات الله عليه والسلام ។ ក្រោយអាប៊ូ មូសា អាំរ៉ូបានឡើងមិមបារ សម្រេចទម្លាក់អ៊ីម៉ាំصلوات الله عليه والسلامហើយបានតែងតាំងមូអាវីយ៉ាស់ជាអភិបាលដឹកនាំអ៊ុមម៉ាត់ ។

ដោយហេតុនេះ អាប៊ូ មូសា អាល់-អាស្ហ់អារីត្រូវរត់គេចខ្លួនទៅឯម៉ាក់កាស់ បន្ទាប់ពីបានបង្កចលាចលនិងការបែកបាក់គ្នានៅក្នុងក្រុមអ៊ីម៉ាំصلوات الله عليه والسلام ។

## ពួកខ៉ំវ៉ារីច្ (الخَوَارِج) បង្កចលាចល

គួរឲ្យចំអកចំអន់មែន ដែលអស់បុគ្គលដែលបានបង្ខំអ៊ីម៉ាំ صلوات الله عليه والسلام ឲ្យចូលក្នុងកលល្បិចរបស់មូអាវីយ៉ាស់រឿងវិនិច្ឆ័យដោយគួរអាននោះ បានបះបោរប្រឆាំងព្រះអង្គ صلوات الله عليه والسلام ដោយថា ព្រះអង្គ صلوات الله عليه والسلام មិនគួរចូលទៅក្នុងកលល្បិចនោះឡើយ ។ ពួកនេះបានបង្កើតចលនានយោបាយមួយដែលហៅថា "ខ៉ំវ៉ារីច្" (ពហុសវចនៈរបស់ពាក្យ ខ៉ំរីយ៉ី (خارجي) មានន័យថា អ្នកប្រឆាំង) ។ ពួកនេះជាពួកជ្រុលនិយម បានសម្លាប់ជនស្លូតត្រង់ជាច្រើន ដូចជា អាប់ឌុលឡោះហ្វ៍ អ៊ីបនូ ខាប់បាប់ សាវកល្អរបស់ព្រះសាស្ដា صلى الله عليه وآله وسلم ជាដើម បោះជំរំនៅឯ អាល់-ណាស្រ់វ៉ាន់ ។

អ៊ីម៉ាំ صلوات الله عليه والسلام ប៉ងឆ្ពោះទៅកាន់ប្រទេសស៊ីរីដើម្បីបង្ក្រាបមូអាវីយ៉ាស់ បុគ្គលបះបោរ តែបណ្ដាសាវកព្រះអង្គ صلوات الله عليه والسلام បានពិភាក្សាជាមួយព្រះអង្គ صلوات الله عليه والسلام ថា គប្បីប្រយុទ្ធនឹងពួកខ៉ំរីយ៉ីជាមុន ព្រោះពួកនេះជាគ្រោះថ្នាក់ធំជាងមូអាវីយ៉ាស់សម្រាប់អ៊ុមម៉ាត់អ៊ីស្លាម ។ ហេតុដូច្នេះព្រះអង្គ صلوات الله عليه والسلام ឆ្ពោះទៅកាន់អាល់-ណាស្រ់វ៉ាន់ ប្រយុទ្ធតទល់ពួកខ៉ំរីយ៉ី បានសម្លាប់ពួកនេះទាំងអស់ សល់តែប្រាំបួននាក់ទេ ។[123]

បន្ទាប់មក យោធិនរបស់អ៊ីម៉ាំ صلوات الله عليه والسلام ធុញទ្រាន់នឹងសង្គ្រាម ដូច្នេះឯងបានជាពួកគេមិនស្ដាប់ព្រះអង្គ صلوات الله عليه والسلام ពេលព្រះអង្គ صلوات الله عليه والسلام ប៉ងប្រយុទ្ធទល់នឹងមូអាវីយ៉ាស់ បុគ្គលល្មើស ទោះបីព្រះអង្គ صلوات الله عليه والسلام ទទូចប្រកាសក៏ដោយ ។

## រដ្ឋបាលសុចរិតអន់ថយ

និយាយពិត ប៉ែកខាងកើតមិនដែលបានឃើញរដ្ឋបាលណាមួយដូចរដ្ឋបាលរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام ឡើយ ទាំងវិស័យសុចរិតធម៌ វិស័យយុត្តិធម៌និងភាពមិនលំអៀង ។ អកុសល បុគ្គលអប្រិយអន្សតិរិយ៍និងបុគ្គលកាលានុវត្តនិយមសម័យព្រះអង្គ صلوات الله عليه والسلام ព្យាយាមប្រើគ្រប់មធ្យោបាយដើម្បីរំលំផែនការស្ដារនយោបាយ និងសង្គមរបស់ព្រះអង្គ

[123] ការប៉ះទង្គិចគ្នានេះហៅថា "សមរភូមិអាល់-ណាស្រ់វ៉ាន់" ។

صلوات الله عليه والسلام ។ ពួកគេបង្ខំឲ្យព្រះអង្គ صلوات الله عليه والسلام លូកដៃក្នុងការប្រយុទ្ធដែលធ្វើឲ្យកងទ័ពព្រះអង្គ صلوات الله عليه والسلام នឿយណាយ ហើយដែលធ្វើឲ្យព្រះអង្គ صلوات الله عليه والسلام អាក់ខានធ្វើផែនការស្តារនិងកែប្រែរដ្ឋ ។

ចំនួនយោធិនរបស់អ៊ីម៉ាំ صلوات الله عليه والسلام អន់ចុះ ជាឱកាសល្អបំផុតសម្រាប់មូអាវីយ៉ាស់ដើម្បីពង្រឹងកម្លាំងនិងប្រដាប់អាវុធទ័ពរបស់ខ្លួន ។ ម្យ៉ាងទៀត មូអាវីយ៉ាស់ចាប់ផ្តើមវាយប្រហារអាណាខេត្ត ដែលនៅក្រោមការគ្រប់គ្រងរបស់អ៊ីម៉ាំ صلوات الله عليه والسلام ដើម្បីធ្វើឲ្យប្រជារាស្ត្រឃើញថាអ៊ីម៉ាំ صلوات الله عليه والسلام បាត់បង់សមត្ថភាពការពារប្រជារាស្ត្ររបស់ព្រះអង្គ صلوات الله عليه والسلام ។ ក្នុងពេលតែមួយនោះ អ៊ីម៉ាំ صلوات الله عليه والسلام ព្យាយាមកម្លាចិត្តយោធិនព្រះអង្គ صلوات الله عليه والسلام តែឥតប្រយោជន៍ ។ ដូច្នេះព្រះអង្គ صلوات الله عليه والسلام បានបួងសួងអល់ឡោះហ៊្ tعالى សូមឲ្យជួយព្រះអង្គ صلوات الله عليه والسلام ឲ្យរួចផុតពីសង្គមមនុស្សស្មឹមចិត្ត ដែលមិនទទួលស្គាល់គោលការណ៍ និងនយោបាយវាតយុត្តិធម៌និងសមធម៌របស់ព្រះអង្គ صلوات الله عليه والسلام ទេនោះ ។

## ឃាតកម្មអ៊ីម៉ាំអាលី صلوات الله عليه والسلام

ក្រុមខ៉័វ៉ារីយ៉្ជីបានប្រជុំគ្នាជាសម្ងាត់នៅឯម៉ាក់កាស់ ពិភាក្សាគ្នារឿងអ៊ុមម៉ាត់អ៊ីស្លាម ។ ពួកគេបានយល់ព្រមមូលមតិគ្នាថាអ៊ីម៉ាំអាលី صلوات الله عليه والسلام, មូអាវីយ៉ាស់ អ៊ីបនូ អាប៊ូ ស៊ុហ្វយ៉ាន និង អាំរ៉ូ អ៊ីបនូ អាល់-អាស់ជាបុគ្គលដែលធ្វើឲ្យអ៊ុមម៉ាត់វិនាសអន្តរធាន ។ ដូច្នេះ ពួកគេបានសម្រេចចិត្តសម្លាប់បុគ្គលទាំងបីរូបនេះ ។

អាប់ដ្វាល់-រ៉ោះហ៊្ម៉ាន អ៊ីបនូ មុលយ៉្ជីម បុគ្គលចង្រៃ បានទទួលភារកិច្ចធ្វើគុតអ៊ីម៉ាំអាលី صلوات الله عليه والسلام ចំណែកឯពីរនាក់ទៀតទទួលភារកិច្ចសម្លាប់បុគ្គលទាំងពីរនាក់ទៀត ។ ពួកគេបានកំណត់ពេលវេលាចុះដៃអនុវត្តផែនការណ៍ គឺពេលស្វឡាត់អាល់-ហ្វាជ៉រ៍ - មុនថ្ងៃរះ- ថ្ងៃទី ១៩ ខែរ៉ម៉ាដ្ធន ។ ហេតុដូច្នេះ អាប់ដ្វាល់-រ៉ោះហ៊្ម៉ាន អ៊ីបនូ មុលយ៉្ជីម បុគ្គលចង្រៃឧបទ្រពបានត្រឡប់ទៅគូហ្វាស់ រាជធានីរបស់រដ្ឋអ៊ីស្លាម ដើម្បីបំពេញបេសកកម្មនេះ ។ នៅទីនេះ គាត់បានជួបនារីខ៉័វ៉ារីយ៉្ជីម្នាក់ដែលបានបាត់បង់ឪពុកនិង

បងប្អូនប្រុសក្នុងសមរភូមិអាល់-ណាស្ស៊រ៉វ៉ាន់ ។ ពេលគាត់សូមស្តីដណ្តឹងនារីនោះៗបានកំណត់ខាន់ស្លាបីពាន់ដៀរហ្វាំ ទាសៈម្នាក់ ស្រីបម្រើម្នាក់ និងឃាតកម្មអ៊ីម៉ាំអាុលី صلوات الله عليه والسلام ។ អាុប់ដ្វាល់-រ៉ោះហ្ម៉ាន បុរសចង្រៃយល់ព្រម បានសន្យានឹងនារីនោះថានឹងធ្វើគ្រប់ប្រការនេះ ។[124]

យប់ថ្ងៃទី ១៨ ខែរ៉ម៉ាដ្ឌន អ៊ីម៉ាំអាុលី صلوات الله عليه والسلام ទទួលអារម្មណ៍ចម្លែក ។ ព្រះអង្គ صلوات الله عليه والسلام បានដឹងរឿងអាក្រក់ជាមុន ដែលនឹងកើតឡើងក្នុងពេលឆាប់ៗខាងមុខនេះ ។ ថ្ងៃសុក្រ យប់នោះ អ៊ីម៉ាំ صلوات الله عليه والسلام មិនផ្ទំទេ ព្រះអង្គ صلوات الله عليه والسلام សូត្រគួរអានអស់មួយយប់នោះ ហើយបានស្វ៉ឡាត្ទ ។ ពេលជិតថ្ងៃរះ ព្រះអង្គ صلوات الله عليه والسلام ប៉ងទៅឯម៉ាស់ឃ្ជិដ្ធ តែក្ងានបានស្រែកឡើង ។ ព្រឹត្តិការណ៍នេះឲ្យសញ្ញាអ៊ីម៉ាំ صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام បានថា៖ "ថាមពលនិងអំណាចទាំងអស់ជាកម្មសិទ្ធិរបស់អល់ឡោះហ្វ៍ عز وجل ។ ការយំយែកនឹងតាមពីក្រោយសម្រែកនេះ ។"[125]

បន្ទាប់ពីនោះ ព្រះអង្គ صلوات الله عليه والسلام សំដៅទៅឯទ្វារ តែពិបាកបើកទ្វារនោះ ។ នេះជាសញ្ញាមួយទៀត មានតែព្រះអង្គ صلوات الله عليه والسلام ទេដែលយល់ន័យ ។ ពេលព្រះអង្គ صلوات الله عليه والسلام ទៅដល់ម៉ាស់ឃ្ជិដ្ធ ព្រះអង្គ صلوات الله عليه والسلام ធ្លាប់តែដាស់មនុស្សម្នាឲ្យក្រោកស្វ៉ឡាត្ទ ។ បន្ទាប់មកព្រះអង្គ صلوات الله عليه والسلام ចាប់ផ្តើមស្វ៉ឡាត្ទ ។ ពេលព្រះអង្គ صلوات الله عليه والسلام អង្គុយក្រោយពីងើបពីស៊ូឃ្ជូដ្ធ[126]ទីមួយ បុរសអប្រិយ អ៊ីបនូ មុលយ៉្ជឹម ប្រហារព្រះអង្គ صلوات الله عليه والسلام នឹងដាវយ៉ាងដំណំ បណ្តាលឲ្យថ្ងាសអ៊ីម៉ាំ صلوات الله عليه والسلام រយៈផ្លែដាវប៉ះខួរក្បាល ។ ពេលអ៊ីម៉ាំ صلوات الله عليه والسلام ដឹងខ្លួនថាត្រូវគេវាយប្រហារ ព្រះអង្គ صلوات الله عليه والسلام បានបន្លឺសូរសព្ទថា៖

فُزْتُ وَرَبِّ ٱلْكَعْبَةِ.

*"សូមស្បថចំពោះព្រះម្ចាស់កាក់បាស្ទ ខ្ញុំជោគជ័យហើយ ។"*

---

[124] សូមមើលសៀវភៅ *អាល់-មុសតាដ្រ៉ក់* របស់លោក អាល់-ហ្វាគីម ក្បាលទី ៣ ទំព័រ ១៤៣ ។

[125] សូមមើលសៀវភៅរបស់លោក អាល់-ម៉ាស់អ៊ូឌី (المسعودي) *មូរួជ អាល់-ស្ហាហ្វាប់ (مُروجُ الذَّهَب)* ក្បាលទី ៣ ទំព័រ ២៩១ ។

[126] ស៊ូឃ្ជូដ្ធ គឺការក្រាបប្រណិប័តន៍វ៉ាឃ្ជិបក្នុងស្វ៉ឡាត្ទ ។

ប្រជារាស្ត្រលើកគ្នាមកពីគ្រប់ទិសទី មូលចិត្តថ្លើមគ្នាទូញសោកអាណិត អ៊ីម៉ាំ صلوات الله عليه والسلام ។ គេបានលើកព្រះអង្គ صلوات الله عليه والسلام ទៅឯដំណាក់ ហើយបានចាប់ខ្លួនឃាតករ ។ ព្រះអង្គ صلوات الله عليه والسلام បានប្រាប់ព្រះរាជបុត្រព្រះអង្គ صلوات الله عليه والسلام អ៊ីម៉ាំអាល់-ហ៊ាសាន់ صلوات الله عليه والسلام ថាកុំឲ្យធ្វើបាបឃាតករ ។ ពេលព្រះរាជបុត្រឆ្លល់ អ៊ីម៉ាំ صلوات الله عليه والسلام បានឆ្លើយថា៖ "បុត្រអើយ យើងជាព្រះរាជកុលដ្ឋាន عليهم السلام នៃមេត្តាធម៌និងខមាទោស ។ ចូរបុត្រផ្តត់ផ្គង់គេដោយចំណីដែលបុត្របរិភោគ ដោយទឹកដែលបុត្រផឹក ។ បើបិតាស្លាប់ បុត្រត្រូវធ្វើទោសគេតបតវិញ (ស្របតាមច្បាប់សងសឹករបស់អល់ឡោះហ៍ عز وجل) ដោយប្រហារជីវិតគេ ។ តែកុំធ្វើអ្វីចំពោះសាកសពគេ ព្រោះបិតាបានឮព្រះអយ្យកោរបស់បុត្រ ព្រះសាសនៈទូត صلى الله عليه وآله وسلم របស់អល់ឡោះហ៍ عز وجل មានព្រះវចនៈថា៖ "ចូរកុំធ្វើអ្វីទៅលើសាកសពឡើយ សូម្បីតែសាកសពឆ្កែខាំគេក៏ដោយ ។" បើបិតារស់ បិតាដឹងថាបិតានឹងធ្វើខ្លះលើបុគ្គលនេះ ។ ប្រសើរគឺបិតាគប្បីលើកទោសឲ្យគេ ពីព្រោះសីលធម៌របស់បិតាគឺលើកលែងទោស ។ យើង អាស្ហ៍លុល-បៃត៍ عليهم السلام បែរទៅរកបុគ្គលដែលប្រព្រឹត្តអាក្រក់ដាក់យើងដោយខមាទោសនិងដោយសប្បុរសធម៌ ។"

## ព្រះនាងស៊ៃណាប់ سلام الله عليها ជាមួយព្រះបិតា

ព្រះនាងស៊ៃណាប់ سلام الله عليها ស្ទុះទៅរកព្រះបិតាត្រូវរបួស ទាំងទឹកភ្នែកនិងខ្លោចចិត្ត ។ ព្រះនាងបានសួរព្រះអង្គ صلوات الله عليه والسلام ថាតើសម្តីព្រះសាស្តា صلى الله عليه وآله وسلم ដែលសច្ចការិនី អ៊ុម អៃម៉ាន បានថ្លែងពាក់ព័ន្ធនឹងគ្រោះកាចនិងវិបត្តិភ័យដែលអាស្ហ៍លុល-បៃត៍ عليهم السلام និងជួបប្រទះនៅក្នុងអនាគតនោះពិតឬទេ ។ អ៊ីម៉ាំ صلوات الله عليه والسلام មានវចនៈថា៖

الْحَدِيثُ كَمَا حَدَّثَتْكَ أُمُّ أَيْمَنَ وَ كَأَنِّي بِكِ وَ بِنِسَاءِ أَهْلِكِ سَبَايَا بِهٰذَا الْبَلَدِ أَذِلَّاءَ خَاشِعِيْنَ تَخَافُوْنَ أَنْ يُتَخَبَّطَكُمُ النَّاسُ فَصَبْرًاصَبْرًا فَوَ الَّذِي فَلَقَ الْحَبَّةَ وَ بَرَأَ النَّسَمَةَ مَا لِلَّهِ عَلَى ظَهْرِ الْأَرْضِ يَوْمَئِذٍ وَلِيٌّ غَيْرُكُمْ وَ غَيْرُ مُحِبِّيْكُمْ وَ شِيعَتِكُمْ وَ لَقَدْ قَالَ لَنَا رَسُوْلُ اللَّهِ (صلى الله عليه و آله و سلم) حِينَ أَخْبَرَنَا بِهٰذَا الْخَبَرِ:اِنَّ إِبْلِيْسَ لَعَنَهُ اللهُ فِيْ

ذٰلِكَ الْيَوْمِ – اَيْ يَوْمَ قُتِلَ الْحُسَيْنُ–يَطِيْرُفَرَحًا فَيَجُوْلُ الْأَرْضَ كُلَّهَا فِي بِشَيَاطِيْنِه وَ عَفَارِيْتِه فَيَقُولُ: يَا مَعَاشِرَ الشَّيَاطِيْنِ قَدْ أَدْرَكْنَا مِنْ ذُرِّيَّة آدَمَ الطَّلِبَة وَ بَلَغْنَا فِي هَلَاكِهِمُ الْغَايَة وَ أَوْرَثْنَاهُمُ النَّارُ. اَلَا مَنِ اعْتَصَمَ بِهٰذِهِ الْعِصَابَة فَاجْعَلُوْا شُغُلَكُمْ بِتَشْكِيْكِ النَّاسِ فِيهِمْ وَ حَمْلِهِمْ عَلٰى عَدَاوَتِهِمْ وَ إِغْرَائِهِمْ بِهِمْ وَ بِأَوْلِيَائِهِمْ حَتّٰى تَسْتَحْكِمَ ضَلَالَة الْخَلْقِ وَ كُفْرُهُمْ وَ لَايَنْجُوَ مِنْهُمْ نَاجٍ.

وَ لَقَدْ صَدَّقَ عَلَيْهِمْ إِبْلِيسُ وَ هُوَ كَذُوْبٌ اَنَّه لَا يَنْفَعُ مَعَ عَدَاوَتِكُمْ عَمَلٌ صَالِحٌ وَ لَا يَضُرُّ مَعَ مَحَبَّتِكُمْ وَ مُوَالَاتِكُمْ ذَنْبٌ غَيْرُ الْكَبَائِرِ.

*"អ៊ូម អៃម៉ាននិយាយពិត ។ បិតាឃើញបុត្រី ព្រមទាំងក្រុមគ្រួសារបុត្រី ជាចំណាប់ឈ្លើយក្នុងស្រុកនេះ ។ បុត្រីនឹងនៅក្រោមអំណាចគេ នឹងភ័យខ្លាច ខ្លាចមនុស្សនាំខ្លួនទៅទាំងបង្ខំ ។ ពេលនោះ ចូរបុត្រីអត់ធ្មត់ ខាំមាត់សង្កត់ចិត្ត ព្រោះថ្ងៃនោះនឹងពុំមានសាវក[របស់អល់ឡោះហ្ជ៍عزوجل]ទេ ក្រៅពីអ្នកបណ្ដាអ្នកតាមបុត្រីនិងបណ្ដាអ្នកគាំទ្របុត្រី ។ បិតាសូមស្បថចំពោះព្រះដែលបំបែកគ្រាប់ពូជ ដែលបង្កើតជីវិត ។ កាលព្រះអង្គصلى الله عليه وآله وسلمថ្លែងប្រាប់យើងជាមុននូវដំណឹងទាំងនេះ ព្រះសាសនៈទូតصلى الله عليه وآله وسلمរបស់អល់ឡោះហ្ជ៍عزوجلបានបន្ថែមថា៖ "ក្នុងថ្ងៃតែមួយនោះ អាល់-ហ៊្វសែន៍صلوات الله عليه والسلامនឹងត្រូវគេសម្លាប់ អ៊ីប្លីសلعن الله [127] មារត្រូវបណ្ដាសា នឹងសប្បាយចិត្ត នឹងដើរប្រកាសនៅលើផែនដីជាមួយបក្សពួកប្រេតព្រាយបិសាច និងយ៉ិនអ៊ុហ្វ៊រិត (عفريت)[128] របស់វាថា៖ "ហៃអស់ប្រេត ព្រាយបិសាចអើយ ថ្ងៃនេះយើងបានសងសឹកទៅកូនចៅអាដាំعليه السلام បានសម្រេចផែនការណ៍ធ្វើឲ្យពួកវាវិនាស បានច្រានពួកវាទម្លាក់ទៅក្នុងភ្លើងនរក ។ ពេលនេះ ពួកឯងទាំងអស់គ្នាត្រូវព្យាយាមចោលការសង្ស័យទៅក្នុងចិត្តមនុស្សរឿងអាល់-ហ៊្វសែន៍صلوات الله عليه والسلام និងបណ្ដាបក្សពួករបស់វា ត្រូវញុះញង់មនុស្សឲ្យប្រឆាំងពួកវា បញ្ចុះបញ្ចូលមនុស្សទាំងនេះ ឲ្យប្រឆាំងនឹងអ្នកណាដែលស្មោះត្រង់ចំពោះពួកវា (ពោលគឺ អាល់-ហ៊្វសែន៍صلوات الله عليه والسلامនិងបណ្ដាសាវកព្រះអង្គصلوات الله عليه والسلام) ដើម្បីនឹង*

[127] អ៊ីប្លីសជាឈ្មោះរបស់មារ ។

[128] អ៊ុហ្វ៊រិតគឺយ៉ិនបិសាចដែលខ្លាំង ។

*ធ្វើឲ្យមនុស្សវង្វេង និងមនុស្សឥតសាសនាទាំងនោះពុំត្រូវជួយសង្គ្រោះឲ្យរួចខ្លួនឡើយ [ក្នុងថ្ងៃរស់ពីស្លាប់វិញ] ។"*

ទោះបីវាﷻជាមុសាវាទីធំបំផុតក៏ដោយ អ៊ីប្លីសﷻនិយាយពិតចំពោះរឿងនេះ ។ ពិតណាស់ ទង្វើល្អរបស់បុគ្គលដែលប្រឆាំងអាស្ហ់លុល-បៃត៍عليهم السلام ត្រូវមោឃៈ (ទោះបីទង្វើល្អនោះធំប៉ុណ្ណាក៏ដោយ) រីឯបាប មិនមែនបាបធំរបស់អ្នកណាដែលស្រឡាញ់ និងស្មោះត្រង់ចំពោះអាស្ហ់លុល-បៃត៍عليهم السلام មិនមានផលអាក្រក់ទេ ។" [129]

## ដំបូន្មានចុងក្រោយរបស់អ៊ីម៉ាំصلوات الله عليه والسلام

ជិតចូលទិវង្គត អ៊ីម៉ាំអាលីصلوات الله عليه والسلامបានផ្ដែផ្ដាំព្រះរាជបុត្រនិងព្រះរាជបុត្រីទាំងអស់របស់ព្រះអង្គصلوات الله عليه والسلامឲ្យប្រកាន់យកសីលធម៌កំពូលឲ្យជាប់ ឲ្យចៀសវាងសេចក្ដីត្រេកត្រអាលមិនឋិតថេរក្នុងលោកនេះ ។

អ៊ីម៉ាំصلوات الله عليه والسلامបានប្រាប់ព្រះរាជបុត្រទាំងពីររបស់ព្រះអង្គصلوات الله عليه والسلام អ៊ីម៉ាំអាល់-ហាសាន់صلوات الله عليه والسلامនិងអ៊ីម៉ាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلام ថា៖ "បិតាសូមឲ្យដំបូន្មានបុត្រទាំងពីរថា ចូរខ្លាចអល់ឡោះហ្ទ៍عز وجل ចូរកុំប៉ងប្រាថ្នា[សេចក្ដីត្រេកត្រអាល]លោកនេះ ទោះបីវាប្រកិតតាមបុត្រទាំងពីរក៏ដោយ ។ ចូរកុំសោកស្ដាយសព្វសារពើនៃលោកនេះ ដែលគេមិនឲ្យមកបុត្រទាំងពីរនោះឡើយ ។ ចូរនិយាយពិត ចូរប្រព្រឹត្តដើម្បីរង្វាន់[មកពីអល់ឡោះហ្ទ៍عز وجل] ។ ចូរជាសត្រូវរបស់បុគ្គលសង្កត់សង្កិតគេ ចូរជួយទ្រទ្រង់បុគ្គលត្រូវគេសង្កត់សង្កិន ។ បិតាសូមឲ្យដំបូន្មានបុត្រទាំងពីរនិងបុត្រទាំងអស់ ព្រមទាំងសមាជិកគ្រួសារបិតានិងបណ្ដាអ្នកដែលសំណេររបស់បិតាបានទៅដល់ ថាចូរខ្លាចអល់ឡោះហ្ទ៍عز وجل ចូររៀបចំរឿងផ្ទាល់ខ្លួនឲ្យមានរបៀបរៀបរយ ចូររក្សាទំនាក់ទំនងល្អជាមួយគ្នាឯង ព្រោះបិតាបានឮព្រះអយ្យកោរបស់បុត្រទាំងពីរ (គឺសាស្ដាصلى الله عليه وآله وسلم) មានព្រះវចនៈថា៖ "ការដោះស្រាយបញ្ហាខ្វែងគំនិតគ្នាប្រសើរជាងស្ម័ឡាត់ជុំគ្នានិងសីលត្រណម ។" ចូរខ្លាចអល់ឡោះហ្ទ៍عز وجل ចូរ

---

[129] សូមមើលសៀវភៅ *កាមីល-អាល់-ស៊ីយ៉ារ៉ត (كامل الزيارات)* ទំព័រ ២៦៦ ។

គិតដល់អល់ឡោះហ្វ៍ﷻក្នុងរឿងកូនកំព្រា ។ ដូច្នេះ ចូរកុំបណ្ដោយឲ្យពួកគេអត់ឃ្លាន ពួកគេមិនត្រូវវិនាសនៅចំពោះមុខបុត្រទាំងពីរទេ ។ ចូរខ្លាចអល់ឡោះហ្វ៍ﷻ ចូរគិតដល់អល់ឡោះហ្វ៍ﷻក្នុងរឿងអ្នកជិតខាង ព្រោះព្រះសាស្ដាﷺបានឲ្យដំបូន្មានអំពីពួកគេ ។ ព្រះអង្គﷺបានឲ្យដំបូន្មានឲ្យយកចិត្តទុកដាក់នឹងអ្នកជិតខាងជាដរាប ទាល់តែយើងគិតថាព្រះអង្គﷺឲ្យពួកគេបាននូវមួយចំណែកក្នុងការចែកមរតក ។ ចូរខ្លាចអល់ឡោះហ្វ៍ﷻ ចូរគិតដល់អល់ឡោះហ្វ៍ﷻក្នុងរឿងគួរអាន ។ បុត្រត្រូវប្រសើរដាច់គេក្នុងការអនុវត្តិប្រការនេះ ។ ចូរខ្លាចអល់ឡោះហ្វ៍ﷻ ចូរគិតដល់អល់ឡោះហ្វ៍ﷻក្នុងរឿងស្វ័ឡាត្ញ ព្រោះវាជាសសរកន្លោងនៃសាសនារបស់បុត្រ ។ ចូរខ្លាចអល់ឡោះហ្វ៍ﷻ ចូរគិតដល់អល់ឡោះហ្វ៍ﷻក្នុងរឿងព្រះមហាគ្រឹះរបស់ព្រះម្ចាស់ﷻបុត្រ (គឺកាក់បាស្ញ) ។ ចូរកុំចោលព្រះមហាគ្រឹះដរាបណាបុត្រនៅមានជីវិត ពីព្រោះ បើបុត្រចោលព្រះមហាគ្រឹះ បុត្រនឹងមិនរួចខ្លួនទេ (ពុំនោះទេបុត្រនឹងលែងបាននូវព្រះមេត្តាធម៌នៃព្រះម្ចាស់បុត្រ) ។ ចូរខ្លាចអល់ឡោះហ្វ៍ﷻ ចូរគិតដល់អល់ឡោះហ្វ៍ﷻក្នុងរឿងឃ្ញីហ្វាដ្ញដោយទ្រព្យសម្បត្តិរបស់បុត្រ ដោយជីវិតនិងដោយអណ្ដាត នៅលើព្រះមាគ៌ាអល់ឡោះហ្វ៍ﷻ ។ បុត្រត្រូវរក្សាការគោរពសាច់ញាតិ ត្រូវបរិច្ចាគឲ្យអ្នកដទៃ ។ ចូរកុំគេចចេញពីគ្នា ចូរកុំផ្ដាច់ទំនាក់ទំនងគ្នា ។ ចូរកុំចោលការប្រកួតប្រជែងធ្វើល្អហាមធ្វើអាក្រក់ ដើម្បីនឹងកុំឲ្យជនកំណាចមានប្រៀបលើបុត្របាន ។ ពុំនោះទេ បើបុត្រស្វ័ឡាត្ញ គេនឹងមិនទទួលស្វ័ឡាត្ញនោះទេ ។"

បន្ទាប់មក អ៊ីម៉ាំصلوات الله عليه والسلامមានវចនៈថា៖ "កូនៗរបស់អាប់ដ្វាល់-មុត្តត៏លិបអើយ បិតាមិនចង់ឃើញបុត្រផុងខ្លួននៅក្នុងឈាមមុស្លីម យ៉ាងឃោរឃៅទេ ដោយស្រែកថា អាមីរុល-មុមីនីនត្រូវគេសម្លាប់ ។ ចូរប្រយ័ត ចូរកុំសម្លាប់ដោយសារបិតា លើកលែងតែឃាតកររបស់បិតា ។ [130] ចូររង់ចាំឲ្យបិតាស្លាប់ដោយសារការវាយប្រហាររបស់គេ (គឺអាប់ដ្វាល់-រ៉ោះហ្ម៉ាន អ៊ីបន្

[130] ស្ដីអំពីការប៉ះទង្គិចគ្នា ដែលអ៊ុស្វាស្ញនិងមូអាវីយ៉ាស្ញបានបង្កដោយសារឃាតកម្មអ៊ុស្វម៉ាន ។

មុលឃ្ជិម)។ បន្ទាប់មក ចូរវាយប្រហារគេមួយដងសងការវាយប្រហាររបស់គេ។ តែចូរកុំធ្វើអ្វីទៅលើសាកសពគេជាដាច់ខាត ព្រោះបិតាបានឮព្រះអយ្យកោបុត្រ ព្រះសាសនៈទូតصلى الله عليه وآله وسلمរបស់អល់ឡោះហ៍عز وجل សូមសិរីសួស្តីកើតមានដល់ព្រះអង្គនិងព្រះកុលដ្ឋានព្រះអង្គ មានព្រះវចនៈថា៖ "ចូរកុំធ្វើអ្វីទៅលើសាកសពឡើយ សូម្បីតែសាកសពឆ្កែខាំគេក៏ដោយ ។""[131]

ព្រះនាងស្ញែណាប់سلام الله عليها បានថ្លែងអំពីបណ្តាំចុងក្រោយរបស់អ៊ីម៉ាំអាលីصلوات الله عليه والسلام ។

បន្ទាប់ពីនោះ អ៊ីម៉ាំصلوات الله عليه والسلامបានចាប់ផ្តើមសូត្រអាយ៉ាត់ព្រះគម្ពីរគួរអាន បានឈឺខ្លាំងឡើង។ បន្ទាប់មក វិញ្ញាណព្រះអង្គصلوات الله عليه والسلامបានអណ្តែតឡើងទៅរកព្រះដែលជាមិត្តជំនិតកំពូល ទៅកាន់សុខុមាលភាពឥតអវសានជាមួយអស់ព្រះសាស្តាទាំងអស់ អស់សន្តបុគ្គលនិងអស់សច្ចការី។ ប្រសើរបំផុតដែលបាននៅជុំជាមួយអស់បុគ្គលបែបនេះ ។

អ៊ីម៉ាំអាល់-ហាសាន់صلوات الله عليه والسلامជ្រោមជ្រែងដោយព្រះអនុជទាំងឡាយរបស់ព្រះអង្គصلوات الله عليه والسلام ទទួលភារកិច្ចពិធីបុណ្យព្រះរាជសពព្រះបិតាព្រះអង្គصلوات الله عليه والسلام ។ នាប៉ែកចុងក្រោយនៃរាត្រីកាល ទាំងអស់គ្នាបានលើកព្រះរាជសពបរិសុទ្ធរបស់អ៊ីម៉ាំអាលីصلوات الله عليه والسلامទៅកាន់ព្រះរាជកំណាក់អវសាននៅឯ អាល់-ណាយ៉ាហ្វ ។ ព្រះនាងស្ញែណាប់سلام الله عليها ថ្វីបើហូរទឹកភ្នែកសស្រាក់ ក៏បានចូលរួមក្នុងពិធីបុណ្យព្រះរាជសពនោះដែរ ។

## រជ្ជកាលអ៊ីម៉ាំអាល់-ហាសាន់صلوات الله عليه والسلام

ថ្ងៃទីពីរ ជ្រោមជ្រែងដោយបងប្អូនប្រុសៗនិងយុវជនហាស្ញ៊ីម អ៊ីម៉ាំអាល់-ហាសាន់صلوات الله عليه والسلامបានទៅកាន់ម៉ាស់ឃ្ជិដគូហ្វាស់ បានធ្វើវិប្បយោគកថា (ការថ្លែងជាកិត្តិយសចំពោះព្រះរាជសពអ៊ីម៉ាំអាលីصلوات الله عليه والسلام) ដោយប្រើសម្តីប្រកបដោយវោហារកោសល្យដូចព្រះបិតាព្រះអង្គصلوات الله عليه والسلامដែរ ។ ព្រះអង្គصلوات الله عليه والسلامបាន

[131] សូមមើលសៀវភៅ *ណាស់យ៉ាល់-បាឡាកោះត៍* ក្បាលទី ៣ ទំព័រ ៨៥ ។

បង្ហាញឲ្យឃើញថាព្រះបិតា ព្រះអង្គصلوات الله عليه والسلامប្រកបដោយបុគ្គលិកលក្ខណៈឯក មិនដែលមានអ្នកណាមួយក្នុងជំនាន់មុននិងក្នុងជំនាន់ក្រោយប្រៀបបានឡើយ ។

ក្នុងវិស័យយុត្តិធម៌ អ៊ីម៉ាំអាល់-ហ៊្សាសាន់صلوات الله عليه والسلامបានថ្លែងអំពីព្រះបិតាព្រះអង្គصلوات الله عليه والسلامដូចតទៅ គឺ៖ "ព្រះអង្គصلوات الله عليه والسلام (គឺអ៊ីម៉ាំអាលីصلوات الله عليه والسلام) មិនដែលមានសល់កាក់លឿង (គឺកាក់មាស) កាក់ស (គឺកាក់ប្រាក់) ឡើយ លើកលែងតែប្រាំពីររយដៀរហ្វាំ ដែលព្រះអង្គصلوات الله عليه والسلامប៉ងចង់បានអ្នកបម្រើស្រីម្នាក់សម្រាប់គ្រួសារព្រះអង្គصلوات الله عليه والسلام ។ តែព្រះអង្គصلوات الله عليه والسلامបានដាក់បញ្ជាឲ្យខ្ញុំប្រគល់ប្រាក់នេះឲ្យទៅក្នុងសម្បត្តិសាធារណៈវិញ ។"

ពេលអ៊ីម៉ាំអាល់-ហ៊្សាសាន់صلوات الله عليه والسلامនិយាយចប់ មហាជនបាននាំគ្នាទៅសូមចុះចូលស្មោះស្ម័គ្រចំពោះព្រះអង្គصلوات الله عليه والسلام ថ្វីបើភាគច្រើនមិនស្មោះត្រង់ ។

ទោះជាយ៉ាងណាក៏ដោយ មូអាវីយ៉ាស្ទ័ដឹងច្បាស់ថាកងទ័ពរបស់អ៊ីម៉ាំអាល់-ហ៊្សាសាន់صلوات الله عليه والسلامខ្សោយ បាត់បង់កម្លាំងចិត្ត ចាំតែបះបោរ ក៏បានបបួលព្រះអង្គصلوات الله عليه والسلامប្រយុទ្ធ ។ មូអាវីយ៉ាស្ទ័ដឹកនាំកងទ័ពដែលសម្បូរដោយបុគ្គលប្រឆាំងអ៊ីម៉ាំصلوات الله عليه والسلام ។ រេហ៍ពលរបស់មូអាវីយ៉ាស្ទ័ស្តាប់បង្គាប់និងចុះចូលខ្លួនទាំងស្រុង ។ ពួកគេបានបោះជំរំនៅឯអាល់-ម៉ាដ្ហាអ៊ីន ។

លុះបានឮដំណឹងនេះ ចិត្តយោធិនរបស់អ៊ីម៉ាំអាល់-ហ៊្សាសាន់صلوات الله عليه والسلامភ័យតក្កមា ស្លន់ស្លោ ។ ដោយហេតុនេះ ពួកគេមិនព្រមស្តាប់ការប្រកាសចម្បាំងរបស់អ៊ីម៉ាំصلوات الله عليه والسلامតទល់នឹងមូអាវីយ៉ាស្ទ័صلوات الله عليه والسلامទេ ។ អ៊ីម៉ាំصلوات الله عليه والسلامនៅតែប្រកាសហៅជាដរាប ព្រះអង្គصلوات الله عليه والسلامព្យាយាមណែនាំប្រជារាស្ត្រឲ្យទៅច្បាំង ។ ទីបំផុត មានមនុស្សចម្រុះដែលមានិន្នាការនិងគំនិតផ្សេងៗគ្នាបានឆ្លើយតបព្រះអង្គصلوات الله عليه والسلام ហើយបានទៅបោះជំរំនៅឯអាល់-ម៉ាដ្ហាអ៊ីន ។

មេបញ្ជាការកងទ័ពអ៊ីម៉ាំصلوات الله عليه والسلام ពោលគឺ អ៊ូបៃឌុលឡោះហ្ប៍ អ៊ីបនូ អាប់បាស់បានទៅចូលបក្សមូអាវីយ៉ាស្ទ័ក្រោយពីបានទទួលសំណូកទាក់ទាញចិត្ត ។ ដូច្នេះភាពឥតរបៀប និងចលាចលបានកើតមាននៅក្នុងកងទ័ពអ៊ីម៉ាំصلوات الله عليه والسلام បុគ្គលល្បីៗច្រើននាក់ ព្រមទាំងយោធិនប្រាំបីពាន់នាក់និងកុលសម្ព័ន្ធ

រ៉ប៊ីអ្អស៊្ហបានចូលខាងមូអ្អាវីយ៉ាស៊្ហ ។[132]

បញ្ហាបានឈានដល់កម្រិតកំពូល ពេលបុគ្គលមួយក្រុមបានមកប្លន់របស់របរសម្ភារអ៊ីម៉ាំអាល់-ហ្ហាសាន់ صلوات الله عليه والسلام ។ គេបានសូកមនុស្សឲ្យសម្លាប់ព្រះអង្គ صلوات الله عليه والسلام លើសពីមួយដង ។ ទីបំផុត បក្សមួយនៅក្នុងកងទ័ពព្រះអង្គ صلوات الله عليه والسلام ទំនងជាពួកខ៏រីយ្ជី បានចោទព្រះអង្គ صلوات الله عليه والسلام ថាកាហ្វៀរ ។

ដើម្បីទប់ទល់នឹងស្ថានការណ៍នេះ អ៊ីម៉ាំអាល់-ហ្ហាសាន់ صلوات الله عليه والسلام ចាំបាច់ត្រូវចរចាសន្តិសុខជាមួយមូអ្អាវីយ៉ាស៊្ហ ទាំងបង្ខំចិត្ត ដើម្បីនឹងកុំឲ្យបក្សព្រះអង្គ صلوات الله عليه والسلام វិនាស ។[133]

បន្ទាប់ពីបានធ្វើកិច្ចព្រមព្រៀងផ្អាកសង្គ្រាម អ៊ីម៉ាំអាល់-ហ្ហាសាន់ صلوات الله عليه والسلام បានចាកចេញពីគូហ្វាស៊្ហ ស្រុកដែលប្រជារាស្ត្រធ្វើឲ្យព្រះបិតាព្រះអង្គ صلوات الله عليه والسلام និងព្រះអង្គ صلوات الله عليه والسلام ស្រងាកចិត្ត ។ ព្រះអង្គ صلوات الله عليه والسلام បានចាកចេញទៅកាន់ម៉ាឌីណាស៊្ហ ។ ទីនោះ ប្រជារាស្ត្រទទួលព្រះអង្គ صلوات الله عليه والسلام យ៉ាងឱឡារិក ព្រោះព្រះអង្គ صلوات الله عليه والسلام ជាមែកធាងដែលជាប់ឫសគល់បរិសុទ្ធឥតខ្ចោះ គឺព្រះសាស្តា صلى الله عليه وآله وسلم ។

ព្រោះតែរដ្ឋបាលត្រឹមត្រូវបានអន់ថយ បុគ្គលអាក្រក់ឡើងកាន់អំណាច ទើបជីវិតព្រះនាងស្ស៊ៃណាប់ سلام الله عليها ឈានដល់ដំណាក់កាលថ្មី ដែលនាំមកនូវគ្រោះកាចអប្រិយថ្មីដែរ ។

## រជ្ជកាលមូអ្អាវីយ៉ាស៊្ហ

ពេលមូអ្អាវីយ៉ាស៊្ហឡើងកាន់អំណាច អំណាចដឹកនាំកាន់លទ្ធិបូជារូបបដិមាសម័យមុនអ៊ីស្លាម បានផ្លាស់អំណាចដឹកនាំប្រជាធិបតេយ្យអ៊ីស្លាម ។ អបាយមុខអសីលធម៌និងការប្រព្រឹត្តបំពារបំពានរបៀបរបប

---

[132] សូមមើលសៀវភៅ *អាន់សាប់ អាល់-អាស្ស៊រ៉ហ្វ (أنساب الأشراف)*, ក្បាលទី ១ ទំព័រ ២២៣ ។

[133] សូមមើលសៀវភៅរបស់លោក ស្ហៃខ៏ មូរតាឌ្ហ៏ អាល់-យ៉ាស៊ីន *ស្ហ៊ុលហ្ហ៍ អាល់-ហ្ហាសាន់*, សៀវភៅរបស់លោក បាគ្ហៀរ ស្ហារីហ្វ អាល់-គ្ហ៏រ៉ស្ហ៊ី (شريف القرشي) *ហ្ហាយ៉ាស៊្ហ អាល់-អ៊ីម៉ាំ អាល់-ហ្ហាសាន់ (حياة الامام الحسن)* ។

វាតសុសសាយពេញសហាគមន៍អ៊ីស្លាម ដោយការបើកដៃឲ្យពីបុគ្គលត្រកូលអ៊ូម៉ៃយ៉ាស់ទាំង[134]នេះ ។

មូអាវីយ៉ាស់បានទទួលមរតកហិង្សាស្រោចមកលើព្រះសាស្ដាﷺ តមកពីឪពុកដែលជាសត្រូវស្លាប់រស់របស់អ៊ីស្លាម និងតមកពីម្ដាយឈ្មោះហ៊ិនដ៍ដែលបានស៊ីថ្លើមហាំស្សាស់នៅឯសមរភូមិអ៊ូហ៊្វូដ្ធ ព្រោះតែស្អប់អ៊ីស្លាម ។ តែកូនអាក្រក់លើសឪពុកម្ដាយទៅទៀត គាត់មិនអាចបិទបាំងអារម្មណ៍បានទេ ជាពិសេស ព្រោះតែការប្រកាសព្រះនាមរបស់ព្រះសាស្ដាﷺក្នុងពេលសូត្រអាស្សាននោះ - ការប្រកាសស្ញូឡាត់ប្រាំដងក្នុងមួយថ្ងៃ - ធ្វើឲ្យគាត់ធុញទ្រាន់ណាស់ ។[135]

ដូច្នេះឯងបានជាគាត់ស្អប់ព្រះរាជកុលដ្ឋានعليهم السلام និងព្រះរាជបុត្ររាជនត្តាعليهم السلامរបស់ព្រះសាស្ដាﷺជាទីបំផុត ។ ដូច្នេះគាត់បានសម្រេចចិត្តបំបិទយ៉ាងអប្រិយ មិនឲ្យគេស្គាល់គុណសម្បត្តិនិងបុណ្យបារីរបស់បុគ្គលថ្លៃថ្លារុងរឿងទាំងនេះឡើយ ។

លោក មូហ៊ាំម៉ាដ្ធ អ៊ីបនូ អ៊ីដ្ធរីស អាល់-ស្ហាហ្វីអ៊ី (محمد ابن إدريس الشافعيّ) អ្នកបង្កើតក្រុមអ៊ីស្លាមស្ហាហ្វីអ៊ី បានឆ្លើយតបបណ្ដាអ្នកដែលបានសូមសួរយោបល់លោកអំពីអ៊ីម៉ាំអាលី អាមីរុល-មុមីនីនصلوات الله عليه والسلام ថា៖ "តើយើងអាចថាអ្វីបានខ្លះអំពីបុគ្គលម្នាក់ ដែលបក្សពួករបស់បុគ្គលនោះចាំបាច់ត្រូវតែលាក់គុណសម្បត្តិរបស់បុគ្គលនោះព្រោះតែខ្លាចគេ ដែលពួកសត្រូវរបស់បុគ្គលនោះលាក់បាំងគុណសម្បត្តិរបស់បុគ្គលនោះ ព្រោះតែច្រណែនឈ្នានីស ? តែរវាងមនុស្សទាំងពីរក្រុមនេះ គុណសម្បត្តិរបស់បុគ្គលនោះដែលគេដឹងស្គាល់ទូទៅហើយនោះមានច្រើនណាស់ រាប់មិន

---

[134] សូមមើលសៀវភៅរបស់ សៃយីដ្ធ អាមៀរ អាលី *រុះហ៊ អាល់-អ៊ីស្លាម* ទំព័រ ២៩៦ ។

[135] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហាឌីដ្ធ *ស្ហារហ៊ ណាស្ហ៊យ៉ាល់-បាឡាក្ហោះត៍* ក្បាលទី ២ ទំព័រ ២២៩៧ និង ក្បាលទី ១០ ទំព័រ ១០១ ។

អស់ទេ ។"[136]

ក្នុងរជ្ជកាលមូអាវីយ៉ាស្ញ បក្សពួករបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام និងអាស្ហ៍លុល-បៃត៍ صلوات الله عليه والسلام រងការសង្កត់សង្កិនគ្រប់យ៉ាង ។ ឧទាហរណ៍ បុគ្គលឧក្រិដ្ឋ ប៊ិសរ៍ អ៊ីបនូ អារត៍អាស្ញ បានសម្លាប់និងបានដុតមនុស្សលើសពីសាមសិបពាន់នាក់; សាម៉ារ៉ោះត៍ អ៊ីបនូ យ៉ុនដាប់ បានសម្លាប់មនុស្សប្រាំបីពាន់នាក់នៅឯបាស្ញរ៉ោះត៍; ស៊ីយ៉ាដ្ញ អ៊ីបនូ អាប៊ិះហ៍ (زياد بن أبيه) ឧក្រិដ្ឋដាច់គេ បានកាត់អវយវៈបក្សពួករបស់អ៊ីម៉ាំ صلوات الله عليه والسلام ។

សូម្បីតែបណ្ដាស្ត្រីដែលស្មោះត្រង់ចំពោះអ៊ីម៉ាំអាលី صلوات الله عليه والسلام និងអាស្ហ៍លុល-បៃត៍ عليهم السلام ឲ្យគេដឹង ក៏ចៀសមិនផុតពីអំពើអមនុស្សធម៌របស់អាជ្ញាធររបស់មូអាវីយ៉ាស្ញដែរ ។ លើសពីនេះទៀត មូអាវីយ៉ាស្ញបានដាក់បញ្ជាឲ្យកម្ទេចផ្ទះសំបែងរបស់បក្សពួកអ៊ីម៉ាំ صلوات الله عليه والسلام ទុកឲ្យពួកគេនៅជាមនុស្សគ្មានជម្រក ។ មូអាវីយ៉ាស្ញហាមពួកគេទទួលចំណែកពីប្រាក់សាធារណៈ[137]ផងដែរ មិនទទួលពួកគេជាសាក្សីនៅក្នុងការកាត់ក្ដីទេ ។ ទីបំផុត មូអាវីយ៉ាស្ញបានបណ្ដេញពួកគេជាងហាសិបពាន់នាក់ចេញពីតំបន់ឃូរ៉សាន ប៉ែកខាងជើងឆៀងកើតនៃប្រទេសពែរ្ស (Persia) ។

សូមបញ្ជាក់ថា ជនដែលត្រូវបណ្ដេញចេញពីស្រុកទេសទាំងនេះបានផ្សព្វផ្សាយឃោសនាលទ្ធិស៊ីអាស្ញនៅក្នុងអាណាខេត្តនោះ ក្រោយមកប្រជារាស្ត្រតំបន់នោះ បានក្លាយទៅជាបក្សរណសិរ្សដ៏ខ្លាំងមួយប្រឆាំងទល់នឹងអំណាចអ៊ូម៉ៃយ៉ាស្ញ ទាល់តែអាចរំលំរដ្ឋអំណាចសង្កត់សង្កិនបាន ក្រោមការដឹកនាំរបស់អាប៊ូ មុស្លីម អាល់-ឃូរ៉សានី ។

## ឃាតកម្មអ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام

ទោះជាយ៉ាងណាក៏ដោយ បទឧក្រិដ្ឋធ្ងន់បំផុតរបស់មូអាវីយ៉ាស្ញគឺការធ្វើ

---

[136] សូមមើលសៀវភៅរបស់លោក អាល់-មូហាដ្ញឌីស្ញ អាល់-គូមី (المحدث القمي) *អាល់-អាន់វ៉ារ៍ អាល់-បាហ៊ីយ៉ាស្ញ (الأنوار البهية)* ។

[137] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហាឌីដ្ញ *ស្ញារហ៍ណាស្ញយ៉ាល់-បាឡាកោះត៍* ក្បាលទី ១១ ទំព័រ ៤៤ ។

គុតអ៊ីម៉ាំអាល់-ហ្វាសាន់صلوات الله عليه والسلام ក្រោយពីបានសន្យានៅក្នុងកិច្ចព្រមព្រៀងឈប់ច្បាំងជាមួយអ៊ីម៉ាំصلوات الله عليه والسلامដ៏ល្បីមួយ ថានឹងប្រគល់តំណែងដឹកនាំឲ្យអ៊ីម៉ាំصلوات الله عليه والسلام ។ ដូច្នេះ មូអាវីយ៉ាស់អាចបង្កើតរដ្ឋរាជអ៊ូម៉ៃយ៉ាស់និយមបាន ។

មូអាវីយ៉ាស់បានមើលក្នុងបញ្ជីឈ្មោះជនឧក្រិដ្ឋ មិនឃើញមានអ្នកណាមួយអាចបំពេញបេសកកម្មនេះបានសម្រេចទេ គាត់មិនឃើញមានអ្នកណាមានសមត្ថភាពជាង យ៉ាក់ដាស់ ប៊ិនទី អាល់-អាស្អាស់ (جعدة بنت الأشعث) ទេ ទោះបីនាងជាមហេសីរបស់អ៊ីម៉ាំصلوات الله عليه والسلامក៏ដោយ ។ នារីរូបនេះត្រូវបានទទួលការចិញ្ចឹមបីបាច់ នៅក្នុងការក្បត់និងការមិនស្មោះត្រង់ ។

មូអាវីយ៉ាស់បានផ្ញើថ្នាំបំពុលកំណាចទៅម៉ារវ៉ាន អ៊ីបនូ អាល់-ហ្វាកាំ ឲ្យគាត់ទាក់ទាញយ៉ាក់ដាស់ឲ្យដាក់ថ្នាំបំពុលស្វាមីខ្លួន ដោយសន្យាថានឹងរៀបការនាងជាមួយយ៉ាស៊ីដ កូនរបស់មូអាវីយ៉ាស់ ។

យ៉ាក់ដាស់ ព្រោះតែមានចរិតលំអៀង មិនរួញរាទេ ទើបបំពុលក្រយាអ៊ីម៉ាំصلوات الله عليه والسلام ។

អ៊ីម៉ាំصلوات الله عليه والسلامបានចាប់ផ្តើមឈឺចាប់ដោយសារថ្នាំបំពុល ព្រះអង្គصلوات الله عليه والسلامទ្រង់អាចៀន (គឺក្អួត) ឈាមនៅក្នុងអាងបោកសំលៀកបំពាក់ ។ ពេលព្រះនាងស៊ែណាប់سلام الله عليهاទៅលេងព្រះអង្គصلوات الله عليه والسلامៗឲ្យលើកអាងនោះចេញ កុំឲ្យព្រះនាងឃើញទិដ្ឋភាពដ៏ឈឺចាប់នេះ ។ តែព្រះនាងកើតទុក្ខខ្លាំងព្រោះដឹងថាព្រះរៀមព្រះនាងនឹងចាកចោលព្រះនាងក្នុងពេលឆាប់ៗនេះ ។

អ៊ីម៉ាំصلوات الله عليه والسلامបានផ្តែផ្តាំបងប្អូននិងបណ្តាសាវកឲ្យកាន់ឥរិយាបថថ្លៃថ្នូរ ឲ្យធ្វើល្អ ឲ្យខ្លាចអល់ឡោះហ្ទ៍عز وجل ។ ខណៈដែលព្រះអង្គصلوات الله عليه والسلامកំពុងសូត្រគួរអានវិញ្ញាណព្រះអង្គصلوات الله عليه والسلامចាកទៅកាន់សុគតិភព ទៅកាន់ឋានឥតអវសាន ។

អ៊ីម៉ាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلامទទួលភារកិច្ចធ្វើបុណ្យព្រះរាជសព ព្រះរៀមព្រះអង្គصلوات الله عليه والسلام ប៉ងនឹងបញ្ចុះព្រះរាជសពក្បែរព្រះអយ្យកោព្រះអង្គصلوات الله عليه والسلام ព្រះសាស្តាមូហាំម៉ាដ់صلى الله عليه وآله وسلم ។ តែអ៊ែស្ហាស់ នៅក្រោមការបញ្ចេះរបស់បុគ្គលត្រកូលអ៊ូម៉ៃយ៉ាស់ បានជិះសេះទេស ស្រែកថា៖ "កុំនាំអ្នកណាដែលខ្ញុំមិនចូលចិត្តមកផ្ទះខ្ញុំ" ហើយបានបង្ករឿងជម្លោះធំមួយដែលនឹងបង្ហូរឈាម

មុស្លីមដ៏ច្រើន ។ ដើម្បីចៀសវាងរឿងនេះ អ៊ីម៉ាំអាល់-ហ៊្វសែន៍ صلوات الله عليه والسلام បានផ្លាស់ប្តូរចិត្ត បានបញ្ចុះព្រះរាជសពព្រះរៀមព្រះអង្គ صلوات الله عليه والسلام នៅកន្លែងផ្សេង ។

## ការតែងតាំងយ៉ាស៊ីដ្ឋជាស្តេចខ៊ីលិហ្វថ្មី

មូអាវីយ៉ាស់បានបញ្ចប់រជ្ជកាលរបស់ខ្លួនដោយលើកយ៉ាស៊ីដ្ឋ កូនប្រុសរបស់ខ្លួនជាស្តេចសោយរាជ្យបន្តជាបង្ខំ ។ ដូចឪពុកនិងតាខ្លួនដែរ គេដឹងថាយ៉ាស៊ីដ្ឋជាបុគ្គលមានពុតត្បុត ជាបុគ្គលកំហូចបោកប្រាស់ និងជាសត្រូវរបស់អ៊ីស្លាម ។ ជាសាធារណៈ គាត់បានមើលស្រាលតម្លៃមនុស្សនិងសីលធម៌ ។ គាត់តែងតែផឹកសុរាយ៉ាម៉ៅពេញមួយជីវិតគាត់ អ្នកប្រវត្តិសាស្ត្រខ្លះបានឲ្យដឹងថា គាត់ស្លាប់ដោយសារពេគញៀនសុរាយ៉ាម៉ៅ ។ គាត់ស្រឡាញ់សត្វចិញ្ចឹម ជាពិសេសសត្វស្វា ។
និយាយសង្ខេប យ៉ាស៊ីដ្ឋជាតួតំណាងអបាយមុខនិងទោសកម្មគ្រប់ប្រភេទ ដែលមិនសក្តិសមនឹងអ៊ីស្លាម ឬមុខតំណែងដឹកនាំអ៊ុមម៉ាត់អ៊ីស្លាមឡើយ ។

## រជ្ជកាលខ្មៅងងឹត

បន្ទាប់ពីមូអាវីយ៉ាស់ធ្លាក់ទៅក្នុងអបាយ អំពើសាហាវយង់ឃ្នងនិងភាវរកម្មស្រោចមកលើអ៊ុមម៉ាត់អ៊ីស្លាម លែងគោរពទំនៀមទម្លាប់ ឬច្បាប់ឬលែងគោរពមនុស្សធម៌ ។ ការពិត មូអាវីយ៉ាស់យកការសង្កត់សង្កិននិងលទ្ធិផ្តាច់ការជាគោលការណ៍ ។
នេះគឺពិពណ៌នារៀបរាប់អំពីរជ្ជកាលរបស់ យ៉ាស៊ីដ្ឋ អ៊ីបនូ មូអាវីយ៉ាស់ដែលគាបសង្កត់មុស្លីមឥតប្រណី ។
នៅក្នុងរជ្ជកាលនេះ ព្រះនាងស្សៃណាប់ سلام الله عليها បានរងទុក្ខវេទនានិងការលំបាកធំបំផុត ព្រះរាជវង្សព្រះសាស្តា صلى الله عليه وآله وسلم រងការប្រល័យបំបាត់ពូជ ។ ត្រូវគេសម្លាប់ ត្រូវពួកយោធិនអ្វម៉ៃយ៉ាស់កាត់អាវយវៈ បំផ្លិចបំផ្លាញសាកសពយ៉ាងអមនុស្សធម៌ ។ ព្រះនាងស្សៃណាប់ سلام الله عليها បានឃើញទិដ្ឋភាពរន្ធត់ទាំង

នេះផ្ទាល់ភ្នែក បានជារងទុក្ខសោករលេះរលួយចិត្ត មិនអាចទប់ទឹកភ្នែកបាន ដោយសេចក្តីអាណិតអាសូរ ។ មិនត្រឹមតែប៉ុណ្ណោះទេ ព្រះនាងនិងក្រុមព្រះរាជវង្សព្រះសាស្តាﷺត្រូវចាប់ខ្លួនជាឈ្លើយ បណ្តើរអាក្រោសតាមបណ្តាខេត្តនានានៃរដ្ឋអ៊ូម៉ៃយ៉ាស់ ។ ត្រូវគេនាំខ្លួនទៅបង្ហាញអ៊ូបៃឌុលឡោះហ៍ អ៊ីបនូ ស៊ីយ៉ាដ់ កូនរបស់ម៉ារយ៉ាណាស់នារីអាស្រូវ បន្ទាប់មកត្រូវនាំទៅបង្ហាញយ៉ាស៊ីដ ចៅរបស់ហ៊ីនដ៍នារីអាស្រូវ ។[138]

[138] ហ៊ីនដ៍ កូនស្រីរបស់ អ៊ុតបាស់ ភរិយារបស់ អាប៊ូ ស៊ុហ្វយ៉ាន ជាសត្រូវស្លាប់រស់របស់អ៊ីស្លាមជាទូទៅ ជាពិសេសរបស់ពួកហ្វាស៊ីម ។ គាត់នេះឯងដែលព្យាយាមស៊ីថ្លើម អាល់-ហាំស្សាស់ អ៊ីបនូ អាប់ដុាល់-មុត្តលិបបន្ទាប់ពីលោកបានទទួលមរណៈភាពនៅឯសមរភូមិអ៊ូហ៊ូដ ។ និយាយអំពីរឿងអាស្រូវរបស់ហ៊ីនដ៍ សូមជ្រាបសេចក្តីរាយការណ៍ដូចតទៅ ។ បន្ទាប់ពីវាយយកម៉ាក់កាស់បាន ហ៊ីនដ៍និងក្រុមគ្រួសារចាំបាច់ត្រូវតែអះអាងថាខ្លួនជាមុស្លីម ដើម្បីចៀសពីការស្លាប់ ។ គាត់បានមកជួបព្រះសាស្តាﷺ ដើម្បីប្តេជ្ញាថាគាត់សូមប្តូរមកកាន់សាសនាអ៊ីស្លាម ។ ស្តាប់ព្រះបញ្ញាអល់ឡោះហ៍عزّ وجلّ ព្រះសាស្តាﷺក៏បានស្តាប់ហ៊ីនដ៍ស្បថស្បែជាសាធារណៈនៅចំពោះមុខមុស្លីមដែលបានដឹងឮ ។ ព្រះសាស្តាﷺបានប្រាប់ឲ្យគាត់ដឹងគោលកាណ៍អ៊ីស្លាមច្រើនប្រការ ឲ្យគាត់ព្រមទទួល ពុំនោះទេគេមិនទទួលការចុះចូលជាមុស្លីមរបស់គាត់ទេ ។ គោលការណ៍មួយ ក្នុងចំណោមគោលការណ៍ទាំងនោះ គឺព្រះសាស្តាﷺបានឲ្យគាត់ស្បថថាគាត់នឹងមិនប្រព្រឹត្តអំពើពេស្យាចារទេ ។ គាត់បានឆ្លើយតបថា៖ "តើស្ត្រីដែលមានកិត្តិស័ព្ទអាចប្រព្រឹត្តអំពើនេះដូចម្តេចទៅ ?" លុះបានឮចម្លើយភ្លាម អ៊ូម៉ារ អ៊ីបនូ អាល់-ខត្តតប់បានសើចចុកពោះ ។ នេះព្រោះតែគាត់ស្គាល់ហ៊ីនដ៍ច្បាស់ ។ ព្រឹត្តិការណ៍នេះត្រូវបានកត់ត្រាទុក ក្នុងសៀវភៅប្រវត្តិសាស្ត្រអ៊ីស្លាមយោងស្ទើរទាំងអស់ ។ ឧទាហរណ៍ សូមមើលសៀវភៅរបស់លោក អ៊ីបនូ គូស្សៃរ៍ *អាល់-ប៊ីដាយ៉ាស់ វ៉ា អាល់-នីហ្វាយ៉ាស់ (البداية والنهاية)* ក្បាលទី ៤ ទំព័រ ៣៦៥; សៀវភៅរបស់លោក អ៊ីបនូ គូស្សៃរ៍ *អាល់-ស៊ីរ៉េះត៍ អាល់-ណាបាវីយ៉ាស់ (السيرة النبوية)* ក្បាលទី ៣ ទំព័រ ៦០៣; សៀវភៅរបស់លោក អាល់-តបារី (محمد بن جرير طبري) *តារិក អាល់-អ៊ូម៉ាំ វ៉ា អាល់-មុលុក (تاريخ الأمم والملوك)* ក្បាលទី ២ ទំព័រ ៣៣៨; សៀវភៅរបស់លោក អាល់-គួរតុប៊ី (القرطبي) អាល់-តាហ្វសៀរ ក្បាលទី ១៨ ទំព័រ ៧២; សៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហាឌីដ *ស្សារហ៍ ណាស់យ៉ាល់-*

ទោះជាយ៉ាងណាក៏ដោយ ព្រះនាងស្ហ៊ៃណាប់ عليها سلام បានរងអំពើអាក្រក់បំផុតនៅក្នុងរជ្ជកាលដ៏ខ្មៅងងឹតរបស់យ៉ាស៊ីដ្ធ បុគ្គលកំណាច បាបចិត្ត គ្មានបទពិសោធន៍ ឆ្កួតនឹងកាម មិនចេះដឹងអំពីមុខតំណែងដឹកនាំ អំពីនយោបាយ ឬការគ្រប់គ្រង ។ បុគ្គលរូបនេះមិនទាំងអាចគ្រប់គ្រងខ្លួនឯងបានផងតាមតែក្បាលចិត្តឯង ឈ្លក់តែនឹងការបង្ហូរឈាម ។

ពេលឪពុកអប្រិយរបស់បុគ្គលរូបនេះស្លាប់នៅឯដាម៉ាស់ យ៉ាស៊ីដ្ធកំពុងតែធ្វើដំណើរ[139] ។ ពេលគាត់បានទទួលដំណឹងឪពុកគាត់ចែកឋាន ហើយគាត់ទៅជាស្តេចខ៉លិហ្វរបស់អ៊ុមម៉ាត្ទ់អ៊ីស្លាមនោះ គាត់ប្រញាប់មកកាន់រាជធានីជាមួយកងទ័ពថោកទាបរបស់គាត់ ។ ចាប់តាំងពីពេលនោះមកប្រជារាស្ត្រចាប់ផ្តើមរិះគន់គាត់ ដោយសារតែគាត់មិនមានស្មារតីទទួលខុសត្រូវ[140] ។

ប្រការដំបូងបង្អស់ដែលគាត់ធ្វើនៅឯដាម៉ាស់ គឺគាត់ប្រកាសប្តេជ្ញាចិត្តធ្វើសង្គ្រាមកម្ទេចប្រជារាស្ត្រប្រទេសអ៊ីរ៉ាក្ទ់ ។ ប្រជារាស្ត្រស៊ីរីបានស្វាគមន៍ការប្តេជ្ញាចិត្តនេះ ហើយបានប្រកាសថាពួកគេត្រៀមខ្លួនចូលរួមក្នុងសង្គ្រាមនេះ[141] ។

បក្សប្រឆាំងគ្រោះថ្នាក់បំផុតរបស់យ៉ាស៊ីដ្ធនៅឯម៉ាឌីណាស្ទ់ គឺអ៊ីម៉ាំអាល់-ហ៊្សៃន៍ صلوات الله عليه والسلام និង អាប់ឌុលឡោះហ៍ អ៊ីបនូ អាល់-ស៊្សបៃរ៍ ។ គាត់បានសម្រេចចិត្តដាច់អហង្ការឲ្យ អាល់-វ៉ាលីដ្ធ អភិបាលស្រុកម៉ាឌីណាស្ទ់ បង្ខំ

---

*បាឡាក្ទុរះត្ទ៍* ក្បាលទី ១៨ ទំព័រ ១៧; សៀវភៅរបស់លោក ស្ហៃខ៍ អាល់-អាមីនី (الأميني) *អាល់-ក៏ដៀរ* ក្បាលទី ១០ ទំព័រ ១៧០ ។

[139] សូមមើលសៀវភៅរបស់លោក អ៊ីបនូ គូស្សៃរ៍ *អាល់-បីដាយ៉ាស្ទ់ វ៉ា អាល់-នីហ្វាយ៉ាស្ទ់ (البداية والنهاية)* ក្បាលទី ៨ ទំព័រ ១៥២ ។

[140] សូមមើលសៀវភៅរបស់លោក អាល់-ស្វាហ្វាប៊ី *តារិក្ទ អាល់-អ៊ីស្លាម* ក្បាលទី ១ ទំព័រ ២៦៧; សៀវភៅរបស់លោក អ៊ីបនូ អាស្សៀរ *អាល់-តារិក្ទ* ក្បាលទី ៣ ទំព័រ ២៦៦ ។

[141] សូមមើលសៀវភៅរបស់លោក អាល់-បាឡាស្ទូរី (البلاذري) *ហ្វ៊ុទុះហ៍ អាល់-ប៊ុលដាន់ (فتوح البلدان)* ក្បាលទី ៥ ទំព័រ ៦ ។

បុគ្គលទាំងពីររូបនេះឲ្យចុះចូលក្រោមអំណាចគ្រប់គ្រងរបស់យ៉ាស៊ុីដ្ធ តែបើបុគ្គលទាំងពីរ ឬអ្នកណាមួយមិនព្រមចុះចូលក្រោមអំណាចស្តេចខ្ញុំលិហ្វថ្មីទេ អភិបាលស្រុកត្រូវកាត់ក្បាលបុគ្គលទាំងនោះ[142] ។
លុះបានទទួលបញ្ជាលាន់ខ្ទរនេះ អាល់-វ៉ាលីដ្ធភ័យរន្ធត់ព្រោះកាត់ក្បាលបុគ្គលដ៏ល្បីល្បាញបែបនេះមិនមែនជាការងាយស្រួលទេ[143] ។ សូម្បីតែមូអ៊ុាវីយ៉ាស្ហ៍ ដែលប៉ិនប្រសប់ដោះស្រាយបញ្ហាដោយមធ្យោបាយកំណាចនោះក៏មិនហ៊ានធ្វើគុតព្រះអង្គصلوات الله عليه والسلامផង ។ តើអភិបាលស្រុកសាមញ្ញដូចអាល់-វ៉ាលីដ្ធនោះអាចធ្វើការនេះបានដូចម្តេចទៅ ?
អាល់-វ៉ាលីដ្ធសូមយោបល់ពីម៉ារវ៉ាន អ៊ីបនូ អាល់-ហ្ាកាំ ម៉ារវ៉ាន អ៊ីបនូ អាល់-ហ្ាកាំបានស្នើឲ្យកោះហៅដោយបង្ខំបុគ្គលទាំងពីររូបនេះ នៅពេលណាមួយ ឲ្យព្រមទទួលយ៉ាស៊ុីដ្ធជាមេដឹកនាំ ពុំនោះទេនឹងត្រូវកាត់ក្បាល[144] ។
យោបល់នេះមិនត្រូវចិត្តអាល់-វ៉ាលីដ្ធទេ តែគាត់ត្រូវឆ្លើយតបម៉ារវ៉ាន[145] ។

## ការបដិសេធទទួលយ៉ាស៊ុីដ្ធជាអភិបាល

ពេលកណ្តាលយប់ អាល់-វ៉ាលីដ្ធបានបញ្ជាឲ្យអ៊ុាប់ឌុលឡោះហ្ អ៊ីបនូ អ៊ុាំរូ អ៊ីបនូ អ៊ុស្ហម៉ាន ទៅកោះហៅ អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلام និងអ៊ុាប់ឌុលឡោះហ្ អ៊ីបនូ អាល់-ស៊្ហបៃរ៍ ។ អ្នកនាំសារបានជួបអ្នកទាំងពីរនៅក្នុងម៉ាស់យ៉ីដ្ធព្រះសាស្តាصلى الله عليه وآله وسلم បានសូមឲ្យទៅកាន់ដំណាក់អភិបាល

---

[142] សូមមើលសៀវភៅរបស់លោក អាល់-យ៉ាក់គូប៊ី (اليعقوبي) *អាល់-តារិក្ (التاريخ)*, ក្បាលទី ២ ទំព័រ ២៤១ ។

[143] សូមមើលសៀវភៅរបស់លោក អាល់-ត៉្ហបារី (محمد بن جرير طبري) *តារិក្ អាល់-អ៊ុម៉ាំ វ៉ា អាល់-មុលុក (تاريخ الأمم والملوك)*, ក្បាលទី ៤ ទំព័រ ២៥ ។

[144] សូមមើលសៀវភៅរបស់លោក អាប៊ូ មិក្ណាហ្វ អាល់-អាស្ស់ឌី *ម៉ាក្ទ៏តាល់-អាល់-ហ៊្វសែន៍ (كتاب مقتل الحسين)* ទំព័រ ៤ ។

[145] សូមមើលសៀវភៅរបស់លោក អាល់-បាឡាស្ហ៊ូរី (البلاذري) *ហ៊្វទុះហ្ អាល់-ប៊ុលដ្ធាន់ (فتوح البلدان)* ក្បាលទី ៥ ទំព័រ ១២-៣ ។

ស្រុក ។ អ្នកទាំងពីរបានយល់ព្រម ។ អាុប់ឌុលឡោះហ្វ៍ អ៊ីបនូ អាល់-ស្ស៊ូបៃរ៍បានបែរមករកអ៊ីម៉ាំអាល់-ហ៊្វូសែន៍صلوات الله عليه والسلام នឹកឆ្ងល់ក្នុងចិត្តថា៖ "តើព្រះអង្គصلوات الله عليه والسلامដឹងឬទេថាគេកោះហៅយើងអំពីរឿងអ្វីលើកនេះ ?"[146]

អ៊ីម៉ាំصلوات الله عليه والسلامបានតបថា៖ "ខ្ញុំគិតថាបុគ្គលគ្រប់គ្រងកំណាចរបស់ពួកគេ - ពោលគឺ មូអាុវីយ៉ាស្ស៊ - ស្លាប់ហើយ ពួកគេកោះហៅយើងឲ្យចុះចូលខ្លួនចំពោះបុគ្គលគ្រប់គ្រងថ្មីមុននឹងដំណឹងនេះលេចឮ ។"[147]

បន្ទាប់មក អ៊ីម៉ាំصلوات الله عليه والسلامបានប្រជុំសាវកព្រះអង្គصلوات الله عليه والسلام ហើយទៅកាន់មណ្ឌលអភិបាលក្រុង ។ ជាដំបូងព្រះអង្គصلوات الله عليه والسلامបានសួរថាតើហេតុអ្វីគេកោះហៅព្រះអង្គصلوات الله عليه والسلامកណ្ដាលអធ្រាត្របែបនេះ ។ គេបានឆ្លើយតបព្រះអង្គصلوات الله عليه والسلامថាព្រះអង្គصلوات الله عليه والسلامត្រូវចុះចូលខ្លួនចំពោះអភិបាលភាពរបស់យ៉ាស៊ីដ្ឋ ។

ដើម្បីពន្យារពេល អ៊ីម៉ាំصلوات الله عليه والسلامមានវចនៈថា៖ "ខ្ញុំមិនប្រកាសចុះចូលខ្លួនដោយស្ងាត់ៗទេ ។ លោកអាចសូមឲ្យខ្ញុំធ្វើបែបនេះបានលុះណាតែលោកសូមឲ្យប្រជារាស្ត្រទាំងអស់ចុះចូលខ្លួនដែរ ដូច្នេះខ្ញុំនិងប្រជារាស្ត្រទាំងអស់នឹងនៅក្នុងស្ថានភាពតែមួយ ។"

មានន័យថាអ៊ីម៉ាំصلوات الله عليه والسلامមានបំណងប្រកាសថាព្រះអង្គصلوات الله عليه والسلامបដិសេធ មិនព្រមស្បថជាសាធារណៈទេ ថាព្រះអង្គصلوات الله عليه والسلامនឹងចុះចូលខ្លួនក្រោមអំណាចរបស់យ៉ាស៊ីដ្ឋ តែម៉ារវ៉ានយល់ជើងការណ៍ ។ ដូច្នេះ គាត់បានស្រែកដាក់អាល់-វ៉ាលីដ្ឋថា៖ "បើគេصلوات الله عليه والسلامចាកចេញពីលោកក្នុងពេលនេះដោយមិនព្រមសច្ចាស្មោះស្ម័គ្រទេ លោកនឹងមិនអាចធ្វើឲ្យគេصلوات الله عليه والسلامសច្ចាស្មោះស្ម័គ្រនៅពេលក្រោយបានទៀតឡើយ លើកលែងតែដោយមានមនុស្សស្លាប់ដ៏ច្រើនទាំងសងខាង ។ ឃាត់ខ្លួនគេصلوات الله عليه والسلامភ្លាម ។ គេصلوات الله عليه والسلامត្រូវតែសច្ចាចុះចូលខ្លួន ឬត្រូវកាត់ក្បាល ។"

អ៊ីម៉ាំصلوات الله عليه والسلامបានបែរទៅរកម៉ារវ៉ាន ដំឡើងសម្លេងមានវចនៈថា៖ "កូនរបស់

[146] សូមមើលសៀវភៅរបស់លោក អ៊ីបនូ គូស្ស៊ៃរ៍ *អាល់-ប៊ីដ្ឋាយ៉ាស្ស៊ វ៉ា អាល់-នីហ្វាយ៉ាស្ស៊ (البداية والنهاية)* ក្បាលទី ៨ ទំព័រ ១៦០ ។

[147] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាល់-អាស្ស៊ៀរ *អាល់-តារីក្* ក្បាលទី ៣ ទំព័រ ២៦៤ ។

អាល់-ស៊ារក្ហ៍អ៊ីយ តើលោកឬគេជាអ្នកសម្លាប់ខ្ញុំ ? ខ្ញុំសូមស្បថចំពោះអល់ឡោះហ៍ លោកបាននិយាយមុសាយ៉ាងកំណាចបំផុត ។" [148]

អ៊ីម៉ាំបានបែរទៅរកអាល់-វ៉ាលីដ្ធ ដើម្បីប្រកាសបដិសេធរឿងសច្ចាចុះចូលខ្លួននេះយ៉ាងដាច់អហង្ការថា៖

أَيُّهَا الأَمِيرُ، إِنَّا أَهْلُ بَيْتِ النُّبُوَّةِ وَمَعْدِنُ الرِّسَالَةِ وَمُخْتَلَفُ المَلاَئِكَةِ وَمَحِلُّ الرَّحْمَةِ. بِنَا فَتَحَ اللهُ وَبِنَا خَتَمَ. وَيَزِيدُ رَجُلٌ أَيُّهَا الأَمِيرُ، إِنَّا أَهْلُ بَيْتِ النُّبُوَّةِ وَمَعْدِنُ الرِّسَالَةِ وَمُخْتَلَفُ المَلاَئِكَةِ وَمَحِلُّ الرَّحْمَةِ. بِنَا فَتَحَ اللهُ وَبِنَا خَتَمَ. وَيَزِيدُ رَجُلٌ فَاسِقٌ شَارِبٌ لِلخَمْرِ وَقَاتِلُ النَّفْسِ المُحْتَرَمَةِ مُعْلِنٌ بِالفِسْقِ. وَمِثْلِي لاَ يُبَايِعُ مِثْلَهُ. وَلكِنْ نُصْبِحُ وَتُصْبِحُونَ وَنَنْظُرُ وَتَنْظُرُونَ أَيُّنَا أَحَقُّ بِالخِلافَةِ وَالبَيْعَةِ.

*"លោកអភិបាលអើយ យើងជាព្រះរាជកុលដ្ឋានរបស់ព្រះសាស្តា ជាខ្លឹមព្រះរាជសារ ដែលអស់ទេវតាតែងតែមកជួប យើងជាបណ្តូលនៃព្រះមេត្តាធម៌ ។ អល់ឡោះហ៍បានផ្តើមដោយយើង ហើយនឹងបញ្ចប់ដោយយើង ។ យ៉ាស៊ីដ្ធជាមនុស្សមានកាមរាគច្រើន ជាមនុស្សស្រវឹង ដែលបំផ្លាញគារវតា លើកស្ទួយអំពើអសីលធម៌របស់ខ្លួន ។ ខ្លួនខ្ញុំមិនចុះចូលខ្លួនចំពោះបុគ្គលនេះនិងបុគ្គលដូចបុគ្គលរូបនេះជាដាច់ខាត ។ ចូររង់ចាំយើងលុះដល់ស្អែកព្រឹក លោកនឹងដឹងថាអ្នកណាសក្តិសមជាអ្នកដឹកនាំ[អ៊ុមម៉ាត់អ៊ីស្លាម] ហើយសក្តិសមនឹងបានទទួលការសូមចុះចូលខ្លួន ។"* [149]

---

[148] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាល់-អាស៊្សៀរ *អាល់-តារិក្ហ* ក្បាលទី ៣ ទំព័រ ២៦៤ ។

[149] សូមមើលសៀវភៅរបស់ សៃយីដ្ធ អ៊ីបនូ ត៏វុស អាល់-ហ៊ាសានី *អាល់-ឡាហ៊ូហ្វ អ៊ាឡា ក្ហត់ឡា អាត្ត៍-ទ្ហ៊ហ្វូហ្វ (اللّهوف على قتلي الطّفوف)* ឬ *អាល់-ម៉ាល់ហ៊ូហ្វ អ៊ាឡា ក្ហត់ឡា អាត្ត៍-ទ្ហ៊ហ្វូហ្វ (الملهوف على قَتلي الطّفوف)* ទំព័រ ១៧; សៀវភៅរបស់ សៃយីដ្ធ មូរតាដ្ហ៏ អាល់-អ៊ាស់ការី (سيّد مُرتضى عسكري) *ម៉ាអ៊ាលីម អាល់-*

នោះគឺការបដិសេធការដឹកនាំមិនស្របច្បាប់របស់យ៉ាស៊ីដដែលអ៊ីម៉ាំអាល់-ហ៊្សសែន៍صلوات الله عليه والسلامបានប្រកាស ។

ម៉ារវ៉ានបន្ទោសអាល់-វ៉ាលីដថាមិនបានធ្វើតាមការណែនាំរបស់ខ្លួន ឯអាល់-វ៉ាលីដបានរិះគន់ម៉ារវ៉ាន ហើយបានថានឹងមិនសម្លាប់អ៊ីម៉ាំអាល់-ហ៊្សសែន៍صلوات الله عليه والسلامឡើយព្រោះឃាតករព្រះអង្គصلوات الله عليه والسلامនឹងទៅឧសភ្លើងនរក ។[150]

ព្រឹកថ្ងៃបន្ទាប់ អ៊ីម៉ាំអាល់-ហ៊្សសែន៍صلوات الله عليه والسلامបានសម្រេចចិត្តចាកចេញពីម៉ាឌីណាស្ទៅកាន់ម៉ាក់កាស្ ។ មុនចាកចេញ ព្រះអង្គصلوات الله عليه والسلامបានទៅស៊ីរ៉ាស្ផ្នូរព្រះអយ្យកោព្រះអង្គصلوات الله عليه والسلام ព្រះសាស្តាមូហាំម៉ាដ្صلى الله عليه وآله وسلم បានត្អូញត្អែរប្រាប់អល់ឡោះហ្ទ៍تعالى អំពីឧប្បសគ្គដែលចោមរោមព្រះអង្គصلوات الله عليه والسلام ថា៖ "អល់ឡោះហ្ទ៍عز وجلអឺយ នេះគឺផ្នូររបស់ព្រះសាស្តាមូហាំម៉ាដصلى الله عليه وآله وسلم សូមសិរីសួស្តីកើតមានដល់ព្រះអង្គصلى الله عليه وآله وسلمនិងព្រះរាជកុលដ្ឋានព្រះអង្គصلى الله عليه وآله وسلم ទូលព្រះបង្គំជាខ្ញុំ ជាព្រះរាជបុត្ររបស់ព្រះរាជបុត្រីរបស់ព្រះសាស្តាមូហាំម៉ាដ្صلى الله عليه وآله وسلمដែលជាព្រះសាស្តារបស់ព្រះអង្គعز وجل ។ ទូលព្រះបង្គំជាខ្ញុំពើបពះបញ្ហាដែលព្រះអង្គعز وجلទ្រង់ញាណស្រាប់ហើយ ។ អល់ឡោះហ្ទ៍عز وجلអឺយ ទូលព្រះបង្គំជាខ្ញុំស្រឡាញ់អ្វីដែលត្រឹមត្រូវ ហាមអ្វីដែលអាក្រក់ ។ ពេលនេះទូលព្រះបង្គំជាខ្ញុំសូមអង្វរព្រះអង្គعز وجل ឱព្រះម្ចាស់វិរោចនភាពនិងកិត្តិយសអឺយ សូមព្រះអង្គعز وجلជ្រើសរើសឲ្យទូលព្រះបង្គំជាខ្ញុំ នូវអ្វីដែលសព្វព្រះហឫទ័យព្រះអង្គعز وجلនិងដែលសព្វព្រះហឫទ័យព្រះសាស្តាصلى الله عليه وآله وسلمព្រះអង្គعز وجل ។"[151]

ក្នុងពេលយប់ជ្រៅ អ៊ីម៉ាំអាល់-ហ៊្សសែន៍صلوات الله عليه والسلامបានទៅកាន់ផ្នូរកំបាំងរបស់ព្រះនាងហ្វាទីម៉ាស្ អាស្-ស្ាស្ស៉រ៉អ៊ែسلام الله عليها ព្រះមាតាព្រះអង្គصلوات الله عليه والسلام ហើយ

---

*ម៉ាដ្វ៉រសាតែន៍ (معالم المدرستين)* ទំព័រ ៤៦ ។

[150] សូមមើលសៀវភៅរបស់លោក អាល់-ត៏្បារី (محمد بن جرير طبري) *តារិក្ អាល់-អ៊ូម៉ាំ វ៉ា អាល់-មុលុក (تاريخ الأمم والملوك)*, ក្បាលទី ៥ ទំព័រ ៣៤០ ។

[151] សូមមើលសៀវភៅរបស់ ស្ហៃខ៍ អាល់-ស្ហ៊រ៉យ់ហ្វី *ម៉ៅស៊ូអ៊ាស្ កាឡីម៉ាត់ អាល់-អ៊ីម៉ាំ អាល់-ហ៊្សសែន៍ (موسوعةُ كَلماتِ الامامِ الحُسَين عليه السّلام)* ទំព័រ ២៨៧ ចែងនៅក្នុងសៀវភៅរបស់ លោក អាល់-ខ៏្វ៉ារីស៊្មី (الخوارزمي) *ម៉ាក់តាល់ អាល់-ហ៊្សសែន៍ (مقتل الحسين) ។*

បានទៅកាន់ផ្ទះអ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام ព្រះរៀមព្រះអង្គ صلوات الله عليه والسلام នៅទីនេះ ព្រះអង្គ صلوات الله عليه والسلام បានរំលឹកដល់សម័យ ដែលព្រះអង្គទាំងអស់គ្នា عليهم السلام មានសេចក្ដីសុខ សេចក្ដីរីករាយ ។

## នៅឯម៉ាក់កាស្ហ

ពេលអ៊ីម៉ាំអាល់-ហ៊្វសែន៍ صلوات الله عليه والسلام បានសម្រេចចិត្តទៅកាន់ម៉ាក់កាស្ហ ព្រះអង្គ صلوات الله عليه والسلام បានផ្ដែផ្ដាំព្រះអនុជាព្រះអង្គ صلوات الله عليه والسلام ព្រះនាងស៊ែណាប់ سلام الله عليها ប្រាប់ព្រះនាងឲ្យដឹងអំពីទង្វើដែលព្រះអង្គ صلوات الله عليه والسلام ត្រូវធ្វើ ហើយសូមឲ្យព្រះនាងចូលរួមក្នុងកិច្ចការដ៏មហាលំបាកនេះ ។ ដោយហេតុតែព្រះនាងមានជំនឿស៊ប់ចិត្ត ព្រះនាងមិនរួញរាទេ ព្រះនាងឆ្លើយតបព្រះរៀមព្រះនាងភ្លាម ។ ព្រះនាងប្ដេជ្ញាចិត្តចូលរួមនិងធ្វើឲ្យបដិវត្តន៍របស់ព្រះអង្គ صلوات الله عليه والسلام បានសម្រេច ជាស្ថាពរ ។ ដូចព្រះនាងស៊ែណាប់ سلام الله عليها ដែរ ព្រះមហេសីទាំងឡាយ ព្រះរាជបុត្រទាំងឡាយ បងៗប្អូនៗទាំងឡាយព្រមទាំងបងប្អូនជីដូនមួយរបស់អ៊ីម៉ាំអាល់-ហ៊្វសែន៍ صلوات الله عليه والسلام ក៏យល់ព្រមចូលរួមក្នុងបដិវត្តន៍ជាមួយព្រះអង្គ صلوات الله عليه والسلام ដែរដើម្បីប្រយុទ្ធទល់នឹងបនសង្កត់សង្កិន ។

ស្អែកឡើង ទាំងអស់គ្នាត្រៀមខ្លួនចេញដំណើរ ។ ព្រះនាងស៊ែណាប់ سلام الله عليها រំភើបចិត្តណាស់ទោះបីមានអ្នុប់បាស់ ព្រះអនុជព្រះនាង នៅក្បែរ មើលថែរក្សាការពារព្រះនាងក៏ដោយ ។ ប្រជារាស្ត្រម៉ាឌីណាស្ហក៏រំភើបចិត្តដែរ ពួកគេមើលព្រះរាជវង្សព្រះសាស្ដា صلى الله عليه وآله وسلم បែកពីពួកគេ ប្រហែលជាបែកគ្នារហូត ។ តាមផ្លូវ អ៊ីម៉ាំអាល់-ហ៊្វសែន៍ صلوات الله عليه والسلام សូត្រដដែលៗនូវព្រះបន្ទូលអល់ឡោះហ្វ៍ تعالى ថា៖ "ព្រះម្ចាស់ទូលព្រះបង្គំជាខ្ញុំអើយ សូមព្រះអង្គឲ្យទូលព្រះបង្គំជាខ្ញុំបានរួចផុតពីប្រជារាស្ត្រអយុត្តិធម៌ (២៨:២១) ។"

សូត្រអាយ៉ាស្ហនេះ អ៊ីម៉ាំអាល់-ហ៊្វសែន៍ صلوات الله عليه والسلام ប្រៀបធៀបដំណើរផ្លូវនេះនឹងដំណើរផ្លូវរបស់ណាប៊ីមូសា عليه السلام ដែលបានប្រទូសប្រឆាំងនឹងបុគ្គលកាន់អំណាចផ្ដាច់ការក្នុងសម័យព្រះអង្គ عليه السلام ។[152]

---

[152] សូមមើលសៀវភៅរបស់លោក អាល់-នុអ៊្ម៉ាន អាល់-ម៉ាក់រីប៊ី (النعمان مغربي) *ស្ហារហ៊្ហ អាល់-អាក់បារ (شرحُ الأخبار)* ក្បាលទី ៣ ទំព័រ ១៥៥ ។

ព្រះអង្គصلوات الله عليه والسلامធ្វើដំណើរតាមផ្លូវសាធារណៈទៅកាន់ម៉ាក់កាស្ហ៍ ដោយប្រកាសការប្រឆាំងអាជ្ញាធរគ្រប់គ្រង មិនខ្លាចស្លាប់ឡើយ ពីព្រោះមនុស្សគ្រប់រូបត្រូវតែស្លាប់ដោយចៀសមិនផុតគ្រប់ពេលវេលា ទោះជានៅទីណាក៏ដោយ[153] ។ ព្រះអង្គصلوات الله عليه والسلامទុកកាយថ្វាយចិត្តលើអល់ឡោះហ្ទ៍تعالىទាំងស្រុង ព្រះដែលគ្រប់គ្រងសព្វសារពើ ។

ការដើរផ្លូវចាកចេញពីម៉ាឌីណាស្ហ៍នេះ ជាលើកទីពីរសម្រាប់ព្រះនាងស្ហៃណាប់سلام الله عليها ។ លើកទីមួយព្រះនាងបានធ្វើដំណើរជាមួយព្រះបិតាព្រះនាង កាលព្រះអង្គបានចាកចេញពីម៉ាឌីណាស្ហ៍ទៅរស់នៅឯគូហ្វាស្ហ៍ កាលព្រះអង្គបានចាត់តាំងស្រុកនេះជារាជធានីរបស់រដ្ឋព្រះអង្គ ។ កាលនោះព្រះនាងបានធ្វើដំណើរនៅក្នុងក្បួនទូរចរដ៏ធំដែលមានព្រះបិតា ព្រះរៀម ព្រះស្វាមីនិងបងប្អូនជីដូនមួយព្រះនាង ។ ការធ្វើដំណើរត្រឡប់មកម៉ាឌីណាស្ហ៍វិញ ក្រោយពីអ៊ីមុាំអាល់-ហ្ហាសាន់صلوات الله عليه والسلامបានសន្យាផ្អាកការប្រយុទ្ធជាមួយមូអាុវីយ៉ាស្ហ៍ក៏ជាដំណើរផ្លូវមិនលំបាកដែរ ដែលប្រកបដោយកិត្តិយសនិងសេចក្តីថ្លៃថ្នូរ ។ តែការធ្វើដំណើរលើកទីបីកំសត់និងស្រពាប់ស្រពោនណាស់ ពីព្រោះពួកសត្រូវជាអ្នកដឹកនាំក្បួនទូរចរ ។

ថ្ងៃអង្គារយប់[154] អ៊ីមុាំអាល់-ហ្ហ៊ូសៃន៍صلوات الله عليه والسلامបានមកដល់ម៉ាក់កាស្ហ៍ ស្នាក់នៅឯគេហដ្ឋានរបស់អាល់-អាុប់បាស់ អ៊ីបនូ អាុប់ដ្វាល់-មុត្តត៏លិប[155] ។ ពួកអ្នកស្រុកម៉ាក់កាស្ហ៍មកសួរសុខទុក្ខព្រះអង្គصلوات الله عليه والسلامជាញឹកញយ ហើយបានសាកសួរព្រះអង្គصلوات الله عليه والسلامរឿងច្បាប់អ៊ីស្លាម និងសាកសួរព្រះអង្គصلوات الله عليه والسلامរឿងរបបគ្រប់គ្រង ។ ពេលដល់រដូវធ្វើពិធីហ្ហាច្ជ ពួកហ្ហាឃ្ជីនិងមុអ៍តាមៀរ

---

[153] សូមមើលសៀវភៅរបស់លោក អាល់-កូន់ឌូស៊ី អាល់-ហ្ហាណាហ្វី *យ៉ាណាប៊ិអ៍ អាល់-ម៉ាវ៉ាដ្ឌ៍ដ្វាស្ហ៍ លីស្ហាវី អាល់-គូរបា(ينابيع المودة لذوي القربى)* ទំព័រ ៤០២ ។

[154] សូមមើលសៀវភៅរបស់លោក មូហ្ហាំម៉ាដ្ឌ៍ អ៊ីបនូ យ៉ាជៀរ អាល់-ត៏បារី (محمد بن جرير طبري) *តារិក្ហ អាល់-អ៊ូមុាំ វ៉ា អាល់-មុលុក (تاريخ الأمم والملوك)* ក្បាលទី ៦ ទំព័រ ១៩០ ។

[155] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាុសាកៀរ (ابن عساكر) *តារិក្ហ ម៉ាឌីនាស្ហ៍ ឌីម៉ាស្ហ៍គ្ហ៍ (تاريخ مدينة دمشق)* ក្បាលទី ១៣ ទំព័រ ៦៨ ។

(معتمر គឺអ្នកធ្វើពិធីហាជ្ជតូច) បានមកចោមរោមព្រះអង្គ صلوات الله عليه والسلام ស្តាប់សម្តី និងដំបូន្មានព្រះអង្គ صلوات الله عليه والسلام ។ ចាប់ពីពេលនោះ ព្រះអង្គ صلوات الله عليه والسلام ចាប់ផ្តើមប្រកាសបដិវត្តន៍ព្រះអង្គ صلوات الله عليه والسلام មហាជនចាប់ផ្តើមយល់គោលដៅរបស់ព្រះអង្គ صلوات الله عليه والسلام ដែលព្រះអង្គ صلوات الله عليه والسلام មករស់នៅឯម៉ាក់កាស្ហ៎នេះ ។

ដោយសារសកម្មភាពនេះ អាជ្ញាធរម៉ាក់កាស្ហ៎ភ័យរន្ធត់ ហើយបានគិតជាមុនថាព្រះអង្គ صلوات الله عليه والسلام យកម៉ាក់កាស្ហ៎ជាមណ្ឌលបដិវត្តន៍ព្រះអង្គ صلوات الله عليه والسلام ដើម្បីប្រឆាំងរបបគាបសង្កត់របស់យ៉ាស៊ីដ្ឌ ។ អភិបាលស្រុកម៉ាក់កាស្ហ៎បានមកជួបអ៊ីម៉ាំ صلوات الله عليه والسلام សួររកមូលហេតុដែលព្រះអង្គ صلوات الله عليه والسلام មករស់នៅឯម៉ាក់កាស្ហ៎នេះ ។ អ៊ីម៉ាំ صلوات الله عليه والسلام បានឆ្លើយតបថាព្រះអង្គ صلوات الله عليه والسلام មកសូមជម្រកអល់ឡោះហ្ទ៍ تعالى និងព្រះមហាគ្រឹះ ។ ដូច្នេះ អភិបាលស្រុកបានផ្ញើសារទៅយ៉ាស៊ីដ្ឌ ប្រាប់ឲ្យដឹងថាអ៊ីម៉ាំ صلوات الله عليه والسلام បានមកដល់ ប្រជារាស្ត្រចោមរោមព្រះអង្គ صلوات الله عليه والسلام ចាំចូលប្រជុំជាមួយព្រះអង្គ صلوات الله عليه والسلام និងស្តាប់ព្រះអង្គ صلوات الله عليه والسلام ។

ដំណឹងនេះធ្វើឲ្យយ៉ាស៊ីដ្ឌស្រឡាំងកាំង ហើយបានផ្ញើសំបុត្រទៅអាុប់ឌុលឡោះហ្ទ៍ អ៊ីបនូ អាុប់បាស់ភ្លាម ថាឲ្យគាត់លើកទោសឲ្យអ៊ីម៉ាំ صلوات الله عليه والسلام បើអ៊ីម៉ាំ صلوات الله عليه والسلام ព្រមទទួលស្គាល់អភិបាលភាពរបស់យ៉ាស៊ីដ្ឌ ពុំនោះទេព្រះអង្គ صلوات الله عليه والسلام នឹងត្រូវទទួលទោស ។ ឆ្លើយតបសាររបស់យ៉ាស៊ីដ្ឌ អាុប់ឌុលឡោះហ្ទ៍ អ៊ីបនូ អាុប់បាស់បានប្រាប់ថាអ៊ីម៉ាំ صلوات الله عليه والسلام បានចាកចេញពីម៉ាឌីណាស្ហ៎ព្រោះអាជ្ញាធរធ្វើអុកឡុកព្រះអង្គ صلوات الله عليه والسلام ។ គាត់បានសន្យាដែរថានឹងជួបព្រះអង្គ صلوات الله عليه والسلام និងពិភាក្សារឿងនេះ ។

ក្នុងពេលតែមួយនៅឯប្រទេសអ៊ីរ៉ាក់ មានការបះបោរជាទូទៅ មិនព្រមទទួលយ៉ាស៊ីដ្ឌមេដឹកនាំអុមម៉ាត្ហ៎ទេ ព្រោះពួកគេចាត់ទុកយ៉ាស៊ីដ្ឌជាសត្រូវស្លាប់រស់របស់អ៊ីស្លាម ។ ពួកមេដឹកនាំពួកស្ហ៊ីអាុស្ហ៎នៅឯគូហ្វាស្ហ៎បានប្រជុំគ្នានៅឯគេហដ្ឋានរបស់ស៊ូឡៃម៉ាន អ៊ីបនូ សាអាុដ្ហ៎ អាល់-ឃូសាអ៊ី បង្ហាញនូវបាបរបស់ពួកអ៊ូម៉ៃយ៉ាស្ហ៎ ហើយប្រកាសឲ្យចូលដៃជាមួយអ៊ីម៉ាំ صلوات الله عليه والسلام អាល់-ហ៊្វូសៃន៍ صلوات الله عليه والسلام ជាអភិបាលដឹកនាំពិតប្រាកដរបស់អុមម៉ាត្ហ៎អ៊ីស្លាម ។[156]

---

[156] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ណាម៉ា អាល់-ហ៊ីល្លី (بن نما الحلي) *មូស្សៀរ*

ពួកអ្នកចូលរួមបានស្រែកថា ពួកគេប្រាកដជានឹងគាំទ្រនិងការពារអ៊ីម៉ាំ صلوات الله عليه والسلام ហើយបានផ្ញើសារទៅសូមឲ្យព្រះអង្គ صلوات الله عليه والسلام ដឹកនាំបដិវត្តន៍ពួកគេប្រឆាំងនឹងពួកកាន់ក្ដាប់ត្រកូលអ៊ូម៉ៃយ៉ាស់ ។ ដូច្នេះ គេបានមកជួបព្រះអង្គ صلوات الله عليه والسلام ទាំងក្រុមៗ មនុស្សសាមញ្ញនិងពួកមេដឹកនាំបានផ្ញើសាររាប់ពាន់មកព្រះអង្គ صلوات الله عليه والسلام ដូចជា ស៊ូឡៃម៉ាន់ អ៊ីបនូ ស៊ូរ៉ត អាល់-ខូហ្សាអ៊ី, ហាប៊ីប អ៊ីបនូ ម៉ាហ្សាហ៊ៀរ, រីហ្វាអាហ់ អ៊ីបនូ ស្ហាដ្ដាដ និង ស្ហាប៊ីសស៍ អ៊ីបនូ រ៉ប៊ីអ៊ុ, ហាជ្ជ៉ារ អ៊ីបនូ អាប់ជ៉ារ អាល់-អ៊ីជ៉្លី និង អាំរ៉ូ អ៊ីបនូ អាល់-ហាជ្ជ៉ាជ្ជ៍[157] ជាដើម ។ អ៊ីម៉ាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ក៏បានសម្រេចចិត្តឆ្លើយតបពួកគេ បានចាត់បញ្ជូន មុស្លីម អ៊ីបនូ អាគ៊ីល បងប្អូនជីដូនមួយរបស់ព្រះអង្គ صلوات الله عليه والسلام ទៅស្ទង់មើលស្ថានការណ៍ពិត ។[158]

## មុស្លីម អ៊ីបនូ អាគ៊ីល នៅគូហ្វាស់

មុស្លីមបានចាកចេញទៅគូហ្វាស់ បានស្នាក់នៅឯលំនៅដ្ឋានរបស់ អាល់-មុក្តារ អាល់-ស្ហាគ៊ីហ្វី ដែលជាអ្នកមានសទ្ធាជ្រះថ្លាម្នាក់ ក្នុងចំណោមអ្នកមានសទ្ធាជ្រះថ្លាដ៏ល្បីៗ[159] - ដែលបានហៅគេឲ្យមកជួបមុស្លីម ។ គេបានមកស្ដាប់ព្រះរាជសាររបស់អ៊ីម៉ាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ដែលមុស្លីមបាននាំ

*អាល់-អាស់ស្ហាន់ (مُثيرُ الأحزان)* ទំព័រ ១៥ ។

[157] សូមមើលសៀវភៅរបស់លោក អាប៊ុល-ហ្វារ៉ជ្ជ៍ អាល់-អ៊ីស្វហ្វាហានី (أبو الفرج الإصفهاني) *ម៉ាក៊្វាទីល អាល់-ត៉្វលីប៊ីយ៉ីន (مَقاتِل الطالِبيّين)* ទំព័រ ១៥៧ និងសៀវភៅ *អាន់សាប់ អាល់-អាស្ហ់រ៉ហ្វ (أنساب الأشراف)* ទំព័រ ១៥៧ ។

[158] សូមមើលសៀវភៅរបស់លោក អាប៊ូ ហានីហ្វាស់ អាល់-ឌៃនូរី (أبو حنيفة الدينوري) *អាល់-អាក់បារ អាល់-ទ៉្វវ៉ាល់ (الأخبار الطوال)* ទំព័រ ២១០ ។

[159] សូមមើលសៀវភៅរបស់លោក ហាមីដ្ឋ អ៊ីបនូ មូហាំម៉ាដ្ឋ អាល់-ម៉ាហ៊ាល្លី *អាល់-ហាដ្ឋាអ៊ីក្វ អាល់-វ៉ារឌ្ឋីយ៉ាស់* ក្បាលទី ១ ទំព័រ ១២៥ ។ អ្នកប្រវត្តិសាស្ត្រច្រើននាក់ទៀតបានឲ្យដឹងថា មុស្លីម អ៊ីបនូ អាគ៊ីល បានស្នាក់នៅឯលំនៅដ្ឋានរបស់ មុស្លីម អ៊ីបនូ អាវ៉្សាជ៉ាស់ ឬ ហានី អ៊ីបនូ អ៊ូរវ៉ាស់ (មើលសៀវភៅរបស់លោក អ៊ីបនូ អាល់-ហាជ៉ារ *អ៊ីស្វាបាស់ ហ្វី ម៉ាក់រីហ្វាស់ អាល់-ស្វហាបាស់ (الإصابة في معرفة الصحابة)* ក្បាលទី ១ ទំព័រ ៣៣២; សៀវភៅរបស់លោក អ៊ីបនូ អាល់-ហាជ៉ារ អាល់-អាស់ក៊្វឡានី *តាស្ហ់ស៊ីប អាល់-តាស្ហ់ស៊ីប (تهذيب التهذيب)*) ។

មក ។ យ៉ាងតិចបំផុត មនុស្សចំនួនសែសិបពាន់នាក់នៅគូហ្វាស្ទ៍បាន ទទួលស្គាល់អ៊ីម៉ាំអាល់-ហ៊្វូសែន៍صلوات الله عليه والسلامជាអភិបាលដឹកនាំពួកគេ ដែលពួកគេត្រូវការពារនិងគាំទ្រ ។[160]

ទំនុកចិត្ត និងជំនឿរបស់ពួកមុស្លីមលើជោគជ័យរបស់បដិវត្តន៍របស់អ៊ីម៉ាំ អាល់-ហ៊្វូសែន៍صلوات الله عليه والسلامមានកំណើនឡើង អាស្រ័យចំនួនអ្នកគាំទ្រដ៏ច្រើននេះ ។ អាស្រ័យហេតុនេះ មុស្លីមបានផ្ញើសារទៅអ៊ីម៉ាំصلوات الله عليه والسلام សូមឲ្យព្រះអង្គصلوات الله عليه والسلامប្រញាប់យាងមកកាន់គូហ្វាស្ទ៍[161] ។ អ៊ីម៉ាំصلوات الله عليه والسلامក៏បានរៀបចំខ្លួនចេញដំណើរ ។

ភ្នាក់ងាររបស់យ៉ាស៊ីដ្ទនៅគូហ្វាស្ទ៍ បាននាំដំណឹងនេះទៅប្រាប់យ៉ាស៊ីដ្ទ ។ ព្រោះតែខ្លាច យ៉ាស៊ីដ្ទបានសូមយោបល់ពីសៀរយ៉ោន៍ (سرجون) បុរសរ៉ូម (គឺបុរសកាន់សាសនាគ្រិស្ត) ដែលជាលេខាឆ្នើមបំផុតរបស់ឪពុកគាត់ ។ បុរសសម្បូរល្បិចរូបនេះបានគិតគូរដ៏យូរ មុននឹងស្នើសូមឲ្យយ៉ាស៊ីដ្ទតែងតាំង អ៊ូបៃឌុលឡោះហ្វ៍ អ៊ីបនូ ស៊ីយ៉ាដ្ទ៍ ជាអភិបាលថ្មីរបស់ស្រុកគូហ្វាស្ទ៍ ។[162]

ទោះបីយ៉ាស៊ីដ្ទក្រោធអ៊ូបៃឌុលឡោះហ្វ៍ អ៊ីបនូ ស៊ីយ៉ាដ្ទ៍ក៏ដោយ ក៏ត្រូវតែបង្ខំចិត្តតែងតាំងអ៊ូបៃឌុលឡោះហ្វ៍ អ៊ីបនូ ស៊ីយ៉ាដ្ទ៍ជាអភិបាលស្រុកគូហ្វាស្ទ៍គូបនឹងស្រុកបាស្វ៉ូរ៉ោះត្វ៍[163] ។ ដូច្នេះ អ៊ីបនូ ស៊ីយ៉ាដ្ទ៍ក្លាយទៅជាអ្នកកាន់ក្ដាប់ប្រទេសអ៊ីរ៉ាក់ទាំងមូល ។ ម្យ៉ាងទៀត យ៉ាស៊ីដ្ទបានផ្ញើសំបុត្រ

---

[160] សូមមើលសៀវភៅរបស់លោក មូហ្ហាំម៉ាដ្ទ៍ បាក្វៀរ អាល់-ម៉ាច្ញ៉លីស៊ី (محمد باقر المجلسي) *ប៊ីហ្ហារ អាល់-អាន់វ៉ារ (بحارالانوار)* ក្បាលទី ៤៤ ទំព័រ ៣៣៧ ។

[161] សូមមើលសៀវភៅរបស់លោក អ៊ីបនូ យ៉ាហ្ចរៀរ អាល់-ត៏្ញបារី (محمد بن جرير طبري) *តារិក្ហ អាល់-អ៊ូម៉ាំ វ៉ា អាល់-មុលុក (تاريخ الأمم والملوك)*, ក្បាលទី ៤ ទំព័រ ២២៤ ។

[162] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាល់-អាស្សៀរ *អាល់-តារិក្ហ* ក្បាលទី ៣ ទំព័រ ២៦៨ ។

[163] សូមមើលសៀវភៅរបស់លោក អ៊ីបនូ គូស្សៃរ៍ *អាល់-ប៊ីដ្ទាយ៉ាស្ទ៍ វ៉ា អាល់-នីហ្វាយ៉ាស្ទ៍ (البداية والنهاية)* ក្បាលទី ៨ ទំព័រ ១៥២ ។

ទៅ អ៊ីបនូ ស៊ីយ៉ាដ្ន ឲ្យគាត់ចាប់ខ្លួនមុស្លីម អ៊ីបនូ អ៊ាគីល[164] ឲ្យនិរទេសលោក ឬ ឲ្យសម្លាប់លោក ហើយបានដាក់បញ្ញាមួយទៀត បន្ទាប់ពីនេះ ឲ្យគាត់ប្រញាប់ទៅកាន់គូហ្វាស្ហ៍បើអាចធ្វើបាន ។[165]

## អ៊ូបៃឌុលឡោះហ្ន៍ អ៊ីបនូ ស៊ីយ៉ាដ្ននៅគូហ្វាស្ហ៍

តាមផ្លូវពីបាស្ហ៍រ៉ោះត្ហ៍ទៅគូហ្វាស្ហ៍ អ៊ូបៃឌុលឡោះហ្ន៍ អមដោយរេហ៍ពលប្រាំរយនាក់ មិនបានឈប់សម្រាកទេ ព្រោះខ្លាចអ៊ីម៉ាំអាល់-ហ៊្វូសែន៍صلوات الله عليه والسلام ទៅដល់មុនខ្លួន ។ គាត់បានកាឡៃខ្លួនដោយដណ្តប់ក្រណាត់ខ្មៅលើមុខដើម្បីនឹងឲ្យគេចាត់ទុកគាត់ជាអ៊ីម៉ាំصلوات الله عليه والسلام ។ គាត់បានចូលទៅក្នុងស្រុកប្រញាប់ទៅកាន់ កូស្ហ៍រ៍ អាល់-អ៊ីម៉ារ៉ោះត្ហ៍ - វាំងអភិបាលស្រុក - ដោយភ័យខ្លាច ព្រោះប្រជារាស្ត្របានស្វាគមន៍គាត់យ៉ាងកក់ក្តៅព្រោះតែគិតថាគាត់ជាអ៊ីម៉ាំអាល់-ហ៊្វូសែន៍صلوات الله عليه والسلامមែន ។[166]

គាត់បានទៅដល់ទីនោះ បានគោះទ្វារ អាល់-នុអ៍ម៉ាន អ៊ីបនូ បាស្ហៀរ អភិបាលស្រុកគូហ្វាស្ហ៍ ដែលស្មានថាគាត់ជាអ៊ីម៉ាំصلوات الله عليه والسلامដែរនោះ ក៏បានស្រែកពីលើយ៉វាំងថា៖ "ព្រះរាជបុត្រព្រះសាស្តាصلى الله عليه وآله وسلمអល់ឡោះហ្ន៍عز وجلអើយ ទូលបង្គំមិនចុះចូលខ្លួនចំពោះព្រះអង្គصلوات الله عليه والسلامទេ ហើយក៏មិនចង់ប្រយុទ្ធតទល់ព្រះអង្គصلوات الله عليه والسلامទេដែរ... ។"[167]

អ៊ូបៃឌុលឡោះហ្ន៍បានស្រែកថា៖ "បើកទ្វារ ពុំនោះទេលោកនឹងដេកមិន

---

[164] សូមមើលសៀវភៅរបស់លោក អ៊ីបនូ យ៉ាវៀរ អាល់-ត្ហ៍បារី (محمد بن جرير طبري) *តារិក្ហ៍ អាល់-អ៊ូម៉ាំ វ៉ា អាល់-មុលុក (تاريخ الأمم والملوك)* ក្បាលទី ៤ ទំព័រ ២៦៥ ។

[165] សូមមើលសៀវភៅរបស់លោក អាល់-ស្ហាហ្ហាប៊ី (الذهبي) *ស៊ីយ៉ារ៍ អាក់ឡាំ អាល់-នូបាឡាអ៍ (سير أعلام النبلاء)* ក្បាលទី ៣ ទំព័រ ២៩៩ ។

[166] សូមមើលសៀវភៅរបស់លោក មូហ្ហាំម៉ាដ្ន អ៊ីបនូ អាល់-ហ្វាត់តាល់ អាល់-នីស្ហាពូរី (محمد بن الفتّال النيشابوري) *រ៉ៅដ្ហោះត្ហ៍ (رَوضَة الواعِظين) អាល់-វ៉ាអ៊ីស្ហ៊ីន* ទំព័រ ១៧៤ ។

[167] សូមមើលសៀវភៅរបស់លោក អាប៊ូ មិក្ហ៍ណាហ្វ៍ អាល់-អាស្ហ៍ឌី *ម៉ាក្ហ៍តាល់-អាល់-ហ៊្វូសែន៍ (كتاب مقتل الحسين)* ទំព័រ ២៨ ។

លក់ទេយប់នេះ !"[168]

ប្រជារាស្ត្រមួយចំនួនដែលបានដើរពីក្រោយអ៊្លបៃឌុលឡោះហ្ទ៍ ទើបតែបានដឹងការពិត ដូច្នេះពួកគេបានស្រែកថា៖ "ការពិត វាជាគឺកូនរបស់ម៉ារយ៉ាហ្គណាស្ញ៉ុសោះ ។"

ពួកគេក៏បាននាំគ្នារត់ដោយភ័យតក្កមា បេះដូងមកនៅត្រង់កន្លើត ។ អ៊្លបៃឌុលឡោះហ្ទ៍រត់សំដៅវាំង ចាប់អាវុធនិងទ្រព្យ ។ គាត់ត្រូវចោមរោមដោយពួកភ្នាក់ងាររបស់ត្រកូលអ៊ូម៉ៃយ៉ាស្ញ៉ ដូចជា អ៊្លម៉ារ អ៊ីបនូ សាអ៊្ទដ្ញ៉, ស្ញ៊ីម្រ អ៊ីបនូ ស៊្ញីល-យ៉ៅស្ញាន (شِمر بن ذى الجَوْشَن), មូហ៊្ហាំម៉ាដ្ញ៉ អ៊ីបនូ អាល់-អាស្ញ៉អ៊្ទស្ញ៉ (محمد بن الأشعث) ជាដើម និងពួកដែលឈ្មោះល្បីៗច្រើនទៀតក្នុងចំណោមពួកមានពុតត្បុតនៃស្រុកគូហ្វាស្ញ៉ ។ ពួកគេបានពិភាក្សាគ្នារឿងបដិវត្តន៍ដែលនឹងកើតឡើងនោះ និងរឿងពួកមេដឹកនាំបដិវត្តន៍នោះ ហើយគិតគូរដាក់ផែនការសម្លាប់ដើម្បីកម្ចាត់បដិវត្តន៍នេះ ។[169]

ស្អែកឡើង អ៊្លបៃឌុលឡោះហ្ទ៍បានប្រជុំប្រជារាស្ត្រនៅក្នុងម៉ាស់យ៊្ញិដធំស្រុកគូហ្វាស្ញ៉ដើម្បីប្រកាសថាគាត់ជាអភិបាលស្រុកថ្មី ។ គាត់បានសន្យាថាអ្នកណាស្តាប់បង្គាប់ អ្នកនោះនឹងបានរង្វាន់ បានគំរាមថាគាត់នឹងគាបសង្កត់ពួកល្មើស ពួកបះបោរដោយធ្វើទណ្ឌកម្មយ៉ាងឈឺចាប់[170] ។ បន្ទាប់មកគាត់បានបង្ហាញនូវអំពើអាក្រក់ច្រើនបែប ដោយធ្វើការប្រហារជីវិតមនុស្សច្រើននាក់បន្ទាប់ពីបានសួរចម្លើយពួកគេ[171] ។ គាត់បានដាក់ពេញ

---

[168] សូមមើលសៀវភៅរបស់ សៃយីដ្ញ មុះហ្ស៊ីន អាល់-អាមីន អាល់-អាមីលី (محسن الأمين العاملي) *ឡាវ៉ាអ៊ីជ្ញ អាល់-អាស្ញ៉យ៉ាន់* (لواعج الاشجان) ទំព័រ ៥៥ ។

[169] សូមមើលសៀវភៅរបស់លោក បាគៀ្រ ស្ញារីហ្វ អាល់-គ៊ូរ៉ស្ញ៊ី (شريف القرشي) *អាល់-អ៊្ទប់បាស់ អ៊ីបនូ អ៊្ទលី* ទំព័រ ១៣៣ ។

[170] សូមមើលសៀវភៅរបស់លោក អាល់-ហ្វាដ្ញ៉ល៍ អ៊ីបនូ ហាសាន់ អាល់-ត្ញ៉បារស៊ី (الفضل بن الحسن الطبرسي) *អ៊ិអ៊្លឡាំ អាល់-វ៉ារ៉ ប៊ីអាក់ឡាំ អាល់-ហ៊្វដា* *(اعلام الورى بأعلام الهدى)* ក្បាលទី ១ ទំព័រ ៤៣៨ ។

[171] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាល់-សាប់បាក៊្ញ អាល់-ម៉ាលីគី *អាល់-ហ្វ៊ូស្ញ៊ូល អាល់-មូហ៊្ទីមម៉ាស្ញ៉* ទំព័រ ១៩៧ ។

ពន្ធនាគារជនស្លូតត្រង់ ។ មធ្យោបាយទាំងនេះមានគោលដៅគ្រប់គ្រងស្រុកទាំងស្រុង ។

លុះបានដឹងថាអ៊ូបៃឌុលឡោះហ្វ៍មកដល់ មុស្លីមបានផ្លាស់ទីសម្នាក់ ។ លោកបានទៅស្នាក់នៅឯលំនៅដ្ឋានរបស់ ហានី អ៊ីបនូ អ៊ូរវ៉ាស់ អ្នកល្បីឈ្មោះម្នាក់នៅឯគូហ្វាស់ ដែលបានស្វាគមន៍លោក បានទទួលបក្សពួកលោកដើម្បីរៀបចំផែនការបដិវត្តន៍ ។

ជោគជ័យរបស់អ៊ូបៃឌុលឡោះហ្វ៍ អ៊ីបនូ ស៊ីយ៉ាដ្ធ័ក្នុងវិស័យនយោបាយស្ថិតនៅលើផែនការដែលគាត់បានរៀបចំ ។ ដំបូងបង្អស់ គាត់បានតាមដានសើុបសកម្មភាពរបស់មុស្លីម ស្ទង់មើលចំណុចខ្លាំងនិងចំណុចខ្សោយរបស់លោក ។ អ៊ូបៃឌុលឡោះហ្វ៍បានជ្រើសមីក្ទូល់ បម្រើម្នាក់ដើម្បីបំពេញបេសកកម្មនេះ ។ អ៊ូបៃឌុលឡោះហ្វ៍បានឲ្យប្រាក់មីក្ទូល់មួយចំនួន ដាក់បញ្ហាឲ្យមីក្ទូល់ទាក់ទងសមាជិកសំខាន់របស់បដិវត្តន៍ដោយថាខ្លួនជាអ្នកស្រឡាញ់អាស្ហ៍លុល-បៃត៍عليهم السلام ថាគាត់មកគូហ្វាស់នេះព្រោះតែបានឮការប្រកាសរបស់អ៊ីម៉ាំអាល់-ហ៊្សៃន៍صلوات الله عليه والسلام ។

ដំបូងមីក្ទូល់បានចូលដល់មុស្លីម អ៊ីបនូ អៅ្សាយ៉ាស់ បានចុះចូលខ្លួនដោយបន្លំ ។ អកុសល មុស្លីម អ៊ីបនូ អៅ្សាយ៉ាស់ បានធ្លាក់ក្នុងអន្ទាក់គេ បានប្រាប់មីក្ទូល់ឲ្យដឹងទីសម្នាក់របស់មុស្លីម អ៊ីបនូ អាគ្ទីល ។ ដូច្នេះមីក្ទូល់បានចេញចូលកន្លែងនោះតាមចិត្ត បានដឹងសព្វគ្រប់អំពីបដិវត្តន៍ បានធ្វើរបាយការណ៍ប្រាប់ម្ចាស់ខ្លួន កូនរបស់ម៉ារយ៉ាណាស់ ។[172]

ដំណាក់ការទីពីរ ដែលជាវិធានការគ្រោះថ្នាក់បំផុតនោះ គឺការចាប់ខ្លួនហានី អ៊ីបនូ អ៊ូរវ៉ាស់ មេដឹកនាំ បានី មីស្ហាយ៉ី (المذحج) - អ្នកស្រុកគូហ្វាស់ភាគច្រើន ។ វិធានការនេះធ្វើឲ្យប្រជារាស្ត្រតក់ស្លុតខ្លាំង ហើយបានវាយប្រហារកម្ទេចចលនាបដិវត្តន៍ដែលគេរង់ចាំនោះ ។

នៅចំពោះមុខអ៊ូបៃឌុលឡោះហ្វ៍ ហានីបានឆ្លើយបដិសេធការចោទប្រកាន់ ។ ដូច្នេះ ពួកគេបានកោះហៅមីក្ទូល់ ចារបុរស មកធ្វើសាក្សី ។ តែ

[172] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាស្ទៀរ *អាល់-តារិក្* ក្បាលទី ៣ ទំព័រ ២៦៩ ។

ហ្វានីមិនព្រមបោះបង់ចោលមិត្តលោកទៅក្នុងកណ្ដាប់ដៃអាជ្ញាធរទេ ។ តែបុរសកំណាចបញ្ជាឲ្យបម្រើនាំហ្វានីមកក្បែរខ្លួន ហើយបានវាយលើមុខហ្វានីដោយដំបងក្នុងដៃ ។ បន្ទាប់មកបានបញ្ជាឲ្យឃុំខ្លួនទុកក្នុងបន្ទប់មួយក្នុងវាំងនោះ ។[173]

វិធានការនេះបានធ្វើឲ្យបក្សពួករបស់ហ្វានីបាក់ទឹកចិត្ត ដោយមាន អុំរ៉ូ អ៊ីបនូ អាល់-ហាច់យ៉ាច់ បុគ្គលច្បត់ជាមេដឹកនាំ បានជម្រុញឲ្យពួកគេទៅឯវាំង ។ អុំរ៉ូបានស្រែកដើម្បីឲ្យអ៊ូបៃឌុលឡោះហ្វ៍ឮ ថា៖ "ខ្ញុំអុំរ៉ូ នេះគឺអ្នកមានមុខមាត់និងមេដឹកនាំ បានី មីស្ហាច់ ។ យើងមិនបដិសេធចុះចូលខ្លួនចំពោះលោកទេ មិនបះបោរប្រឆាំងលោកទេ ។"

ម្យ៉ាងទៀត អុំរ៉ូសូមចុះចាញ់ សូមដាក់ខ្លួន តែអ៊ូបៃឌុលឡោះហ្វ៍មិនអើពើទេ ។ បន្ទាប់ពីនោះ អ៊ូបៃឌុលឡោះហ្វ៍បានឲ្យស៊ូរ៉យ់ហ្វ៍ (شريح) ចៅក្រម ទៅជួបហ្វានី បន្ទាប់ពីនោះឲ្យប្រកាសប្រាប់ជនរួមកុលសម្ព័ន្ធលោកអំពីស្ថានការលោក ។ ចៅក្រមបានចូលក្នុងបន្ទប់ឃុំឃាំងហ្វានីៗបានស្រែកថា៖ "ចម្លែកមែន ! តើប្រជារាស្ត្រខ្ញុំស្លាប់អស់ហើយឬ ? ប្រសិនបើមានជនរួមកុលសម្ព័ន្ធខ្ញុំតែដប់នាក់ ពួកគេប្រាកដជាអាចជួយខ្ញុំបាន ។"

ពេលស៊ូរ៉យ់ហ្វ៍ទៅវិញ គាត់បានប្រាប់កប្បពួករបស់ហ្វានីថា៖ "ខ្ញុំបានជួបចៅហ្វាយរបស់អស់លោក ។ គាត់នៅរស់ទេ ។ គាត់បានដាក់បញ្ជាឲ្យអស់លោកត្រឡប់ទៅផ្ទះវិញ ។" អុំរ៉ូបានស្រែកថា៖ "ល្អ លោកមិនត្រូវស្លាប់ទេ ។ សូមអរព្រះគុណអល់ឡោះហ្វ៍ !"

ហាក់ដូចជាគេបានបើកឱកាសតែមួយគត់ឲ្យពួកគេរត់គេចខ្លួនពីគុកងងឹត ពួកកុលសម្ព័ន្ធមីស្ហាច់ក៏បានបែរក្រោយរត់គេចខ្លួន ។ ប្រហែលជាមានការព្រមព្រៀងគ្នាជាសម្ងាត់រវាងពួកមេដឹកនាំកុលសម្ព័ន្ធមីស្ហាច់ និងអ៊ូបៃឌុលឡោះហ្វ៍ក្នុងការសម្លាប់ហ្វានី ពុំនោះទេពួកគេប្រាកដជាវាយលុកវាំង រំដោះមេដឹកនាំពួកគេជាមិនខាន ។

មុស្លីម អ៊ីបនូ អាគ្វីលបានដឹងស្ថានភាពរបស់ហ្វានីដែលជាសមាជិក

---

[173] សូមមើលសៀវភៅរបស់លោក អាល់-ម៉ាស់អ៊ូឌី (المسعودي) *ម្រូច អាល់-ស្ហាហ្វាប់ (مُروجُ الذَّهَب)*, ក្បាលទី ៣ ទំព័រ ៧ ។

សំខាន់ម្នាក់របស់បដិវត្តន៍ ក៏បានប្រកាសបដិវត្តន៍ជាសាធារណៈប្រឆាំងទល់នឹងអ៊្ហូបៃខ្ទុលឡោះហ្វ៍ ។ ដូច្នេះ យុទ្ធជនចំនួនបួនឬសែសិបពាន់នាក់បានចូលរួមជាមួយលោក ។[174]

អ៊្ហូបៃខ្ទុលឡោះហ្វ៍បានថ្លែងសុន្ទរកថាមួយ ពេលបានឮដំណឹងថាការបះបោរមានកំណើន ហើយសំដៅមុខព្រួញមកកាន់វាំងអភិបាលក្រុង ។ ដូចផ្អែកំណាច អ៊្ហូបៃខ្ទុលឡោះហ្វ៍បានប្រញាប់ទៅឯវាំង ។ មានប៉ូលីសនគរបាលតែសាមសិបនាក់ទេ ដូច្នេះអ៊្ហូបៃខ្ទុលឡោះហ្វ៍ត្រូវតែប្រើមធ្យោបាយថោកទាបបំផុតដើម្បីរំដោះខ្លួន គឺសង្គ្រាមផ្លូវប្រាសាទ ។[175] ព្រោះតែគាត់ស្គាល់អ្នកស្រុកគូហ្វាស់ច្បាស់ណាស់ បានជាគាត់បញ្ជាឲ្យមេដឹកនាំរបស់អ្នកស្រុកគូហ្វាស់ដែលពូកែក្បត់ដាច់គេ លួចចូលទៅក្នុងទ័ពរបស់មុស្លីមដើម្បីផ្សាយដំណឹងចចាមអារ៉ាមថាកងទ័ពស៊ីរីធ្វើទណ្ឌកម្មពួកដែលចូលដៃជាមួយកងទ័ពរបស់មុស្លីម រដ្ឋបាលនឹងកាត់ប្រាក់ខែពួកគេ ហើយគេនឹងប្រើច្បាប់អាជ្ញាសឹកលើពួកគេ ។ ពាក្យចចាមអារ៉ាមទាំងនេះមានប្រសិទ្ធិភាពដូចគ្រាប់ផ្ទុះនៅពីក្បាលប្រជារាស្ត្រៗ ក៏បានថា៖ "យើងគួរតែកុំប្រថុយខ្លួនក្នុងរឿងនយោបាយ ។"[176]

មិនយូរប៉ុន្មាន ពួកគេភាគច្រើនបានបោះបង់មុស្លីមៗបាននាំបក្សពួកដែលនៅសល់ទៅស្វ៍ឡាត្ញុំឯម៉ាស់យ៊ិដ្ឋ ។ ក្នុងពេលស្វ៍ឡាត្ញុំនេះដែរ បក្សពួកឯទៀតបានចាកចោល ពេលមុស្លីមស្វ៍ឡាត្ញុំចប់ ឃើញមាននៅសល់តែលោកម្នាក់ឯង[177] ។ យប់នោះ លោករកផ្ទះសម្នាក់មិនបានទេ ។ ដូច្នេះ

---

[174] សៀវភៅរបស់លោក អ៊ីបនូ អាល់-ហាយ៉ារ អាល់-អាស់ក៏ឡានី *តាស់ស៊ីប អាល់-តាស់ស៊ីប (تهذيب التهذيب)* ក្បាលទី ២ ទំព័រ ៣៥១ ។

[175] សូមមើលសៀវភៅរបស់លោក អ៊ីបនូ គូស្ស៊ែរ *អាល់-ប៊ីដាយ៉ាស់ វ៉ា អាល់-នីហ្វាយ៉ាស់ (البداية والنهاية)* ក្បាលទី ៨ ទំព័រ ១៥៤ ។

[176] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាល់-អាស្ទៀរ *អាល់-តារិក្* ក្បាលទី ៣ ទំព័រ ២៦៩ ។

[177] សូមមើលសៀវភៅរបស់លោក អាប៊ុល-ហ្វីដាអ៊ុំ (أبو الفداء) *អាល់-មុក្តាស្វារ ហ្វី អាក់បារ អាល់-បាស្ហារ (المختصر في أخبار البشر)* ក្បាលទី ១ ទំព័រ ៣០០ ។

លោកចាំបាច់ត្រូវដើរឥតទីដៅតាមផ្លូវគូហ្វាស់ ។
មានតែនារីថ្លៃថ្នូរម្នាក់ទេ មាននាមថាតៅអាស់ ដែលក្លាហានហ៊ានឲ្យមុស្លីចូលផ្ទះ ។ ពេលស្ត្រីរូបនេះលើកបាយមកឲ្យមុស្លីមបរិភោគ លោកមិនទទួលទានទេ មិនផឹកទឹកទេព្រោះលោកគិតដល់ជោគវាសនាដែលអ៊ីម៉ាំអាល់-ហ៊្វូសៃន៍ﷺនឹងជួបប្រទះ ក្រោយពីប្រជារាស្ត្រនោះបានក្បត់ ។ កូនរបស់លោកស្រីតៅអាស់ទើបតែបានដឹងរឿងសព្វគ្រប់ ។ ព្រឹកឡើងពេលថ្ងៃទើបនឹងរះ គាត់ប្រញាប់ទៅរាយការណ៍ប្រាប់អាជ្ញាធរអំពីរឿងនេះ ទោះបីលោកបានស្បថយ៉ាងម៉ឺងម៉ាត់ជាមួយម្ដាយហើយ ថានឹងមិនប្រាប់គេឲ្យដឹងរឿងនេះទេក៏ដោយ ។
កងទ័ពសេះបីរយនាក់ ដឹកនាំដោយ មូហ្ហាំម៉ាដ្ទ អ៊ីបនូ អាល់-អាស្វ៉ាស្វ៍ បានវាយលុកផ្ទះអ្នកស្រីតៅអាស់ តែមុស្លីមបានវាយតទល់ពួកគេដោយសេចក្ដីក្លាហានឥតប្រៀបបាន សេចក្ដីក្លាហានដែលជាកេរដំណែលពីដូនតាលោក[178] ។ លោកម្នាក់ឯងអាចបង្ក្រាបទាហានសេះ បានសម្លាប់ពួកយោធិនបានយ៉ាងច្រើន ។ បុគ្គលកំណាចបានចោលដុំថ្មនិងដុំភ្លើងមកលើលោក ពួកសត្រូវក៏មានប្រៀបលើលោក ។[179]
ពេលមូហ្ហាំម៉ាដ្ទ អ៊ីបនូ អាល់-អាស្វ៉ាស្វ៍ ត្រឡប់ទៅជួបអ៊ូបៃឌុលឡោះហ្វ៍វិញ បានសូមទ័ពនិងអាវុធបន្ថែម តែអ៊ូបៃឌុលឡោះហ្វ៍បានឆ្លើយតបវិញដោយញ័រខ្លួនថា៖ "ខ្ញុំបានចាត់បញ្ជូនលោកទៅចាប់មនុស្សម្នាក់ តែអ្នកនោះបានធ្វើបែបនេះមកលើទ័ពលោក !" មូហ្ហាំម៉ាដ្ទ អ៊ីបនូ អាល់-អាស្វ៉ាស្វ៍បានតបវិញថា៖ "លោកគិតថាលោកបានចាត់បញ្ជូនខ្ញុំទៅចាប់អ្នកស្រុកគូហ្វាស់សាមញ្ញ ឬអ្នកស្រុកជិតខាងឬ ? លោកបានបញ្ជូនខ្ញុំទៅ

[178] សូមមើលសៀវភៅរបស់លោក បាហ្វាអ៊ុ អាល់-ឌីន អ៊ុលី អ៊ីបនូ អ៊ុប់ដ្វាល់-ការីម (بهاء الدين علي بن عبد الكريم) *អាល់-ឌូរ អាល់-ណាឌីដ្ទ ហ្វី អាត់-តាអ៊ុស្ស៊ី អាល់-អ៊ីម៉ាំ ស្វាហ៊ីដ្ទ* ទំព័រ ១៦៤ ។
[179] សូមសៀវភៅរបស់លោក អ៊ីបរ៉ាហ៊ីម អ៊ីបនូ មូហ្ហាំម៉ាដ្ទ អាល់-បៃហ្វាគ្គី (ابراهيم بن محمد البيهقي) *អាល់-ម៉ាហ្វាស៊ីន វ៉ា អាល់-ម៉ាសាវី (المحاسن و المساوئ)* ក្បាលទី ១ ទំព័រ ៤៣ ។

ចាប់រាជសីហ៍ក្លាហាន វីរបុរសត្រកូលអ្នកកាន់ដាវដែឯកល្អប្រសើរដាច់[180]
គេ ។
អ៊្ហូបៃឌុលឡោះហ្ញ៍បានផ្តល់ទ័ពនិងអាវុធបន្ថែមឲ្យមូហ៊ាំម៉ាដ្ទ អ៊ីបនូ អាល់-អាស្វ៉អាស្វ៍ តែមុស្លីម វីរបុរសនៅតែប្រយុទ្ធតទល់ពួកគេយ៉ាងក្លាហាន ។ ការប៉ះទង្គិចគ្នានេះបានប្រព្រឹត្តទៅអស់ពេលយូរ មុស្លីមស្រេកទឹក រីឯទ័ពអាជ្ញាធរបានកើនឡើងជុំវិញលោក ទោះបីពួកគេភ័យខ្លាចវាយលុកមកលើលោកក៏ដោយ ។ ទីបំផុត ពួកគេបានចាក់លោកដោយលំពែងលុះត្រាតែចាប់ខ្លួនលោកបាន ។ បន្ទាប់ពីបានផ្តួលលោក ពួកអ្នកស្រុកគូហ្វាស្ទ់បានប្រជ្រៀតគ្នាមើលគេចាប់លោកយកទៅវាំង ។
មុស្លីមបានបដិសេធយ៉ាងក្លាហាន មិនចុះចូលក្រោមអំណាចបុគ្គលកំណាចជាដាច់ខាត ។ ដោយហេតុនេះ គេបានដាក់បញ្ជាឲ្យប៊ូកៃរ៍ អ៊ីបនូ ហាំរ៉ានដាក់លោកផ្ទាប់នឹងផ្ទៃវាំង ហើយកាត់ក្បាលលោក ។ អ៊្ហូបៃឌុលឡោះហ្ញ៍បានដាក់បញ្ជាឲ្យសម្លាប់ហ្ញានីដែរ នៅពីមុខបណ្តាជនរួមកុលសម្ព័ន្ធលោក ។
សាកសពរបស់មុស្លីមនិងហ្ញានីត្រូវអូសលើដីតាមផ្លូវស្រុកគូហ្វាស្ទ់ ដើម្បីបង្ហាញនូវការបង្ក្រាបការបះបោរ ក្នុងបំណងផ្ចាញ់ផ្ចាលបណ្តាអ្នកគាំទ្រការបះបោរនោះ ។[181]

## ចាកចេញទៅកាន់អ៊ីរ៉ាក់

មុននឹងចាកចេញទៅកាន់ប្រទេសអ៊ីរ៉ាក់ជាមួយព្រះរៀមព្រះនាង ព្រះនាងស្វៃណាប់ﷺបានសូមអនុញ្ញាតពីព្រះស្វាមីព្រះនាង ។ មុនអ៊ីម៉ាំអាល់-ហ៊្វូសៃន៍ﷺចាកចេញទៅប្រទេសអ៊ីរ៉ាក់ អាប់ឌុលឡោះហ្ញ៍ អ៊ីបនូ អាប់បាស់ បងប្អូនជីដូនមួយរបស់ព្រះអង្គ បានសូមឲ្យព្រះអង្គផ្លាស់ប្តូរចិត្ត

---

[180] សូមមើលសៀវភៅរបស់លោក អាប់ឌុលឡោះហ្ញ៍ អាល់-បាស្ទ៉ានី *អាល់-អាក៉ាលីម អាល់-អ៊ីម៉ាំ អាល់-ហ៊្វូសៃន៍* ទំព័រ ២០៣ ។

[181] សូមមើលសៀវភៅរបស់លោក អាស្ទ៉ម៉ាដ្ទ អ៊ីបនូ យ៉ាស្ទ៉យ៉ា អាល់-បាឡាស្ទ៉រី (أحمد بن يحيى البلاذري) *អាន់សាប់ អាល់-អាស្វ៉ារ៉ហ្វ (أنساب الأشراف)* ទំព័រ ៨៣ ។

តែអ៊ីម៉ាំ صلوات الله عليه والسلام បដិសេធ ។ ដូច្នេះ អ៊ីបនូ អ៊ាប់បាស់បានសូមកុំឲ្យព្រះរាជវង្ស និងសមាជិកព្រះរាជវង្សព្រះអង្គតាមព្រះអង្គទៅដែរ តែអ៊ីម៉ាំ صلوات الله عليه والسلام បានតបថា៖ "បុគ្គលទាំងនេះជាបញ្ញើរបស់ព្រះសាសនៈទូត صلى الله عليه وآله وسلم របស់អល់ឡោះហ្ទ៍ عز وجل ខ្ញុំមិនអាចផ្ញើបុគ្គលទាំងនេះជាមួយអ្នកណាបានទេ ។"

ព្រះនាងស្សៃណាប់ سلام الله عليها បានប្រាប់អ៊ីបនូ អ៊ាប់បាស់ទាំងទឹកភ្នែកថា៖ "បុត្ររបស់អ៊ាប់បាស់អឺយ លោកស្នើសូមឲ្យព្រះអគ្គប្រមុខយើងចោលយើងនៅទីនេះ ទៅតែព្រះអង្គឯងឬ? ទេ សូមស្បថចំពោះអល់ឡោះហ្ទ៍ عز وجل យើងរស់នៅជាមួយព្រះអង្គ យើងស្លាប់ជាមួយព្រះអង្គ ។ យើងមិនមានអ្វីនៅសល់ក្រៅពីព្រះអង្គទេ ។"[182]

អ៊ាប់ឌុលឡោះហ្ទ៍ អ៊ីបនូ អ៊ាប់បាស់មិនអាចទប់ចិត្តបានទេ ពេលលោកស្រក់ទឹកភ្នែក លោកបានថា៖ "ទូលបង្គំពិបាកបណ្តោយឲ្យព្រះអង្គ صلوات الله عليه والسلام ទៅណាស់ ។"

ផែនការបដិវត្តន៍របស់អ៊ីម៉ាំអាល់-ហ៊្សៃន៍ صلوات الله عليه والسلام ដ៏ល្អមួយគឺ ព្រះរាជវង្សព្រះអង្គនៅជាមួយព្រះអង្គ ជាពិសេសព្រះនាងស្សៃណាប់ سلام الله عليها ដែលមានមុខនាទីដឹកនាំនៅក្នុងវិធានការប្រតិបត្តិបដិវត្តន៍នេះ នៅជាប់ជាមួយព្រះអង្គ ។ ព្រះអង្គបានគិតគូរជាមុនអំពីព្រឹត្តិការណ៍ដែលនឹងកើតឡើងនៅខាងមុខ ដូច្នេះឯងបានជាព្រះអង្គរៀបផែនការឲ្យព្រះអនុជាព្រះអង្គទទួលមុខនាទីថ្លៃថ្នូរ ក្នុងការធ្វើឲ្យការបះបោររបស់ព្រះអង្គនោះមានសុក្រឹតភាព ដោយបង្ហាញឲ្យគេឃើញការលះបង់របស់ព្រះអង្គ ដើម្បីនឹងធ្វើឲ្យពួកកាន់អំណាច់ផ្តាច់ការអ៊ូម៉ៃយ៉ាស្ទ៍ដែលព្យាយាមបិទបាំងវានោះបរាជ័យ ហើយធ្វើឲ្យគោលការណ៍និងគោលដៅព្រះអង្គវាតចលនាសុសសាយ ។

ការពិត ក្រុមព្រះរាជវង្សរបស់អ៊ីម៉ាំ صلوات الله عليه والسلام បានចូលរួមយ៉ាងសកម្មក្នុងបុនរុឌ្ឍិ (គឺក្នុងការដុះដាល រីកចម្រើនឡើងវិញ) នៃសង្គមមុស្លីម និងក្នុងការរំលំកិត្យានុភាពកាឡៃរបស់របបអ៊ូម៉ៃយ៉ាស្ទ៍ ។ តាមរយៈសាទរកថា (គឺពាក្យពេជន៍ប្រកបដោយសេចក្តីរំជួល) ក្រុមព្រះរាជវង្សរបស់អ៊ីម៉ាំ صلوات الله عليه والسلام

---

[182] សូមមើលសៀវភៅរបស់ សៃយីដ្ទ ហ្ទាស្ទីម អាល់-បាស្ទ៍រ៉នី *ម៉ាឌីណាស្ទ៍ អាល់-ម៉ាអ៊ាយ៉ីស្ទ៍ (مدينة المعاجز)* ក្បាលទី ៣ ទំព័រ ៤៨៥ ។

បានផ្ដើមធ្វើបដិវត្តន៍ប្រឆាំងរបប និងធ្វើឲ្យរដ្ឋខុសច្បាប់ទាំងមូលរបស់ពួកគេរង្គោះរង្គើ ។

អំពីចំណុចនេះ លោក មូហ្ាំម៉ាដ្ ហ៊ូសែន៍ កាស្ហ៊ីហ្វ អាល់-គ៊ីត៍អ៊ ( محمد حسين كاشِف الغِطاء) បានឲ្យដឹងថា៖ "តើមិនមានអ្នកណាជឿហេតុការណ៍នេះទេ គឺហេតុការណ៍ដែល ប្រសិនបើបណ្ដាស្ត្រី - ដែលជាព្រះរាជវង្សរបស់ព្រះសាស្ដាصلى الله عليه وآله وسلمនោះ - ពុំបានប្រឆាំងជំទាស់របបកាន់ក្ដាប់អំណាច តាមរយៈព្រឹត្តិការណ៍និងពាក្យពេជន៍នានាទេនោះ ឈាមអ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامនិងបណ្ដារាជបុត្ររបស់ព្រះអង្គصلوات الله عليه والسلام បានហូរស្រក់មកឥតប្រយោជន៍ ហើយពុំមានអ្នកណាមួយទាមទារការផ្ដន្ទាទោសពួកឃាតករទេ ចំណែកឯបដិវត្តន៍ព្រះអង្គصلوات الله عليه والسلامក៏ទៅជាមោឃៈអសាបង់ ? អំពីរឿងនេះ អ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامបានរៀបចំកំណាក់ការនេះរួចស្រេចហើយ ។ ព្រះអង្គصلوات الله عليه والسلامបានដឹងច្បាស់ជាមុនហើយថាពុំមានអ្នកណាមានសមត្ថភាពបំពេញបេសកកម្មនេះបានយ៉ាងល្អបំផុតទេ ក្រៅពីបណ្ដាស្ត្រីទាំងនោះ ។ ដូច្នេះឯងបានជាព្រះអង្គصلوات الله عليه والسلامសូមឲ្យបណ្ដាស្ត្រីទាំងនោះទៅជាមួយព្រះអង្គصلوات الله عليه والسلام ដើម្បីបន្ថែមនូវកត្តាមួយទៀតទៅក្នុងអំណាចគាបសង្កត់ដែលពួកកំណាចទាំងនោះនឹងពើបពះ កត្តានោះគឺពេលបណ្ដាស្ត្រីទាំងនោះត្រូវគេចាប់ខ្លួនជាឈ្លើយ ។ ម្យ៉ាងទៀត គោលបំណងរបស់អ៊ីម៉ាំصلوات الله عليه والسلامនៅពីក្រោយការឲ្យបណ្ដាស្ត្រីទៅជាមួយនេះ មានជម្រៅជ្រៅហើយមានគោលដៅនយោបាយ ។ ព្រះអង្គصلوات الله عليه والسلامមានបំណងឲ្យបណ្ដាស្ត្រីទាំងនោះធ្វើបដិវត្តន៍របស់ព្រះអង្គصلوات الله عليه والسلام និងរំលំរបបមិនស្របច្បាប់របស់ពួកកាន់ក្ដាប់ត្រកូលអ៊ូម៉ៃយ៉ាស្ម៉ មុនពួកគេនឹងកម្ចាត់អ៊ីស្លាមផ្ដាច់ឫស ហើយដឹកនាំប្រជារាស្ត្រទៅរកទំនៀមទម្លាប់ និងប្រពៃណីបុរាណសម័យមុនអ៊ីស្លាមវិញ ។"[183]

លោកបណ្ឌិត អាស្ម៉ាដ្ ម៉ាស្ម៉ូដ្ ស្ហ៊ុបហ៊ីបានឲ្យដឹងថា៖ "អាល់-ហ៊ូសែន៍صلوات الله عليه والسلامទទូចសូមឲ្យព្រះរាជវង្ស និងសមាជិកព្រះរាជវង្សព្រះអង្គទៅជាមួយ

---

[183] សូមមើលសៀវភៅរបស់លោក មូហ្ាំម៉ាដ្ ហ៊ូសែន៍ កាស្ហ៊ីហ្វ អាល់-គ៊ីត៍អ៊ ( محمد حسين كاشِف الغِطاء) *អាល់-ស៊ីយ៉ាសាស្ម៉ អាល់-ហ៊ូសែនីយ៉ាស្ម៉* ទំព័រ ៤៦-៤៧ ។

ព្រះអង្គដើម្បីនឹងឲ្យមនុស្សឃើញផ្ទាល់ភ្នែកថា ពួកសត្រូវរបស់ព្រះអង្គទាំងអស់عليهم السلامបានប្រព្រឹត្តអំពើឧក្រិដ្ឋដែលមិនអាចអត់ឱនឲ្យបាន និងអមនុស្សធម៌មកលើព្រះអង្គទាំងអស់គ្នាعليهم السلام ។ អាស្រ័យលើការសម្រេចចិត្តនេះ អ៊ីម៉ាំصلوات الله عليه والسلامបានតស៊ូ បានបះបោរដើម្បីករណីមួយដែលនឹងមិនរលាយសាបសូន្យបាត់បង់ទៅក្នុងវាលខ្សាច់ ជាមួយឈាមព្រះអង្គصلوات الله عليه والسلامនោះទេ ។ បើពុំមានព្រះរាជវង្សនិងសមាជិកព្រះរាជវង្សព្រះអង្គصلوات الله عليه والسلامទេ ឧប្បត្តិហេតុទាំងអស់ដែលបានកើតឡើងចំពោះអាល់-ហ៊្វសែន៍صلوات الله عليه والسلام និងបណ្ដាសត្រូវរបស់ព្រះអង្គصلوات الله عليه والسلامនោះនឹងត្រូវគេក្លែងបន្លំ បំភ្លៃទាំងអស់ ហើយភ័ស្តុតាងសាក្សីទាំងអស់នឹងទៅជាមោឃៈ ឥតប្រយោជន៍ ។"

លោកស្រី បណ្ឌិត អ៊ៃស្ហាស់ ប៊ិនទី អាល់-ស្ហាទី មានប្រសាសន៍ថា៖ "ស៊ៃណាប់ ប្អូនស្រីរបស់អាល់-ហ៊្វសែន៍ បានធ្វើឲ្យអ៊ូបៃឌុលឡោះហ្វ៍ អ៊ីបនូស៊ីយ៉ាដ្វ៍ និងត្រកូលអ៊ូម៉ៃយ៉ាស្វ៍បាត់បង់ការត្រេកអរនឹងជ័យជំនះ ព្រោះព្រះនាងបានរោយថ្នាំពិសកំណាចទៅក្នុងកែវទឹកពួកគេ ។ ព្រឹត្តិការណ៍ទាំងអស់ដែលបានកើតឡើងក្រោយពីនោះ ដូចជាការបះបោររបស់អាល់-មុខ្តារ និងបដិវត្តន៍របស់ អ៊ាប់ឌុលឡោះហ្វ៍ អ៊ីបនូ អាល់-ស៊្ហបៃរ៍ ជាដើម បណ្ដាលឲ្យរបបអ៊ូម៉ៃយ៉ាស្វ៍អន់ថយ បណ្ដាលឲ្យត្រកូលអ៊ាបាស៊ីយ៉ាស្វ៍ឡើងកាន់អំណាច បណ្ដាលឲ្យស្ហ៊ីអាស្វ៍កាន់តែមានភាពមាំមួន - ព្រឹត្តការណ៍ទាំងនេះបណ្ដាលមកពីក្រុមស៊ៃណាប់ ។"[184]

និយាយសង្ខេប បើពុំមានព្រះនាងស៊ៃណាប់سلام الله عليهاទេ ប្រវត្តិសាស្ត្រខ្លោចផ្សានៅការបាឡាអ៍ប្រាកដជាត្រូវចារទុក តាមតែសម្ដីរបស់ពួកសត្រូវរបស់អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلامទេ រីឯឈាមបរិសុទ្ធរបស់អ៊ីម៉ាំ របស់សាច់ញាតិព្រះអង្គصلوات الله عليه والسلام របស់បណ្ដាសាវកព្រះអង្គصلوات الله عليه والسلام ដែលបានហូរស្រក់មកដោយមិនសមហេតុ មិនសមផលនៅទីនោះនោះ ប្រាកដជាបាត់អស់ទៅក្នុងវាលខ្សាច់ជាមិនខាន ។

ទោះជាយ៉ាងណាក៏ដោយ មុនព្រះអង្គصلوات الله عليه والسلامចាកចេញពីម៉ាក់កាស្វ៍ អ៊ីម៉ាំ

---

[184] សូមមើលសៀវភៅរបស់លោកស្រី អ៊ៃស្ហាស់ ប៊ិនទី អាល់-ស្ហាទី *Zaynab, the Heroine of Karbala (ស៊ៃណាប់ វីរនារីនៃនគរការបាឡាអ៍)* ។

អាល់-ហ៊្វសែន៍صلوات الله عليه والسلامបានកោះហៅប្រជុំជាទូទៅ នៅក្នុងអង្គប្រជុំនោះព្រះអង្គصلوات الله عليه والسلامមានវចនៈថា៖

اَلْحَمْدُ لِلّٰهِ وَ مَا شَاءَ اللّٰهُ وَ لَا حَوْلَ وَ لَا قُوَّةَ إِلَّا بِاللّٰهِ وَ صَلَّى اللّٰهُ عَلٰى رَسُولِه وَ سَلَّمَ خُطَّ الْمَوْتُ عَلٰى وُلْدِ آدَمَ مَخَطَّ الْقِلَادَة عَلٰى جِيْدِ الْفَتَاة وَ مَا أَوْلَهَنِي إِلٰى أَسْلَافِي اشْتِيَاقَ يَعْقُوبَ إِلٰى يُوسُفَ وَ خُيِّرَ لِي مَصْرَعٌ أَنَا لَاقِيْهِ كَأَنِّي بِأَوْصَالِيْ تُقَطِّعُهَا عُسْلَانُ الْفَلَوَاتِ بَيْنَ النَّوَاوِيْسِ وَ كَرْبَلَاءَ فَيَمْلَأَنَّ مِنِّي أَكْرَاشًا جُوفًا وَ أَجْرِبَة سُغْبًا لَا مَحِيْصَ عَنْ يَوْمٍ خُطَّ بِالْقَلَمِ.

رِضَا اللّٰهِ رِضَانَا أَهْلَ الْبَيْتِ نَصْبِرُ عَلٰى بَلَائِه وَ يُوَفِّيْنَا أُجُوْرَ الصَّابِرِيْنَ لَنْ تَشُذَّ عَنْ رَسُولِ اللّٰهِ ((صلى الله عليه و آله و سلم)) لَحْمَتُه وَ هِيَ مَجْمُوعَة لَه فِي حَضِيْرَة الْقُدْسِ تَقَرُّ بِهِمْ عَيْنُه وَ يُنْجِزُ بِهِمْ وَعْدَهُ . مَنْ كَانَ بَاذِلًا مُهْجَتَه مُوَطِّنًا عَلٰى لِقَاءِ اللّٰهِ نَفْسَه فَلْيَرْحَلْ مَعَنَا فَإِنِّي رَاحِلٌ مُصْبِحًا إِنْ شَاءَ اللّٰهُ تَعَالٰي.

*"សូមថ្វាយថោមនាការចំពោះអល់ឡោះហ្ទ៍عز وجل មានតែអ្វីដែលអល់ឡោះហ្ទ៍عز وجلមានព្រះបំណងឲ្យកើតឡើងទេដែលនឹងកើតឡើងបាន កម្លាំងពលំទាំងអស់នៅលើអល់ឡោះហ្ទ៍عز وجل សូមអល់ឡោះហ្ទ៍عز وجلប្រោសប្រណីមេត្តានិងប្រទានពរជ័យដល់ព្រះសាសនៈទូតصلى الله عليه وآله وسلمរបស់ព្រះអង្គعز وجل ។ ការស្លាប់ត្រូវបានគូសគូរសម្រាប់មនុស្សគ្រប់រូបដូចៗគ្នា ដូចខ្សែកធ្វើឲ្យមានស្នាមនៅលើដើមកក្មេងស្រី ។ សម្រាប់ខ្ញុំ បំណងខ្ញុំដែលចង់ជួបជុំដូនតាខ្ញុំដែលជាទុក្ករបុគ្គលនោះ ដូចបំណងរបស់ព្រះសាស្តាយ៉ាក៉ូគូបعليه السلامចង់ឃើញយូស៊ុហ្វعليه السلام ព្រះរាជបុត្រព្រះអង្គ[ដែលបានបាត់ខ្លួន]នោះដែរ ។ ខ្ញុំនឹងបានជួបអវសានដែលគេបានជ្រើសរើសឲ្យខ្ញុំជាមិនខាន ។ ខ្ញុំមើលឃើញមុនថាអវយវៈ និងសរីរាង្គរបស់ខ្ញុំនឹងត្រូវពួកឆ្កែព្រៃវាលខ្សាច់[185] កាត់នៅឯកន្លែងមួយចន្លោះអាល់-ណាវ៉ាវីសនិងការបាឡាអ៊្ ពួកវានឹងបំពេញពោះស្រេកឃ្លានរបស់ពួកវាដោយខ្លួនខ្ញុំនៅទីនោះ ។ ពុំមានអ្នកណាមួយ*

[185] មានន័យថា ពួកដែលប្រយុទ្ធទល់នឹងខ្ញុំនោះសាហាវនិងឃោរឃៅព្រៃផ្សៃដូចឆ្កែព្រៃ ។

*អាចចៀសរួចពីអ្វីដែលស្លាប់ប៉ាកកាបានចារហើយនោះទេ*[186] *។*
*មានតែអ្វីដែលសព្វព្រះហឫទ័យអល់ឡោះហ៑ عزوجل ទេដែលគាប់ចិត្តយើង - អាស្ស៊ុលុល-បៃត៑ عليهم السلام - យើងអត់ទ្រាំនឹងការល្បងពិសោធន៍របស់ព្រះអង្គ عزوجل (ដែលព្រះអង្គ عزوجل ដាក់មកជាទុក្ខវេទនាជាដើម) ព្រះអង្គ عزوجل ច្បាស់ជាតបស្នង យើងមិនខ្វះឡើយដោយរង្វាន់សម្រាប់អ្នកអត់ធ្មត់ ។ សាច់របស់ព្រះសាសនៈទូត صلى الله عليه وآله وسلم របស់អល់ឡោះហ៑ عزوجل - សូមសិរីសួស្តីកើតមានដល់ព្រះអង្គ صلى الله عليه وآله وسلم និងព្រះរាជកុលដ្ឋាន عليهم السلام ព្រះអង្គ صلى الله عليه وآله وسلم - នឹងមិនដើរខុសមាគ៌ាព្រះអង្គ صلى الله عليه وآله وسلم ទេ នឹងស្ថិតនៅលើគោលជំហារពិសិដ្ឋដូចព្រះអង្គ صلى الله عليه وآله وسلم ដែរដើម្បីផ្គាប់ព្រះអង្គ صلى الله عليه وآله وسلم ហើយនឹងធ្វើតាមសន្យាដែលបានសន្យាជាមួយព្រះអង្គ صلى الله عليه وآله وسلم ។ ហេតុដូច្នេះ អ្នកណាលះបង់ខ្លួនដើម្បីយើង ប្តេជ្ញាចិត្តចង់ជួបអល់ឡោះហ៑ عزوجل ចូរអ្នកនោះធ្វើដំណើរទៅជាមួយខ្ញុំ ។ ស្អែកព្រឹកខ្ញុំនឹងចេញដំណើរ បើអល់ឡោះហ៑ تعالى មានព្រះបំណងដូច្នេះមែន*[187] *។"*

ពេលជិតចេញពីម៉ាក់កាស្ហ៑ អ៊ីម៉ាំអាល់-ហ៊្វសែន៑ صلوات الله عليه والسلام បានទៅឯព្រះមហាគ្រឹះ (កាក់បាស្ហ៑) បានស្វ៑ឡាត់ស្វ៑ហ្វ៑រ៍នៅទីនោះ ។ ថ្ងៃទី ៨ ខែស៊្វុល-ហ៊ិច្ចយ៉ាស្ហ៑ ឆ្នាំ ៦០ ហ៊ិច្ចរ៉ោះត៑សករាជ ព្រះអង្គ صلوات الله عليه والسلام បានចេញដំណើរពីម៉ាក់កាស្ហ៑ អ្នកស្រុកម៉ាក់កាស្ហ៑ឃើញព្រះអង្គ صلوات الله عليه والسلام ស្រក់ទឹកភ្នែក ចិត្តក្រៀមក្រំ ។ តាមផ្លូវព្រះអង្គ صلوات الله عليه والسلام តែងតែនិយាយរឿងព្រះសាស្តាយ៉ាស៊្ហ៑យ៉ា عليه السلام ធ្វើទុក្ករកម្ម ។

ដល់កន្លែងមួយដែលគេហៅថា អាល់-ស៊ីហ្វាស្ហ៑ អ៊ីម៉ាំអាល់-ហ៊្វសែន៑ صلوات الله عليه والسلام បានជួបអាល់-ហ្វារ៉ស្ហ៑ដ្ហាក់ កវីល្បីម្នាក់ បានប្រាប់គាត់ថាអាជ្ញាធរកាន់អំណាចបានរៀបផែនការធ្វើគុតព្រះអង្គ صلوات الله عليه والسلام នៅឯម៉ាក់កាស្ហ៑[188] ។ អ៊ីម៉ាំ

[186] ស្តីអំពីព្រះអភិញ្ញាទាំងស្រុងរបស់អល់ឡោះហ៑ عزوجل ។

[187] សូមមើលសៀវភៅរបស់លោក អ៊ាលី អ៊ីបនូ អាប៊ុល-ហ្វាត់ហ៑ អាល់-អៀរបាលី *កាស្ហ៑ហ្វ៑ អាល់-គ៊ម៉្មាស្ហ៑ ហ្វី ម៉ាក់រីហ្វាស្ហ៑ អាល់-អាអ៊ីម៉្មាស់ (كشفُ الغُمَّة فى مَعرِفَةِ الأئمّة)* ក្បាលទី ២ ទំព័រ ២៣៩ ។

[188] សូមមើលសៀវភៅរបស់លោក ខ៊ លីហ្វាស្ហ៑ អ៊ីបនូ ខ៊យ៉ាត្ហ៑ អាល់-អ៊ាស្ហ៑ហ្វារី (خليفة بن خياط العصفري) *តារិក្ហ៑ ខ៊លីហ្វាស្ហ៑ អ៊ីបនូ ខ៊យ៉ាត្ហ៑ (تاريخ خليفة بن خياط)* ទំព័រ

صلوات الله عليه والسلامបានសួរគាត់អំពីស្ថានភាពអ្នកស្រុកគូហ្វាស់ ដែលគាត់ទើបនឹងចាកចេញមកនោះ ។ អាល់-ហ្វារ៉ស្ស៍ដ្ឋាក្ក៍បានទូលថា៖ "ចិត្តពួកគេនៅខាងព្រះអង្គصلوات الله عليه والسلام តែដាវពួកគេភ្ជង់មករកព្រះអង្គصلوات الله عليه والسلام[189] ។" ព្រះអង្គصلوات الله عليه والسلامយល់ឃើញដូចគាត់ដែរ តែព្រះអង្គصلوات الله عليه والسلامធ្វើដំណើរបន្តយ៉ាងមុតមាំ ។

ដល់កន្លែងមួយដែលគេហៅថា ស្ទាត់-អៀ្សក្ក៍ (ذات عرق) អ៊ីម៉ាំصلوات الله عليه والسلامបានជួបអាប៊ូ ហៀរ៉េាះត្ត៍ដែលបានសួរព្រះអង្គصلوات الله عليه والسلامថាហេតុអ្វីព្រះអង្គصلوات الله عليه والسلامចាកចេញពីម៉ាក់កាស្ស៍ ។ អ៊ីម៉ាំصلوات الله عليه والسلامបានតបថា៖ "អាប៊ូ ហៀរ៉េាះត្ត៍អើយ ពេលពួកអ៊ូម៉ៃយ៉ាស្ស៍ប្លន់ទ្រព្យសម្បត្តិខ្ញុំ ខ្ញុំអត់ទ្រាំបាន ។ ពេលពួកគេប្រមាទកិត្តិយសខ្ញុំ ខ្ញុំខំអត់ទ្រាំទៀត ។ ពេលពួកគេប៉ងបង្ហូរឈាមខ្ញុំ ខ្ញុំបានគេចរួច ។ សូមស្បថចំពោះអល់ឡោះហ្វ៍عزوجل ខ្ញុំសូមស្បថថា ព្រោះតែបក្សគាបសង្កត់នឹងសម្លាប់ខ្ញុំ បានជាអល់ឡោះហ្វ៍عزوجلនឹងបំបាក់មុខពួកគេ នឹងធ្វើឲ្យដាវមុតកាប់ពួកគេ ។ អល់ឡោះហ្វ៍عزوجلបើកដៃឲ្យពួកកាន់ក្តាប់បំបាក់មុខពួកគេ ទាល់តែអាម៉ាស់លើសពួកអ្នកស្រុកស្ហាបាទៅទៀត ស្រីម្នាក់នឹងកាន់ក្តាប់ពួកគេ នឹងរឹបអូសយកទ្រព្យនិងខ្លួនពួកគេស្រេចតែចិត្ត ។"

បន្ទាប់ពីនោះ អ៊ីម៉ាំصلوات الله عليه والسلامបានលាបុរសនេះដែលមិនយល់អត្ថន័យការគាំទ្រយុត្តិធម៌និងការការពារអ៊ីស្លាម ។

មកដល់កន្លែងមួយដែលគេហៅថា អាល់-ឃូស្សៃមីយ៉ាស្ស៍ ព្រះនាងស្សៃណាប់سلام الله عليهاមកក្បែរអ៊ីម៉ាំصلوات الله عليه والسلام សួរព្រះអង្គصلوات الله عليه والسلامអំពីជោគវាសនារបស់ខ្លួន ។ ព្រះអង្គصلوات الله عليه والسلامបានតបថាព្រះនាងនឹងប្រឈមនឹងឧបសគ្គដ៏លំបាក និងគ្រោះកាច ។ ព្រះអង្គصلوات الله عليه والسلامមានវចនៈថា៖ "ប្អូនអើយ អ្វីដែលត្រូវកើតឡើងនឹងកើតឡើង ។"[190]

---

១៧៦ ។

[189] សូមមើលសៀវភៅរបស់លោក មូហាំម៉ាដ្ឋ៍ អ៊ីបនូ យ៉ាៀរៀរ អាល់-ត្ព៍បារី (محمد بن جرير طبري) *ណាវ៉ាឌៀ្សរ អាល់-មុអ្ជីស្សាត់ (نوادر المعجزات)* ទំព័រ ១០៧ ។

[190] សូមមើលសៀវភៅរបស់លោក ស្សៃខ្ហ៍ អាុលី អាល់-ណាម៉ាស្ស៊ី (شيخ علي نمازي شاهرودي) អាល់-ស្ហាស្ស៍រូឌី *មុសតាដ្ឋ៍រ៉ក់ សាហ្វីណាស្ស៍ អាល់-ប៊ីហ្ការ (مُسْتَدْرَک سَفينة البِحار)* ក្បាលទី ៥ ទំព័រ ៩៥០ ។

មកដល់កន្លែងមួយដែលគេហៅថា ស្ហារូដ្ទ ក្បួនទូរចររបស់អ៊ីម៉ាំصلوات الله عليه والسلامបាន ទទួលដំណឹងអាក្រក់បំផុត មុស្លីម អ៊ីបនូ អាគ្ហ៊ីល បានបូជាជីវិតនៅ គូហ្វាស្ហ ។ ទាំងអស់គ្នាយំ អ៊ីម៉ាំصلوات الله عليه والسلامបានទៅជួបក្រុមគ្រួសាររបស់ ទុក្ករបុរស ហើយបានសួរថា៖ "មុស្លីមបានបូជាជីវិតហើយ តើពេលនេះ អស់លោកគិតយ៉ាងណា ?"

ទាំងអស់គ្នាបានឆ្លើយតបយ៉ាងមុតមាំថា៖ "យើងនឹងមិនត្រឡប់ក្រោយ វិញទេ លុះត្រាតែយើងបានសងសឹកឲ្យលោក ឬទៅតាមលោក ។" សម្ដី នេះបង្ហាញនូវសេចក្ដីប្ដេជ្ញាចិត្តរបស់វីរជនទាំងនេះ ធ្វើឲ្យអ៊ីម៉ាំصلوات الله عليه والسلامកាន់តែ ទុកចិត្តលើបេសកកម្មរបស់ព្រះអង្គصلوات الله عليه والسلام ។

ពេលថ្ងៃត្រង់ អ៊ីម៉ាំអាល់-ហ៊្វូសៃន៍صلوات الله عليه والسلامបានផ្ទំ ហើយបានសុបិនអាក្រក់ ។ ព្រះអង្គصلوات الله عليه والسلامភ្ញាក់ពីផ្ទំវិញដោយភ័យរន្ធត់ ព្រះរាជបុត្រព្រះអង្គصلوات الله عليه والسلام អាគ្ហលី អាក្កបារ៍ ស្ទុះមកសួរព្រះអង្គصلوات الله عليه والسلام ។ អ៊ីម៉ាំصلوات الله عليه والسلامបានប្រាប់ព្រះរាជបុត្រព្រះ អង្គصلوات الله عليه والسلامថាព្រះអង្គصلوات الله عليه والسلامបានឃើញក្នុងសុបិន ទាហានសេះម្នាក់បាន និយាយដាក់ព្រះអង្គصلوات الله عليه والسلامថា៖ "ព្រះអង្គصلوات الله عليه والسلامកំពុងតែបន្តដំណើរ ខណៈ ដែលការស្លាប់នាំព្រះអង្គصلوات الله عليه والسلامទៅកាន់ឋានសួគ៌យ៉ាងលឿន ។" អ៊ីម៉ាំصلوات الله عليه والسلام បានអធិប្បាយសុបិននេះថាពួកគេនឹងត្រូវសម្លាប់ ។

ព្រះរាជបុត្របានសួរថា៖ "តើយើងមិនមែនបក្សត្រឹមត្រូវទេ ?" អ៊ីម៉ាំصلوات الله عليه والسلام បានតបយ៉ាងជឿជាក់ថា៖ "ពិតណាស់ យើងជាបក្សត្រឹមត្រូវ ។ បិតាសូម ស្បថក្នុងព្រះនាមព្រះعزّ وجلّ ដែលសត្វលោកទាំងអស់នឹងវិលត្រឡប់ទៅរក ព្រះអង្គعزّ وجلّវិញនោះ ។" ព្រះរាជបុត្របានទូលថា៖ "ព្រះបិតាអើយ យើងនឹង មិនអើពើអំពីការស្លាប់ឡើយ ។" ពាក្យពេជន៍នេះបានធ្វើឲ្យអ៊ីម៉ាំصلوات الله عليه والسلامធូរ ព្រះហឫទ័យ ព្រះអង្គصلوات الله عليه والسلامបានថ្លែងអំណរគុណចំពោះជំនឿដ៏មាំនេះ[191] ។

មកដល់កន្លែងមួយដែលគេហៅថា ស្ហារ៉ហ្វ អ៊ីម៉ាំصلوات الله عليه والسلامបានបញ្ជាឲ្យ

---

[191] សូមមើលសៀវភៅរបស់លោក មូហ៊ាំម៉ាដ្ទ អ៊ីបនូ យ៉ាហ្ស៊ៀរ អាល់-ត្ហ៍បារី (محمد بن جرير طبري) *តារិក្ហ អាល់-អ៊ូម៉ាំ វ៉ា អាល់-មុលុក (تاريخ الأمم والملوك)*, ក្បាលទី ៤ ទំព័រ ៣០៨; សៀវភៅរបស់លោក អាប៊ុល-ហ្វារ៉ាជ្ហ៍ អាល់-អ៊ីស្វហ្វាហានី (أبو الفرج الإصفهاني) *ម៉ាក្ហ៍ទីល អាល់-ត្ហ៍លីប៊ីយ៉ីន (مَقاتِل الطالِبيّين)* ទំព័រ ១១១ ។

ព្យាយាមរកទឹកតាមដែលអាចរកបាននៅទីនោះ ។ មិនឆ្ងាយប៉ុន្មានពីប្រភពទឹកទាំងនោះ សាវកម្នាក់បានឃើញមានដើមឈើស្រដៀងដើមលម៉ើ បានស្រែកប្រាប់គ្នីគ្នា ។ សាវកខ្លះដែលស្គាល់កន្លែងនេះច្បាស់ ដឹងថានេះមិនមែនអ្វីក្រៅពីផ្លែព្រួញនិងត្រចៀកសេះទេ ។ អ៊ីម៉ាំصلوات الله عليه والسلامក៏ដឹងដែរថានេះគឺកងស្រួចរបស់ទ័ពអ៊ូម៉ៃយ៉ាស់ ។ ព្រះអង្គصلوات الله عليه والسلامបានសួរបក្សពួកព្រះអង្គصلوات الله عليه والسلامថាតើស្គាល់កន្លែងលាក់ខ្លួននៅក្បែរនេះទេ ។ ខ្លះប្រាប់ថាមានភ្នំ ស្ហ៊ូ-ហ៊្វសាំ នៅខាងឆ្វេង ។

ក្បួនទូរចររបស់អ៊ីម៉ាំصلوات الله عليه والسلامបានសំដៅទៅកាន់ភ្នំនោះ ។ កងទ័ពធំមួយ - មានវេហ៍ពលសេះប្រមានជាង ១០០០ នាក់ យោលតាមសេចក្តីថ្លែងការណ៍របស់អ្នកប្រវត្តិសាស្ត្រខ្លះ - នៅក្រោមបញ្ជាការរបស់ អាល់-ហ៊្វរ អ៊ីបនូ យ៉ាស៊ុីដ្ទ អាល់-រីយ៉ាហ៊ី (حر بن يزيد الرياحي) ដែលអ៊ូបៃឌុលឡោះហ៍ អ៊ីបនូ ស៊ុីយ៉ាដ្ទ បានដាក់មុខនាទីឲ្យដើរល្បាតក្នុងវាលរហោឋានដើម្បីស្វែងរកនិងចាប់ក្បួនទូរចរអ៊ីម៉ាំអាល់-ហ៊្វសៃន៍صلوات الله عليه والسلامនោះ បានចូលមកក្បែរនោះ ។ ពេលថ្ងៃត្រង់ កងទ័ពរបស់អាល់-ហ៊្វរស្រេកទឹកពេក មិនអាចបន្តដំណើរទៅមុខទៀតបានទេ ។ អ៊ីម៉ាំصلوات الله عليه والسلامឃើញដូច្នេះក៏មានចិត្តអាណិតពួកនេះ បានបញ្ជាឲ្យបណ្តាសាវកព្រះអង្គصلوات الله عليه والسلام ឲ្យទឹកដែលពួកគេមាននោះទៅពួកគេផឹក ។ សូម្បីតែសេះក៏ត្រូវឲ្យទឹកផឹកដែរ ។

បន្ទាប់ពីនោះ អ៊ីម៉ាំصلوات الله عليه والسلامបានថ្លែងប្រាប់កងទ័ពនេះថា៖

أَيُّهَا النَّاسُ اِنَّهَا مَعْذِرَة اِلَي اللهِ وَ اِلَيْكُمْ. إِنّي لَمْ آتِكُمْ حتّٰى أَتَتْنِيْ كُتُبُكُمْ وَ قَدِمَتْ عَلَيَّ رُسُلُكُمْ أَنْ اَقْدِمْ عَلَيْنا فَاِنَّه لَيْسَ لَنا إِمامٌ لَعَلَّ اللّهَ أَنْ يَجْمَعَنا بِكَ عَلَى الْهُدٰى.فَإِنْ كُنْتُمْ عَلٰى ذٰلِكَ فَقَدْ جِئْتُكُمْ فَأَعْطُوْنِيْ مَا أَطْمَئِنُّ بِه مِنْ عُهُودِكُمْ وَ مَوَاثِيْقِكُمْ وَ إِنْ كُنْتُمْ لِمَقْدَمِي كَارِهِيْنَ انْصَرَفْتُ عَنْكُمْ إِلَى الْمَكَانِ الَّذِي جِئْتُ مِنْهُ إِلَيْكُمْ.

*"ប្រជារាស្ត្រអើយ នេះគ្រាន់តែជាពាក្យពេជន៍ផ្តែផ្តាំដើម្បីបំពេញករណីយកិច្ចខ្ញុំចំពោះអល់ឡោះហ៍عزوجلនិងចំពោះអស់លោកទេ ។ ខ្ញុំមករកអស់លោកបន្ទាប់ពីបានទទួលសារពីអស់លោក និងអ្នកនាំសាររបស់អស់លោក ដែលសូមឲ្យខ្ញុំមករកអស់លោកព្រោះអស់លោកពុំមានអ្នកដឹកនាំព្រោះអស់លោកចង់បាននូវការដឹកនាំទៅរកមាគ៌ាត្រឹមត្រូវ តាមរយៈ*

*អភិបាលភាពរបស់ខ្ញុំ ។ បើអស់លោកនៅតែមាននិន្នាការនេះដដែល ខ្ញុំនៅទីនេះ (បានសេចក្តីថា ខ្ញុំយល់ព្រម) ។ សូមអស់លោកធ្វើកិច្ចសន្យា និងសន្និសញ្ញាយល់ព្រមទទួលស្គាល់ខ្ញុំជាអភិបាលដឹកនាំ ដើម្បីខ្ញុំនឹងដឹងចិត្តអស់លោក ។ តែបើខ្ញុំមកនេះមិនគាប់ចិត្តអស់លោកទេ ខ្ញុំនឹងលាអស់លោកត្រឡប់ទៅកន្លែងខ្ញុំវិញ ។"*

ព្រោះតែនៅក្នុងកងទ័ពនេះ មានបុគ្គលភាគច្រើនផ្ញើសំបុត្រទៅសូមឲ្យអ៊ីម៉ាំصلوات الله عليه والسلامមករកពួកគេ ពួកគេនឹងចុះចូលខ្លួន យកព្រះអង្គصلوات الله عليه والسلامជាអភិបាលដឹកនាំតាមរយៈ មុស្លីម អ៊ីបនូ អាគីលដែលជាតំណាងព្រះអង្គصلوات الله عليه والسلامនោះ បានជាពួកគេមិនអាចឆ្លើយតបព្រះអង្គصلوات الله عليه والسلامបាន ។

ដ្បិតពេលនោះ ដល់ពេលស្ឡាត់ស្ហ្វហ៊្ហ្វរ អ៊ីម៉ាំصلوات الله عليه والسلامបានបញ្ជាឲ្យមូអាស់ស៊ីន[192]ប្រកាសស្ឡាត់ ។ បន្ទាប់មកព្រះអង្គصلوات الله عليه والسلامបានបែរទៅរកអាល់-ហ៊្វរ សូមឲ្យគាត់ដឹកនាំស្ឡាត់ ។ អាល់-ហ៊្វរបានតបយ៉ាងសុភាពថា៖ "អស់ទូលបង្គំនឹងស្ឡាត់ពីក្រោយព្រះអង្គصلوات الله عليه والسلام ។" ពេលបានស្ឡាត់អាស្ហរួច អ៊ីម៉ាំصلوات الله عليه والسلامបានថ្លែងយុត្តបាស់មួយទៀតថា៖

أَيُّهَا النَّاسُ إِنَّكُمْ إِنْ تَتَّقُوا اللَّهَ وَ تَعْرِفُوْا الْحَقَّ وَأَهْلَه يَكُنْ أَرْضٰى لِلَّهِ.وَ نَحْنُ أَهْلَالْبَيْتِ أَوْلٰى بِهٰذَا الْأَمْرِ مِنْ هٰؤُلَاءِ الْمُدَّعِينَ مَا لَيْسَ لَهُمْ وَ السَّائِرِيْنَ فِيكُمْ بِالْجَوْرِ وَ الْعُدْوَانِوَ إِنْ أَنْتُمْ إِلَّا كَرِهْتُمُوْنَا وَ جَهِلْتُمْ حَقَّنَا وَ كَانَ رَأْيُكُمُ الْآنَ عَلٰي غَيْرِ مَا أَتَتْنِي بِه كُتُبُكُمْ انْصَرَفْتُ عَنْكُمْ.

*"ប្រជារាស្ត្រអើយ បើអស់លោកខ្លាចអល់ឡោះហ៍عز وجل ទទួលស្គាល់អ្នកត្រឹមត្រូវ ព្រះអង្គعز وجلនឹងសព្វព្រះហឫទ័យលើសអ្វីៗទាំងអស់ ។ យើងអាស់លុល-បៃត៍عليهم السلام សក្តិសមទទួលមុខតំណែងដឹកនាំជាងអស់បុគ្គលទាំងនោះដែលបានទាមទារមុខតំណែងនោះដោយមុសាវាទ បានគ្រប់គ្រងអស់លោកដោយមធ្យោបាយកំណាចនិងគាបសង្កត់ ។ បើអស់លោកស្អប់យើង មិនទទួលស្គាល់សិទ្ធិយើងទេ ហើយផ្លាស់ប្តូរចិត្តដែលអស់លោកបានប្រាប់នៅក្នុងសេចក្តីសំបុត្រ ដែលអស់លោកបានផ្ញើទៅខ្ញុំនោះ*

[192] មូអាស់ស៊ីន គឺអ្នកប្រកាសស្ឡាត់ ។

*ខ្ញុំនឹងសូមលាអស់លោក..."*[193]

ព្រោះតែមិនដឹងអំពីសារទាំងនេះបានជាអាល់-ហ៊្វូរសួរអ៊ីម៉ាំصلوات الله عليه والسلامថា៖ "ព្រះអង្គصلوات الله عليه والسلامនិយាយអំពីសារអ្វី ?"

ដូច្នេះ អ៊ីម៉ាំصلوات الله عليه والسلامបានបញ្ជាឲ្យសាវកម្នាក់របស់ព្រះអង្គصلوات الله عليه والسلامទៅយកសារទាំងនោះមកបង្ហាញអាល់-ហ៊្វូរ ។ អាល់-ហ៊្វូរស្រឡាំងកាំង ពេលបានឃើញសារទាំងនោះ ។ គាត់បានទូលថា៖ "អស់ទូលបង្គំមិនបានសរសេរសំបុត្រទាំងនេះទេ ។"

បន្ទាប់មក អ៊ីម៉ាំصلوات الله عليه والسلامត្រៀមខ្លួនចាកចេញពីទីនោះ ត្រឡប់ទៅលំនៅដ្ឋានវិញ តែអាល់-ហ៊្វូរបានឃាត់ព្រះអង្គصلوات الله عليه والسلامថា៖ "ទូលបង្គំមិនឲ្យព្រះអង្គصلوات الله عليه والسلامទៅវិញទេ ទូលនឹងនាំព្រះអង្គصلوات الله عليه والسلامទៅគូហ្វាស់ ទៅជួបអ៊្ហូបៃឌុលឡោះហ្វ៍ អ៊ីបនូ ស៊ីយ៉ាដ្ស ។"

អ៊ីម៉ាំصلوات الله عليه والسلامមានវចនៈថា៖ "ការស្លាប់នៅក្បែរលោកជាងធ្វើបែបនេះ" ហើយព្រះអង្គصلوات الله عليه والسلامបានបញ្ជាឲ្យបណ្ដាសាវកព្រះអង្គصلوات الله عليه والسلامឡើងសេះ ទៅកាន់ម៉ាឌីណាស់ ។ តែអាល់-ហ៊្វូរបានឃាត់ព្រះអង្គصلوات الله عليه والسلام ។ អ៊ីម៉ាំصلوات الله عليه والسلامសួរគាត់ថា៖ "លោកចង់បានអ្វីពីយើង ?" អាល់-ហ៊្វូរបានតបថា៖ "ទូលបង្គំចង់នាំព្រះអង្គصلوات الله عليه والسلامទៅជួបអ៊្ហូបៃឌុលឡោះហ្វ៍ អ៊ីបនូ ស៊ីយ៉ាដ្ស ។" អ៊ីម៉ាំصلوات الله عليه والسلامមានវចនៈថា៖ "ខ្ញុំមិនទៅតាមលោកទេ ។" អាល់-ហ៊្វូរបានតបថា៖ "ទូលបង្គំនឹងមិនលែងព្រះអង្គصلوات الله عليه والسلامទេ ។"

ការប្រយុទ្ធគ្នាហៀបនឹងផ្ទុះ តែអាល់-ហ៊្វូរបានដោះស្រាយស្ថានការណ៍ដោយទូលថា៖ "ទូលបង្គំមិនបានទទួលញ្ជាថាឲ្យប្រយុទ្ធទេ ។ ទូលបង្គំគ្រាន់តែបានទទួលបញ្ជាមកថាមិនឲ្យលែងព្រះអង្គصلوات الله عليه والسلامទេ លុះត្រាតែបាននាំព្រះអង្គصلوات الله عليه والسلامទៅគូហ្វាស់ ។ បើព្រះអង្គصلوات الله عليه والسلامបដិសេធ ព្រះអង្គصلوات الله عليه والسلامមិនអាចទៅគូហ្វាស់ ហើយមិនអាចទៅម៉ាឌីណាស់បានទេ ដើម្បីទូលបង្គំនឹងធ្វើរបាយការណ៍ប្រាប់អ៊្ហូបៃឌុលឡោះហ្វ៍ ទូលបង្គំសង្ឃឹមថាអល់ឡោះហ្វ៍عزّ وجلّ នឹងធ្វើឲ្យទូលបង្គំចៀសផុតពីការប្រយុទ្ធទល់នឹងព្រះអង្គ

193 សូមមើលសៀវភៅរបស់លោក ស្ហៃខ៍ អាល់-មូហ៊ីដ្ស (الشيخ المفيد) *អាល់-អៀរស្ហាដ្ស (الإرشاد)* ទំព័រ ៧៩ ។

صلوات الله عليه والسلام ។"

ហេតុដូច្នេះ ក្បួនទូរចរអ៊ីម៉ាំ صلوات الله عليه والسلام បានធ្វើដំណើរតាមផ្លូវមួយផ្សេងទៀត ឆ្ពោះទៅខាងត្បូង រវាងអាល់-អ៊ុដៃប៍ (عديب) និង អាល់-ក៏ឌីស៊ីយ៉ាស់ (القادسية)[194] ។ កងទ័ពរបស់អាល់-ហ៊ួរមើលអ្នកដំណើរ ។

មកដល់កន្លែងមួយដែលគេហៅថា អាល់-បៃដ្ហាស់ អ៊ីម៉ាំ صلوات الله عليه والسلام បានថ្លែងសុន្ទរកថាមួយថា៖

اَيُّهَا النَّاسُ اِنَّ رَسُولَ اللَّهِ (صلى الله عليه و آله و سلم) قَالَ: مَنْ رَأَى سُلْطَانًا جَائِرًا مُسْتَحِلًّا لِحُرُمِ اللَّهِ– نَاكِثًا لِعَهْدِ اللَّهِ مُخَالِفًا لِسُنَّةِ رَسُولِ اللَّهِ (صلى الله عليه و آله و سلم) يَعْمَلُ فِي عِبَادِ اللَّهِ بِالْإِثْمِ وَ الْعُدْوَانِ فَلَمْ يُغَيِّرْ عَلَيْهِ بِفِعْلٍ وَ لَاقَوْلٍ كَانَ حَقًّا عَلَى اللَّهِ أَنْ يُدْخِلَهُ مُدْخَلَهُ اَلَا وَ اِنَّ هٰؤُلَاءِ قَدْ لَزِمُوا طَاعَةَ الشَّيْطَانِوَ تَرَكُوْا طَاعَةَ الرَّحْمَنِ وَ أَظْهَرُوا الْفَسَادَوَ عَطَّلُوْا الْحُدُودَ وَ اسْتَأْثَرُوا بِالْفَيْءِ، وَ أَحَلُّوْا حَرَامَ اللَّهِ وَ حَرَّمُوْا حَلَالَهُ وَ اَنَا أَحَقُّ مِمَّنْ غَيْرَ.

*"ប្រជារាស្ត្រអើយ ព្រះសាសនៈទូត صلى الله عليه وآله وسلم របស់អល់ឡោះហ៍ عز وجل មានព្រះវចនៈថា៖ "បុគ្គលណាដែលស្គាល់អ្នកគ្រប់គ្រងកំណាចដែលប្រមាទព្រះសន្តភាពអល់ឡោះហ៍ عز وجل ដែលក្បត់សន្យាចំពោះអល់ឡោះហ៍ عز وجل ដែលល្មើសព្រះស៊ូណាស់ព្រះសាស្តា صلى الله عليه وآله وسلم ដែលប្រព្រឹត្តបាបកម្មនិងអំពើផ្តាច់ការទៅលើបាវអល់ឡោះហ៍ عز وجل ហើយបុគ្គលនោះមិនបដិសេធអំពើទាំងនេះដោយទង្វើឬដោយសម្តីទេ អល់ឡោះហ៍ عز وجل មានករណីយកិច្ចទុកដាក់អ្នកនោះក្នុងកន្លែងដែលសក្តិសមនឹងអ្នកនោះ (ពោលគឺ ឋាននរក) ។" បុគ្គលទាំងនោះ - ពួកអ្នកគ្រប់គ្រងត្រកូលអ៊ូម៉ៃយ៉ាស់ - ស្ម័គ្រចិត្តគោរពស្ហៃតន لعنه الله បោះបង់ចោលការគោរពអល់ឡោះហ៍ ព្រះដ៏មានព្រះមេត្តាធម៌ ប្រព្រឹត្តបាបយ៉ាងជាក់ស្តែង ផ្តើនមាត្រាវិន័យសាសនា យកសម្បត្តិរដ្ឋជាកម្មសិទ្ធិផ្ទាល់ខ្លួន ចាត់ទុកថាស្របច្បាប់អ្វីដែលអល់ឡោះហ៍ عز وجل ចែងថាខុសច្បាប់ ចាត់ទុកថាខុសច្បាប់អ្វីដែលអល់ឡោះហ៍ عز وجل ចែងថាត្រឹមត្រូវ ។ ខ្ញុំសក្តិសម*

---

[194] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាល់-អាស្សៀរ *អាល់-តារិក្ហ* ក្បាលទី ៣ ទំព័រ ២៨០ ។

*កាន់មុខតំណែងនេះជាងបុគ្គលទាំងនោះ ដែលបង្ខូច[គោលការណ៍អ៊ីស្លាម] ។*

وَ قَدْ أَتَتْنِي كُتُبُكُمْ وَ قَدِمَتْ عَلَيَّ رُسُلُكُمْ بِبَيْعَتِكُمْأَنَّكُمْ لَا تُسَلِّمُونِي وَ لَا تَخْذُلُونِي فَإِنْ اَقَمْتُمْعَلٰي بَيْعَتِكُمْ تُصِيْبُوْا رُشْدَكُمْ.فَاَنَاالْحُسَيْنُ بْنُ عَلِيٍّ وَ ابْنُ فَاطِمَةَ بِنْتِ رَسُوْلِ اللهِ (صلى الله عليه و آله و سلم) نَفْسِي مَعَ أَنْفُسِكُمْ وَ أَهْلِي مَعَ أَهَالِيْكُمْ فَلَكُمْ فِيْ أُسْوَةٌ وَ إِنْ لَمْ تَفْعَلُوا وَ نَقَضْتُمْ عَهْدَكُمْ وَ خَلَعْتُمْ بَيْعَتِيْ مِنْ اَعْنَاقِكُمْ فَلَعَمْرِيْ مَا هِيَ لَكُمْ بِنُكْرٍ لَقَدْ فَعَلْتُمُوهَا بِأَبِي وَ أَخِيوَ ابْنِ عَمِّي مُسْلِمٍ.وَ الْمَغْرُورُ مَنِ اغْتَرَّ بِكُمْفَحَظَّكُمْ أَخْطَأْتُمْ وَ نَصِيبَكُمْ ضَيَّعْتُمْ.فَمَنْ نَكَثَ فَإِنَّمَا يَنْكُثُ عَلٰى نَفْسِهِ وَ سَيُغْنِي اللّٰهُ عَنْكُمْ وَ السَّلَامُ عَلَيْكُمْ وَ رَحْمَةُ اللهِ وَ بَرَكَاتُهُ .

*"ខ្ញុំបានទទួលសាររបស់អស់លោក បានទទួលអ្នកនាំពាក្យរបស់អស់លោកដែលបានប្រាប់ខ្ញុំថាអស់លោកព្រមស្ម័គ្រស្មោះ ទទួលស្គាល់ខ្ញុំ ថាអស់លោកនឹងមិនចោលខ្ញុំទេ មិនធ្វើឲ្យខ្ញុំខកចិត្តទេ ។ បើអស់លោកនៅតែស្មោះស្ម័គ្រ ទទួលស្គាល់ខ្ញុំដដែល អស់លោកប្រាកដជាធ្វើត្រឹមត្រូវណាស់ ។ ខ្ញុំអាល់-ហ៊ូសែន៏صلوات الله عليه والسلام បុត្ររបស់អាលីصلوات الله عليه والسلامនិងហ្វាទីម៉ាស់سلام الله عليها ព្រះរាជបុត្រីរបស់ព្រះសាសនៈទូតصلى الله عليه وآله وسلمរបស់អល់ឡោះហ៍عز وجل ។ រូបខ្ញុំនៅខាងអស់លោក ព្រះរាជវង្សខ្ញុំនៅខាងអស់លោក (ពួកគេនឹងរួមជោគវាសនាតែមួយជាមួយអស់លោក) ។ ខ្ញុំជាគំរូដែលត្រូវតាម ។ ក៏ប៉ុន្តែ បើអស់លោកផ្តាច់ការស្មោះស្ម័គ្រនិងកិច្ចសន្យា វាមិនមែនអ្វីប្លែកទេដែលចេញមកពីខ្លួនអស់លោក ។ អស់លោកបានធ្វើបែបនេះចំពោះបិតាខ្ញុំ ព្រះរៀមខ្ញុំនិងចំពោះមុស្លីម [អ៊ីបនូ អាគ្គីល] បងប្អូនជីដូនមួយរបស់ខ្ញុំរួចហើយកាលពីមុន ។ អ្នកណាជឿអស់លោក អ្នកនោះត្រូវបោកប្រាស់ ។ ទោះជាយ៉ាងណាក៏ដោយ អស់លោកបានបណ្តោយឱកាសដែលនាំមកនូវជោគជ័យនោះកន្លងផុតទៅបាត់ ហើយបានព្រងើយកន្តើយដាក់សន្តិសុខ ។ អ្នកណាបំភ្លេចពាក្យសន្យា អ្នកនោះធ្វើអាក្រក់ដាក់ខ្លួនឯង ។ អល់ឡោះហ៍عز وجلប្រាកដជាផ្លាស់ប្តូរខ្ញុំដោយអ្នកផ្សេង ។ សូមសិរីសួស្តី ព្រះ*

*ធម៌មេត្តាប្រណីរបស់អល់ឡោះហ៍عزّ وجلّនិងព្រះពរជ័យកើត មានដល់អស់លោក ។"*[195]

ពេលថ្លែងចប់សុន្ទរកថានេះ អាល់-ហ៊្វូរបានទូលអ៊ីមុាំصلوات الله عليه والسلامថា៖ "ទូលបង្គំសូមប្រាប់ព្រះអង្គصلوات الله عليه والسلام ។ ទូលបង្គំជឿជាក់ថាព្រះអង្គصلوات الله عليه والسلامនឹងស្លាប់ បើព្រះអង្គصلوات الله عليه والسلامប្រយុទ្ធ ។ ទូលបង្គំសូមស្បថ ។"

អ៊ីមុាំصلوات الله عليه والسلامបានតបថា៖ "លោកយកការស្លាប់មកគំរាមខ្ញុំឬ ? បើលោកសម្លាប់ខ្ញុំ តើមហន្តរាយនឹងចៀសឆ្ងាយពីលោកទេ ? ខ្ញុំមិនដឹងនឹងអាចនិយាយអ្វីប្រាប់លោកបានទេ ។ តែខ្ញុំសូមលើកយកសម្ដីរបស់បុរសអ្នកកុលសម្ព័ន្ធអៅស៍ម្នាក់ បងប្អូនជីដូនមួយគាត់ត្រូវគេគំរាមថាគាត់នឹងស្លាប់កាលគាត់បានចេញទៅការពារព្រះសាស្ដាصلى الله عليه وآله وسلم ។ គាត់បានថ្លែងពាក្យកាព្យថា៖[196]

*"ខ្ញុំនឹងទៅ ការស្លាប់មិនមែនអ្វីដែលធ្វើឲ្យខូចកិត្តិយសទេសម្រាប់វីរបុរស*
*ដែលមានបំណងល្អ ដែលប្រយុទ្ធដើម្បីអ៊ីស្លាម*
*ដែលបូជាជីវិតដើម្បីមនុស្សសុច្ចៈ*
*ដែលអួតដាក់អ្នកស្លាប់ ដែលចាកចោលមនុស្សខុស*
*បើខ្ញុំនៅរស់ ខ្ញុំនឹងមិនស្ដាយក្រោយទេ បើខ្ញុំស្លាប់ ខ្ញុំនឹងមិនត្រូវគេស្ដីបន្ទោសទេ*
*នេះគឺភាពតូចទាបគ្រប់គ្រាន់ណាស់សម្រាប់រស់នៅក្នុងការដាក់ខ្លួន ។"*

ពេលបានឮពាក្យពេជន៍នេះ អាល់-ហ៊្វូរបានលែងអ៊ីមុាំصلوات الله عليه والسلام ហើយដឹងខ្លួនថាលោកបានសម្រេចចិត្តលះបង់ជីវិត ដើម្បីសង្គ្រោះមុស្លីមទាំងឡាយឲ្យរួចផុតពីរបបផ្ដាច់ការ របបមិនត្រឹមត្រូវរបស់ពួកគ្រប់គ្រងត្រកូលអ៊ូម៉ៃយ៉ាស្ស៍ ។

---

[195] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ស្ហ៊ុអ៊្ប៉ាស្ស៍ អាល់-ហារ៉ានី (بن شعبه الحرَّاني) *ទូហ្វាហ្វ៍ អាល់-អ៊ុគូល (تُحَفُ العُقول)* ទំព័រ ៥០៥ ។

[196] សូមមើលសៀវភៅរបស់លោក មូហ៊ាំម៉ាដ្ស៍ អ៊ីបនូ យ៉ាជៀរ អាល់-ត៍ាបារី (محمد بن جرير طبري) *តារិក្ហ៍ អាល់-អ៊ូមុាំ វ៉ា អាល់-មុលុក (تاريخ الأمم والملوك)*, ក្បាលទី ៤ ទំព័រ ៣០៥ ។

ព្រះនាងស្រែណាប់ﷺក៏បានយល់ន័យដែរ ថាព្រះរៀមព្រះនាង ពេលថ្លែងពាក្យពេជន៍នេះ ព្រះអង្គﷺបានសម្រេចព្រះហឫទ័យបូជាព្រះជន្មដោយធ្វើទុក្ករកម្ម ។ ដូច្នេះ ព្រះនាងសោកសៅខ្លាំង អង្វរករអល់ឡោះហ្វ៍ ﷻ សូមព្រះអង្គﷻប្រទានជ័យជំនះឲ្យព្រះរៀមព្រះនាង ។

អាល់-តារីមម៉ាស្ទ់ជាអ្នកដឹកនាំក្បួនទូរចរអ៊ីម៉ាំﷺ ព្រោះគាត់ស្គាល់តំបន់នេះច្បាស់ជាងគេ ។ ក្បួនទូរចរបន្តដំណើរទៅមុខទៀត[197] ។ កងទ័ពរបស់អាល់-ហ៊្វូរឃាត់កុំឲ្យក្បួនទូរចរសំដៅទៅរកវាលរហោឋាន ព្យាយាមជម្រុញក្បួនទូរចរនេះទៅរកគូហ្វាស្ទ់ ។ ទទឹមនឹងពេលនោះ បុរសជិះសេះម្នាក់បានមកដល់ គឺអ្នកនាំសារពីអ៊ូបៃឌុលឡោះហ្វ៍ អ៊ីបនូ ស៊ីយ៉ាដ្ទ៍មកឲ្យអាល់-ហ៊្វូរ សារនោះមានសេចក្ដីថា៖ "ពេលបានទទួលសារនេះភ្លាម ចូរនាំអាល់-ហ៊្វូសែន៍ﷺទៅកាន់កន្លែងគ្មានមនុស្សនៅ ក្នុងវាលរហោឋានដែលគ្មានជម្រកនិងគ្មានទឹក ។ ខ្ញុំដាក់បញ្ជាឲ្យអ្នកនាំសារនេះរំអុកលោកទាល់តែលោកធ្វើតាមបញ្ជាសារនេះ ។"[198]

## នៅឯការបាឡាអ៊ុំ

អ៊ីម៉ាំអាល់-ហ៊្វូសែន៍ﷺចង់ស្នាក់នៅកន្លែងដែលមានទឹកឬជម្រក តែអាល់-ហ៊្វូរបានឃាត់ព្រះអង្គﷺ លើកយកសារបញ្ជារបស់អ៊ូបៃឌុលឡោះហ្វ៍មករំលឹក ។ ស្ថានភាពបានឈានដល់កម្រឹតកំពូល ស៊ូហ្វៃរ៍ អ៊ីបនូ អាល់-ក្វុយន៍ (زهير بن القين) សាវកស្មោះត្រង់ម្នាក់របស់អ៊ីម៉ាំﷺបានស្នើសូមប្រយុទ្ធទល់អាល់-ហ៊្វូរនិងកងទ័ព តែអ៊ីម៉ាំﷺបានបដិសេធដោយមានវចនៈថា៖ "ខ្ញុំនឹងមិនបង្កចម្បាំងជាដាច់ខាត ។"[199]

---

[197] សូមមើលសៀវភៅរបស់លោក អាប៊ុល-ហ្វារ៉ាច្ញ៍ អាល់-អ៊ីស្វហ្វាហ្វានី (أبو الفرج الإصفهاني) *ម៉ាក់ទីល អាល់-ត៏លីប៊ីយ៉ីន (مَقاتِل الطالِبيّين)* ទំព័រ ១១១ ។

[198] សូមមើលសៀវភៅរបស់លោក អាល់-បាឡាស៊ូរី (أحمد بن يحيى البلاذري) *អាន់សាប់ អាល់-អាស្រ៉ហ្វ៍ (أنساب الأشراف)* ទំព័រ ២៤០ ។

[199] សូមមើលសៀវភៅរបស់លោក អាល់-ហ្វាដ្ទ៍ល៍ អ៊ីបនូ ហាសាន់ អាល់-ត៏បារស៊ី (الفضل بن الحسن الطبرسي) *អ៊ិអ៍ឡាំ អាល់-វ៉ារ៉ា ប៊ី អាក់ឡាំ អាល់-ហ៊ូដា*

អាល់-ហ៊ួរបានបង្ខំអ៊ីម៉ាំ صلوات الله عليه والسلام ឲ្យស្នាក់នៅកន្លែងមួយ អ៊ីម៉ាំ صلوات الله عليه والسلام ក៏បានធ្វើតាមទាំងបង្ខំចិត្ត ។ អ៊ីម៉ាំ صلوات الله عليه والسلام បានសួរថា៖ "គេហៅកន្លែងនេះថាអ្វី ?" សាវក ម្នាក់បានទូលថា៖ "គេហៅកន្លែងនេះថាការបាឡាអ៊ ។" អ៊ីម៉ាំ صلوات الله عليه والسلام បាន បួងសួងដោយទឹកភ្នែកថា៖ "អល់ឡោះហ៍ عز وجل អើយ សូមព្រះអង្គ عز وجل ការពារទូលព្រះបង្គំជាខ្ញុំពីការឈឺចាប់និងទុក្ខវេទនា ។"[200]
បន្ទាប់មក ព្រះអង្គ صلوات الله عليه والسلام បានបែរមករកបក្សទាំងឡាយរបស់ព្រះអង្គ صلوات الله عليه والسلام ហើយមានវចនៈថា៖

اَرْضُ كَرْبٍ وَ بَلَاءٍ. هَا هُنَا مُنَاخُ رِكَابِنَا وَ مَحَطُّ رِحَالِنَا وَ سَفْكُ دِمَائِنَا.

*"នេះគឺកន្លែងឈឺចាប់និងទុក្ខវេទនា ។ នេះគឺកន្លែងដែលយើងនិងសត្វជំនិះរបស់យើងនឹងស្នាក់នៅ ឈាមយើងនឹងត្រូវបង្ហូរនៅកន្លែងនេះ ។"*
អាល់-អ៊ុប់បាស់ អមដោយវីរបុរសរបស់ព្រះរាជកុលដ្ឋានព្រះសាស្តា صلى الله عليه وآله وسلم និងបណ្តាសាវករបស់អ៊ីម៉ាំ صلوات الله عليه والسلام ប្រញាប់លើកជំរំព្រះរាជវង្ស ក្រោមការដឹកនាំរបស់ព្រះនាងស៊ៃណាប់ سلام الله عليها ដែលរន្ធត់ចិត្ត ពេលគិតដល់ព្រឹត្តិការណ៍ដែលនឹងកើតឡើងនៅពេលខាងមុខនៅក្នុងតំបន់នេះ ។
បន្ទាប់មក អ៊ីម៉ាំ صلوات الله عليه والسلام លើកព្រះហត្ថបួងសួងអល់ឡោះហ៍ عز وجل ថា៖

اللّهُمَّ إِنّا عِتْرَةُ نَبِيّكَ مُحَمَّدٍ، صَلّىٰ اللهُ عَلَيْهِ وَآلِهِ، قَدْ أُخْرِجْنَا وَطُرِدْنَا وَأُزْعِجْنَا عَنْ حَرَمِ جَدّنَا، وَتَعَدَّتْ بَنُو أُمَيَّةَ عَلَيْنَا. اللَّهُمَّ فَخُذْ لَنَا بِحَقِّنَا وَانْصُرْنَا عَلَىٰ الْقَوْمِ الظَّالِمِينَ.

*"អល់ឡោះហ៍ عز وجل អើយ ព្រះរាជកុលដ្ឋានរបស់មូហាំម៉ាដ់ ព្រះសាស្តា صلى الله عليه وآله وسلم*

---

*(اعلام الورى بأعلام الهدى)* ក្បាលទី ១ ទំព័រ ៤៥១ ។

[200] ពាក្យអារ៉ាប់ "ការប៍" មានន័យថា "ការឈឺចាប់" ឯពាក្យ "បាឡាអ៊" មានន័យថា "ទុក្ខវេទនា" ។ ដូច្នេះ ពាក្យ "ការបាឡាអ៊" មកពីពាក្យទាំងពីរនេះគួបគ្នា ។ ការពិត "ការបាឡាអ៊" ជាឈ្មោះដើមរបស់តំបន់មួយ ។ ចង់ដឹងន័យលំអិតអំពីដើមកំណើតរបស់ពាក្យ "ការបាឡាអ៊" សូមមើលសៀវភៅរបស់ Sayyid Sami al-Badri, *The Holy Quran and Archaeology* (សៃយីដ្ឋ សាមី អាល់-បាដ់រី, *គួរអាន និង បុរាណវត្ថុវិទ្យា)* បកប្រែដោយលោក Badr Shahin, Issue No. 1, Chapter: Karbala in the Ancient Oriental Linguistic Heritage, First Edition, 1421.

*របស់ព្រះអង្គ عزوجل ត្រូវគេបណ្តេញចេញពីព្រះបូជនីយដ្ឋានរបស់ព្រះអយ្យកោរបស់អស់ទូលព្រះបង្គំជាខ្ញុំ ត្រូវត្រកូលអ៊ូម៉ៃយ៉ាស៊ុយឈ្លានពាន ។ អល់ឡោះហ៍ عزوجل អើយ សូមព្រះអង្គ عزوجل សងសឹកពួកសង្កត់សង្កិនគេ សូមព្រះអង្គ عزوجل គាំទ្រអស់ទូលព្រះបង្គំជាខ្ញុំទល់នឹងជនអន្យត្តិរ្តិយ ។"*[201]

បន្ទាប់មក ព្រះអង្គ صلوات الله عليه والسلام បែរមករកព្រះរាជកុលដ្ឋាននិងបណ្តាសាវកព្រះអង្គ صلوات الله عليه والسلام ហើយមានវចនៈថា៖

اِنَّ هٰذِهِ الدُّنْيَا قَدْ تَغَيَّرَتْ وَ تَنَكَّرَتْ وَ أَدْبَرَ مَعْرُوْفُهَا فَلَمْ يَبْقَ مِنْهَا إِلَّا صَبَابَةٌ كَصَبَابَةِ الْإِنَاءِ وَ خَسِيْسُ عَيْشٍ كَالْمَرْعَى الْوَبِيْلِ أَ لَا تَرَوْنَ أَنَّ الْحَقَّ لَا يُعْمَلُ بِهِ وَ أَنَّ الْبَاطِلَ لَا يُتَنَاهٰى عَنْهُ؟ لِيَرْغَبِ الْمُؤْمِنُ فِي لِقَاءِ اللّٰهِ مُحِقًّا فَإِنِّي لَا أَرَى الْمَوْتَ إِلَّا سَعَادَةً وَ لَا الحَيَاةَ مَعَ الظَّالِمِيْنَ إِلَّا بَرَمًا إِنَّ النَّاسَ عَبِيْدُ الدُّنْيَا وَ الدِّيْنُ لَعِقٌ عَلٰى أَلْسِنَتِهِمْ يَحُوْطُوْنَهُ مَا دَرَّتْ مَعَايِشُهُمْ فَإِذَا مُحِّصُوا بِالْبَلَاءِ قَلَّ الدَّيَّانُوْنَ.

*"លោកនេះបានផ្លាស់ប្តូរ បានព្រងើយកន្តើយដោយមើលងាយ អ្វីៗដែលល្អប្រសើរនៅលើលោកនេះបានប្រែត្រឡប់ ។ មិនមានអ្វីនៅសល់លើលោកនេះទេ ក្រៅពីវត្ថុដ៏តូចប៉ុនសំណល់បាតកែវនិងជីវិតតោកយ៉ាកដូចស្មៅសត្វដែលខូច ។ តើអស់លោកឃើញទេថាគេមិនអើពើអំពីអ្វីដែលត្រឹមត្រូវទេ គេមិនហាមឃាត់អ្វីដែលអាក្រក់ទេ ? អ្វីទាំងនេះគ្រប់គ្រាន់ណាស់ដើម្បីធ្វើឲ្យបណ្តាអ្នកមានសទ្ធាចង់ជួបអល់ឡោះហ៍ عزوجل យ៉ាងសក្តិសម ។ ខ្ញុំមិនចាត់ទុកវាជាការស្លាប់ទេ តែជាសុភមង្គល ខ្ញុំមិនស្មានជីវិតរស់នៅដោយមានជនទុច្ចរិតទេ តែជីវិតជាការធុញទ្រាន់ ។ ពិតណាស់ មនុស្សជាទាសៈរបស់លោកនេះ ។ សាសនាគ្រាន់តែជាសម្តីនៅលើអណ្តាតពួកគេប៉ុណ្ណោះ ។ ពួកគេផ្លាស់ប្តូរសាសនាតាមជីវភាពរស់នៅ ។ បើពួកគេត្រូវល្បងពិសោធដោយទុក្ខវេទនា អ្នកមានជំនឿច្បាស់ជាមានចំនួនតិចណាស់ ។"*[202]

---

[201] សូមមើលសៀវភៅរបស់លោក មូហ៊ាំម៉ាដ់ បាគៀរ អាល់-ម៉ាច់លីស៊ី (محمد باقر المجلسي) *ប៊ីហ៊ារ អាល់-អាន់វ៉ារ (بحارالانوار)* ក្បាលទី ៤៤ ទំព័រ ៣៨៣ ។

[202] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ស៊្ហុអ៊ុបាស៊ុ អាល់-ហ៊ារ៉ានី (بن شعبه الحرَّاني)

អ៊ីម៉ាំអាល់-ហ៊្វូសៃន៍صلوات الله عليه والسلامបានប្រាប់ព្រះរាជកុលដ្ឋានព្រះអង្គصلوات الله عليه والسلام ដោយពាក្យពេជន៍ទាំងនេះ ឲ្យដឹងអំពីទុក្ខវេទនាដែលពួកគេនឹងជួបប្រទះនៅពេលខាងមុខ ឲ្យដឹងថាព្រះអង្គصلوات الله عليه والسلامត្រៀមខ្លួនប្រយុទ្ធជាស្រេចទល់នឹងបក្សខុសច្បាប់ដរាបណាព្រះអង្គصلوات الله عليه والسلامនៅមានព្រះជន្ម ។ ពេលបានឮពាក្យពេជន៍នេះ បុគ្គលឥតប្រៀបផ្ទឹមបានទាំងនោះដែលបានត្រាយផ្លូវសន្តិភាពឲ្យមនុស្សជាតិតាមរយៈស្ថានការណ៍ឥតឧបមា បានប្ដេជ្ញានៅចំពោះមុខព្រះអគ្គមគ្គុទេសក៍របស់ខ្លួន ដើម្បីបង្ហាញថាពួកគេត្រៀមខ្លួនចូលរួមនិងបន្តដំណើរទៅមុខទៀត ទោះជាត្រូវលះបង់ប៉ុណ្ណាក៏ដោយ ។ ស៊្វហៃរ៍ អ៊ីបនូ អាល់-ក្វយ់ន៍ (زهير بن القين) ជាសាវកដែលបានប្ដេជ្ញាមុនគេថា៖ "ព្រះរាជបុត្ររបស់ព្រះសាសនៈទូតﷺអល់ឡោះហ្វ៍عز وجلអឺយ អស់ទូលបង្គំយល់ព្រះវាចាព្រះអង្គصلوات الله عليه والسلام ។ អស់ទូលបង្គំនឹងឈប់គាំទ្រព្រះអង្គصلوات الله عليه والسلامបើអស់ទូលបង្គំយល់ថាលោកនេះ នឹងឋិតថេរសម្រាប់អស់ទូលបង្គំមែន... ។ល ។"

វីរបុរសម្នាក់ទៀតឈ្មោះ ប៊ូរ៉យ៉រ៍ អ៊ីបនូ ឃ្វុដ្ហយ់រ៍ (بُرَير بن خُضَير) បានថ្លែងពាក្យពេជន៍ស្រដៀងនេះដែរ ។ វីរបុរសឯទៀតបានប្ដេជ្ញាតស៊ូនៅលើគោលសីលធម៌របស់ខ្លួន ត្រៀមខ្លួនបូជាជីវិតដើម្បីព្រះអគ្គមគ្គុទេសក៍របស់ខ្លួន ។ អ៊ីម៉ាំصلوات الله عليه والسلامបានថ្លែងអំណរគុណចំពោះវីរបុរសទាំងអស់គ្នាដែលមានទឹកចិត្ត ហើយបានជូនពរជ័យពួកគេ ។

នៅគូហ្វាស្ហ៍ អ៊្ហូបៃឌុលឡោះហ្វ៍ អ៊ីបនូ ស្ហ៊ីយ៉ាដ្ហ៍សប្បាយចិត្តណាស់ដែលបានទទួលដំណឹងថា កងស្រួចរបស់ខ្លួនចាប់ខ្លួនអ៊ីម៉ាំអាល់-ហ៊្វូសៃន៍صلوات الله عليه والسلام បាន ។ បន្ទាប់មកគាត់បានផ្ដើមរៀបផែនការសម្រាប់កំណាក់ការបន្ទាប់ ។ តើគាត់ត្រូវជ្រើសរើសអ្នកណា ដើម្បីដឹកនាំកងទ័ពក្នុងការធ្វើគុតបុគ្គលជាទីស្រឡាញ់បំផុតរបស់ព្រះសាស្ដាﷺ ? ពេលពិនិត្យមើលឈ្មោះបេក្ខជន គាត់ឃើញថាពុំមានអ្នកណាកោងកាចនិងអាក្រក់ជាង អ៊្ហូម៉ារ អ៊ីបនូ សាអ៊្ហដ្ហ៍ (عمر بن سعد) ទេ ។

ដំបូង អ៊្ហូម៉ារបានបដិសេធប្រយុទ្ធទល់នឹងអ៊ីម៉ាំصلوات الله عليه والسلام តែអ៊្ហូបៃឌុលឡោះហ្វ៍

*ទូហ្វាហ្វ៍ អាល់-អ៊្ហូគ្វូល (تُحَفُ العُقول)* ទំព័រ ២៨៧ ។

គំរាមទម្លាក់គាត់ពីមុខតំណែងអភិបាលស្រុក រ៉យ - ស្រុកទេស្ហរ៉ន ឬ ទេហ្ររ៉ន (تهران) សព្វថ្ងៃ ។ ហេតុដូច្នេះ គាត់យល់ព្រម ហើយបានចាប់ផ្ដើមលើកទ័ពទៅកាន់ការបាឡាអ៊ុំដោយមានវរេហ៍ពលសេះ ៤០០០ នាក់ទៅចូលរួមជាមួយទ័ពអាល់-ហ៊្សួរនៅទីនោះ ។ អ៊ុំម៉ារ អ៊ីបនូ សាអាដ់ត្រូវជ្រើសរើសព្រោះគាត់បានប្រព្រឹត្តអំពើឧក្រិដ្ឋគួររន្ធត់ គាត់មិនញញើតលើកទ័ពទៅប្រយុទ្ធទល់នឹងអ៊ីម៉ាំដែលត្រូវអល់ឡោះហ្ញ៉ عز وجل ជ្រើសរើសទេ ។ គាត់បានព័ទ្ធអ៊ីម៉ាំ صلوات الله عليه والسلام ជុំជិត ហ៊ុមព្រះអង្គ صلوات الله عليه والسلام បិទផ្លូវមិនឲ្យអ្នកណាមួយអាចចូលជួយឬគាំទ្រព្រះអង្គ صلوات الله عليه والسلام បានទេ ។

នៅឯគូហ្វាស់ដែរ អ៊ុំបៃឌុលឡោះហ្ញ៉បានប្រជុំអ្នកស្រុក ប្រកាសថា៖ "ប្រជារាស្ត្រអើយ អស់លោកបានសាកល្បងបណ្ដាកូនចៅរបស់អាប៊ូស៊ុហ្វយ៉ានហើយ អស់លោកបានឃើញថាពួកគេដូចអស់លោកចូលចិត្តមែន ។ អស់លោកស្គាល់យ៉ាស៊ីដ្ឋ មគ្គទេសក៍របស់អស់លោក ដែរថាលោកជាមនុស្សល្អ គួរជាទីគោរព ។ លោកធ្វើល្អចំពោះប្រជារាស្ត្រ លោកប្រទានប្រាក់ចំណែកឲ្យគ្រប់ៗគ្នាដោយសក្ដិសម ផ្ដល់កិត្តិយសដល់ប្រជារាស្ត្រដោយទ្រព្យសម្បត្តិរបស់លោក ។ លោកដាក់បញ្ជាឲ្យខ្ញុំថែម ១០០ ដៀរហ្ញ៉ាំរៀងរាល់ខែពីលើប្រាក់ចំណែក ដែលអស់លោកបានស្រាប់ហើយនោះ ។ លោកបានដាក់បញ្ជាដែរ ឲ្យខ្ញុំកោះហៅប្រយុទ្ធតទល់នឹងអាល់-ហ៊្សៃន៍ សត្រូវរបស់លោក ។ ហេតុដូច្នេះ សូមអស់លោកស្ដាប់ខ្ញុំសូមអស់លោកធ្វើតាមបញ្ជាលោកអភិបាល... ។"[203]

អកុសល ប្រជារាស្ត្រភាគច្រើនគោរពបញ្ជានេះ ហើយប្រជុំគ្នាជាកងទ័ពធំមួយទល់នឹងក្រុមដ៏តូចរបស់អ៊ីម៉ាំ صلوات الله عليه والسلام ។ បន្ទាប់ពីនោះ ពួកគេបានចេញដំណើរទៅកាន់ការបាឡាអ៊ុំ បានកាន់កាប់ត្រើយទាំងពីរនិងព្រៃកទាំងអស់នៃស្ទឹងអឺប្រ្ហាត់ (ឬ ហ្វ៊ូរ៉ត الفرات Euphrate) ។

អ្នកប្រវត្តិសាស្ត្រខ្លះបានថ្លែងថាបីថ្ងៃមុនការប៉ះទង្គិចគ្នា អ៊ីម៉ាំអាល់-

[203] សូមមើលសៀវភៅរបស់លោក អាប៊ូ ហា្ញនីហ្វាស់ អាល់-ឌៃនូរី (أبو حنيفة الدينوري) *អាល់-អាក់បារ អាល់-ទ្វីវ៉ាល់ (الأخبار الطوال)* ទំព័រ ២៥៣ ។

ហ៊ូសែន៍صلوات الله عليه والسلامត្រូវគេបង្អត់ទឹក[204] ។ ព្រឹត្តិការណ៍នេះជាគ្រោះកាចធំបំផុតដែលព្រះអង្គصلوات الله عليه والسلامពើបពះ ។ អ្វីដែលចម្លែកនោះ គឺបនកងទ័ពអ៊ូម៉ៃយ៉ាស្ស៊ុ មានមោទនភាពចំពោះអំពើឧក្រិដ្ឋនេះណាស់ ដែលឈ្លានពានតម្លៃមនុស្សធម៌ ។ ឧទាហរណ៍ ទាហានអ៊ូម៉ៃយ៉ាស្ស៊ុម្នាក់បានស្រែកដាក់អ៊ីម៉ាំ អាល់-ហ៊ូសែន៍صلوات الله عليه والسلامថា៖ "ហ៊ូសែន៍អឺយ ឯងឃើញទឹកហូរដូចពស់លូន តែឯងផឹកមិនបានទេ មុនឯងស្លាប់... ។"[205]

អុំរ៉ូ អ៊ីបនូ អាល់-ហាជ្ជ៉ុយ៉ាជ្ជ៉ុ រីករាយចំពោះស្ថានភាពនេះ បានប្រកាសថា៖ "ហ៊ូសែន៍ នេះគឺស្ទឹងអឺប្រ្វាត់ (ឬ ហ្វ៊ូរ៉ាត) ។ ឆ្កែ លា ជ្រូកផឹកទឹកស្ទឹងនេះ ។ តែយើងនឹងហាមឃាត់ឯង មិនឲ្យឯងផឹកទឹកស្ទឹងនេះមួយតំណក់ឡើយ... !"[206]

ពុំមានច្បាប់ ឬ វិន័យណាមួយនៅលើផែនដីនេះអនុញ្ញាតឲ្យអ្នកណាមួយនៅក្នុងកាលៈទេសៈណាមួយ បង្អត់ទឹកស្ត្រីនិងក្មេងៗទេ លើកលែងតែច្បាប់របស់ត្រកូលអ៊ូម៉ៃយ៉ាស្ស៊ុ ចាប់តាំងពីដើមកំណើតអ៊ីស្លាមមកម្ល៉េះ ពួកគេផ្តែផ្តាំគ្នា ឲ្យរារាំងព្រះរាជកុលដ្ឋានរបស់ព្រះសាស្តាصلى الله عليه وآله وسلم មិនឲ្យកាន់មុខតំណែងដឹកនាំប្រភេទណាមួយឡើយ ។

ប្រឈមនឹងគ្រោះកាចអត់ទឹកនេះ ព្រះនាងស្ហៃណាប់سلام الله عليهاខិតខំយ៉ាងលំបាកបំពេញបេសកកម្មប្រមូលក្មេងៗនិងស្ត្រីស្រេកទឹក នឹងព្យាយាមលួងចិត្តពួកគេ សន្យាពួកគេថានឹងយកទឹកមកឲ្យ ។ ព្រះនាងរល្ហួយចិត្តរល្ហួយថ្លើម ពេលឃើញក្មេងៗនិងទារកយំព្រោះស្រេក តែព្រះនាងពុំមាន

[204] សូមមើលសៀវភៅរបស់លោក ស៊ីបត៏ អ៊ីបនូ អាល់-យ៉ៅហ្ស៊ី (سبط بن الجوزي) *មីរ៉ោះត៏ អាល់-ស្សាម៉ាន់ ហ្វី តាវ៉ារីក អាល់-អាក់យ៉ាន់ (مراة الزمان في تواريخ الاعيان)* ទំព័រ ៨៩ ។

[205] សូមមើលសៀវភៅរបស់លោក ស្ហៃខ៏ អាល់-ស្វ៏ឌូក្វ (الشيخ الصدوق) *អាល់-អាម៉ាលី (الامالي)* ទំព័រ ២២១ ។

[206] សូមមើលសៀវភៅរបស់លោក អាស្ហ៍ម៉ាដ្ធ អ៊ីបនូ យ៉ាស្ហ៍យ៉ា អាល់-បាឡាស្ហ៊ូរី (أحمد بن يحيى البلاذري) *អាន់សាប់ អាល់-អាស្ហ៊ូរ៉ាហ្វ (أنساب الأشراف)* ក្បាលទី ៣ ទំព័រ ១៨១ ។

ទឹកឲ្យផឹកមួយតំណក់ឡើយ ។

អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلامសូមជួបអ៊្វម៉ារ អ៊ីបនូ សាអ៊្វដ្ធមួយទល់មួយ ។ បុរសឧក្រិដ្ឋមកជួបអ៊ីម៉ាំصلوات الله عليه والسلامជាមួយកូននិងបម្រើម្នាក់ អ៊ីម៉ាំصلوات الله عليه والسلامសូមឲ្យព្រះអនុជព្រះអង្គصلوات الله عليه والسلام អាល់-អ៊្វប់បាស់និងព្រះរាជបុត្រព្រះអង្គصلوات الله عليه والسلام អ៊្វលី អាក់ប៉ារ៍ចូលរួមក្នុងជំនួបនេះ ។ អ៊ីម៉ាំصلوات الله عليه والسلامសូមឲ្យអ៊្វម៉ារគិតឲ្យម៉ត់ចត់រឿងនេះ សូមឲ្យគាត់គិតដល់គ្រោះកាចក្នុងពេលខាងមុខដែលគាត់នឹងពើបពះយ៉ាងពិតប្រាកដក្នុងលោកនេះនិងក្នុងលោកមុខ បើគាត់ប្រយុទ្ធទល់នឹងព្រះអង្គصلوات الله عليه والسلام ។ អ៊្វម៉ារព្យាយាមឆ្លើយដោះសាឲ្យរួចខ្លួន តែអ៊ីម៉ាំصلوات الله عليه والسلامបានបង្ហាញឲ្យឃើញថា ចម្លើយដោះសានោះពុំមានតម្លៃទេ ។ ទីបំផុត អ៊ីម៉ាំصلوات الله عليه والسلامឃើញថាអ៊្វម៉ារមិនផ្លាស់ប្ដូរចិត្តជាដាច់ខាត ដូច្នេះព្រះអង្គصلوات الله عليه والسلامបានប្រាប់គាត់ថា៖ "តើលោកកើតអ្វី ? សូមអល់ឡោះហ្វ៍عز وجلសម្លាប់លោកនៅលើគ្រែដេក ។ សូមកុំឲ្យអល់ឡោះហ្វ៍عز وجلលើកទោសឲ្យលោកក្នុងថ្ងៃដែលលោកនឹងរស់ឡើងវិញ ។ ខ្ញុំឃើញជាមុនថាបើលោកធ្វើបែបនេះមែន លោកនឹងមិនអាចបរិភោគឆ្អែតដោយសារស្រូវប្រទេសអ៊ីរ៉ាក់ទេ ។"

អ៊្វម៉ារបានតបវិញដោយចំអកថា៖ "ស្រូវប្រទេសនេះនឹងគ្រប់គ្រាន់ណាស់សម្រាប់ទូលបង្គំ !"[207]

ការពិត អល់ឡោះហ្វ៍تعالىបានឆ្លើយតបការបួងសួងរបស់អ៊ីម៉ាំصلوات الله عليه والسلامអាល់-ហ៊្វសែន៍صلوات الله عليه والسلامរឿងអ៊្វម៉ារ ។ ពួកទាហានរបស់អាល់-មុក្ខតារបានសម្លាប់អ៊្វម៉ារនៅក្នុងគ្រែដេករបស់គាត់ ។

នៅលើទឹកដីការបាឡាអ៍ ព្រះនាងស៊្វេណាប់سلام الله عليهاតស៊ូនឹងកំណើនមហន្តរាយដោយអារុធអត់ធ្មត់និងស្មារតីរឹងមាំ ។ ក្នុងយប់ថ្ងៃទី ៩ ខែមូហារ៉ម កងទ័ពអ៊្វម៉ៃយ៉ាស្ហ៍ ឆ្ពោះទៅរកក្រុមតូចរបស់អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلام ។ អ៊ីម៉ាំصلوات الله عليه والسلامហៀបនឹងផ្ទំមួយស្របលេត ស្រាប់តែព្រះអនុជាព្រះអង្គصلوات الله عليه والسلام ព្រះនាងស៊្វេណាប់سلام الله عليها រួសរាន់មករកព្រះអង្គصلوات الله عليه والسلامដោយភ័យតក្កមា

[207] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ស្ហាស្ហ៍រូ អាស្ហ៊ូប (إبن شهر آشوب) *ម៉ាណាគ៊្វីប អាលី អាប៊ី ត៊្វលិប (مَناقِبُ آلِ أبي طالب)* ក្បាលទី ៣ ទំព័រ ២១៣ ។

ព្រោះព្រះនាងបានឮសម្លេងខ្មាំងមករកពួកគេ ។ ព្រះនាងបានដាស់ព្រះអង្គ(صلوات الله عليه والسلام) ទូលថា៖ "ព្រះរៀមអើយ ពួកខ្មាំងចូលមករកយើងហើយ ។" ព្រះអង្គ(صلوات الله عليه والسلام)បានឆ្លើយថា៖ "រៀមទើបនឹងបានឃើញព្រះសាសនៈទូត(صلى الله عليه وآله وسلم) អល់ឡោះហ្វ៍(عز وجل) ព្រះបិតាអ៊ាលី(صلوات الله عليه والسلام) ព្រះមាតាហ្វាទីម៉ាស្ហ(سلام الله عليها) និងព្រះរៀមអាល់-ហាសាន់(صلوات الله عليه والسلام)ក្នុងសុបិន ។ ព្រះអង្គ(عليهم السلام)បានប្រាប់ថារៀមនឹងបានជួបព្រះអង្គទាំងអស់(عليهم السلام)ក្នុងពេលឆាប់ៗនេះ ។"

សម្ដីនេះមានឥទ្ធិពលដូចរន្ទះបាញ់មកលើអារម្មណ៍ព្រះនាងស៊ៃណាប់(سلام الله عليها) ធ្វើឲ្យបេះដូងព្រះនាងខ្ទេចខ្ទាំ ។ ព្រះនាងពុំអាចធ្វើអ្វីបានឡើយ ក្រៅពីទះមុខខ្លួនឯង ហើយស្រែកថា៖ "អនិច្ចាអ្វីម្ល៉េះទេ !" អ៊ីម៉ាំ(صلوات الله عليه والسلام)ព្យាយាមសម្រាលទុក្ខព្រះនាងដោយមានវចនៈថា៖ "រឿងអនិច្ចាមិនមែននៅលើរូបប្អូនទេ ។ សូមប្អូនរក្សាការស្ងៀមស្ងាត់ ។ សូមអល់ឡោះហ្ទ៍(تعالى)អាណិតមេត្តាប្អូន ។"[208]

អាល់-អាប់បាស់ ដែលតាមព្រះរៀមជាប់មិនលែងនោះ បានបែរទៅរកព្រះអង្គ(صلوات الله عليه والسلام) ហើយទូលថា៖ "ពួកគេមករកព្រះរៀម ។" អ៊ីម៉ាំ(صلوات الله عليه والسلام)ឲ្យអាល់-អាប់បាស់ពិនិត្យមើលគោលបំណងពួកគេ ។ អាល់-អាប់បាស់បានទូលព្រះអង្គ(صلوات الله عليه والسلام)ថា៖ "សូមឲ្យទូលបង្គំបានបូជាជីវិតដើម្បីព្រះអង្គ(صلوات الله عليه والسلام) យើងទៅជួបពួកគេ ដើម្បីសួរឲ្យដឹងគោលបំណងពួកគេ ។"

ជាមួយរហ័ពលសេះម្ភៃនាក់ អាល់-អាប់បាស់បានចេញទៅជួបកងទ័ពនោះ សួរអំពីគោលបំណងពួកគេ ។

ពួកគេបានតបថា៖ "លោកអភិបាលក្រុងបានបញ្ជាឲ្យយើងប្រកាសឲ្យអស់លោកព្រមចុះចូលខ្លួនក្រោមបញ្ជាលោក ពុំនោះទេយើងនឹងប្រយុទ្ធទល់នឹងអស់លោក ។"

អាល់-អាប់បាស់ត្រឡប់ទៅរាយការណ៍ប្រាប់ព្រះរៀម អំពីគោលបំណង

[208] សូមមើលសៀវភៅរបស់ ស្ហៃខ៍ អាល់-ស្ហូរ៉យហ្វី *ម៉ៅស៊ូអាស្ហ កាឡីម៉ាត់ អាល់-អ៊ីម៉ាំ អាល់-ហ៊ូសៃន៍ (موسوعةُ كَلماتِ الامامِ الحُسَين عليه السّلام)* ទំព័រ ៣៩១ ចែងនៅក្នុងសៀវភៅរបស់លោក អ៊ីបនូ អាល់-អាស្ហៀរ *អាល់-កាមីល ហ្វី អាល់-តារីក (الكامل في التاريخ)* ក្បាលទី ២ ទំព័រ ៥៥៨ ។

ពួកគេ ។ ទន្ទឹមនឹងពេលនោះដែរ ហាប៊ីប អ៊ីបនូ មូស្ហ៊ហ្ហៀរ៍ (حبيب بن مظاهر) បានថ្លែងណែនាំកងទ័ពនោះ ។ លោកបានដាស់តឿននិងព្រមានពួកគេឲ្យប្រយ័តខ្លួនអំពីទណ្ឌកម្មរបស់អល់ឡោះហ្ញ៍عزوجلដែលពួកគេនឹងពើបពះបើពួកគេប្រយុទ្ធទល់នឹងព្រះរាជវង្សព្រះសាស្ដាصلى الله عليه وآله وسلم ។ តែពួកគេខ្លះបានឆ្លើយតបលោកវិញដោយឥតអៀនខ្មាស់ ។

ពេលបានឮសម្ដីព្រះអនុជព្រះអង្គصلوات الله عليه والسلام អ៊ីម៉ាំអាល់-ហ៊្សៃសែន៍صلوات الله عليه والسلامបានប្រាប់អាល់-អ្ហាប់បាស់ថា៖ "ចូរត្រឡប់ទៅជួបពួកគេវិញ ហើយព្យាយាមពន្យារពេលពួកគេលុះដល់ព្រឹក ដើម្បីយើងនឹងមានពេលបួងសួងព្រះម្ចាស់យើងក្នុងយប់នេះ ព្រះអង្គعزوجلទ្រង់ញាណថាបងចូលចិត្តបួងសួងព្រះអង្គعزوجل ចូលចិត្តសូត្រព្រះគម្ពីរព្រះអង្គعزوجل ចូលចិត្តអង្វរករព្រះអង្គعزوجلណាស់ ។"

អាល់-អ្ហាប់បាស់បាននាំសម្ដីនេះទៅប្រាប់ទ័ពអ៊ូម៉ៃយ៉ាស្ហ៍ ។ អ៊្ហម៉ារ អ៊ីបនូ សាអ្ហាដ្ហ៍ ព្រោះតែខ្លាចគេនាំរឿងគាត់ទៅប្រាប់អភិបាលក្រុង បានស្នើសូមឲ្យនាំពាក្យនេះទៅប្រាប់ស្ហ៊ីមរូដែលជាគូប្រជែងតែមួយរបស់គាត់ ។ ស្ហ៊ីមរូមិននិយាយអ្វីទេ តែអ្ហាំរូ អ៊ីបនូ អាល់-ហ្ហាច្ហ៍យ៉្ហាច្ហ៍បានស៊កសម្ដីថា៖ "ចម្លែកមែន ទោះបីពួកគេពុំមែនជនជាតិអារ៉ាប់ក៏ដោយ ក៏យើងឆ្លើយតបសំណូមពរពួកគេដែរ ។!"

ការពិត អ្ហាំរូមិនចង់សារភាពទេថាក្រុមប្រឆាំងពួកគេនោះជាព្រះរាជនត្តាជាទីស្រឡាញ់របស់ព្រះសាស្ដាصلى الله عليه وآله وسلم និងជាព្រះអគ្គមហាប្រមុខរបស់យុវជនឋានសួគ៌ ។ នេះព្រោះតែគាត់ប្រយ័តខ្លួនជាមុន មិនចង់ឲ្យគេនាំសម្ដីគាត់ទៅរាយការណ៍ប្រាប់អាជ្ញាធរកាន់អំណាចនោះទេ ។

ព្រោះតែច្រើននាក់ទៀតគាំទ្រសម្ដីអ្ហាំរូ បានជាអ៊្ហម៉ារ អ៊ីបនូ សាអ្ហាដ្ហ៍ព្រមពន្យារពេលវាយលុកទៅលើជំរំអ៊ីម៉ាំصلوات الله عليه والسلام ។ គាត់បញ្ជាឲ្យកូនទាហានម្នាក់ចូលទៅក្បែរជំរំអ៊ីម៉ាំصلوات الله عليه والسلام ហើយប្រកាសប្រាប់ថាចម្បាំងត្រូវលើកទៅឯថ្ងៃក្រោយ ។

ដូច្នេះ ចម្បាំងត្រូវផ្អាកក្នុងយប់នោះ ទ័ពរបស់អ៊្ហម៉ារ អ៊ីបនូ សាអ្ហាដ្ហ៍បានរង់ចាំចម្លើយពីអ៊ីម៉ាំصلوات الله عليه والسلام ថាព្រះអង្គصلوات الله عليه والسلامយល់ព្រមនឹងពួកគេឬក៏ប្រយុទ្ធ ។

أُثْنِي عَلَىٰ اللهِ أَحْسَنَ الثَّنَاءِ وَأَحْمَدُهُ عَلَىٰ السَّرَّاءِ وَالضَّرَّاءِ. اللَّهُمَّ إِنِّي أَحْمَدُكَ عَلَىٰ أَنْ

أَكْرَمْتَنَا بِالنُّبُوَّةِ، وَعَلَّمْتَنَا القُرْآنَ، وَفَهَّمْتَنَا فِي الدِّينِ، وَجَعَلْتَ لَنا أَسْمَاعاً وَأَفْئِدَةً، وَلَمْ تَجْعَلْنَا مِنَ المُشْرِكِينَ.

أَمَّا بَعْدُ: فَإِنِّي لاَ أَعْلَمُ أَصْحَاباً أَوْفَىٰ وَلاَ خَيْراً مِنْ أَصْحَابِي، وَلاَ أَهْلَ بَيْتٍ أَبَرَّ وَلا أَوْصَلَ مِنْ أَهْلِ بَيْتِي. فَجَزَاكُمُ اللهُ عَنِّي خَيْراً. أَلا وَإِنِّي لأَظُنُّ أَنَّهُ آخِرُ يَوْمٍ لَنَا مِنْ هٰؤُلاءِ. أَلا وَإِنِّي قَدْ أَذِنْتُ لَكُمْ فَانْطَلِقُوا جَمِيعاً فِي حِلٍّ لَيْسَ عَلَيْكُمْ مِنِّي ذِمَامٌ. هٰذَا اللَّيْلُ قَدْ غَشِيَكُمْ فَاتَّخِذُوهُ جَمَلاً. وَلْيَأْخُذْ كُلُّ رَجُلٍ مِنْكُمْ بِيَدِ رَجُلٍ مِنْ أَهْلِ بَيْتِي وَتَفَرَّقُوا فِي سَوَادِ هٰذَا اللَّيْلِ وَذَرُونِي وَهٰؤُلاءِ القَوْمَ فَإِنَّهُمْ لا يُرِيدُونَ غَيْرِي.

*"ទូលព្រះបង្គំជាខ្ញុំសូមគោរពសក្ការៈអល់ឡោះហ៍ ដោយថ្វាយថោមនាទដ៏ប្រណីតលើសលុប និងសូមអរព្រះគុណព្រះអង្គដែលបានឲ្យមានគ្រាសុខសាន្តនិងគ្រាលំបាក ។ អល់ឡោះហ៍អើយ ទូលព្រះបង្គំជាខ្ញុំសូមអរព្រះគុណព្រះអង្គ ដែលបានលើកតម្កើងអស់ទូលព្រះបង្គំជាខ្ញុំអាស្រ័យព្រះសាស្តា ដែលបានឲ្យអស់ទូលព្រះបង្គំជាខ្ញុំចេះដឹងព្រះគម្ពីរគួរអាន ដែលបានឲ្យអស់ទូលព្រះបង្គំជាខ្ញុំយល់ដឹងសាសនា ដែលបានព្រះរាជទានត្រចៀកនិងបេះដូងឲ្យអស់ទូលព្រះបង្គំជាខ្ញុំ ដែលពុំបានធ្វើឲ្យអស់ទូលព្រះបង្គំជាខ្ញុំទៅជាអ្នកសក្ការៈរូបបដិមា ។*

*ការពិត ខ្ញុំដឹងថាពុំមានបណ្តាអ្នកតាមណាល្អប្រសើរជាងបណ្តាអ្នកតាមខ្ញុំទេ ហើយពុំមានត្រកូលណាមួយប្រសើរជាងវង្សត្រកូលខ្ញុំទេ ។ សូមអល់ឡោះហ៍ឲ្យរង្វាន់អស់លោកទាំងអស់គ្នា ។ ការពិត ថ្ងៃស្អែកជាថ្ងៃផ្តាច់ព្រ័ត្រជាមួយពួកទាំងនេះ ។ ខ្ញុំអនុញ្ញាតឲ្យអស់លោកចាកចោលខ្ញុំបាន ទៅកាន់ផ្លូវផ្ទាល់ខ្លួនរបស់អស់លោក ។ ក្នុងយប់នេះអស់លោកគ្រប់គ្នាអាចចាកចោលខ្ញុំបាន ។ អស់លោករាល់គ្នាអាចយកសមាជិកគ្រួសារខ្ញុំចាកចេញទៅបាន អាចបែកផ្លូវគ្នាក្នុងស្បៃងងឹតនៃយប់នេះបាន ។ ការពិត ខ្ញុំជាបុគ្គលដែលពួកគេចង់បាន ។ ពេលពួកគេចាប់ខ្លួនខ្ញុំបាន ពួកគេនឹងមិនដេញតាមអ្នកឯទៀតទេ ។"*[209]

---

[209] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាល់-អាស្សៀរ *អាល់-កាមីល ហ្វី អាល់-តារីក្ហ (الكامل في التاريخ)* ក្បាលទី ៣ ទំព័រ ២៨៥ ។

ពេលអ៊ីម៉ាំصلوات الله عليه والسلامមានវចនៈចប់ភ្លាម អាប៊ូ អាល់-ហ្វាឌ្ឋ៍ល៍ អាល់-អាុប់បាស់ តំណាងអាស្ហ៍លុល-បៃត៍عليهم السلام បានទូលព្រះរៀមថា៖ "ហេតុអ្វីអស់ទូលបង្គំធ្វើដូច្នេះ ? អត់ពីព្រះអង្គصلوات الله عليه والسلامទៅ នឹងឲ្យអស់ទូលបង្គំរស់នៅជាមួយទង្វើនេះឬ ? ទេ យើងនឹងបួងសួងព្រះម្ចាស់ សូមព្រះអង្គعز وجلហាមឃាត់ទង្វើនេះ[210] ។"

កូនៗរបស់អាុគ៊ីល និងបណ្តាសាវកឯទៀតក៏មានឥរិយាបថបែបនេះដែរ ពួកគេត្រៀមខ្លួនបូជាជីវិតដើម្បីអ៊ីម៉ាំصلوات الله عليه والسلام ។ ហេតុដូច្នេះ ទាំងអស់គ្នាបានចំណាយពេលយប់នោះសក្ការៈនិងគោរពបូជាអល់ឡោះហ្ជ៍عز وجل ។ ទាំងអស់គ្នារង់ចាំថ្ងៃរះ ក្នុងថ្ងៃដែលពួកគេនឹងបានសម្រេចគោលដៅធំបំផុតក្នុងជីវិតលោកនេះ គោលដៅនោះគឺទុក្ករកម្មដោយបូជាជីវិត ។

## ព្រះនាងស្ហៃណាប់سلام الله عليهaភ័យរន្ធត់

អ៊ីម៉ាំ علي بن الحسين زين العابدين (អាុលី អ៊ីបនូ អាល់-ហ៊ូសៃន៍ ស្ហៃន៍ អាល់-អាុប៊ីឌីនصلوات الله عليه والسلام) អ្នករួចជីវិតពីសោកនាដកម្មការបាឡាអ៊ រ៍ មានវចនៈក្រោយមកថា៖ "ព្រះនាងស្ហៃណាប់سلام الله عليها ព្រះបិតុច្ឆារបស់ខ្ញុំ បាននៅព្យាបាលខ្ញុំ (ក្នុងយប់មុនថ្ងៃទី ១០ ខែមូហារ៉ម) ពេលព្រះបិតាខ្ញុំបានស្មឹងស្មាធ៏នៅក្នុងព្រះពន្លា ។ មានតែឃ្ជូវ៉ៃន៍ (جُوَين) បម្រើរបស់អាប៊ូ ស្ហារ៍ម្នាក់គត់ដែលនៅជាមួយព្រះអង្គصلوات الله عليه والسلام ដើម្បីជួសជុលដាវព្រះអង្គصلوات الله عليه والسلام ។ អ៊ីម៉ាំصلوات الله عليه والسلامមានវចនៈថា៖

*"ថ្ងៃអើយ គួរឲ្យស្អប់អ្នកណាស់ អ្នកជាមិត្តអន់មែន*
*ពេលព្រឹកនិងពេលព្រលប់ មានមនុស្សច្រើនពេកដែល*
*ស្លាប់ ឬ ដែលនៅដាច់ស្រយាលពីគេឯង*
*តែថ្ងៃមិនផ្លាស់ប្តូរឡើយ មិនខូចឡើយ*
*សត្វលោកគ្រប់រូបត្រូវបានទៅដល់អវសាន*
*អ្វីដែលចៀសមិនរួចនឹងកើតឡើងឆាប់ៗនេះ*

---

[210] សូមមើលសៀវភៅរបស់លោក អាប៊ូ មិក្ហណាហ្វ អាល់-អាស្ហ៍ឌី *ម៉ាក់ត៍តាល់-អាល់-ហ៊ូសៃន៍ (كتاب مقتل الحسين)* ទំព័រ ១៧៧ ។

*រឿងទាំងអស់នឹងវិលត្រឡប់ទៅឯព្រះដ៏មហាខ្ពង់ខ្ពស់បំផុត ។"*

ព្រះអង្គ(صلوات الله عليه والسلام)បានថាដូចនេះពីរឬបីដង លុះត្រាតែខ្ញុំយល់គោលបំណង ព្រះអង្គ(صلوات الله عليه والسلام) ។ ហេតុដូច្នេះ ខ្ញុំមិនអាចទប់ទឹកភ្នែកបានទេ ។ តែខ្ញុំព្យាយាមទប់យំ ព្យាយាមស្ងាត់មាត់ ។ ខ្ញុំបានយល់ថាយើងនឹងរងទុក្ខវេទនាអាក្រក់បំផុតអត់ពីព្រះអង្គ(صلوات الله عليه والسلام)ទៅ ។ ព្រះបិតុច្ឆាខ្ញុំ ព្រះនាងស៊ែណាប់(سلام الله عليها) ដូចស្ត្រីឯទៀតដែរដែលមានចិត្តទន់នោះ ពុំអាចទប់ខ្លួនបានទេ ។ ព្រះនាង(سلام الله عليها)បានរត់ទៅរកព្រះអង្គ(صلوات الله عليه والسلام) ក្បាលទទេ ស្រែកដាក់ព្រះអង្គ(صلوات الله عليه والسلام)ថា៖

وَاثُكْلَاهُ! وَا حُزْنَاهُ! لَيْتَ الْمَوْتَ اَعْدَمَنِيَ الْحَيَاةَ! يَا حُسَيْنَاهُ! يَا سَيِّدَاهُ! يَا بَقِيَّةَ اَهْلِ بَيْتَاهُ! اَسْتَسْلَمْتَ لِلْمَوْتِ وَ يَئِسْتَ مِنَ الْحَيَاةِ؟ الْيَوْمَ مَاتَ جَدِّيْ رَسُوْلَ اللهِ ، الْيَوْمَ مَاتَتْ اُمِّيْ فَاطِمَةُ الزَّهْرَاءُ وَ اَبِيْ عَلِيٌّ الْمُرْتَضٰي وَ اَخِيْ الْحَسَنُ الزَّكِيُّ. يَا خَلِيْفَةَ الْمَاضِيْنَ وَ ثِمَالَ الْبَاقِيْنَ.

*"ឱអនិច្ចា និរាសព្រះអង្គ(صلوات الله عليه والسلام) ឱអនិច្ចាសោកស្តាយព្រះអង្គ(صلوات الله عليه والسلام) សូមមរណៈផ្តាច់សង្ខារខ្ញុំម្ចាស់ ។ ឱអនិច្ចាអាល់-ហ៊ូសែន៍(صلوات الله عليه والسلام) ព្រះរាជអគ្គនាយកខ្ញុំម្ចាស់អឺយ ឱអនិច្ចាព្រះរាជវង្សតែមួយគត់របស់ខ្ញុំម្ចាស់ដែលនៅសេសសល់! ពិតមែនឬ ព្រះអង្គ(صلوات الله عليه والسلام)ព្រមចុះចាញ់សេចក្តីស្លាប់ មិនសង្ឃឹមគង់ព្រះជន្មទេ ? ថ្ងៃនេះឯងដែលព្រះអយ្យកោខ្ញុំម្ចាស់ ព្រះសាស្តា(صلى الله عليه وآله وسلم)របស់អល់ឡោះហ្(عز وجل) ព្រះមាតាខ្ញុំម្ចាស់ ហ្វាទីម៉ាស្ហ៍ អាស់-ស្ហាស្ហ៍រ៉អ៍(سلام الله عليها) ព្រះបិតាខ្ញុំម្ចាស់ អ៊ុាលី អាល់-មូរតាឌ្ហ៍(صلوات الله عليه والسلام) (علي المرتضی បុគ្គលរីករាយ) ព្រះរៀមខ្ញុំម្ចាស់ អាល់-ហ្ហាសាន់ អាល់-ស្ហាគី (الحسن الزكي សុក្រឹតបុគ្គល) បានចូលទិវង្គត ។ ព្រះអង្គ(صلوات الله عليه والسلام)ជាព្រះឧត្តរាធិការីរបស់វីរជនមុនៗ និងជាបុគ្គលចុងក្រោយបង្អស់ ក្នុងចំណោមវីរជនចុងក្រោយរបស់វីរជនមុនៗ ។"*

បានឮពាក្យពេជន៍ទាំងនេះពីព្រះអនុជាជាទីស្រឡាញ់ អ៊ីម៉ាំអាល់-ហ៊្វូសែន៍(صلوات الله عليه والسلام) មើលមុខព្រះនាង ហើយមានវចនៈថា៖

يَا اُخْتَاهُ، لَا يَذْهَبَنَّ بِحِلْمِكَ الشَّيْطَانُ.

*"ព្រះអនុជាជាទីស្រឡាញ់អើយ ចូរកុំបើកដៃឲ្យស្មែត្ន لعنه الله រំលាយការអត់ធ្មត់របស់នាងបានឡើយ ។"*

ព្រះនេត្រអ៊ីម៉ាំ صلوات الله عليه والسلام ជោកជាំដោយទឹកនេត្រា ព្រះអង្គ صلوات الله عليه والسلام មានវចនៈបន្ថែមថា៖ "ក្រោយពីពួកគេបានធ្វើឲ្យរៀមរើបម្រះ ពួកគេបានប្រព្រឹត្តមិនគប្បីមកលើរៀម ។"

បន្ទាប់មក ព្រះនាងបានស្រែកថា៖

يَا وَيْلَتَاهُ! اَتَغْتَصِبُ نَفْسَكَ اغْتِصَابًا؟ فَذَاكَ اَقْرَحُ لِقَلْبِيْ وَ اَشَدُّ عَلٰي نَفْسِيْ.

*"អពមង្គល ! ព្រះអង្គ صلوات الله عليه والسلام ដកជីវិតដោយកម្លាំងបាយឬ ? ខ្ញុំម្ចាស់ឈឺចាប់និងពិបាកអត់ទ្រាំរឿងនេះណាស់ ។"*

ព្រះនាងទះមុខ ហែកអាវខ្លួនឯង ហើយក៏ដួលបាត់ស្មារតីនៅលើដី ។ អ៊ីម៉ាំ صلوات الله عليه والسلام ស្ទុះទៅប្រោះទឹកលើមុខព្រះនាង ។ ពេលព្រះនាងដឹងខ្លួនវិញ ព្រះអង្គ صلوات الله عليه والسلام លួងលោមព្រះនាងថា៖

يَا أُخْتَاهُ! اِتَّقِيْ اللّٰهَ وَ تَعَزِّيْ بِعَزَاءِ اللّٰهِ وَ اعْلَمِيْ أَنَّ أَهْلَ الْأَرْضِ يَمُوْتُوْنَ وَ أَهْلَ السَّمَاءِ لَا يَبْقَوْنَ وَ أَنَّ كُلَّ شَيْءٍ هَالِكٌ إِلَّا وَجْهَ اللّٰهِ الَّذِي خَلَقَ الْخَلْقَ بِقُدْرَتِه وَ اِلَيْهِ يَعُوْدُوْنَ وَ هُوَ فَرْدٌ وَاحِدٌ. وَ اِنْ أَبِي خَيْرٌ مِنِّي وَ أَخِي خَيْرٌ مِنِّي وَ لِكُلِّ مُسْلِمٍ بِرَسُولِ اللّٰهِ أُسْوَة

يَا أُخْتَاهُ إِنِّي أَقْسَمْتُ عَلَيْكِ فَأَبِرِّي قَسَمِيْ: لَا تَشُقِّي عَلَيَّ جَيْبًا وَ لَا تَخْمِشِي عَلَيَّ وَجْهًا وَ لَا تَدْعِيْ عَلَيَّ بِالْوَيْلِ وَ الثُّبُورِ إِذَا أَنَا هَلَكْتُ.

*"ព្រះអនុជាជាទីស្រឡាញ់អើយ ចូរខ្លាចអល់ឡោះហ៍ عزّ وجلّ ចូរលួងលោមចិត្តខ្លួនឯងដោយការលួងលោមចិត្តដែលមកពីអល់ឡោះហ៍ عزّ وجلّ ចូរដឹងថាប្រជានិករផែនដីនេះនឹងស្លាប់ជាមិនខាន ឯប្រជានិករមេឃនឹងមិនរស់នៅរហូតទេ ។ ព្រះអនុជាបានដឹងស្រាប់ហើយថាសព្វសារពើនឹងវិនាសសូន្យបង់ លើកលែងតែអល់ឡោះហ៍ عزّ وجلّ ដែលបានបង្កើតសព្វសារពើដោយព្រះមហិទ្ធិឫទ្ធិព្រះអង្គ عزّ وجلّ ហើយអ្វីទាំងអស់នេះនឹងវិលប្រឡប់ទៅរកព្រះអង្គ عزّ وجلّ វិញ ។ មានតែព្រះអង្គ عزّ وجلّ មួយគត់ មានតែព្រះអង្គ عزّ وجلّ ឯកឯង ។ ព្រះបិតាប្រសើរជាងរៀម ព្រះរៀមប្រសើរជាងរៀម មុស្លីមគ្រប់រូបត្រូវយកគំរូតាម*

*ព្រះសាស្ដា*صلى الله عليه وآله وسلم*របស់អល់ឡោះហ៍*عز وجل *។*

*ព្រះអនុជាជាទីស្រឡាញ់អើយ វៀមសូមឲ្យព្រះអនុជានៅក្រោមសម្បថនេះ សូមកុំផ្ដាច់សម្បថនេះ ។ ចូរកុំហែកសំលៀកបំពាក់ឯងជាដាច់ខាត (ដើម្បីសម្ដែងនូវទុក្ខសោកចំពោះវៀម) ចូរកុំទះមុខខ្លួនឯងជាដាច់ខាត (ដើម្បីសោកស្ដាយការស្លាប់របស់វៀម) ចូរកុំបន់ស្រន់ប្រទេចអពមង្គលនិងវិនាសហិនហោចជាដាច់ខាតពេលវៀមស្លាប់ ។"*

បន្ទាប់មក អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلامបានជូនព្រះនាងទៅឯជំរំខ្ញុំ ។

សម្រាប់បណ្ដាសាវករបស់អ៊ីម៉ាំصلوات الله عليه والسلام យប់នោះជាយប់ដែលភ្លឺបំផុតក្នុងជីវិតពួកគេ ។ ពួកគេមិនអាចទ្រាំចាំថ្ងៃរះបានទេដើម្បីទៅកាន់ឋានសួគ៌ ហើយបានស្ថិតនៅក្នុងបរមសុខអមតៈ។ ឧទាហរណ៍ ហ្ាប៊ីប អ៊ីបនូ ម្វស្ឌ៏ហៀ៌ (حبيب بن مظاهر) សប្បាយចិត្តណាស់ ពេលគេសួរគាត់ថាហេតុអ្វីបានជាសប្បាយចិត្តម្ល៉េះនោះ គាត់បានតបថា៖ "នៅសល់តែពីរបីម៉ោងទៀតទេ ពួកកំណាចនឹងវាយប្រហារយើងដោយដាវ ដើម្បីនឹងឲ្យយើងបានថើបនារីសួគ៌ ។ ដូច្នេះ ពេលនេះគួរឲ្យអបអរសាទរណាស់ ។" បណ្ដាសាវកឯទៀតដែលមានជំនឿមាំឥតប្រែប្រួលនោះ ក៏បាននិយាយស្រដៀងនេះដែរ ។[211]

យប់នោះដែរ អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلامបានផ្ទំមួយល្បក់ ពេលព្រះអង្គصلوات الله عليه والسلام ភ្ញាក់វិញ ព្រះអង្គصلوات الله عليه والسلامបានថ្លែងសុបិនព្រះអង្គصلوات الله عليه والسلامប្រាប់ព្រះរាជវង្សនិងសាវកព្រះអង្គصلوات الله عليه والسلامថា៖ "ខ្ញុំបានសុបិនឃើញឆ្កែប្រយុទ្ធនឹងខ្ញុំយ៉ាងសាហាវទាល់តែបានខាំខ្ញុំ ។ ឆ្កែសាហាវជាងគេគឺឆ្កែពពាល ។ ខ្ញុំអាចកាត់សុបិននេះបានថាខ្ញុំនឹងត្រូវសម្លាប់ដោយដៃមនុស្សឃ្លង់ ។ ខ្ញុំបានឃើញក្នុងសុបិនដែរថាព្រះអយ្យកោខ្ញុំ ព្រះសាស្ដាصلى الله عليه وآله وسلمអល់ឡោះហ៍عز وجل ជាមួយសាវកព្រះអង្គصلى الله عليه وآله وسلمមួយក្រុម បានប្រាប់ខ្ញុំថា៖ "អ្នកصلوات الله عليه والسلامជាស្ហ៊ាហ៊ីដ្ធរបស់ព្រះរាជវង្សមូហាំម៉ាដ្ធ៍صلى الله عليه وآله وسلم ។ ប្រជានិករឋានសួគ៌ ជាពិសេសបុគ្គលខ្ពង់ខ្ពស់ មាន

---

[211] សូមមើលសៀវភៅរបស់លោក មូហ្ាំម៉ាដ្ធ៍ អ៊ីបនូ យ៉ាហ្វៀរ អាល់-ត៍្ឋបារី (محمد بن جرير طبري) *តារិក្ហ៍ អាល់-អ៊ូម៉ាំ វ៉ា អាល់-មុលុក (تاريخ الأمم والملوك)*, ក្បាលទី ៦ ទំព័រ ២៤១ ។

សេចក្តីសោមនស្សព្រោះពួកគេដឹងជាមុនថា អ្នកصلوات الله عليه والسلامនឹងបានមកជួបជុំពួកគេ ។ យប់នេះ សូមអ្នកصلوات الله عليه والسلامជាភ្ញៀវរបស់អយ្យកោ ។ ចូរប្រញាប់ឡើង កុំបង្អែបង្អង់ ។""[212]

យប់នោះដែរ ព្រះរាជវង្សភ័យព្រួយ ។ ម្នាក់ៗមិនធូស្រាកស្រាន្តចិត្តសោះ ខ្វល់តែគិតអំពីអនាគតអាក្រក់ ពេលអត់ពីព្រះអគ្គមគ្គទេសក៍និងព្រះអភិបាលរបស់ខ្លួន អ៊ីម៉ាំអាល់-ហ៊្វូសែន៍صلوات الله عليه والسلام ពេលអត់ពីអាប៊ូ អាល់-ហ្វាដ្ឍ៍ល៍ អាល់-អ៊្ពប់បាស់ និងពេលអត់ពីបុរសៗមេគ្រួសារខ្លួន ។ ទាំងអស់គ្នាពុំមានអាវុធណា ក្រៅពីការយំសោកនិងការបួងសួងអល់ឡោះហ្វ៍عز وجلទេ ។

បុគ្គលដែលកើតទុក្ខខ្លាំងជាងគេគឺព្រះអគ្គនាយិការបស់ពួកគេ ព្រះនាងស៊្សៃណាប់سلام الله عليها ដែលពិនិត្យមើលព្រឹត្តិការណ៍ទាំងអស់យ៉ាងយកចិត្តទុកដាក់ ហើយដឹងច្បាស់ថាការទទួលខុសត្រូវទាំងអស់នឹងធ្លាក់មកលើព្រះនាងسلام الله عليها ។ ព្រះនាងسلام الله عليهاដឹងជាមុនថាពុំមានបុរសព្រះរាជវង្សព្រះនាងسلام الله عليها ណាមួយនឹងរួចជីវិតទេក្រោយពីថ្ងៃស្អែក ស្អែកខ្មោងងឹត ។

ព្រោះតែបារម្ភព្រះរៀមព្រះនាង ព្រះនាងស៊្សៃណាប់سلام الله عليهاសម្លឹងមើលជំរំបក្សពួកនិងជំរំបានី ហ្វាស៊្ឝុំមដើម្បីនឹងដឹងនូវស្ថានភាពពិតរបស់ពួកគេ ដោយហេតុនេះ ព្រះនាងអាចដឹងថាពួកគេនឹងប្រព្រឹត្តបែបណាក្នុងថ្ងៃស្អែក ។ ដំបូងព្រះនាងទៅក្បែរជំរំ អាប៊ូ អាល់-ហ្វាដ្ឍ៍ល៍ អាល់-អ៊្ពប់បាស់ ព្រះអនុជព្រះនាង យ៉ាងស្ងាត់ៗ ទៅស្តាប់ព្រះអង្គពេលដែលព្រះអង្គកំពុងប្រាប់យុទ្ធសាស្ត្រដល់យុទ្ធជនបានី ហ្វាស៊្ឝុំម ។ អាល់-អ៊្ពប់បាស់បានថ្លែងថា៖ "បងប្អូន ក្មួយៗ និងបងប្អូនជីដូនមួយទាំងឡាយ តើយើងនឹងធ្វើអ្វីនៅពេលព្រឹក ?" ទាំងអស់គ្នាបានថា៖ "ព្រះអង្គជាអ្នកសម្រេច អស់ទូលបង្គំនឹងអនុវត្តិ ។" អាល់-អ៊្ពប់បាស់បានថ្លែងយ៉ាងក្លាហានថា៖ "បណ្តាបក្សពួកយើងនិងបណ្តាអ្នកគាំទ្រយើងពុំជាប់សាច់ញាតិយើងទេ ។ ត្រកូលយើងត្រូវតែទទួលបន្ទុកធ្ងន់ជាងគេ ។ ព្រឹកស្អែកនេះ យើងនឹងវាយលុកមុនគេ

[212] សូមមើលសៀវភៅរបស់លោក មូហ៊ាំម៉ាដ្ឌ៍ បាគ៊្វៀរ អាល់-ម៉ាច្ឈ៍លីស៊ី (محمد باقر المجلسي) *ប៊ីហ្ហារ អាល់-អាន់វ៉ារ (بحارالانوار)* ក្បាលទី ៤៥ ទំព័រ ៣ ។

យើងនឹងស្លាប់មុនកនយើង ដើម្បីនឹងកុំឲ្យគេស្ដីបន្ទោសយើង ។"
មុនព្រះអង្គនិយាយចប់ ទាំងអស់គ្នាបានស្រែកឡើងដោយសម្ដីតែមួយថា៖ "ទូលបង្គំទាំងអស់គ្នាយល់ស្របនឹងមតិនេះ ។"

ការសន្ទនាគ្នានេះបានធ្វើឲ្យព្រះនាងស៊ៃណាប់سلام الله عليهاមានសង្ឃឹមបន្តិច រួចហើយព្រះនាងسلام الله عليهاសំដៅទៅឯជំរំបក្សពួក ទៅស្ដាប់ពួកគេ ។ ពួកគេបានប្រជុំគ្នានៅក្នុងជំរំមេដឹកនាំពួកគេ ហាប៊ីប អ៊ីបនូ មូស្ហ៍ហ្ចៀរ៍ដែលសួរពួកគេថា៖ "កនយើង តើអស់លោកនឹងធ្វើអ្វីពេលព្រឹក ?" ពួកគេបានថា៖ "លោកជាអ្នកសម្រេច យើងនឹងអនុវត្តិ ។"

ហាប៊ីបបាននិយាយថា៖ "ស្អែកព្រឹក យើងនឹងចូលប្រយុទ្ធមុនគេ យើងស្លាប់មុនបានី ហាស៊ីម ។ យើងមិនត្រូវឃើញបានី ហាស៊ីមប្រទ្បាក់ឈាមជាដាច់ខាត ។ ពុំនោះទេ គេនឹងស្ដីបន្ទោសយើង ថាយើងទុកឲ្យពួកគេប្រយុទ្ធមុនយើងដើម្បីយើងនឹងអាចរួចជីវិតបាន ។" កនទាំងអស់បានស្រែកក្នុងសម្ដីតែមួយថា៖ "ហាប៊ីបអឺយ យើងយល់ស្របនឹងយោបល់នេះ ។"

ដូច្នេះ ព្រះនាងស៊ៃណាប់سلام الله عليهاបានយល់ថាបណ្ដាសាវកនឹងមិនបោះបង់អ៊ីម៉ាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلامជាដាច់ខាត ពួកគេនឹងការពារព្រះអង្គصلوات الله عليه والسلامលុះដល់ដង្ហើមចុងក្រោយ ។ បន្ទាប់ពីនោះ ព្រះនាងسلام الله عليهاទៅឯជំរំព្រះអគ្គនិយកអ៊ីម៉ាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلام ដើម្បីនាំដំណឹងនេះទៅប្រាប់ព្រះអង្គصلوات الله عليه والسلام ។ អ៊ីម៉ាំصلوات الله عليه والسلامអរព្រះគុណអល់ឡោះហ្ទ៍عزوجلដែលពួកគេមានទឹកចិត្ត ហើយព្រះអង្គصلوات الله عليه والسلامបានប្រាប់ព្រះនាងسلام الله عليهاថា អស់បុគ្គលទាំងនេះជាជនជម្រើសរបស់អល់ឡោះហ្ទ៍عزوجل ។[213]

## ថ្ងៃអាស៊ូរ៉អ៍ (عاشوراء)

ថ្ងៃអាស៊ូរ៉អ៍ ថ្ងៃទី ១០ ខែមូហារ៉ម ជាថ្ងៃដែលមានលក្ខណៈប្លែកគ្នាពីរ

[213] សូមមើលសៀវភៅរបស់ ស្ហៃខ៍ អាល់-ស៊ូរ៉យ់ហ្វី *ម៉ៅស៊ូអាស្ទ៍ កាឡីម៉ាត់ អាល់-អ៊ីម៉ាំ អាល់-ហ៊ូសៃន៍ (موسوعةُ كَلماتِ الامامِ الحُسَين عليه السّلام)* ទំព័រ ៤០៩ ។

ដែលសម្បូរដោយសោកនាដកម្ម ទុក្ខវេទនានិងមហន្តរាយ ។ ក្នុងថ្ងៃនោះ អាស្ហ៍លុល-បៃត៍عليهم السلامបានរងគ្រោះអាក្រក់បំផុតក្នុងលោកនេះ ។ ដោយហេតុនេះ ថ្ងៃនេះជាថ្ងៃមានទុក្ខ ។

ព្រលឹម ពេលអ៊ីម៉ាំអាល់-ហ៊្សៃន៍صلوات الله عليه والسلامបានចេញពីពន្លា នៅចំពីមុខព្រះអង្គصلوات الله عليه والسلامព្រះអង្គصلوات الله عليه والسلامឃើញយុទ្ធជនច្រើនឥតគណនានិងសេះពួកគេ ពេញវាលរហោឋាន ប្រដាប់ដាវក្នុងស្រោម ប៉ងបង្ហូរឈាមព្រះអង្គصلوات الله عليه والسلام ។ ដូច្នេះ ព្រះអង្គصلوات الله عليه والسلامបានឲ្យគេយកគម្ពីរអានមួយមកឲ្យព្រះអង្គصلوات الله عليه والسلام មកដាក់លើព្រះសិរព្រះអង្គصلوات الله عليه والسلام ហើយព្រះអង្គصلوات الله عليه والسلامលើកដៃឡើងដើម្បីបួងសួងសូមជម្រកពីព្រះម្ចាស់عزّ وجلّព្រះអង្គعزّ وجلّថា៖

اَللّٰهُمَّ أَنْتَ ثِقَتِيْ فِي كُلِّ كَرْبٍ وَ رَجَائِي فِي كُلِّ شِدَّةٍ وَ أَنْتَ لِي فِي كُلِّ أَمْرٍ نَزَلَ بِي ثِقَةٌ وَ عِدَّةٌ. كَمْ مِنْ هَمٍّ يَضْعُفُ فِيهِ الْفُؤَادُ وَ تَقِلُّ فِيهِ الْحِيلَةُ وَ يَخْذُلُ فِيْهِ الصَّدِيْقُ وَ يَشْمَتُ فِيْهِ الْعَدُوُّ أَنْزَلْتُهُ بِكَ وَ شَكَوْتُهُ إِلَيْكَ رَغْبَةً مِنِّي إِلَيْكَ عَمَّنْ سِوَاكَ فَفَرَّجْتَهُ وَ كَشَفْتَهُ فَأَنْتَ وَلِيُّ كُلِّ نِعْمَةٍ وَ صَاحِبُ كُلِّ حَسَنَةٍ وَ مُنْتَهٰى كُلِّ رَغْبَةٍ.

*"អល់ឡោះហ៍عزّ وجلّអឺយ ទូលព្រះបង្គំជាខ្ញុំសូមទុកកាយថ្វាយចិត្តលើព្រះអង្គعزّ وجلّក្នុងគ្រាអាសន្ន សូមផ្ញើខ្លួនលើព្រះអង្គعزّ وجلّដោយសេចក្ដីសង្ឃឹមក្នុងពេលទុក្ខ (គឺទុក្ខធំ) សូមផ្ញើជំនឿនិងសេចក្ដីសង្ឃឹមលើព្រះអង្គعزّ وجلّក្នុងគ្រាពើបពះទុក្ខវេទនា ។ ទុក្ខព្រួយច្រើនគាបសង្កត់ចិត្តទូលព្រះបង្គំជាខ្ញុំ ដែលពិបាកព្យាបាល វាធ្វើឲ្យមិត្តទូលព្រះបង្គំជាខ្ញុំធ្វើឲ្យទូលព្រះបង្គំជាខ្ញុំខកចិត្ត វាធ្វើឲ្យសត្រូវទូលព្រះបង្គំជាខ្ញុំសប្បាយលើគំនរទុក្ខទូលព្រះបង្គំជាខ្ញុំ ។ តែពេលទូលព្រះបង្គំជាខ្ញុំថ្លែងនិងត្អូញត្អែរទុក្ខព្រួយទាំងនេះប្រាប់ព្រះអង្គعزّ وجلّ ព្រោះទូលព្រះបង្គំជាខ្ញុំមានតែព្រះអង្គعزّ وجلّមួយនៅក្នុងចិត្ត ពុំមានអ្នកណាផ្សេងឡើយ ព្រះអង្គعزّ وجلّជួយរំលែកទុក្ខព្រួយទាំងនោះ ហើយព្រះអង្គعزّ وجلّបានជួយ ។ ព្រះអង្គعزّ وجلّពិតជាព្រះម្ចាស់នៃសព្វធម៌មេត្តា ជាដើមកំណើតនៃសប្បុរសធម៌ទាំងអស់ មានតែព្រះអង្គعزّ وجلّមួយទេដែលសក្តិសមនឹងនឹករលឹកដល់ ។"*[214]

---

[214] សូមមើលសៀវភៅរបស់លោក អាល់-នូរី អាល់-តាប់រ៉ស៊ី (النوري الطبرسي)

បន្ទាប់ពីនោះ ព្រះអង្គ صلوات الله عليه والسلام បានទៅប្រកាសប្រាប់កងទ័ពទាំងនោះ ដើម្បីនឹងឲ្យពួកគេដឹងស្ថានភាពពិត ។ ព្រះអង្គ صلوات الله عليه والسلام បានជិះសេះទៅរកពួកគេ ដំឡើងសម្លេងបន្លឺពាក្យពេជន៍ប្រកបដោយឧត្តមគតិ ដើម្បីនឹងឲ្យពួកគេយ៉ាងហោចណាស់ បានឮសម្លេងព្រះអង្គ صلوات الله عليه والسلام ថា៖[215]

أَمَّا بَعْدُ فَتَبًّا لَكُمْ أَيَّتُهَا الْجَمَاعَةُ وَ تَرْحًا حِينَ اسْتَصْرَخْتُمُوْنَا وَالِهِيْنَ فَأَصْرَخْنَاكُمْ مُوْجِفِيْنَ سَلَلْتُمْ عَلَيْنَا سَيْفًا كَانَ فِي أَيْمَانِنَا وَ حَشَشْتُمْ عَلَيْنَا نَارًا اقْتَدَحْنَاهَا عَلٰى عَدُوِّنَا وَ عَدُوِّكُمْ فَأَصْبَحْتُمْ إِلْبًا عَلٰى أَوْلِيَائِكُمْ وَ يَدًا لِأَعْدَائِكُمْ بِغَيْرِ عَدْلٍ أَفْشَوْهُ فِيكُمْوَ لَا لِأَمَلٍ أَصْبَحَ لَكُمْ فِيهِمْ وَ عَنْ غَيْرِ حَدَثٍ كَانَ مِنَّا وَ لَا رَأْيٍ تَفَيَّلَ عَنَّا فَهَلَّا – لَكُمُ الْوَيْلَاتُ – تَرَكْتُمُوْنَا وَ السَّيْفُ مَشِيْمٌ وَ الْجَأْشُ طَامِنٌ وَ الرَّأْيُ لَمْ يُسْتَحْصَفْ. وَ لٰكِنِ اسْتَسْرَعْتُمْ إِلَيْهَا كَتَطَائِرِ الدِّبَا وَ تَدَاعَيْتُمْ عَنْهَا كَتَدَاعِي الْفَرَاشِ. فَسُحْقًا وَ بُعْدًا لِطَوَاغِيْتِ الْأُمَّةِ وَ شِذَّاذِ الْأَحْزَابِ وَ نَبَذَةِ الْكِتَابِ وَ نَفَثَةِ الشَّيْطَانِ وَ مُحَرِّفِي الْكَلَامِ وَ مُطْفِئِي السُّنَنِ وَ مُلْحِقِي الْعَهَرَةِ بِالنَّسَبِ الْمُسْتَهْزِئِيْنَ الَّذِيْنَ جَعَلُوْا الْقُرْآنَ عِضِيْنَ.

*"ប្រជានិករអស់ទាំងនេះអើយ ចូរសេចក្តីអាម៉ាស់និងទុក្ខព្រួយពើបពះលើអស់លោក ។ កាលអស់លោកបានហៅរកជំនួយពេលអស់លោកមានទុក្ខ យើងរូសរាន់មកជួយអស់លោកដោយនឿយហត់ អស់លោកបានហូតដាវដាក់យើង ដាវដែលធ្លាប់បាននៅក្នុងដៃស្តាំយើង (ពោលគឺ ក្បត់យើង) អស់លោកបានបង្កាត់ភ្លើងប្រឆាំងយើង ភ្លើងដែលយើងបានបង្កាត់ប្រឆាំងនឹងសត្រូវរបស់អស់លោកនិងសត្រូវរបស់យើង ។ អស់លោកបានប្រួតគ្នាជាក្រុមដើម្បីឡោមព័ទ្ធសម្ព័ន្ធមិត្តរបស់អស់លោក អស់លោកក្លាយទៅជាអ្នកគាំទ្រពួកសត្រូវរបស់អស់លោក ទោះបីពួកគេពុំបាន*

---

*មុសតាដ្រ៉ក់ អាល់-វ៉ាសាអ៊ីល (مُستَدرَكُ الوَسائل)* ក្បាលទី ១១ ទំព័រ ១១២ ថ្លែងនៅក្នុងសៀវភៅរបស់លោក អាល់-ស្ហៃខ៍ អាល់-មូហ្ស៊ីដ្ឋ *អាល់-អៀរស្ហាដ្ឋ៍*។

[215] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ស្ហុអ៊្ប៊ាស្ហ៊ុ អាល់-ហ្ហារ៉ានី (بن شعبه الحرَّاني) *ទូហ្ហាហ្វ អាល់-អ៊ូគូល (تُحَفُ العُقول)* ជាភាសាអង់គ្លេស Tuhaf al-Uqul; the Masterpieces of the Intellects, p. 282, translated by Badr Shahin, First Edition, Ansariyan Publications, 2001.

*ប្រព្រឹត្តយុត្តិធម៌ទៅលើអស់លោក ឯអស់លោកអស់សង្ឃឹមលើពួកគេក៏ដោយ ។ លើសពីនេះ អស់លោកដឹងច្បាស់ថាយើងពុំបានក្បត់សាសនា ឬពុំបានប្រឌិតឡើងនូវគំនិតថ្មីឡើយ ។ អពមង្គលលើអស់លោក ហេតុអ្វីអស់លោកមិនចាកចោលយើងខណៈដែលដាវនៅក្នុងស្រោម ខណៈដែលអំពើអាក្រក់មិនទាន់ចេញមុខ និងខណៈដែលមិនទាន់បានសម្រេចចិត្តទេនោះ ? តែអស់លោកស្ទុះទៅរកការបង្កចលាចលដូចកណ្តូបចោមរោមចលាចលនោះដូចហ្វូងមេអំបៅ ។ សូមចង្រៃឧបទ្រពនិងវិនាសហិនហោចពើបពះលើពួកត្ថ៏គូត (គឺពួកកំណាច សាហាវ ព្រៃផ្សៃ) នៃអ៊ុមម៉ាត់នេះ ពួកមិនទៀងទាត់ក្នុងក្រុមទាំងនេះ ពួកចោលព្រះគម្ពីរ ពួកភ្នាក់ងារដៃគូរបស់ស្ហៃតនﷻ ពួកបំភ្លៃអត្ថន័យ ពួកបំបាត់ប្រពៃណី[ព្រះសាស្តាﷺ] ពួកដែលប្តេជ្ញាស្មោះស្ម័គ្របុគ្គលខុសច្បាប់ បុគ្គលចំអកនិងបំបែកគួរអាន - ដោយជឿតែមួយផ្នែក ចោលផ្នែកឯទៀត ។*

أَ هٰؤُلَاءِ تَعْضُدُوْنَ وَ عَنَّا تَتَخَاذَلُوْنَ؟ أَجَلْ وَ اللّٰهِ اِنَّهُ لَخَذْلٌ فِيْكُمْ مَعْرُوْفٌ، قَدْ وَشَجَتْ عَلَيْهِ عُرُوْقُكُمْ وَ تَوَارَتْ عَلَيْهِ اُصُوْلُكُمْ فَكُنْتُمْ أَخْبَثَ ثَمَرَةٍ شَجًا لِلنَّاظِرِ وَ أُكْلَةً لِلْغَاصِبِ. أَلَا فَلَعْنَةُ اللّٰهِ عَلَى النَّاكِثِيْنَ الَّذِيْنَ يَنْقُضُوْنَ الْأَيْمَانَ بَعْدَ تَوْكِيْدِهَا وَ قَدْ جَعَلُوْا اللّٰهَ عَلَيْهِمْ كَفِيْلًا أَلَا وَ إِنَّ الدَّعِيَّ ابْنَ الدَّعِيِّ قَدْ رَكَزَ مِنَّابَيْنَ اثْنَتَيْنِ بَيْنَ السِّلَّةِ وَ الذِّلَّةِ، وَ هَيْهَاتَ مِنَّا الذِّلَّةِ: يَأْبِي اللّٰهُ لَنَا ذٰلِكَ وَ رَسُوْلُهُ وَ الْمُؤْمِنُوْنَ وَ حُجُوْرٌ طَابَتْ وَ اُنُوْفٌ حَمِيَّةٌ وَ نُفُوْسٌ اَبِيَّةٌ اَنْ تُؤْثِرَ طَاعَةَ اللِّئَامِ عَلٰي مَصَارِعِ الْكِرَامِ. وَ اِنِّيْ زَاحِفٌ اِلَيْهِمْ بِهٰذِهِ الْاُسْرَةِ عَلٰي كَلَبِ الْعَدُوِّ وَ كَثْرَةِ الْعَدَدِ وَ خِذْلَةِ النَّاصِرِ.

*ហេតុអ្វីអស់លោកគាំទ្រពួកគេ ធ្វើឲ្យយើងខូចចិត្ត ? មែនហើយ ហេតុអ្វីអស់លោកមិនអាចធ្វើដូច្នេះបាន ? ខ្ញុំសូមស្បថក្នុងព្រះនាមអល់ឡោះហ៊្ ﷻ ការគ្មានភ័ក្តីភាពរបស់អស់លោកនោះមិនចម្លែកទេ ព្រោះវាវ័ណ្ឋជាប់នឹងសរសៃឈាមរបស់អស់លោក វាមានឡើងវិញនៅក្នុងពូជពង្សអស់លោក ។ អស់លោកជាផ្លែដ៏ល្វីងដែលធ្វើឲ្យអ្នកថែរក្សាស្លាក់ក ដែលផ្តល់*

*រស់ជាតិផ្អែមឆ្ងាញ់ឲ្យទៅអ្នកប្អូនវា ។ សូមអល់ឡោះហ៍ عزّ وجلّ ដាក់បណ្ដាសាពួកដែលគ្មានភ័ក្ដីភាព ពួកដែលមិនគោរពពាក្យសម្បថបន្ទាប់ពីបានស្បថដោយបានយកអល់ឡោះហ៍ عزّ وجلّ ជាសាក្សីហើយ ។ បុគ្គលខុសច្បាប់ កូនរបស់បុគ្គលខុសច្បាប់ បានបង្ខំឲ្យខ្ញុំជ្រើសយកវត្ថុមួយ ក្នុងចំណោមវត្ថុពីរ គឺ៖ ហូតដាវ ឬ ទុរយស ។ យើងមិនអាចទទួលយកទុរយសបានជាដាច់ខាត ។ អល់ឡោះហ៍ عزّ وجلّ ព្រះសាស្ដា صلى الله عليه وآله وسلم ព្រះអង្គ عزّ وجلّ បណ្ដាអ្នកមានសទ្ធាជ្រះថ្លា អ្នកភ្លៅបរិសុទ្ធ (គឺអ្នកមានគុណ ?) អ្នករាំងខ្លួន និងអ្នកមានអាត្ម័នថ្លៃថ្នូរមិនសុខចិត្តឲ្យយើងឱនក្បាលទៅរកអំពើកំណាច ចោលការស្លាប់ក្នុងសេចក្ដីថ្លៃថ្នូរនោះឡើយ ។ ដូច្នេះ ខ្ញុំដើរសំដៅទៅរកពួកទាំងនោះ ជាមួយក្រុមគ្រួសារនេះ ទោះជាពួកសត្រូវប្រួតដៃគ្នា ទោះជាពួកសត្រូវមានគ្នាច្រើន ទោះជាមានពួកអ្នកគាំទ្រក្បត់ក៏ដោយ ។"*

បន្ទាប់ពីនោះ ព្រះអង្គ صلوات الله عليه والسلام បានថ្លែងពាក្យកាព្យដូចតទៅ៖[216]

*បើយើងឈ្នះ យើងធ្លាប់តែជោគជ័យ*
*បើយើងចាញ់ យើងមិនដែលទន់ខ្សោយទេ*
*កំសាកមិនមែនចរិតយើងទេ តែសម្រាប់យើង*
*វាជាឱកាសស្លាប់ និងជាឱកាសរបស់អ្នកឯទៀតដែលកាន់អំណាច*
*បើការស្លាប់ត្រូវពន្យារសម្រាប់អ្នកខ្លះ*
*វាប្រាកដជាពើបពះលើអ្នកឯទៀតជាមិនខាន*
*ដូច្នេះឯងបានជាវាពើបពះលើបុគ្គលល្បីៗនៃត្រកូលខ្ញុំ*
*ដូចដែលវាបានបញ្ចប់ជីវិតមនុស្សមុនៗដែរ*
*បើស្ដេចរស់នៅរៀងរហូត យើងក៏រស់នៅរៀងរហូតដែរ*
*បើមេដឹកនាំត្រូវទ្រុទ្រង់ យើងក៏ត្រូវទ្រុទ្រង់ដែរ*
*ដូច្នេះ ចូរប្រាប់បណ្ដាអ្នកសប្បាយលើគំនរទុក្ខយើងថា៖ ឈប់សិន*
*អស់លោកប្រាកដជានឹងជួបប្រទះជោគវាសដូចគ្នា ។*

---

[216] សូមមើលសៀវភៅរបស់ សៃយីដ្ធ មុះហ៊ុស៊ីន អាល់-អាមីន អាល់-អាមីលី (محسن الأمين العاملي) *ឡាវ៉ាអ៊ីជ្ជ អាល់-អាស្ជ៉ាន់* (لواعج الاشجان) ទំព័រ ១៣១ ។

اَمَا وَاللهِ لَا يَلْبَثُوْنَ اِلاَّ كَرَيْثِ مَا يُرْكَبُ الْفَرَسُ حَتّٰي تَدُوْرَ رَحَا الْحَرْبِ وَ تُعَلَّقَ النُّحُوْرُ. عَهْدٌ عَهِدَهُ اِلَيَّ اَبِيْ عَنْ جَدِّيْ، (صلى الله عليه و آله و سلم). فَاَجْمِعُوْا اَمْرَكُمْ ثُمَّ كِيْدُوْنِ فَلَا تُنْظِرُوْنِ، إِنِّي تَوَكَّلْتُ عَلَى اللهِ رَبِّي وَرَبِّكُمْ مَا مِنْ دَابَّةٍ إِلَّا هُوَ آخِذٌ بِنَاصِيَتِهَا إِنَّ رَبِّي عَلٰى صِرَاطٍ مُسْتَقِيْمٍ.

*"ខ្ញុំសូមស្បថក្នុងព្រះនាមអល់ឡោះហ៑عزوجل គេនឹងមិនទុកពេលឲ្យអស់លោកយូរទេ បន្តិចទៀត សេះនឹងត្រឡប់ទៅវិញ ថ្ងៃនឹងវិលជុំវិញអស់លោកដូចត្បាល់កិន សង្គ្រាមនឹងឆេះឡើង កនឹងត្រូវកាត់ ។ ព្រះបិតាខ្ញុំ ត មកពីព្រះអយ្យកោខ្ញុំ បានថ្លែងរឿងនេះប្រាប់ខ្ញុំ ។ ដូច្នេះ ចូរអស់លោករៀបផែនការប្រឆាំងខ្ញុំកុំបង្អង់ ។ ខ្ញុំទុកចិត្តលើអល់ឡោះហ៑عزوجل ព្រះម្ចាស់ខ្ញុំ និងអស់លោក ។ មានតែអល់ឡោះហ៑عزوجلទេជាអ្នកគ្រប់គ្រងវាសនាសត្វលោកទាំងអស់ ។ មានតែព្រះម្ចាស់عزوجلខ្ញុំទេដែលដឹងផ្លូវត្រូវ ។"*

បន្ទាប់មក អ៊ីម៉ាំអាល់-ហ៊្សសែន៑صلوات الله عليه والسلام លើកដៃទាំងពីរឡើងទៅរកមេឃ ហើយបួងសួងសូមអល់ឡោះហ៑عزوجلដាក់បណ្ដាសាពួកគេ ថា៖[217]

اَللّٰهُمَّ احْبِسْ عَنْهُمْ قَطْرَ السَّمَاءِ وَ ابْعَثْ عَلَيْهِمْ سِنِيْنَ كَسِنِي يُوسُفَ وَ سَلِّطْ عَلَيْهِمْ غُلَامَ ثَقِيفٍ يَسُوْمُهُمْ كَأْساً مُصَبَّرَةً فَإِنَّهُمْ كَذَّبُونَا وَ خَذَلُونَا وَ أَنْتَ رَبُّنَا عَلَيْكَ تَوَكَّلْنا وَ إِلَيْكَ أَنَبْنا وَ إِلَيْكَ الْمَصِيرُ.

*"អល់ឡោះហ៑عزوجلអើយ សូមព្រះអង្គعزوجلកុំឲ្យពួកគេបាននូវសព្វសាធុពរដែលមកពីលើមេឃ សូមព្រះអង្គعزوجلធ្វើឲ្យពួកគេរងទុក្ខដោយជាប់ឃុំឃាំងច្រើនឆ្នាំ ដូចបុគ្គលទាំងនោះដែរក្នុងសម័យព្រះសាស្ដាយូស៊ុហ្វعليه السلام សូមព្រះអង្គصلوات الله عليه والسلامតែងតាំងបុរសកុលសម្ព័ន្ធស្សាគ៊ីហ្វ[218] ម្នាក់ ឲ្យគ្រប់គ្រងពួកគេ*

---

[217] សូមមើលសៀវភៅរបស់ សៃយីដ្ មូរតាឌ៏ អាល់-អាស់ការី (سيّد مُرتضى العَسكري) *ម៉ាអាលីម អាល់-ម៉ាដ្ទ័រ៉សាតែន៍ (معالم المدرستين)* ក្បាលទី ៣ ទំព័រ ១០១ ។

[218] បុរសកុលសម្ព័ន្ធស្សាគ៊ីហ្វ គឺអាល់-មុក្ខតារ អ៊ីបនូ អាប៊ូ អ៊ូបៃដ្ហាស្ អាល់-ស្សាគ៊ីហ្វី (المختار بن أبي عبيدة الثقفي) ដែលបានដឹកនាំបដិវត្តន៍ក្រោយពីអ៊ីម៉ាំអាល់-ហ៊្សសែន៑صلوات الله عليه والسلامបានទទួលទុក្ករកម្ម ហើយបានសងសឹកសងវិញលើពួកដែលបាន

*ដោយអំណាចផ្តាច់ការ គាបសង្កត់ពួកគេយ៉ាងឃឺចាប់បំផុត ព្រោះពួកគេបានបោកប្រាស់អស់ទូលព្រះបង្គំជាខ្ញុំ បានធ្វើឲ្យអស់ទូលព្រះបង្គំជាខ្ញុំខកចិត្ត ។ ព្រះអង្គعزّ وجلជាព្រះម្ចាស់របស់អស់ទូលព្រះបង្គំជាខ្ញុំ អស់ទូលព្រះបង្គំជាខ្ញុំអាស្រ័យលើព្រះអង្គعزّ وجل អស់ទូលព្រះបង្គំជាខ្ញុំទុកចិត្តលើព្រះអង្គعزّ وجل សព្វសារពើនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់ព្រះអង្គعزّ وجل ។"*

ព្រះរាជវង្សបានឮពាក្យពេជន៍នេះខ្លះ បានយំស្រែក តែអ៊ីម៉ាំصلوات الله عليه والسلامបានឲ្យអាល់-អ៊ាប់បាស់ ព្រះអនុជព្រះអង្គصلوات الله عليه والسلامនិងអ៊ាលី អាល់-អាក់បារ៍ ព្រះរាជបុត្រព្រះអង្គصلوات الله عليه والسلام សូមឲ្យទាំងអស់គ្នាឈប់យំស្រែក ។ រួចហើយព្រះអង្គصلوات الله عليه والسلامថ្លែងពាក្យពេជន៍ប្រចះត្រចង់តទៀត ដែលគួរតែនាំបុគ្គលវៀចវេរគ្រប់រូបទៅរកផ្លូវល្អ ។ ប៉ុន្តែទ័ពអ៊ូម៉ៃយ៉ាស់មិនអាចយល់សម្តីអ៊ីម៉ាំصلوات الله عليه والسلامទេ ព្រោះពួកគេអវិជ្ជាមោហ៍បាំងពេក មិនអាចយល់អ្វីបានក្រៅពីយល់អារម្មណ៍ឧក្រិដ្ឋនោះទេ ។ ក៏ប៉ុន្តែពួកគេពុំអាចនិយាយអ្វីបានឡើយជាចម្លើយតបអ៊ីម៉ាំصلوات الله عليه والسلامអាល់-ហ៊្វសែន៍صلوات الله عليه والسلام ។

អ៊ីម៉ាំصلوات الله عليه والسلامបាននិយាយសំដៅពួកគេមួយចំនួនជាពិសេស ហើយបានរំលឹកពួកគេអំពីសារទាំងឡាយដែលពួកគេបានផ្ញើទៅព្រះអង្គصلوات الله عليه والسلام តែពួកគេបានបដិសេធរឿងនេះទាំងអស់ ។

---

ប្រយុទ្ធទល់នឹងអ៊ីម៉ាំصلوات الله عليه والسلام ឬ អាល់-ហាជ៉្ជ៉ាជ់ អ៊ីបនូ យូស៊ុហ្វ អាល់-សាគ៊ីហ្វី ដែលមានសេរីភាពប្រព្រឹត្តតាមអំពើចិត្តលើអ្នកស្រុកគូហ្វាស់ ដោយហេតុនេះបានកាន់ក្តាប់ពួកគេដោយគាបសង្កត់បំផុត ។ ប៉ុន្តែ ស្ហៃខ៍ អាល់-ស្ហ៊ូរ៉យ៉ហ្វី នៅក្នុងសៀវភៅលោកដែលមានចំណងជើងថា *ម៉ៅស៊ូអ៊ាស់ កាឡីម៉ាត់ អាល់-អ៊ីម៉ាំ អាល់-ហ៊្វសែន៍ (موسوعةُ كَلماتِ الامامِ الحُسَين عليه السّلام)* ទំព័រ ៤២៣ និងលោកអ៊ាប់ឌុលឡោះហ្វ៍ អាល់-បាស៊ូរ៉នី នៅក្នុងសៀវភៅលោកដែលមានចំណងជើងថា *អាល់-អ៊ាវ៉ាលីម អាល់-អ៊ីម៉ាំ អាល់-ហ៊្វសែន៍* ទំព័រ ២៥៣ បានកត់ត្រាបន្ថែមពីលើការបួងសួងរបស់អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلامនូវពាក្យពេជន៍នេះគឺ៖ "សូមព្រះអង្គصلوات الله عليه والسلامតែងតាំងបុរសកុលសម្ព័ន្ធស្ហាគ៊ីហ្វម្នាក់ ឲ្យគ្រប់គ្រងពួកគេដោយអំណាចផ្តាច់ការ សម្លាប់ពួកគេទាំងអស់គ្នា ម្នាក់ៗឲ្យស្លាប់យ៉ាងសក្តិសមនឹងការចូល [ក្នុងការប្រយុទ្ធទល់នឹងអ៊ីម៉ាំصلوات الله عليه والسلام] ។" ដោយហេតុនេះ "បុរសកុលសម្ព័ន្ធស្ហាគ៊ីហ្វ" គឺអាល់-មុក្តារ អ៊ីបនូ អាប៊ូ អ៊ូបៃដ្ហាស់ អាល់-ស្ហាគ៊ីហ្វី ។

ក្វយ៍ស៍ អ៊ីបនូ អាល់-អាស្វ់អាស្វ់ (قيس بن أشعث) បានស្នើសូមឲ្យអ៊ីម៉ាំصلوات الله عليه والسلام ចុះចាញ់ ព្រមចុះចូលក្រោមរដ្ឋបាលអ៊្វម៉ៃយ៉ាស្វ់ តែអ៊ីម៉ាំصلوات الله عليه والسلامបានបដិសេធយ៉ាងក្លាហាន យ៉ាងម៉ឺងម៉ាត់ ដោយប្រកាសមិនផ្លាស់ប្តូរគោលជំហរថា៖

لاَ و اللهِ! لا أُعْطِيْكُمْ بِيَدِي إِعْطَاءَ الذَّلِيْلِ وَلاَ أُقِرُّ لَكُمْ اِقْرَارَ العَبِيْدِ.

*"ទេ សូមស្បថចំពោះអល់ឡោះហ៍عزّ وجلّ ខ្ញុំនឹងមិនហុចដៃទៅរកអស់លោកដូចបុគ្គលថោកទាបជាដាច់ខាត ខ្ញុំនឹងមិននៅក្រោមបង្គាប់អស់លោក ដូចទាសៈជាដាច់ខាត ។"*

បណ្តាសាវកអ៊ីម៉ាំصلوات الله عليه والسلامក៏បាននិយាយស្រដៀងនេះដែរ នៅចំពោះមុខទ័ពអ៊្វម៉ៃយ៉ាស្វ់ តែឥតប្រយោជន៍ ។

ទីបំផុត អ៊ីម៉ាំصلوات الله عليه والسلامបានព្រមានពួកគេម្តងទៀត ដើម្បីនឹងកុំឲ្យអ្នកណាម្នាក់ឆ្លើយដោះសាថាពុំបានដឹងរឿងនោះច្បាស់ទេ ។

ក្នុងពេលនេះ អាល់-ហ៊្វរភ្ញាក់ស្មារតី ។ គាត់ចាប់ផ្តើមគិតអំពីជោគវាសនាគាត់បើគាត់ប្រយុទ្ធទល់នឹងអ៊ីម៉ាំអាល់-ហ៊្វសៃន៍صلوات الله عليه والسلام ដែលជាតំណាងបក្សត្រឹមត្រូវនិងជាតំណាងសាសនាពិតរបស់អល់ឡោះហ៍عزّ وجلّ ។ ទីបំផុតគាត់បានសម្រេចចិត្តនៅខាងព្រះអង្គصلوات الله عليه والسلام ។ គាត់បានទៅសួរអ៊្វម៉ារថា៖ "តើលោកចង់ប្រយុទ្ធនឹងបុរសនោះមែនឬ ?" អ៊្វម៉ារបានឆ្លើយថា៖ "មែន ។ ខ្ញុំចង់ប្រយុទ្ធណាស់ បើខ្ញុំអាចធ្វើបាន ។" អាល់-ហ៊្វរបានសួរថា៖ "ហេតុអ្វីលោកមិនឆ្លើយតបការអំពាវនាវរបស់បុរសនេះ ព្រមទទួលជម្រើសដែលគេដាក់ឲ្យរើសនោះ ?" អ៊្វម៉ារបានឆ្លើយថា៖ "ខ្ញុំនឹងជ្រើសរើសបើខ្ញុំមានសិទ្ធិជ្រើសរើស ។ តែរឿងនេះមិនមែនរឿងខ្ញុំទេ វាជារឿងរបស់អភិបាលលោក ។"

ក្នុងពេលនោះ អាល់-ហ៊្វរដឹងច្បាស់ថាអ៊្វម៉ារប្រុងខ្លួនប្រយុទ្ធទល់នឹងអ៊ីម៉ាំអាល់-ហ៊្វសៃន៍صلوات الله عليه والسلامជាស្រេច ។ ដូច្នេះ គាត់បានទៅរកអ៊ីម៉ាំصلوات الله عليه والسلام ព្រោះគាត់ស្តាយក្រោយដែលបានធ្វើមិនគប្បីចំពោះព្រះអង្គصلوات الله عليه والسلام ។

ពេលអ៊ីម៉ាំصلوات الله عليه والسلامបានលើកទោសឲ្យគាត់[219] អាល់-ហ៊្វរបានបែរមុខទៅរក

[219] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាល់-អាស្សៀរ *អាល់-កាមីល ហ្វី អាល់-*

ទ័ពរបស់អ៊ុម៉ារ បានថ្លែងពាក្យស្ដីបន្ទោសដែលបានធ្វើឲ្យអ៊ីម៉ាំ صلوات الله عليه والسلام ខកចិត្ត ។ តែសម្ដីគាត់ពុំបានជ្រាបចូលទៅក្នុងក្រអៅបេះដូងពួកគេទេ ។

## សង្គ្រាម

ព្រោះតែអ៊ុម៉ារ អ៊ីបនូ សាអាដ្ឋ់គិតជាមុនថាពួកមេដឹកនាំឯទៀតនឹងយកតម្រាប់តាមអាល់-ហ៊្វូរបានជាគាត់សម្រុកចូលទៅឯទីតាំងអ៊ីម៉ាំ صلوات الله عليه والسلام បាញ់ព្រួញមួយគ្រាប់ដោយស្រែកថា៖ "ចូរជាសាក្សីថាខ្ញុំជាអ្នកបាញ់អាល់-ហ៊្វូសៃន៍ صلوات الله عليه والسلام មុនគេ ។"

នេះគឺការបើកផ្លូវ ឲ្យគ្រាប់ព្រួញរាប់រយបោះពួយសំដៅទីតាំងអ៊ីម៉ាំ صلوات الله عليه والسلام ។ ឃើញស្ថានការណ៍នេះ អ៊ីម៉ាំ صلوات الله عليه والسلام បានបែរទៅរកបក្សពួកហើយមានវចនៈថា៖ "អ្នកក្លាហានអើយ ចូរងើបឡើង ។ គ្រាប់ព្រួញទាំងនេះជាអ្នកនាំសាររបស់សត្រូវអស់លោក មករកអស់លោក ។"[220]

ដូច្នេះ ពលសេះសាមសិបពីរនាក់និងយុទ្ធជនសែសិបនាក់ត្រូវប្រឈមមុខនឹងដប់ពាន់នាក់ ។ តែក្រុមដ៏តូចនេះអាចទប់ទល់រេហ៍ពលដ៏សម្បើមដែលបំពាក់គ្រឿងបរិក្ខារគ្រប់គ្រាន់បំផុតនេះបាន ហើយអាចបង្ហាញឲ្យឃើញបាននូវសេចក្ដីអង់អាចក្លាហានដ៏អស្ចារ្យ ដែលមិនធ្លាប់ឃើញពីមុន ។ បន្ទាប់មក អ៊ុម៉ារបានចេញបញ្ជាឲ្យចូលប្រយុទ្ធនៅក្នុងសមរភូមិនេះ កងយុទ្ធទាំងអស់នៃទ័ពអ៊ូម៉ៃយ៉ាស្ហ៊ុប្រយុទ្ធគ្រប់ដៃ ។ ទោះបីបក្សពួកអ៊ីម៉ាំ صلوات الله عليه والسلام ចំនួនពាក់កណ្ដាលបានបាត់បង់ជីវិតនៅក្នុងសមរភូមិនេះក៏ដោយ ក៏ពួកគេបានប្រយុទ្ធយ៉ាងក្លាហានជាទីបំផុត បានធ្វើឲ្យទ័ពអ៊ូម៉ៃយ៉ាស្ហ៊ុវិនាសស្លាប់រេហ៍ពលអស់យ៉ាងច្រើន ។

បន្ទាប់ពីការប្រយុទ្ធប្រលូកគ្នានេះ សាវកឯទៀតបានចាប់ផ្ដើមប្រយុទ្ធតត្ដូ ។ ការពិត វីរភាពដែលពួកគេបានបញ្ចេញឲ្យឃើញនេះបានធ្វើឲ្យទ័ពអ៊ូម៉ៃយ៉ាស្ហ៊ុទាំងមូលខ្លបខ្លាច ហើយបានធ្វើឲ្យទ័ពអ៊ូម៉ៃយ៉ាស្ហ៊ុរងវិនាស

---

*តារីក៏ (الكامل في التاريخ)* ក្បាលទី ៣ ទំព័រ ២៨៩ ។

[220] សូមមើលសៀវភៅរបស់លោក អ៊ីបនូ ស្ហាស្ហ៊ូរ អាស្ហ៊ូប (إبن شهر آشوب) *ម៉ាណាគ៊ីប អាលី អាប៊ី ត៉ត៏លិប (مَناقِبُ آلِ أبي طالب)* ក្បាលទី ៣ ទំព័រ ២៥០ ។

ស្លាប់យុទ្ធជនយ៉ាងច្រើន ។ ដូច្នេះ អុាំរ្ញ អ៊ីបនូ អាល់-ហ្វាច់យ៉្វាច់បានស្រែកទៅរកពួកគេថា៖ "តើអស់លោកដឹងទេថាអស់លោកកំពុងប្រយុទ្ធទល់នឹងអ្នកណា ? អស់លោកកំពុងប្រយុទ្ធទល់នឹងទ័ពសេះដ៏ក្លាហានបំផុតក្នុងស្រុកនេះ ។ ពួកគេនឹងសម្លាប់អ្នកណាដែលចង់ប្រយុទ្ធនឹងពួកគេ ។ ខ្ញុំសូមស្បថចំពោះអល់ឡោះហ្ទ៍عزّ وجلّ បើអស់លោកចោលតែដុំថ្មទៅលើពួកគេ អស់លោកនឹងសម្លាប់ពួកគេ ។"[221]

អ៊្ញម៉ារយល់ឃើញដូចអុាំរ្ញដែរ ហើយបានបញ្ជាឲ្យកងទ័ពគាត់ឈប់ប្រយុទ្ធតតូនឹងវីរបុរសទាំងនោះ ។ គាត់បានបញ្ជាឲ្យវាយប្រលូកទៅលើពួកគេ ។ បណ្ដាសាវកបានធ្វើឲ្យទ័ពវាយប្រលូកនោះ ស្លាប់រេហ៍ពលយ៉ាងច្រើន ដល់ថ្នាក់អ៊្ញរវ៉ាស្ញ អ៊ីបនូ ក្វយ៉ស៍ចាំបាច់ត្រូវសូមឲ្យមេបញ្ជាការផ្ដល់មនុស្ស និងអាវុធឲ្យគាត់ជាបន្ថែម ។

អ៊្ញម៉ារត្រូវតែកោះហៅអាល់-ហ៊្វសែន៍صلوات الله عليه والسلام អ៊ីបនូ នូម៉ៃរ៍ មកចូលរួម បានផ្ដល់ទ័ពធ្នូប្រាំរយនាក់ឲ្យគាត់ ទ័ពធ្នូនេះអាចបង្ក្រាបសត្វដែលបណ្ដាបក្សពួករបស់អ៊ីម៉ាំصلوات الله عليه والسلامជិះនោះបាន ។ ដោយហេតុនេះ សាវកទាំងអស់ ព្រមទាំងអាល់-ហ៊្វរ អ៊ីបនូ យ៉ាស៊ីដ្ទ ដែរត្រូវតែប្រយុទ្ធទល់នឹងខ្មាំងដោយជើងផ្ទាល់ដី ។ ការប្រយុទ្ធនេះ ដែលអ្នកប្រវត្តិសាស្ត្របានពិព័ណ៌នាថាជាការប្រយុទ្ធសាហាវបំផុតក្នុងប្រវត្តិសាស្ត្រនោះ បានប្រព្រឹត្តទៅលុះដល់ថ្ងៃត្រង់ ។

នៅកណ្ដាលទិដ្ឋភាពដ៏រន្ធត់នោះ អាប៊ូ ស្ញ៊ម៉ាម៉ាស្ញ អាល់-ស្ញ៍អ៊ីឌ្មី បានងើយមើលមេឃ ហើយប្រាប់អ៊ីម៉ាំصلوات الله عليه والسلامអំពីម៉ោងស្ញ៍ឡាត៍ស្ញ៊ហ្ញរ ។ អ៊ីម៉ាំصلوات الله عليه والسلام បានឲ្យបក្សពួកព្រះអង្គصلوات الله عليه والسلامទាមទារការផ្អាកប្រយុទ្ធ ដើម្បីនឹងស្ញ៍ឡាត៍ ។ ពួកគេយល់ព្រម តែពេលអ៊ីម៉ាំصلوات الله عليه والسلامនិងបណ្ដាសាវកព្រះអង្គصلوات الله عليه والسلامឈរស្ញ៍ឡាត៍ ទ័ពអ្វម៉ៃយ៉ាស្ញបានចាប់ផ្ដើមបាញ់ព្រួញមកលើពួកគេ ។ សាអ៊ីដ្ទ អាល់-ហ្វាណាហ្វីបានយកខ្លួនលោកធ្វើខែលបាំងអ៊ីម៉ាំصلوات الله عليه والسلام ខណៈដែល

[221] សូមមើលសៀវភៅរបស់លោក មូហ្វាំម៉ាដ្ញ អ៊ីបនូ យ៉ាវៀរ អាល់-ត្ញ៍បារី (محمد بن جرير طبري) *តារិក្ញ អាល់-អ៊្វម៉ាំ វ៉ា អាល់-មុលុក (تاريخ الأمم والملوك)*, ក្បាលទី ៤ ទំព័រ ៣៣១ ។

ព្រះអង្គ صلوات الله عليه والسلام កំពុងស្ងំឡាត់។ ពេលអ៊ីម៉ាំ صلوات الله عليه والسلام ស្ងំឡាត់ចប់ សាអ៊ីដត្រូវរបួសធ្ងន់ ដួលស្លាប់។

បណ្ដាសាវកឯទៀតបន្តការប្រយុទ្ធយ៉ាងអង់អាចក្លាហាន ដើម្បីអ៊ីម៉ាំ صلوات الله عليه والسلام ពួកគេលុះក្ស័យអាត្មាទាំងអស់គ្នា។

អស់ពីបណ្ដាសាវក ដល់វេនយុវជនព្រះរាជកុលដ្ឋាន عليهم السلام ព្រះសាស្ដា صلى الله عليه وآله وسلم ចូលប្រយុទ្ធ។ ដូចរាជសីហ៍វាយលុក ពួកគេស្ទុះចូលទៅក្នុងលានប្រយុទ្ធបានសូមលាគ្នាដោយទឹកភ្នែករលីងរលោង ដ្បិតអាណិតអាសូរអ៊ីម៉ាំ صلوات الله عليه والسلام របស់ខ្លួនដែលនៅឯកោ ហើយនឹងពុំមានជំនួយក្នុងពេលឆាប់ៗខាងមុខនេះ។

អ្នកចូលប្រយុទ្ធមុនគេបង្អស់គឺព្រះយុវរាជព្រះជន្មដប់ប្រាំបីវស្សា ដែលមានរូបរាង មានសីលធម៌ និងមានគុណសម្បត្តិស្រដៀងព្រះសាស្ដា صلى الله عليه وآله وسلم ជាងគេ។ នេះគឺអ៊ាលី អាល់-អាក់បារ៍ ព្រះរាជបុត្ររបស់អ៊ីម៉ាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ។ អ៊ីម៉ាំ صلوات الله عليه والسلام សោកសៅជាទីបំផុតដែលបានដឹងច្បាស់ថាព្រះរាជបុត្រព្រះអង្គ صلوات الله عليه والسلام បានចូលប្រយុទ្ធមុនគេ។ ដូច្នេះព្រះអង្គ صلوات الله عليه والسلام បានងើយមុខទៅឯមេឃ ប្ដឹងព្រះម្ចាស់ عز وجل អំពីបនពាលនេះដែលវាយប្រហារព្រះអង្គ صلوات الله عليه والسلام ហើយប្រុងសម្លាប់បុគ្គលសំណព្វចិត្តព្រះអង្គ صلوات الله عليه والسلام ។ ព្រះអង្គ صلوات الله عليه والسلام ព្រមទាំងព្រះរាជវង្សព្រះសាស្ដា صلى الله عليه وآله وسلم ដែរ បានបណ្ដោយឲ្យអ៊ាលី អាល់-អាក់បារ៍ចេញទៅដោយទឹកភ្នែក ដោយយំថ្ងូរ។ បន្ទាប់មកព្រះអង្គ صلوات الله عليه والسلام ដាក់ដៃក្រោមពុកចង្កា លើកវាទៅឯមេឃ ហើយសូត្រថា៖

اَللّٰهُمَّ اشْهَدْ عَلٰي هٰؤُلاَءِ القَوْمِ، فَقَدْ بَرَزَ اِلَيْهِمْ غُلامٌ اَشْبَهُ النَّاسِ خَلْقًا وَ خُلْقًا وَ مَنْطِقًا بِرَسُوْلِكَ، وَ كُنَّا اِذَا اشْتَقْنَا اِلٰي نَبِيِّكَ نَظَرْنَا اِلٰي وَجْهِهِ. اللّٰهُمَّ امْنَعْهُمْ بَرَكَاتِ الاَرْضِ، وَ فَرِّقْهُمْ تَفْرِيْقًا، وَ مَزِّقْهُمْ تَمْزِيْقًا، وَاجْعَلْهُمْ طَرَائِقَ قِدَدًا، وَلاَ تُرْضِ الوُلاَةَ عَنْهُمْ اَبَدًا فَاِنَّهُمْ دَعَوْنَا لِيَنْصُرُوْنَا ثُمَّ عَدَوْا عَلَيْنَا يُقَاتِلُوْ نَنَا.

*"អល់ឡោះហ៍ عز وجل អើយ សូមព្រះអង្គ عز وجل ជាសាក្សីលើជនទាំងនោះ! យុវបុរស[222] ដែលមានរូបរាង មានសីលធម៌និងមានគុណសម្បត្តិដូចព្រះ*

[222] សូមមើលសៀវភៅរបស់លោក មូហ៊ាំម៉ាដ់ បាក្វៀរ អាល់-ម៉ាច់លីស៊ី

*សាស្តាﷺព្រះអង្គﷻកំពុងប្រឈមមុខនឹងពួកគេ ពេលនេះ ក្នុងលានប្រយុទ្ធ ។ អស់ទូលព្រះបង្គំជាខ្ញុំតែងមើលមុខគេ ពេលអស់ទូលព្រះបង្គំជាខ្ញុំនឹករលឹកព្រះសាស្តាﷺ ។ អលឡោះហ្ម៍ﷻអើយ សូមព្រះអង្គﷻផ្តាច់សព្វសាធុពរនៃផែនដីពីពួកគេ សូមព្រះអង្គﷻធ្វើឲ្យពួកគេរាយពពាយ សូមព្រះអង្គصلوات الله عليه والسلامពង្រាត់ពង្រាយពួកគេ សូមព្រះអង្គﷻបំបែកពួកគេឲ្យបែកខ្ញែកគ្នា សូមព្រះអង្គﷻកុំធ្វើឲ្យអ្នកគ្រប់គ្រងពួកគេស្រឡាញ់ពួកគេឡើយ ព្រោះពួកគេបានវាយប្រហារអស់ទូលព្រះបង្គំជាខ្ញុំដោយឈ្លានពាន បន្ទាប់ពីបានសន្យាថាពួកគេនឹងគាំទ្រអស់ទូលព្រះបង្គំជាខ្ញុំហើយ ។"*

រួចហើយ អ៊ីម៉ាំصلوات الله عليه والسلامបានបែរទៅរកអ៊ុម៉ារ មានវចនៈថា៖ "តើលោកកើតអ្វី ? ខ្ញុំ[បានបួងសួងសូមអល់ឡោះហ្ម៍ﷻដាក់បណ្តាសាលោក ហើយខ្ញុំ] បានអង្វរសូមព្រះអង្គﷻផ្តាច់ពូជលោក សូមព្រះអង្គﷻកុំទទួលទង្វើរបស់លោក សូមព្រះអង្គﷻបើកដៃឲ្យបុគ្គលនីមួយសម្លាប់លោកនៅក្នុងគ្រែដេក ព្រោះលោកផ្តាច់វង្សត្រកូលខ្ញុំ បានរំលោភទំនាក់ទំនងខ្ញុំជាមួយព្រះសាស្តាﷺអល់ឡោះហ្ម៍ﷻ ។"

បន្ទាប់មកអ៊ីម៉ាំصلوات الله عليه والسلامបានសូត្រព្រះបន្ទូលអល់ឡោះហ្ម៍ﷻថា៖

إِنَّ اللَّهَ اصْطَفَى آدَمَ وَنُوْحًا وَآلَ إِبْرَاهِيْمَ وَآلَ عِمْرَانَ عَلَى الْعَالَمِيْنَ. ذُرِّيَّةً بَعْضُهَا مِنْ بَعْضٍ ۗ وَاللَّهُ سَمِيْعٌ عَلِيْمٌ.

*ពិតណាស់អល់ឡោះហ្ម៍បានជ្រើសរើសអាដាំ នុះហ្ម៍ បណ្តាកូនចៅរបស់អ៊ិបរ៉ហ៊ីមនិងបណ្តាកូនចៅរបស់អ៊ីមរ៉នលើប្រជានិករទាំងឡាយ [ដែលមានច្រើន]តំណពូជតៗគ្នារៀងមក [ដែលប្រកបដោយគុណសម្បត្តិឥតខ្ចោះ] ។ អល់ឡោះហ្ម៍ទ្រង់សវនាការ ព្រះអង្គទ្រង់ញាណសព្វសារពើ (៣:៣៣-៣៤) ។*

បន្ទាប់មកព្រះយុវរាជបានថ្លែងអំពីគោលសីលធម៌ ដែលព្រះអង្គប្រយុទ្ធការពារ និងអំពីការប្តេជ្ញាចិត្តដ៏មហិមាដើម្បីការពារព្រះសាសនា

---

(محمد باقر المجلسي) *ប៊ីហ្ការ អាល់-អាន់វ៉ារ (بحارالانوار)* ក្បាលទី ៤៤ ទំព័រ ៤២ ។

អល់ឡោះហ៍ عز وجل ទោះបីព្រះអង្គត្រូវលះបង់ព្រះជន្មក៏ដោយ ។ រួចហើយព្រះអង្គវាយលុកខ្មាំងដោយសេចក្ដីអង់អាច ដោយវីរភាពហួសនឹងពិពណ៌នាបាន ដល់ថ្នាក់លោកអ្នកប្រវត្តិសាស្រ្តបានថ្លែងរៀបរាប់អំពីការប្រយុទ្ធរបស់ព្រះអង្គថា៖ "ការប្រយុទ្ធរបស់អ៊ុាលី អាល់-អាក់ប៉ារ៍ធ្វើឲ្យពួកសត្រូវនឹកឃើញការវាយលុករបស់អាមីរុល-មុមីនីន صلوات الله عليه والسلام ព្រះអយ្យកោព្រះអង្គ ។"

កំពុងតែប្រយុទ្ធ អ៊ុាលីស្រេកទឹកណាស់ពីព្រោះខ្មាំងបានបង្អត់ទឹកពួគេ ។ ដូច្នេះ ព្រះអង្គត្រូវតែត្រឡប់ទៅសូមទឹកពីព្រះបិតាព្រះអង្គ តែព្រះបិតា صلوات الله عليه والسلام ពុំមានអ្វីឲ្យទេ ។ ព្រះបិតា صلوات الله عليه والسلام ពុំមានទឹកមួយតំណក់ឲ្យបុត្រទេ ។ ព្រះអង្គ صلوات الله عليه والسلام សូមទោសដោយខ្លោចចិត្ត ហើយបានសន្យាថាបន្តិចទៀតព្រះសាស្ដា صلى الله عليه وآله وسلم នឹងប្រទានទឹកឲ្យដែលនឹងធ្វើឲ្យបាត់ស្រេករហូត ។

ព្រះយុវរាជក៏បានត្រឡប់ទៅលានសឹកវិញ បានប្រយុទ្ធយ៉ាងអច់អាចទោះបីត្រូវរបួសច្រើនកន្លែងក៏ដោយ ។ ទ័ពអ៊ូម៉ៃយ៉ាស់ទាំងមូលត្អូញត្អែរដែលបានស្លាប់រេហ៍ពលច្រើន ក្រោមដៃព្រះយុវរាជបុត្ររបស់អ៊ីម៉ាំអាល់-ហ៊្វូសែន៍ صلوات الله عليه والسلام ។ ដូច្នេះ មូរ៉ោះត៍្ អ៊ីបនូ មុនគ៊្វីស៊ុ (مُرّة بن مُنقذ) តាំងចិត្តធ្វើគុតព្រះអង្គ ។ មូរ៉ោះត៍្បានចាក់ អ៊ុាលី អាល់-អាក់ប៉ារ៍ ដោយលំពែងពីក្រោយខ្នងព្រះអង្គ ហើយបានកាប់ព្រះសិរព្រះអង្គពេញទំហឹងដាវ ។

អ៊ុាលី អាល់-អាក់ប៉ារ៍បានតោងកសេះជាប់ ដោយគិតថាសេះនឹងនាំព្រះអង្គទៅឯជំរំព្រះបិតាព្រះអង្គ ។ អកុសល សេះនាំព្រះអង្គទៅឯទីតាំងខ្មាំង ។ ពួកខ្មាំងបានឡោមព័ទ្ធព្រះអង្គ ហើយបានកាប់ព្រះកាយព្រះអង្គជាបំណែក ។ ខ្យល់បាននាំសម្រែកព្រះរាជបុត្រទៅដល់ព្រះបិតាៗក៏ប្រញាប់ប្រញាល់ទៅរកបុត្រ បានជួបបុត្រក្នុងគ្រាអវសាន ។ ព្រះអង្គ صلوات الله عليه والسلام បានដាក់ថ្ពាល់លើព្រះកាយបុត្រព្រះអង្គ صلوات الله عليه والسلام ដែលត្រូវគេកាត់ផ្ដាច់ ហើយបានជូតទឹកភ្នែកឲ្យបុត្រដោយមានវចនៈថា៖

قَتَلَ اللهُ قَوْمًا قَتَلُوكَ يَا بُنَيَّ، مَا اَجْرَاَهُمْ عَلٰي اللهِ وَ عَلٰي انْتِهَاكِ حُرْمَةِ الرَّسُوْلِ عَلٰي الدُّنْيَا بَعْدَكَ العَفَا.

*"បុត្រអើយ សូមឲ្យអល់ឡោះហ៍ عز وجل សម្លាប់បុគ្គលដែលបានសម្លាប់បុត្រ !*

*ពួកគេព្រហើនមែន មិនកោតក្រែងអល់ឡោះហ៍ﷻ ឡើយ មិនកោតក្រែងព្រះសាស្ដាﷺ របស់អល់ឡោះហ៍ﷻ ឡើយ ដែលបុត្រជាព្រះរាជកុលដ្ឋាននោះ ។ អត់ពីបុត្រ សូមឲ្យធូលីគ្រប់ដណ្ដប់លោក[ឥតន័យ]នេះ ។"*[223]

លុះបានដំណឹងទុក្ករកម្មរបស់ អាុលី អាល់-អាក់ុបារ៍ភ្លាម ព្រះនាងស្រែណាប់سلام الله عليها ទប់ចិត្តមិនបាន ។ ព្រះនាងប្រញាប់ទៅរកព្រះរាជសពរងរបួសដោយយំយែកថាៈ "ព្រះភាតុបុត្តសំឡាញ់អឺយ !"[224] កែវភ្នែកបិតុថ្លាអឺយ ! បាវបណ្ដូលចិត្តបិតុថ្លាអឺយ !"[225] ព្រះនាងسلام الله عليها ស្ទុះទៅឱបព្រះរាជសព សម្រក់ទឹកភ្នែកដែលហូរមកឥតឈប់លើសាកសព យំថ្ងូរសោកស្ដាយទុក្ករបុគ្គលអាុលី អាល់-អាក់ុបារ៍ ។ អ៊ីមុាំصلوات الله عليه والسلام អាល់-ហ៊ុសៃន៍صلوات الله عليه والسلام មិនអាចធ្វើអ្វីបានក្រៅពីព្យាយាមលួងលោមចិត្ត ។ បន្ទាប់មក ព្រះអង្គصلوات الله عليه والسلام ដឹកដៃព្រះអនុជាព្រះអង្គصلوات الله عليه والسلام ទៅជំរំវិញ ។[226]

បន្ទាប់ពីនោះ យុវជនកុលដ្ឋានអាុគ៊ីល អ៊ីបនូ អាប៊ូ ត៉ូលិបស្ទុះទៅក្នុងឃ្យីហ្វាដ់ក្នុងគោលបំណងបូជាជីវិតដើម្បីព្រះអគ្គមគ្គទេសក៍ខ្លួន ។ ពួកគេបានប្រយុទ្ធយ៉ាងអង់អាចក្លាហាន បណ្ដាលឲ្យទ័ពអ៊ូម៉ៃយ៉ាស្លាប់បាត់បង់រៀហ៍ពលច្រើន ។ ក៏ប៉ុន្តែ ទាំងអស់គ្នាបានទទួលទុក្ករកម្ម ។

បន្ទាប់មកដល់វេនព្រះរាជកុលដ្ឋានអ៊ីមុាំអាល់-ហាសាន់صلوات الله عليه والسلام ។ ពួកគេបានយកខ្លួនពាំងការពារព្រះបិតុលាខ្លួន និងការពារសាសនារបស់ខ្លួន ។ នៅក្នុងចំណោមវីរបុគ្គលទាំងនេះមាន អាល់-ក៉ូសីម ដែលលោកអ្នក

---

[223] សូមមើលសៀវភៅរបស់ ស្សៃខ៊ុ មូហ៊ាំម៉ាដ់ អ៊ីបនូ អាល់-ម៉ាស្ហ៊ាឌី *អាល់-ម៉ាស្ហារ អាល់-កាបៀរ (المزار الكبير)* ទំព័រ ៥៨៧ ។

[224] សូមមើលសៀវភៅរបស់លោក អាប៊ុល-ហ្វារ៉ាច់ អាល់-អ៊ីស្វហ្វាហានី (أبو الفرج الإصفهاني) *ម៉ាក៉ូទីល អាល់-ត៉ូលីប៊ីយ៊ីន (مَقاتِل الطالِبيّين)* ទំព័រ ៧៦ ។

[225] សូមមើលសៀវភៅរបស់លោក មូហ៊ាំម៉ាដ់ បាក៉ៀរ អាល់-ម៉ាច់លីស៊ី (محمد باقر المجلسي) *ប៊ីហ៊ារ អាល់-អាន់វ៉ារ (بحارالانوار)* ក្បាលទី ៤៥ ទំព័រ ៤៤ ។

[226] សូមមើលសៀវភៅរបស់ សៃយីដ អ៊ីបនូ ត៉ូវុស អាល់-ហាសានី *អាល់-ឡាហ៊ុហ្វ អាុឡា ក៉ូត់ឡា អាត់-ទូហ៊ុហ្វ (أللُّهوف عَلى قتلَىِ الطّفوف)* ឬ *អាល់-ម៉ាល់ហ៊ុហ្វ អាុឡា ក៉ូត់ឡា អាត់-ទូហ៊ុហ្វ (ألمَلهوف عَلى قَتلَىِ الطّفوف)* ទំព័រ ៦៨ ។

ប្រវត្តិសាស្ត្របានពិពណ៌នាថាភ្លឺដូចដួងខែ ។ មុនព្រះអង្គវាយលុកខ្មាំង ព្រះអង្គបានប្រកាសថា៖ "ដរាបណាខ្ញុំមានជីវិត ដរាបនោះព្រះបិតុលាខ្ញុំ អាល់-ហ៊ូសែន៍صلوات الله عليه والسلامនឹងមិនត្រូវគេធ្វើគុតទេ ។"

តែអ៊ីម៉ាំصلوات الله عليه والسلامមិនអនុញ្ញាតឲ្យអាល់-ក៏ស៊ីមចូលប្រយុទ្ធទេ តែអាល់-ក៏ស៊ីម ទទូចសូម បានថើបជើងនិងដៃព្រះបិតុលាព្រះអង្គហើយសូមឲ្យព្រះអង្គ صلوات الله عليه والسلامអនុញ្ញាតឲ្យព្រះអង្គទៅប្រយុទ្ធ ។ អ៊ីម៉ាំصلوات الله عليه والسلامក៏បានអនុញ្ញាតឲ្យព្រះ អង្គប្រយុទ្ធដោយស្រក់ទឹកភ្នែក រលួយចិត្តរលួយថ្លើម ។ ដូចវីរបុរស ហ្វាស៊ីមឯទៀតដែរ អាល់-ក៏ស៊ីមប្រយុទ្ធយ៉ាងអង់អាចក្លាហាន បាន សម្លាប់រេហ៍ពលទ័ពអ៊ូម៉ៃយ៉ាស្ញ់ច្រើននាក់ ។

កំពុងតែប្រយុទ្ធពេញទំហឹង កែងស្បែកជើងព្រះអង្គដាច់ ។ ពេលព្រះអង្គ ឱនដើម្បីជួសជុលវា យោធិនអ៊ូម៉ៃយ៉ាស្ញ់ដែលស្អប់ព្រះអង្គនោះ ឆ្លៀតយក ឱកាសនេះកាប់ព្រះអង្គចំក្បាល ។ ព្រះអង្គស្រែកហៅព្រះបិតុលាៗស្ទុះ មករកព្រះអង្គហើយបានសម្លាប់ឃាតករព្រះអង្គ ។ ព្រះបិតុលាصلوات الله عليه والسلامបាន បីសពក្មួយទៅដាក់ត្រៀបនឹងសពទុក្ករបុគ្គលឯទៀត ។ ព្រះអង្គصلوات الله عليه والسلام សម្លឹងមើលសាកសពទាំងឡាយមួយភ្លែត ហើយបានដាក់បណ្តាសា ឃាតកររបស់អ្នកស្លាប់ទាំងនេះ ។

អៅ៊ន៍ អ៊ីបនូ អាប់ឌុលឡោះហ្ម៍ អ៊ីបនូ យ៉ាក់ហ្វារ៍ (عون بن عبد الله بن جعفر) ព្រះ រាជបុត្ររបស់ព្រះនាងស៊ៃណាប់سلام الله عليها បានចូលប្រយុទ្ធ ទោះបីព្រះអង្គក្មេង ពេកក៏ដោយ ។ ដូចព្រះយុវរាជអង់អាចឯទៀតដែរ អៅ៊ន៍បានប្រយុទ្ធយ៉ាង អង់អាចក្លាហានលុះបានបូជាព្រះជន្ម ។ ព្រះមាតាسلام الله عليهاព្រះអង្គបានទទួល ព្រះរាជសពព្រះអង្គដោយស្មារតីរឹងមាំ ហើយព្រះនាងបានបូជាព្រះអង្គ ថ្វាយអល់ឡោះហ្ម៍عز وجل ដោយសង្ឃឹមទុកជាមុនថាព្រះអង្គعز وجلនឹងតបស្នង វិញឥតគណនា ។

ទោះជាយ៉ាងណាក៏ដោយ ទិដ្ឋភាពនោះមិនចម្លែកសម្រាប់ព្រះនាងعليهم السلام ទេ ។ ព្រះនាងបានទទួលសាកសពយុវរាជទុក្ករបុគ្គលត្រចះត្រចង់ ដូច ដួងខែជាច្រើនហើយ មុនបានទទួលព្រះរាជសពព្រះរាជបុត្រព្រះនាង ។ ពុំមានអ្វីក្រៅពីជំនឿមាំមិនកក្រើករបស់ព្រះនាងទេ ដែលផ្តល់ឲ្យព្រះនាង

នូវការអត់ទ្រាំ និងសមត្ថភាពចេះអត់ធ្មត់សង្កត់ចិត្តឲ្យមានគោលជំហររឹងមាំនៅពីមុខទិដ្ឋភាពមហារន្ធត់បែបនេះ ។

មកដល់ពេលនេះ យុទ្ធជនហ្វាស្ទីមទាំងអស់បានបូជាជីវិត នៅសល់តែអ្នកការពារព្រះរាជវង្សព្រះសាស្ដាﷺ និងសេនាស្ដាំរបស់អ៊ីម៉ាំអាល់-ហ៊្វូសៃន៍صلوات الله عليه والسلام គឺវីរបុរស អាប៊ូ អាល់-ហ្វាដ្ធ៍ល៍ អាល់-អាប់បាស់ ។

អាល់-អាប់បាស់បានពិនិត្យមើលភ័យវិបត្តិ និងគ្រោះកាចទាំងនេះដោយអត់ធ្មត់ រង់ចាំឱកាសល្អចូលប្រយុទ្ធទល់នឹងខ្មាំងហើយសងសឹកពួកគេ ។ បន្ទាប់ពីយុវរាជព្រះរាជកុលដ្ឋានعليهم السلامព្រះសាស្ដាﷺបានធ្វើទុក្ករកម្ម អាល់-អាប់បាស់បានទៅរកបងប្អូនព្រះអង្គ ហើយបានថ្លែងថា៖ "ប្អូនៗ ចូរចូលប្រយុទ្ធដើម្បីខ្ញុំនឹងជឿជាក់ថា អស់លោកធ្វើដើម្បីអល់ឡោះហ្ទ៍عز وجلនិងព្រះសាស្ដាﷺព្រះអង្គعز وجل ដើម្បីខ្ញុំនឹងសងសឹកឲ្យអស់លោកដែលពុំមានកូន ។" ប្អូនៗព្រះអង្គទាំងអស់គ្នារីករាយនឹងការស្នើនេះ ហើយចេញទៅប្រយុទ្ធយ៉ាងអង់អាចក្លាហាន ។ ទាំងអស់គ្នាបានបូជាជីវិតបន្តបន្ទាប់គ្នានៅពីមុខអាល់-អាប់បាស់ បងប្រុសដែលឈរស្រក់ទឹកភ្នែកព្រោះបាត់បង់វង់មុខដែលភ្លឺត្រចះត្រចង់ទាំងនេះ ។

## អាល់-អាប់បាស់ធ្វើទុក្ករកម្មបូជាជីវិត

អាល់-អាប់បាស់ ជាបុគ្គលសំណព្វចិត្តបំផុតម្នាក់របស់អ៊ីម៉ាំអាល់-ហ៊្វូសៃន៍صلوات الله عليه والسلام ព្រះអង្គصلوات الله عليه والسلامបានអប់រំ បំពាក់បំប៉នព្រះអង្គឲ្យមានលក្ខណៈសម្បត្តិថ្លៃថ្លានិងសីលធម៌ ។ អ៊ីម៉ាំصلوات الله عليه والسلامបានបង្ហាត់បង្រៀនព្រះអង្គនូវច្បាប់អ៊ីស្លាមស្ទាវអាស៊ូផងដែរ គេចាត់ទុកព្រះអង្គជាអ្នកប្រាជ្ញអ៊ីស្លាមមានមារយាទកំពូលមួយរូប ។ អាល់-អាប់បាស់តែងតែនៅជាប់ជាមួយព្រះរៀមព្រះអង្គជួយសម្រាលទុក្ខព្រះអង្គصلوات الله عليه والسلامក្នុងគ្រប់គ្រាលំបាក ។

ព្រោះតែទឹកមុខអាល់-អាប់បាស់មានរស្មីភ្លឺត្រះចះត្រចង់ ទើបគេហៅព្រះអង្គថា "ដួងខែរបស់បានី ហ្វាស្ទីម"។ ព្រោះតែព្រះអង្គជាវីរបុរសឥតប្រៀបផ្ទឹមបាន បានជាគេតែងតាំងអាល់-អាប់បាស់ជាមេដឹកនាំទ័ពអ៊ីម៉ាំអាល់-ហ៊្វូសៃនصلوات الله عليه والسلام និងជាខ្មាន់ទង់ ។ លើសពីនេះទៀត ព្រះអង្គជា

អនុរក្សព្រះរាជវង្សនិងព្រះរាជកុមារទាំងឡាយ ។ ដូច្នេះ ព្រះអង្គមានទំនាក់ទំនងពិសេសជាមួយព្រះជេដ្ឋា (គឺបងស្រី) ព្រះអង្គ ព្រះនាងស្រៃណាប់سلام الله عليهاដែលបានមើលថែរក្សាព្រះអង្គតាំងពីតូចមកម្ល៉េះ និងបានស្រឡាញ់ថ្នាក់ថ្នមព្រះអង្គ ។ ព្រះអង្គក៏ស្រឡាញ់ព្រះជេដ្ឋាណាស់ដែរ ព្រះអង្គទទួលភារកិច្ចមើលការពារព្រះនាង និងបំពេញសេចក្តីត្រូវការរបស់ព្រះនាង ។

ពេលអាុប់-អាុប់បាស់ដឹងថាព្រះរៀមព្រះអង្គកណ្តោចកណ្តែង ឯបណ្តាសាវកនិងសមាជិកព្រះរាជវង្សព្រះអង្គបានធ្វើទុក្ករកម្ម អាល់-អាុប់បាស់ទៅរកអ៊ីមុាំصلوات الله عليه والسلام សូមអ៊ីមុាំصلوات الله عليه والسلامអនុញ្ញាតឲ្យព្រះអង្គចូលប្រយុទ្ធ ។ អ៊ីមុាំصلوات الله عليه والسلامមិនអនុញ្ញាតឲ្យព្រះអង្គចូលប្រយុទ្ធទេ អ៊ីមុាំصلوات الله عليه والسلامមានវចនៈទាំងក្រៀមក្រំថា៖ "ប្អូនជាខ្មាន់ទង់របស់បង... ។" ការពិត ដរាបណាអាល់-អាុប់បាស់នៅជាប់ជាមួយព្រះអង្គصلوات الله عليه والسلام ដរាបនោះព្រះអង្គصلوات الله عليه والسلامមានអារម្មណ៍ថាមានកម្លាំង មានអារម្មណ៍ថាមានការគាំពារ ។ តែអាល់-អាុប់បាស់ទទូចសូមប្រយុទ្ធថា៖ "ទូលបង្គំមិនអាចអត់ទ្រាំបានទេ ។ ទូលបង្គំចង់សងសឹកពួកមានពុតត្បុតទាំងនោះណាស់ ។"

អ៊ីមុាំصلوات الله عليه والسلامពុំអាចធ្វើអ្វីបាន ក្រៅពីអនុញ្ញាតឲ្យអាល់-អាុប់បាស់ប្រយុទ្ធ ។ ដំបូង ព្រះអង្គصلوات الله عليه والسلامឲ្យអាល់-អាុប់បាស់ព្យាយាមទៅរកទឹកមកឲ្យព្រះរាជវង្សនិងក្មេងៗដែលកំពុងតែស្រេកទឹកខ្លាំង ។ ដំបូង អាល់-អាុប់បាស់បានទៅរកទ័ពអ្វម៉ែយ៉ាស្ទ ដោយដាស់តឿននិងរំលឹកឲ្យប្រយ័តអល់ឡោះហ៍عز وجلដាក់ទោស ។ ព្រះអង្គបានថ្លែងសំដៅមេបញ្ជាការថា៖ "អ្វម៉ារអើយ នេះគឺអាល់-ហ្វ៊ូសៃន៍صلوات الله عليه والسلام ព្រះរាជបុត្ររបស់ព្រះរាជបុត្រីរបស់ព្រះសាស្តាصلى الله عليه وآله وسلمអល់ឡោះហ៍عز وجل ។ លោកបានសម្លាប់សាវកនិងព្រះរាជកុលដ្ឋានعليهم السلامព្រះអង្គصلوات الله عليه والسلام ។ នេះគឺព្រះរាជកុមារនិងព្រះរាជវង្សព្រះអង្គصلوات الله عليه والسلامដែលស្រេកទឹក ខ្ញុំសូមលោកឲ្យទឹកព្រះអង្គសោយ ។ យ៉ាងហោចព្រះអង្គصلوات الله عليه والسلامនៅតែសូមឲ្យលោកដោះលែងឲ្យព្រះអង្គصلوات الله عليه والسلامទៅឯរូម ឬឥណ្ឌា ព្រះអង្គصلوات الله عليه والسلامប្រគល់តំបន់អាល់-ហ៊្ជីយ៉ាស្ទ់និងប្រទេសអ៊ីរ៉ក់ឲ្យលោក... ។"

នៅក្នុងទ័ពអ៊្វម៉ៃយ៉ាស្ស៊ ពុំមានអ្នកណាមួយឆ្លើយតបអាល់-អ៊ុាប់បាស់ទេ ក្រៅពីស្ទ៊ីមរ្វដែលនិយាយដាក់ព្រះអង្គថា៖ "ទោះបីផែនដីនេះពោរពេញដោយទឹកដែលយើងកាន់កាប់ក៏ដោយ ក៏យើងមិនឲ្យទឹកពួកឯងមួយតំណក់ផឹកទេ លុះណាតែពួកឯងព្រមនៅក្រោមអំណាចយ៉ាស៊ីដ្ឋ ។"

អាល់-អ៊ុាប់បាស់បានរាយការណ៍រឿងនេះប្រាប់ព្រះរៀមព្រះអង្គ ។ ទទឹមពេលនោះ ព្រះអង្គបានឮសម្លេងក្មេងយំដោយសារស្រេកទឹក ឃើញមុខវាផ្លាស់ប្តូរ ហើយឃើញបបូរមាត់វាក្រៀម ។ ដូច្នេះ ព្រះអង្គបានសម្រេចចិត្តទៅយកទឹកមកឲ្យកុមារទាំងនោះ ។ ព្រះអង្គជិះសេះ យកថង់ស្បែកជាប់ខ្លួន សំដៅទៅឯស្ទឹងអឺប្រា្វាត់ (ហ្វ៊ូរ៉ត) ។

កងទ័ពអ៊្វម៉ៃយ៉ាស្ស៊ដែល យោលតាមកំណត់ហេតុខ្លះ មានវរេហ៍ពលចំនួនបួនពាន់នាក់ បានរត់ប្រាសអាយុអស់ ព្រះអង្គក៏បានកាន់កាប់ត្រើយស្ទឹងនោះតែម្នាក់ឯង ។ ខ្លួនព្រះអង្គក្តៅដូចភ្លើងដោយសារស្រេកទឹកខ្លាំង តែពេលព្រះអង្គលូកដៃទៅក្បង់ទឹកមកសោយ ព្រះអង្គនឹកឃើញព្រះរៀមព្រះអង្គដែលកំពុងស្រេកទឹក ព្រមទាំងព្រះរាជកុមារនិងព្រះរាជវង្ស ។ ហេតុដូច្នេះ ព្រះអង្គគ្រវាត់ទឹកចោល ហើយប្តេជ្ញាថាព្រះអង្គនឹងមិនសោយទឹកជាដាច់ខាតដរាបណាព្រះរៀមអង្គ ព្រះអគ្គប្រមុខ អ៊ីម៉ាំអាល់-ហ៊្វូសៃន៍ صلوات الله عليه والسلام ស្រេកទឹក (ពោលគឺ មិនផឹកទឹកមុនអ៊ីម៉ាំ صلوات الله عليه والسلام ទេ) ។

ក្រោយពីទង្វើបរទត្ថនិយម (គឺការគិតដល់អ្នកដទៃជាងខ្លួនឯង) ដ៏អស្ចារ្យនេះដែលធំធេងលើសទំហំសម័យកាលនិងវេហា អាល់-អ៊ុាប់បាស់បានយកថង់ស្បែកដាក់ទឹកពេញ ហើយត្រឡប់ទៅកាន់ជំរំព្រះរៀមព្រះអង្គវិញ ។ ទទឹមនឹងពេលនេះដែរ ខ្មាំងបានព័ទ្ធព្រះអង្គជុំជិត រារាំងព្រះអង្គយកទឹកនោះ ។ ឥតព្រឺទ្បើយ ព្រះអង្គវាយប្រហារពួកវាស្លាប់អស់ច្រើន ។ ព្រោះតែស្លុតរន្ធត់ ភ័យតក្កមា ពួកខ្មាំងរត់គេចខ្លួនពីមុខអាល់-អ៊ុាប់បាស់ដែលយកព្រះបិតាព្រះអង្គជាតម្រាប់ក្លាហាន ។ តែបុគ្គលមានពុតថោកទាបស្រុកគូហ្វាស្ស៊ម្នាក់ពួនស្កាត់ផ្លូវព្រះអង្គពីក្រោយដើមលម៉ើ បានកាប់ព្រះអង្គពីក្រោយខ្នងដាច់ដៃស្តាំ ។ ទោះជាដូច្នេះក៏ដោយ វីរបុរសអាល់-អ៊ុាប់បាស់ មិនខ្វល់ខ្វាយទ្បើយ ព្រះអង្គកាន់ទង់ដោយដៃឆ្វេង បន្តដំណើរ

ដោយប្រកាសថា៖ "ទោះបីពួកអ្នកកាត់ដៃខ្ញុំក៏ដោយ ក៏ខ្ញុំនៅតែការពារព្រះសាសនានិងព្រះអគ្គប្រមុខរបស់ខ្ញុំ ។" បន្ទាប់ពីនោះបន្តិច បុរសម្នាក់ទៀតដែលពួននៅក្រោយដើមឈើ បានកាប់អាល់-អ្ពាប់បាស់មួយដាវដាច់ដៃឆ្វេង ។

ទោះបីព្រះអង្គហូរឈាម ឈឺចាប់ដោយសាររបួសថែមពីលើអាការស្រេកទឹកក៏ដោយ អាល់-អ្ពាប់បាស់ពាំថង់ទឹកធ្វើអំពីស្បែកដោយធ្មេញ រត់យកទៅឲ្យរាជបុត្រនិងព្រះរាជវង្សរបស់ព្រះរៀមព្រះអង្គ ។ ក្នុងពេលនោះ លំពែងមួយបានទម្លុះថង់ទឹក ហូរទឹកមកលើដី ។ ឃើញបែបនេះ អាល់-អ្ពាប់បាស់ស្រយុតចិត្ត ស្រឡាំងកាំង ។ ព្រះអង្គមិនដឹងនឹងត្រូវធ្វើអ្វីទេ ។ បន្ទាប់ពីនោះបន្តិច បុរសម្នាក់ទៀតវាយព្រះអង្គដោយបង្គោលដែកចំក្បាល ។ អាល់-អ្ពាប់បាស់ដួលទៅលើដី ហើយស្រែកថា៖ "អាប៊ូអ្ពាប់ឌុលឡោះហ្វ៍صلوات الله عليه والسلامអឺយ សូមសិរីសួស្តីកើតមានដល់ព្រះអង្គصلوات الله عليه والسلام ។" ខ្យល់បាននាំពាក្យពេជន៍សូមលាទៅឲ្យអ៊ីម៉ាំصلوات الله عليه والسلام ។ ព្រះអង្គصلوات الله عليه والسلامស្ទុះទៅឯស្ទឹងអាល់-អាល់ក៏មី កន្លែងដែលអាល់-អ្ពាប់បាស់ដួល ។ ព្រះអង្គصلوات الله عليه والسلامសម្រុកទៅលើទ័ពខ្មាំង ស្ទុះទៅឱបព្រះរាជសពប្អូន ។ ព្រះអង្គصلوات الله عليه والسلامថ្លែងសាទុក្ខក្នុងគ្រារងទុក្ខវេទនាដ៏ធ្ងន់នេះ គ្រាដែលអាល់-អ្ពាប់បាស់បានធ្វើទុក្ករកម្មដោយបូជាជីវិត អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلامបានស្រែកថា៖

الآنَ انْكَسَرَ ظَهْرِي، وَ قَلَّتْ حِيْلَتِيْ، وَ شَمُتَ بِي عَدُوِّي.

*"ចាប់ពីពេលនេះតទៅ ខ្នងខ្ញុំបាក់ (ពោលគឺ ខ្ញុំពុំមានពំនាក់ទៀតទេ) ខ្ញុំគ្មានសង្ឃឹមខណៈដែលសត្រូវខ្ញុំសប្បាយលើគំនរទុក្ខខ្ញុំ ។"*

ពុំមានអ្នកណាអាចរៀបរាប់អំពីអារម្មណ៍ពិតរបស់អ៊ីម៉ាំصلوات الله عليه والسلامបានទេ បន្ទាប់ពីអាល់-អ្ពាប់បាស់បានធ្វើទុក្ករកម្មដោយបូជាព្រះជន្ម ។ តែអស់លោកអ្នកប្រវត្តិសាស្ត្របានឲ្យដឹងថា ពេលព្រះអង្គصلوات الله عليه والسلامចាកចេញពីព្រះរាជសពព្រះអនុជព្រះអង្គصلوات الله عليه والسلام ព្រះអង្គصلوات الله عليه والسلامស្ទើរតែឈានជើងដើរមិនរួច ។ ព្រះអង្គصلوات الله عليه والسلامមកជំរំវិញដោយជូតទឹកភ្នែក ។ ព្រះរាជបុត្រីព្រះអង្គصلوات الله عليه والسلامដែលមានព្រះនាមថា ស៊ូកៃណាស្ហ៍ (سُكَينَة) បានទទួលព្រះអង្គصلوات الله عليه والسلامដោយសួរថា៖ "ឯណាព្រះបិតុលាអាល់-អ្ពាប់បាស់ ?"

អ៊ីមុាំصلوات الله عليه والسلامក៏ទ្រង់ព្រះកន្សែងដោយឥតលាក់លៀម ថ្លែងប្រាប់ព្រះនាងស៊ូកៃណាស់ថា ព្រះបិតុលាព្រះនាងបានធ្វើទុក្ករកម្មដោយបូជាព្រះជន្ម ។ ព្រះរាជបុត្រីព្រះអង្គصلوات الله عليه والسلامមិនអាចធ្វើអ្វីបានឡើយ ក្រៅពីយំឮៗ ។ ព្រះនាងស៊ែណាប់سلام الله عليهاពិបាកអត់ទ្រាំស្ថានភាពនេះលើសនេះទៀត ពេលបានដឹងដំណឹងភ្លាម ព្រះនាងដាក់ដៃលើបេះដូងហើយថ្លែងឮៗថា៖ "អនិច្ចាព្រះអនុជអើយ! អនិច្ចាអាល់-អ៊ុប់បាស់អើយ! យើងបាត់បង់ព្រះអនុជហាក់ដូចយើងបាត់បង់អ្វីៗទាំងអស់ ។"

នេះជាគ្រោះកាចបំផុតសម្រាប់អ៊ីមុាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلام និងព្រះរាជវង្សដែលយំសោកស្តាយទ្រហឹងនៅទីនោះ អាល័យព្រះអនុរក្ស អ្នកគាំពារព្រះអង្គទាំងអស់ ។ អ៊ីមុាំصلوات الله عليه والسلام ដែលបានចូលរួមជាមួយទាំងអស់គ្នានេះដែរនោះ ទ្រង់ព្រះកន្សែងឮៗថា៖ "យើងបាត់បង់អ្វីៗទាំងអស់ ពេលយើងបាត់បង់ប្អូន ឱអាល់-អ៊ុប់បាស់អើយ ។"

## ទារកដែរ

អ៊ុប់ឌុលឡោះហ្វ៍ ទារកអាយុប្រាំមួយខែ ព្រះរាជបុត្ររបស់អ៊ីមុាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلامសន្លប់ព្រោះស្រេកទឹក ។ មាតាព្រះរាជទារកនាំបុត្រទៅជួបព្រះនាងស៊ែណាប់سلام الله عليها សង្ឃឹមថាព្រះនាងអាចដោះស្រាយបញ្ហាបាន ។ ព្រះនាងស៊ែណាប់នាំព្រះរាជទារកទៅជួបអ៊ីមុាំអាល់-ហ៊ូនៃន៍صلوات الله عليه والسلام ព្រះរៀមព្រះនាង សូមព្រះអង្គصلوات الله عليه والسلامឲ្យទឹកព្រះរាជទារកសោយបន្តិច ។ អ៊ីមុាំصلوات الله عليه والسلام បីព្រះរាជទារក ថើបព្រះរាជទារកយ៉ាងច្រើន ហើយនាំព្រះរាជទារកទៅរកទ័ពអ៊ូម៉ៃយ៉ាស់ សង្ឃឹមថានឹងអាចធ្វើឲ្យពួកគេទន់ចិត្តបាន អាណិតអាសូរទារក នឹងឲ្យទឹកសោយខ្លះ ។

ស្ថានភាពនេះពុំមានប្រសិទ្ធិភាពលើបុគ្គលឥតបេះដូង អមនុស្សធម៌ទាំងនោះទេ ។ ជំនួសការអាណិតអាសូរ ពួកគេបាញ់ព្រួញតម្រង់ទារក គ្រាប់ព្រួញទម្លុះកព្រះរាជទារក ។ កម្លាំងគ្រប់ព្រួញធ្វើឲ្យទារកដកដៃទាំងពីរចេញពីក្រណាត់រុំខ្លួន កម្រើករវើកដូចសត្វស្លាបត្រូវសំឡេះផ្ទាប់នឹងទ្រូងបិតា ។ ទីបំផុត ព្រះរាជទារកងើបក្បាលទៅឯមេឃ ដកដង្ហើមចុងក្រោយ

នៅចំពោះមុខបិតា ។

អ៊ីម៉ាំصلوات الله عليه والسلامត្រឡប់វិញដោយស្មារតីរឹងមាំ បីទារកស្លាប់ទៅឲ្យព្រះនាងស៊ែណាប់سلام الله عليها ហើយព្រះអង្គصلوات الله عليه والسلامលើកដៃទាំងពីរដែលប្រឡាក់ឈាមទារកនោះសំដៅមេឃ ប្ដឹងព្រះអ្នកបង្កើតعز وجل ។

## មហាវិបត្តិ

អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلامឈរនៅតែម្នាក់ឯង ឥតញញើត ប្រកបដោយការប្ដេជ្ញាចិត្តដ៏អស្ចារ្យមិនធ្លាប់មានពីមុនឡើយ នៅកណ្ដាលលានប្រយុទ្ធឡោមព័ទ្ធជុំជិតដោយខ្មាំងសាហាវយង់ឃ្នង ។ អ្នកខ្លះកោតស្ងើចសេចក្ដីក្លាហានព្រះអង្គصلوات الله عليه والسلام ខ្លះទៀតមិនអាចអត់ភ្ញាក់ផ្អើលបានឡើយ ។ ទោះជាយ៉ាងណាក៏ដោយ អ៊ីម៉ាំصلوات الله عليه والسلامសម្រុកចូលវាយ ប្រហារបច្ចាមិត្តប្រល័យពួកសត្រូវក្ស័យមួយចំនួនធំ ។

បន្ទាប់មក ព្រះអង្គصلوات الله عليه والسلامត្រឡប់ទៅជំរំវិញដើម្បីសូមលា និងផ្ដែផ្ដាំព្រះរាជវង្សព្រះអង្គصلوات الله عليه والسلامជាគ្រាចុងក្រោយ ។ ព្រះអង្គصلوات الله عليه والسلامបានដាក់ព្រះរាជបញ្ជាឲ្យពឹងផ្អែកលើអល់ឡោះហ្ទ៍تعالىដោយការអត់ធ្មត់ និងដោយស្មារតីម៉ឹងម៉ាត់ កុំស្លុត ។ បន្ទាប់មក ព្រះអង្គصلوات الله عليه والسلامបែរទៅរកព្រះអនុជាព្រះអង្គصلوات الله عليه والسلام ព្រះនាងស៊ែណាប់سلام الله عليها ផ្ដែផ្ដាំព្រះនាងسلام الله عليهاឲ្យអត់ធ្មត់ ឲ្យខំទប់ទឹកភ្នែកនិងអត់ទ្រាំការឈឺចាប់ ។ ទីបញ្ចប់ព្រះអង្គصلوات الله عليه والسلامដាក់បញ្ជាឲ្យព្រះនាងسلام الله عليهاជាព្រះអនុរក្ស (គឺអ្នកបីបាច់ថែរក្សា មើលខុសត្រូវ) ព្រះរាជកុមារនិងព្រះហ្ញារីមទាំងអស់ ។

ពេលជិតចាកចេញ ព្រះហ្ញារីមព្រះអង្គصلوات الله عليه والسلامចោមព្រះអង្គصلوات الله عليه والسلامដោយភ្នែកជោកជាំ ដោយរលួយចិត្តរលួយថ្លើម ។ អ្ញលី ស៊ែន៍ អាល់-អ្ញប៊ីឌីនصلوات الله عليه والسلام ដែលឈឺនិងខ្សោយក្រៃលែងនោះ បានសូមព្រះបិតុច្ឆាព្រះអង្គصلوات الله عليه والسلام ព្រះនាងស៊ែណាប់سلام الله عليها ឲ្យរកឈើច្រត់និងដាវឲ្យព្រះអង្គصلوات الله عليه والسلام ។ ឈើច្រត់សម្រាប់ទប់ខ្លួនព្រះអង្គصلوات الله عليه والسلامឲ្យអាចឈរបាន ដាវសម្រាប់ការពារព្រះបិតាព្រះអង្គصلوات الله عليه والسلام ។ ឃើញដូច្នេះ អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلامប្រាប់ព្រះអនុជាព្រះអង្គصلوات الله عليه والسلامឲ្យឃាត់ អ្ញលី អ៊ីបនូ អាល់-ហ៊្វសែន៍صلوات الله عليه والسلام កុំឲ្យទៅឯលាន

ប្រយុទ្ធ ព្រះនាងسلام الله عليهاបានធ្វើតាម តែដោយប្រើកម្លាំង ។
ទីបំផុត ព្រះអង្គصلوات الله عليه والسلامបានផ្ដែផ្ដាំព្រះរាជហ្ការីមព្រះអង្គصلوات الله عليه والسلامជាបណ្ដាំចុងក្រោយ ឲ្យស្លៀកពាក់អន់ ឲ្យត្រៀមខ្លួនរងមហាវិបត្តិ ឲ្យផ្ញើខ្លួនលើអល់ឡោះហ៊្ញ៉عز وجلទាំងស្រុង ។ ពាក្យពេជន៍ចុងក្រោយដែលអ៊ីម៉ាំصلوات الله عليه والسلامផ្ដែផ្ដាំព្រះរាជហ្ការីមព្រះអង្គصلوات الله عليه والسلامគឺ៖

اِسْتَعِدُّوا لِلْبَلاَءِ وَ اَعْلَمُوْا اَنَّ اللهَ حَامِيْكُمْ وَ حَافِظُكُمْ وَ سَيُنْجِيْكُمْ مِنْ شَرِّ الأَعْدَاءِ وَ يَجْعَلُ عَاقِبَةَ أَمْرِكُمْ اِلٰي خَيْرٍ وَ يُعَذِّبُ عَدُوَّكُمْ بِاَنْوَاعِ العَذَابِ وَ يُعَوِّضُكُمْ عَنْ هٰذِهِ البَلِيَّة بِاَنْوَاعِ النِّعَمِ وَ الْكَرَامَةِ فَلاَ تَشْكُوا وَلاَ تَقُوْلُوا بِأَلْسِنَتِكُمْ مَا يُنْقِصُ قَدْرَكُمْ.

*"ចូរទាំងអស់គ្នាត្រៀមខ្លួនទទួលរងគ្រោះកាចក្នុងពេលឆាប់ៗនេះ ។ ចូរទាំងអស់គ្នាដឹងថាអល់ឡោះហ៊្ញ៉عز وجلនឹងថែរក្សា ការពារ សង្គ្រោះអ្នកទាំងអស់គ្នា មិនឲ្យពួកនោះប្រព្រឹត្តអាក្រក់លើអ្នកទាំងអស់គ្នាទេ ។ ព្រះអង្គعز وجلនឹងឲ្យអ្នកទាំងអស់គ្នាបានសម្រេច បានជោគជ័យ ព្រះអង្គعز وجلនឹងធ្វើទណ្ឌកម្មសត្រូវរបស់អ្នកទាំងអស់គ្នាយ៉ាងឈឺចាប់បំផុត ព្រះអង្គعز وجلនឹងតបស្នងអ្នកទាំងអស់គ្នាដែលបានអត់ទ្រាំគ្រោះកាចនេះ ដោយព្រះមេត្តាធម៌និងព្រះសាធុពរ ។ ដូច្នេះ អ្នកទាំងអស់គ្នាមិនត្រូវត្អូញត្អែរ មិនត្រូវនិយាយអ្វីដែលធ្វើឲ្យខូចកិត្តិយសឡើយ ។*

រួចហើយ ព្រះអង្គصلوات الله عليه والسلامបួងសួងព្រះម្ចាស់عز وجلព្រះអង្គصلوات الله عليه والسلام ប្ដឹងព្រះអង្គعز وجلអំពីគ្រោះកាចដែលទាំងអស់គ្នាទទួលរង ។ ព្រះអង្គصلوات الله عليه والسلامបានទូលថា៖

صَبْرًا عَلٰي قَضَائِكَ يَا رَبُّ، لاَ اِلٰهَ سِوَاكَ، يَا غِيَاثَ الْمُسْتَغِيْثِيْنَ، مَا لِي رَبٌّ سِوَاكَ وَلاَ مَعْبُوْدٌ غَيْرُكَ صَبْرًا عَلٰي حَكْمِكَ يَا غِيَاثَ مَنْ لاَ غِيَاثَ لَهُ ، يَا دَائِمًا لاَ نَفَادَ لَهُ، يَا مُحْيِيَ المَوْتٰي، يضا قَائِمًا عَلٰي كُلِّ نَفْسٍ بِمَا كَسَبَتْ، اَحْكُمْ بَيْنِي وَ بَيْنَهُمْ وَ اَنْتَ خَيْرُ الْحَاكِمِيْنَ.

*"ព្រះម្ចាស់عز وجلអើយ ទូលព្រះបង្គំជាខ្ញុំعز وجلអត់ធ្មត់បានដោយសារព្រះអង្គعز وجلប្រោសប្រណី ។ ពុំមានព្រះទេក្រៅពីព្រះអង្គعز وجل ។ ព្រះអង្គعز وجلជួយបណ្ដាអ្នកស្វែងរកជំនួយ ។ ក្រៅពីព្រះអង្គعز وجل ទូលព្រះបង្គំជាខ្ញុំصلوات الله عليه والسلامពុំមានម្ចាស់*

*ឬព្រះផ្សេងទេ ។ ព្រះអង្គ عزّ وجلّ ជាអ្នកសង្គ្រោះបណ្ដាអ្នកគ្មានជម្រក ។ ព្រះអង្គ عزّ وجلّ គង់នៅជានិច្ចឥតសាបសូន្យ ។ ព្រះអង្គ عزّ وجلّ ជាអ្នកឃ្លាំមើលសត្វលោកគ្រប់រូបពាក់ព័ន្ធនឹងទង្វើដែលសត្វលោកគ្រប់រូបធ្វើ ។ [ទូលព្រះបង្គំជាខ្ញុំសូមអង្វរព្រះអង្គ عزّ وجلّ] សូមព្រះអង្គ عزّ وجلّ កាត់ក្ដីឲ្យអស់ទូលព្រះបង្គំជាខ្ញុំផង ព្រោះព្រះអង្គ عزّ وجلّ ជាអ្នកកាត់ក្ដីប្រសើរដាច់គេ ។"*

បនឧក្រិដ្ឋ ទ័ពអ៊ូម៉ៃយ៉ាស៍គួរឲ្យស្អប់ខ្ពើម វាយប្រហារអ៊ីម៉ាំអាល់-ហ៊្វូសែន៍ صلوات الله عليه والسلام គ្រប់ទិសទី ។ ពួកវាកាប់ព្រះអង្គ صلوات الله عليه والسلام ដោយដាវ ចាក់ព្រះអង្គ صلوات الله عليه والسلام ដោយលំពែង ។[227]

ពេលព្រះអង្គ صلوات الله عليه والسلام នៅលើដី ពុំមានអ្នកណាមួយហ៊ានបង្ហើយជីវិតព្រះអង្គ صلوات الله عليه والسلام ទេ ។ ដូច្នេះ ព្រះអង្គ صلوات الله عليه والسلام នៅមួយកន្លែងអស់រយៈពេលដ៏យូរ ។

ឃើញដូច្នេះ ព្រះនាងស៊្សេណាប់ سلام الله عليها ឈរនៅឯពន្លាបើករបស់ព្រះនាង យំសោកស្ដាយអ៊ីម៉ាំ صلوات الله عليه والسلام យ៉ាងអាណោចអាធ័មជាទីបំផុត ។ ព្រះនាងថ្លែងថា៖ "អនិច្ចាព្រះរៀម ! អនិច្ចាព្រះអគ្គប្រមុខ ! អនិច្ចាព្រះរាជកុលដ្ឋានចុងក្រោយរបស់ខ្ញុំម្ចាស់ ! សូមអល់ឡោះហ៑ عزّ وجلّ ទម្លាក់មេឃមកលើផែនដី ! សូមអល់ឡោហ៑ عزّ وجلّ កម្ទេចភ្នំមកលើដីរាប !"

បន្ទាប់ពីនោះ ព្រះនាង سلام الله عليها ស្រែកដាក់អ៊្ហម៉ារ អ៊ីបនូ សាអ្ហដ៑ថា៖ "អ្នកឯងទ្រាំមើលគេសម្លាប់អាប៊ូ អ្ហប់ឌុលឡោះហ៑បានដូចម្ដេច ?"

ជាចម្លើយតបសំណួរព្រះនាងស៊្សេណាប់ سلام الله عليها អ៊្ហម៉ារ បុគ្គលចង្រៃ បែរមុខចេញពីព្រះនាងដោយហូរទឹកភ្នែកមកលើពុកមាត់ ។

មិនអាចទ្រាំមើលព្រះរៀមព្រះនាងក្នុងសភាពនេះបានតទៅទៀតទេ ព្រះនាងស៊្សេណាប់ سلام الله عليها ត្រឡប់ទៅកាន់ពន្លាវិញ ដើម្បីមើលថែទាំព្រះរាជកុមារនិងព្រះរាជហ្ការីមដែលបន្តិចទៀតនឹងអត់ទីពឹងពាក់ ។

អ៊្ហម៉ារ អ៊ីបនូ សាអ្ហដ៑បញ្ជាឲ្យមេបញ្ជាការទ័ពគាត់បង្ហើយជីវិតអ៊ីម៉ាំ តែពុំមានអ្នកណាម្នាក់យល់ព្រមទេ ក្រៅពីស្ហ៊ីមរ ។ ស្ហ៊ីមរដើរសំដៅអ៊ីម៉ាំ صلوات الله عليه والسلام ហើយបានកាត់ព្រះសិរព្រះអង្គ صلوات الله عليه والسلام ។

---

[227] សូមមើលសៀវភៅរបស់លោក ស្ហាហ្វ៊ីដ្ ហាមីដ្ អ៊ីបនូ មូហ៊ាំម៉ាដ៑ អាល់-ម៉ាហ៊្លី *អាល់-ហ្កាដ្វាអ៊ុក្ក អាល់-វ៉ារឌ្វីយ៉ាស៑* ក្បាលទី ១ ទំព័រ ១២៦ ។

សេះអ៊ីម៉ាំ صلوات الله عليه والسلام កញ្ជ្រៀវខ្លាំង វាព្យាយាមប្រាយបច្ចាមិត្ត ។ បន្ទាប់មក វាប៉ាតមុខវាដោយឈាមអ៊ីម៉ាំ صلوات الله عليه والسلام ហើយសំដៅទៅឯជំរំព្រះរាជវង្ស ។
ព្រះនាងស្សៃណាប់ سلام الله عليها រត់ទៅរកព្រះរាជសពបរិសុទ្ធរបស់អ៊ីម៉ាំ صلوات الله عليه والسلام អាល់-ហ៊្វូសៃន៍ صلوات الله عليه والسلام ឃើញព្រះរាជសពដាច់ រហែកដោយដាវនិងលំពែងរបស់ពួកបិសាចឥតមេត្តា ។ នៅពីមុខព្រះរាជសពនោះ ព្រះនាង سلام الله عليها ឈរដោយសេចក្តីថ្លៃថ្នូរ ដោយដាក់ខ្លួនទោះបីពួកសត្រូវឡោមព័ទ្ធក៏ដោយ ព្រះនាងក្រឡេកមើលទៅលើមេឃ ថ្លែងពាក្យពេជន៍ ពោរពេញដោយរស្មីជំនឿនិងសេចក្តីស្មោះស្ម័គ្រ ចំពោះអល់ឡោះហ្ទ៍ عزّ وجلّ ថា៖

اَللّٰهُمَّ تَقَبَّلْ مِنَّا هٰذَا الْقُرْبَانَ.

*"អល់ឡោះហ្ទ៍ عزّ وجلّ អឺយ សូមព្រះអង្គ عزّ وجلّ ទទួលពីអស់ទូលព្រះបង្គំខ្ញុំនូវព្រះតង្វាយនេះ ។"*

ព្រះនាងស្សៃណាប់ سلام الله عليها ទទួលរងគ្រោះកាចនោះដោយស្មារតីរឹងមាំ ដើម្បីអល់ឡោះហ្ទ៍ عزّ وجلّ និងដើម្បីការពារព្រះសាសនាអល់ឡោះហ្ទ៍ عزّ وجلّ ឲ្យនៅតែបរិសុទ្ធនិងពិតមិនក្លែងក្លាយ ដូចកាលព្រះសាសនានេះត្រូវបានដាក់មកពីលើមេឃ ។ តាមរយៈពាក្យពេជន៍ទាំងនេះ ព្រះនាង سلام الله عليها បង្ហាញឲ្យឃើញនូវអត្ថន័យពិតនៃមរតករបស់ព្រះសាស្តា صلى الله عليه وآله وسلم និងការខិតខំព្យាយាមក្នុងការអនុវត្តិតាមបំណងព្រះបិតាព្រះនាង ។

បន្ទាប់ពីបានធ្វើគុតនិងលួចប្លន់អ៊ីម៉ាំ صلوات الله عليه والسلام ទ័ពអ៊្វម៉ៃយ៉ាស្ទ់ ក្រោមបញ្ជារបស់មេបញ្ជាការ បានយកគប់ភ្លើងសំដៅទៅឯជំរំពន្លាអ៊ីម៉ាំ صلوات الله عليه والسلام ដើម្បីដុតបំផ្លាញពន្លាទាំងនោះ ។

ពេលពន្លាទាំងនេះឆេះ ព្រះរាជកុមារនិងព្រះរាជវង្សរត់ប្រសាច ។ បណ្តាស្ត្រីព្រះរាជវង្សព្រះសាស្តា صلى الله عليه وآله وسلم រត់គេចពីពន្លាមួយទៅពន្លាមួយ ចំណែកឯព្រះរាជកុមារព្រះកុលដ្ឋានព្រះសាស្តា صلى الله عليه وآله وسلم យំ ខំតោងអ្នកថែរក្សាជាប់ គឺព្រះនាងស្សៃណាប់ سلام الله عليها ។ ព្រះរាជកុមារខ្លះរត់គ្មានគោលដៅ ។

គ្រានេះព្រះរាជកុលដ្ឋានព្រះសាស្តា صلى الله عليه وآله وسلم បានរងគ្រោះកាចធ្ងន់បំផុត មិនដែលពើបពះឡើយ ។ ពេញមួយជីវិតព្រះអង្គ صلوات الله عليه والسلام អ៊ីម៉ាំអាលី ស្សៃន៍ អាល់-អាប៊ីឌ្ទីន صلوات الله عليه والسلام មិនអាចភ្លេចគ្រានេះបានឡើយ ។ ព្រះអង្គ صلوات الله عليه والسلام រំលឹក

គ្រានោះឡើងវិញដោយឈឺចាប់ថា៖ "ពេលខ្ញុំមើលព្រះបិតុច្ឆានិងប្អូនស្រី ទាំងអស់របស់ខ្ញុំ ខ្ញុំស្រក់ទឹកភ្នែក ។ ខ្ញុំនឹកឃើញពេលព្រះនាងទាំងអស់រត់ ពីពន្លាមួយទៅរកពន្លាមួយទៀត ខណៈដែលពួកខ្មាំងស្រែកថា៖ "ដុតផ្ទះ របស់ពួកប្រព្រឹត្តខុសចោល ។""

លើសពីនោះ បនឧក្រិដ្ឋប្លន់យកសព្វសារពើដែលមាននៅក្នុងពន្លាទាំង នោះ ។ ពួកវាប្លន់យកគ្រឿងអលង្ការដែរ ។ ពួកវាវាយស្ត្រីព្រះរាជកុលដ្ឋាន ព្រះសាស្ដាصلى الله عليه وآله وسلمដោយដងលំពែង ខណៈដែលព្រះនាងរត់រកគ្នាដើម្បី ការពារខ្លួន ។

បនឧក្រិដ្ឋវាយប្រហារអ៊ុលី ស៊ែន៍ អាល់-អ៊ុាប៊ីឌីនដែលកំពុងឈឺ ។ ស៊្ហីមរ្ហ បម្រុងសម្លាប់ព្រះអង្គصلوات الله عليه والسلام តែបុរសម្នាក់បានស្ដីបន្ទោសគាត់ ព្យាយាម ហាមឃាត់គាត់ ។ តែស៊្ហីមរ្ហមិនអើពើទេ គាត់សំដៅទៅរកអ៊ីម៉ាំصلوات الله عليه والسلامដែល មានជម្ងឺនោះដើម្បីធ្វើគុតព្រះអង្គصلوات الله عليه والسلام[228] ។ ព្រះនាងស៊ែណាប់سلام الله عليهاស្ទុះទៅ រកព្រះភាតុបុត្តព្រះនាង ចាប់ព្រះអង្គصلوات الله عليه والسلامជាប់ហើយថា៖ "ទេ អ្នកឯងត្រូវ សម្លាប់ខ្ញុំសិន មុនសម្លាប់គេصلوات الله عليه والسلام ។" ស៊្ហីមរ្ហចង្រៃក៏បានឈប់ ។

ក្រៅពីឃោរឃៅ អ៊ុំម៉ារ ដែលគេសន្យាឲ្យរង្វាន់នោះ បានកែនអ្នកស្ម័គ្រចិត្ត យកសេះខ្លួនទៅជាន់ទ្រូង និងខ្នងព្រះរាជសពអ៊ីម៉ាំصلوات الله عليه والسلامអាល់-ហ៊្វសៃន៍ صلوات الله عليه والسلام ។ បុគ្គលអាក្រក់អន្យតិរ្ថិយដប់នាក់បានបង្ហាញខ្លួន ជិះសេះជាន់ឈ្លី ព្រះរាជសពអ៊ីម៉ាំصلوات الله عليه والسلام ។

ដល់ពេលយប់ ហើយនេះជាពេលយប់អប្រិយបំផុតក្នុងព្រះជន្មព្រះរាជ កុលដ្ឋានព្រះសាស្ដាصلى الله عليه وآله وسلم ។ ពុះពារឧបសគ្គសព្វយ៉ាង ព្រះនាងស៊ែណាប់ سلام الله عليهاបំពេញបេសកកម្មអ្នកថែរក្សាព្រះរាជបុត្រ និងព្រះរាជហ្ញាំរីមរបស់ព្រះ រៀមព្រះនាងسلام الله عليهاដែលបានធ្វើទុក្ករកម្មដោយបូជាព្រះជន្ម ។ ព្រះនាងដើរ រកព្រះរាជកុមារនៅឯទីរហោឋាននោះ មកជុំគ្នាមួយកន្លែង ។ បន្ទាប់មក ព្រះនាងسلام الله عليهاលួងលោមចិត្តព្រះរាជកុមារទាំងអស់ឲ្យខិតខំអត់ធ្មត់ ខាំមាត់ សង្កត់ចិត្ត ខណៈដែលព្រះរាជសពបិតានិងព្រះរៀមព្រះរាជកុមារទាំង

[228] សូមមើលសៀវភៅលោក អាល់-គ៉្មៀរម៉ានី (القرماني) *អាក់បារ អាល់-ឌូវ៉ាល់* *(أخبار الدول)* ទំព័រ ១០៨ ។

នោះដេកស្លាប់ដេរដាសនៅកន្លែងនោះ រីឯពួកឧក្រិដ្ឋដែលគេចាត់ឲ្យយាមព្រះរាជកុមារនិងព្រះរាជហ្គារីមនោះឡោមព័ទ្ធព្រះអង្គទាំងអស់គ្នា ។

នៅក្នុងពេលយប់អប្រិយនោះដែរ ព្រះនាងស្ហៃណាប់سلام الله عليهاបានប្រមូលកម្លាំងពលំទាំងអស់ ដើម្បីងើបឡើងបំពេញស្ហ៍ឡាត៉អរព្រះគុណព្រះជាម្ចាស់عز وجل ដែលបានឲ្យព្រះនាងسلام الله عليهاពើបពះភ័យវិបត្តិនិងគ្រោះកាច ។ ព្រះនាងسلام الله عليهاបានបួងសួងព្រះជាម្ចាស់عز وجلដែរ សូមឲ្យព្រះអង្គعز وجلសព្វព្រះហឫទ័យទទួលពលីកម្មទាំងនេះ ។ ព្រះនាងسلام الله عليهاបានស្ហ៍ឡាត៉យាមយប់ដែរ តែដោយអង្គុយព្រោះព្រះនាងسلام الله عليهاលែងមានកម្លាំងឈរតទៅ[229]ទៀត ។

ថ្ងៃបន្ទាប់ បនឧក្រិដ្ឋសម្រេចចាប់ខ្លួនព្រះរាជកុមារនិងព្រះរាជហ្គារីមទៅងគូហ្វាស៊ុជាឈ្លើយ ។ បណ្ដាស្ត្រីអង្វរបនឧក្រិដ្ឋសូមទៅមើលព្រះរាជសពអ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلامនិងអ្នកដែលបានធ្វើពលីកម្មជីវិតឯទៀត ។ ពេលព្រះនាងប្រទះភ្នែកលើព្រះរាជសពអ៊ីម៉ាំអាល់-ហ៊ូសែន៍صلوات الله عليه والسلام គ្មានព្រះសិរព្រះនាងស្ហៃណាប់سلام الله عليهاបានស្រែកដោយឈឺចាប់ រន្ធត់ចិត្ត ថា៖

يَا مُحَمَّدَاهُ! صَلّي عَلَيْكَ مَلِيْكُ السَّمَاءِ! هٰذَا حُسَيْنٌ مُرَمَّلٌ بِالدِّمَاءِ مُقَطَّعُ الأَعْضَاءِ، وَ بَنَاتُكَ سَبَايَا! اِلٰي اللهِ الْمُشْتَكيٰ وَ اِلٰي عَلِيٍّ الْمُرْتَضٰي وَ اِلٰي فَاطِمَةَ الزَّهْرَاءِ وَ اِلٰي حَمْزَةَ سَيِّدِ الشُّهَدَاءِ هٰذَا حُسَيْنٌ بِالعَرَاءِ، نَسْفِي عَلَيْهِ الصَّبَا، قَتِيْلَ اَوْلاَدِ الأَدْعِيَاءِ وَاحُزْنَاهُ! وَاكَرْبَاهُ! اَلْيَوْمَ مَاتَ جَدِّي رَسُوْلُ اللهِ! يَا اَصْحَابَ مُحَمَّدَاهُ! هٰؤلاَءِ ذُرِّيَّةُ الْمُصْطَفٰي يُسَاقُوْنَ سَوْقَ السَّبَايَا.

*"មូហ៊ាំម៉ាដ្ឋ៍ﷺអើយ សូមព្រះម្ចាស់មេឃប្រសិទ្ធិពរព្រះអង្គﷺ ! នេះគឺអាល់-ហ៊ូសែន៍صلوات الله عليه والسلام ព្រះអង្គصلوات الله عليه والسلامប្រឡាក់ឈាម អវយវៈព្រះអង្គصلوات الله عليه والسلامត្រូវគេកាត់ ! នេះគឺបណ្ដាព្រះរាជបុត្រីព្រះអង្គﷺ ត្រូវគេចាប់ជាឈ្លើយសង្គ្រាម ! សូមប្ដឹង[អំពីរឿងនេះ]ដល់អល់ឡោះហ៊ុعز وجل ដល់អាលីអាល់-មូរតាដ្ហ៍صلوات الله عليه والسلام ដល់ហ្វាទីម៉ាស្ហ់ អាស្ហ់-ស្ហាស្ហ៉រ៉អ៊ុسلام الله عليها ដល់ហ៊ាំស្ហាស្ហ់ ព្រះអគ្គ*

[229] សូមមើលសៀវភៅរបស់លោក បាគៀរ ស្ហារីហ្វ អាល់-ក៉ូរ៉ស្ហ៊ី (شريف القرشي) *ហ៊ាយ៉ាស្ហ់ អាល់-អ៊ីម៉ាំ អាល់-ហ៊ូសែន៍ (حياة الإمام الحسين)* ក្បាលទី ៣ ទំព័រ ៣០៩ ។

*ប្រមុខរបស់បណ្ដាទុក្ករបុគ្គល ។ នេះគឺអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام នៅក្នុងរហោឋាន ។ ខ្យល់បក់មកលើព្រះរាជសពព្រះអង្គ صلوات الله عليه والسلام ។ ពួកទុច្ចរិតបានសម្លាប់ព្រះអង្គ صلوات الله عليه والسلام ។ អនិច្ចា ឈឺចាប់ម្ល៉េះទេ ! អិច្ចាទុក្ខធំម្ល៉េះទេ ! ថ្ងៃនេះហើយដែលព្រះអយ្យកោខ្ញុំម្ចាស់ ព្រះសាស្ដា صلى الله عليه وآله وسلم អល់ឡោះហ៍ عز وجل ចូលទិវង្គត ។ បណ្ដាសាវករបស់មូហាំម៉ាដ់ صلى الله عليه وآله وسلم អើយ នេះគឺព្រះរាជបុត្ររាជនត្តារបស់អាល់-មុសត្វាហ្វា صلوات الله عليه والسلام ព្រះសាស្ដាសម្រិតសម្រាំងដោយព្រះ عز وجل ។ ពួកគេត្រូវគេបង្ខិតបង្ខំ រុញច្រានដូចអ្នកទោសសង្គ្រាម ។"*

អ៊ីម៉ាំស៊្រែន៍ អាល់-អ៊ាប៊ីឌីន صلوات الله عليه والسلام ជាបុរសម្នាក់គត់ដែលរួចជីវិត ។ ព្រះអង្គ صلوات الله عليه والسلام មិនអាចទប់ខ្លួនបានទេ ពេលបានឃើញព្រះរាជសពព្រះបិតាព្រះអង្គ صلوات الله عليه والسلام និងទុក្ករបុគ្គលឯទៀតត្រូវគេទុកចោលកណ្ដាលវាល ។ ព្រះអង្គ صلوات الله عليه والسلام ឈឺចាប់ស្ទើរក្ស័យបង់អាត្មា តែព្រះនាងស៊្រៃណាប់ سلام الله عليها ពេលសម្គាល់ឃើញអាកប្បកិរិយាព្រះភាតុបុត្តព្រះនាង ក៏ប្រញាប់ទៅជួបព្រះអង្គ صلوات الله عليه والسلام ប្រាប់ព្រះអង្គ صلوات الله عليه والسلام ថា៖

مَا لِي أَرَاكَ تَجُوْدُ بِنَفْسِكَ– يَا بَقِيَّةَ جَدِّيْ وَ أَبِي وَ إِخْوَتِيْ؟ لَا يَجْزَعَنَّكَ مَا تَرَى، فَوَ اللَّهِ إِنَّ ذٰلِكَ لَعَهْدٌ مِنَ اللَّهِ إِلٰى جَدِّكَ وَ أَبِيْكَ.وَ لَقَدْ أَخَذَ اللَّهُ مِيْثَاقَ أُنَاسٍ مِنْ هٰذِهِ الْأُمَّةِ لَا تَعْرِفُهُمْ فَرَاعِنَة هٰذِهِ الْأُمَّةِ وَهُمْ مَعْرُوْفُوْنَ فِي أَهْلِالسَّمَاوَاتِ أَنَّهُمْ يَجْمَعُوْنَ هٰذِهِ الْأَعْضَاءَ الْمُتَفَرِّقَةَ وَهٰذِهِ الْجُسُوْمَ الْمُضَرَّجَةَ فَيُوَارُوْنَهَا وَ يُنْصِبُوْنَ بِهٰذَا الطَّفِّ عَلَمًا لِقَبْرِ أَبِيْكَ سَيِّدِ الشُّهَدَاءِ لَا يَدْرُسُ أَثَرُهُوَ لَا يَعْفُوْ رَسْمُهُ عَلٰى كُرُوْرِ اللَّيَالِي وَ الْأَيَّامِوَ لَيَجْتَهِدَنَّ أَئِمَّةُ الْكُفْرِ وَ أَشْيَاعُ الضَّلَالَةِ فِي مَحْوِهِ وَ تَطْمِيسِهِ فَلَا يَزْدَادُ أَثَرُهُ إِلَّا ظُهُوْراً وَ أَمْرُهُ إِلَّا عُلُوّاً.

*"ព្រះឧត្ដរាធិការីស្នងព្រះអយ្យកោខ្ញុំម្ចាស់ ស្នងព្រះបិតាខ្ញុំម្ចាស់ ស្នងព្រះរៀមខ្ញុំម្ចាស់អើយ ម្ដេចខ្ញុំម្ចាស់ឃើញព្រះអង្គ صلوات الله عليه والسلام ហៅរកសេចក្ដីស្លាប់ ?*[230]

---

[230] សូមមើលសៀវភៅ *កាមីល-អាល់-ស៊ីយ៉ារ៉ត (كامل الزيارات)* អ៊ីម៉ាំអ៊ាលី ស៊្រែន៍ អាល់-អ៊ាប៊ីឌីន صلوات الله عليه والسلام បានឆ្លើយតបព្រះបិតុច្ឆាព្រះអង្គ صلوات الله عليه والسلام ថា៖ "មិនឲ្យទូលបង្គំអស់សង្ឃឹមនិងអត់ទ្រាំម្ដេចបាន ពេលបានឃើញព្រះអគ្គប្រមុខរបស់ទូលបង្គំព្រះបិតុលាទូលបង្គំ បងប្អូននិងអស់បុគ្គលត្រកូលទូលបង្គំប្រឡាក់ឈាម ដេក

*សូមព្រះអង្គصلوات الله عليه والسلامកុំសោកសៅដោយសារទិដ្ឋភាពទាំងនេះ ។ ខ្ញុំម្ចាស់សូមស្បថ ក្នុងព្រះនាមអល់ឡោះហ្ទ៍عز وجل នេះគ្រាន់តែជាអ្វីដែលអល់ឡោះហ្ទ៍عز وجل បានប្រាប់ព្រះអយ្យកោនិងព្រះបិតាព្រះអង្គصلوات الله عليه والسلامពីមុនរួចមកហើយ ។ ការពិត អល់ឡោះហ្ទ៍عز وجلបានសន្យាជាមួយបុគ្គលមួយចំនួនដែលមនុស្សអាក្រក់មិនស្គាល់នៅលើផែនដីនេះ ក៏ប៉ុន្តែប្រជានិករមេឃស្គាល់ច្បាស់ថាឲ្យបុគ្គលអស់ទាំងនោះប្រមូលអវយវៈដែលត្រូវគេកាត់ទាំងនេះ និងសាកសពប្រឡាក់ឈាមទាំងនេះទៅបញ្ចុះ ឲ្យអស់បុគ្គលទាំងនោះលើកទង់ជ័យមួយនៅក្នុងទឹកដីនេះ អាល់-តួហ្វ៍ (الطف គឺឈ្មោះមួយទៀតរបស់ស្រុកការបាឡាអ៍) ពីលើផ្នូរព្រះបិតាព្រះអង្គصلوات الله عليه والسلام ព្រះអគ្គប្រមុខរបស់អស់ទុក្ករបុគ្គល ។ គ្រប់សម័យ គ្រប់ជំនាន់តំណមនុស្ស សញ្ញាចំណាំផ្នូរនេះនឹងមិនរលុបបាត់ឡើយ រូបសណ្ឋានរបស់ផ្នូរនេះនឹងមិនត្រូវបាត់បង់ស្លាកស្នាមទេ ។ តែពួកមេដឹកនាំជនឥតសាសនានិងពួកបង្កឲ្យកាន់តែមានការវៀចវេរឡើងនោះនឹងព្យាយាមលុបបំបាត់ផ្នូរទាំងនេះ តែផ្ទុយទៅវិញ វាកាន់តែធ្វើឲ្យលេចអណ្ដែតខ្ពស់ឡើងៗ ។"****

***សូមមើលសៀវភៅរបស់លោក យ៉ាក់ហ្វារ អ៊ីបនូ មូហាំម៉ាដ់ អាល់-គូមី (جعفر بن محمد القمي) *កាមីល-អាល់-ស៊ីយ៉ារ៉ត (كامل الزيارات)* ទំព័រ ៤៤៧ ។ នេះគឺហាឌីស្ហវែងមួយ ដែលមានសេចក្ដីសង្ខេបដូចតទៅ ។ អ៊ីមុាំស្ហៃន៍ អាល់-អាប៊ីឌីនصلوات الله عليه والسلامបានសួរព្រះបិតុច្ឆាព្រះអង្គصلوات الله عليه والسلامថា៖ "អ្វីទៅសន្យានោះ អ្វីទៅការប្ដេជ្ញានោះ ?" ព្រះនាងស្ហៃណាប់سلام الله عليهاបានឲ្យដឹងថា៖ "អ៊ូម អៃម៉ានបានប្រាប់ខ្ញុំម្ចាស់ថា ថ្ងៃមួយព្រះសាស្ដាصلى الله عليه وآله وسلمអល់ឡោះហ្ទ៍عز وجلបានទៅលេងផ្ទះព្រះនាងហ្វាទីម៉ាស្ហ៍سلام الله عليها ។ ព្រះនាងបានធ្វើម្ហូបហារីរ៉ោះត៍ឲ្យព្រះអង្គصلى الله عليه وآله وسلم សោយ - បបរលាយប្រេងនិងម្សៅ - អាលីصلوات الله عليه والسلامបានលើកផ្លែលម៉ើមួយចានមកឲ្យព្រះអង្គصلى الله عليه وآله وسلم ។ ខ្ញុំម្ចាស់ អ៊ូម អៃម៉ាន បន្ទាប់ពីនោះ បានលើកទឹក

អាក្រាតហើយត្រូវគេលួចប្លន់ គ្មានមឈូស គ្មានផ្នូរ ពុំអាចទៅស៊ីរ៉ាស្ហ៍ព្រះរាជសពព្រះអង្គបាន ពុំអាចទៅជិតព្រះអង្គបាន ហាក់ដូចជាព្រះអង្គទាំងអស់ពុំមែនជនជាតិអារ៉ាប់ ។"

ដោះគោមួយកែវនិងប័រមកឲ្យព្រះអង្គទាំងអស់គ្នា ។ ព្រះសាស្តាصلى الله عليه وآله وسلم អល់ឡោះហ្វ៍عز وجل អាុលីصلوات الله عليه والسلام ហ្វាទីម៉ាស់سلام الله عليها អាល់-ហាសាន់صلوات الله عليه والسلام និងអាល់-ហ៊ូសៃន៍صلوات الله عليه والسلام បានសោយចំណីនោះ សោយទឹកដោះគោនោះ ។ រួចហើយព្រះសាស្តាصلى الله عليه وآله وسلم លាងព្រះហត្ថ អាុលីصلوات الله عليه والسلام ស្រោចទឹកឲ្យព្រះអង្គصلى الله عليه وآله وسلم ។ បន្ទាប់មក ព្រះសាស្តាصلى الله عليه وآله وسلم យកព្រះហត្ថលុបមុខ ហើយក្រឡេកមើលអាុលីصلوات الله عليه والسلام ហ្វាទីម៉ាស់سلام الله عليها អាល់-ហាសាន់صلوات الله عليه والسلام និងអាល់-ហ៊ូសៃន៍صلوات الله عليه والسلام ដោយខ្សែភ្នែករីករាយ ។

បន្ទាប់មក ព្រះអង្គصلى الله عليه وآله وسلم ងើយមើលមេឃមួយភ្លែត បែរទៅរកគីបឡាត់ ហើយបានលាតសន្ធឹងព្រះហត្ថដើម្បីបួងសួង ។ បន្ទាប់មកព្រះអង្គصلى الله عليه وآله وسلم ក្រាបប្រណិប័តន៍ ហើយទ្រង់ព្រះកន្សែងពួៗ ហូរទឹកភ្នែក ។ បន្ទាប់មកព្រះអង្គصلى الله عليه وآله وسلم ងក់ព្រះសិរ ខណៈដែលទឹកភ្នែកហូរសស្រាក់ដូចភ្លៀង ។ ហ្វាទីម៉ាស់سلام الله عليها អាុលីصلوات الله عليه والسلام អាល់-ហាសាន់صلوات الله عليه والسلام អាល់-ហ៊ូសៃន៍صلوات الله عليه والسلام និងខ្ញុំម្ចាស់رضي الله عنها សោកស្តាយទិដ្ឋភាពនេះ តែពុំមានអ្នកណាមួយហ៊ានសួរព្រះអង្គصلوات الله عليه والسلام រកមូលហេតុទេ ។ តែពេលយំនោះបានប្រព្រឹត្តទៅអស់រយៈពេលយូរ អាុលីصلوات الله عليه والسلام និងហ្វាទីម៉ាស់سلام الله عليها បានសួរព្រះអង្គصلى الله عليه وآله وسلم ថា៖ "ព្រះសាស្តាصلى الله عليه وآله وسلم អល់ឡោះហ្វ៍عز وجل អឺយ ហេតុអ្វីព្រះអង្គصلى الله عليه وآله وسلم ទ្រង់ព្រះកន្សែង ? សូមអល់ឡោះហ្វ៍عز وجل កុំធ្វើឲ្យព្រះអង្គصلى الله عليه وآله وسلم ទ្រង់ព្រះកន្សែងឡើយ ។ អស់ទូលបង្គំពិបាកចិត្តណាស់ដែលឃើញព្រះអង្គصلى الله عليه وآله وسلم នៅក្នុងសភាពនេះ ។"

ព្រះសាស្តាصلى الله عليه وآله وسلم បានតបថា៖ "ប្អូនអឺយ ពេលខ្ញុំមើលអ្នកទាំងអស់គ្នា ខ្ញុំរីករាយណាស់ មិនដែលរីករាយបែបនេះទេកាលពីមុន ។ ដូច្នេះ ខ្ញុំអរព្រះគុណអល់ឡោះហ្វ៍عز وجل ដែលបានប្រោសប្រណីបែបនេះ ។ ទន្ទឹមនឹងពេលនេះដែរ ព្រះអគ្គទេវតាយ៉ីបរ៉អ៊ីលعليه السلام បានចុះមកប្រាប់ឲ្យដឹងជាមុនថា៖ "មូហាំម៉ាដ្ឋ៍صلى الله عليه وآله وسلم អឺយ អល់ឡោះហ្វ៍عز وجل ទ្រង់ញាណអារម្មណ៍ព្រះអង្គصلى الله عليه وآله وسلم ទ្រង់ញាណច្បាស់ថាព្រះអង្គصلى الله عليه وآله وسلم រីករាយនឹងព្រះអនុជព្រះអង្គصلى الله عليه وآله وسلم ព្រះរាជបុត្រីព្រះអង្គصلى الله عليه وآله وسلم និងព្រះរាជនត្តាទាំងពីររបស់ព្រះអង្គصلى الله عليه وآله وسلم ។ ដូច្នេះ ព្រះអង្គعز وجل បានធ្វើឲ្យព្រះឧបការគុណនេះសុក្រឹតឥតខ្ចោះឲ្យព្រះអង្គصلى الله عليه وآله وسلم ព្រះអង្គعز وجل អបអរសាទរព្រះអង្គصلى الله عليه وآله وسلم សម្រាប់ព្រះអំណោយនេះ ។ ព្រះអង្គعز وجل បាន

សម្រេចព្រះហឫទ័យ បង្រួបបង្រួមព្រះរាជបុត្រាជនត្តារបស់ពួកគេعليهم السلام បណ្ដាបក្សពួកពួកគេعليهم السلام បណ្ដាអ្នកស្រឡាញ់ពួកគេعليهم السلامនិងខ្លួនពួកគេផ្ទាល់ឲ្យបាននៅជុំជាមួយព្រះអង្គصلى الله عليه وآله وسلمក្នុងឋានសួគ៌ ។ ព្រះអង្គعز وجلបានសម្រេចព្រះហឫទ័យដែរ ថានឹងមិនបំបែកពួកគេពីព្រះអង្គصلى الله عليه وآله وسلمទេ ។ ព្រះអង្គعز وجلនឹងលើកតម្កើងពួកគេعليهم السلام ដូចព្រះអង្គعز وجلលើកតម្កើងព្រះអង្គصلى الله عليه وآله وسلمដែរ ព្រះអង្គعز وجلនឹងប្រទានឲ្យពួកគេعليهم السلامនូវព្រះឧបការគុណ ដែលព្រះអង្គعز وجل ប្រទានឲ្យព្រះអង្គصلى الله عليه وآله وسلمនោះដែរ លុះត្រាតែព្រះអង្គصلى الله عليه وآله وسلمគាប់ព្រះហឫទ័យ ឬលើសពីគាប់ព្រះហឫទ័យ ។

ទាំងនេះជាការតបស្នងគ្រោះកាចដែលពួកគេعليهم السلامនឹងពើបពះ និងជាការតបស្នងភ័យវិបត្តិដែលពួកគេعليهم السلامនឹងទទួលរង នៅក្នុងកណ្ដាប់ដៃពួកដែលអះអាងដោយខុសថាខ្លួននៅក្នុងសាសនារបស់ព្រះអង្គصلى الله عليه وآله وسلم ហើយថាខ្លួននៅក្នុងអ៊ុមម៉ាត់ព្រះអង្គصلى الله عليه وآله وسلم ទោះបីព្រះអង្គصلى الله عليه وآله وسلمនិងអល់ឡោះហ៍عز وجلមិនទទួលស្គាល់ពួកគេទាំងនោះក៏ដោយ ។ ពួកគេនឹងកាប់សម្លាប់ព្រះរាជកុលដ្ឋានព្រះអង្គصلى الله عليه وآله وسلم និងបណ្ដាអ្នកស្រឡាញ់ព្រះរាជកុលដ្ឋានព្រះអង្គصلى الله عليه وآله وسلم ពួកគេនឹងត្រូវកាប់សម្លាប់នៅឯទីកន្លែងផ្សេងៗ ផ្នូរពួកគេនឹងដាច់ឆ្ងាយពីគ្នាណាស់ ។ នេះគឺអ្វីដែលអល់ឡោះហ៍عز وجلបានជ្រើសរើសឲ្យពួកគេعليهم السلام និងព្រះអង្គصلى الله عليه وآله وسلم ។ ដូច្នេះ ចូរព្រះអង្គصلى الله عليه وآله وسلمអរព្រះគុណអល់ឡោះហ៍عز وجلដែលរើសយកជម្រើសនេះ ចូរព្រះអង្គصلى الله عليه وآله وسلمគាប់ព្រះហឫទ័យនឹងព្រះឧបការគុណនេះ ។"

ព្រះសាស្ដាصلى الله عليه وآله وسلمមានព្រះវចនៈថា៖ "ដូច្នេះ ខ្ញុំصلى الله عليه وآله وسلمក៏បានអរព្រះគុណអល់ឡោះហ៍عز وجل ពេញចិត្តនឹងអ្វីដែលព្រះអង្គعز وجلសម្រេចឲ្យខ្ញុំصلى الله عليه وآله وسلمរឿងពួកអ្នកعليهم السلام ។ ព្រះអគ្គទេវតាបានបន្ថែមទៀតថា៖ "មូហាំម៉ាដ់صلى الله عليه وآله وسلمអើយ បន្ទាប់ពីព្រះអង្គصلى الله عليه وآله وسلمចូលទិវង្គត អ៊ុមម៉ាត់ព្រះអង្គصلى الله عليه وآله وسلمនឹងធ្វើទុក្ខបុកម្នេញនិងរើសអើងអាលីصلوات الله عليه والسلام ព្រះអនុជព្រះអង្គصلى الله عليه وآله وسلم ។ សត្រូវព្រះអង្គصلى الله عليه وآله وسلمនឹងរំខានអាលីصلوات الله عليه والسلام ។ ទីបំផុត អាលីصلوات الله عليه والسلامនឹងត្រូវសម្លាប់ដោយដៃបុគ្គលអប្រិយបំផុតដែលគេចាត់ទុក ដូចឃាតករមេអូដ្ឋរបស់ព្រះសាស្ដាស្វលិះហ្ស៍عليه السلامដែរ ។ ព្រឹត្តិការណ៍នេះកើតឡើងនៅឯស្រុកមួយ ដែលអាលីصلوات الله عليه والسلامនឹងភៀសខ្លួន

ទៅស្នាក់នៅ ហើយស្រុកនោះ ក្រោយមក នឹងក្លាយទៅជាមណ្ឌលរបស់បណ្តាអ្នកស្រឡាញ់ព្រះអង្គ صلوات الله عليه والسلام និងរបស់បណ្តាអ្នកស្រឡាញ់ព្រះរាជបុត្ររាជនត្តារបស់ព្រះអង្គ صلوات الله عليه والسلام ។ នៅក្នុងទឹកដីនេះដែរ ពួកគេ عليهم السلام នឹងរងទុក្ខវេទនាធ្ងន់និងគ្រោះមហន្តរាយធំបំផុត ។

ពាក់ព័ន្ធនឹងព្រះរាជនត្តាព្រះអង្គ صلى الله عليه وآله وسلم អាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام រួមជាមួយបុគ្គលថ្លៃថ្លានៃព្រះរាជវង្សព្រះអង្គ صلوات الله عليه والسلام មួយក្រុម ព្រមទាំងសីលវន្តជ្រះថ្លាជាងគេក្នុងអ៊ុមម៉ាត់ព្រះអង្គ صلى الله عليه وآله وسلم នឹងត្រូវគេសម្លាប់នៅឯត្រើយស្ទឹងហ្វ៊ូរ៉ាតក្នុងទឹកដីមួយដែលគេហៅថាការបាឡាអ៊ុំ ។ ដោយហេតុនេះ ពួកសត្រូវរបស់ព្រះអង្គ صلى الله عليه وآله وسلم នឹងរងការឈឺចាប់ និងទារុណកម្មមិនអាចចៀសបាន ក្នុងថ្ងៃឈឺចាប់ឥតឈប់ឈរ ឯទុក្ខវេទនានឹងគ្មានទីបញ្ចប់ (គឺថ្ងៃរស់ពីស្លាប់វិញ) ។

ទឹកដីនោះ គឺការបាឡាអ៊ុំ ជាទីកន្លែងល្អបំផុតនៅលើផែនដីនេះ ហើយជាបូជណីយស្ថាន ។ កន្លែងនោះជាចំណែកមួយនៃឋានសួគ៌ដែរ ។ ក្នុងថ្ងៃដែលព្រះរាជនត្តាព្រះអង្គ صلى الله عليه وآله وسلم និងព្រះរាជកុលដ្ឋានព្រះអង្គ صلى الله عليه وآله وسلم ត្រូវគេសម្លាប់ ត្រូវពួកឥតសាសនាចង្រៃមួយក្រុមឡោមព័ទ្ធ ដីនឹងរញ្ជួយ ភ្នំនឹងរង្គើនិងយោល ខ្យល់សមុទ្រនឹងបក់គ្មានសណ្តាប់ធ្នាប់ មេឃនិងប្រជានិករមេឃនឹងញ័រ ជាសញ្ញាកំហឹងដោយឈឺឆ្អាលព្រះអង្គ صلى الله عليه وآله وسلم និងព្រះរាជកុលដ្ឋានព្រះអង្គ صلى الله عليه وآله وسلم ហើយជាសញ្ញាបាបដ៏ធំនៃការប្រព្រឹត្តបំពារបំពានលើព្រះរាជបុត្ររាជនត្តាព្រះអង្គ صلى الله عليه وآله وسلم និងព្រះសន្តភាពព្រះអង្គ صلى الله عليه وآله وسلم និងជាសញ្ញាបាបធំនៃការល្មើសគុណចំពោះព្រះអង្គ صلى الله عليه وآله وسلم រឿងព្រះរាជបុត្ររាជនត្តាព្រះអង្គ صلى الله عليه وآله وسلم ។

សត្វលោកទាំងនេះ ពោលគឺ ផែនដី ភ្នំ សមុទ្រនិងមេឃនឹងទទូចសូមអល់ឡោះហ្ 'عز وجل' សូមព្រះអង្គ عز وجل អនុញ្ញាតឲ្យពួកគេឈរនៅខាងព្រះរាជបុត្ររាជនត្តាព្រះអង្គ صلى الله عليه وآله وسلم ដែលត្រូវគេប្រព្រឹត្តបំពារបំពានលើ ដែលត្រូវគេធ្វើបាបនោះ គឺអស់បុគ្គលដែលអល់ឡោះហ៍ عز وجل បានចាត់ទុកជាបុគ្គលចម្បងលើមនុស្សជាតិក្រោយពីព្រះអង្គ صلى الله عليه وآله وسلم ។ ដូច្នេះ អល់ឡោះហ៍ عز وجل នឹងបើកឲ្យមេឃ ផែនដី ភ្នំនិងសមុទ្រដឹងថា៖ "អញគឺអល់ឡោះហ៍ ព្រះដ៏មាន

សព្វានុភាព ព្រះដ៏មានមហិទ្ធិឫទ្ធិ ។ ពុំមានការពេបជ្រាយណាមួយកំបាំងពីអញបានឡើយ ពុំមានអ្វីមួយអាចទប់ទល់អំណាចអញបានឡើយ ។ អញសក្តិសមជាអ្នកការពារ សក្តិសមជាអ្នកសងសឹកពួកឧក្រិដ្ឋទាំងនោះ ។ អញសូមស្បថ ក្នុងនាមនៃបរមានុភាពនិងវិរោចនភាពអញ ថាអញធ្វើទណ្ឌកម្មអ្នកណាមួយដែលឈ្លានពានព្រះសាស្តាអញ និងបុគ្គលជំនិតរបស់គេដោយប្រព្រឹត្តអគប្បីទៅលើរាជបុត្ររាជនត្តារបស់គេ អ្នកណាមួយដែលប្រមាថសន្តភាពគេ អ្នកណាមួយដែលសម្លាប់បណ្តាកូនចៅគេ អ្នកណាមួយដែលផ្តាច់សម្បថ អ្នកណាមួយដែលធ្វើបាបរាជកុលដ្ឋានគេ ។ អញនឹងធ្វើទោសបុគ្គលអស់ទាំងនោះដោយទោសនីមួយដែលអញមិនដែលធ្វើចំពោះសត្វលោកណាមួយឡើយ ។"

ឥឡូវនេះ សព្វសារពើនៅលើមេឃនិងផែនដីនឹងបួងសួងអល់ឡោះហ៍ﷻ ឲ្យដាក់បណ្តាសាបុគ្គលអស់ទាំងនោះ ដែលប្រព្រឹត្តអាក្រក់ទៅលើបណ្តាកូនចៅព្រះអង្គﷺ ដែលប្រមាថសន្តភាពព្រះអង្គﷺ ។ ពេលក្រុមបុគ្គលថ្លៃថ្លា [ដែលប្រយុទ្ធខាងអាល់-ហ៊ូសៃន៍ﷺ] នឹងចាកចោលជីវិត អល់ឡោះហ៍ﷻនឹងទទួលវិញ្ញាណពួកគេដោយព្រះអង្គﷻផ្ទាល់ ។ បណ្តាទេវតាមេឃជាន់ទីប្រាំពីរ កាន់ផើងធ្វើអំពីជាតិវ៉ែនិងត្បូងមរកតដាក់ "វារិជីវៈ" (ទឹកជីវិត) កាន់គ្រឿងសំលៀកបំពាក់និងពិដោរសួគ៌ ចុះមកឯផែនដីលាងសាកសពពួកគេដោយទឹកនោះ ស្លៀកពាក់ពួកគេដោយគ្រឿងសំលៀកបំពាក់នោះ លាបពួកគេដោយទេព្វិរូដើម្បីនឹងមានពិដោរនោះ ។

បន្ទាប់មក បណ្តាទេវតានឹងតម្រង់ជួរស្វ័ឡាត់ឲ្យសាកសពទាំងនោះ ។ រួចហើយ អល់ឡោះហ៍ﷻនឹងនាំមកនូវប្រជានិករអ៊ុមម៉ាត់ព្រះអង្គﷺដែលពួកឥតសាសនាមិនស្គាល់ ដែលមិនបានចូលរួមក្នុងការបង្ហូរឈាមនោះទេ ទោះជាដោយទង្វើក្តី ដោយសម្តីក្តី ឬដោយបំណងក្តី មកបញ្ចុះសាកសពទាំងនោះ ដាក់សញ្ញាចំណាំផ្នូរព្រះអគ្គប្រមុខរបស់អស់ទុក្ករបុគ្គល (គឺអាល់-ហ៊ូសៃន៍ﷺ) ដោយសញ្ញាមួយនៅក្នុងទឹកដីនោះ ។ សញ្ញានេះជាត្រានៃបក្សត្រឹមត្រូវ ហើយវាជាមូលហេតុនៃជោគជ័យរបស់បណ្តាអ្នក

មានសទ្ធាជ្រះថ្លា ។

រាល់ថ្ងៃ រាល់យប់ ទេវតាគ្រប់ជាន់មេឃ ១០០ ០០០ អង្គ នឹងឆ្វៃលជុំវិញផ្នូរនោះ ប្រសិទ្ធិពរឲ្យផ្នូរនោះ គោរពបូជាអល់ឡោះហ្វ៎ﷻនៅឯផ្នូរនោះ សូមឲ្យអល់ឡោះហ្វ៎ﷻខមាទោសឲ្យអ្នកណាដែលមកស៊ីរ៉ាស់ផ្នូរនោះ កត់ត្រាទុកឈ្មោះឪពុក កុលសម្ព័ន្ធនិងស្រុករបស់អ្នកនោះ ។ ចុងក្រោយ អស់ទេវតាទាំងនោះដាក់សញ្ញានៅលើថ្ងាសអ្នកនោះ ដោយរស្មីព្រះរាជបល្ល័ង្គអល់ឡោះហ្វ៎ﷻ ហើយនឹងចារទុកថា៖ "នេះគឺភ្ញៀវផ្នូរព្រះអគ្គប្រមុខរបស់អស់ទុក្ករបុគ្គល ព្រះរាជបុត្ររបស់ព្រះរាជសាស្ដាﷺប្រសើរបំផុត ។

ថ្ងៃរស់ពីស្លាប់វិញ សញ្ញានោះនឹងចែងចាំងរស្មីនៅមុខពួកគេដល់ថ្នាក់ធ្វើឲ្យអ្នកដទៃស្រវាំងភ្នែក ។ គេនឹងស្គាល់អ្នកស៊ីរ៉ាស់ផ្នូររបស់អាល់-ហ៊្វសៃន៍ صلوات الله عليه والسلام ដោយសារសញ្ញាទាំងនេះ ។ ក្នុងថ្ងៃនោះដែរ មូហាំម៉ាដ្ឋ៍ﷺអើយ ព្រះអង្គﷺនឹងឈរចន្លោះទេវតាមីកាអ៊ីលعليه السلامនិងទូលបង្គំعليه السلام អាុលី صلوات الله عليه والسلام នឹងនៅជាមួយយើង ទេវតាច្រើនរាប់មិនអស់នឹងនៅជាមួយយើងដែរ ។ យើងនឹងស្គាល់ពួកគេដោយសារសញ្ញាភ្លឺនេះឯងនៅលើមុខពួកគេ ដាច់ឡែកពីសត្វលោកឯទៀត លុះអល់ឡោះហ្វ៎ﷻសង្គ្រោះពួកគេឲ្យរួចផុតពីភ័យវិបត្តិនិងគ្រោះកាចនៃថ្ងៃនោះ ។

នេះគឺរង្វាន់មួយចំនួនរបស់អល់ឡោះហ្វ៎ﷻ សម្រាប់បណ្ដាអ្នកដែលមកស៊ីរ៉ាស់ផ្នូរព្រះអង្គﷺ ឬផ្នូររបស់ព្រះអនុជព្រះអង្គﷺ អាុលី صلوات الله عليه والسلام ផ្នូររបស់ព្រះរាជនត្តាទាំងពីររបស់ព្រះអង្គﷺ ដើម្បីអល់ឡោះហ្វ៎ﷻតែមួយ ។ បុគ្គលខ្លះដែលត្រូវរងបណ្ដាសានិងព្រះពិរោធអល់ឡោះហ្វ៎ﷻនោះ នឹងព្យាយាមឥតសំចៃកម្លាំងដើម្បីបំផ្លាញចោល លុបបំបាត់កន្លែងផ្នូរនោះ ។ តែអល់ឡោះហ្វ៎ﷻនឹងមិនបើកឱកាសឲ្យពួកនោះធ្វើដូច្នេះទេ ។"

ព្រះសាស្ដាﷺមានព្រះវចនៈថា៖ "ទំនាយនេះធ្វើឲ្យខ្ញុំព្រួយបារម្ភ ធ្វើឲ្យខ្ញុំយំ ។"

បន្ទាប់ពីនោះ ព្រះនាងស្បៃណាប់سلام الله عليهاមានវចនៈបន្ថែមថា៖ "កាលអាុប់ដ្វាល់-រ៉ោះហ៊្មាន អ៊ីបនូ មុលយ៉ឹម បុគ្គលត្រូវបណ្ដាសា បានប្រហារព្រះបិតាខ្ញុំម្ចាស់ ខ្ញុំម្ចាស់ទៅជួបព្រះអង្គ صلوات الله عليه والسلام សួរព្រះអង្គ صلوات الله عليه والسلام ថាតើរឿង

ដែល អ៊ូម អៃម៉ាន បានតំណាលប្រាប់ខ្ញុំម្ចាស់នោះពិតឬទេ ។ ព្រះបិតាខ្ញុំម្ចាស់មានវចនៈថា៖ "អ៊ូម អៃម៉ាននិយាយពិត ។ បិតាឃើញរឿងដែលនឹងកើតមានឡើង រឿងនោះគឺបុត្រីនិងគ្រួសារបុត្រីនឹងត្រូវគេចាប់ខ្លួនជាអ្នកទោសនៅក្នុងស្រុកនេះ ។ បុត្រីនឹងនៅក្រោមអំណាចគេនិងភ័យរន្ធត់ ខ្លាចមនុស្សបណ្តេញបុត្រី និងគ្រួសារទាំងអស់គ្នាចេញពីផ្ទះសម្បែងដោយបង្ខំ ។ ពេលនោះ ចូរបុត្រីអត់ធ្មត់ ខាំមាត់សង្កត់ចិត្ត ពីព្រោះថ្ងៃនោះ នឹងពុំមានអ្នកភក្តី[ចំពោះអល់ឡោះហ្វា عزّ وجلّ]ទេនៅលើផែនដី ក្រៅពីបុត្រីនិងក្រុមគ្រួសារ បណ្តាអ្នកតាមនិងអ្នកស្រឡាញ់បុត្រី ។ បិតាសូមស្បថក្នុងព្រះនាមព្រះដែលបំបែកគ្រប់ពូជ ដែលបង្កើតជីវិតទាំងឡាយ ។

កាលព្រះសាស្តា صلى الله عليه وآله وسلم អល់ឡោះហ្វា عزّ وجلّ បានប្រាប់យើងរឿងនេះ ព្រះអង្គ صلى الله عليه وآله وسلم មានវចនៈបន្ថែមថា៖ "ក្នុងថ្ងៃតែមួយនោះដែរដែលអាល់-ហ៊ូសែន صلوات الله عليه والسلام នឹងត្រូវគេធ្វើគុតនោះ អ៊ីប្លីសត្រូវបណ្តាសានឹងសប្បាយរីករាយអនេក វានឹងដើរពាសពេញនៅលើផែនដី ជាមួយបនបិសាចរបស់វានិងពួកអ៊ុហ្វ៊ុរិតប្រកាសថា៖ "ហៃបិសាច ថ្ងៃនេះយើងបានសងសឹកទៅលើបណ្តាកូនចៅរបស់អាដាំ عليه السلام យើងបានសម្រេចគោលដៅកម្ចាត់ពួកវា ច្រានពួកវាទៅក្នុងភ្លើងនរក ។ ពេលនេះ ពួកឯងទាំងអស់គ្នាត្រូវព្យាយាមធ្វើឲ្យចិត្តមនុស្សកើតមានការសង្ស័យទៅលើអាល់-ហ៊ូសែន صلوات الله عليه والسلام និងបណ្តាសាវករបស់វា ចូរពួកឯងញុះញង់មនុស្សឲ្យស្អប់ពួកវា បញ្ចុះបញ្ចូលមនុស្សឲ្យប្រឆាំងអ្នកណាដែលស្រឡាញ់ពួកវា ដើម្បីនឹងធ្វើឲ្យមនុស្សទាំងនោះវង្វេង ដើម្បីនឹងធ្វើឲ្យមនុស្សទាំងនោះពុំបានទទួលការជួយសង្គ្រោះដោយសារតែគ្មានសាសនានេះឯង[ក្នុងថ្ងៃរស់ពីស្លាប់វិញ] ។"

ទោះបីវាជាអ្នកនិយាយមុសាធំបំផុតក៏ដោយ អ៊ីប្លីសនិយាយពិតរឿងនេះ ។ ពិតប្រាកដមែន ទង្វើល្អរបស់បុគ្គលណាដែលប្រឆាំងអាស្ហ៊ុលុលបៃត៍ عليهم السلام ទង្វើល្អទាំងនោះត្រូវមោឃៈ [ទោះបីទង្វើល្អទាំងនោះធំប៉ុណ្ណាក៏ដោយ] ចំណែកឯបាប ពុំមែនបាបធំ របស់បុគ្គលណាដែលស្រឡាញ់អាស្ហ៊ុលុល-បៃត៍ عليهم السلام ស្មោះត្រង់ចំពោះអាស្ហ៊ុលុល-បៃត៍ عليهم السلام បាបទាំងនោះពុំធ្វើឲ្យមានផលអាក្រក់ទេ ។"

អាស្រ័យពាក្យពេជន៍ទាំងនេះ ព្រះនាងស្សៃណាប់سلام الله علیها អាចធ្វើឲ្យព្រះភាតុបុត្តឈឺចិត្តរបស់ព្រះនាងនោះបានធូរស្រាលចិត្ត ។ ព្រះនាងسلام الله علیها បានអះអាងបញ្ជាក់ទៀតថា សាកសពទាំងនេះនឹងត្រូវបានបូជាជូនធរណីឯផ្នូរសពទាំងនេះនឹងត្រូវបំពាក់ដោយសញ្ញាអត់ធ្មត់ ក្នុងនាមគោលសីលធម៌និងពលីកម្មដើម្បីសាសនា ។ ផ្នូរអ៊ីម៉ាំអាល់-ហ៊្សសែន៍صلوات الله علیه والسلام ជាពិសេស ជាសម្រែកឥតអវសានដាក់មុខជនកំណាចគ្រប់រូប ហើយនឹងគង់នៅរហូត ទោះបីជនកំណាចទាំងនោះព្យាយាមលុបបំបាត់ចោលក៏ដោយ ។

ប្រវត្តិសាស្ត្របានឆ្លើយបញ្ជាក់ថាព្រឹត្តិការណ៍ទាំងនេះ ជាព្រឹត្តិការណ៍ពិត ។ ស្តេចត្រកូលអ៊ូម៉ៃយ៉ាស់ ស្តេចត្រកូលអាប់បាស៊ីយ៉ាស់ប្រឹងប្រែងលុបបំបាត់ផ្នូរអ៊ីម៉ាំអាល់-ហ៊្សសែន៍صلوات الله علیه والسلام តែការព្យាយាមទាំងអស់នោះត្រូវបរាជ័យ ពីព្រោះផ្នូរនោះពុំត្រឹមតែជាកន្លែងកប់សពដែលត្រូវគេកាត់ប៉ុណ្ណោះទេ តែវាជាការប្រកាសជាឱឡារិកដាក់មុខបុគ្គលគ្រប់រូបដែលកាន់អំណាចផ្តាច់ការ ឬដែលប្រឹងប្រែងគាបសង្កត់គេ ។ វាជាភ័ស្តុតាងបញ្ជាក់អំពីកម្មវាសនារបស់ពួកទុច្ចរិតអន្យត្តិរ្ថិយ ហើយវាជាលទ្ធផលត្រចះត្រចង់ដែលតបស្នងបណ្តាអ្នកដែលស្ថិតនៅលើមាគ៌ាត្រឹមត្រូវ ។ រីឯផែនដីក៏មិនព្រមបិទបាំមោទនភាពរបស់វាដែរ វាមានមោទនភាពណាស់ដែលបានកប់សពទាំងនេះដែលត្រូវគេកាត់នេះ គឺសពដែលទ្រទ្រង់នូវវិញ្ញាណឥតប្រៀបបាននិងឧត្តុង្គឧត្តម គឺវិញ្ញាណដែលការពារគោលសីលធម៌មនុស្សជាតិ ។ ការពិត ផែនដីនេះពុំមានកន្លែងណាមួយថ្លៃថ្នូរ និងល្អប្រពៃជាងកន្លែងដែលកប់ព្រះរាជសពអ៊ីម៉ាំអាល់-ហ៊្សសែន៍صلوات الله علیه والسلام ព្រះបិតាសេរីភាពនោះទេ ។

ក្នុងប្រវត្តិសាស្ត្រសម័យថ្មីនេះដែរ គ្រាប់បែកនិងរត់ក្រោះពុំអាចតទល់នឹងដោមផ្នូរអ៊ីម៉ាំអាល់-ហ៊្សសែន៍صلوات الله علیه والسلام ខ្ពស់ត្រដែតនោះបានទេ ។ ជាហេតុការណ៍ធម្មតា ដែលពួកដាក់បញ្ជាឲ្យដាក់គ្រាប់ផ្ទុះកម្ទេចដោមចោលនោះបានពើបពះកម្មវាសនាដូចពួកដែលបានដាក់បញ្ជា បានប្រមូលគ្នា

ប្រយុទ្ធតទល់នឹងអ៊ីម៉ាំ صلوات الله عليه والسلام ។

មនុស្សជាតិដែរគប្បីមានមោទនាភាពចំពោះបុណ្យខួបរំលឹកអ៊ីម៉ាំ អាល់-ហ៊្វូសែន៍ صلوات الله عليه والسلام ដែលបានធ្វើទុក្ករកម្មដោយបូជាព្រះជន្ម ដើម្បីទទួលបានមកវិញនូវលក្ខណៈមនុស្សជាតិពិត និងដើម្បីអនុវត្តិតាមមុខងារដែលព្រះអ្នកបង្កើតបានជ្រើសរើសឲ្យ ។

## ព្រះនាងស៊ែណាប់ سلام الله عليها ត្រូវចាប់ជាចំណាប់ខ្មាំង

ជាប់ចំណង ត្រូវបង្ខំឲ្យជិះអូដ្ឋសម្គមគ្មានកែប បណ្តាស្ត្រីនិងព្រះរាជកុមារកំព្រាព្រះរាជវង្សព្រះសាស្តា صلى الله عليه وآله وسلم ត្រូវនាំខ្លួនទៅកាន់ស្រុកគូហ្វាស៊ ជាចំណាប់ឈ្លើយ ។ ការធ្វើដំណើរនេះជាបទពិសោធន៍រន្ធត់ មានសម្លេងត្រែអឺងកង មានទង់បក់រវិច ។ យើងសូមលើកយកនូវសាក្សីផ្ទាល់ភ្នែកព្រឹត្តិការណ៍នេះមកអធិប្បាយជូន ។ លោកមុស្លីម អ្នកបូកកំបោរបាយអបានតំណាលថា៖ "កាលខ្ញុំបូកកំបោរបាយអលើទ្វាររាំងអភិបាលក្រុងគូហ្វាស៊ ខ្ញុំបានឮសម្លេងត្រែគ្រប់ទិសទី ។ ខ្ញុំបានសួរបម្រើម្នាក់ក្នុងវាំងនោះថា៖ "ហេតុអ្វីគូហ្វាស៊លាន់ឮម្ល៉េះ ?" បម្រើនោះបានឆ្លើយថា៖ "មេដឹកនាំបះបោរប្រឆាំងយ៉ាស៊ីដ្ឋម្នាក់បានចូលមកស្រុកឥឡូវនេះ ។" ខ្ញុំបានសួរថា៖ "អ្នកបះបោរនោះជាអ្នកណា ?" បម្រើនោះបានឆ្លើយថា៖ "អាល់-ហ៊្វូសែន៍ អ៊ីបនូ អាុលី صلوات الله عليه والسلام ។"

ចម្លើយនេះប្រៀបបាននឹងរន្ទះបាញ់ចំកណ្តាលក្បាលខ្ញុំ ។ ខ្ញុំវាយមុខខ្លួនឯងខ្លាំងពេក បណ្តាលឲ្យខ្ញុំខ្លាចភ្នែកខ្លួនឯង ។ ខ្ញុំប្រញាប់លាងកំបោរបាយអឲ្យជ្រះពីដៃ ហើយចាកចេញពីវាំង ។ ខណៈដែលខ្ញុំឈរជាមួយមនុស្សឯទៀត រង់ចាំមើលក្រុមចំណាប់ឈ្លើយនិងក្បាលកាត់ អូដ្ឋសែសិបក្បាលដឹកស្ត្រីនិងកុមារបានមកដល់ ។

ខ្ញុំបានឃើញអាុលី អ៊ីបនូ អាល់-ហ៊្វូសែន៍ صلوات الله عليه والسلام ជិះអូដ្ឋគ្មានកែប ។ កព្រះអង្គ صلوات الله عليه والسلام ទាំងសងខាងហូរឈាមដោយសារច្រវាក់រឹក ហើយព្រះអង្គ صلوات الله عليه والسلام ជាប់ខ្នោះដៃ ។ ព្រះអង្គ صلوات الله عليه والسلام យំថា៖ "ប្រជារាស្ត្រអាក្រក់អើយ សូមឲ្យពួកអ្នកឯងត្រូវបណ្តាសា ! ពួកអ្នកឯងមិនសន្តោសយើងដោយយោគយល់ព្រះ

អយ្យកោយើងបន្តិចទេ ។ តើអស់អ្នកឯងនឹងមានអ្វីនិយាយក្នុងថ្ងៃរស់ពីស្លាប់វិញ ពេលអល់ឡោះហ្ (عزّ وجلّ) នឹងឲ្យយើងជួបជុំព្រះសាស្តា (صلى الله عليه وآله وسلم) ? យើងមិនបានដឹកនាំពួកអ្នកឯងទៅរកសាសនាទេឬ ទើបពួកអ្នកឯងចាប់ខ្លួនយើងដាក់លើខ្នងអូដ្ឋគ្មានកែប ។"[231]

ពេលបានឃើញស្ថានភាពរន្ធត់នេះ បណ្តាស្ត្រីស្រុកគូហ្វាស់ថ្ងូរយំ ។ ស្ត្រីម្នាក់បានទៅក្បែរស្ត្រីចំណាប់ម្នាក់ សួរថា៖ "តើអ្នកត្រកូលអ្វី ?" ស្ត្រីនោះបានតបថា៖ "ខ្ញុំត្រកូលអាស់ហ្លុល-បៃត៍ (عليهم السلام) ។"

ស្ត្រីគូហ្វាស់ជាមួយស្ត្រីឯទៀតដែលនៅក្បែរគាត់ស្រែកភ្លាត់មាត់ ពេលបានឮចម្លើយភ្ញាក់ផ្អើលនោះ ហើយប្រញាប់ត្រឡប់ទៅផ្ទះវិញដើម្បីប្រមូលយកសំពត់ដែលខ្លួនមាននោះ មកបោះឲ្យបណ្តាស្ត្រីចំណាប់គេដើម្បីដណ្តប់ខ្លួន កុំឲ្យមនុស្សមើល ស្ត្រីម្នាក់ទៀតបានយកបាយនិងផ្លែលម៉ើខ្លះមកបោះឲ្យក្មេងៗចំណាប់គេដែលឃ្លានខ្លាំង ។ ព្រះនាងអ៊្វមគុលស៊្វមបានស្រែកឲ្យថា៖ "នេះគឺអ្វីដែលហារ៉ាំ - ត្រូវហាម - សម្រាប់យើង អាស់ហ្លុល-បៃត៍ (عليهم السلام) គេមិនឲ្យយើងទទួលយកអំណោយទានទេ ។" ឮសម្តីនេះ ក្មេងៗគ្រវាត់ចំណីចោល ខ្ជាក់អស់ពីមាត់ ។

## សុន្ទរកថាទីមួយរបស់ព្រះនាងស្វៃណាប់ (سلام الله عليها)

ពេលឃើញមនុស្សកុះករពេញផ្លូវដើរស្រុកគូហ្វាស់ ចោមរោមក្រុមអ្នកដំណើរ ព្រះនាងស្វៃណាប់ (سلام الله عليها) បានសម្រេចចិត្តថ្លែងសុន្ទរកថាមួយក្នុងគោលបំណងប្រមូលមតិមហាជន ដោយលើកយកវិបត្តិធំដែលបនអ៊្វម៉ៃយ៉ាស់បានបង្កឡើងនៅក្នុងអ៊ុមម៉ាត់អ៊ីស្លាមដោយសម្លាប់អ៊ីម៉ាំ អាល់-ហ៊្សៃន៍ (صلوات الله عليه والسلام) អ្នកដឹកនាំបច្ចុប្បន្ន ដោយទម្លាក់ទោសនេះទៅលើអ្នកស្រុកគូហ្វាស់ ព្រោះពួកអ្នកស្រុកនេះបានក្បត់ពាក្យសម្បថដែលខ្លួនបានសន្យាថានឹងគាំទ្រអ៊ីម៉ាំ (صلوات الله عليه والسلام) និងការពារព្រះអង្គ (صلوات الله عليه والسلام) ។ ផ្ទុយទៅវិញ ពួកគេបែរជាកាន់ទុក្ខឲ្យអ៊ីម៉ាំ (صلوات الله عليه والسلام) យំសោកអាណិតព្រះរាជវង្សនិងក្មេងៗជាប់ចំណាប់

[231] សូមមើលសៀវភៅរបស់លោក មូហាំម៉ាដ់ បាគៀរ អាល់-ម៉ាច្ល៍លីស៊ី (محمد باقر المجلسي) *ប៊ីហារ អាល់-អាន់វ៉ារ (بحار الأنوار)* ក្បាលទី ៤៥ ទំព័រ ១១៤ ។

គេ ហាក់ដូចជាពុំមែនពួកគេទេដែលបានបង្កឲ្យការកាប់សម្លាប់នោះកើតមានឡើងបាន ។

ព្រះនាងស្ងៀមស្ងាត់ណាប់عليهم السلامសូមឲ្យទាំងអស់គ្នាស្ងាត់ ។ បន្ទាប់មក ដោយឥរិយាបថស្ងប់ ស្រគត់ស្រគំ ក្លាហាន ព្រះនាងបានថ្លែងថា៖

الحَمْدُ للهِ، وَالصَّلاةُ عَلَىٰ أَبِي مُحَمَّدٍ، وَآلِهِ الطَّيِّبِينَ الأَخْيَارِ. أَمَّا بَعْدُ يَا أَهْلَ الكُوفَةِ، يَا أَهْلَ الخَتْلِ وَالغَدْرِ، أَ تَبْكُونَ؟ فَلا رَقَأَتِ الدَّمْعَةُ وَلا هَدَأَتِ الرَّنَّةُ. إِنَّمَا مَثَلُكُمْ كَمَثَلِ الَّتِي نَقَضَتْ غَزْلَهَا مِنْ بَعْدِ قُوَّةٍ أَنْكَاثاً، تَتَّخِذُونَ أَيْمَانَكُمْ دَخَلاً بَيْنَكُمْ. أَلا وَهَلْ فِيكُمْ إلاّ الصَّلَفُ وَالنَّطَفُ، وَالصَّدْرُ الشَّنِفُ، وَمَلَقُ الإِمَاءِ وَغَمْزُ الأَعْدَاءِ؟ أَوْ كَمَرْعىً عَلَىٰ دِمْنَةٍ، أَوْ كَفِضَّةٍ عَلَىٰ مَلْحُودَةٍ. أَلا سَاءَ مَا قَدَّمَتْ لَكُمْ أَنْفُسُكُمْ أَنْ سَخِطَ اللهُ عَلَيْكُمْ وَفِي العَذَابِ أَنْتُمْ خَالِدُونَ.

*"សូមថ្វាយថោមនាការចំពោះអល់ឡោះហ៍عز وجل ។ សូមពរជ័យកើតមានដល់មូហាំម៉ាដ់صلى الله عليه وآله وسلم ព្រះបិតាខ្ញុំ និងដល់ព្រះរាជបុត្រារាជនត្តាល្អបរិសុទ្ធទាំងឡាយរបស់ព្រះអង្គعليهم السلام ។ ពេលនេះ ប្រជារាស្ត្រគូហ្វាស់ ប្រជារាស្ត្របោកប្រាស់ ប្រជារាស្ត្រក្បត់អើយ ! អស់លោកយំឬ ? សូមឲ្យទឹកភ្នែកអស់លោកហូរកុំឈប់ សូមឲ្យមហាន្តរាយនេះល្បីលាន់ឮឥតអវសាន ។ អស់លោកប្រៀបបាននឹងស្រីស្រាយអំបោះម្នាក់ ហើយបានកាត់ផ្តាច់អំបោះនោះខ្ទេចខ្ទីបន្ទាប់ពីបានវេញវាយ៉ាងតឹង ។ អស់លោកយកពាក្យសម្បថជាមធ្យោបាយបោកប្រាស់គ្នា ។ តើមានអស់លោកណាម្នាក់ទេដែលអួតអាងអំពីអ្វីដែលខ្លួនពុំមាននោះ ដែលនិយមអបាយមុខ ហៃអួតដោយក្រអឺត ជាមនុស្សគុំកួនក្រៅតម្រា ដាក់ខ្លួនដូចស្រីខ្ញុំបម្រើគេ ទន់ជ្រាយនៅពីមុខសត្រូវ ដូចសំណល់កណ្តាលវាល ឬដូចបំណែកក្រណាត់កខ្វក់នៅលើផ្នូរ ? អំពើដែលខ្លួនអស់លោកបានប្រព្រឹត្តនោះអាក្រក់មែន ។ អស់លោកបានធ្វើឲ្យអល់ឡោះហ៍عز وجلទ្រង់ព្រះក្រោធពិរោធ អស់លោករងនឹងទណ្ឌកម្មឥតអវសាន ។"*

أَ تَبْكُوْنَ وَ تَنْتَحِبُوْنَ؟ إِيْ وَ اللهِ فَابْكُوْا كَثِيْراً وَ اضْحَكُوْا قَلِيْلًا فَلَقَدْ ذَهَبْتُمْ بِعَارِهَا

وَ شَنَآنِهَا (وَ شَنَارِهَا) وَ لَنْ تَرْحَضُوْهَا بِغَسْلٍ بَعْدَهَا أَبَداً وَ أَنَّى تَرْحَضُونَ قَتْلَ سَلِيلِ خَاتَمِ الْأَنْبِيَاءِ وَ سَيِّدِ شَبَابِ أَهْلِ الْجَنَّة وَ مَلَاذِ خِيَرَتِكُمْ وَ مَفْزَعِ نَازِلَتِكُمْ وَ مَنَارِ حُجَّتِكُمْ وَ مَدَرَةِ سُنَّتِكُمْ؟ أَلَا سَاءَ مَا تَزِرُونَ وَ بُعْداً لَكُمْ وَ سُحْقاً فَلَقَدْ خَابَ السَّعْيُ وَ تَبَّتِ الْأَيْدِي وَ خَسِرَتِ الصَّفْقَةُ وَ بُؤْتُمْ بِغَضَبٍ مِنَ اللَّهِ وَ ضُرِبَتْ عَلَيْكُمُ الذِّلَّةُ وَ الْمَسْكَنَةُ.

*"អស់លោកយំខ្សឹកខ្សួលមែនឬ ? សូមស្បថចំពោះអល់ឡោះហ៍ﷻ អស់លោកគួរតែយំច្រើន សើចតិច ព្រោះអស់លោកពុំបានសាងអ្វីទេ ក្រៅពីសេចក្តីអាម៉ាស់និងទុយ៌ស អស់លោកមិនអាចលុបលាងវាបានជាដាច់ខាត ។ ហេតុម្តេចអស់លោកហ៊ានធ្វើអំពើនេះ ? ព្រះរាជបុត្ររាជនត្តារបស់ខ្នាន់ព្រះរាជសារចុងក្រោយ បុគ្គលដែលជាខ្លឹមពិតៗនៃព្រះរាជសារ ព្រះរាជអគ្គមហាប្រមុខរបស់យុវជនឋានសួគ៌ បុគ្គលដែលជាព្រះជម្រករបស់សច្ចបុគ្គលក្នុងចំណោមអស់លោក បុគ្គលដែលសង្គ្រោះអស់លោកពីមហន្តរាយ បុគ្គលដែលជាគោមបង្ហាញផ្លូវអស់លោក ព្រះអនុរក្សនៃប្រពៃណីរបស់អស់លោកត្រូវគេសម្លាប់ ។ បាបដែលអស់លោកលីវែកនោះអាក្រក់ណាស់ ! សូមឲ្យគេរលាស់អស់លោកចោល សូមឲ្យអស់លោកបរាជ័យ ។ ការព្យាយាមទៅជាមោឃៈ វិនាសហិនហោចដោះដៃមិនរួច កិច្ចការត្រូវវិនាសសូន្យបង់ អស់លោកមិនបានអ្វីមកវិញទេ ក្រៅពីព្រះពិរោធអល់ឡោះហ៍ﷻនិងព្រះសាស្តាﷺព្រះអង្គﷻ ។ អស់លោកប្រាកដជានៅក្នុងទាសភាពនិងភាពថោកទាប ។"*

وَيْلَكُمْ يَا أَهْلَ الْكُوفَةِ! اَ تَدْرُوْنَ أَيَّ كَبِدٍ لِرَسُولِ اللَّهِ فَرَيْتُمْ؟ وَ أَيَّ كَرِيمَةٍ لَهُ أَبْرَزْتُمْ؟ وَ أَيَّ دَمٍ لَهُ سَفَكْتُمْ؟ وَ أَيَّ حُرْمَةٍ لَهُ انْتَهَكْتُمْ؟ لَقَدْ جِئْتُمْ شَيْئًا اِدًّا تَكَادُ السَّمٰوَاتُ يَتَفَطَّرْنَ مِنْهُ وَ تَنْشَقُّ الْاَرْضُ وَ تَخِرُّ الْجِبَالُ هَدًّا. بِهَا صَلْعَاءَ عَنْقَاءَ سَوْدَاءَ فَقْمَاءَ (خَرْقَاءَ شَوْهَاءَ كَطِلَاعِ الْأَرْضِ وَ مِلَاءِ السَّمَاءِ). أَ فَعَجِبْتُمْ أَنْ قَطَرَتِ السَّمَاءُ دَماً؟ وَ لَعَذَابُ الْآخِرَةِ أَخْزَى وَ أَنْتُمْ لَا تُنْصَرُونَ. فَلَا يَسْتَخِفَّنَّكُمُ الْمَهْلُ فَإِنَّهُ لَا يَحْفِزُهُ

الْبِدَارُ وَ لَا يَخَافُ فَوْتُ الثَّأْرِ وَ إِنَّ رَبَّكُمْ لَبِالْمِرْصَادِ.

*"ប្រជារាស្ត្រគូហ្វាស់អឺយ សូមអបមង្គលពើបពះលើអស់លោក! តើអស់លោកដឹងទេថាអស់លោកបានធ្វើឲ្យអ្នកណាខ្លោចផ្សា អស់លោកមានតេជដៃអ្វីខ្លះ ឈាមណាខ្លះដែលអស់លោកបានបង្ហូរ សន្តភាពណាដែលអស់បានរំលោភ? អស់លោកបានប្រព្រឹត្តអំពើអាក្រក់ក្រៃលែង អំពើដែលស្ទើរតែធ្វើឲ្យមេឃនិងផែនដីរលំបាក់បែក ស្ទើរតែធ្វើឲ្យភ្នំរលាយ។ អស់លោកបានប្រព្រឹត្តអំពើចម្លែកក្រៃលែង អំពើដែលធ្វើឲ្យខូចក្រៃលែង អំពើដែលធ្វើឲ្យស្រអាប់ក្រៃលែង អំពើអប្រិយបំផុត ដែលអាចបំពេញផែនដីនិងមេឃបាន។ អស់លោកឆ្ងល់ទេ ថាហេតុអ្វីមេឃធ្លាក់ភ្លៀងឈាម? ពិតណាស់ ទណ្ឌកម្មលោកមុខជាទណ្ឌកម្មធំបំផុត អស់លោកនឹងពុំមានជំនួយទេ។ ចូរអស់លោកកុំសប្បាយចិត្តនឹងចន្លោះពេលដែលគេទុកឲ្យនោះឡើយ ពីព្រោះបង្ខំឲ្យពេលវេលាឲ្យឆាប់មកដល់ពុំអាចធ្វើឲ្យវាហួសទៅបានឡើយ ហើយវាមិនខ្លាចបាត់បង់ឱកាសសងសឹកឡើយ។ ព្រះម្ចាស់عزّ وجلّរបស់អស់លោកឆ្មក់ធ្វើបែបនេះ។*

ព្រោះតែដឹងថាស្ថានភាពទីនោះ ពុំអាចអត់ទ្រាំឥទ្ធិពលពាក្យពេជន៍ព្រះបិតុច្ឆាព្រះអង្គصلوات الله عليه والسلامបាន ទើបអ៊ីម៉ាំស្ញែន៍ អាល់-អាប៊ីឌីនصلوات الله عليه والسلامផ្អាកសុន្ទរកថាព្រះនាងថា៖ "ព្រះបិតុច្ឆាអឺយ ឈប់ត្រឹមនេះបានហើយ។ ដោយសារអល់ឡោះហ្ទ៍عزّ وجلّ ព្រះបិតុច្ឆាسلام الله عليهاជាស្ត្រីមានប្រាជ្ញាចេះដឹងដោយពុំមានអ្នកណាបង្ហាត់ ព្រះអង្គسلام الله عليهاអាចយល់ដឹងបានដោយពុំមានអ្នកណាមួយបង្ខិតបង្ខំ។"

## ឥទ្ធិពលពាក្យពេជន៍

ពាក្យពេជន៍ប្រកបដោយវោហារកោសល្យរបស់ព្រះនាង ស្ញៃណាប់سلام الله عليها ដែលប្រៀបបាននឹងពាក្យពេជន៍អ៊ីម៉ាំអាលីصلوات الله عليه والسلامនោះ បានស្តីបន្ទោសអ្នកស្រុកគូហ្វាស់ដោយប្រសិទ្ធិភាព បានបង្ហាញឲ្យឃើញថាពួកគេមានជំនឿមិនត្រឹមត្រូវចំពោះអ៊ីស្លាម បានបកអាក្រាតទឹកភ្នែកបញ្ឆោតរបស់ពួកគេ បានបង្ហាញខ្លួនពួកគេថាជាជនឧក្រិដ្ឋអប្រិយបំផុត ព្រោះពួកគេបានរួមដៃ

ក្នុងការសម្លាប់អ៊ីម៉ាំអាល់-ហ៊្សសែន៍صلوات الله عليه والسلام ព្រះរាជកុលដ្ឋានព្រះអង្គصلوات الله عليه والسلامនិង បណ្ដាសាវកព្រះអង្គصلوات الله عليه والسلام ។

ព្រះនាងស្សៃណាប់سلام الله عليهاបានវាយទៅលើពួកអ្នកស្រុកគូហ្វាស់ បានចង្អុលសំដៅភាពថោកទាប និងសំដៅទៅលើចិត្តគម្រក់របស់ពួកគេដោយសូរសព្ទយុត្តិធម៌និងសច្ចធម៌ ដោយសម្លេងក្លាហាននិងសម្លេងត្រឹមត្រូវ ។ អំពើក្លែងបន្លំនិងអំពើអសុទ្ធរបស់ពួកគេ មិនអាចឆបោកព្រះនាងបានឡើយ ព្រោះព្រះនាងបានបន្ទោសពួកគេជាជនមានទោស បានចាត់ទុកពួកគេជាជនមានចរិតកំណាចបំផុត ។ ម្យ៉ាងទៀត ព្រះនាងسلام الله عليهاបានអធិប្បាយអំពីការយំយែករបស់ពួកគេនោះថា ពួកគេគប្បីយំសោកស្ដាយបទឧក្រិដ្ឋធំវិញដោយធ្វើឲ្យអ៊ីម៉ាំصلوات الله عليه والسلامខូចចិត្ត និងដោយចោលព្រះអង្គصلوات الله عليه والسلامនោះ ។

ម្យ៉ាងទៀត ពាក្យពេជន៍នេះធ្វើឲ្យពួកគេស្ងើចនិងស្រឡាំងកាំង ។ ពួកគេយកដៃខ្ទប់មាត់ មិនដឹងនឹងធ្វើអ្វី ។ ឧទាហរណ៍ បុរសចំណាស់ម្នាក់បានដើរចូលមករកព្រះនាងسلام الله عليهاដោយទឹកភ្នែក ទូលថា៖ "សូមឲ្យឪពុកម្ដាយទូលបង្គំបានធ្វើពលីកម្មដើម្បីព្រះអង្គسلام الله عليها ។ អស់ទាំងបុរសព្រះរាជវង្សព្រះអង្គسلام الله عليهاជាបុរសប្រសើរបំផុត ។ អស់ទាំងយុវជនព្រះរាជវង្សព្រះអង្គسلام الله عليها ជាយុវជនប្រសើរបំផុត ។ អស់ទាំងស្ត្រីព្រះរាជវង្សព្រះអង្គسلام الله عليهاជាស្ត្រីប្រសើរបំផុត ។ អស់ទាំងព្រះរាជបុត្ររាជនត្តាព្រះរាជវង្សព្រះអង្គسلام الله عليهاមិនរលត់សាបសូន្យជាដាច់ខាត ឬមិនអន់ខ្សោយជាដាច់ខាត ។"[232]

បន្ទាប់មក អ្នកអង្គម្ចាស់ស្ត្រី ហ្វាទីម៉ាស់ ព្រះរាជបុត្រីរបស់អ៊ីម៉ាំអាល់-ហ៊្សសែន៍صلوات الله عليه والسلامបានថ្លែងសុន្ទរកថាមួយ ស្រដៀងសុន្ទរកថាព្រះបិតុច្ឆាព្រះនាងដែរ ។ ព្រោះតែពាក្យពេជន៍ព្រះនាងធ្ងន់ហើយផ្ដោតទៅរកពួកគេ បានជាពួកអ្នកស្រុកគូហ្វាស់អង្វរសូមឲ្យព្រះនាងឈប់ ។ ព្រះនាងក៏បានឈប់ តែពួកអ្នកស្រុកគូហ្វាស់មិនអាចឈប់ថ្ងូរយំបានទេ ។

បន្ទាប់មក អ្នកអង្គម្ចាស់ស្ត្រី អ៊ុម គុលស៊្សូមបានថ្លែងពាក្យពេជន៍ស្រដៀងគ្នាដែរដែលធ្វើឲ្យរំភើបចិត្តក្រៃលែង បណ្ដាលឲ្យបណ្ដាស្ត្រីវាយមុខខ្លួន

---

[232] សូមមើលសៀវភៅ *វ៉ាហ្វីយ៉ាត់ អាល់-អាអ៊ីមម៉ាស់ (وفيات الأئمة)* ទំព័រ ៤៥៣ ។

ឯង បណ្ដាបុរសយំឥតឈប់ ។
បន្ទាប់មកទៀត អ៊ីម៉ាំស្សែន៍ អាល់-អ្ពាប៊ីឌីន صلوات الله عليه والسلام មានវចនៈ ។ ព្រះអង្គ صلوات الله عليه والسلام បានបង្ហាញភ័ស្ដុតាងបញ្ជាក់ថាពួកគេពុំមែនមុស្លីមពិតទេ ថាពួកគេបានចូលរួមក្នុងបទឧក្រិដ្ឋសម្លាប់អ៊ីម៉ាំ صلوات الله عليه والسلام ។ ដូច្នេះពួកគេនិយាយប្រាប់គ្នាថា៖ "យើងពិតជាវិនាសជាមិនខាន ។" បន្ទាប់មក ពួកគេសូមឲ្យព្រះអង្គ صلوات الله عليه والسلام ឈប់ ព្រះអង្គ صلوات الله عليه والسلام ក៏បានឈប់និយាយតទៅទៀត ព្រោះពួកគេបានយំស្រែកខ្លាំងឡើង ។

## ប្រឈមមុខអភិបាលក្រុង

អ៊ូបៃឌុលឡោះហ្វ៍ អ៊ីបនូ ស៊ីយ៉ាដ្ឋ៍ កូនរបស់ម៉ារយ៉ាណាស្ញ៉ូនារីអាស្រូវ អង្គុយលើបល្ល័ង្កនៅក្នុងវាំងអភិបាលក្រុង ពេលគេបាននាំខ្លួននារីនិងកុមារចំណាប់ព្រះរាជវង្សព្រះសាស្ដា صلى الله عليه وآله وسلم មកបង្ហាញ ។ ព្រះអង្គទាំងអស់រងការអាប់ឱនក្នុងសភាពជាចំណាប់ នៅក្រោមផ្លែដាវរបស់បនឥតសទ្ធា ដែលនៅទីនេះដើម្បីសរសើរអ៊ូបៃឌុលឡោះហ្វ៍ ដែលបានទទួលជ័យជំនះ ដើម្បីថ្លាថ្លែងប្រាប់អ៊ូបៃឌុលឡោះហ្វ៍ នូវបទឧក្រិដ្ឋដែលព្រះអង្គទាំអស់បានប្រព្រឹត្តនៅឯការបាឡាអ៍ ខណៈដែលអ៊ូបៃឌុលឡោះហ្វ៍ស្ដាប់យ៉ាងក្រអឺតក្រទម យ៉ាងសប្បាយចិត្ត ។ កាន់ដំបងក្នុងដៃ អ៊ូបៃឌុលឡោះហ្វ៍វាយព្រះសិរអ៊ីម៉ាំអាល់-ហ៊្វូសៃន៍ صلوات الله عليه والسلام មួយទំហឹង ដោយនិយាយចំអកឲ្យថា៖ "ខ្ញុំមិនដែលឃើញមុខដូចនេះឡើយ ។"
មុននិយាយបួរបាច់សម្ដីព្យាបាទចប់ អាណាស់ អ៊ីបនូ ម៉ាលិក សាវកព្រះសាស្ដា صلى الله عليه وآله وسلم បានប្រាប់គាត់ថា៖ "មែនហើយ ព្រះអង្គ صلوات الله عليه والسلام ដូចព្រះសាស្ដា صلى الله عليه وآله وسلم ។" សម្ដីនេះធ្វើឲ្យអ៊ូបៃឌុលឡោះហ្វ៍ចុកមាត់ មិនមានពាក្យអ្វីឆ្លើយតបវិញទេ ។
បន្ទាប់ពីបានរម្ងាប់អារម្មណ៍អប្រិយ ដោយជេរប្រទេចព្រះរាជវង្សព្រះសាស្ដា صلى الله عليه وآله وسلم អ៊ូបៃឌុលឡោះហ្វ៍បានបែរទៅរកជនចំណាប់ ។ មានស្ត្រីម្នាក់ព្យាយាមលាក់ខ្លួននៅឯជ្រុងមួយនៃសភានោះ ។ ភាពថ្លៃថ្នូរនិងវិរោចនភាពលេចច្បាស់នៅលើទ្រង់ទ្រាយស្ត្រីរូបនោះ ទោះបីគាត់ស្លៀក

ពាក់ជាសាមញ្ញក៏ដោយ ។ លុះប្រទះភ្នែកនឹងស្ត្រីរូបនោះភ្លាម អ៊ូបៃឌុលឡោះហ្ស៍សួរភ្លាមថាៈ "តើស្ត្រីម្នាក់នោះជាអ្នកណា ដែលនៅដាច់ពីគេក្នុងសភានេះ ?"

ស្ត្រីរូបនោះមិនឆ្លើយទេព្រោះគាត់ខ្ពើមបុគ្គលនេះ ។ បុគ្គនេះសួរម្តងទៀត ទាល់ស្ត្រីម្នាក់ឆ្លើយថាៈ "នេះគឺព្រះនាងស៊ែណាប់ﷺ ព្រះរាជបុត្រីរបស់ព្រះនាងហ្វាទី៉ម៉ាស់ﷺ ព្រះរាជបុត្រីរបស់ព្រះសាស្តាﷺអល់ឡោះហ្ស៍ ﷻ ។" បុគ្គលនេះខិតខំចំអកលើគំនរទុក្ខព្រះនាងﷺថាៈ "សូមអរគុណអល់ឡោះហ្ស៍ﷻដែលបានបើកមុខ បានសម្លាប់និងបានប្រឆាំងបដិវត្តន៍របស់អ្នកឯង ។"

ដូចព្រះបិតានិងព្រះរៀម បុគ្គលក្លាហានទាំងពីររបស់ព្រះនាងដែរ ព្រះនាងស៊ែណាប់ﷺបានតបបកវិញថាៈ

اَلْحَمْدُ لِلّٰهِ الَّذِي أَكْرَمَنَا بِنَبِيِّهِ، وَ طَهَّرَنَا مِنَ الرِّجْسِ تَطْهِيرًا. إِنَّمَا يَفْتَضِحُ الْفَاسِقُ وَ يُكَذِّبُ الْفَاجِرُ، وَ هُوَ غَيْرُنَا، وَ هُوَ غَيْرُنَا يَا بْنَ مَرْجَانَة...

*"សូមអរព្រះគុណអល់ឡោះហ្ស៍ﷻ ដែលបានលើកតម្កើងអស់ទូលព្រះបង្គំជាខ្ញុំដោយសារព្រះសាស្តាﷺព្រះអង្គﷻ ដែលបានជម្រះបន្សុទ្ធអស់ទូលព្រះបង្គំជាខ្ញុំឲ្យជ្រះស្អាតពីកខ្វក់ ។ មានតែបុគ្គលអាស (គឺបុគ្គលឥតអៀនខ្មាស) ទេដែលត្រូវបើកមុខ មានតែបុគ្គលប្រព្រឹត្តខុសគន្លងធម៌ទេដែលត្រូវបើកឲ្យគេឃើញថាខុស ។ យើងពុំមែនជនទាំងពីរប្រភេទនេះទេ ។ ការពិត យើងពុំនៅក្នុងចំណោមបុគ្គលទាំងពីរនេះទេ កូនរបស់ម៉ារយ៉ាណាស់អើយ..."*

អ៊ូបៃឌុលឡោះហ្ស៍ពុំមានអ្វីនិយាយទេ ពេលបានទទួលបកមកវិញនូវសម្តីធ្វើឲ្យឈឺចាប់ទាំងនេះ ។ គាត់ក៏បាននិយាយបញ្ឆឹដើម្បីបិទបាំងចំណុចខ្សោយនិងការខ្វះសមត្ថភាពឆ្លើយតបព្រះនាងﷺវិញ ដោយសួរព្រះនាងﷺថាៈ "តើនាងឯងយល់ឃើញយ៉ាងណាដែលអល់ឡោះហ្ស៍ﷻប្រព្រឹត្តទៅលើបងនាងឯងនោះ ?"

ដោយសេចក្តីក្លាហាន ដោយស្មារតីរឹងមាំ ព្រះនាងស៊ែណាប់ﷺបានឆ្លើយតបវិញដោយជ័យវាចាថាៈ

مَا رَأَيْتُ إِلَّا جَمِيْلًا- هٰؤُلَاءِ قَوْمٌ كَتَبَ اللهُ عَلَيْهِمُ الْقَتْلَ فَبَرَزُوْا إِلٰى مَضَاجِعِهِمْ- وَ سَيَجْمَعُ اللهُ بَيْنَكَ وَ بَيْنَهُمْ فَتُحَاجُّ وَ تُخَاصَمُ- فَانْظُرْ لِمَنِ الْفَلَجُ يَوْمَئِذٍ. ثَكَلَتْكَ أُمُّكَ يَا ابْنَ مَرْجَانَةَ.

*"រឿងនេះគ្រាន់តែជារឿងដែលល្អប្រសើរទេ ។ បុគ្គលទាំងនោះជាបុគ្គលដែលអល់ឡោះហ៍ﷻទ្រង់ញាណច្បាស់ថាជាបុគ្គលដែលត្រូវស្លាប់ ។ ទោះជាដូច្នេះក៏ដោយ ក៏ពួកគេមកកាន់កន្លែងដែលពួកគេនឹងត្រូវសម្លាប់ដែរ ។ អល់ឡោះហ៍ﷻនឹងប្រជុំអ្នកឯងជាមួយពួកគេដើម្បីជម្រះក្តី និងដាក់ទណ្ឌកម្ម ។ ចូរគិតមើលចុះ ថាអ្នកណានឹងឈ្នះក្នុងថ្ងៃនោះ ។ អបមង្គលលើអ្នកឯង កូនរបស់ម៉ារយ៉ាណាស្ញ៉អើយ ។"*

ពាក្យស្តីបន្ទោស និងសម្តីចោលការស្អប់ខ្ពើមនេះបានធ្វើអភិបាលក្រុងខុសច្បាប់រូបនេះទប់កំហឹងមិនបាន ដល់ថ្នាក់ក្រោកពីកន្លែងអង្គុយទៅវាយព្រះនាងស៊ែណាប់ﷺ តែអុំរ្វ អ៊ីបនូ ហ៊្វរ៉យ៉ស្ឍ៍បានឃាត់ទាន់ កុំឲ្យប្រព្រឹត្តទង្វើនេះ ដោយនិយាយថា៖ "នាងគ្រាន់តែជានារីម្នាក់ទេ សម្តីនារីមិនសំខាន់ទេ ។"

ទោះជាយ៉ាងណាក៏ដោយ អ៊ូបៃឌុលឡោះហ្ហ៍ត្រឡប់ទៅនិយាយចំអកលើគំនរទុក្ខអាស្ញ៉លុល-បៃត៍عليهم السلامវិញ ដោយនិយាយដាក់ព្រះនាងស៊ែណាប់ﷺថា៖ "យ៉ាងហោចណាស់ អល់ឡោះហ្ហ៍បានព្យាបាលចិត្តយើង បានដាក់ទោសយើងឲ្យទៅជាម្ចាស់កំណាចរបស់នាងឯង និងពួកប្រឆាំងបះបោរត្រកូលនាងឯង ។"

សម្តីនេះធ្វើឲ្យព្រះនាងស៊ែណាប់ﷺសោកសៅនិងព្រួយបារម្ភ ពេលព្រះនាងនឹកឃើញមុខអ្នកថែរក្សាព្រះនាងឡើងវិញ ។ ហេតុដូច្នេះ ព្រះនាងប្រាប់អ៊ូបៃឌុលឡោះហ្ហ៍ថា៖

لَعَمْرِيْ لَقَدْ قَتَلْتَ كَهْلِيْ وَ قَطَعْتَ فَرْعِيْ وَ اجْتَثَثْتَ أَصْلِيْ فَإِنْ كَانَ هٰذَا شِفَاؤُكَ فَقَدِ اشْتَفَيْتَ

*"ខ្ញុំសូមស្បថលើជីវិតខ្ញុំ អ្នកឯងបានសម្លាប់អាណាព្យាបាលខ្ញុំ អ្នកឯងបានផ្តាច់មែកសាខាខ្ញុំ អ្នកឯងបានបំផ្លាញឫសគល់ខ្ញុំ ។ បើទង្វើនេះធ្វើឲ្យចិត្ត*

*អ្នកឯងជាសះស្បើយ អ្នកឯងបានជាសះស្បើយហើយ ។"*
ព្រោះតែក្រោធទប់មិនបាន អ៊្ូបៃឌុលឡោះហ្ស៍ថា៖ "នាងនេះពូកែតែងពាក្យមែន ។ ឪពុកនាងនេះពូកែតែងពាក្យហើយជាកវីផង ខ្ញុំសូមស្បថ ។"
ព្រះនាងស្ហ៊ៃណាប់បានតបវិញថា៖ "ខ្ញុំមិនមានពេលទំនេរសម្រាប់តែងពាក្យទេ ។ តែងពាក្យមិនមានប្រយោជន៍សម្រាប់នារីទេ ។"
ព្រោះតែគ្មានអ្វីនិយាយ ទើបអ៊្ូបៃឌុលឡោះហ្ស៍បែរទៅរកអ៊ីម៉ាំស្ហ៊ៃន៍ អាល់-អា្ុប៊ីឌ្ហីនصلوات الله عليه والسلام សួរថា៖ "ឯងជាអ្នកណា ?"
អ៊ីម៉ាំصلوات الله عليه والسلامបានតបថា៖ "អា្ុលី បុត្ររបស់អាល់-ហ៊្ូសៃន៍صلوات الله عليه والسلام ។" បុគ្គលឧក្រិដ្ឋថោកទាបបានស្រែកថា៖ "អល់ឡោះហ្ស៍عز وجلបានសម្លាប់អា្ុលី អ៊ីបនូអាល់-ហ៊្ូសៃន៍صلوات الله عليه والسلامហើយ ។" អ៊ីម៉ាំصلوات الله عليه والسلامបានតបវិញដោយទប់ស្មារតីថា៖ "ខ្ញុំមានបងម្នាក់ឈ្មោះអា្ុលីដែរ ។ អ្នកឯងបានសម្លាប់ព្រះអង្គ ។ ថ្ងៃរស់ពីស្លាប់វិញអ្នកឯងនឹងត្រូវសួរចម្លើយអំពីរឿងនេះ ។" អ៊្ូបៃឌុលឡោះហ្ស៍បានគំហកពេញកំហឹងថា៖ "ទេ អល់ឡោះហ្ស៍ទេជាអ្នកសម្លាប់វានោះ ។" អ៊ីម៉ាំស្ហ៊ៃន៍ អាល់-អា្ុប៊ីឌ្ហីនصلوات الله عليه والسلامបានតបវិញដោយព្រះបន្ទូលអល់ឡោះហ្ស៍عز وجل ថា៖ *"អល់ឡោះហ្ស៍យកវិញ្ញាណនៅពេលពួកគេស្លាប់ (៣៩:៤២) ។ ពុំមាននរណាស្លាប់ដោយមិនបានទទួលការអនុញ្ញាតពីអល់ឡោះហ្ស៍ឡើយ តាមពេលវេលាដែលត្រូវបានកំណត់ទុកស្រេចហើយ (៣:១៤៥) ។"*
ចម្លើយនេះធ្វើឲ្យបុរសកំណាចសុញគំនិត មិននឹកស្មានថានឹងបានឮភ័ស្តុតាងមាំដកស្រង់មពីក្នុងព្រះគម្ពីរគួរអានទេ បុរសកំណាចរូបនេះភ្លេចថាព្រះគម្ពីរគួរអានត្រូវបើកឲ្យដឹង នៅក្នុងលំនៅដ្ឋានរបស់បុគ្គលទាំងនោះ ហើយបុគ្គលដែលគេបានបើកឲ្យដឹងព្រះគម្ពីរគួរអាន គឺព្រះអយ្យកោរបស់បុគ្គលទាំងអស់នោះ ហើយជាបុគ្គលអាទិ (គឺជាឫសកែវដំបូងបង្អស់) ។ បុរសកំណាចរូបនេះបាននិយាយយ៉ាងក្រអឺតថា៖ "ឯងហ៊ានតមាត់អញផង ? ឯងហ៊ានប្រកែកសម្ដីអញផង ?" បុរសកំណាចក៏បានបញ្ជាឲ្យសេនាម្នាក់កាត់ព្រះសិរអ៊ីម៉ាំ ស្ហ៊ៃន៍ អាល់-អា្ុប៊ីឌ្ហីនصلوات الله عليه والسلام ។ តែព្រះនាងស្ហ៊ៃណាប់سلام الله عليهاបានស្ទុះទៅឱបព្រះភាគុបុត្តព្រះនាង ហើយថ្លែងដាក់អ៊្ូបៃឌុលឡោះហ្ស៍ថា៖ "កូនរបស់ស៊្ហុីយ៉ាដ្ហ៍អឺយ អ្នកឯងបង្ហូរឈាមយើង

គ្រប់គ្រាន់ហើយ ។ តើអ្នកឯងបាន ទុកឲ្យអ្នកណាម្នាក់រួចជីវិតទេក្រៅពីនេះ ? បើអ្នកឯងចង់សម្លាប់គេ ចូរសម្លាប់ខ្ញុំផង ។"

វីរភាព និងទង្វើបរទត្ថនិយមនេះបានធ្វើឲ្យអ៊ូបៃឌុលឡោះហ្ស៍ភ្ញាក់ផ្អើល ។ ដូច្នេះ បុរសកំណាចបានបញ្ជាថា៖ "លែងវាឲ្យនាងហ្នឹងទៅ ។ ខ្សែលោហិតថ្លៃមែន ! នាងហ្នឹងចង់ស្លាប់ជាមួយវា ។"

ដោយសារព្រះនាងស្ហៃណាប់سلام الله عليها អ៊ីម៉ាំស្ហៃន៍ អាល់-អាប៊ីឌីនصلوات الله عليه والسلامបានរួចផុតពីបុរសកំណាច ។

ស្ត្រីទាំងឡាយនិងព្រះរាជកុមារ ព្រះរាជវង្សព្រះសាស្តាصلى الله عليه وآله وسلمត្រូវឃុំឃាំងត្រូវធ្វើបាបនៅក្នុងបន្ទប់មួយក្បែរម៉ាស់យ៉ិដគូហ្វាស្ហ ។ ម្នាក់ៗបានទទួលនំប៉័ងតែមួយដុំសម្រាប់មួយថ្ងៃពេញ ។ ចំណែកឯព្រះនាងស្ហៃណាប់سلام الله عليها វិញតែងតែចែកចំណែកព្រះនាងឲ្យទៅកុមារ មិនសោយអ្វីទេពេញមួយថ្ងៃ បណ្ដាលឲ្យអស់កម្លាំងដល់ថ្នាក់មិនអាចឈរស្ងួឡាត្ហ៍បាន ។ ឃើញដូច្នេះ អ៊ីម៉ាំស្ហៃន៍ អាល់-អាប៊ីឌីនصلوات الله عليه والسلامបានសាកសួរព្រះបិតុច្ឆាព្រះអង្គصلوات الله عليه والسلامដោយភ័យស្លន់ស្លោ ឯព្រះបិតុច្ឆាក៏បានប្រាប់អំពីមូលហេតុ ។

ដោយឃើញថា ព្រះនាងស្ហៃណាប់سلام الله عليهاមានកេរ្តិ៍ឈ្មោះក្រអូបពេញរដ្ឋអ៊ីស្លាម បណ្ដាស្ត្រីស្រុកគូហ្វាស្ហប្រជែងគ្នាដណ្ដើមកិត្តិយសទៅជួបព្រះនាងسلام الله عليها តែព្រះនាងបដិសេធ មិនព្រមជួបអ្នកណាទេដោយថា៖ "អ្នកណាក៏ដោយ មិនត្រូវមកជួបយើងទេ លើកលែងតែបម្រើព្រោះពួកគេជាចំណាប់ដូចយើងដែរ ។"

អាជ្ញាធរដឹកនាំរង់ចាំបញ្ជាពីបុគ្គលកំណាចយ៉ាស៊ីដ្ហ រឿងចំណាប់ឈ្លើយ ។ ពីរបីថ្ងៃក្រោយមក ពួកគេបានទទួលបញ្ជាឲ្យបញ្ជូនខ្លួនចំណាប់ទៅឯដ្ហាម៉ាស់ ។

ទន្ទឹមនឹងក្រុមចំណាប់ឈ្លើយ ក្បាលរបស់អស់ទាំងទុក្ករបុគ្គលត្រូវដោតលើចុងលំពែង ដើម្បីនឹងឲ្យប្រជារាស្ត្រស្រុកស៊ីរីឃើញដូចអ្នកស្រុកគូហ្វាស្ហដែរ នឹងដើម្បីធ្វើឲ្យបុគ្គលកំណាចសប្បាយចិត្ត ។

## ចំណាប់ឈ្លើយនៅដ្ហាម៉ាស់

ជាប់ចំណង ត្រូវបង្ខំឲ្យជិះអូដ្ឋសម្គមគ្មានកែប នៅក្នុងសភាពអាម៉ាស់ ព្រះរាជហ្ការីម (حريم គឺបណ្ដាស្ត្រីមហេសីរបស់អ៊ីម៉ាំនិងព្រះរាជកុលដ្ឋានស្ត្រីរបស់ព្រះសាស្ដាﷺ) និងព្រះរាជកុមារព្រះរាជវង្សព្រះសាស្ដាﷺត្រូវនាំខ្លួនទៅកាន់ប្រទេសស៊ីរី ។ តាមផ្លូវ ទាំងអស់គ្នាមិននិយាយស្ដីសោះ មិនហាមាត់សូមអ្វីឡើយពីពួកដឹកនាំក្បួនដំណើរ ។ ជិតដល់ប្រសេទស៊ីរី ក្បួនដំណើរឈប់ដើម្បីទុកពេលឲ្យគេតែងលំអស្រុក ដោយការសម្ដែងគគ្រឹកគគ្រេងនិងដើម្បីប្រមូលមនុស្ស ឲ្យមកមើលជ័យជំនះក្លែងក្លាយរបស់មេគ្រប់គ្រងពួកគេ ។

ក្បួនដំណើរនៅឆ្ងាយពីប្រទេសស៊ីរីប្រមាណបួនប៉ារ៉ាសាង[233] ពេលពួកអ្នកស្រុកទទួលពួកគេដោយសោមនស្ស ទូងស្គរ ផ្លុំត្រែ ស្លៀកពាក់ស្អាតបាតដើម្បីសម្ដែងសេចក្ដីរីករាយ ចំពោះការកាប់សម្លាប់ព្រះរាជវង្សព្រះសាស្ដាﷺ ។

យើងសូមលើកយកទិដ្ឋភាព និងកំណត់ហេតុរបស់សាក្សីផ្ទាល់ភ្នែកម្នាក់ឈ្មោះ សាស្ល៍ អ៊ីបនូ សាអាុដ្ឋ៍ អាល់-សាអ៊ីឌី (سَهل بن سَعد الساعِدي) ដែលបានតំណាលថា៖ "ខ្ញុំបានកាត់តាមផ្សារម៉ាស់ដើម្បីទៅលេងយេរូសាឡេមតែចម្លែក ស្រុកត្រូវតុបតែងហួសហេតុពេកដោយពណ៌ទឹកមាស ពួកអ្នកស្រុកសប្បាយរីករាយណាស់ ពួកស្ត្រីវាយស្គរតូចនិងស្គរធំ ។ ខ្ញុំគិតក្នុងចិត្តថាអ្នកស្រុកនោះធ្វើបុណ្យអ្វីមួយដែលយើងមិនធ្លាប់ស្គាល់ ។ ដោយបានឃើញអ្នកខ្លះនិយាយដោយស្ងាត់ៗ ខ្ញុំក៏បានចូលទៅជិត សូមសួរពួកគេថា៖ "តើអស់លោកអ្នកស្រុកស៊ីរីកំពុងធ្វើពិធីបុណ្យមួយដែលយើងមិនស្គាល់មែនទេ ?"

ពួកគេបានសួរថា៖ "លោកប្រហែលជាអ្នកចម្ងាយមែនទេ ?" ខ្ញុំបានឆ្លើយថា៖ "មែន ខ្ញុំឈ្មោះ សាស្ល៍ អ៊ីបនូ សាអាុដ្ឋ៍ ខ្ញុំធ្លាប់បានជួបព្រះសាស្ដាﷺអល់ឡោះហ្ទ៍عز وجل ។" ពួកគេបានសួរថា៖ "សាស្ល៍អឺយ តើលោកមិនឃើញថាប្លែកទេដែលមេឃមិនធ្លាក់ភ្លៀងឈាម ដីមិនស្រូបអ្នកស្រុក

---

[233] ប៉ារ៉ាសាង ជាមាត្រារង្វាស់ដែលស្មើនឹង ៣ ឬ ៣.៥ ម៉ៃស៍ ឬ ៥ ទៅ ៥.៥ គីឡូម៉ែត្រ ។

នេះ ?" ខ្ញុំបានសួរថា៖ "តើគេធ្វើបុណ្យអ្វីទៅ ?" ពួកគេបានបើកឲ្យដឹងថា៖ "នេះគឺដើម្បីរង់ចាំព្រះសិរអាល់-ហ៊្សៃសែន៍صلوات الله عليه والسلامមកពីគូហ្វាស្ង់ ។" ខ្ញុំបានសួរថា៖ "ចម្លែកមែន ! ព្រះសិររបស់អាល់-ហ៊្សៃសែន៍صلوات الله عليه والسلامដើរមកទីនោះ ខណៈដែលមនុស្សអបអរសាទរជាហ្វូងៗ ។ តើព្រះសិរនឹងចូលមកក្នុងស្រុកតាមទ្វារមួយណា ?"

ពេលពួកគេចង្អុលទៅឯទ្វារអាល់-សាអ៊ុត់ (باب الساعات) ខ្ញុំរួសរាន់ទៅឯទ្វារនោះ ។ កងទង់ជ័យមួយជួរដើរចូលមក តែខ្ញុំបានដាក់ភ្នែកទៅលើពលសេះម្នាក់ដែលកាន់ទង់មួយគ្មានផ្លែលំពែង នៅពីលើចុងទង់នោះមានក្បាលមនុស្សស្រដៀងព្រះសិរព្រះសាស្តាصلى الله عليه وآله وسلم ។ នោះគឺព្រះសិរ អាល់-ហ៊្សៃសែន៍صلوات الله عليه والسلام ! បន្ទាប់មកបន្តិចជនចំណាប់បានមកដល់ ជិះអូដ្ឋសម្គមគ្មានកែប ។ លុះបានទៅជួបស្ត្រីចំណាប់ម្នាក់ ខ្ញុំបានសួរឈ្មោះគាត់ ។

ស្ត្រីនោះបានឆ្លើយថា៖ "ខ្ញុំឈ្មោះស៊ូកៃណាស៉្ង បុត្រីរបស់អាល់-ហ៊្សៃសែន៍صلوات الله عليه والسلام ។" ខ្ញុំបានទូលថា៖ "ទូលបង្គំឈ្មោះសាស្ង់ល៍ សាវកម្នាក់របស់ព្រះអយ្យកោព្រះនាងسلام الله عليها ព្រះសាស្តាصلى الله عليه وآله وسلمអល់ឡោះហ្វ៍عز وجل ។" ដោយឈឺចាប់ព្រះនាងមានវចនៈថា៖ "ចូរលោកសូមឲ្យខ្មាន់ព្រះសិរអាល់-ហ៊្សៃសែន៍صلوات الله عليه والسلامដើរឲ្យឆ្ងាយពីមុខយើងដើម្បីនឹងឲ្យមនុស្សមើលព្រះសិរ មិនមើលយើង ព្រះរាជកុលដ្ឋានعليهم السلامព្រះសាស្តាصلى الله عليه وآله وسلمរបស់អល់ឡោះហ្វ៍عز وجل ។"

ខ្ញុំក៏រត់ទៅរកពលសេះនោះ សូកប្រាក់គាត់បួនរយឌៀរហ្ម៍ សូមឲ្យគាត់ជិះឲ្យលឿនទៅមុខ ឆ្ងាយពីបណ្តាស្ត្រីចំណាប់ ពលសេះនោះក៏បានធ្វើតាមសំណូម ។

នៅក្នុងពេលនោះដែរ បុរសចំណាស់ជនជាតិស៊ីរីម្នាក់ ច្រត់ឈើច្រត់ ដែលសប្បាយលើភាពអាម៉ាស់របស់ជនចំណាប់ បានចូលទៅជិតអ៊ីម៉ាំ អ៊ុលីស្សៃន៍ អាល់-អ៊ុប៊ីឌីនصلوات الله عليه والسلام និយាយបញ្ឈឺថា៖ "សូមថ្វាយថោមនាការចំពោះអល់ឡោះហ្វ៍عز وجلដែលបានកម្ចាត់ពួកឯង ហើយបានប្រទានអំណាចឲ្យទៅស្តេចដើម្បីឈ្នះពួកឯង ។"

ប្រកបដោយប្រាជ្ញាវាងវៃ ប្រកបដោយឈ្វេងគំនិត អ៊ីម៉ាំصلوات الله عليه والسلامឃើញថាបុរសចំណាស់រូបនេះត្រូវគេបោកបញ្ឆោតដោយសម្តីចចាមអារ៉ាម ដែល

អាជ្ញាធរកាន់អំណាចបានផ្សព្វផ្សាយបង្ខូចអាស្ស់លុល-បៃត៍عليهم السلام ។ ព្រះអង្គصلوات الله عليه والسلامបានសួរបុរសចំណាស់នោះថា៖ "តើលោកសូត្រព្រះគម្ពីរគួរអានទេ ?"

វចនៈនេះធ្វើឲ្យបុរសចំណាស់ភ្ញាក់ នឹកឆ្ងល់ក្នុងចិត្ត ហើយបានឆ្លើយថាគាត់សូត្រគួរអាន ។

អ៊ីម៉ាំصلوات الله عليه والسلامបានសួរគាត់ថាតើគាត់ដែលឃើញអាយ៉ាស្ទ៍គួរអាននេះទេ គឺ៖

قُل لَّآ أَسۡـَٔلُكُمۡ عَلَيۡهِ أَجۡرًا إِلَّا ٱلۡمَوَدَّةَ فِي ٱلۡقُرۡبَىٰۗ

*"ចូរអ្នកថា៖ "ខ្ញុំមិនសូមឈ្នួលពីអស់លោកសម្រាប់អ្វីទាំងនេះទេ សូមឲ្យតែអាណិតស្រឡាញ់បណ្តាសាច់សាលោហិតជំនិតរបស់ខ្ញុំ (៤២:២៣) ។"*

وَءَاتِ ذَا ٱلۡقُرۡبَىٰ حَقَّهُۥ

*"ចូរអ្នកប្រគល់ឲ្យទៅបណ្តាសាច់ញាតិជិតស្និទ្ធអ្នក នូវអ្វីដែលពួកគេត្រូវបាន (១៧:២៦) ។"*

وَٱعۡلَمُوٓاْ أَنَّمَا غَنِمۡتُم مِّن شَيۡءٖ فَأَنَّ لِلَّهِ خُمُسَهُۥ وَلِلرَّسُولِ وَلِذِي ٱلۡقُرۡبَىٰ...

*"ចូរពួកអ្នកដឹងថា អ្វីក៏ដោយដែលពួកអ្នកបានប្រមូលយកជាជ័យភណ្ឌមួយភាគប្រាំនៃជ័យភណ្ឌនោះជាកម្មសិទ្ធិរបស់អល់ឡោះហ្ទ៍ របស់សាស្តា និងរបស់ញាតិជិតស្និទ្ធ... (៨:៤១) ។"*

ស្រឡាំងកាំង បុរសចំណាស់បានឆ្លើយថាគាត់បានសូត្រអាយ៉ាស្ទ៍ទាំងនេះ ។ អ៊ីម៉ាំصلوات الله عليه والسلامមានវចនៈថា៖ "ព្រះបន្ទូលថា "សាច់ញាតិជិតស្និទ្ធ" ដែលអល់ឡោះហ្ទ៍عز وجلថែងនៅក្នុងអាយ៉ាស្ទ៍ទាំងនេះនោះ សំដៅមកលើរូបយើងនេះឯង ។"

អ៊ីម៉ាំصلوات الله عليه والسلامបានសួរបុរសចំណាស់នោះទៀតថាតើគាត់បានសូត្រព្រះបន្ទូលអល់ឡោះហ្ទ៍عز وجلទេ គឺ៖

إِنَّمَا يُرِيدُ ٱللَّهُ لِيُذۡهِبَ عَنكُمُ ٱلرِّجۡسَ أَهۡلَ ٱلۡبَيۡتِ وَيُطَهِّرَكُمۡ تَطۡهِيرٗا

*"សមាជិកនៃគេហដ្ឋាន[របស់សាស្តា]អើយ អល់ឡោះហ្ទ៍គ្រាន់តែប្រាថ្នាឲ្យពួកអ្នកចាកផុតពីមន្ទិល ហើយព្រះអង្គប្រាថ្នាសំអាតពួកអ្នកឲ្យបរិសុទ្ធជ្រះស្អាតតែប៉ុណ្ណោះទេ (៣៣:៣៣) ។"*

ដោយភ្ញាក់ផ្អើល បុរសចំណាស់បានឆ្លើយថាគាត់បានសូត្រអាយ៉ាស់នេះដែរ ។ អ៊ីម៉ាំصلوات الله عليه والسلامមានវចនៈថា៖ "យើងនេះឯងដែលជា "សមាជិកនៃគេហដ្ឋាន" ដែលអល់ឡោះហ្ទ៍عز وجلជម្រះបន្សុទ្ធឲ្យស្អាតបរិសុទ្ធនោះ ។"
ការពិតនេះបានធ្វើឲ្យបុរសចំណាស់ផ្លាស់ប្ដូរទាំងស្រុង បានធ្វើឲ្យគាត់ស្ដាយក្រោយដែលបានធ្វើខុស ក្នុងសម័យដែលគាត់មិនស្គាល់មេដឹកនាំត្រកូលអ៊្វម៉ៃយ៉ាស់និងអាជ្ញាធររបស់ពួកគេនោះច្បាស់ ។ សូម្បីតែអណ្ដាតគាត់ក៏គាំងដោយសារព្រឹត្តិការណ៍ថ្មីដែរ ។ គាត់ក៏បានទូលអ៊ីម៉ាំصلوات الله عليه والسلام ដោយញញើតញញើមថា៖ "ក្នុងព្រះនាមអល់ឡោះហ្ទ៍عز وجل សូមប្រាប់ខ្ញុំមកថាអ្នកទាំងអស់គ្នាជាបុគ្គលទាំងនោះមែនឬ ?" អ៊ីម៉ាំصلوات الله عليه والسلامបានតបវិញដោយធានារ៉ាប់រងថា៖ "មែន ខ្ញុំសូមស្បថចំពោះព្រះអយ្យកោយើង ព្រះសាស្ដាصلى الله عليه وآله وسلمអល់ឡោះហ្ទ៍عز وجل ។"
ដឹងខ្លួនថាបានធ្វើខុសឆ្គងចំពោះអ៊ីម៉ាំصلوات الله عليه والسلام ដែលបាននិយាយស្ដីពីមុនបន្តិចនេះ បុរសចំណាស់បានស្ទុះទៅថើបដៃអ៊ីម៉ាំصلوات الله عليه والسلامយ៉ាងខ្លាំង ជាសញ្ញានៃការស្ដាយក្រោយ ដោយប្ដេជ្ញាថា៖ "ទូលបង្គំសូមបដិសេធអស់បុគ្គលដែលសម្លាប់ព្រះអង្គعليهم السلام ។"

## យ៉ាស៊ីដចំអក

យ៉ាស៊ីដូចង្រៃមានអារម្មណ៍សោមនស្ស មានបំណងព្យាបាទ ពេលបានទទួលដំណឹងថាចំណាប់ឈ្លើយបានមកដល់ ។ ស្ហ៊ីម្រ អ៊ីបនូ ស៊ីល-យ៉ៅស្ហាន (شِمر بن ذى الجَوْشَن) និង ម៉ាក់ហ្វារ អ៊ីបនូ ស្ហាឡាបាស់ បានបង្ហាញយ៉ាស៊ីដព្រះសិរអ៊ីម៉ាំصلوات الله عليه والسلامអាល់-ហ៊្វសែន៍صلوات الله عليه والسلام ។ យ៉ាស៊ីដអនុញ្ញាតឲ្យប្រជារាស្ត្រតូចតាចនៃស្រុកដ្វាម៉ាស់ មកប្រជុំគ្នានៅក្នុងវាំងរបស់ខ្លួន ឲ្យសរសើរខ្លួនដែលបានទទួលជ័យជំនះ "ក្លែងក្លាយ" និងដែលបានសសឹកទៅលើព្រះសាស្ដាصلى الله عليه وآله وسلمនិងព្រះរាជវង្សព្រះអង្គصلى الله عليه وآله وسلم ។
គេបានដាក់ព្រះសិរនៅពីមុខបុរសកំណាច ដែលដើរទៅវាយដោយរំពាត់ក្នុងដៃ ។ បន្ទាប់មកបុរសកំណាចសម្ដែងឲ្យឃើញចិត្តព្យាបាទឥតព្រំដែនដាក់អ៊ីម៉ាំصلوات الله عليه والسلام ដាក់ព្រះរាជវង្សព្រះអង្គصلوات الله عليه والسلام ដាក់ព្រះរាជសារដែលព្រះ

សាស្តាﷺផ្ញើជូនមនុស្សជាតិ គឺព្រះរាជសារដែលបំបាក់មុខយ៉ាស៊ីដនិងត្រកូលរបស់យ៉ាស៊ីដដែលពួកគេព្យាយាមប្រឹងប្រែងបំបាត់តាំងពីដើមមកម្ល៉េះ ។

អាប៊ី បារ៍ស្ញាស្ញ់ អាល់-អាស់ឡាមី ពេលបានឃើញទិដ្ឋភាពគួរឲ្យស្អប់នេះមិនអាចអត់ទ្រាំបាន ក៏បាននិយាយដាក់យ៉ាស៊ីដថា៖ "ហេតុអ្វីក៏ហ៊ានវាយព្រះឱស្ឋ (គឺមាត់) អាល់-ហ៊្សសែន៍صلوات الله عليه والسلامដោយរំពាត់ ? ខ្ញុំសូមស្បថថាខ្ញុំបានឃើញព្រះសាស្តាﷺថើបលើព្រះឱស្ឋនេះជាញឹកញយ ។ ថ្ងៃជំនុំជម្រះអ្នកបែខ្ទុលឡោះហ្វ៍ អ៊ីបនូ ស៊ីយ៉ាដ៍ជាអ្នកជួយធ្វើអន្តរាគមន៍ឲ្យលោក រីឯអ្នកជួយធ្វើអន្តរាគមន៍ឲ្យអាល់-ហ៊្សសែន៍صلوات الله عليه والسلامគឺមូហាំម៉ាដ៍ﷺ ។"[234]

ពួកនគរបាលអន្យតិរ្ថិយរបស់យ៉ាស៊ីដបានចងចំណាប់ទាំងអស់គ្នាជាមួយខ្សែ ដោយផ្ដើមចងកអ៊ីម៉ាំស្ញែន៍ អាល់-អ្ញាប៊ីឌីនصلوات الله عليه والسلامជាប់នឹងកព្រះនាងស្ញៃណាប់سلام الله عليها រហូតទៅដល់ក្មេងក្រោយគេ ។ ពួកគេបង្ខំឲ្យទាំងអស់គ្នាដើរក្នុងសភាពនេះ បើអ្នកណាមួយចំពប់ជើង នគរបាលវាយអ្នកនោះយ៉ាងធ្ងន់ ។ ម្យ៉ាងទៀត ទាំងអស់គ្នាត្រូវឡោមព័ទ្ធដោយសម្រែកជ័យជំនះ ។

ជនចំណាប់ត្រូវគេនាំមកបង្ហាញខ្លួនពីមុខបុរសកំណាចយ៉ាស៊ីដ ក្នុងសភាពអាម៉ាស់នេះ ។ អ៊ីម៉ាំស្ញែន៍ អាល់-អ្ញាប៊ីឌីនصلوات الله عليه والسلامសម្លឹងបុរសកំណាចមានវចនៈថា៖ "បើព្រះសាស្តាﷺឃើញយើងនៅក្នុងសភាពនេះ តើព្រះអង្គﷺនឹងមានអារម្មណ៍យ៉ាងណា ?"

សម្ដីនេះធ្វើឲ្យទាំងអស់គ្នារំភើបចិត្ត រួមទាំងបុរសកំណាចដែរ ដូច្នេះបណ្ដាអ្នកហែហាមក៏បានយំ ។ ពេលបែរទៅរកព្រះហ្ញារីមចំណាប់ព្រះរាជវង្សព្រះសាស្តាﷺ យ៉ាស៊ីដបានថា៖ "អបមង្គលលើកូនរបស់ម៉ារយ៉្ញាណាស្ញ់ ! បើពួកអ្នកថ្លែងរឿងនេះប្រាប់បុគ្គលនោះគ្រប់ពេល បុគ្គលនោះនឹងមិនប្រព្រឹត្តបែបនេះលើពួកអ្នកទេ ។"

ខុសស្រឡះ ពីព្រោះកូនរបស់ម៉ារយ៉្ញាណាស្ញ់មិនហ៊ានធ្វើអ្វីឡើយដោយពុំ

---

[234] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាល់-អាស្ញៀរ *អាល់-តារិក្ញ* ក្បាលទី ៣ ទំព័រ ៣៩៨ ។

បានទទួលបញ្ញានិងបង្គាប់ពីយ៉ាស៊ីដ្ធបុរសកំណាចទេ ។
បន្ទាប់ពីនោះ បុរសអន្យតិរ្ថិយបែរទៅរកអ៊ីម៉ាំស្ស៊ែន៍ អាល់-អ៊ុបីឌីនﷺ ថា៖ "អ៊ុលី អ៊ីបន្ធ អាល់-ហ៊្វសែន៍ﷺ ! ដោយសារតែបិតាអ្នកមិនអើពើនឹងសាលោហិតយើងជាមួយគេ មិនអើពើនឹងសិទ្ធិយើង ប៉ងរឹបអូសអំណាចយើង បានជាអល់ឡោះហ្វាំ ធ្វើបែបនេះលើគេ ។"
អ៊ីម៉ាំﷺឆ្លើយតបការអះអាងមិនត្រឹមត្រូវនេះ ដោយលើកយកព្រះបន្ទូលអល់ឡោះហ្វាំ ពីក្នុងគួរអានថា៖

مَا أَصَابَ مِنْ مُصِيبَةٍ فِي الْأَرْضِ وَلَا فِي أَنْفُسِكُمْ إِلَّا فِي كِتَابٍ مِنْ قَبْلِ أَنْ نَبْرَأَهَا ۚ إِنَّ ذَٰلِكَ عَلَى اللَّهِ يَسِيرٌ ﴿٢٢﴾ لِكَيْلَا تَأْسَوْا عَلَىٰ مَا فَاتَكُمْ وَلَا تَفْرَحُوا بِمَا آتَاكُمْ ۗ وَاللَّهُ لَا يُحِبُّ كُلَّ مُخْتَالٍ فَخُورٍ ﴿٢٣﴾

*"ភ័យវិបត្តិកើតមាននៅលើផែនដីនិងលើពួកអ្នកសុទ្ធតែមាន [កត់ត្រាទុក] នៅក្នុងបញ្ជីជាស្រេច មុនយើងនឹងឲ្យវាកើតឡើង ។ ពិតណាស់ នេះជាការងាយស្រួលសម្រាប់អល់ឡោះហ្វាំ (៥៧:២២) ។ ដើម្បីនឹងកុំឲ្យពួកអ្នកអស់សង្ឃឹមលើអ្វីមួយដែលបានរបូតផុតពីពួកអ្នក និងដើម្បីនឹងកុំឲ្យពួកអ្នកសប្បាយរីករាយជ្រុលពេកជាមួយអ្វីមួយ ដែលគេបានប្រទានឲ្យពួកអ្នក ។ អល់ឡោះហ្វាំមិនសព្វព្រះហឫទ័យបុគ្គលណាដែលព្រហើនមានអំនួតឡើយ (៥៧:២៣) ។"*
ចម្លើយនេះធ្វើឲ្យយ៉ាស៊ីដ្ធក្តៅក្រហាយចិត្ត ព្យាយាមរកពាក្យឆ្លើយតបឲ្យស័ក្តិសម ហើយក៏បានសូត្រអាយ៉ាស់គួរអានមួយទៀតថា៖

وَمَآ أَصَٰبَكُم مِّن مُّصِيبَةٍ فَبِمَا كَسَبَتۡ أَيۡدِيكُمۡ وَيَعۡفُواْ عَن كَثِيرٍ ۝٣٠

*"ទុក្ខវេទនាណាក៏ដោយដែលពើបពះលើពួកអ្នក វាកើតឡើងដោយសារអំពើដែលដៃពួកអ្នកបានប្រព្រឹត្ត ហើយព្រះអង្គអត់ឱនឲ្យយ៉ាងច្រើន [កំហុសដែលពួកអ្នកបានធ្វើ] (៤២:៣០) ។*
អ៊ីម៉ាំស្ស៊ែន៍ អាល់-អ៊ុបីឌីនﷺ ដែលចេះដឹងព្រះគម្ពីរគួរអានថ្នាក់កំពូលមានវចនៈថា៖ "អាយ៉ាស់នេះស្តីអំពីបុគ្គលដែលប្រព្រឹត្តខុសលើគេទេ មិន

ទាក់ទងនឹងបុគ្គលដែលត្រូវគេប្រព្រឹត្តខុសមកលើខ្លួនទេ ។"[235]

## សុន្ទរកថាទីពីររបស់ព្រះនាងស៊ែណាប់سلام الله عليها

ពេលយ៉ាស៊ីដ្ធនឹកឃើញថ្ងៃដ៏ជូរចត់ដែលឪពុក និងតារបស់ខ្លួនបានប្រយុទ្ធទល់នឹងព្រះអយ្យកោﷺរបស់អាល់-ហ៊្វសែន៍صلوات الله عليه والسلام និងបរាជ័យដែលអន្ទោលតាមមកដល់ក្នុងផ្ទះខ្លួននោះ យ៉ាស៊ីដ្ធសប្បាយចិត្តខ្លាំងណាស់អំពីស្ថានភាពបច្ចុប្បន្ន ចំណែកឯព្រះរាជវង្សព្រះសាស្ដាﷺធ្លាក់ខ្លួនជាចំណាប់ក្នុងកណ្ដាប់ដៃខ្លួន ព្រះសិររបស់ព្រះនត្តាទាំងពីររបស់ព្រះសាស្ដាﷺត្រូវចោលនៅពីមុខខ្លួន ។ ដូច្នេះ គាត់បានស្រង់យកនូវកំណាព្យដែលគេសូត្រនៅឯសមរភូមិអ៊្វហ៊្វដ្ធ ដោយផ្លាស់ប្ដូរតាមតម្រូវចិត្តគាត់ថា៖

*ខ្ញុំចង់ឲ្យដូនតាខ្ញុំនៅឯបាដ្វារ*[236] *ជាសាក្សី*
*ថាខុស្ស៊់រ៉ជ្*[237] *ត្រូវបន្លាធ្វើទុក្ខបុកម្នេញ*
*អស់លោកច្បាស់ជាសប្បាយរីករាយអនេក*
*អស់លោកច្បាស់ជានឹងថា៖ "យ៉ាស៊ីដ្ធអើយ សូមកុំឲ្យដៃអ្នកគាំងឡើយ*
*យើងបានសម្លាប់មេរបស់ពួកដឹកនាំពួកវា*
*បានសងសឹកស្មើនឹងភូមិបាដ្វារ ពិតជាដូច្នេះមែន*
*ពួកហ្ហាស៊្ហីមបានលេងល្បែងកាន់អំណាចដូច្នេះឯង*
*ថ្វីបើពុំមានដំណឹងមកពីលើមេឃទេ*
*ពុំមានអ្វីត្រូវបើកឲ្យដឹងឡើយ*[238]
*ខ្ញុំនឹងទទួលស្គាល់ខាន់ដ្វាក៍បើខ្ញុំមិនសងទេនោះ*

---

[235] សូមមើលសៀវភៅរបស់លោក ស្ហៃខ៍ អាល់-មូហ៊ីដ្ធ (الشيخ المفيد) *អាល់-អៀរស្ហាដ្ធ៍ (الإرشاد)* ទំព័រ ២៧៦ ។

[236] ស្ដីអំពីសមរភូមិបាដ្វារ ដែលសាច់ញាតិរបស់យ៉ាស៊ីដ្ធត្រូវសម្លាប់ដោយដៃបិតា និងសាច់ញាតិរបស់អាល់-ហ៊្វសែន៍صلوات الله عليه والسلام ។

[237] ខុស្ស៊់រ៉ជ្គឺកុលសម្ព័ន្ធដែលគាំទ្រព្រះសាស្ដាﷺនិងបក្សពួកព្រះអង្គﷺ ។

[238] នេះគឺភ័ស្ដុតាងច្បាស់ក្រឡែតបញ្ជាក់ឲ្យដឹងយ៉ាស៊ីដ្ធមិនជឿសាសនាអ៊ីស្លាមទេ មិនជឿព្រះបេសសកម្មរបស់ព្រះសាស្ដាមូហ៊ាំម៉ាដ្ធ៍ﷺទេ ។

*លើកូនៗរបស់អាស្ម៉ាដ្ទ*[239] *សងអំពើដែលគេបានប្រព្រឹត្តមកលើយើង*
តបកំណាព្យនេះ ព្រះនាងស៊ៃណាប់سلام الله عليهاបានប្រឆាំងបុរសអន្យតិរ្ថិយថា៖

اَلْحَمْدُ لِلّٰهِ رَبِّ الْعالَمِيْنَ وَ صَلَّى اللّٰهُ عَلٰى رَسُوْلِهِ مُحَمَّدٍ وَ آلِهِ اَجْمَعِيْنَ. صَدَقَ اللّٰهُ سُبْحَانَهُ، كَذٰلِكَ يَقُولُ: "ثُمَّ كانَ عاقِبَةَ الَّذِينَ أَساؤُا السُّوْاٰى أَنْ كَذَّبُوْا بِآيَاتِ اللّٰهِ وَ كَانُوْا بِهَا يَسْتَهْزِؤُنَ" أَ ظَنَنْتَ يا يَزِيْدُ حِيْنَ أَخَذْتَ عَلَيْنَا أَقْطَارَ الْأَرْضِ وَ آفَاقَ السَّمَاءِ فَأَصْبَحْنَا نُسَاقُ كَمَا تُسَاقُ الْإِمَاءِ أَنَّ بِنَا عَلَي اللّٰهِ هَوَاناً وَ بِكَ عَلَيْهِ كَرَامَةً وَ أَنَّ ذٰلِكَ لِعِظَمِ خَطَرِكَ عِنْدَهُ؟ فَشَمَخْتَ بِأَنْفِكَ وَ نَظَرْتَ فِي عَطْفِكَجَذْلَانَ مَسْرُوْرًا حِيْنَ رَأَيْتَ الدُّنْيَا لَكَ مُسْتَوْسِقَةً وَ الْأُمُوْرَ مُتَّسِقَةً، وَ حِيْنَ صَفَاَ لَكَ مُلْكُنَا وَ سُلْطَانُنَا؟

*"សូមថ្វាយថោមនាការចំពោះអល់ឡោះហ្ទ៍﷿ ព្រះម្ចាស់ពិភពទាំងពួង ។ សូមអល់ឡោះហ្ទ៍﷿ប្រទានពរជ័យដល់មូហាំម៉ាដ្ទﷺ ព្រះសាស្តាព្រះអង្គ﷿និងព្រះរាជបុត្ររាជនត្តាព្រះអង្គﷺទាំងអស់គ្នា ។ ពិតណាស់ អល់ឡោះហ្ទ៍﷿មានព្រះបន្ទូលថា៖ "អវសានអាក្រក់របស់ពួកប្រព្រឹត្តិអំពើអាក្រក់មកពីពួកគេបានបដិសេធ សញ្ញាទាំងឡាយរបស់អល់ឡោះហ្ទ៍ ពួកគេតែងតែចំអកឲ្យសញ្ញាទាំងនោះ (៣០:១០) ។" យ៉ាស៊ីដ្ទអឺយ ពេលអ្នកឯងបិទផ្លូវយើងទាំងអស់នៅលើផែនដីនិងលើមេឃនោះ ហើយយើងត្រូវកៀងជាចំណាប់ អ្នកឯងគិតថាយើងពុំមានតម្លៃសម្រាប់អល់ឡោះហ្ទ៍﷿ទេ ចំណែកអ្នកឯងនោះវិញទៅជាមនុស្សស្អាតស្អំ ប្រកបដោយសេចក្តីគោរពសម្រាប់អល់ឡោះហ្ទ៍﷿ឬ ? ឬក៏អ្នកឯងបានទទួលឋានៈខ្ពង់ខ្ពស់ពីអល់ឡោះហ្ទ៍﷿ ? ដូច្នេះ អ្នកឯងឃើញថាយើងតូចទាប អ្នកឯងទៅជាក្រអឺតក្រទមលើកខ្លួន ពេលអ្នកឯងឃើញថាពិភពលោកនៅក្រោមអំណាចអ្នកឯង ឃើញគេធ្វើអ្វីៗតាមក្បាលចិត្តអ្នកឯង ឃើញអាជ្ញាធរនិងអំណាចយើងនៅក្នុងកណ្តាប់ដៃអ្នកឯង ?*

239 អាស្ម៉ាដ្ទជាព្រះនាមរបស់មូហាំម៉ាដ្ទﷺដែលមកពីឋានសួគ៌ ។

فَمَهْلًا مَهْلًا أَ نَسِيْتَ قَوْلَ اللّهِ تَعَالٰي: "وَ لا يَحْسَبَنَّ الَّذِينَ كَفَرُوْا أَنَّما نُمْلِيْ لَهُمْ خَيْرٌ لِأَنْفُسِهِمْ إِنَّما نُمْلِيْ لَهُمْ لِيَزْدَادُوْا إِثْماً وَ لَهُمْ عَذابٌ مُهِيْنٌ" أَ مِنَ الْعَدْلِ يَا ابْنَ الطُّلَقَاءِ تَخْدِيْرُكَ حَرَائِرَكَ وَ اِمَائَكَ وَ سَوْقُكَ بَنَاتِ رَسُولِ اللّهِ (صلى الله عليه و آله و سلم) سَبَايَا قَدْ هَتَكْتَ سُتُوْرَهُنَّ وَ أَبْدَيْتَ وُجُوْهَهُنَّ يَحْدُوْ بِهِنَّ الْأَعْدَاءُ مِنْ بَلَدٍ إِلٰى بَلَدٍ وَ يَسْتَشْرِفُهُنَّ أَهْلُ الْمَنَاهِلِ وَ الْمَعَاقِلِ وَ يَتَصَفَّحُ وُجُوهَهُنَّ الْقَرِيْبُ وَ الْبَعِيْدُ وَ الدَّنِيُّ وَ الشَّرِيفُ لَيْسَ مَعَهُنَّ مِنْ رِجَالِهِنَّ وَلِيٌّ وَ لَا مِنْ حُمَاتِهِنَّ حَمِيٌّ

*ឈប់សិន ! អ្នកឯងភ្លេចហើយថាអល់ឡោះហ៊្ ﷻ មានព្រះបន្ទូលថា៖ "ចូរពួកបដិសេធសទ្ធាកុំគិតឡើយថា ដែលយើងពន្យារពេលឲ្យពួកគេនោះជាការល្អប្រសើរសម្រាប់ពួកគេ ។ យើងពន្យារពេលឲ្យពួកគេដើម្បីនឹងឲ្យពួកគេសាងបាបកាន់តែច្រើនឡើង ។ ពួកគេនឹងទទួលទណ្ឌកម្មថោកទាប (៣:១៧៨) ។"*

*កូនរបស់ "បុគ្គលដែលគេដោះលែង" អើយ ត្រឹមត្រូវទេដែលអ្នកឯងទុកបណ្ដាស្ត្រីនិងបម្រើអ្នកឯងនៅក្នុងបន្ទប់ (គឺក្រោមការថែរក្សា) តែអ្នកឯងបែរជានាំខ្លួនព្រះរាជបុត្រីព្រះសាស្ដា ﷺ អល់ឡោះហ៊្ ﷻ ជាចំណាប់ឈ្លើយ បករបាំងខ្លួន បើកមុខឲ្យគេឃើញ ត្រូវសត្រូវចាប់បណ្ដើរខ្លួនពីទឹកដីមួយទៅឯទឹកដីមួយ ត្រូវគេមើលនៅកន្លែងដងទឹក ត្រូវពួកបុរសបន្ទាយអ្នកឯងមើល ត្រូវបើកមុខឲ្យមនុស្សទូទៅមើល ជិតឬឆ្ងាយ ដោយខ្សែភ្នែកអាក្រកឬល្អ ពុំមានបុរសត្រកូលខ្លួនឬអាណាព្យាបាលនៅក្បែរទេ ?*

وَ كَيْفَ يُرْتَجٰى مُرَاقَبَةُ مَنْ لَفَظَ فُوْهُ أَكْبَادَ الْأَزْكِيَاءِ وَ نَبَتَ لَحْمُهُ مِنْ دِمَاءِ الشُّهْدَاءِ؟ وَ كَيْفَ لَا يَسْتَبْطِئُ فِي بُغْضِنَا أَهْلَ الْبَيْتِ مَنْ نَظَرَ إِلَيْنَا بِالشَّنَفِ وَ الشَنَآنِ وَ الاِحْنِوَ الْاَضْغَانِ؟ ثُمَّ تَقُوْلُ غَيْرَ مُتَاَثِّمٍ وَ لَا مُسْتَعْظِمٍ

لَأَهَلُّوْا وَ اسْتَهَلُّوْا فَرَحاً

ثُمَّ قَالُوْا يَا يَزِيْدُ لَا تُشَلْ

مُنْتَحِياً عَلٰى ثَنَايَا أَبِيْ عَبْدِ اللّهِ سَيِّدِ شَبَابِ أَهْلِ الْجَنَّةِ تَنْكُتُهَا بِمِخْصَرَتِكَ وَ كَيْفَ لَا

تَقُوْلُ ذٰلِكَ وَ قَدْ نَكَأْتَ الْقَرْحَةَ وَ اسْتَأْصَلْتَ الشَّافَةَ بِإِرَاقَتِكَ دِمَاءَ ذُرِّيَّةِ مُحَمَّدٍ (صلى الله عليه و آله و سلم) وَ نُجُومِ الْأَرْضِ مِنْ آلِ عَبْدِ الْمُطَّلِبِ وَ تَهْتِفُ بِأَشْيَاخِكَ وَ زَعَمْتَ أَنَّكَ تُنَادِيهِمْ فَلَتَرِدَنَّ وَشِيكاً مَوْرِدَهُمْ وَ لَتَوَدَّنَّ أَنَّكَ شُلِلْتَ وَ بُكِمْتَ وَ لَمْ يَكُنْ قُلْتَ مَا قُلْتَ وَ فَعَلْتَ مَا فَعَلْتَ.

*"តើអាចទុកចិត្តបានទេ លើបុគ្គលដែលជាកូនចៅរបស់បុគ្គលមាត់ទំពារ ថ្លើមបុគ្គលបរិសុទ្ធ របស់បុគ្គលដែលមានសាច់ធាត់ធំដោយសារឈាម របស់ទុក្ករបុគ្គល ? តើអាចទុកចិត្តបានទេ លើបុគ្គលដែលមើលមកយើង - អាស្ហុលុល-បៃត៍ عليهم السلام - ដោយខ្សែភ្នែកពោរពេញដោយគំនុំ ដោយទោសៈ ដោយសម្អប់និងចិត្តព្យាបាទនោះ ថាបុគ្គលនោះនឹងមិនស្អប់ខ្ពើមយើង ? ម្យ៉ាងទៀត ដោយមិនដឹងខ្លួនថាខុស ឬចេះថ្លឹងសម្តីខ្លួនទេនោះ អ្នកឯង ថា៖*

*អស់លោកច្បាស់ជាសប្បាយរីករាយអនេក*

*អស់លោកច្បាស់ជានឹងថា៖ "យ៉ាស៊ីដ្ហអ៊ីយ សូមកុំឲ្យដៃអ្នកគាំងឡើយ អ្នកឯងព្រហើន ហ៊ានវាយព្រះឱស្ឋ អាប៊ូ អាប់ឌុលឡោះហ៍ صلوات الله عليه والسلام ព្រះអគ្គមហាប្រមុខរបស់យុវជនឋានសួគ៌ផង ? មែនហើយ ហេតុអ្វីអ្នកឯងមិនហ៊ានធ្វើបែបនេះ ពីព្រោះអ្នកឯងបានធ្វើឲ្យមុខរបួសដែលជិតជាហើយ នោះរើឡើងវិញ ឯធម៌មេត្តាបានបាត់អស់គ្មានសល់ពីក្នុងបេះដូងអ្នកឯង ក្រោយពីបានបង្ហូរឈាមរាជបុត្ររាជនត្តា عليهم السلام របស់មូហាំម៉ាដ្ឋ صلى الله عليه وآله وسلم - សូមអល់ឡោះហ៍ عز وجل ព្រះរាជទានសិរីសួស្តីនិងពរជ័យដល់ព្រះអង្គ صلى الله عليه وآله وسلم - និងព្រះរាជកុលដ្ឋាន عليهم السلام ព្រះអង្គ صلى الله عليه وآله وسلم ដែលជាដួងតារានៅលើផែនដីនេះក្នុងព្រះរាជវង្សរបស់អាប់ឌុល-មត្តត៍លិប ? អ្នកឯងនិយាយអំពីបណ្តាអ្នកប្រៀនប្រដៅអ្នកឯងហាក់ដូចជាអ្នកឯងនិយាយជាមួយពួកគេ ។ បន្តិចទៀតអ្នកឯងនឹងបាននៅជាមួយពួកគេ ។ បន្តិចទៀតអ្នកឯងនឹងចង់ឲ្យខ្លួនអ្នកឯងគាំង នឹងចង់ឲ្យខ្លួនអ្នកឯងគ កុំអាចនិយាយបាននូវអ្វីដែលអ្នកឯងបាននិយាយហើយ កុំអាចធ្វើបាននូវអ្វីដែលអ្នកឯងបានធ្វើហើយ ។*

اَللّٰهُمَّ خُذْ لَنَا بِحَقِّنَا وَ انْتَقِمْ مِمَّنْ ظَلَمَنَا وَ أحْلُلْ غَضَبَكَ بِمَنْ سَفَكَ دِمَاءَنَا وَ قَتَلَ حُمَاتَنَا فَوَ اللّٰهِ مَا فَرَيْتَ إِلَّا جِلْدَكَ وَ لَا جَزَزْتَ إِلَّا لَحْمَكَ وَ لَتَرِدَنَّ عَلٰى رَسُوْلِ اللّٰهِ (صلى الله عليه و آله و سلم) بِمَا تَحَمَّلْتَ مِنْ سَفْكِ دِمَاءِ ذُرِّيَّتِهِ وَ انْتَهَكْتَ مِنْ حُرْمَتِهِ فِي عِتْرَتِهِ وَ لُحْمَتِهِ حَيْثُ يَجْمَعُ اللّٰهُ شَمْلَهُمْ وَ يَلُمُّ شَعَثَهُمْ وَ يَأْخُذُ بِحَقِّهِمْ: "وَ لا تَحْسَبَنَّ الَّذِيْنَ قُتِلُوْا فِي سَبِيْلِ اللّٰهِ أَمْواتاً بَلْ أَحْياءٌ عِنْدَ رَبِّهِمْ يُرْزَقُوْنَ" وَ حَسْبُكَ بِاللّٰهِ حَاكِماً وَ بِمُحَمَّدٍ خَصِيْماً وَ بِجَبْرَئِيْلَ ظَهِيْراً وَ سَيَعْلَمُ مَنْ سَوَّلَ لَكَ وَ مَكَّنَكَ مِنْ رِقَابِ الْمُسْلِمِيْنَ بِئْسَ لِلظَّالِمِيْنَ بَدَلًا وَ أَيُّكُمْ شَرٌّ مَكَاناً وَ أَضْعَفُ جُنْداً.

"អល់ឡោះហ៍ﷻអឺយ សូមព្រះអង្គﷻរឹបអូសយកកម្មសិទ្ធិរបស់អស់ទូលព្រះបង្គំជាខ្ញុំពីក្នុងដៃបុគ្គលនេះ សូមព្រះអង្គﷻសងសឹកអស់បុគ្គលណាដែលសង្កត់សង្កិនអស់ទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គﷻទម្លាក់ព្រះពិរោធព្រះអង្គﷻមកលើបុគ្គលណាដែលបង្ហូរឈាមអស់ទូលព្រះបង្គំជាខ្ញុំ និងឈាមអាណាព្យាបាលរបស់អស់ទូលព្រះបង្គំជាខ្ញុំ! សូមស្បថចំពោះអល់ឡោះហ៍ﷻ អ្នកឯងបានត្រឹមតែដុតស្បែកខ្លួនឯងទេ អ្នកឯងបានត្រឹមតែកាត់សាច់ខ្លួនឯងទេ អ្នកឯងនឹងប្រឈមមុខជាមួយព្រះសាស្ដាﷺអល់ឡោះហ៍ﷻ - សូមអល់ឡោះហ៍ﷻប្រទានសិរីសួស្ដីដល់ព្រះអង្គﷺនិងព្រះរាជកុលដ្ឋានព្រះអង្គﷺ - អ្នកឯងនឹងលីអំពែកឈាមដែលអ្នកឯងបានបង្ហូរ ឈាមរបស់ព្រះរាជបុត្រារាជនត្តារបស់ព្រះអង្គﷺ និងអំពែកសន្ដភាពដែលអ្នកឯងបានជាន់ឈ្លី ពេលអល់ឡោះហ៍ﷻនឹងប្រមូលបុគ្គលទាំងអស់នោះដើម្បីរកយុត្តិធម៌ឲ្យពួកគេ ។ "ចូរអ្នកកុំគិតថា បណ្ដាអ្នកដែលត្រូវសម្លាប់លើមាគ៌ាអល់ឡោះហ៍នោះស្លាប់ឡើយ ។ តែពួកគេនៅរស់ពួកគេបានទទួលការផ្ដត់ផ្គង់ [នៃឋានសួគ៌] ពីព្រះម្ចាស់ពួកគេ (៣:១៦៩) ។" គ្រប់គ្រាន់ណាស់ដែលអល់ឡោះហ៍ﷻជាអ្នកកាត់ក្ដីរវាងអ្នកឯងនិងមូហាំម៉ាដ់ﷺ - សូមអល់ឡោះហ៍ﷻប្រទានសិរីសួស្ដីដល់ព្រះអង្គﷺនិងព្រះរាជកុលដ្ឋានព្រះអង្គﷺ - និងជាគូជំទាស់របស់អ្នកឯង ឯយ៉ីបរ៉អ៊ីលؑជាអ្នកគាំទ្រ[មូហាំម៉ាដ់ﷺ] ។ អស់ទាំងបុគ្គលដែលបានញុះញង់អ្នកឯងឲ្យធ្វើអ្វីដែលអ្នកឯងបានធ្វើ អស់ទាំងបុគ្គលដែលបានឲ្យ

*អំណាចទៅអ្នកឯង ហើយអ្នកឯងបានបំផ្លាញជីវិតមុស្លីមដោយអំណាចនេះ អស់ទាំងបុគ្គលទាំងនោះច្បាស់ជានឹងដឹងថា អវសានរបស់បុគ្គលសង្កត់សង្កិនគេនោះជាអវសានអាក្រក់បែបណាខ្លះ អ្នកណាខ្លះក្នុងចំណោមពួកអ្នកឯងទាំងអស់គ្នានឹងមានលំនៅអាក្រក់បំផុត ហើយនឹងមានជំនួយតិចជាងគេបំផុត ?*

وَ لَئِنْ جَرَتْ عَلَيَّ الدَّوَاهِيْ مُخَاطَبَتَكَ إِنِّي لَأَسْتَصْغِرُ قَدْرَكَ وَ أَسْتَعْظِمُ تَقْرِيْعَكَ وَ أَسْتَكْبِرُ تَوْبِيْخَكَ لٰكِنَّ الْعُيُوْنُ عَبْرَى وَ الصُّدُوْرُ حَرَّى أَلَا فَالْعَجَبُ كُلُّ الْعَجَبِ لِقَتْلِ حِزْبِ اللّٰهِ النُّجَبَاءِ بِحِزْبِ الشَّيْطَانِ الطُّلَقَاءِ فَهٰذِهِ الْأَيْدِيْ تَنْطِفُ مِنْ دِمَائِنَا وَ الْأَفْوَاهُ تَتَحَلَّبُ مِنْ لُحُومِنَا وَ تِلْكَ الْجُثَثُ الطَّوَاهِرُ الزَّوَاكِيْ تَنْتَابُهَا الْعَوَاسِلُ وَ تُعَفِّرُهَا أُمَّهَاتُ الْفَرَاعِلِ وَ لَئِنِ اتَّخَذْتَنَا مَغْنَماً لَتَجِدُنَا وَشِيْكاً مُغْرَماً حِيْنَ لَا تَجِدُ إِلَّا مَا قَدَّمْتَ "وَ مَا رَبُّكَ بِظَلَّامٍ لِلْعَبِيْدِ" فَإِلَى اللّٰهِ الْمُشْتَكٰى وَ عَلَيْهِ الْمُعَوَّلُ.

*"ទោះបីមហន្តរាយបង្ខំឲ្យខ្ញុំនិយាយរកអ្នកឯងក៏ដោយ ខ្ញុំឃើញថាអ្នកឯងពុំមានខ្លឹមសារទេសម្រាប់ខ្ញុំ ការវាយប្រហាររបស់អ្នកឯងខ្លាំង ការបន្ទោសរបស់អ្នកឯងពិបាកអត់ទ្រាំបាន តែភ្នែកសើម ទ្រូងក្ដៅក្រហាយ ។ អ្វីដែលធ្វើឲ្យភ្ញាក់ខ្លាំងបំផុតនោះ គឺបុគ្គលជំនិតរបស់អល់ឡោះហ្ជ៏ត្រូវសម្លាប់ដោយបក្ស "បុគ្គលដែលគេដោះលែង" បក្សស្នេហ៍តួន ។ ដៃទាំងនោះបានបង្ហូរឈាមយើង មាត់ទាំងនោះស៊ីសាច់យើង រីឯអង្គប្រាណរបស់បូជនីយបុគ្គលនិងបុគ្គលបរិសុទ្ធជាចំណីសត្វព្រៃនៃវាលរហោឋាន ហើយត្រូវបំផ្លាញដោយមនុស្សតិរច្ឆាន ។ បើអ្នកឯងទុកយើងជារបស់ដែលយកបានពីសត្រូវ បន្តិចទៀតអ្នកឯងនឹងចាត់ទុកយើងជាគូប្រឆាំងអ្នកឯង ពេលដែលអ្នកឯងនឹងពុំឃើញមានអ្វីឡើយ ក្រៅអំពើដែលដៃអ្នកឯងបានសាង ។ "ព្រះម្ចាស់អ្នកមិនប្រព្រឹត្តអំពើអយុត្តិធម៌លើបាវបម្រើទាំងឡាយរបស់ព្រះអង្គឡើយ (៤១:៤៦) ។" ខ្ញុំត្អូញត្អែរប្ដឹងអល់ឡោះហ្ជ៏ ខ្ញុំទុកកាយថ្វាយចិត្តលើអល់ឡោះហ្ជ៏ ។*

فَكِدْ كَيْدَكَ وَ اسْعَ سَعْيَكَ وَ نَاصِبْ جُهْدَكَ فَوَ اللّٰهِ لَا تَمْحُوَنَّ ذِكْرَنَا وَ لَا تُمِيْتُ وَحْيَنَا وَ لَا

تُدْرِكُ أَمَدَنَا وَ لَا تَرْحَضُ عَنْكَ عَارَهَا وَ هَلْ رَأْيُكَ إِلَّا فَنَدٌ وَ أَيَّامُكَ إِلَّا عَدَدٌ وَ جَمْعُكَ إِلَّا بَدَدٌ يَوْمَ يُنَادِ الْمُنَادِ "أَلَا لَعْنَةُ اللّٰهِ عَلَى الظَّالِمِيْنَ" فَالْحَمْدُ لِلّٰهِ رَبِّ الْعَالَمِيْنَ الَّذِيْ خَتَمَ لِأَوَّلِنَا بِالسَّعَادَةِ وَ لِآخِرِنَا بِالشَّهَادَةِ وَ الرَّحْمَةِ وَ نَسْأَلُ اللّٰهَ أَنْ يُكْمِلَ لَهُمُ الثَّوَابَ وَ يُوْجِبَ لَهُمُ الْمَزِيْدَ وَ يُحْسِنَ عَلَيْنَا الْخِلَافَةَ إِنَّهُ رَحِيْمٌ وَدُوْدٌ وَ حَسْبُنَا اللّٰهُ وَ نِعْمَ الْوَكِيْلُ.

*"ចូរប្រើឧបាយកលដែលអ្នកឯងចង់ប្រើទៅ ចូរធ្វើផែនការក្បត់ទៅ ចូរខិតខំប្រឹងប្រែងទៅ ព្រោះ សូមស្បថចំពោះអល់ឡោះហ៍عزوجل អ្នកឯងមិនអាចលុបបំបាត់ឈ្មោះយើងបានជាដាច់ខាត មិនអាចសម្លាប់វ៉ាហ៊្យី (គឺអ្វីដែលគេបើកឲ្យយើងដឹង) បានជាដាច់ខាត មិនអាចឡើងថ្កានដល់ឋានៈយើងបានជាដាច់ខាត មិនអាចលុបលាងភាពថោកទាបរបស់អ្នកឯងបានជាដាច់ខាត ។ គំនិតអ្នកឯងពុំមែនអ្វីក្រៅពីគំនិតឥតប្រយោជន៍ឡើយ អ្នកឯងជិតដល់ថ្ងៃអវសានហើយ ទ្រព្យអ្នកឯងនឹងឥតប្រយោជន៍ក្នុងថ្ងៃដែលអ្នកប្រកាសនឹងកោះហៅ ។ "បណ្តាសារបស់អល់ឡោះហ៍ធ្លាក់លើជនទុច្ចរិតទាំងឡាយ (១១:១៨) ។" សូមថ្វាយថោមនាការចំពោះអល់ឡោះហ៍عزوجل ព្រះម្ចាស់ពិភពទាំងពួង ព្រះដែលទ្រង់ប្រថាប់ត្រាសុភមង្គលនិងខមាទោសលើជីវិតបក្សពួកយើងមុនៗ ព្រះដែលប្រថាប់ត្រាទុក្ករកម្មនិងព្រះមេត្តាលើបក្សពួកយើងក្រោយៗ ។ យើងតវ៉ាអល់ឡោះហ៍عزوجل សូមឲ្យព្រះអង្គعزوجلព្រះរាជទានរង្វាន់បរិបូរឲ្យពួកគេទាំងនោះ សូមព្រះអង្គعزوجلព្រះរាជទានបន្ថែមឲ្យពួកគេ សូមព្រះអង្គعزوجلព្រះរាជទានរង្វាន់ជាទីគាប់ចិត្តឲ្យយើង ព្រោះព្រះអង្គعزوجلប្រកបដោយព្រះធម៌មេត្តា ព្រះអង្គعزوجلអាណិតអាសូរជាទីបំផុត ព្រះអង្គعزوجلជាអ្នកជំនុំជម្រះឲ្យយើង ព្រះអង្គعزوجلជាអ្នកថែរក្សាការពារប្រសើរបំផុត ។"*

## មតិនានាស្តីអំពីសុន្ទរកថា

សុន្ទរកថានេះជាកិច្ចបង្ហើយការរើបម្រះរបស់អ៊ីម៉ាំអាល់-ហ៊្សៃសេន៍صلوات الله عليه والسلام និងជាពាក្យពេជន៍បដិវត្តន៍ដ៏អស្ចារ្យមួយក្នុងសាសនាអ៊ីស្លាម ។ អាស្រ័យសម្តីប្រកបដោយឥទ្ធិពលទាំងនេះ ព្រះនាងស៊្សៃណាប់سلام الله عليهاបានរំលំលទ្ធិផ្តាច់ការរបស់យ៉ាស៊ីដ្ឋ បានធ្វើឲ្យយ៉ាស៊ីដ្ឋនិងអស់បុគ្គលដែលបានបើកដៃ

ឲ្យបុគ្គលរូបនេះឡើងកាន់អំណាចនោះ អាម៉ាស់មុខនិងខូចកិត្តិយស។ ស្ហៃខ៍ មូហ៊ាំម៉ាដ់ ហ៊្វូសែន៍ កាស្ហ៊ីហ្វបានថ្លែងអំពីសុន្ទរថានេះថា៖ "តើមានជក់ជាងគំនូរជំនាញដាច់គេ ឬស្លាបប៉ាកកាអ្នកនិពន្ធដ៏មានទេពកោសល្យដាច់គេណាមួយអាចបរិយាយភាពក្រអឺតក្រទម មោទនភាពនិងសេចក្តីរីករាយហួសប្រមាណរបស់យ៉ាស៊ីដ្ធបានទេ ដែលបានបញ្ចុះបញ្ចូលពិភពលោកក្រោមអំណាចខ្លួន ដែលគ្រេកគ្រអាលក្នុងការច្បាំងសង្ហាតចង់បាននោះ គឺបរិយាយដោយវិធីប្រសើរជាង ដោយវិធីដែលមានប្រសិទ្ធិភាពជាងសម្តីព្រះនាងស៊្សៃណាប់عليهم السلامបរិយាយនោះ នៅក្នុងសុន្ទរកាថានេះ? តើមានអ្នកណាមួយអាចប្រកែកពាក្យអះអាងរបស់គូប្រឆាំងដោយរបៀបដូចនេះដែរបានទេ ដែលពោរពេញដោយមនោសញ្ចេតនា ពោរពេញដោយភ័ស្តុតាង ព្រមទាំងពោរពេញដោយការស្តីបន្ទោសនិងការចាប់ពិរុទ្ធ? លើសពីនេះទៀត ហាក់ដូចជាពាក្យស្តីបន្ទោសរបស់ព្រះនាងسلام الله عليهاនៅមិនទាន់គ្រប់គ្រាន់នៅឡើយ ព្រះនាងស៊្សៃណាប់سلام الله عليهاបានបង្ហាញភ័ស្តុតាង នៅពីមុខបុគ្គលតិរច្ឆាននិងបរិវារទាំងអស់ អំពីអវសានអប្រិយដែលមិនអាចចៀសរួចរបស់វិរុទ្ធបុគ្គល និងអវសានជាទីគាប់ចិត្តរបស់បុគ្គលត្រឹមត្រូវ។ ព្រះនាងسلام الله عليهاបានបង្ហាញឲ្យយ៉ាស៊ីដ្ធឃើញភាពអន់ថយ ភាពថោកទាប ភាពអាក្រក់និងភាពអាម៉ាស់ពិតៗរបស់ខ្លួន ដោយប្រើសម្តីក្លាហាន សម្តីអង់អាចមោះមុត។"[240]

លោកបណ្ឌិត តៅហ្វិក្វ ហ្វាកៃគី បានថ្លែងថា៖ "សូមចូលរួមជាមួយខ្ញុំដើម្បីពិចារណាសុន្ទរកថានេះដែលប្រកបដោយអត្ថន័យទូលំទូលាយ ដែលមានគ្រប់វោហារសិល្ប ដែលមានរចនាបថសិល្បៈនៃការថ្លែងសុន្ទរកថាដែលមានការសម្តែងឲ្យឃើញនូវមនោសញ្ចេតនា ដែលមានគតិសាទរដែលមានអានុភាពក្នុងការថ្លែងអះអាង ដែលមានអំណាចការពារសេរីភាពនិងជំនឿ ដោយប្រើមធ្យោបាយត្រង់ៗដែលមុតជាងមុខដាវទៅទៀត។ សម្រាប់យ៉ាស៊ីដ្ធ ឈានទៅរកចង្កូមពស់វែក ឬទៅរកមុខលំពែង

240 សូមមើលសៀវភៅរបស់លោក មូហ៊ាំម៉ាដ់ ហ៊្វូសែន៍ កាស្ហ៊ីហ្វ អាល់-គ៊ីត៏អ៊ុ៍ (محمد حسين كاشِف الغِطاء) *អាល់-ស៊ីយ៉ាសាស៊ុ អាល់-ហ៊្វូសៃនីយ៉ាស៊ុ* ទំព័រ ៣០។

ស្រួចរលែមនោះ ងាយស្រួលអត់ទ្រាំជាងឮពាក្យពេជន៍ទាំងនេះដែលវាយតប់មុខក្រាស់ឥតអៀនខ្មាស់របស់ខ្លួន នៅក្នុងលំនៅដ្ឋានរបស់ខ្លួនកណ្ដាលរាជធានីនៃរដ្ឋខុសច្បាប់ នៃរដ្ឋអំណាចផ្ដាច់ការរបស់ខ្លួន ។ ពេញសម័យកាល សុន្ទរកថាប្រវត្តិសាស្ត្រ ប្រកបដោយឥទ្ធិពលខ្លាំងនេះបានពង្រាយស្មារតីក្លៀវក្លាដែលរកប្រដូចគ្មាន បានពង្រាយសេចក្ដីក្លាហានខុសធម្មតា បានពង្រាយឧត្ដមគតិខ្ពង់ខ្ពស់របស់ព្រះនាងស្ហៃណាប់ﷺ ។ ទីបំផុត វាជាឯកសារឥតរលុបបាត់បានដែលស្រែកដាក់មុខទុរជនទាំងឡាយដែលកាន់អំណាចផ្ដាច់ការក្នុងជំនាន់នានា ។"[241]

## មាតិកាសុន្ទរកថា

ពាក្យពេជន៍ដ៏អស្ចារ្យរបស់ព្រះនាងស្ហៃណាប់ﷺ ជាការវាតការរើបម្រះនាការបាឡូអ៊ុំនិងជាការបង្ហាញតម្លៃ និងគោលដៅនៃការរើបម្រះនេះ ។ យើងនឹងស្ដីអំពីគោលដៅ ដែលអាចសម្រេចបានដោយសារពាក្យពេជន៍នេះគឺៈ

១) ព្រះនាងស្ហៃណាប់ﷺស្ដីអំពីសេចក្ដីសោមនស្សមិនត្រឹមត្រូវ របស់យ៉ាស៊ីដ្ធដែលគិតថាខ្លួនជាអ្នកឈ្នះនៅក្នុងការប្រយុទ្ធគ្នានោះ ។ ព្រះនាងﷺបានបើកឲ្យឃើញការពិតថា ទ័ពធំជាងគេរបស់ខ្លួននោះមិនបិតថេរទេ ថាអល់ឡោះហ៍ﷻ នឹងឲ្យបណ្ដាអ្នកគ្មានសទ្ធាសោយសុខក្នុងលោកនេះ ដើម្បីនឹងឲ្យបាបពួកគេកើនឡើង ដូច្នេះ ពួកគេនឹងទទួលទណ្ឌកម្មដ៏ឈឺចាប់នាបរលោក (គឺថ្ងៃរស់ពីស្លាប់វិញ) ។

២) ព្រះនាងﷺបានថ្កោលទោសយ៉ាស៊ីដ្ធ ដែលចាប់ព្រះហ្វារីមព្រះរាជកុលដ្ឋានព្រះសាស្ដាﷺជាចំណាប់សឹក ។ ព្រះសាស្ដាﷺជាអ្នកដោះលែងយ៉ាស៊ីដ្ធនិងគ្រួសារគ្មានសទ្ធារបស់គាត់ឲ្យមានសេរីភាព កាលពួកគេទាំងនេះត្រូវទ័ពអ៊ីស្លាមចាប់ខ្លួនជាឈ្លើយសឹក ។ គួរតែយ៉ាស៊ីដ្ធអរព្រះគុណព្រះសាស្ដាﷺដែលបានសង្គ្រោះខ្លួនឲ្យរួចផុតពីទាសៈភាព តែ

---

[241] សូមមើលសៀវភៅរបស់លោក បាក្ហៀរ ស្ហារីហ្វ អាល់-ក៏ុរ៉ស្ហី (شريف القرشي) *ហ្វាយ៉ាស្ហ អាល់-អ៊ីមុាំ អាល់-ហ៊្សៃសែន៍ (حياة الإمام الحسين)* ក្បាលទី ៣ ទំព័រ ៣៨១ ។

យ៉ាស៊ីដ្ធបែរជាតបស្នងព្រះរាជវង្សព្រះអង្គﷺវិញយ៉ាងអាក្រក់បំផុត ។
៣) ព្រះនាងعليها السلامថ្លែងដល់មូលហេតុតំណពូជ មូលហេតុចំណេះដឹងនិងមូលហេតុផ្លូវចិត្ត នៅពីក្រោយការកាប់សម្លាប់ព្រះរាជវង្សព្រះសាស្ដាﷺ ដែលយ៉ាស៊ីដ្ធបានប្រព្រឹត្ត ។ ឧទាហរណ៍ ព្រះនាងعليها السلامបានថ្លែងដល់ជីដូនរបស់យ៉ាស៊ីដ្ធឈ្មោះ ហ៊ិនដ៍ ដែលបានទំពារថ្លើមរបស់ហាំស្សាស់ ព្រោះតែនារីរូបនេះមានចិត្តព្យាបាទឥតព្រំដែនទៅលើព្រះសាស្ដាﷺ និងត្រកូលហាស្ហ៊ីម ។ ព្រះនាងعليها السلامបានថ្លែងដល់ជីតារបស់យ៉ាស៊ីដ្ធដែរឈ្មោះ អាប៊ូស៊ុហ្វយ៉ាន ដែលជាមេដឹកនាំរបស់សពួកសត្រូវអ៊ីស្លាម ដែលបានដឹកនាំសង្គ្រាមទល់នឹងព្រះសាស្ដាﷺនិងព្រះបេសកកម្ម ។ មិនភ្លេចឪពុករបស់យ៉ាស៊ីដ្ធទេ ព្រះនាងស៊្រៃណាប់عليها السلامបានថ្លែងដល់មូអាវីយ៉ាស់ដែលបានសម្លាប់មុស្លីមស្លូតត្រង់ ហើយបានបំពារបំពានអ្វីដែលអល់ឡោះហ្វ៍عز وجلបានដាក់បញ្ញាឲ្យគោរពសក្ការៈ ។
៤) ព្រះនាងعليها السلامជំទាស់កំណាព្យដែលយ៉ាស៊ីដ្ធសូត្រ ។ នៅក្នុងកំណាព្យនោះ យ៉ាស៊ីដ្ធសូមឲ្យដូនតាខ្លួន - ដែលត្រូវអ៊ីម៉ាំអាលីصلوات الله عليه والسلامសម្លាប់ក្នុងទំនាស់ដែលពួកគេនោះបានបង្កទៅលើព្រះសាស្ដាﷺ ព្រមទាំងយុទ្ធជនមុស្លីមឯទៀតដែរ - ធ្វើសាក្សីឲ្យខ្លួនដែលបានសងសឹកលើព្រះសាស្ដាﷺ នោះ ។ ព្រះនាងعليها السلامបានអះអាងយ៉ាងក្លាហានដាក់យ៉ាស៊ីដ្ធថាយ៉ាស៊ីដ្ធនឹងជួបប្រទះវាសនាដូចដូនតាត្រូវណ្ដាសារបស់ខ្លួនដែរ ។
៥) ព្រះនាងعليها السلامឆ្លុះបញ្ចាំងទៅលើចំណុចសំខាន់មួយគឺ ដោយសម្លាប់អ៊ីម៉ាំអាល់-ហ៊្វសៃន៍صلوات الله عليه والسلام ព្រះរាជវង្សនិងបណ្ដាសាវកបរិសុទ្ធរបស់ព្រះអង្គصلوات الله عليه والسلام នោះ បុគ្គលកាន់អំណាចផ្ដាច់ការបានសម្លាប់ខ្លួនឯង មិនបានសម្លាប់អ្នកណាផ្សេងទេ ។ វិញ្ញាណរបស់ទុក្ករបុគ្គលជាវិញ្ញាណបរិសុទ្ធ ជាវិញ្ញាណរស់ ជាវិញ្ញាណអចិន្ត្រៃយ៍ ជាវិញ្ញាណឡោមព័ទ្ធដោយរស្មីនៃភាពរុងរឿង ។ អបយសនិងវិនាសខាតបង់បានតែលើយ៉ាស៊ីដ្ធទេ ។
៦) ព្រះនាងថ្លែងដល់អស់បុគ្គលដែលបានត្រាយផ្លូវឲ្យយ៉ាស៊ីដ្ធ ដើម្បីឲ្យកាន់មុខតំណែងនេះ ដោយប្រើពាក្យរិះគន់ចាប់កំហុសពួកគេព្រោះព្រះនាងរាប់បញ្ចូលពួកគេជាមួយយ៉ាស៊ីដ្ធ ។ គួរសិក្សាចំណុចនេះដោយយក

ចិត្តទុកដាក់បំផុត ។
៧) ព្រះនាងបានថ្លែងដល់ឋានៈខ្ពង់ខ្ពស់ និងកិត្តិយសរបស់ព្រះនាងسلام الله عليها ដែលមិនអាចឈោងដល់ ជាមធ្យោបាយមួយទៀតដើម្បីបញ្ជាក់ឲ្យឃើញថាបុគ្គលកាន់អំណាចផ្តាច់ការនោះតូចទាបបំផុត ។ ទោះបីព្រះនាងسلام الله عليهاរងគ្រោះកាចគ្រប់មុខដែលធ្វើឲ្យព្រះនាងខ្សោយក៏ដោយ ក៏ព្រះនាងسلام الله عليهاនៅតែសម្តែងឫទ្ធពលឧត្តមកំពូល ដោយស្តីបន្ទោសបុគ្គលកាន់អំណាចផ្តាច់ការយ៉ាងខ្លាំង ធ្វើឲ្យបុគ្គលនោះពុំអាចឆ្លើយតបវិញបានឡើយ ។
៨) ព្រះនាងបានបង្ហាញឲ្យឃើញថា ការខឹតខំប្រឹងប្រែងរបស់យ៉ាស៊ីដ្ទដើម្បីកម្ចាត់ឈ្មោះល្អអមតៈរបស់អាស្ហ់លុល-បៃត៍عليهم السلامនោះ រមែងតែបរាជ័យពីព្រោះអាស្ហ់លុល-បៃត៍عليهم السلامជាតំណាងខាងត្រូវ ដែលនឹងឈ្នះជាមិនខាន ។

ដូច្នេះ ចាប់តាំងពីពេលនោះមក គេបានបញ្ជាក់ឲ្យឃើញថាអ៊ីម៉ាំអាល់-ហ៊្វូសែន៍صلوات الله عليه والسلامនិងបក្សព្រះអង្គصلوات الله عليه والسلامជាអ្នកឈ្នះ រីឯយ៉ាស៊ីដ្ទនិងបក្សខ្លួនជាខាងចាញ់ជានិច្ច ។ ទោះជាយ៉ាងណាក៏ដោយ ពាក្យពេជន៍ព្រះនាងស្សៃណាប់سلام الله عليهاមាននូវមេរៀនសន្ធឹកសន្ធាប់ មិនអាចលើកយកមកអធិប្បាយទាំងអស់នៅក្នុងវគ្គសិក្សាដ៏ខ្លីនេះបានទេ ។ គ្រាន់តែនិយាយបានថា ពាក្យពេជន៍ទាំងនេះជាស្នៀតមរណៈដែលកម្ទេចរជ្ជអ៊ូម៉ៃយ៉ាស្ហ់ឲ្យវិនាសអន្តរធាន ។

ដោយឃើញថាមោទនភាព និងភាពក្រអឺតក្រទមរបស់ខ្លួនរលំបះជើង យ៉ាស៊ីដ្ទមិនអាចរកពាក្យអ្វីឆ្លើយតបបានទេ វៀរលែងតែថ្លែងកំណាព្យមួយឃ្លាដែលពុំមានខ្លឹមសារពាក់ព័ន្ធនឹងរឿងនោះឡើយ ។ ម្យ៉ាងទៀត បរិយាកាសនយោបាយស្រអាប់បកមកលើខ្លួនឯងវិញ ដែលកំពុងតែស្ថិតនៅក្នុងអាការស្រឡាំងកាំង ភាំងស្មារតីដោយសារព្រះនាងស្សៃណាប់سلام الله عليهاបានធ្វើឲ្យខ្លួនធ្លាក់ទៅក្នុងស្ថានការណ៍អៀនខ្មាស់ ធ្វើឲ្យខ្លួនគ្មានសមត្ថភាពធ្វើអ្វីបានឡើយ ។ សព្វមួយដង យ៉ាស៊ីដ្ទខំប្រឹងឆ្លើយដោះសាបទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្តនោះ ច្រើនលើកទៀត យ៉ាស៊ីដ្ទខំប្រឹងធ្វើការប្រៀបធៀបរវាងអ៊ីម៉ាំصلوات الله عليه والسلامនិងខ្លួនឯងតែម្តង ។

## ព្រះនាងស្សៃណាប់سلام الله عليهاនិងបុរសជាតិស៊ីរី

បុរសជាតិស៊ីរីម្នាក់ដែលបានចូលរួមក្នុងអង្គប្រជុំក្នុងវាំងយ៉ាស៊ីដ្ សម្លឹងមើលព្រះនាងហ្វាទីម៉ាស្ ព្រះរាជបុត្រីរបស់អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلامនៅក្នុងចំណាប់ឈ្លើយ ហើយបានប្រាប់យ៉ាស៊ីដ្ថា៖ "សូមឲ្យក្មេងស្រីនេះមកខ្ញុំ ជាបម្រើរបស់ខ្ញុំ ។" ពេលបានឮសម្ដីទ្រគោះខ្លាំងនេះ ព្រះនាងញ័រខ្លួនតោងដៃអាវព្រះបិតុច្ឆា ។

ព្រះនាងស្សៃណាប់سلام الله عليهاបានស្រែកដាក់បុរសជាតិស៊ីរីនោះថា៖ "អ្នកឯងបុគ្គលថោកទាប ច្រឡំធំហើយ ។ អ្នកឯងឬមេអ្នកឯង (ពោលគឺ យ៉ាស៊ីដ្) មិនអាចធ្វើដូច្នេះបានទេ ។" សម្ដីនេះធ្វើឲ្យយ៉ាស៊ីដ្ច្រឡោតថា៖ "យើងអាចធ្វើបាន បើយើងចង់ ។" ព្រះនាងស្សៃណាប់سلام الله عليهاបានតបថា៖ "ទេ អ្នកឯងមិនអាចធ្វើដូច្នេះបានជាដាច់ខាត វៀរលែងតែអ្នកឯងបោះបង់ចោលសាសនាយើង យកសាសនាមួយផ្សេងទៀតជាសាសនាអ្នកឯង ។" យ៉ាស៊ីដ្យល់ឃើញថា សម្ដីដែលព្រះនាងស្សៃណាប់سلام الله عليهاស្រែកដាក់ខមុខខ្លួននោះជាការប្រមាថធ្ងន់បំផុត ដូច្នេះបុរសរូបនេះបានស្រែកដាក់ព្រះនាងسلام الله عليهاថា៖ "ម្ដេចនាងឯងហ៊ាននិយាយសម្ដីនេះដាក់មុខយើង ? ឪពុកនាងឯងនិងបងនាងឯងទេដែលបោះបង់ចោលសាសនានោះ !"

មិនអើពើនឹងអាជ្ញាធររបស់បុរសកាន់អំណាចផ្ដាច់ការទេ មិនខ្លាចត្រូវទទួលទោសទេ ព្រះនាងស្សៃណាប់سلام الله عليهاឆ្លើយតបវិញយ៉ាងអង់អាចថា៖ "បើអ្នកឯងពិតជាមុស្លីមមែននោះ ដោយសារតែព្រះសាសនារបស់អល់ឡោះហ្ ៍عز وجل និងសាសនារបស់ព្រះបិតាខ្ញុំនិងព្រះអយ្យកោខ្ញុំទេដែលអ្នកឯងនិងដូនតាអ្នកឯងបានទទួលការដឹកនាំទៅរកផ្លូវល្អនោះ ។"

ជាមួយពាក្យពេជន៍ទាំងនេះ ព្រះនាងស្សៃណាប់سلام الله عليهاបានបើកមុខបុរសកាន់អំណាចផ្ដាច់ការដែលបានអះអាចថា អ៊ីម៉ាំអាល់-ហ៊្វសែន៍صلوات الله عليه والسلامនិងព្រះរាជវង្សព្រះអង្គصلوات الله عليه والسلامក្បត់សាសនា ។ លទ្ធផលចុងក្រោយ ប្រជារាស្ត្រប្រទេសស៊ីរីបានដឹងថា ចំណាប់ឈ្លើយទាំងនេះជាព្រះរាជវង្សរបស់ព្រះសាស្ដាصلى الله عليه وآله وسلم ដែលច្រើនអាយ៉ាស្ព្រះគម្ពីរគួរអានមកព្រះម្ចាស់عز وجلនោះបានចែង

ដល់ រីឯយ៉ាស៊ីដ្ធវិញមិនលើសពីបុគ្គលបោកប្រាស់ឥតសទ្ធានោះទេ ។ មិនមានពាក្យអ្វីឆ្លើយតបព្រះនាងស្ញៃណាប់عليهم السلامវិញទេ យ៉ាស៊ីដ្ធបានត្រឹមតែថា៖ "សត្រូវអល់ឡោះហ្វ៍ នាងឯងនិយាយកុហក !" ព្រះនាងسلام الله عليهاបានតបវិញថា៖ "អ្នកឯងកាន់កាប់លើគេ ! អ្នកឯងអាចជេរប្រមាថ[អ្នកណាក៏បាន] ដោយអយុត្តិធម៌ អ្នកឯងអាចបង្រ្កាបអ្នកណាក៏បានដោយអំណាចអ្នកឯង ។"

កំហឹងបុរសកាន់អំណាចផ្តាច់ការបានអន់ថយ ហើយបានឱនក្បាល ។ ទន្ទឹមនឹងពេលនោះ បុរសជាតិស៊ីរីបានស្នើសូមម្តងទៀត តែយ៉ាស៊ីដ្ធបានស្រែកដាក់បុរសនោះថា៖ "សូមអល់ឡោះហ្វ៍عز وجلឲ្យលោកឯងស្លាប់យ៉ាងទាន់ហាន់ !" ដូច្នេះ ព្រះនាងស្ញៃណាប់سلام الله عليهاបានអំណាចនិងឆន្ទះមកវិញ ដែលជាកេរមរតកតមកពីព្រះបុព្វបុរសព្រះនាងسلام الله عليها ដើម្បីតទល់នឹងបុរសកាន់អំណាចផ្តាច់ការ ហើយឈ្នះបុគ្គលនោះ ។

លោកអ្នកនិពន្ធបានឲ្យដឹងថា៖ "ទោះបីព្រះនាងسلام الله عليهاខ្សោយ នៅក្នុងសភាពចំណាប់ឈ្លើយក៏ដោយ ក៏ព្រះនាងស្ញៃណាប់سلام الله عليهاបានទទួលជ័យជំនះផ្តាច់ព្រ័ត្រដំបូងលើបុគ្គលកាន់អំណាចផ្តាច់ការដែរ ដែលមានអំណាចឥទ្ធិពលកំពូល ។ លើសពីមួយដង ព្រះនាងسلام الله عليهاបានធ្វើឲ្យឃើញថាយ៉ាស៊ីដ្ធខុស បានប្រកាសចំពោះមុខមហាជនថាយ៉ាស៊ីដ្ធអវិជ្ជា ហើយខ្វះការចេះដឹងផ្នែកសាសនា ពីព្រោះ យោលតាមច្បាប់អ៊ីស្លាម មិនត្រឹមត្រូវទេដែលចាត់ទុកស្ត្រីមុស្លីមជាចំណាប់ឈ្លើយ ឬប្រព្រឹត្តបែបនេះទៅលើស្ត្រីក្នុងសង្រ្គាម ។"[242]

ទោះជាយ៉ាងណាក៏ដោយ គួរទុកសំណូមរបស់បុរសជាតិស៊ីរីជាអត្ថបទតម្រាយមុខវែងមួយក្នុងការរិះគន់ និងក្នុងការស្តីបន្ទោសទៅលើរូបយ៉ាស៊ីដ្ធ ។ ព្រឹត្តិការណ៍នេះបានធ្វើឲ្យប្រជារាស្ត្រប្រទេសស៊ីរីចាប់ផ្តើមយល់ស្ថានការណ៍ពិត ។ បុរសជាតិស៊ីរីទំនងជាមិនមែនមនុស្សមិនវាងវៃនោះទេ ជាពិសេសបន្ទាប់ពីគាត់បានឮចម្លើយព្រះនាងស្ញៃណាប់سلام الله عليهاនៅ

---

[242] សូមមើលសៀវភៅរបស់លោក បាគៀរ ស្ហារីហ្វ អាល់-គ៏ូរ៉ស្ហី (شريف القرشي) *ហាយ៉ាស្ហ អាល់-អ៊ីម៉ាំ អាល់-ហាសាន់ (حياة الامام الحسن)* ក្បាលទី ៣ ទំព័រ ៣៩០ ។

ចំពោះមុខមហាជនដែលសម្ដែងឲ្យឃើញថា យ៉ាស៊ីដ្ឋត្រូវចេញពីសាសនាអ៊ីស្លាម បើធ្វើតាមសំណូមពររបស់បុរសជាតិស៊ីរី ។ ព្រឹត្តិការណ៍នេះបង្ហាញឲ្យឃើញថាបុរសរូបនេះគ្រាន់តែចង់បំបាក់មុខយ៉ាស៊ីដ្ឋទេ ។

## កាន់ទុក្ខអ៊ីម៉ាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام

បណ្ដាស្ត្រីព្រះរាជវង្សព្រះសាស្ដា صلى الله عليه وآله وسلم បានសូមទីសម្នាក់ពីបុរសកាន់អំណាចផ្ដាច់ការ ដើម្បីនឹងអាចធ្វើពិធីកាន់ទុក្ខអ៊ីម៉ាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ព្រោះពីមុន ព្រះនាងទាំងអស់គ្នាពុំអាចសម្ដែងទុក្ខសោករបស់ខ្លួនបានទេ នៅចំពោះមុខឆ្មាំរបស់យ៉ាស៊ីដ្ឋ បើបង្ហាញទុក្ខសោកឲ្យគេឃើញនឹងត្រូវវាយដោយរំពាត់ខ្សែតីនិងជេរប្រទេច ។ អំពីរឿងនេះ អ៊ីម៉ាំអាលី ស្ស៊ែន៍ អាល់-អាប៊ីឌីន صلوات الله عليه والسلام មានវចនៈថា៖ "លំពែងឆ្មាំនឹងធ្លាក់មកលើក្បាលអ្នកណាមួយ ក្នុងចំណោមពួកយើង ដែលហ៊ានស្រក់ទឹកភ្នែក ទោះជាមួយតំណក់ក៏ដោយ ។"

យ៉ាស៊ីដ្ឋក៏បង្ខំចិត្តឆ្លើយតបសំណូមពរបណ្ដាស្ត្រី ។ ទាំងអស់គ្នាក៏បានស្លៀកពាក់ខ្មៅ កាន់ទុក្ខ យំសោកស្ដាយអ៊ីម៉ាំ صلوات الله عليه والسلام និងអស់ទុក្ករបុគ្គលប្រាំពីរថ្ងៃឥតឈប់ ។

# ត្រឡប់មកម៉ាឌីណាស់វិញ

ដោយបានឃើញពាក្យពេជន៍របស់អ៊ីម៉ាំស្ស៊ែន៍ អាល់-អាប៊ីឌីន صلوات الله عليه والسلام និងព្រះនាងស្ស៊ៃណាប់ سلام الله عليها មានឥទ្ធិពល យ៉ាស៊ីដ្ឋបានប្រុងប្រយ័តជាមុនក្រែងលោមានការបះបោរ ឬយ៉ាងហោចណាស់ក្រែងលោមានចលាចលនៅក្នុងរាជធានីនៃរដ្ឋរបស់ខ្លួន ។ ហេតុដូច្នេះ យ៉ាស៊ីដ្ឋបានសម្រេចចិត្តបញ្ជូនព្រះរាជវង្សព្រះសាស្ដា صلى الله عليه وآله وسلم ចេញឆ្ងាយពីទីក្រុងដាម៉ាស់ ទៅកាន់ម៉ាឌីណាស់ ស្រុកកំណើតវិញ ។ យ៉ាស៊ីដ្ឋបានប្រជុំព្រះរាជកុលដ្ឋានព្រះសាស្ដា صلى الله عليه وآله وسلم នៅក្នុងវាំង បានបាចប្រាក់យ៉ាងច្រើនទៅលើកម្រាលព្រំសូត្រ ជាថ្លៃជម្ងឺចិត្តសងទុក្ករកម្មអ៊ីម៉ាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ព្រះរាជវង្សព្រះអង្គ صلوات الله عليه والسلام និងបណ្ដាសាវកព្រះអង្គ صلوات الله عليه والسلام ។ ព្រឹត្តិការណ៍នេះបានធ្វើឲ្យព្រះនាង

ទាំងអស់ក្រោធខ្លាំងណាស់ ទើបទាំងអស់គ្នាស្រដីដោយឈឺចាប់ ។

ព្រះនាងស៊ៃណាប់سلام الله عليهاមានវចនៈថា៖ "អ្នកឯងគ្មានអៀនខ្មាស់ មានអំនួតគឃរមែន ! អ្នកឯងបានសម្លាប់ព្រះរៀមនិងសមាជិកព្រះរាជវង្សយើងហើយ អ្នកឯងចង់ឲ្យយើងទទួលប្រាក់សងជម្ងឺចិត្ត !" ព្រះនាងស៊ូកៃណាស៎មានវចនៈថា៖ "យើងមិនដែលឃើញអ្នកណាគ្មានមេត្តាករុណា យើងមិនដែលឃើញមនុស្សក្បត់សាសនា មនុស្សពហុទេពនិយមណាមួយដែលអាក្រក់ជាងអ្នកឯងទេ... ។ល ។"

បុរសកាន់អំណាចផ្ដាច់ការ ដែលគិតថាអាចបង្ក្រាបអាស្ល់លុល-បៃត៍បានដោយឲ្យប្រាក់ឬវត្ថុមិនបិតថេរឯទៀតនោះ បានទទួលបរាជ័យក្នុងការដាក់ព្រះរាជកុលដ្ឋានព្រះសាស្ដាصلى الله عليه وآله وسلمនៅក្រោមអំណាចខ្លួន ព្រោះតែខ្លួនមិនជឿព្រះបន្ទូលអល់ឡោះហ្ទ៍عز وجلដែលបានបើកដឹងនោះថា៖ *"សមាជិកនៃគេហដ្ឋាន[របស់សាស្ដា]អឺយ អល់ឡោះហ្ទ៍គ្រាន់តែប្រាថ្នាឲ្យពួកអ្នកចាកផុតពីមន្ទិល ហើយព្រះអង្គប្រាថ្នាសំអាតពួកអ្នកឲ្យបរិសុទ្ធជ្រះស្អាតតែប៉ុណ្ណោះទេ (៣៣:៣៣) ។"*

ដូច្នេះ យ៉ាស៊ីដ្ទបានដាក់បញ្ជាឲ្យអាល់-នុអ៊ុម៉ាន អ៊ីបនូ បាស្សៀរជូនដំណើរព្រះរាជវង្សព្រះសាស្ដាصلى الله عليه وآله وسلمទៅកាន់ម៉ាឌីណាស្ទ ឲ្យមើលថែរក្សាព្រះអង្គទាំងអស់តាមផ្លូវ ។[243] ហើយយ៉ាស៊ីដ្ទបានសម្រេចឲ្យចេញដំណើរពេលយប់ដើម្បីនឹងចៀសវាងការបង្កចលាចលឬការបះបោរជាមុន ។

អាុប់ដ្ទាល់-ម៉ាលិក អាល់-សាទ្បាមី ដោយអនុវត្តិតាមបញ្ជារបស់ អ៊ុម៉ារ អ៊ីបនូ សាអាុដ្ទ បានផ្ញើដំណឹងអ៊ីម៉ាំអាល់-ហ៊្ទុសៃន៍صلوات الله عليه والسلامធ្វើទុក្ករកម្មដោយបូជាព្រះជន្មទៅម៉ាឌីណាស្ទ មុនចំណាប់បានទៅដល់ ។[244] ដំណឹងនេះផ្ញើ

---

[243] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាល់-អាស្សៀរ *អាល់-តារិក្វ* ក្បាលទី ៣ ទំព័រ ៣០០ ។

[244] សេចក្ដីរាយការណ៍នេះ ត្រូវបានដកស្រង់មកពីក្នុងសៀវភៅរបស់លោក បាក្វៀរ ស្ហារីហ្វ អាល់-ក៊្វរ៉ស្ហី (شريف القرشي) ដែលមានចំណងជើងថា *អាល់-សៃយីដ្ទាស្ទ ស៊ៃណាប់ ។* តែសេចក្ដីរាយការណ៍នេះអាចផ្ទុយពីសេចក្ដីរាយការណ៍ឯទៀត ។

ឲ្យអ្នកកាន់ក្តាប់ម៉ាឌីណាស្ញូរីករាយប៉ុណ្ណា វាធ្វើឲ្យអ្នកស្រុកក្រៀមក្រំប៉ុណ្ណោះដែរ ។ ពួកគេមិនអាចទប់ខ្លួនបានទេ សម្លេងទួញយំរបស់អ្នកស្រុកបានលាន់ឮពេញស្រុក ។

បន្ទាប់មក អភិបាលក្រុងម៉ាឌីណាស្ញូបានឡើងលើវេទិកាម៉ាស់យ៊ិដព្រះសាស្តា صلى الله عليه وآله وسلم បានប្រកាសសេចក្តីត្រេកអរនិងសេចក្តីពេញចិត្តលើទុក្ករកម្មអ៊ីម៉ាំ صلوات الله عليه والسلام និងលើគំនរទុក្ខបក្សព្រះអង្គ صلوات الله عليه والسلام ។ អាុប់ឌុលឡោះហ្ន៍ អ៊ីបនូ អាល់-សាអ៊ីប បានរិះគន់មេកាន់ក្តាប់ថា៖ "បើហ្វាទីម៉ាស្ញូ سلام الله عليها នៅរស់ប្រាកដជាព្រះនាង سلام الله عليها នឹងយំស្តាយបុត្រព្រះនាង سلام الله عليها ។"[245] អភិបាលបានស្រែកដាក់លោកវិញដោយសម្តីគ្មានន័យ ។[246]

ពួកហ្ហាស៊្ហីមយំស្រែក សោកស្តាយណាអាព្យាបាលខ្លួនដែលបានបូជាជីវិត ។ ពួកគេធ្វើពិធីកាន់ទុក្ខក្នុងឱកាសនោះ ។ អាុប់ឌុលឡោះហ្ន៍ អ៊ីបនូ យ៉ាក់ហ្វារ៍ ព្រះស្វាមីរបស់ព្រះនាងស៊ៃណាប់ سلام الله عليها បានរៀបចំពិធីបុណ្យព្រះរាជសព ។ ប្រជារាស្ត្របានចូលរួមក្នុងពិធីបុណ្យព្រះរាជសពនេះដើម្បីជួយរំលែកទុក្ខ ។

បន្ទាប់មក យ៉ាស៊ីដបានបញ្ជូនព្រះសិរអ៊ីម៉ាំអាល់-ហ៊្វសៃន៍ صلوات الله عليه والسلام ទៅម៉ាឌីណាស្ញូដើម្បីបន្លាច បំភ័យប្រជារាស្ត្រស្រុកនេះ ។ អភិបាលនគរបានបដិសេធទង្វើនេះ រីឯម៉ារវ៉ាន អ៊ីនបូ អាល់-ហាកាំស្វាគមន៍ទង្វើនេះ ហើយសម្តែងសន្តានចិត្តព្យាបាទទៅលើព្រះសាស្តា صلى الله عليه وآله وسلم និងសាសនាព្រះ

---

[245] ថ្ងៃមួយ អ៊ីម៉ាំអាុលី صلوات الله عليه والسلام បានតំណាលថាព្រះសាស្តា صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "ថ្ងៃរស់ពីស្លាប់វិញ ហ្វាទីម៉ាស្ញូ បុត្រីខ្ញុំ នឹងត្រឡប់មកវិញកាន់សំលៀកបំពាក់ប្រឡាក់ឈាមបុត្រព្រះនាងក្នុងដៃ ។ ព្រះនាងនឹងយកវាទៅព្យួរលើសសរព្រះរាជបល្ល័ង្ក ហើយមានវចនៈថា៖ "ឱព្រះដ៏ទៀងត្រង់អើយ សូមព្រះអង្គជម្រះក្តីខ្ញុំម្ចាស់និងឃាតករបុត្រខ្ញុំម្ចាស់ផង ។" ព្រះម្ចាស់ عز وجل ក៏នឹងកាត់ក្តីឲ្យបុត្រីខ្ញុំ ។ ខ្ញុំសូមស្បថចំពោះព្រះម្ចាស់ឋានសួគ៌ ។" សូមមើលសៀវភៅ *អាល់-ស៊្វីរ៉ត្ញ៉ អាល់-សាវី ហ្វីម៉ាណាគ្វីប អាលី ណាប៊ី* ទំព័រ ៩៣ ។

[246] សូមមើលសៀវភៅរបស់លោក អាុប់ដ្វាល់-រ៉ស្សាក្វ អាល់-មូក្សារ៉មម៉ាក្វ៏តាល់-*អាល់-ហ៊្វសៃន៍ (كتاب مقتل الحسين)* ទំព័រ ៤១៧ ។

អង្គ صلى الله عليه وآله وسلم ។ ពេលសម្លឹងមើលមុខអ៊ីម៉ាំ صلوات الله عليه والسلام បុរសរូបនេះនឹកឃើញដូនតាខ្លួនដែលបានស្លាប់ ដោយដៃព្រះបិតានិងព្រះអយ្យកោរបស់អ៊ីម៉ាំ صلوات الله عليه والسلام ។ បន្ទាប់មក បុរសនេះបានបែរទៅរកព្រះរាជផ្នូរព្រះសាស្ដា صلى الله عليه وآله وسلم ថា៖ "មូហាំម៉ាដ់ صلى الله عليه وآله وسلم នេះគឺការតបស្នងថ្ងៃ[ប្រយុទ្ធនៅឯសមរភូមិ]បាដារ ។"[247] តាមផ្លូវទៅម៉ាឌីណាស់ ចំណាប់អាស់លុល-បៃត៍បានសូមឲ្យឆ្មាំដែលជូនដំណើរនោះនាំផ្លូវព្រះអង្គទាំងអស់គ្នាកាត់តាមផ្លូវទៅការបាឡាអ៊័ ពួកឆ្មាំក៏បានធ្វើតាមសំណូមពរ ។ លុះបានទៅដល់ការបាឡាអ៊័ បណ្ដាស្ត្រីបានយំសោកនៅព្រះរាជផ្នូរអ៊ីម៉ាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ។ ទាំងអស់គ្នាបានស្នាក់នៅទីនោះបីថ្ងៃ បីថ្ងៃដែលទឹកភ្នែកហូរមិនឈប់ ។ អ៊ីម៉ាំស្ស៊ែន៍ អាល់-អ៊ាប៊ីឌីន صلوات الله عليه والسلام ខ្លាចមានគ្រោះថ្នាក់ដល់អាយុជីវិតព្រះបិតុច្ឆា និងបណ្ដាស្ត្រីឯទៀត ខ្លាចព្រះនាងទាំងអស់គ្នាស្លាប់ដោយសារសោកសៅខ្លាំងពេក ។ ព្រះអង្គ صلوات الله عليه والسلام ក៏បានចេញបញ្ជាឲ្យរៀបខ្លួន ចេញដំណើរទៅកាន់ម៉ាឌីណាស់ ។ ទាំងអស់គ្នាបានចាកចេញពីការបាឡាអ៊័ទាំងទឹកភ្នែកនិងអួលដើមក ។ កាលនោះម៉ាឌីណាស់បានស្លៀកពាក់ខ្មៅ ព្រោះព្រះនាងអ៊ូម សាឡាម៉ាស់ ព្រះមហេសីព្រះសាស្ដា صلى الله عليه وآله وسلم បានចូលទិវង្គតមួយខែក្រោយអ៊ីម៉ាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام បានបូជាព្រះជន្ម ដោយសារមានទុក្ខអំពីព្រះអង្គ صلوات الله عليه والسلام ខ្លាំងពេក ។[248] ពេលក្រុមអ្នកដំណើរជិតទៅដល់ម៉ាឌីណាស់ប្រមាណពីរបីប៉ារ៉ាសាង អ៊ីម៉ាំស្ស៊ែន៍ អាល់-អ៊ាប៊ីឌីន صلوات الله عليه والسلام បានឈប់នៅទីនោះបន្តិច ។ ព្រះអង្គ صلوات الله عليه والسلام បានសូមឲ្យប៊ីស្ហ៊័រ អ៊ីបនូ ហ៊ីស្លុំលីមតែងកំណាព្យស្ដីអំពីទុក្ករកម្មរបស់អ៊ីម៉ាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ហើយទៅសូត្រកំណាព្យនេះក្នុងនគរម៉ាឌីណាស់ជាមុន ។ បុរសនេះបានចូលទៅក្នុងនគរម៉ាឌីណាស់ ទៅឈប់ក្បែរម៉ាស់ឃ៊ិដព្រះសាស្ដា صلى الله عليه وآله وسلم ប្រកាសទុក្ករកម្មអ៊ីម៉ាំ صلوات الله عليه والسلام ដោយសម្ដី

[247] សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាប៊ី អាល់-ហាឌីដ *ស្ហារហ៍ ណាស់យ៉ាល់-បាឡាកោះត៍*, ក្បាលទី ៤ ៧២ ។

[248] សូមមើលសៀវភៅរបស់ សៃយីដ អ៊ីបនូ ត៊័វុស អាល់-ហាសានី *អាល់-ឡាហ៊ុហ្វ អ៊ាឡា ក្វត់ឡា អាត់-ទូហ៊ុហ្វ (أللُّهوف عَلى قتلَى الطّفوف)* ឬ *អាល់-ម៉ាល់ហ៊ុហ្វ អ៊ាឡា ក្វត់ឡា អាត់-ទូហ៊ុហ្វ (ألمَلهوف عَلى قَتلَى الطّفوف)* ទំព័រ ១១៦ ។

សោកសៅ ។

ប្រជារាស្ត្រស្ទុះទៅរកលោក ដើម្បីសូមពត៌មានបន្ថែមអំពីជោគវាសអ្នកឯទៀត ។ ប៊ីស្ហ៍រតំណាលប្រាប់ពួកគេអំពីអ៊ីម៉ាំស៊្សែន៍ អាល់-អាប៊ីឌីនصلوات الله عليه والسلامនិងស្ត្រីព្រះរាជកុលដ្ឋានព្រះសាស្តាصلى الله عليه وآله وسلمឯទៀត ដែលត្រូវគេចាប់ជាចំណាប់ឈ្លើយ ។ ពួកគេរត់ទៅឯជាយក្រុងទៅទទួលក្រុមអ្នកដំណើរ ទាំងយំខ្សឹកខ្សួល ។ ពេលព្រះរាជកុលដ្ឋានព្រះសាស្តាصلى الله عليه وآله وسلمមកដល់ភ្លាម ពួកគេចោមរោមដោយទឹកភ្នែករលីងរលោង ហើយថ្ងៃនោះស្រដៀងថ្ងៃដែលព្រះសាស្តាصلى الله عليه وآله وسلمចូលទិវង្គតដែរ ។

ក្នុងពេលប្រជុំកាន់ទុក្ខនោះ អ៊ីម៉ាំស៊្សែន៍ អាល់-អាប៊ីឌីនصلوات الله عليه والسلامបានថ្លែងសុន្ទរថាស្តីអំពីព្រះបិតាព្រះអង្គصلوات الله عليه والسلام និងគ្រោះកាចដែលព្រះអង្គបានទទួលរង ។ ព្រះអង្គصلوات الله عليه والسلام ព្រមទាំងព្រះបិតុច្ឆាព្រះអង្គصلوات الله عليه والسلامនិងព្រះអនុជាទាំងអស់ អមដោយប្រជារាស្ត្រ បានសំដៅទៅកាន់ម៉ាស់យ៊ិដ្ឋព្រះសាស្តាصلى الله عليه وآله وسلم ។ ព្រះនាងស៊្សៃណាប់سلام الله عليهاកាន់ខ្លោងទ្វារម៉ាស់យ៊ិដ្ឋព្រះសាស្តាصلى الله عليه وآله وسلم ហើយបានស្រែកថា៖ "ព្រះអយ្យកោصلى الله عليه وآله وسلمអឺយ ខ្ញុំម្ចាស់សូមទូលព្រះអង្គصلى الله عليه وآله وسلم ថាអាល់-ហ៊្សៃសែន៍صلوات الله عليه والسلام ព្រះរៀមខ្ញុំម្ចាស់ បានធ្វើទុក្ករកម្មដោយបូជាព្រះជន្ម ។"[249]

ចាប់ពីថ្ងៃនោះតទៅ ធុរៈតែមួយគត់របស់ព្រះនាងស៊្សៃណាប់سلام الله عليهاគឺកាន់ព្រះរាជទុក្ខព្រះរាជវង្សនិងមិត្តទាំងអស់របស់ព្រះនាងسلام الله عليها ដែលបានធ្វើទុក្ករកម្មដោយបូជាជីវិត និងខិតខំឥតស្រាកស្រាន្តដើម្បីផ្សព្វផ្សាយសារទុក្ករកម្មរបស់អ៊ីម៉ាំអាល់-ហ៊្សៃសែន៍صلوات الله عليه والسلام ។ ព្រះនាងسلام الله عليهاទ្រង់ព្រះកន្សែង ពេលណាព្រះនាងسلام الله عليهاមើលមុខព្រះភាតុបុត្តព្រះនាងسلام الله عليها អ៊ីម៉ាំស៊្សែន៍ អាល់-អាប៊ីឌីនصلوات الله عليه والسلام លុះត្រាតែព្រះនាងسلام الله عليهاក្លាយទៅជាដូចសាកសពគ្មានជីវិត ។[250]

---

[249] សូមមើលសៀវភៅរបស់លោក អាប់ដ្វាល់-រ៉ស្សាក់ អាល-មូក្ករ៉មម៉ាក្ទ័តាល់-អាល់-ហ៊្សៃសែន៍ (كتاب مقتل الحسين) ទំព័រ ៤៧២ ។

[250] សូមមើលសៀវភៅរបស់លោក មូហ៊ាំម៉ាដ្ឋ អ៊ីបនូ យ៉ារៀរ អាល់-ត៍ាបារី (محمد بن جرير طبري) *តារិក្ខ អាល់-អ៊ូម៉ាំ វ៉ា អាល់-មុលុក (تاريخ الأمم والملوك)* ក្បាលទី ៦

## ទៅកាន់បរលោក

ទិដ្ឋភាពរន្ធត់ដែលព្រះនាងស្សៃណាប់سلام الله عليهاបានឃើញផ្ទាល់ភ្នែក ក្នុងជីវិតព្រះនាងسلام الله عليهاនោះមិនអាចរលុបបាត់ពីអារម្មណ៍ព្រះនាងسلام الله عليهاបានឡើយ វារស់នៅក្នុងវិញ្ញាណព្រះនាងسلام الله عليهاជានិច្ច ។ ព្រះនាងسلام الله عليهاហូរទឹកភ្នែកជានិច្ច ព្រះនាងسلام الله عليهاយំសោកទុក្ខសោកស្តាយព្រះរៀម និងទុក្ករបុគ្គលទាំងអស់ ។ ព្រះនាងسلام الله عليهاតែងតែហៅព្រះនាមព្រះរៀម ព្រះអនុជ ព្រះរាជបុត្រ ព្រះភាគុបុត្តទាំងឡាយរបស់ព្រះនាងسلام الله عليها ហើយក៏បានសន្លប់ បាត់បង់ស្មារតី ។ ព្រះនាងسلام الله عليهاនៅក្នុងសភាពនេះ ទន់ខ្សោយហាក់ដូចជាគ្មានវិញ្ញាណក្នុងខ្លួន រង់ចាំការស្លាប់ ដើម្បីនឹងបានរួចផុតពីទុក្ខវេទនាទាំងឡាយ ។ ព្រះនាងسلام الله عليهاរង់ចាំការស្លាប់ដើម្បីនឹងបានថ្លែងទុក្ខសោកប្រាប់ព្រះអយ្យកោនិងព្រះមាតាបិតាព្រះនាងسلام الله عليها អំពីអ្វីៗដែលព្រះនាងسلام الله عليهاបានឃើញ ។ ដូច្នេះ ព្រះនាងត្រូវជម្ងឺបៀតបៀន ដល់ថ្នាក់ឈឺចាប់ងើបមិនរួចពីដំណេកអស់រយៈពេលដ៏យូរ ។

ទោះបីជិតអវសានជីវិតក៏ដោយ ក៏ទិដ្ឋភាពការបាឡាអ៊ុំនិងដ្វាម៉ាស់នៅតែរស់រវើកនៅចំពោះមុខព្រះនាងسلام الله عليهاដែរ ។ ក៏ប៉ុន្តែ មរណៈបានមករកព្រះនាងسلام الله عليهاខណៈដែលអណ្តាតព្រះនាងسلام الله عليهاស្ញើចសរសើរព្រះម្ចាស់عز وجل ដែលនឹងសងសឹកអស់បុគ្គល ដែលបានប្រព្រឹត្តអាក្រក់មកលើព្រះនាងسلام الله عليها ។ ព្រះនាងسلام الله عليهاបានចូលទិវង្គតថ្ងៃអាទិត្យ ទី ១៥ ខែរ៉យ៉ាប់ ឆ្នាំ ៦២ ហ៊ីជ្រ៉ោះត៍សករាជ ក្នុងព្រះជន្ម ៥៧ វស្សា ។[251]

## ព្រះរាជផ្នូរព្រះនាងស្សៃណាប់سلام الله عليها

---

ទំព័រ ៣៦៦; សូមមើលសៀវភៅរបស់លោក អ៊ីបនូ អាល់-អាស្សៀរ *អាល់-តារិក្* ក្បាលទី ៣ ទំព័រ ៤២៨ ។

[251] សូមមើលសៀវភៅរបស់លោក អាល់-អ៊ូបៃដាលី *អាល់-សៃយីដ្វាស្ស៍ ស្សៃណាប់ វ៉ា អាក់បារ អាល់-ស្សៃណាប៊ីយ៉ាស្ស៍* ទំព័រ ៩ ។

លោកអ្នកប្រវត្តិសាស្ត្រមានមតិខុសគ្នា ពាក់ព័ន្ធនឹងកន្លែងបញ្ចុះព្រះរាជសពព្រះនាងសៃណាប់سلام الله عليها ។ ខ្លះថាព្រះរាជសពព្រះនាងត្រូវបញ្ចុះនៅឯអាល់-បាគីអ៊ុ នៅម៉ាឌីណាស់ ។ មតិនេះមិនអាចទទួលយកបានទេពីព្រោះប្រសិនបើព្រះរាជសពព្រះនាងត្រូវបញ្ចុះនៅទីនោះមែន ប្រាកដជាមានផ្នូរពិសេសដូចផ្នូរឯទៀតនៅទីនោះដែរ ។ ប្រហែលដូចព្រះមាតាព្រះនាងسلام الله عليهاដែរ គឺព្រះនាងسلام الله عليهاបានសូមឲ្យគេបញ្ចុះព្រះរាជសពព្រះនាងក្នុងពេលយប់ដើម្បីនឹងកុំឲ្យគេស្គាល់កន្លែងព្រះរាជផ្នូរព្រះនាងسلام الله عليها ។

លោកអ្នកប្រវត្តិសាស្ត្រមួយក្រុមធំបានមូលមតិគ្នាថា ព្រះនាងسلام الله عليهاចូលទិវង្គតនៅឯភូមិតូចមួយនៃស្រុកដាម៉ាស់ ហើយព្រះរាជសពព្រះនាងسلام الله عليهاត្រូវបញ្ចុះនៅទីនោះ ។ អស់លោកបានឲ្យដឹងថាព្រះនាងسلام الله عليهاបានភៀសខ្លួនទៅឯប្រទេសស៊ីរីកាលនគរម៉ាឌីណាស់រងការអត់ឃ្លានខ្លាំង ហេតុដូច្នេះ អាប់ឌុលឡោះហ៍ អ៊ីបនូ យ៉ាក់ហ្វារ៍បានចាកចេញទៅឯប្រទេសស៊ីរី ។

តែរឿងអត់ឃ្លាននេះដូចជាពុំមានហេតុផល ពុំមានមូលដ្ឋានទេ ពីព្រោះលោកអ្នកប្រវត្តិសាស្ត្រភាគច្រើន និងអស់លោកអ្នកតំណាលពុំដែលថ្លែងដល់ឧប្បត្តិហេតុដូចនេះឡើយក្នុងសម័យនោះ ។ ម្យ៉ាងទៀតអាប់ឌុលឡោះហ៍ អ៊ីបនូ យ៉ាក់ហ្វារ៍មានទ្រព្យសម្បត្តិមហាសាល មិនអាចរងឥទ្ធិពលអាក្រក់ដោយសារការអត់ឃ្លាននោះបានឡើយ ហើយព្រះអង្គមានសប្បុរសធម៌ទូលំទូលាយពេកណាស់ មិនអាចចោលសាច់ញាតិនិងបងប្អូនរួមស្រុកនៅក្នុងការអត់ឃ្លាននោះ ដោយភៀសខ្លួនទៅរកសំបុកសត្រូវរបស់ព្រះអង្គនោះបានទេ ។ ទោះជាយ៉ាងណាក៏ដោយ គេបានទទួលដឹងគ្រប់គ្នាហើយថា ព្រះរាជសពព្រះនាងសៃណាប់سلام الله عليهاត្រូវបញ្ចុះនៅឯដាម៉ាស់ ហើយសព្វថ្ងៃនេះមានបូជណីយស្ថានដ៏ប្រណិតមួយដែលមនុស្សទៅសម្តែងសេចក្តីគោរពរាប់ពាន់នាក់រាល់ថ្ងៃ ដើម្បីស្វែងរកព្រះពរនិងព្រះមេត្តាប្រណីពីអល់ឡោះហ៍عز وجل ដូចបូជណីស្ថានរបស់អ៊ីម៉ាំអាល់-ហ៊្វសៃន៍صلوات الله عليه والسلامដែរ ។

អស់លោកអ្នកប្រវត្តិសាស្ត្រច្រើនទៀតបានឲ្យដឹងថា ព្រះរាជសពព្រះនាង

ស្ទៃណាប់سلام الله عليهاត្រូវបញ្ចុះនៅឯប្រទេសអេស៊ីបត៍ ។[252] សម្រាប់ប្រជារាស្ត្រអេស៊ីបត៍ទាំងអស់ នេះគឺការណ៍ពិតមួយដែលមិនអាចប្រកែកបាន បូជណីយស្ថានរបស់ព្រះនាងسلام الله عليها នៅទីនោះជាសញ្ញាមួយដែលមានសារៈសំខាន់បំផុតនៃប្រទេសអេស៊ីបត៍ ។ អស់លោកអ្នកប្រវត្តិសាស្ត្របានថ្លែងអំពីការភៀសខ្លួនរបស់ព្រះនាងស្ទៃណាប់ ទៅឯប្រទេសអេស៊ីបត៍ដូចតទៅគឺ៖

នៅឯម៉ាឌីណាស់ ព្រះនាងស្ទៃណាប់سلام الله عليهاបានប្រជុំប្រជារាស្ត្រប្រឆាំងអំណាចកាន់ក្តាប់និងប្រឆាំងរដ្ឋអ៊ូម៉ៃយ៉ាស់មិនត្រឹមត្រូវ ។ ទីបំផុត ប្រជារាស្ត្រម៉ាឌីណាស់បានបះបោរ ហើយបានកកើតជាក្រុមប្រដាប់អាវុធមួយដើម្បីប្រឆាំងអាជ្ញាធរកាន់អំណាច ។ តទល់នឹងការបះបោរនេះ យ៉ាស៊ីដបានចាត់បញ្ជូនកងទ័ពប្រដាប់អាវុធធំមួយ ដឹកនាំដោយបុគ្គលឧក្រិដ្ឋមុស្លីម អ៊ីបនូ អ៊ុក្ហ៍បាស់ ទៅសម្លាប់ពួកបះបោរនិងប្រជារាស្ត្រស៊ីវិលយ៉ាងឃោរឃៅ ឥតត្រាប្រណី ។ ពួកគេថែមទាំងបានចាប់ជនបះបោរនិងស៊ីវិល

---

[252] មានអស់លោកអ្នកប្រាជ្ញច្រើននាក់យល់ស្របនឹងសេចក្តីថ្លែងការណ៍នេះ ដូចជា លោក អ៊ីបនូ អ៊ុសាកៀរ នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា *តារិក អាល់-កាបៀរ;* លោក អ៊ីបនូ តៅឡៅន៍ នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា*អាល់-រីសាឡាស់ អាល់-ស្ទៃណាប៊ីយ៉ាស់;* លោក អាល់-ស្ហាក់រ៉នី នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា *ឡាវ៉ាគិះហ៍ អាល់-អាន់វ៉ារ;* លោក មូហ៊ាំម៉ាដ់ សាប់បាន់ នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា *អ៊ីសអាហ្វ អាល់-រ៉ាគីប៊ីន;* លោក អាល់-ស្ហាបាល់ណាឃ្យី នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា *នូរ អាល់-អាប់សារ;* លោក អាល់-ស្ហាប់រ៉ាវី នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា *អាល់-អ៊ីតហ្វាហ្វ;* លោក ហ៊ាសាន់ អាល់-អាដាវី នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា *ម៉ាស្ហារិក្វ អាល់-អាន់វ៉ារ;* លោក អាល់-ម៉ាន់ណាវី នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា *តាបាក្វាត់;* លោក យ៉ាឡាល់ អាល់-ឌីន អាល់-ស៊ូយូទី នៅក្នុងសៀវភៅលោកដែលមានចំណងជើងថា *អាល់-រីសាឡាស់ អាល់-ស្ទៃណាប៊ីយ៉ាស់;* លោក អាច់ហ្យូរី នៅក្នុងសៀវភៅលោកដែលមានចំណងជើងថា *មូសាល់សាល់ អាល់-អ៊ុស្ហារ៉ាំ* និងច្រើននាក់ទៀត ។

ជាទាសៈឲ្យយ៉ាស៊ីដូទៀតផង ។

ខ្លាចសកម្មភាពព្រះនាងស្រៃណាប់عليها السلام អភិបាលគ្រប់គ្រងនគរម៉ាឌីណាស្ញុំ បានផ្ញើសំបុត្រទៅប្រាប់យ៉ាស៊ីដូ អំពីគ្រោះថ្នាក់ដែលអាចកើតឡើងពីវត្តមានព្រះនាងسلام الله عليهاនៅក្នុងនគរម៉ាឌីណាស្ញុំ ។ បុរសកំណាចបានផ្ញើសំបុត្រតបវិញ ឲ្យអភិបាលក្រុងនិរទេសព្រះនាងسلام الله عليهاទៅឯប្រទេសណាមួយដែលព្រះនាងسلام الله عليهاអាចជ្រើសរើសយកបាន ។ ដំបូងព្រះនាងស្រៃណាប់سلام الله عليهاបដិសេធ តែស្រៃណាប់ បុត្រីរបស់អ្នគ្វីល បងប្អូនជីដូនមួយរបស់ព្រះនាងسلام الله عليها បានទាក់ទាញចិត្តព្រះនាងسلام الله عليهاឲ្យចាកចេញដើម្បីសាសនា ។ ព្រះនាងسلام الله عليهاក៏បានជ្រើសយកប្រទេសអេស៊ីបត៍ ។ ហ្វាទីម៉ាស្ញុំ និងស្វៃកែណាស្ញុំ ព្រះភាគុបុត្រីរបស់អ៊ីម៉ាំអាល់-ហ៊្វសៃន៍صلوات الله عليه والسلامបានទៅតាមព្រះនាងسلام الله عليها ។

ទៅដល់ប្រទេសអេស៊ីបត៍ថ្ងៃដាច់ខែស៊្ញុល-ហ៊ីច្ចយ៉ាស្ញុំ អភិបាលគ្រប់គ្រងប្រទេសអេស៊ីបត៍ឈ្មោះ ម៉ាស់ឡាម៉ាស្ញុំ អ៊ីបនូ មូខុល់ឡាដ្ញុំ អាល់-អាន់ស្វ៏រី បានទទួលព្រះនាងយ៉ាងរាក់ទាក់ បានឲ្យព្រះនាងسلام الله عليهاស្នាក់នៅឯលំនៅដ្ឋានលោកឯអាល់-ហ៊ាំរ៉អ៊ុំតែម្តង ។ ព្រះនាងسلام الله عليهاបានស្នាក់នៅទីនោះអស់ដប់មួយខែ ដប់ប្រាំថ្ងៃ ។ ថ្ងៃអាទិត្យទី ១៥ ខែរ៉យ៉ាប់ ឆ្នាំ ៦២ ហ៊ីច្ចរ៉េះត្ញុំសករាជ ព្រះនាងស្រៃណាប់سلام الله عليهاបានចាកចោលលោកនេះ ឯព្រះរាជសពព្រះនាងسلام الله عليهاត្រូវបញ្ចុះនៅក្នុងលំនៅដ្ឋាននោះ ។ សព្វថ្ងៃនេះទីនោះជាបូជណីយស្ថានដែលគេដាក់ឈ្មោះព្រះនាងسلام الله عليها ដែលគេអប់រំមនុស្សគ្រប់ជំនាន់ឲ្យស្គាល់អត្ថន័យពិតនៃមនុស្សធម៌ ឲ្យចេះការពារសេរីភាពនិងជំនឿ ។[253]

នៅក្នុងសៀវភៅលោក មានចំណងជើងថា *អាល់-តារិក្ញ* លោក អ៊ីបនូ អ្ញសាកៀរ (ابن عساكر) បានថ្លែងថា៖ "ព្រះនាងស្រៃណាប់سلام الله عليهاបានស្នាក់នៅ

---

[253] សូមមើលសៀវភៅ *អ៊ីសអាហ្ញុំ រ៉ត្ញីប៊ិន ទំព័រ ១៩៦;* សៀវភៅរបស់លោក អាល់-ស្ញាំរ៉នី *ឡាវ៉ាគ្វិះហ៍ អាល់-អាន់វ៉ារ* ទំព័រ ២៣; សៀវភៅ *អាល់-អ៊ីតហ្ញាហ្ញុំ ប៊ី ហ៊្ញុប អាល់-អាស្ញុរ៉ាហ្ញុំ (الإتحاف بحب الأشراف)* ទំព័រ ៩៣; សៀវភៅ *ម៉ាសាស់រិក្វ អាល់-អាន់វ៉ារ* ទំព័រ ១០០ ។

ឯប្រទេសអេស៊ីបត៍ បានចូលទិវង្គតហើយព្រះរាជសពព្រះនាងﷺត្រូវបញ្ចុះនៅទីនោះ ។ សពស្ត្រីដែលត្រូវបញ្ចុះនៅឯផ្ទាម៉ាស់គឺសពប្អូនស្រីព្រះនាងﷺដែលមានឈ្មោះថា ស៊ៃណាប់ អាល់-រុសត៍ ។"

ប្រជារាស្ត្រអេស៊ីបត៍ ព្រមទាំងមុស្លីមនៅលើផែនដីទាំងមូលទៅសម្តែងសេចក្តីគោរពបូជណីយស្ថានព្រះនាងរាល់ថ្ងៃ ជាពិសេសក្នុងឱកាសបុណ្យខួបរំលឹកទិវាព្រះនាងﷺសោយទិវង្គត ។ ពួកគេ រួមទាំងអ្នកប្រាជ្ញនិងប្រជារាស្ត្រមានជំនឿ ប្រជុំគ្នាជុំវិញបូជណីយស្ថានដើម្បីស្វែងរកព្រះពរជ័យនិងព្រះមេត្តាប្រោសប្រណីពីព្រះម្ចាស់ﷻ តាមរយៈអន្តរាគមន៍របស់ព្រះនាងស៊ៃណាប់ﷺ ។ អស់លោកថ្នាក់ដឹកនាំប្រទេសអេស៊ីបត៍ដូចជាលោក កាហ្វូរ អាល់-អាក់ស្ទីឌី លោក អាស៊ុម៉ាដ់ អ៊ីបនូ តៅឡៅន៍ និងលោក អាល់-ដាហៀរ ប៊ី ណាស់រីលឡោះហ៍ ជាដើមក៏មានកិត្តិយសទៅសម្តែងសេចក្តីគោរពបូជណីយស្ថានដែរ ។

ពេលដល់ខែរ៉យ៉ាប់ ប្រជារាស្ត្រគ្រប់ទិសទីបានមកប្រជុំគ្នាជុំវិញបូជណីយស្ថានដោយសូត្រព្រះគម្ពីរអល់ឡោះហ៍ﷻ និងឌូអាអ៊ំផ្សេងៗ ។ ម្យ៉ាងទៀត ប្រជារាស្ត្រមួយចំនួនបានស្នាក់នៅទីនោះអស់កន្លះខែ ។

ការស្តាបនាឡើងវិញ និងការជួសជុលបូជណីយស្ថានបានប្រព្រឹត្តទៅច្រើនលើកក្នុងប្រវត្តិសាស្ត្រ ដោយស្តេចនិងអ្នកកាន់អំណាចដឹកនាំប្រកបដោយសច្ចធម៌នៃប្រទេសអេស៊ីបត៍ ដូចជា ហ្វាក់រុដឌីន អាល់-យ៉ាក់ហ្វារី, អាលី ប៉ាស្វា អាល់-វ៉ាស៊ៀរ (ក្នុងឆ្នាំ ៩៥៦ ហ៊ីជ្រេ៉ាះត៍សករាជ) និងអាប់ឌុលរ៉េះហ៍ម៉ាន កាត់ខុដា (ក្នុងឆ្នាំ ១១៧៤ ហ៊ីជ្រេ៉ាះត៍សករាជ) ជាដើម ។ ក្នុងឆ្នាំ ១២១២ ហ៊ីជ្រេ៉ាះត៍សករាជ អ៊ុស្មម៉ាន អាល់-មូរ៉ឌីបានសាងសង់ឡើងវិញបូជណីយស្ថាន តែត្រូវបានផ្អាកព្រោះបារាំងបានកាន់កាប់ទឹកដី ។ ក្នុងឆ្នាំ ១៣២៦ ហ៊ីជ្រេ៉ាះត៍សករាជ យូស៊ុហ្វ ប៉ាស្វាបានបន្តការកសាងឡើងវិញ បានចារកំណត់ថ្ងៃខែស្នាដៃលោកដោយឃ្លាកំណាព្យនៅលើបន្ទះថ្មកែវ ។ ទោះជាយ៉ាងណាក៏ដោយស្នាដៃចុងក្រោយនៅលើមូហ្ហាំម៉ាដ់ អាលី ប៉ាស្វា ។ ក្នុងឆ្នាំ ១២៧៦ ហ៊ីជ្រេ៉ាះត៍សករាជ សាអ៊ីដ ប៉ាស្វា បានកសាងឡើងវិញប៉ែកខ្លះនៃ បូជណីយស្ថាន ។ ក្នុងឆ្នាំ

១២៩៩ ហ៊ីច្ចរ៉េះត៍សកករាជ ខេ្ឌឌីវ មូហ៊ាំម៉ាដ់ តៅហ៊្វីក្ក ប៉ាស្វាបានកសាង ឡើងវិញប៉ែកងទៀតនៃបូជណីយស្ថាន ។ ដំណើរការបានសម្រេចសព្វ គ្រប់ក្នុងឆ្នាំ ១៣០៤ ហ៊ីច្ចរ៉េះត៍សកករាជ ។

គ្រប់ប្រទេស ឬទីកន្លែងដែលព្រះនាងស្មែណាប់ﷺបានស្នាក់នៅមាន សិទ្ធិសម្ដែងមោទនភាពអំពីមហាស្ត្រីអង្គនេះ ដែលជាកិត្តយសរបស់ អ៊ីស្លាមនិងមុស្លីមទាំងអស់ ។ ទោះជាយ៉ាងណាក៏ដោយ ទីកន្លែងរបស់ ព្រះនាងស្មែណាប់ﷺ ឋិតនៅក្នុងក្រអៅបេះដូងអ្នកស្វែងរកការពិតគ្រប់ រូប ។ ព្រះនាងវិសេសវិសាលមហិមា ពុំអាចបញ្ចុះទុកនៅក្នុងផ្នូរណាមួយ បានឡើយ រីឯទង្វើរបស់បុគ្គលនីមួយៗស្ថិតនៅលើចិត្ត ។

## ស៊ីយ៉ារ៉ាស់ព្រះនាងស្មែណាប់ﷺ

بِسْمِ اللهِ الرَّحْمٰنِ الرَّحِيْمِ.

ក្នុងព្រះនាមអល់ឡោះហ្ម៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តា ករុណាប្រណី ។

السَّلاَمُ عَلَيْكِ يَا بِنْتَ سَيِّدِ الأَنْبِياءِ

សូមសិរីសួស្ដីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ព្រះរាជអគ្គមហា ប្រមុខរបស់ព្រះសាស្ដាទាំងឡាយអើយ ។

السَّلاَمُ عَلَيْكِ يَا بِنْتَ صَاحِبِ الحَوْضِ وَاللِّوَاءِ

សូមសិរីសួស្ដីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ម្ចាស់ស្រះ ម្ចាស់ ទង់អើយ ។

السَّلاَمُ عَلَيْكِ يَا بِنْتَ مَنْ عُرِجَ بِهِ إِلى السَّمَاءِ وَ وَصَلَ إِلى مَقَامِ قَابَ قَوْسَيْنِ أَوْ أَدْنَىٰ

សូមសិរីសួស្ដីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីបុគ្គលដែលត្រូវលើក ឡើងទៅលើមេឃ បុគ្គលដែលបាននៅដល់កន្លែងឆ្ងាយប្រវែងពីរធ្នូឬជិត

ជាងនោះ (៥៣:៩)

اَلسَّلاَمُ عَلَيْكِ يَا بِنْتَ نَبِيِّ الْهُدٰى وَ سَيِّدِ الْوَرٰى وَ مُنْقِذِ الْعِبَادِ مِنَ الرَّدٰى

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីព្រះសាស្តានៃមាគ៌ាត្រង់ត្រូវ ព្រះអភិបាលរបស់មនុស្សជាតិ[ទាំងអស់] អ្នកស្រោចស្រង់បាវទាំងឡាយ[របស់អល់ឡោះហ្ទ៍ﷻ]ពីមហន្តរាយ ។

اَلسَّلاَمُ عَلَيْكِ يَا بِنْتَ صَاحِبِ الْخُلُقِ الْعَظِيْمِ وَ الشَّرَفِ الْعَمِيْمِ وَ الْاٰيَاتِ وَ الذِّكْرِ الْحَكِيْمِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់បុគ្គលដែលបានប្រព្រឹត្តខ្លួនឲ្យស្របតាមសីលធម៌កំពូល ដែលមានកិត្តិយសខ្ពង់ខ្ពស់មហិមា ដែលមានសញ្ញានិងការរំលឹករបស់អល់ឡោះហ្ទ៍ﷻ (ពោលគឺ ព្រះគម្ពីរគួរអាន) ។

اَلسَّلاَمُ عَلَيْکِ يَا بِنْتَ صَاحِبِ الْمَقَامِ الْمَحْمُوْدِ وَ الْحَوْضِ الْمَوْرُوْدِ وَاللِّوَآءِ الْمَشْهوْدِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ម្ចាស់ឋានន្តរស័ក្តិខ្ពស់ត្រដែត ម្ចាស់ស្រះដែលគេនឹងផឹកទឹក[ក្នុងថ្ងៃរស់ពីស្លាប់វិញ] ម្ចាស់ទង់ជ័យដែលអស់ទាំងគេនឹងបានឃើញ ។

اَلسَّلاَمُ عَلَيْكِ يَا بِنْتَ مَنْهَجِ دِيْنِ الْاِسْلاَمِ وَ صَاحِبِ الْقِبْلَةِ وَ الْقُرْاٰنِ وَ عَلَمِ الصِّدْقِ وَ الْحَقِّ وَ الْاِحْسَانِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ព្រះមាគ៌ាអ៊ីស្លាមរបស់បុគ្គលដែលគេប្រទានគិបឡាស់និងគួរអានឲ្យ របស់គំរូនៃសេចក្តីស្មោះត្រង់ នៃសច្ចធម៌ នៃសប្បុរសធម៌ ។

اَلسَّلاَمُ عَلَيْكِ يَا بِنْتَ صَفْوَةِ الْاَنْبِيَاءِ وَ عَلَمِ الْاَتْقِيَآءِ وَ مَشْهُوْرِ الذِّكْرِ فِى السَّمَاءِ وَ رَحْمَةُ اللهِ وَ بَرَكَاتُهُ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ព្រះសាស្តាសម្រិតសម្រាំង របស់គំរូនៃបុគ្គលមានសទ្ធាជ្រះថ្លា របស់បុគ្គលដែលគេស្គាល់ច្បាស់ទាំងលើផែនដីនិងលើមេឃ ។

السَّلَامُ عَلَيْكِ يَا بِنْتَ خَيْرِ خَلقِ اللهِ وَسَيِّدِ خَلْقِهِ وَأَوَّلِ العَدَدِ قَبْلَ إِيْجَادِ أَرْضِهِ وَسَمَاوَاتِهِ وَآخِرِ الأَبَدِ بَعْدَ فَناءِ الدُّنْيا وَأَهْلِهَا الَّذِيْ رُوحُهُ نُسْخَةُ اللاَّهُوتِ وَصُورَتُهُ نُسْخَةُ المُلْكِ وَالمَلَكُوتِ وَقَلْبُهُ خُزانَةُ الحَيِّ الَّذِي لا يمُوتُ، وَرَحْمَةُ اللهِ وَبَرَكَاتُهُ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់សត្វលោកប្រសើរបំផុតរបស់អល់ឡោះហ៍ﷻ របស់ព្រះអគ្គប្រមុខរបស់សត្វលោករបស់អល់ឡោះហ៍ﷻ របស់បុគ្គលដែលត្រូវបង្កើតឡើងមុនគេមុនផែនដីនិងមេឃ របស់បុគ្គលចុងក្រោយបង្អស់ក្រោយពីពិភពលោកនេះនិងសត្វលោកនេះបានរលាយសាបសូន្យអស់ របស់បុគ្គលដែលមានវិញ្ញាណចម្លងមកពីព្រះភពរបស់ព្រះជាម្ចាស់ ដែលមានសណ្ឋានចម្លងមកពីភពនេះ ដែលមានដួងចិត្តជាព្រះរាជសម្បត្តិរបស់ព្រះដែលអមតៈ ព្រះដែលគង់នៅជានិច្ច ព្រមទាំងព្រះមេត្តាធមិនិងព្រះមេត្តាសន្តោសរបស់អល់ឡោះហ៍ﷻ ។

السَّلَامُ عَلَيْكِ يَا بِنْتَ المُظَلَّلِ بِالغَمَامِ سَيِّدِ الكَوْنَيْنِ وَمَوْلى الثَّقَلَينِ وَشَفِيعِ الأُمَّةِ يومَ الْمَحْشَرِ وَرَحْمَةُ اللهِ وَبَرَكَاتُهُ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់បុគ្គលពពកបាំងឲ្យ ដែលជាព្រះអភិបាលរបស់លោកទាំងពីរ ដែលជាចៅហ្វាយរបស់បន្ទុកទាំងពីរ (ពោលគឺ មនុស្សនិងយ៉ិន) ដែលជាអ្នកធ្វើអន្តរាគមន៍ឲ្យអ៊ុមម៉ាត់ ក្នុងថ្ងៃរស់ពីស្លាប់វិញ ព្រមទាំងជាព្រះមេត្តាធមិនិងព្រះមេត្តាសន្តោសរបស់អល់ឡោះហ៍ﷻ ។

السَّلاَمُ عَلَيْكِ يَا بِنْتَ سَيِّدِ الأَوْصِياءِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ព្រះអគ្គមហាប្រមុខរបស់បណ្តាព្រះឧត្តរាធិការី (គឺអ្នកស្នង) ទាំងឡាយ ។

السَّلاَمُ عَلَيْكِ يَا بِنْتَ إمَامِ الأَتْقِياءِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ព្រះនាយករបស់បណ្តាអ្នកខ្លាចក្រែងអល់ឡោះហ្ 

السَّلاَمُ عَلَيْكِ يَا بِنْتَ رُكْنِ الأَوْلِيَاءِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ព្រះជម្រករបស់អស់សន្តបុគ្គល ។

السَّلاَمُ عَلَيْكِ يَا بِنْتَ عِمَادِ الأَصْفِيَاءِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ទីពឹងពាក់របស់អស់បុគ្គលសច្ចការីទាំងឡាយ ។

السَّلاَمُ عَلَيْكِ يَا بِنْتَ يَعْسوبِ الدِّينِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ព្រះមគ្គទេសក៍ព្រះសាសនា ។

السَّلاَمُ عَلَيْكِ يَا بِنْتَ أَمِيْرِ المُؤْمِنِيْنَ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ព្រះរាជអធិបតីរបស់បណ្តាអ្នកសទ្ធាជ្រះថ្លា ។

السَّلاَمُ عَلَيْكِ يَا بِنْتَ سَيِّدِ الوَصِيِّيْنَ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ព្រះរាជអភិបាលរបស់បណ្ដាឧត្តរាធិការីទាំងឡាយ ។

السَّلاَمُ عَلَيْكِ يَا بِنْتَ قَائِدِ البرَرَةِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ព្រះរាជមគ្គុទេសក៍របស់បណ្ដាអ្នកមានសទ្ធាស៊ប់ចិត្ត

السَّلاَمُ عَلَيْكِ يَا بِنْتَ قَامِعِ الكَفَرَةِ وَالفَجَرَةِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់បុគ្គលដែលបង្ក្រាបពួកសត្រូវសាសនានិងពួកឥតសីលធម៌ ។

السَّلاَمُ عَلَيْكِ يَا بِنْتَ وَارِثِ النَّبِيِّيْنَ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ព្រះទាយាទរបស់ព្រះសាស្តាទាំងឡាយ ។

السَّلاَمُ عَلَيْكِ يَا بنتَ خَلِيفَةِ سَيِّدِ الـمُرسَلِيْنَ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ព្រះឧត្តរាធិការីរបស់ព្រះរាជអគ្គមហាប្រមុខរបស់ព្រះសាសនៈទូតទាំងឡាយ ។

السَّلاَمُ عَلَيْكِ يَا بِنْتَ ضِياءِ الدِّينِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ព្រះរស្មីនៃព្រះសាសនា ។

السَّلاَمُ عَلَيْكِ يَا بِنْتَ النَّبَأ العَظِيمِ عَلى اليَقِينِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ព្រះរាជដំណឹងឱឡារិក [ដែលនឹងទៅជាពិតជាមិនខាន] ។

السَّلاَمُ عَلَيْكِ يَا بِنْتَ مَنْ حِسابُ النَّاسِ عَلَيهِ وَالكَوْثَرُ بَينَ يَدَيْهِ وَالنَّصُّ يَومَ الغَدِيرِ عَلَيهِ، وَرَحْمَةُ اللهِ وَبَرَكَاتُهُ
សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់បុគ្គលដែលទទួលភារកិច្ចជំនុំជម្រះក្តីមនុស្ស[ក្នុងថ្ងៃរស់ពីស្លាប់វិញ] បុគ្គលដែលគេព្រះរាជទានស្រះសួគ៌ឲ្យនៅក្នុងដៃ (គឺអាល់-កៅស្ឆារ៍) បុគ្គលដែលត្រូវតែងតាំងដោយព្រះវចនៈ[របស់ព្រះសាស្តាﷺ]ថ្ងៃអាល់-ក៏ង្វៀរ ព្រមទាំងព្រះមេត្តាធម៌និងព្រះមេត្តាសន្តោសប្រណីរបស់អល់ឡោះហ្ទ៍ﷻផងដែរ ។

السَّلاَمُ عَلَيْكِ يَا بِنْتَ مَنْ قَادَ زِمَامَ نَاقَتِهَا جِبرَائِيلُ وَشَارَكَها فِي مُصَابِهَا إِسْرافِيلُ، وَغَضِبَ بِسَبَبِها الرَّبُّ الجَلِيلُ، وَبَكى لِمُصَابِهَا إبْراهِيمُ الخَلِيلُ وَنُوحٌ وَمُوسَى الكَلِيمُ فِي كَرْبَلاءَ
សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់មហានារីដែលយ៉ីបរ៉អ៊ីលដឹកខ្សែមេអូដ្ឋឲ្យ មហានារីដែលអ៊ីសរ៉ហ្វីលជួយរំលែកទុក្ខ[អ៊ីម៉ាំអាល់-ហ៊ូសៃន៍صلوات الله عليه والسلامត្រូវធ្វើគុតនៅការបាឡាអ៊ុំ] មហានារីដែលពេលណាមហានារីអង្គនេះក្រោធ ពេលនោះព្រះជាម្ចាស់ដ៏មហាឧត្តុង្គឧត្តមទ្រង់ព្រះពិរោធដែរ មហានារីដែលអ៊ីបរ៉ហ៊ីម عليه السلام មិត្តជំនិតរបស់អល់ឡោះហ្ទ៍ﷻ នុះហ្ម៍ និងមូសាបានថ្លាថ្លែងទុក្ខការបាឡាអ៊ុំរបស់មហានារីអង្គនេះប្រាប់អល់ឡោះហ្ទ៍ﷻដោយយំយែក ។

السَّلاَمُ عَلَيْكِ يَا بِنْتَ البُدُوْرِ السَّواطِعِ
សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់អស់ដួងខែពេញបូណ៌មី ។

السَّلاَمُ عَلَيْكِ يَا بِنْتَ الشُّمُوسِ الطَّوَالِعِ، وَرَحْمَةُ اللهِ وَبَرَكَاتُهُ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់អស់សុរិយភ្លឺត្រចះត្រចង់ ។

السَّلاَمُ عَلَيْكِ يَا بِنْتَ زَمْزَمَ وَالصَّفَا

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ស៊ាំស៊ុមនិងស្វ័ហ្វា ។

السَّلاَمُ عَلَيْكِ يَا بِنْتَ مَكَّةَ وَمِنَى

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ម៉ាក់កាស្ទ់និងមីណា ។

السَّلاَمُ عَلَيْكِ يَا بِنْتَ مَنْ حُمِلَ عَلى البُرَاقِ فِي الْهَوَاءِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់បុគ្គលដែលជិះអាល់-ប៊ូរ៉ក់ទៅលើមេឃ ។

السَّلاَمُ عَلَيْكِ يَا بِنْتَ مَنْ حَمَلَ الزَّكَاةَ بِأَطْرَافِ الرِّدَاءِ وَبَذَلَهُ عَلَى الفُقَرَاءِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់បុគ្គលដែលដាក់ស៊ាកាត់ក្នុងជាយអាវទៅចែកឲ្យជនក្រខ្សត់ ។

السَّلاَمُ عَلَيْكِ يَا بِنْتَ مَنْ أُسْرِيَ بِهِ مِنَ الْمَسْجِدِ الحَرَامِ إِلَى الْمَسْجِدِ الأَقْصَى

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់បុគ្គលដែលបានធ្វើដំណើរពេលយប់ពីម៉ាស់យ៊ិដ្ទពិសិដ្ឋ (គឺម៉ាស់យ៊ិដ្ទ អាល់-ហារ៉ម) ទៅកាន់ម៉ាស់យ៊ិដ្ទឆ្ងាយបំផុត (គឺម៉ាស់យ៊ិដ្ទ អាល់-អាក់ស្វ៍) ។

السَّلاَمُ عَلَيْكِ يَا بِنْتَ مَنْ ضَرَبَ بِالسَّيْفَيْنِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់បុរសដែលច្បាំង

ដោយដាវពីរ ។

السَّلاَمُ عَلَيْكِ يَا بِنْتَ مَنْ صَلَّى القِبْلَتَينِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់បុរសដែលបានស៊ូឡាត់ទៅរកទិសពីរ (គឺគីបឡាត់) ។

السَّلاَمُ عَلَيْكِ يَا بِنْتَ مُحَمَّدٍ المُصْطَفَى

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់មូហាំម៉ាដ់ អាល់-មុសត៏ហ្វា (បុគ្គលជ្រើសរើសដោយអល់ឡោះហ្វ៏ﷻ) ។

السَّلاَمُ عَلَيْكِ يَا بِنْتَ عَلِيٍّ المُرْتَضَى

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ អ៊ុលី អាល់-មូរតាដ្ធ៏ (បុគ្គលសំណព្វ) ។

السَّلاَمُ عَلَيْكِ يَا بِنْتَ فَاطِمَةَ الزَّهْراءِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ហ្វាទីម៉ាស់ អាល់-ស្ហាស់រ៉អ៊ុំ (គឺនារីស្រស់ប្រិមប្រិយ) ។

السَّلاَمُ عَلَيْكِ يَا بِنْتَ خَدِيْجَةَ الكُبْرَى

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ ខ៉ិឌីយ៉ាស់ អាល់-គុបរ៉ (គឺមហានារី) ។

السَّلاَمُ عَلَيْكِ وَعَلَى جَدِّكِ مُحَمَّدٍ المُخْتَارِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គនិងព្រះអយ្យកោព្រះអង្គ មូហាំម៉ាដ់ អាល់-មុក្កតារ៍ (បុគ្គលជម្រើស) ។

السَّلَامُ عَلَيْكِ وعَلَى أَبِيْكِ حَيْدَرِ الْكَرَّارِ
សូមសិរីសួស្តីកើតមានដល់ព្រះអង្គនិងព្រះបិតាព្រះអង្គ ហៃដារ៍ អាល់-ការ៍រ៉ារ៍ (គឺរាជសីហ៍វាយសម្រុក) ។

السَّلَامُ عَلَيْكِ وَعَلَى السَّادَاتِ الأَطْهارِ الأَخْيَارِ، وَهُمْ حُجَجُ اللهِ عَلَى الأَقْطَارِ وَسَادَاتُ الأَرْضِ وَالسَّمَاءِ الَّذِيْنَ حُبُّهُمْ فَرْضٌ عَلَى أَعْنَاقِ كُلِّ الخَلائِقِ
សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ដល់អស់ព្រះអគ្គប្រមុខ ដល់អស់បុគ្គលបរិសុទ្ធនិងដល់អស់បុគ្គលជម្រើស ដែលជាព្រះអាជ្ញាធររបស់អល់ឡោះហ៍ﷻនៅលើដី ដែលជាព្រះអគ្គនាយករបស់ផែនដីនិងមេឃ គឺអស់បុគ្គលដែលគេដាក់បញ្ជាឲ្យសត្វលោកទាំងអស់គោរពស្រឡាញ់ ។

اَلسَّلَامُ عَلَيْكِ يَا بِنْتَ وَلِيِّ اللهِ الْاَعْظَمِ
សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបុត្រីរបស់ជំនិតអល់ឡោះហ៍ﷻ ព្រះដ៏មហាធំុធ្ងើងបំផុត ។ see mafatih

السَّلَامُ عَلَيْكِ يَا أُخْتَ وَلِيِّ اللهِ الـمُعَظَّمِ
សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជអនុជារបស់ជំនិតអល់ឡោះហ៍ﷻ ព្រះជាទីគោរពសក្ការជាទីបំផុត ។ see mafatih

السَّلَامُ عَلَيْكِ يا عَمَّةَ وَلِيِّ اللهِ الـمُكَرَّمِ
សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះរាជបិតុច្ឆារបស់ជំនិតអល់ឡោះហ៍ﷻ ព្រះដ៏ថ្លៃថ្លាជាទីបំផុត ។ see mafatih

السَّلَامُ عَلَيْكِ يَا أُمَّ الـمَصَائِبِ يَا زَيْنَبُ وَرَحْمَةُ اللهِ وَبَرَكَاتُهُ
សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱព្រះមាតានៃទុក្ខវេទនា ឱស៊ៃណាប់

سلام الله عليها ព្រមទាំងព្រះមេត្តាធម៌និងព្រះមេត្តាសន្ដោសប្រណីរបស់អល់ឡោះហ្ទ៍ عزوجل ផងដែរ ។

السَّلاَمُ عَلَيْكِ أَيَّتُهَا الصِّدِّيْقَةُ الْمَرْضِيَّةُ

សូមសិរីសួស្ដីកើតមានដល់ព្រះអង្គ ឱសច្ចការិនី ឱបុគ្គលពេញចិត្តដោយសន្ដោស ។ see mafatih

السَّلاَمُ عَلَيْكِ أَيَّتُهَا الفَاضِلَةُ الرَّشِيْدَةُ

សូមសិរីសួស្ដីកើតមានដល់ព្រះអង្គ ឱសីលវតី (ស្ត្រីប្រកបដោយសីល) ឱបុគ្គលនៅលើមាគ៌ាត្រង់ត្រូវ ។

السَّلاَمُ عَلَيْكِ أَيَّتُهَا الكَامِلَةُ العَالِمَةُ العَامِلَةُ

សូមសិរីសួស្ដីកើតមានដល់ព្រះអង្គ ឱនារីសុក្រឹតឥតខ្ចោះ នារីប្រកបដោយអភិញ្ញា នារីសកម្ម[ក្នុងការប្រព្រឹត្តល្អ] ។

السَّلاَمُ عَلَيْكِ أَيَّتُهَا الكَرِيْمَةُ النَّبِيْلَةُ

សូមសិរីសួស្ដីកើតមានដល់ព្រះអង្គ ឱនារីថ្លៃថ្នូរ នារីស្លូតត្រង់ ។

السَّلاَمُ عَلَيْكِ أَيَّتُهَا التَّقِيَّةُ النَّقِيَّةُ

សូមសិរីសួស្ដីកើតមានដល់ព្រះអង្គ ឱនារីមានសទ្ធាជ្រះថ្លា នារីបរិសុទ្ធ ។

السَّلاَمُ عَلَيْكِ يَا مَن ظَهَرَتْ مَحَبَّتُها لِلحُسَينِ الْمَظْلُوْمِ فِي مَوارِدَ عَديدَةٍ وَ تَحْمِلُ المَصَائِبَ المُحْرِقَةَ لِلقُلُوْبِ مَعَ تَحَمُّلَّاتٍ شَديدَةٍ

សូមសិរីសួស្ដីកើតមានដល់ព្រះអង្គ ឱនារីដែលបានសម្ដែងសេចក្ដីស្រឡាញ់អាល់-ហ៊ូសៃន៍ បុគ្គលរងការសង្កត់សង្កិន ច្រើនលើកច្រើនគ្រា

នារីដែលទ្រាំទទួលគ្រោះកាចរលួចចិត្តរលួយថ្លើម ដោយការអត់ធ្មត់សង្កត់ចិត្ត ។

اَلسَّلاَمُ عَلَيْكِ يَا مَنْ حَفَظَتِ الْاِمَامَ فِيْ يَوْمِ عَاشُورَاءَ فِيْ قَتْلٰى وَبَذَلَتْ نَفْسَها فِيْ نَجَاةِ زَيْنِ الْعَابِدِيْنَ فِيْ مَجْلِسِ اَشْقَى الْاَشْقِيَاءِ وَ نَطَقَتْ كَنُطْقِ عَلِيٍّ عَلَيْه السَّلاَمُ فِيْ سِكَكِ الْكُوفَةِ وَ حَوْلُها كَثِيْرٌ مِنَ الْاَعْدَاءِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱនារីដែលបានការពារអ៊ីម៉ាំថ្ងៃអាស៊ូរ៉អ៊ុកាលព្រះអង្គصلوات الله عليه والسلامត្រូវគេធ្វើគុត ដែលបានលះបង់ជីវិតដើម្បីសង្គ្រោះជីវិតស្ញែន៍ អាល់-អាប៊ីឌីនصلوات الله عليه والسلامនៅក្នុងចំណោមមនុស្សអន្យតិរ្ថិយ ដែលមានវចនៈ ប្រកបដោយវោហារកោសល្យអ៊ីម៉ាំអាលីصلوات الله عليه والسلامតាមផ្លូវគូហ្វាស៊ុំ ទោះបីត្រូវសត្រូវឡោមព័ទ្ធក៏ដោយ ។

السَّلاَمُ عَلَيْكِ يا مَنْ نَطَحَتْ جَبِينَها بِمُقَدَّمِ المَحْمَلِ إذْ رَأتْ رَأسَ سَيِّدِ الشُّهَدَاءِ وَيَخْرُجُ الدَّمُ مِن تَحْتِ قِناعِها وَ مِنْ مَحْمَلِها بِحَيْثُ يَرَى مِن حَوْلِها الأعْداءُ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱនារីដែលបោកថ្ងាសនឹងគ្រែស្នែង ពេលបានឃើញព្រះសិរព្រះអគ្គមហាប្រមុខរបស់យុវជនឋានសួគ៌ (គឺអ៊ីម៉ាំអាល់-ហ៊្វូសែន៍صلوات الله عليه والسلام) ហើយឈាមហូរពីរបាំងមុខព្រះនាងនិងពីគ្រែស្នែង បណ្តាលឲ្យពួកសត្រូវនៅជុំវិញខ្លួនព្រះនាងបានឃើញ ។

السَّلاَمُ عَلَيْكِ يا تالِيَ المَعْصُوْمِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱតំណាងអវិរុទ្ធភាព (គឺតំណាងអ៊ីម៉ាំអវិរុទ្ធទាំងឡាយ) ។

السَّلاَمُ عَلَيْكِ يا مُمْتَحَنَةُ في تَحَمُّلِ المَصَائِبِ كالحُسَيْنِ المَظْلُومِ، وَرَحْمَةُ اللهِ

وَبَرَكَاتُهُ
សូមសិរីសួស្ដីកើតមានដល់ព្រះអង្គ ឱនារីឆ្លងកាត់បទពិសោធន៍ទុក្ខវេទនាដូចអាល់-ហ៊្សៃសែន៍ﷺ បុគ្គលរងការសង្កត់សង្កិន ព្រមទាំងព្រះមេត្តាធម៌ និងព្រះមេត្តាប្រណីរបស់អល់ឡោះហ៍ផងដែរ ។

السَّلاَمُ عَلَيْكِ أَيَّتُهَا البَعِيْدَةُ عَنِ الأَوْطَانِ
សូមសិរីសួស្ដីកើតមានដល់ព្រះអង្គ ឱនារីឃ្លាតឆ្ងាយពីមាតុភូមិ

السَّلاَمُ عَلَيْكِ أَيَّتُهَا الأَسِيْرَةُ فِيْ البُلْدَانِ
សូមសិរីសួស្ដីកើតមានដល់ព្រះអង្គ ឱនារីដែលត្រូវចាប់ជាចំណាប់ឈ្លើយនៅក្នុងស្រុក ។

السَّلاَمُ عَلَيْكِ أَيَّتُهَا الْمُتَحَيِّرَةُ فِيْ خُرَابَةِ الشَّامِ
សូមសិរីសួស្ដីកើតមានដល់ព្រះអង្គ ឱនារីច្របូកច្របល់ចិត្តនៅក្នុងផ្ទះបាក់បែកនៅឯទឹកដីស្វាំ (គឺប្រទេសស៊ីរី) ។

السَّلاَمُ عَلَيْكِ أَيَّتُهَا المُتَحَيِّرَةُ فِي وُقُوفِكِ عَلَى جَسَدِ سَيِّدِ الشُّهَداءِ وخَاطَبْتِ جَدَّكِ رَسولَ اللهِ صَلّى اللهُ عَلَيهِ وَآلهِ بِهَذا النِّدَاءِ: "صَلَّىٰ عَلَيْكَ مَلَائِكَةُ السَّمَاءِ! هٰذَا حُسَيْنٌ بِالعَراءِ مَسْلُوبُ العِمَامَةِ وَالرِّدَاءِ، مُقَطَّعُ الأَعْضَاءِ، وَبَنَاتُكَ سَبَايَا! وَإِلَىٰ اللهِ المُشْتَكَىٰ".
សូមសិរីសួស្ដីកើតមានដល់ព្រះអង្គ ឱនារីឈឺចាប់កាលព្រះអង្គឈរក្បែរព្រះរាជសពព្រះរាជអគ្គមហាម្រុខរបស់អស់ទុក្ករបុគ្គល ថ្លែងដាក់ព្រះអយ្យកោព្រះអង្គ ព្រះសាសនៈទូតﷺអល់ឡោះហ៍ﷻ - សូមអល់ឡោះហ៍ﷻប្រទានពរជ័យដល់ព្រះអង្គﷺនិងព្រះរាជកុលដ្ឋានព្រះអង្គﷺ - ថា៖ "សូមអស់ទេវតាលើមេឃជួយបួងសួងពរជ័យឲ្យព្រះអង្គﷺ ! នេះគឺ

អាល់-ហ៊្ូសែន៍صلوات الله عليه والسلامនៅកណ្ដាលវាល ! ឈ្នួតក្បាលនិងសំលៀកបំពាក់រហែកជាចម្រៀក ! អវយវៈត្រូវគេកាត់ ! បណ្ដាព្រះរាជបុត្រីព្រះអង្គصلى الله عليه وآله وسلمត្រូវគេចាប់ជាចំណាប់ឈ្លើយ សូមប្ដឹងអល់ឡោះហ្ូعز وجل !"

وقَالَتْ: "يَا مُحَمَّدُ! هٰذَا حُسَيْنٌ تَسْفِي عَلَيْهِ رِيحُ الصَّبَا، مَجْذُوْذُ الرَّأْسِ مِنَ القَفا، قَتِيلُ أَوْلادِ البِغا. وَاحُزْنَاهُ عَلَيْكَ يا أَبَا عَبْدِ اللَّهِ."

ព្រះអង្គមានវចនៈដែរថា៖ "មូហាំម៉ាដ្ឋ៍صلى الله عليه وآله وسلمអឺយ ! នេះគឺអាល់-ហ៊្ូសែន៍صلوات الله عليه والسلام ! ខ្យល់ទិសខាងកើតអាណិតអាសូរព្រះរាជសពព្រះអង្គصلوات الله عليه والسلام ! ព្រះសិរព្រះអង្គصلوات الله عليه والسلامត្រូវកាត់ត្រឹមដើមក ! ពួកមនុស្សអប្រិយបានធ្វើគុតព្រះអង្គصلوات الله عليه والسلام ! ឱអនិច្ចា ឱអាប៊ូ អាប់ឌុលឡោះហ្ូអឺយ !"

اَلسَّلاَمُ عَلٰى مَنْ تَهَيَّجَ قَلْبُها لِلْحُسَيْنِ الْمَظْلُوْمِ الْعُرْيَانِ الْمَطْرُوْحِ عَلَى الثَّرَى وَ قَالَتْ بِصَوْتٍ حَزِيْنٍ بِاَبِي مَنْ نَفْسِي لَهُ الْفِدَاءُ بِاَبِي الْمَهْمُوْمِ حَتّٰى قَضٰى بِاَبِي الْعَطْشَانِ حَتّٰى مَضٰى بِاَبِي مَنْ شَيْبَتُهُ تَقْطُرُ بِالدِّمَاءِ

សូមសិរីសួស្ដីកើតមានដល់ព្រះអង្គ ឱនារីដែលរល្ងួយចិត្តរល្ងួយថ្លើមអាណិតអាល់-ហ៊្ូសែន៍صلوات الله عليه والسلام បុគ្គលរងការសង្កត់សង្កិន បុគ្គលត្រូវគេសម្រាតសំលៀកបំពាក់ បុគ្គលដួលលើដី ហើយព្រះអង្គسلام الله عليهاមានវចនៈយ៉ាងសោកសៅថា៖ "ក្នុងនាមព្រះបិតាខ្ញុំ ខ្ញុំសូមបូជាជីវិតដើម្បីព្រះអង្គصلوات الله عليه والسلام ! ក្នុងនាមព្រះបិតាខ្ញុំ បុគ្គលខ្វល់ខ្វាយលុះចូលទិវង្គត ! ក្នុងនាមព្រះបិតាខ្ញុំ បុគ្គលស្រេកលុះអស់ព្រះជន្ម ! ក្នុងនាមព្រះបិតាខ្ញុំ បុគ្គលដែលហូរឈាមពីពុកមាត់ស ។"

اَلسَّلاَمُ عَلٰى مَنْ بَكَتْ عَلٰى جَسَدِ اَخِيْها بَيْنَ الْقَتْلٰى حَتّٰى بَكَى لِبُكَاءِها كُلُّ عَدُوٍّ وَ صَدِيْقٍ وَرَأَى النَّاسُ دُمُوعَ الْخَيْلِ تَنْحَدِرُ عَلٰى حَوَافِرِها عَلَى التَّحْقِيْقِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ سلام الله عليها ឱនារីដែលយំស្រែកលើព្រះរាជសពព្រះរៀមព្រះនាងក្នុងគំនរសពយ៉ាងឈឺចាប់ បណ្តាលឲ្យគ្រប់គ្នា ទាំងមិត្ត ទាំងសត្រូវ យំយែកដោយសារសម្រែកយំព្រះនាង سلام الله عليها ហើយគេបានឲ្យដឹងតាមរយៈកំណត់ហេតុពិតថា គេបានឃើញសេះស្រក់ទឹកភ្នែកមកលើជើងវាដែរ ។

اَلسَّلاَمُ عَلٰى مَنْ تَكَفَّلَتْ وَجَمَعَتْ فِيْ عَصْرِ عَاشُوْرَاءِ بَنَاتِ رَسُوْلِ اللّٰهِ وَ اَطْفَالَ الْحُسَيْنِ وَ قَامَتْ لَهَا الْقِيٰمَةُ فِيْ شَهادَةِ الطِّفْلَيْنِ الْغَرِيْبَيْنِ الْمَظْلُوْمَيْنِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ سلام الله عليها ឱនារីដែលបានទទួលភារកិច្ចប្រជុំព្រះរាជបុត្រីទាំងឡាយរបស់ព្រះសាស្តា صلى الله عليه وآله وسلم អល់ឡោះហ៊ូ عز وجل និងព្រះរាជបុត្រទាំងឡាយរបស់អាល់-ហ៊ូសែន៍ صلوات الله عليه والسلام ពេលរសៀលថ្ងៃអាស៊ូរ៉អ៊ុ កាលៈទេសៈកាន់តែអាក្រក់ឡើង ពេលកុមារបរទេសរងការសង្កត់សង្កិនពីរនាក់បានបូជាជីវិត ។

اَلسَّلاَمُ عَلٰى مَنْ لَمْ تَنَمْ عَيْنُها لِاَجْلِ حِرَاسَةِ آلِ رَسُولِ اللّٰهِ فِيْ طَفِّ نَيْنَوٰى وَ صَارَتْ اَسِيْرًا ذَلِيلًا بِيَدِ الْاَعْدَاءِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ سلام الله عليها ឱនារីដែលមិនសម្រាកទេដើម្បីរក្សាការពារព្រះរាជវង្សព្រះសាស្តា صلى الله عليه وآله وسلم អល់ឡោះហ៊ូ عز وجل នៅឯតំបន់ណៃណាវ៉ា ដែលត្រូវចាប់ជាចំណាប់ឈ្លើយ ត្រូវបំបាក់មុខដោយសត្រូវ ។

اَلسَّلاَمُ عَلٰى مَنْ رَكِبَتْ بَعِيْرًا بِغَيْرِ وَطَاءٍ وَنَادَتْ اَخِيْها اَبَا الْفَضْلِ بِهٰذَ النِّدَاءِ اَخِي اَبَا الْفَضْلِ اَنْتَ الَّذِيْ أَرْكَبْتَني اِذْ اَرَدْتُ الْخُرُوْجَ مِنَ الْمَدِيْنَةِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱនារីដែលជិះអូដ្ឋគ្មានកែប ដែលហៅព្រះអនុជ អាប៊ូ អាល់-ហ្វាដ្ឋ៉ល៍ ថា៖ "ព្រះអនុជអើយ ! អាប៊ូ អាល់-ហ្វាដ្ឋ៉ល៍ អើយ ! ប្អូនបានជួយបងឡើងជិះអូដ្ឋពេលបងចាកចេញពីម៉ាឌីណាស៊ុ ។"

اَلسَّلاَمُ عَلَى مَنْ خَطَبَتْ فِي مَيْدَانِ الْكُوْفَةِ بِخُطْبَةٍ نَافِعَةٍ حَتَّى سَكَنَتْ الْاَصْوَاتُ مِنْ كُلِّ نَاحِيَةٍ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱនារីដែលបានថ្លែងសុន្ទរកថាដ៏មានប្រសិទ្ធិភាពនៅកណ្តាលក្រុងគូហ្វាស់ បណ្តាលឲ្យមនុស្សទាំងឡាយស្ងាត់មាត់ ។

اَلسَّلاَمُ عَلٰى مَنِ احْتَجَّتْ فِي مَجْلِسِ ابْنِ زِيَادٍ بِاحْتِجَاجَاتٍ وَاضِحَةٍ وَ قَالَتْ فِي جَوَابِهِ بِبَيِّنَاتٍ صَادِقَةٍ اِذْ قَالَ ابْنُ زِيَادٍ لِزَيْنَبَ سَلاَمُ اللهِ عَلَيْها كَيْفَ رَاَيْتِ صُنْعَ اللهِ بِاَخِيْكِ الْحُسَيْنِ قَالَتْ مَا رَاَيْتُ اِلاَّ جَمِيْلًا

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱនារីដែលឆ្លើយតបនៅក្នុងសម័យប្រជុំរបស់ អ៊ីបនូ ស៊ីយ៉ាដ្ទ ដោយពាក្យសំអាងច្បាស់លាស់ ពេលអ៊ីបនូ ស៊ីយ៉ាដ្ទ បានសួរព្រះនាងﷺថា៖ "តើនាងយល់ឃើញយ៉ាងណាដែលអល់ឡោះហ្ទ៏បានប្រព្រឹត្តចំពោះបងនាងនោះ ?" ព្រះនាងបានឆ្លើយតបវិញដោយស្មោះថា៖ "ខ្ញុំមិនមានពាក្យអ្វីឆ្លើយតបវិញក្រៅពីពាក្យថាល្អប្រសើរនោះទេ ។"

السَّلاَمُ عَلَيْكِ يا أَسيرَةً بِأَيْدِي الأَعْداءِ فِي الفَلواتِ وَرَأَيْتِ أَهْلِ الشَّامِ فِي حالَةِ العَيْشِ والسُّرُوْرِ وَ نَشْرِ الرَّاياتِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱនារីដែលត្រូវសត្រូវចាប់ឃុំឃាំងកណ្តាលវាល ដែលបានឃើញប្រជារាស្ត្រស៊ីរីសប្បាយរីករាយ អបអរលើកទង់ជ័យ ។

السَّلاَمُ عَلٰى مَنْ شُدَّ الْحَبْلُ عَلٰى عَضُدِهَا وَعُنُقِ الْاِمَامِ زَيْنِ الْعَابِدِيْنَ

وَاَدْخَلُوهَا مَعَ سِتَّةِ عَشَرَ نَفَرًا مِنْ آلِ رَسُوْلِ اللهِ وَ هَمْ كَاالْأَسَرَاءِ مُقَرَّنِيْنَ بِالحَدِيْدِ مَظْلُوْمِيْنَ وَ قَالَ عَلِيُّ ابْنُ الحُسَيْنِ عَلَيْهِ لسَّلاَمُ لِيَزِيْدَ يَا يَزِيْدُ مَا ظَنُّكَ بِرَسُوْلِ اللهِ صَلَّى اللهُ عَلَيْهِ وَ اٰلِهِ لَوْ رَاٰنَا عَلٰى هٰذِهِ الْحَالَةِ

សូមសិរីសួស្តីកើតមានដល់ព្រះអង្គ ឱនារីដែលត្រូវគេចងដៃដោយខ្សែចំណងកអ៊ីម៉ាំស្ញែន៍ អាល់-អ៊ុប៊ីឌ្ទីនصلوات الله عليه والسلام ! នារីដែលត្រូវគេបង្ខំ ជាមួយព្រះរាជវង្សព្រះសាស្តាصلى الله عليه وآله وسلمអល់ឡោះហ្ទ៍عز وجلដប់ប្រាំមួយអង្គទៀត ឲ្យចូល[ទៅក្នុងអង្គប្រជុំរបស់យ៉ាស៊ុីដ្ទ]ជាចំណាប់ឈ្លើយ ជាប់ច្រវាក់ ។ អ៊ុលី អ៊ីបនូអាល់-ហ៊ូសៃន៍صلوات الله عليه والسلامបាននិយាយដាក់យ៉ាស៊ុីដ្ទថា៖ "តើអ្នកឯងគិតដល់ព្រះសាស្តាصلى الله عليه وآله وسلمអល់ឡោះហ្ទ៍عز وجلទេ បើព្រះអង្គصلى الله عليه وآله وسلمឃើញយើងនៅក្នុងសភាពនេះ ?"

ثُمَّ قَالَتْ اُمُّ الْمَصَاءِبِ زَيْنَبُ لَهُ: قَائِلًا لِأَهَلُّوْا وَاسْتهَلُّوْا فَرَحًا ثُمَّ قَالُوْا يَا يَزِيْدُ لاَ تُشَلْ مُنْتَحِيًا عَلٰى ثَنَايَا اَبِيْ عَبْدِ اللهِ سَيِّدِ شَبَابِ اَهلِ الْجَنَّةِ تَنْكُتَهَا بِمِخْصَرَتِكَ

បន្ទាប់មក ព្រះអង្គسلام الله عليها - មាតាទុក្ខ - បាននិយាយដាក់យ៉ាស៊ុីដ្ទ [បន្ទាប់ពីបានសូត្រកំណាព្យ] ថា៖ "[បើដូនតាខ្ញុំដែលត្រូវសម្លាប់នៅឯសមរភូមិបាដ្ទារបានឃើញព្រឹត្តិការណ៍នេះ] អស់លោកច្បាស់ជានឹងយល់ស្របនិងសប្បាយចិត្តហើយនឹងថា៖ "យ៉ាស៊ុីដ្ទ ចូរអ្នកកុំបង្អង់ដៃ" ហើយអ្នកឯងហ៊ានវាយព្រះឱស្ឋ អាប៊ូ អ៊ុបឌុលឡោះហ្ទ៍صلوات الله عليه والسلام ព្រះរាជអគ្គមហាប្រមុខរបស់យុវជនឋានសួគ៌ដោយរំពាត់ ?"

ثُمَّ قَالَتْ لَهُ وَ لَئِنْ جَرَّتْ عَلَيَّ الدَّوَاهِيْ مُخَاطَبَتَكَ فَاِنِّيْ لَاَسْتَصْغِرُ قَدْرَكَ وَ اَسْتَعْظِمُ تَقْرِيْعَكَ وَ اَسْتَكْثِرُ تَوْبِيْخَكَ لَكِنَّ الْعُيُوْنَ عَبْرَا وَ الصُّدُوْرَ حَرَّا اَلاَ فَالْعَجَبُ كُلُّ الْعَجَبِ مِنْ اَقْدَامِكَ عَلَى قَتْلِ حِزْبِ اللهِ النُّجَبَاءِ بِحِزْبِ

الشَّيْطَانِ الطُّلَقَاءِ
បន្ទាប់មក ព្រះនាងﷺបាននិយាកដាក់យ៉ាស៊ីដ្ធថា៖ "ទុក្ខវេទនាបង្ខំឲ្យយើងនិយាយរកអ្នកឯង ពីព្រោះយើងស្អប់ខ្ពើមអំណាចអ្នកឯង ហើយយើងយល់ឃើញថាឲ្យតម្លៃអ្នកឯងខ្លាំងពេកជាងស្តីបន្ទោសអ្នកឯង ឲ្យកិត្តិយសអ្នកឯងខ្លាំងពេកជាងថ្កោលទោសអ្នកឯង តែដោយទឹកភ្នែកដោយក្តៅចិត្ត! ចម្លែកមែនដែលអ្នកឯងសម្រេចចិត្តសម្លាប់បក្សអល់ឡោះហ្ទ៍ﷻដោយដៃ "បុគ្គលដែលគេដោះលែង" [ដែលជាចំណាប់ឈ្លើយកាលវាយយកម៉ាក់កាស្ញបាន] នៃបក្សស្ញែត្ន ។

وَ لَئِنِ اتَّخَذْتَنَا مَغْنَمًا لَتَجِدُنَا وَ شِيْكًا مَغْرَمًا حِيْنَ لاَ تَجِدُ اِلاَّ مَا قَدَّمَتْ يَدَاكَ "وَ مَا رَبُّكَ بِظَلاَّمٍ لِلْعَبِيْدِ" وَ اِلَى اللهِ الْمُشْتَكَى وَ عَلَيْهِ الْمُعَوَّلُ فِيْ الشِدَّةِ وَ الرَّخَاءِ فَكِدْ كَيْدَكَ وَاسْعَ سَعْيَكَ وَنَاصِبْ جُهْدَكَ!
បើអ្នកឯងចាប់យើងជាចំណាប់ឈ្លើយ មិនយូរទេ អ្នកឯងនឹងបានដឹងថាអ្នកឯងបរាជ័យ ពេលអ្នកឯងបានឃើញអំពើដែលដៃអ្នកឯងបានសាង ។ *"ព្រះម្ចាស់អ្នកមិនប្រព្រឹត្តអំពើអយុត្តិធម៌លើបាវបម្រើទាំងឡាយរបស់ព្រះអង្គឡើយ (៤១:៤៦) ។"* យើងប្ដឹងអល់ឡោះហ្ទ៍ﷻមួយគត់ ព្រះអង្គﷻជាអ្នកធ្វើឲ្យជួបប្រទះវិបត្តិ ព្រះអង្គﷻជាអ្នកធ្វើឲ្យជួបប្រទះការងាយស្រួល ។ ដូច្នេះ ចូរអ្នកឯងធ្វើឧបាយកលទៅ ចូរអ្នកឯងព្យាយាមសម្តែងការប្រទូសប្រឆាំងទៅ!"

فَوَاللهِ لا تَمْحُوْ ذِكْرَنَا وَلا تُمِيْتُ وَحْيَنَا وَلا تُدْرِكُ أَمَدَنَا وَلا تَرْحَضُ عَنْكَ عَارَهَا.
សូមស្បថចំពោះអល់ឡោះហ្ទ៍ﷻ អ្នកឯងមិនអាចលុបបំបាត់ការចង់ចាំរបស់យើងបានឡើយ អ្នកឯងមិនអាចសម្លាប់វ៉ាហ៊្យីយើងបានឡើយ អ្នកឯងមិនអាចឡើងថ្កានដល់ឋានន្តរស័ក្តិយើងបានឡើយ អ្នកឯងមិនអាច

លុបលាងភាពថោកទាបរបស់អ្នកឯងបានឡើយ ។

وَهَلْ رَأْيُكَ إلاّ فَنَدٌ وَأيّامُكَ إلاّ عَدَدٌ وَجَمْعُكَ إلاّ بَدَدٌ. يا يزيد أما سمعت قول الله تعالى: ﴿وَلَا تَحْسَبَنَّ الَّذِينَ قُتِلُوا فِي سَبِيلِ اللَّهِ أَمْوَاتًا بَلْ أَحْيَاءٌ عِنْدَ رَبِّهِمْ يُرْزَقُونَ.﴾

មតិអ្នកឯងពុំមែនអ្វីក្រៅពីមតិខុសទេ ។ អ្នកឯងជិតដល់ថ្ងៃអវសានហើយ ទ្រព្យអ្នកឯងនឹងឥតប្រយោជន៍ ។ យ៉ាស៊ីដ្ធ អ្នកឯងបានឮព្រះបន្ទូលអល់ឡោះហ៍ﷻទេ៖ *"ចូរអ្នកកុំគិតថាបណ្ដាអ្នកដែលត្រូវសម្លាប់លើមាគ៌ាអល់ឡោះហ៍នោះស្លាប់ឡើយ ។ តែពួកគេនៅរស់ ពួកគេបានទទួលការផ្គត់ផ្គង់[នៃឋានសួគ៌]ពីព្រះម្ចាស់ពួកគេ (៣:១៦៩) ។"*

وَ حَسْبُكَ بِاللهِ حَاكِمًا وَ بِمُحَمَّدٍ صَلَّى اللهُ عَلَيْهِ وَ آلِهِ خَصْمًا وَ بِجِبْرِيْلَ عَدُوًّا ثُمَّ قَالَتْ اَلْحَمْدُ لِلّٰهِ الَّذِيْ خَتَمَ لِاَوَّلِنَا بِالسَّعَادَةِ وَ الْمَغْفِرَةِ وَ لِآخِرِنَا بِالشَّهادَةِ وَ الرَّحْمَةِ اِنَّهُ رَحِيْمٌ وَدُوْدٌ وَ هُوَ حَسْبُنَا وَ نِعْمَ الْوَكِيْلُ

គ្រប់គ្រាន់ណាស់សម្រាប់អ្នកឯង ដែលអល់ឡោះហ៍ﷻកាត់ក្ដីអ្នកឯង ដែលមូហាំម៉ាដ្ធﷺទូទាត់អ្នកឯង ដែលយ៉ិបរ៉អ៊ីលعليه السلامជាសត្រូវរបស់អ្នកឯង ។" បន្ទាប់មកព្រះនាងعليها السلامមានវចនៈថា៖ "សូមថ្វាយថោមនាការចំពោះអល់ឡោះហ៍ﷻ ព្រះដែលទ្រង់ប្រថាប់ត្រាសុមង្គលនិងខមាទោសលើជីវិតបក្សពួកយើងមុនៗ ដែលប្រថាប់ត្រាទុក្ករកម្មនិងព្រះមេត្តាលើបក្សពួកយើងក្រោយៗ ព្រោះព្រះអង្គﷻប្រកបដោយព្រះធម៌មេត្តា ព្រះអង្គﷻអាណិតអាសូរជាទីបំផុត ព្រះអង្គﷻជាអ្នកជំនុំជម្រះឲ្យយើង ព្រះអង្គﷻជាអ្នកថែរក្សាការពារប្រសើរបំផុត ។"

وَصَلَّى اللهُ عَلَى مُحَمَّدٍ وَ أَهْلِ بَيْتِهِ الطَّيِّبِيْنَ الطَّاهِرِيْنَ.

សូមអល់ឡោះហ៍ﷻប្រទានពរជ័យដល់មូហាំម៉ាដ្ធﷺនិងព្រះរាជកុលដ្ឋាន

បរិសុទ្ធនិងអរិរុទ្ធរបស់មូហាំម៉ាដ្ឋ ៗ

## ស៊ីយ៉ារ៉ាស់ព្រះនាងសែរុណាប់ (ច្បាប់ខ្លី)

اَلسَّلامُ عَلی آدَمَ صِفْوَةِ اللهِ،

اَلسَّلامُ عَلی نُوح نَبِيّ اللهِ،

اَلسَّلامُ عَلی اِبْراهيمَ خَليلِ اللهِ،

اَلسَّلامُ عَلی مُوسی كَليمِ اللهِ،

اَلسَّلامُ عَلی عيسی رُوحِ اللهِ،

اَلسَّلامُ عَلَيْكَ يا رَسُولَ اللهِ،

اَلسَّلامُ عَلَيْكَ يا خَيْرَ خَلْقِ اللهِ،

اَلسَّلامُ عَلَيْكَ يا صَفِيَّ اللهِ،

اَلسَّلامُ عَلَيْكَ يا مُحَمَّدَ بْنَ عَبْدِ اللهِ خاتَمَ النَّبِيّينَ،

اَلسَّلامُ عَلَيْكَ يا اَميرَ الْمُؤْمِنينَ عَلِيَّ بْنَ اَبي طالِب وَصِيَّ رَسُولِ اللهِ،

اَلسَّلامُ عَلَيْكِ يا فاطِمَةُ سَيِّدَةَ نِساءِ الْعالَمينَ،

اَلسَّلامُ عَلَيْكُما يا سِبْطَيْ نَبِيِّ الرَّحْمَةِ، وَسَيِّدَيْ شَبابِ اَهْلِ الْجَنَّةِ،

اَلسَّلامُ عَلَيْكَ يا عَلِيَّ بْنَ الْحُسَيْنِ سَيِّدَ الْعابِدينَ وَقُرَّةَ عَيْنِ النّاظِرينَ،

اَلسَّلامُ عَلَيْكَ يا مُحَمَّدَ بْنَ عَلِيّ باقِرَ الْعِلْمِ بَعْدَ النَّبِيِّ،

اَلسَّلامُ عَلَيكَ يا جَعْفَرَ بْنَ مُحَمَّد الصّادِقَ الْبارَّ الْاَمينَ، اَلسَّلامُ عَلَيْكَ يا مُوسَى بْنَ جَعْفَر الطّاهِرَ الطُّهْرَ،

اَلسَّلامُ عَلَيْكَ يا عَلِيَّ بْنَ مُوسَى الرِّضَا الْمُرْتَضى،

اَلسَّلامُ عَلَيْكَ يا مُحَمَّدَ بْنَ عَلِيّ التَّقِيَّ،

اَلسَّلامُ عَلَيْكَ يا عَلِيَّ بْنَ مُحَمَّد النَّقِيَّ النّاصِحَ الْاَمينَ، اَلسَّلامُ عَلَيْكَ يا حَسَنَ بْنَ عَلِيّ،

اَلسَّلامُ عَلَى الْوَصِيِّ مِنْ بَعْدِهِ، اَللّهُمَّ صَلِّ عَلى نُورِكَ وَسِراجِكَ وَوَلِيِّ وَلِيِّكَ، وَوَصِيِّ وَصيِّكَ، وَحُجَّتِكَ عَلى خَلْقِكَ،

اَلسَّلامُ عَلَيْكِ يا بِنْتَ رَسُولِ اللهِ،

اَلسَّلامُ عَلَيْكِ يا بِنْتَ فاطِمَةَ وَخَديجَةَ،

اَلسَّلامُ عَلَيْكِ يا بِنْتَ اَميرِ الْمُؤْمِنينَ،

اَلسَّلامُ عَلَيْكِ يا اُخْتَ الْحَسَنِ وَالْحُسَيْنِ،

اَلسَّلامُ عَلَيْكِ يا بِنْتَ وَلِيِّ اللهِ،

اَلسَّلامُ عَلَيْكِ يا اُخْتَ وَلِيِّ اللهِ،

اَلسَّلامُ عَلَيْكِ يا عَمَّةَ وَلِيِّ اللهِ وَرَحْمَةُ اللهِ وَبَرَكاتُهُ،

اَلسَّلامُ عَلَيْكِ عَرَّفَ اللهُ بَيْنَنا وَبَيْنَكُمْ فِي الْجَنَّةِ، وَحَشَرَنا في زُمْرَتِكُمْ، وَاَوْرَدَنا حَوْضَ نَبِيِّكُمْ، وَسَقانا بِكَاْسِ جَدِّكُمْ مِنْ يَدِ عَلِيِّ بْنِ اَبي طالِب، صَلَواتُ اللهِ عَلَيْكُمْ، اَسْئَلُ اللهَ اَنْ يُرِيَنا فيكُمُ السُّرُورَ وَالْفَرَجَ، وَاَنْ يَجْمَعَنا وَاِيّاكُمْ في زُمْرَةِ جَدِّكُمْ مُحَمَّد صَلَّى اللهُ عَلَيْهِ وَآلِهِ، وَاَنْ لا يَسْلُبَنا مَعْرِفَتَكُمْ، اِنَّهُ وَلِيٌّ قَديرٌ، اَتَقَرَّبُ اِلَى اللهِ بِحُبِّكُمْ، وَالْبَرائَةِ مِنْ اَعْدائِكُمْ، وَالتَّسْليمِ اِلَى اللهِ راضِياً بِهِ غَيْرَ مُنْكِر وَلا مُسْتَكْبِر، وَعَلى يَقينِ ما اَتى بِهِ مُحَمَّدٌ، وَبِهِ راض نَطْلُبُ بِذلِكَ وَجْهَكَ يا سَيِّدي، اَللّهُمَّ وَرِضاكَ وَالدّارَ الآخِرَةَ، يا سَيِّدَتي يا زَيْنَبُ، اِشْفَعي لي فِي الْجَنَّةِ، فَاِنَّ لَكِ عِنْدَ اللهِ شَاْناً مِنَ الشَّاْنِ، اَللّهُمَّ اِنّي اَسْئَلُكَ اَنْ تَخْتِمَ لي بِالسَّعادَةِ، فَلا تَسْلُبْ مِنّي ما اَنَا فيهِ، وَلا حَوْلَ وَلا قُوَّةَ اِلاّ بِاللهِ

الْعَلِيِّ الْعَظيمِ، اَللّهُمَّ اسْتَجِبْ لَنا وَتَقَبَّلْهُ بِكَرَمِكَ وَعِزَّتِكَ، وَبِرَحْمَتِكَ وَعافِيَتِكَ، وَصَلَّى اللهُ عَلى مُحَمَّد وَآلِهِ اَجْمَعينَ، وَسَلَّمَ تَسْليماً يا اَرْحَمَ الرّاحِمينَ.

# បញ្ជីមាតិកា


អាស្ហលុល-បៃត៍ﷺនៅក្នុងគួរអាននិងស៊ូណាស្ហ ................................ ៩
ជីវិតព្រះនាងស្វៃណាប់سلام الله عليها........................................................... ៥៦
ព្រះរាជវង្សព្រះនាងស្វៃណាប់سلام الله عليها ................................................ ៥៦
ព្រះទារកប្រកបដោយសិរីសួស្តី......................................................... ៦២
ការជ្រើសរើសព្រះនាម...................................................................... ៦៥
វិសេសសព្ទ ........................................................................................ ៦៦
១) អាល់-អ៊ុគ៏ីឡាស្ហ (العقيلة)....................................................... ៦៦
២) អាល់-អ៊ុលីម៉ាស្ហ (العالمة) .........................................................៦៧
៣) អ៊ុប៊ីដ្ហាទូ អាលី អ៊ុលី ..............................................................៦៧
៤) អាល់-កាមីឡាស្ហ (الكاملة) .........................................................៦៧
៥) អាល់-ហ្វាឌ្ហីឡាស្ហ (الفضيلة)........................................................ ៦៨
៦) អាល់-ស្វាដ់ឌ្ហីកោះត៍ អាល់-ស៊ុក្ររ៍ (الصادقة الصغرى).................... ៦៨
៧) អ៊ូម អាល់-ម៉ាស្ហ៊ីប (أم المصائب) ................................................ ៦៨
ឆ្នាំប្រសូត..........................................................................................៧០
បឋមវ័យ ...........................................................................................៧១
កម្រិតប្រាជ្ញា...................................................................................... ៧២
ព្រះអាពាហ៍ពិពាហ៍.............................................................................៨៣
លក្ខណៈបុគ្គល .................................................................................... ៨៩
ជំនឿ .................................................................................................. ៨៩
សេចក្តីរឹងមាំ....................................................................................... ៩១
សេចក្តីថ្លៃថ្នូរ....................................................................................... ៩២
សេចក្តីក្លាហាន ...................................................................................៩៣
ចៀសវាងសេចក្តីត្រេកត្រអាលលោកិយ........................................... ៩៦
សេចក្តីម៉ឺងម៉ាត់...................................................................................៩៧
ព្រះនាងស្វៃណាប់នៅក្នុងហ្វាឌ្ហីស្ហ................................................. ៩៩

ហ្វាឌីស្ហ្វព្រះនាងស្សៃណាប់ ........................................................ ១០២
ព្រឹត្តិការណ៍ខ្លោចផ្សា ................................................................ ១០៤
សុបិនរបស់ព្រះនាងស្សៃណាប់سلام الله عليها ................................................ ១០៥
-ពិធីហ្វាច្ជលាគ្នា (ចុងក្រោយ) ...................................................... ១០៦
ជម្ងឺចុងក្រោយរបស់ព្រះសាស្តាصلى الله عليه وآله وسلم ............................................. ១០៩
មហន្តរាយថ្ងៃព្រហស្បតិ៍ .............................................................. ១១១
ទុក្ខព្រួយរបស់ព្រះនាងហ្វាទីម៉ាស្ហ៍ អាស្ហ៍-ស្ហាស្ហ៍រ៉ស៊្ហ៍سلام الله عليها .............. ១១២
ព្រះសាស្តាមូហាំម៉ាដ្ហ៍صلى الله عليه وآله وسلمចូលទិវង្គត ............................................ ១១៤
រដ្ឋកាលខ៊ុលិហ្វ ........................................................................ ១១៦
ផែនការណ៍ក្បត់អាល់-សាគីហ្វាស្ហ៍ ................................................ ១១៧
ពួកមូហាឃ្ជីរូនលេចមុខច្រងោ ...................................................... ១១៨
អ៊ីម៉ាំអាលីصلوات الله عليه والسلامនិងការគោរពបុគ្គលមិនស្របច្បាប់........................ ១១៩
វិធានការតឹងរ៉ឹងប្រឆាំងអាស្ហ៍លុល-សៃបត៍عليهم السلام............................ ១២០
បដិសេធខមាទោស .................................................................. ១២៣
សេចក្តីសៅហ្មងរបស់ព្រះនាងហ្វាទីម៉ាស្ហ៍ អាស្ហ៍-ស្ហាស្ហ៍រ៉ស៊្ហ៍سلام الله عليها..... ១២៥
ព្រះនាងហ្វាទីម៉ាស្ហ៍سلام الله عليهاសោយទិវង្គត ........................................ ១២៦
រដ្ឋកាលអ៊ុំម៉ារ ........................................................................ ១២៩
រដ្ឋកាលអ៊ុស្ហ៍ម៉ាន .................................................................... ១៣៣
រដ្ឋកាលអ៊ីម៉ាំអាលីصلوات الله عليه والسلام.............................................................. ១៣៤
ការប្រទូសប្រឆាំងអ៊ីម៉ាំصلوات الله عليه والسلام...................................................... ១៣៦
មូអាវីយ៉ាស្ហ៍បង្កចលាចល .......................................................... ១៤០
ពួកខ៊ុវ៉ារីជ្ហ៍ (الخَوَارِج) បង្កចលាចល .................................................. ១៤៣
រដ្ឋបាលសុចរិតអន់ថយ.............................................................. ១៤៣
ឃាតកម្មអ៊ីម៉ាំអាលីصلوات الله عليه والسلام.............................................................. ១៤៤
ព្រះនាងស្សៃណាប់سلام الله عليهاជាមួយព្រះបិតា......................................... ១៤៦
ដំបូន្មានចុងក្រោយរបស់អ៊ីម៉ាំصلوات الله عليه والسلام .......................................... ១៤៨
រដ្ឋកាលអ៊ីម៉ាំអាល់-ហាសាន់صلوات الله عليه والسلام ................................................ ១៥០

រជ្ជកាលមូអាវីយ៉ាស់ ........................................ ១៥២
  ឃាតកម្មអ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام ........................................ ១៥៤
  ការតែងតាំងយ៉ាស៊ីដជាស្តេចខ្ទីលិហ្វថ្មី ........................................ ១៥៦
រជ្ជកាលខ្មៅងងឹត ........................................ ១៥៦
  ការបដិសេធទទួលយ៉ាស៊ីដជាអភិបាល ........................................ ១៥៩
  នៅឯម៉ាក់កាស់ ........................................ ១៦៣
  មុស្លីម អ៊ីបនូ អាគ្គីល នៅគូហ្វាស់ ........................................ ១៦៦
  អ៊ូបៃឌុលឡោះហ្ស៍ អ៊ីបនូ ស៊ីយ៉ាដ់នៅគូហ្វាស់ ........................................ ១៦៨
  ចាកចេញទៅកាន់អ៊ីរ៉ាក់ ........................................ ១៧៤
នៅឯការបាឡាអ៊ ........................................ ១៨៨
  ព្រះនាងស៊ៃណាប់ سلام الله عليها ភ័យរន្ធត់ ........................................ ១៩៨
ថ្ងៃអាស៊ូរ៉អ៊ (عاشوراء) ........................................ ២០៣
  សង្គ្រាម ........................................ ២១១
  អាល់-អាប់បាស់ធ្វើទុក្ករកម្មបូជាជីវិត ........................................ ២១៨
  ទារកដៃរ ........................................ ២២២
  មហាវិបត្តិ ........................................ ២២៣
ព្រះនាងស៊ៃណាប់ سلام الله عليها ត្រូវចាប់ជាចំណាប់ខ្មាំង ........................................ ២៣៨
  សុន្ទរកថាទីមួយរបស់ព្រះនាងស៊ៃណាប់ سلام الله عليها ........................................ ២៣៩
    ឥទ្ធិពលពាក្យពេជន៍ ........................................ ២៤២
    ប្រឈមមុខអភិបាលក្រុង ........................................ ២៤៤
  ចំណាប់ឈ្លើយនៅដ្វាម៉ាស់ ........................................ ២៤៨
    យ៉ាស៊ីដចំអក ........................................ ២៥២
  សុន្ទរកថាទីពីររបស់ព្រះនាងស៊ៃណាប់ سلام الله عليها ........................................ ២៥៥
    មតិនានាស្តីអំពីសុន្ទរកថា ........................................ ២៦១
    មាតិកាសុន្ទរកថា ........................................ ២៦៣
    ព្រះនាងស៊ៃណាប់ سلام الله عليها និងបុរសជាតិស៊ីរី ........................................ ២៦៦
    កាន់ទុក្ខអ៊ីម៉ាំអាល់-ហ៊្វសៃន៍ صلوات الله عليه والسلام ........................................ ២៦៨

ត្រឡប់មកម៉ាឌីណាស្ទវិញ ........................................................ ២៦៨
ទៅកាន់បរលោក........................................................................២៧៣
ព្រះរាជផ្នូរព្រះនាងស្មៃណាប់ﷺ.............................................២៧៣
ស៊ីយ៉ារ៉ាត់ស្ទព្រះនាងស្មៃណាប់ﷺ ................................................២៧៨
ស៊ីយ៉ារ៉ាត់ស្ទព្រះនាងស្មៃណាប់ﷺ (ច្បាប់ខ្លី) ................................... ២៩៦